# សុត្តន្តបិដក





៣៥

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ សឡាយតនវគ្គ
# សត្តមភាគ
# ៣៥



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## SAṂYUTTANIKĀYA

## SAḶĀYATANAVAGGA

## SATTAMABHĀGA

## 35

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមធ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

*ឧទាហរណ៍*

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សង្ខិកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## សំយុត្តនិកាយ  សឡាយតនវគ្គ

## សត្តមភាគ

## ៣៤

ព.ស. ២៤០៦

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សឡាយតនវគ្គោ

## សត្តមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកំ

## អនិច្ចវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចក្ខុំ ភិក្ខវេ អនិច្ចំ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា

# សុត្តន្តបិដក

# សំយុត្តនិកាយ  សឡាយតនវគ្គ

# សត្តមភាគ

សូមក្រាបថ្វាយបង្គំ  ព្រះមានព្រះភាគ

អរហន្តសម្មាសម្ពុទ្ធអង្គនោះ  ។

## បឋមបណ្ណាសកៈ

## អនិច្ចវគ្គ

*[១]  ខ្ញុំបានស្តាប់មក  យ៉ាងនេះ  ។  សម័យមួយ  ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន  របស់អនាថបិណ្ឌិកសេដ្ឋី  ជិតក្រុងសាវត្ថី  ។  ក្នុងទីនោះឯង  ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកថា  ម្នាលភិក្ខុទាំងឡាយ  ។  ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា  ព្រះករុណា  ព្រះអង្គ  ។  ព្រះមានព្រះភាគ  ទ្រង់ត្រាស់ដូច្នេះថា  ម្នាលភិក្ខុទាំងឡាយ  ភ្នែកមិនទៀង  របស់ណាមិនទៀង  របស់នោះជាទុក្ខ  របស់ណាជាទុក្ខ  របស់នោះជាអនត្តា  របស់ណា*

យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តា-
តិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សោតំ
អនិច្ចំ យទនិច្ចំ ។ បេ ។ ឃានំ អនិច្ចំ យទនិច្ចំ
។ បេ ។ ជិវ្ហា អនិច្ចា យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ
តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ
ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ
ទដ្ឋព្វំ ។ កាយោ អនិច្ចោ យទនិច្ចំ ។ បេ ។ មនោ
អនិច្ចោ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា
យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ
អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។
ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ
និព្វិន្ទតិ សោតស្មឹបិ និព្វិន្ទតិ ឃានស្មឹបិ និព្វិន្ទតិ

ជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ត្រចៀកមិនទៀង របស់ណាមិនទៀង ។ បេ ។ ច្រមុះមិនទៀង របស់ណាមិនទៀង ។ បេ ។ អណ្តាតមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាយមិនទៀង របស់ណាមិនទៀង ។ បេ ។ ចិត្តមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ជាអ្នកចេះដឹង ឃើញយ៉ាងនេះ ក៏នឿយណាយនឹងភ្នែកផង នឿយណាយនឹងត្រចៀកផង នឿយណាយនឹងច្រមុះផង

៣

អវិជ្ជាវគ្គោ បឋមោ

ជិវ្ហាយបិ និព្វិន្ទតិ កាយស្មឹបិ និព្វិន្ទតិ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ ប-ជានាតីតិ ។ បឋមំ ។

[២] ចក្ខុំ ភិក្ខវេ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សោតំ ទុក្ខំ ។ បេ ។ ឃានំ ទុក្ខំ ។ ជិវ្ហា ទុក្ខា ។ កាយោ ទុក្ខោ ។ មនោ ទុក្ខោ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។

នឿយណាយនឹងអណ្ដាតផង នឿយណាយនឹងកាយផង នឿយណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា ជាតិ (របស់អញ) អស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ១ ។

[២] ម្នាលភិក្ខុទាំងឡាយ ភ្នែកជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ត្រចៀកជាទុក្ខ ។ បេ ។ ច្រមុះជាទុក្ខ ។ អណ្ដាតជាទុក្ខ ។ កាយជាទុក្ខ ។ ចិត្តជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។

ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទុតិយំ ។

[៣] ចក្ខុំ ភិក្ខវេ អនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សោតំ អនត្តា ។ បេ ។ ឃានំ អនត្តា ។ ជិវ្ហា អនត្តា ។ កាយោ អនត្តា ។ មនោ អនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ តតិយំ ។

កាលបើឃើញយ៉ាងនេះ ។ បេ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ២ ។

[៣] ម្នាលភិក្ខុទាំងឡាយ ភ្នែកជាអនត្តា របស់ណាជាអនត្តា របស់នោះ បុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ត្រចៀកជាអនត្តា ។ បេ ។ ច្រមុះជាអនត្តា ។ អណ្តាតជាអនត្តា ។ កាយជាអនត្តា ។ ចិត្តជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រទី ៣ ។

៥

អនិច្ចវគ្គោ បឋមោ

[៤] រូបា ភិក្ខវេ អនិច្ចា យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថា-ភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ រូបេសុបិ និព្ពិន្ទតិ សទ្ទេសុបិ និព្ពិន្ទតិ គន្ធេសុបិ និព្ពិន្ទតិ រសេសុបិ និព្ពិន្ទតិ ផោដ្ឋព្វេសុបិ និព្ពិន្ទតិ ធម្មេសុបិ និព្ពិន្ទតិ និព្ពិន្ទំ វិរជ្ជតិ វិរាគា វិមុច្ច-តិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ

អនិច្ចវគ្គ ទី ១

[៤] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ ដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ក៏នឿយណាយនឹងរូបទាំងឡាយផង នឿយណាយនឹងសំឡេងទាំងឡាយផង នឿយណាយនឹងក្លិនទាំងឡាយផង នឿយណាយនឹងរសទាំងឡាយផង នឿយណាយនឹងសម្ផស្សទាំងឡាយផង នឿយណាយនឹងធម្មារម្មណ៍ទាំងឡាយផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តផុតស្រឡះ (ចាកអាសវៈ) ហើយ ញាណក៏កើតឡើងថា ចិត្ត (របស់អញ) ផុតស្រឡះហើយ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា ជាតិអស់ហើយ

៦



វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ចតុត្ថំ ។

[៤] រូបា ភិក្ខវេ ទុក្ខា យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ បញ្ចមំ ។

មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៨ ។

[៩] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយ ជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណា ជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាលបើឃើញយ៉ាងនេះហើយ ។ បេ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៩ ។

៧

## អនិច្ចវគ្គោ បឋមោ

[៦] រូបា ភិក្ខវេ អនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជា-នាតីតិ ។ ឆដ្ឋំ ។

[៧] ចក្ខុំ ភិក្ខវេ អនិច្ចំ អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិ-យសាវកោ អតីតស្មឹ ចក្ខុស្មឹ អនបេក្ខោ ហោតិ អ-នាគតំ ចក្ខុំ នាភិនន្ទតិ បច្ចុប្បន្នស្ស ចក្ខុស្ស និព្វិ-ទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ សោតំ អនិច្ចំ ។ ឃានំ អនិច្ចំ ។ ជិវ្ហា អនិច្ចា អតីតា-

អនិច្ចវគ្គ ទី ១

[៦] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយ ជាអនត្តា របស់ណាជាអនត្តា របស់នោះបុគ្គលត្រូវយល់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៦ ។

[៧] ម្នាលភិក្ខុទាំងឡាយ ភ្នែកជាអតីតអនាគត មិនទៀងទៅហើយ ចាំបាច់និយាយថ្វីដល់ភ្នែកជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងភ្នែកជាអតីត មិនត្រេកអរចំពោះភ្នែកជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវភ្នែកជាបច្ចុប្បន្ន ។ ត្រចៀកមិនទៀង ។ ច្រមុះមិនទៀង ។ អណ្តាតជាអតីត

ជាតតា កោ បន វាទោ បច្ចុប្បន្នាយ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតាយ ជិវ្ហាយ អនបេក្ខោ ហោតិ អនាគតំ ជិវ្ហំ នាភិនន្ទតិ បច្ចុប្បន្នាយ ជិវ្ហាយ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ កាយោ អនិច្ចោ ។ បេ ។ មនោ អនិច្ចោ អតីតានាគតោ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ មនស្មឹ អនបេក្ខោ ហោតិ អនាគតំ មនំ នាភិនន្ទតិ បច្ចុប្បន្នស្ស មនស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។ សត្តមំ ។

[៨] ចក្ខុំ ភិក្ខវេ ទុក្ខំ អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតស្មឹ ចក្ខុស្មឹ អនបេក្ខោ ហោតិ អនាគតំ ចក្ខុំ នាភិនន្ទតិ បច្ចុប្បន្នស្ស ចក្ខុស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ

អនាគតមិនទៀងទៅហើយ ចាំបាច់និយាយថ្វីដល់អណ្តាតជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងអណ្តាតជាអតីត មិនត្រេកអរចំពោះអណ្តាតជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវអណ្តាតជាបច្ចុប្បន្ន ។ កាយមិនទៀង ។ បេ ។ ចិត្តជាអតីតអនាគត មិនទៀងទៅហើយ ចាំបាច់និយាយថ្វីដល់ចិត្តជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងចិត្តជាអតីត មិនត្រេកអរចំពោះចិត្តជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់នូវចិត្តជាបច្ចុប្បន្ន ។ ចប់សូត្រ ទី ៧ ។

[៨] ម្នាលភិក្ខុទាំងឡាយ ភ្នែកជាអតីតអនាគតជាទុក្ខទៅហើយ ចាំបាច់និយាយថ្វីដល់ភ្នែកជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងភ្នែកជាអតីត មិនត្រេកអរចំពោះភ្នែកជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវភ្នែកជាបច្ចុប្បន្ន

។ បេ ។ ជិវ្ហា ទុក្ខា អតីតានាគតា កោ បន វាទោ បច្ចុប្បន្នាយ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ អតីតាយ ជិវ្ហាយ អនបេក្ខោ ហោតិ អនាគតំ ជិវ្ហំ នាភិនន្ទតិ បច្ចុប្បន្នាយ ជិវ្ហាយ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ កាយោ ទុក្ខោ ។ បេ ។ មនោ ទុក្ខោ អតីតានាគតោ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ អតីតស្មឹ មនស្មឹ អនបេក្ខោ ហោតិ អនាគតំ មនំ នាភិនន្ទតិ បច្ចុប្បន្នស្ស មនស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។ អដ្ឋមំ ។

[៩] ចក្ខុំ ភិក្ខវេ អនត្តា អតីតានាគតំ កោ បន វាទោ បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ អតីតស្មឹ ចក្ខុស្មឹ អនបេក្ខោ ហោតិ អនាគតំ ចក្ខុំ នាភិនន្ទតិ បច្ចុប្បន្នស្ស ចក្ខុស្ស និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោ-តិ ។ បេ ។ ជិវ្ហា អនត្តា អតីតានាគតា កោ បន

។ បេ ។ អណ្តាតជាអតីតអនាគត ជាទុក្ខទៅហើយ ចាំបាច់និយាយថ្វី ដល់អណ្តាតជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងអណ្តាតជា អតីត មិនត្រេកអរចំពោះអណ្តាតជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយ ណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវអណ្តាតជាបច្ចុប្បន្ន ។ កាយជាទុក្ខ ។ បេ ។ ចិត្តជាអតីតអនាគត ជាទុក្ខទៅហើយ ចាំបាច់ និយាយថ្វីដល់ចិត្តជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយ-សាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យក្នុងចិត្ត ជាអតីត មិនត្រេកអរចំពោះចិត្តជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយ ណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវចិត្តជាបច្ចុប្បន្ន ។ ចប់សូត្រ ទី ៨ ។

[៩] ម្នាលភិក្ខុទាំងឡាយ ភ្នែកជាអតីតអនាគត ជាអនត្តាទៅ ហើយ ចាំបាច់និយាយថ្វីដល់ភ្នែកជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអា-ល័យនឹងភ្នែកជាអតីត មិនត្រេកអរចំពោះភ្នែកជាអនាគត ជាអ្នកប្រតិ-បត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវភ្នែក ជាបច្ចុប្បន្ន ។ បេ ។ អណ្តាតជាអតីតអនាគត ជាអនត្តាទៅហើយចាំ

ភវេា បច្ចុប្បន្នាយ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយ-
សាវកោ អតីតាយ ជិវ្ហាយ អនបេក្ខោ ហោតិ អនា-
គតំ ជិវ្ហំ នាភិនន្ទតិ បច្ចុប្បន្នាយ ជិវ្ហាយ និព្វិទាយ
វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ កាយោ អនត្តា
។ បេ ។ មនោ អនត្តា អតីតានាគតោ កោ បន វាទោ
បច្ចុប្បន្នស្ស ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវ-
កោ អតីតស្មឹ មនស្មឹ អនបេក្ខោ ហោតិ អនាគតំ
មនំ នាភិនន្ទតិ បច្ចុប្បន្នស្ស មនស្ស និព្វិទាយ វិរា-
គាយ និរោធាយ បដិបន្នោ ហោតីតិ ។ នវមំ ។

[១០] រូបា ភិក្ខវេ អនិច្ចា អតីតានាគតា កោ
បន វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុ-
តវា អរិយសាវកោ អតីតេសុ រូបេសុ អនបេក្ខោ
ហោតិ អនាគតេ រូបេ នាភិនន្ទតិ បច្ចុប្បន្នានំ រូបានំ
និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។
សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា អតីតានាគតា

បាច់និយាយថ្វីដល់អណ្តាតជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងអណ្តាតជាអតីត មិនត្រេកអរចំពោះអណ្តាតជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវអណ្តាតជាបច្ចុប្បន្ន ។ កាយជាអនត្តា ។ បេ ។ ចិត្តជាអតីតអនាគត ជាអនត្តាទៅហើយ ចាំបាច់និយាយថ្វីដល់ចិត្តជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងចិត្តជាអតីត មិនត្រេកអរចំពោះចិត្តជាអនាគត ជាអ្នកប្រតិ-បត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវចិត្តជាបច្ចុប្បន្ន ។ ចប់សូត្រ ទី ៩ ។

[១០] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយជាអតីតអនាគត មិនទៀងទៅហើយ ចាំបាច់និយាយថ្វីដល់រូបទាំងឡាយជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យ នឹងរូបទាំងឡាយជាអតីត មិនត្រេកអរចំពោះរូបទាំង-ឡាយជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវរូបទាំងឡាយជាបច្ចុប្បន្ន ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ទាំងឡាយជាអតីតអនាគត មិនទៀងទៅហើយ

កោ បន វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតេសុ ធម្មេសុ អនបេក្ខោ ហោតិ អនាគតេ ធម្មេ នាភិនន្ទតិ បច្ចុប្បន្នានំ ធម្មានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។

[១១] រូបា ភិក្ខវេ ទុក្ខា អតីតានាគតា កោ បន វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតេសុ រូបេសុ អនបេក្ខោ ហោតិ អនាគតេ រូបេ នាភិនន្ទតិ បច្ចុប្បន្នានំ រូបានំ និព្វិ-ទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។

[១២] រូបា ភិក្ខវេ អនត្តា អតីតានាគតា កោ បន វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ អតីតេសុ រូបេសុ អនបេក្ខោ ហោតិ អនាគតេ រូបេ នាភិនន្ទតិ បច្ចុប្បន្នានំ រូបានំ និព្វិទា-យ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ។ សទ្ទា

ចាំបាច់និយាយថ្វីដល់ធម្មារម្មណ៍ទាំងឡាយជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹងឃើញយ៉ាងនេះ ជាអ្នកមិនអា-ឡោះអាល័យនឹងធម្មារម្មណ៍ទាំងឡាយជាអតីត មិនត្រេកអរចំពោះធម្មា-រម្មណ៍ទាំងឡាយជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវធម្មារម្មណ៍ទាំងឡាយជាបច្ចុប្បន្ន ។

[១១] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយជាអតីតអនាគត ជាទុក្ខទៅហើយ ចាំបាច់និយាយថ្វីដល់រូបទាំងឡាយជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងរូបទាំងឡាយជាអតីត មិនត្រេកអរចំពោះរូបទាំងឡាយជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវរូបទាំងឡាយជាបច្ចុប្បន្ន ។

[១២] ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយជាអតីតអនាគត ជាអនត្តាទៅហើយ ចាំបាច់និយាយថ្វីដល់រូបទាំងឡាយជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងរូបទាំងឡាយជាអតីត មិនត្រេកអរចំពោះរូបទាំងឡាយ ជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវរូបទាំងឡាយជាបច្ចុប្បន្ន ។ សំឡេង

១២



កណ្ហា វសា ដោជ្ជញា ជម្មា អងត្តា អតីតាណាគតា កោ បង វាទោ បច្ចុប្បន្នានំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ អតីតេសុ ជម្មេសុ អងបេក្ខោ ហោតិ អណាគតេ ជម្មេ ណាភិងន្ទតិ បច្ចុប្បន្នានំ ជម្មានំ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតីតិ ។ ទសមំ ។

អនិច្ចវគ្គោ បឋមោ ។

## តស្សុទ្ទានំ

អនិច្ចំ ទុក្ខំ អនត្តា ច

តយោ អជ្ឈត្តពាហិរា

។ បេ ។ យទនិច្ចេន តយោ

វុត្តា តេ តេ អជ្ឈត្តពាហិរាតិ ។

ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ទាំងឡាយ ជាអតីតអនាគត ជាអនត្តា ទៅហើយ ចាំបាច់និយាយថ្វីដល់ធម្មារម្មណ៍ទាំងឡាយជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង ឃើញយ៉ាងនេះ ជាអ្នកមិនអាឡោះអាល័យនឹងធម្មារម្មណ៍ទាំងឡាយជាអតីត មិនត្រេក-អរចំពោះធម្មារម្មណ៍ទាំងឡាយ ជាអនាគត ជាអ្នកប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរំលត់ នូវធម្មារម្មណ៍ទាំងឡាយជាបច្ចុប្បន្ន ។ ចប់សូត្រ ទី ១០ ។

ចប់ អនិច្ចវគ្គ ទី ១ ។

# ឧទ្ទាននៃអនិច្ចវគ្គនោះ គឺ

និយាយអំពី (អាយតនៈ) មិនទៀង ជាទុក្ខ ជាអនត្តា ទាំងខាងក្នុងនិងខាងក្រៅ ៣ លើក ។ បេ ។ និយាយអំពី (អា-យតនៈ) ទាំងនោះ ទាំងខាងក្នុងនិងខាងក្រៅ (ជាអតីត អនាគត បច្ចុប្បន្ន) ដែលលោកពោល ៣ លើកទៀត ដោយអំណាចអនិច្ចាទិលក្ខណៈ ។

# យមកវគ្គោ

[១៣] បុព្វេ មេ ភិក្ខវេ សម្ពោធាយ[១] អនភិ-
សម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ
នុ ខោ ចក្ខុស្ស អស្សាទោ កោ អាទីនវោ កឹ
និស្សរណំ កោ សោតស្ស ។ បេ ។ កោ ឃានស្ស ។
កោ ជិវ្ហាយ ។ កោ កាយស្ស ។ កោ មនស្ស អស្សា-
ទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តស្ស មយ្ហំ
ភិក្ខវេ ឯតទហោសិ យំ ខោ ចក្ខុំ បដិច្ច ឧប្បជ្ជតិ
សុខំ សោមនស្សំ អយំ ចក្ខុស្ស អស្សាទោ យំ ចក្ខុំ
អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ ចក្ខុស្ស អាទីនវោ
យោ ចក្ខុស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ
ចក្ខុស្ស និស្សរណំ ។ បេ ។ យំ ជិវ្ហំ បដិច្ច ឧប្បជ្ជតិ
សុខំ សោមនស្សំ អយំ ជិវ្ហាយ អស្សាទោ យា ជិវ្ហា

---

១ ឱ. ម. សម្ពោធា ។

# យមកវគ្គ

[១៣] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងសម្ពោធិញ្ញាណនៅឡើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា អ្វីហ្ន៎ជាអានិសង្សរបស់ភ្នែក អ្វីហ្ន៎ជាទោសរបស់ភ្នែក អ្វីជាគ្រឿងរលាស់ចេញនូវភ្នែក អ្វីជាអានិសង្សរបស់ត្រចៀក ។ បេ ។ អ្វីជាអានិសង្សរបស់ច្រមុះ ។ អ្វីជាអានិសង្សរបស់អណ្តាត ។ អ្វីជាអានិសង្សរបស់កាយ ។ អ្វីជាអានិសង្សរបស់ចិត្ត អ្វីជាទោសរបស់ចិត្ត អ្វីជាគ្រឿងរលាស់ចេញនូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យភ្នែក នេះជាអានិសង្សរបស់ភ្នែក ភ្នែកណា មិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសរបស់ភ្នែក ការកម្ចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងភ្នែកណា នេះជាគ្រឿងរលាស់ចេញនូវភ្នែក ។ បេ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យអណ្តាត នេះជាអានិសង្សរបស់អណ្តាត អណ្តាតណា

អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ ជិវ្ហាយ អាទីនវោ យោ ជិវ្ហាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ ជិវ្ហាយ និស្សរណំ ។ បេ ។ យំ មនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ មនស្ស អស្សាទោ យោ មនោ អនិច្ចោ ទុក្ខោ វិបរិណាមធម្មោ អយំ មនស្ស អាទីនវោ យោ មនស្មឹ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ មនស្ស និស្សរណំ ។ យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ ឆន្នំ អជ្ឈត្តិកានំ អាយតនានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសឹ ។ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បច្ចញ្ញាសឹ ។ យតោ ច ខោហំ ភិក្ខវេ

មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសរបស់អណ្តាត ការកម្ចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងអណ្តាតណា នេះជាគ្រឿងរលាស់ចេញនូវអណ្តាត ។ បេ ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យចិត្ត នេះជាអានិសង្សរបស់ចិត្ត ចិត្តណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសរបស់ចិត្ត ការកម្ចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគ ក្នុងចិត្តណា នេះជាគ្រឿងរលាស់ចេញនូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្នុងទាំង ៦ នេះ យ៉ាងនេះ អស់កាលត្រឹមណា ។ ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ដែលឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស អស់កាលត្រឹមណោះឡើយទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគត

ឥមេសំ ឆន្នំ អជ្ឈត្តិកានំ អាយតនានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ ។ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ[១] អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ បឋមំ ។

[១៤] បុព្វេ មេ ភិក្ខវេ សម្ពោធាយ អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ កោ នុ ខោ រូបានំ អស្សាទោ កោ អាទីនវោ កឹ

១ ឱ. ម. ចេតោវិមុត្តិ ។

បានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្នុងទាំង ៦ នេះ យ៉ាងនេះហើយ ។ ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារ-លោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ។ បញ្ញាដែលដឹងច្បាស់ឃើញច្បាស់របស់តថាគត ក៏កើតឡើងដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីគឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។ ចប់សូត្រ ទី ១ ។

[១៤] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា អ្វីហ្ន៎ជាអានិសង្សរបស់រូប អ្វីជាទោសរបស់រូប អ្វី

និស្សរណំ កោ សទ្ទានំ ។ បេ ។ កោ គន្ធានំ ។ បេ ។
កោ រសានំ ។ កោ ផោដ្ឋព្វានំ ។ កោ ធម្មានំ
អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ តស្ស
មយ្ហំ ភិក្ខវេ ឯតទហោសិ យំ ខោ រូបេ បដិច្ច ឧប្ប-
ជ្ជតិ សុខំ សោមនស្សំ អយំ រូបានំ អស្សាទោ យំ រូបា
អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ រូបានំ អាទីនវោ
យោ រូបេសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបានំ
និស្សរណំ ។ យំ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ យំ ធម្មេ
បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ ធម្មានំ
អស្សាទោ យំ ធម្មា អនិច្ចា ទុក្ខា វិបរិណាមធម្មា

ជាគ្រឿងរលាស់ចេញនូវរូប អ្វីជាអានិសង្សរបស់សំឡេង ។ បេ ។ អ្វីជាអានិសង្សរបស់ក្លិន ។ បេ ។ អ្វីជាអានិសង្សរបស់រស ។ អ្វីជាអានិសង្សរបស់ផោដ្ឋព្វៈ ។ អ្វីជាអានិសង្សរបស់ធម្មារម្មណ៍ អ្វីជាទោសរបស់ធម្មារម្មណ៍ អ្វីជាគ្រឿងរលាស់ចេញនូវធម្មារម្មណ៍ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូប រូបណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសរបស់រូប ការកម្ចាត់បង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគក្នុងរូបណា នេះជាគ្រឿងរលាស់ចេញនូវរូប ។ សេចក្តីសុខនិងសោមនស្សណា កើតឡើងព្រោះអាស្រ័យសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ នេះជាអានិសង្សរបស់ធម្មារម្មណ៍ ធម្មារម្មណ៍ណា មិនទៀង ជាទុក្ខ មានសេចក្តី

១៧

យមកវគ្គោ ទុតិយោ

អយំ ធម្មានំ អាទីនវោ យោ ធម្មេសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ ធម្មានំ និស្សរណំ ។ យាវកី-វញ្ចាហំ ភិក្ខវេ ឥមេសំ ឆន្នំ ពាហិរានំ អាយតនានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសិំ ។ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ ស-ទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ-តិ បច្ចញ្ញាសិំ ។ យតោ ច ខោហំ ភិក្ខវេ ឥមេ-សំ ឆន្នំ ពាហិរានំ អាយតនានំ ឯវំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច

យមកវគ្គ ទី ២

ប្រែប្រួលជាធម្មតា នេះជាទោសរបស់ធម្មារម្មណ៍ ការកម្ចាត់បង់នូវឆន្ទ-
រាគ ការលះបង់នូវឆន្ទរាគ ក្នុងធម្មារម្មណ៍ណា នេះជាគ្រឿងរលាស់
ចេញនូវធម្មារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានដឹងច្បាស់
តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿង
រលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្រៅទាំង ៦ នេះ
យ៉ាងនេះ អស់កាលត្រឹមណា ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិន
ទាន់ប្ដេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ដែលឥតមាន
សេចក្ដីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារ-
លោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រម
ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស អស់កាលត្រឹមណោះ នៅ
ឡើយទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគតបានដឹងច្បាស់តាម
ពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿង

និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ ។ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្ស-មណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយ-មន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ទុតិយំ ។

[១៩] ចក្ខុស្សាហំ ភិក្ខវេ អស្សាទបរិយេសនំ អ-ចរឹ យោ ចក្ខុស្ស អស្សាទោ តទជ្ឈគមំ យាវតា ចក្ខុ-ស្ស អស្សាទោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ ចក្ខុ-ស្សាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ ចក្ខុស្ស អាទីនវោ តទជ្ឈគមំ យាវតា ចក្ខុស្ស អាទីនវោ បញ្ញា-យ មេ ឯសោ សុទិដ្ឋោ ចក្ខុស្សាហំ ភិក្ខវេ និស្សរណ-បរិយេសនំ អចរឹ យំ ចក្ខុស្ស និស្សរណំ តទជ្ឈគមំ

រលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្រៅទាំង ៦ នេះ យ៉ាងនេះហើយ ។ ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ របស់តថាគតក៏កើតឡើងដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីគឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។ ចប់សូត្រ ទី ២ ។

[១៥] ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវអានិសង្សនៃភ្នែក ក៏បានចួបប្រទះនឹងអានិសង្ស នៃភ្នែកនោះឯង តថាគតបានឃើញដោយងាយ នូវអានិសង្ស នៃភ្នែកនុ៎ះទាំងប៉ុន្មានដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃភ្នែក ក៏បានចួបប្រទះនូវទោស នៃភ្នែកនោះឯង តថា-គតបានឃើញដោយងាយ នូវទោសនៃភ្នែកនុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវគ្រឿងរលាស់ចេញនូវភ្នែក ក៏បានចួបប្រទះ នូវគ្រឿងរលាស់ចេញ

១៩

## យមកវគ្គោ ទុតិយោ

យាវតា ចក្ខុស្ស និស្សរណំ បញ្ញាយ មេ ឯតំ សុទិដ្ឋំ ។ សោតស្សាហំ ភិក្ខវេ ។ ឃានស្សាហំ ភិក្ខវេ ។ ជិវ្ហាយាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ យោ ជិវ្ហាយ អស្សាទោ តទជ្ឈគមំ យាវតា ជិវ្ហាយ អស្សាទោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ ជិវ្ហាយាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ ជិវ្ហាយ អាទីនវោ តទជ្ឈគមំ យាវតា ជិវ្ហាយ អាទីនវោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ ជិវ្ហាយាហំ ភិក្ខវេ និស្សរណបរិយេសនំ អចរឹ យំ ជិវ្ហាយ និស្សរណំ តទជ្ឈគមំ យាវតា ជិវ្ហាយ និស្សរណំ បញ្ញាយ មេ ឯតំ សុទិដ្ឋំ ។ បេ ។ មនស្សាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ

នូវត្រែកនោះឯង តថាគតបានឃើញដោយផាយ នូវគ្រឿងរលាស់ចេញនូវត្រែកនុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វែងរកនូវអានិសង្សនៃត្រចៀក ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វែងរកនូវអានិសង្សនៃច្រមុះ ។ ម្នាលភិក្ខុទាំងឡាយ តថា-គតបានប្រព្រឹត្ត ស្វែងរកនូវអានិសង្សនៃអណ្តាត ក៏បានចួបប្រទះនូវអា-និសង្សនៃអណ្តាតនោះឯង តថាគតបានឃើញដោយផាយ នូវអានិសង្សនៃអណ្តាតនុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃអណ្តាត ក៏បានចួបប្រទះនូវទោសនៃអណ្តាតនោះ តថាគតបានឃើញដោយផាយ នូវទោសនៃអណ្តាតនុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្តស្វែងរកនូវគ្រឿងរលាស់ចេញនូវអណ្តាត ក៏បានចួបប្រទះ នូវគ្រឿងរលាស់ចេញនូវអណ្តាតនោះ តថាគតបានឃើញដោយផាយ នូវគ្រឿងរលាស់ចេញ នូវអណ្តាតនុ៎ះ ទាំងប៉ុន្មាន ដោយបញ្ញា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវអានិសង្សនៃចិត្ត

២០



យោ មនស្ស អស្សាទោ តទជ្ឈគមំ យាវតា បនស្ស អស្សាទោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ មនស្សាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ មនស្ស អាទីនវោ តទជ្ឈគមំ យាវតា មនស្ស អាទីនវោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ មនស្សាហំ ភិក្ខវេ និស្សរណបរិយេសនំ អចរឹ យំ មនស្ស និស្សរណំ តទជ្ឈគមំ យាវតា មនស្ស និស្សរណំ បញ្ញាយ មេ ឯតំ សុទិដ្ឋំ ។ យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ ឆន្នំ អជ្ឈត្តិកានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសឹ ។ បេ ។ អព្ភញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ តតិយំ ។

ក៏បានចួបប្រទះនូវអានិសង្សនៃចិត្តនោះ តថាគតបានឃើញដោយឆ្ងាយ នូវអានិសង្សនៃចិត្តនុ៎ះ ទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃចិត្ត ក៏បានចួបប្រទះនូវទោសនៃចិត្តនោះឯង តថាគតបានឃើញដោយឆ្ងាយ នូវទោសនៃចិត្តនុ៎ះ ទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវគ្រឿងរលាស់ចេញនូវចិត្ត ក៏បានចួបប្រទះនូវគ្រឿងរលាស់ចេញនូវចិត្តនោះ តថាគតបានឃើញដោយឆ្ងាយ នូវគ្រឿងរលាស់ចេញនូវចិត្តនុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានដឹងច្បាស់ នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្នុងទាំង ៦ នេះ អស់កាលត្រឹមណា ។ បេ ។ បានដឹងច្បាស់ ។ បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ របស់តថាគត ក៏កើតឡើងហើយដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីគឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។ ចប់សូត្រ ទី ៣ ។

យមកវគ្គោ ទុតិយោ

[១៦] រូបានាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ យោ រូបានំ អស្សាទោ តទជ្ឈគមំ យាវតា រូបានំ អស្សាទោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ រូបានាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ យោ រូបានំ អាទីនវោ តទជ្ឈគមំ យាវតា រូបានំ អាទីនវោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ រូបានាហំ ភិក្ខវេ និស្សរណបរិយេ-សនំ អចរឹ យំ រូបានំ និស្សរណំ តទជ្ឈគមំ យាវតា រូបានំ និស្សរណំ បញ្ញាយ មេ ឯតំ សុទិដ្ឋំ ។ សទ្ទា-នាហំ ភិក្ខវេ ។ គន្ធានាហំ ភិក្ខវេ ។ រសានាហំ ភិក្ខវេ ។ ផោដ្ឋព្វានាហំ ភិក្ខវេ ។ ធម្មានាហំ ភិក្ខវេ អស្សាទបរិយេសនំ អចរឹ យោ ធម្មានំ អស្សាទោ ត-ទជ្ឈគមំ យាវតា ធម្មានំ អស្សាទោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ ធម្មានាហំ ភិក្ខវេ អាទីនវបរិយេសនំ អចរឹ

យមកវគ្គ ទី ២

[១៦] ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវអានិសង្សនៃរូប ក៏បានចួបប្រទះនូវអានិសង្សនៃរូបនោះ តថាគតបានឃើញដោយងាយ នូវអានិសង្សនៃរូបទុំះទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃរូប ក៏បានចួបប្រទះនូវទោសនៃរូបនោះ តថាគតបានឃើញដោយងាយ នូវទោសនៃរូបទុំះទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវគ្រឿងរលាស់ចេញនូវរូប ក៏បានចួបប្រទះនូវគ្រឿងរលាស់ចេញនូវរូបនោះ តថាគតបានឃើញដោយងាយ នូវគ្រឿងរលាស់ចេញ នូវរូបទុំះទាំងប៉ុន្មាន ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃសំឡេង ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃក្លិន ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃរស ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃផោដ្ឋព្វៈ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវអានិសង្សនៃធម្មារម្មណ៍ ក៏បានចួបប្រទះ នូវអានិសង្សនៃធម្មារម្មណ៍នោះ តថាគតបានឃើញដោយងាយ នូវអានិសង្សនៃធម្មារម្មណ៍ទុំះ ទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំង-ឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវទោសនៃធម្មារម្មណ៍ ក៏បាន

យោ ធម្មានំ អាទីនវោ តទជ្ឈគមំ យាវតា ធម្មានំ អាទីនវោ បញ្ញាយ មេ ឯសោ សុទិដ្ឋោ ធម្មានាហំ ភិក្ខវេ និស្សរណបរិយេសនំ អចរឹ យំ ធម្មានំ និស្សរណំ តទជ្ឈគមំ យាវតា ធម្មានំ និស្សរណំ បញ្ញាយ មេ ឯតំ សុទិដ្ឋំ ។ យាវកីវញ្ចាហំ ភិក្ខវេ ឥមេសំ ឆន្នំ ពាហិរានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសឹ ។ បេ ។ អព្ភញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ចតុត្ថំ ។

[១៧] នោ ចេទំ ភិក្ខវេ ចក្ខុស្ស អស្សាទោ អភវិស្ស ន យិទំ សត្តា ចក្ខុស្មឹ សារជ្ជេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ចក្ខុស្ស អស្សាទោ តស្មា សត្តា ចក្ខុស្មឹ សារជ្ជន្តិ នោ ចេទំ ភិក្ខវេ ចក្ខុស្ស អាទីនវោ

ចួបប្រទះនូវទោសនៃធម្មារម្មណ៍នោះ តថាគតបានឃើញដោយផាយនូវទោសនៃធម្មារម្មណ៍នុ៎ះ ទាំងប៉ុន្មាន ដោយបញ្ញា ម្នាលភិក្ខុទាំងឡាយ តថាគតបានប្រព្រឹត្ត ស្វែងរកនូវធម៌ជាគ្រឿងរលាស់ចេញ នូវធម្មារម្មណ៍ ក៏បានចួបប្រទះនូវធម៌ជាគ្រឿងរលាស់ចេញនូវធម្មារម្មណ៍នោះ តថាគតបានឃើញដោយផាយ នូវធម៌ជាគ្រឿងរលាស់ចេញនូវធម្មារម្មណ៍នុ៎ះទាំងប៉ុន្មាន ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្រៅទាំង ៦ នេះ អស់កាលត្រឹមណា ។ បេ ។ បានដឹងច្បាស់ ។ បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់របស់តថាគត ក៏កើតឡើងដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះ ក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីគឺការត្រឡប់កើតទៀត ក៏មិនមានឡើយ ។ ចប់សូត្រ ទី ៤ ។

[១៧] ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃភ្នែក មិនមានទេ សត្វទាំងឡាយ ក៏មិនត្រេកអរនឹងភ្នែកឡើយ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃភ្នែក មាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយ ត្រេកអរនឹងភ្នែក ម្នាលភិក្ខុទាំងឡាយ បើទោសនៃភ្នែក

២៣

យមកវគ្គោ ទុតិយោ

អភវិស្ស ន យិទំ សត្តា ចក្ខុស្មឹ និព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ចក្ខុស្ស អាទីនវោ តស្មា សត្តា ចក្ខុស្មឹ និព្វិន្ទន្តិ នោ ចេទំ ភិក្ខវេ ចក្ខុស្ស និស្សរណំ អភវិស្ស ន យិទំ សត្តា ចក្ខុស្មា និស្សរេយ្យុំ យស្មា ច[១] ភិក្ខវេ អត្ថិ ចក្ខុស្ស និស្សរណំ តស្មា សត្តា ចក្ខុស្មា និស្សរន្តិ ។ នោ ចេទំ ភិក្ខវេ សោតស្ស អស្សាទោ អភវិស្ស ។ នោ ចេទំ ភិក្ខវេ ឃានស្ស អស្សាទោ អភវិស្ស ។ នោ ចេទំ ភិក្ខវេ ជិវ្ហាយ អស្សាទោ អភវិស្ស ន យិទំ សត្តា ជិវ្ហាយ សារជ្ជេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ជិវ្ហាយ អស្សាទោ តស្មា សត្តា ជិវ្ហាយ សារជ្ជន្តិ នោ ចេទំ ភិក្ខវេ ជិវ្ហាយ អាទីនវោ អភវិស្ស ន យិទំ សត្តា ជិវ្ហាយ និព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ជិវ្ហាយ អាទីនវោ តស្មា

---

១ ឱ. ម. ច ខោ ។

យមកវគ្គ ទី ២

មិនមានទេ សត្វទាំងឡាយមិននឿយណាយនឹងភ្នែកឡើយ ម្នាលភិក្ខុទាំងឡាយ ទោសនៃភ្នែកមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយ នឿយណាយនឹងភ្នែក ម្នាលភិក្ខុទាំងឡាយ បើគ្រឿងរលាស់ចេញនូវភ្នែកមិនមានទេ សត្វទាំងឡាយមិនរលាស់ចេញចាកភ្នែកឡើយ ម្នាលភិក្ខុទាំងឡាយ គ្រឿងរលាស់ចេញ នូវភ្នែកមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយរលាស់ចេញចាកភ្នែក ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃត្រចៀកមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃច្រមុះមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃអណ្តាតមិនមានទេ សត្វទាំង-ឡាយមិនត្រេកអរនឹងអណ្តាតឡើយ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃអណ្តាតមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយត្រេកអរនឹងអណ្តាត ម្នាលភិក្ខុទាំងឡាយ បើទោសនៃអណ្តាតមិនមានទេ សត្វទាំងឡាយមិននឿយណាយនឹងអណ្តាតឡើយ ម្នាលភិក្ខុទាំងឡាយ ទោសនៃអណ្តាតមាន ព្រោះហេតុណា ហេតុនោះ

សត្តា ជិវ្ហាយ និព្វិន្ទន្តិ នោ ចេតំ ភិក្ខវេ ជិវ្ហាយ និស្សរណំ អភវិស្ស នយិទំ សត្តា ជិវ្ហាយ និស្សរេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ជិវ្ហាយ និស្សរណំ តស្មា សត្តា ជិវ្ហាយ និស្សរន្តិ ។ នោ ចេតំ ភិក្ខវេ កាយស្ស អស្សាទោ អភវិស្ស ។ នោ ចេតំ ភិក្ខវេ មនស្ស អស្សាទោ អភវិស្ស នយិទំ សត្តា មនស្មឹ សារជ្ជេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ មនស្ស អស្សាទោ តស្មា សត្តា មនស្មឹ សារជ្ជន្តិ នោ ចេតំ ភិក្ខវេ មនស្ស អាទីនវោ អភវិស្ស នយិទំ សត្តា មនស្មឹ និព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ មនស្ស អាទីនវោ តស្មា សត្តា មនស្មឹ និព្វិន្ទន្តិ នោ ចេតំ ភិក្ខវេ មនស្ស និស្សរណំ អភវិស្ស នយិទំ សត្តា មនស្មា និស្សរេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ មនស្ស និស្សរណំ តស្មា សត្តា មនស្មា និស្សរន្តិ ។ យាវកីវញ្ច ភិក្ខវេ សត្តា ឥមេសំ ឆន្នំ អជ្ឈត្តិកានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច

បានជាសត្វទាំងឡាយនឿយណាយនឹងអណ្តាត ម្នាលភិក្ខុទាំងឡាយ បើការរលាស់ចេញនូវអណ្តាតមិនមានទេ សត្វទាំងឡាយមិនរលាស់ចេញចាកអណ្តាតឡើយ ម្នាលភិក្ខុទាំងឡាយ ការរលាស់ចេញនូវអណ្តាតមានព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយរលាស់ចេញចាកអណ្តាត ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃកាយមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃចិត្តមិនមានទេ សត្វទាំងឡាយមិនត្រេកអរនឹងចិត្តឡើយ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃចិត្តមានព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយត្រេកអរនឹងចិត្ត ម្នាលភិក្ខុទាំងឡាយ បើទោសនៃចិត្តមិនមានទេ សត្វទាំងឡាយមិននឿយណាយនឹងចិត្តឡើយ ម្នាលភិក្ខុទាំងឡាយ ទោសនៃចិត្តមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយនឿយណាយនឹងចិត្ត ម្នាលភិក្ខុទាំងឡាយ បើការរលាស់ចេញនូវចិត្តមិនមានទេ សត្វទាំងឡាយមិនរលាស់ចេញចាកចិត្តឡើយ ម្នាលភិក្ខុទាំងឡាយ ការរលាស់ចេញនូវចិត្តមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយរលាស់ចេញចាកចិត្ត ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយមិនបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿង

និស្សរណតោ យថាភូតំ នាព្ភញ្ញាសុំ ។ នេវ តាវ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ[១] និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិបរិយាទិកតេន[២] ចេតសា វិហរឹសុ ។ យតោ ច ខោ ភិក្ខវេ សត្តា ឥមេសំ ឆន្នំ អជ្ឈត្តិកានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសុំ ។ អថ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិបរិយាទិកតេន ចេតសា វិហរន្តីតិ ។ បញ្ចមំ ។

[១៨] នោ ចេទំ ភិក្ខវេ រូបានំ អស្សាទោ អភវិស្ស ន យិទំ សត្តា រូបេសុ សារជ្ជេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបានំ អស្សាទោ តស្មា សត្តា

---

១ សស្សមណព្រាហ្មណី បជា សទេវមនុស្សាតិ ឯវំ ភវិតព្វំ ។ ២ កត្ថចិ វិមរិយាទិកតេនាតិ វា បាឋោ ។

រលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្នុងទាំង ៦ នេះ អស់កាលត្រឹមណា ។ ម្នាលភិក្ខុទាំងឡាយ សត្វលោកទាំងឡាយព្រមទាំងទេវលោក មារលោក ព្រហ្មលោក ព្រមទាំងពពួកសត្វនិងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស មិនបានរលាស់ចេញ មិនបានប្រាសចេញ មិនបានរួចស្រឡះ មានចិត្តមិនបានប្រព្រឹត្តកន្លងនូវដែនគឺកិលេសនិងវដ្ដៈ អស់កាលត្រឹមណោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែសត្វទាំងឡាយបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្ស នូវទោសថាជាទោស នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ នៃអាយតនៈខាងក្នុងទាំង ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ ទើបសត្វលោកទាំងឡាយ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ព្រមទាំងពពួកសត្វនិងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស រលាស់ចេញ ប្រាសចេញ រួចស្រឡះ មានចិត្តប្រព្រឹត្តកន្លងនូវដែនគឺកិលេសនិងវដ្ដៈបាន ។ ចប់សូត្រ ទី ៥ ។

[១៨] ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនៃរូបមិនមានទេ សត្វទាំងឡាយ មិនត្រេកអរក្នុងរូបឡើយ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃរូបមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយ

រូបេសុ សារជ្ជន្តិ នោ ចេទំ ភិក្ខវេ រូបានំ អាទីនវោ អភវិស្ស ន យិទំ សត្តា រូបេសុ និព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបានំ អាទីនវោ តស្មា សត្តា រូបេសុ និព្វិន្ទន្តិ នោ ចេទំ ភិក្ខវេ រូបានំ និស្សរណំ អភវិស្ស ន យិទំ សត្តា រូបេហិ និស្សរេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ រូបានំ និស្សរណំ តស្មា សត្តា រូបេហិ និស្សរន្តិ ។ នោ ចេទំ ភិក្ខវេ សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានំ ធម្មានំ អស្សាទោ អភវិស្ស ន យិទំ សត្តា ធម្មេសុ សារជ្ជេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ធម្មានំ អស្សាទោ តស្មា សត្តា ធម្មេសុ សា-រជ្ជន្តិ នោ ចេទំ ភិក្ខវេ ធម្មានំ អាទីនវោ អភវិស្ស ន យិទំ សត្តា ធម្មេសុ និព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ ធម្មានំ អាទីនវោ តស្មា សត្តា ធម្មេសុ និព្វិន្ទន្តិ នោ ចេទំ ភិក្ខវេ ធម្មានំ និស្សរណំ អភវិស្ស ន យិទំ សត្តា ធម្មេហិ និស្សរេយ្យុំ យស្មា ច ខោ ភិក្ខវេ

ត្រេកអរនឹងរូប ម្នាលភិក្ខុទាំងឡាយ បើទោសនៃរូបមិនមានទេ សត្វទាំងឡាយមិននឿយណាយនឹងរូបឡើយ ម្នាលភិក្ខុទាំងឡាយ ទោសនៃរូបមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយនឿយណាយនឹងរូប ម្នាលភិក្ខុទាំងឡាយ បើគ្រឿងរលាស់ចេញនូវរូបមិនមានទេ សត្វទាំងឡាយមិនរលាស់ចេញចាករូបឡើយ ម្នាលភិក្ខុទាំងឡាយ គ្រឿងរលាស់ចេញនូវរូបមាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយរលាស់ចេញចាករូប ។ ម្នាលភិក្ខុទាំងឡាយ បើអានិសង្សរបស់សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍មិនមានទេ សត្វទាំងឡាយមិនត្រេកអរនឹងធម្មារម្មណ៍ឡើយ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃធម្មារម្មណ៍មាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយត្រេកអរនឹងធម្មារម្មណ៍ ម្នាលភិក្ខុទាំងឡាយ បើទោសនៃធម្មារម្មណ៍មិនមានទេ សត្វទាំងឡាយមិននឿយណាយនឹងធម្មារម្មណ៍ឡើយ ម្នាលភិក្ខុទាំងឡាយ ទោសនៃធម្មារម្មណ៍មាន ព្រោះហេតុណា ហេតុនោះ បានជាសត្វទាំងឡាយរមែងនឿយណាយនឹងធម្មារម្មណ៍ ម្នាលភិក្ខុទាំងឡាយ បើគ្រឿងរលាស់ចេញនូវធម្មារម្មណ៍មិនមានទេសត្វទាំងឡាយមិនរលាស់ចេញចាកធម្មារម្មណ៍ឡើយ ម្នាលភិក្ខុទាំងឡាយ

២៧



អត្ថិ ធម្មានំ និស្សរណំ តស្មា សត្តា ធម្មេហិ និស្សរន្តិ ។ យាវកីវញ្ច ភិក្ខវេ សត្តា ឥមេសំ ឆន្នំ ពាហិរានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសុំ ។ នេវ តាវ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិបរិយាទិកតេន ចេតសា វិហរឹសុ ។ យតោ ច ខោ ភិក្ខវេ សត្តា ឥមេសំ ឆន្នំ ពាហិរានំ អាយតនានំ អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ ។ បេ ។ យថាភូតំ អព្ភញ្ញាសុំ ។ អថ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសញ្ញុត្តា វិប្បមុត្តា វិបរិយាទិកតេន ចេតសា វិហរន្តីតិ ។ ឆដ្ឋំ ។

គ្រឿងរលាស់ចេញនូវធម្មារម្មណ៍មាន ព្រោះហេតុណា ហេតុនោះ បាន ជាសត្វទាំងឡាយរលាស់ចេញចាកធម្មារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ មិនបានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវគ្រឿងរលាស់ចេញថាជាគ្រឿងរលាស់ចេញ ផង នៃអាយតនៈខាងក្រៅទាំង ៦ នេះ អស់កាលត្រឹមណា ។ ម្នាល ភិក្ខុទាំងឡាយ សត្វលោកទាំងឡាយ ព្រមទាំងទេវលោក មារ-លោក ព្រហ្មលោក ព្រមទាំងពពួកសត្វនិងសមណព្រាហ្មណ៍ ព្រម ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស មិនបានរលាស់ចេញ មិន បានប្រាសចេញ មិនបានរួចស្រឡះ មានចិត្តមិនបានប្រព្រឹត្តកន្លងនូវ ដែនគឺកិលេសនិងវដ្តៈ អស់កាលត្រឹមណោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែសត្វទាំងឡាយ បានដឹងច្បាស់តាមពិត នូវអានិសង្សថាជាអានិ-សង្សផង នូវទោសថាជាទោសផង នៃអាយតនៈខាងក្រៅទាំង ៦ នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទើបសត្វលោកទាំងឡាយ ព្រមទាំង ទេវលោក មារលោក ព្រហ្មលោក ព្រមទាំងពពួកសត្វនិងសមណ-ព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រលាស់ ចេញ ប្រាសចេញ រួចស្រឡះ មានចិត្តប្រព្រឹត្តកន្លងនូវដែនគឺកិលេស និងវដ្តៈបាន ។ ចប់សូត្រ ទី ៦ ។

[១៩] យោ ភិក្ខវេ ចក្ខុំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ បេ ។ យោ ជិវ្ហំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ បេ ។ យោ មនំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ ច ខោ ភិក្ខវេ ចក្ខុំ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ ។ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ បេ ។ យោ ជិវ្ហំ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ ។ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ មនំ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ ។ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមីតិ ។ សត្តមំ ។

[១៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ត្រេកអរចំពោះភ្នែក បុគ្គលនោះ ឈ្មោះថាត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាត្រេកអរចំពោះទុក្ខ បុគ្គលនោះមិនផុតចាកទុក្ខ ។ បេ ។ បុគ្គលណាត្រេកអរចំពោះអណ្តាត បុគ្គលនោះឈ្មោះថាត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាត្រេកអរចំពោះទុក្ខ បុគ្គលនោះមិនផុតចាកទុក្ខ ។ បេ ។ បុគ្គលណាត្រេកអរចំពោះចិត្ត បុគ្គលនោះឈ្មោះថាត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាត្រេកអរចំពោះទុក្ខ បុគ្គលនោះមិនផុតចាកទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា មិនត្រេកអរចំពោះភ្នែក បុគ្គលនោះ ទើបឈ្មោះថាមិនត្រេកអរចំពោះទុក្ខ តថាគតពោលថា បុគ្គលណាមិនត្រេកអរចំពោះទុក្ខ បុគ្គលនោះរួចផុតចាកទុក្ខ ។ បេ ។ បុគ្គលណាមិនត្រេកអរចំពោះអណ្តាត បុគ្គលនោះឈ្មោះថាមិនត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាមិនត្រេកអរចំពោះទុក្ខ បុគ្គលនោះរួចផុតចាកទុក្ខ ។ បុគ្គលណា មិនត្រេកអរចំពោះចិត្ត បុគ្គលនោះ ឈ្មោះថាមិនត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាមិនត្រេកអរចំពោះទុក្ខ បុគ្គលនោះរួចផុតចាកទុក្ខ ។

ចប់សូត្រ ទី ៧ ។

យមកវគ្គោ ទុតិយោ

[២០] យោ ភិក្ខវេ រូបេ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ បេ ។ យោ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ ច ខោ ភិក្ខវេ រូបេ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ ។ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ នាភិនន្ទតិ ទុក្ខំ សោ នាភិនន្ទតិ ។ យោ ទុក្ខំ នាភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមីតិ ។ អដ្ឋមំ ។

យមកវគ្គ ទី ២

[២០] ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ត្រេកអរចំពោះរូប បុគ្គលនោះ ឈ្មោះថាត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាត្រេកអរចំពោះទុក្ខ បុគ្គលនោះមិនរួចផុតចាកទុក្ខ ។ បេ ។ បុគ្គលណាត្រេកអរចំពោះសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ បុគ្គលនោះឈ្មោះថាត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាត្រេកអរចំពោះទុក្ខ បុគ្គលនោះមិនរួចផុតចាកទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណាមិនត្រេកអរចំពោះរូប បុគ្គលនោះទើបឈ្មោះថាមិនត្រេកអរចំ-ពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាមិនត្រេកអរចំពោះទុក្ខ បុគ្គលនោះរួចផុតចាកទុក្ខ ។ បុគ្គលណាមិនត្រេកអរ ចំពោះសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ បុគ្គលនោះឈ្មោះថាមិនត្រេកអរចំពោះទុក្ខ ។ តថាគតពោលថា បុគ្គលណាមិនត្រេកអរចំពោះទុក្ខ បុគ្គលនោះរួចផុតចាកទុក្ខ ។ ចប់សូត្រ ទី ៨ ។

[៦១] យោ ភិក្ខវេ ចក្ខុស្ស ឧប្បាទោ ឋិតិ អភិ-និព្វត្តិ ចាតុភាវោ ទុក្ខស្សេសោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស ចាតុភាវោ យោ សោតស្ស ។ បេ ។ យោ ឃានស្ស ។ យោ ជិវ្ហាយ ។ យោ កាយស្ស ។ យោ មនស្ស ឧប្បាទោ ឋិតិ អភិនិព្វត្តិ ចាតុភាវោ ទុក្ខស្សេ-សោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស ចាតុភា-វោ ។ យោ ច ខោ ភិក្ខវេ ចក្ខុស្ស និរោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គមោ ។ យោ សោតស្ស ។ យោ ឃានស្ស ។ យោ ជិវ្ហាយ ។ យោ កាយស្ស ។ យោ មនស្ស និរោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គ-មោតិ ។ ឆដ្ឋំ ។

[២១] ម្នាលភិក្ខុទាំងឡាយ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដ នៃភ្នែកណា នុ៎ះ ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគទាំងឡាយ ការកើតប្រាកដនៃជរានិងមរណៈ (ការកើតឡើងជាដើម) នៃត្រចៀកណា ។ បេ ។ នៃច្រមុះណា ។ នៃអណ្តាតណា ។ នៃកាយណា ។ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដ នៃចិត្តណា នុ៎ះ ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគទាំងឡាយ ការកើតប្រាកដនៃជរានិងមរណៈ ។ ម្នាលភិក្ខុទាំងឡាយ លុះតែការរលត់ ការរម្ងាប់ ការវិនាស នៃភ្នែកណា នុ៎ះទើបឈ្មោះថាការរលត់នៃទុក្ខ ការរម្ងាប់នៃរោគទាំងឡាយ ការវិនាសនៃជរានិងមរណៈបាន ។ (ការរលត់) នៃត្រចៀកណា ។ នៃច្រមុះណា ។ នៃអណ្តាតណា ។ នៃកាយណា ។ ការរលត់ ការរម្ងាប់ ការវិនាស នៃចិត្តណា នុ៎ះ ឈ្មោះថាការរលត់នៃទុក្ខ ការរម្ងាប់នៃរោគទាំងឡាយ ការវិនាសនៃជរានិងមរណៈបាន ។ ចប់សូត្រ ទី ៩ ។

យមកវគ្គោ ទុតិយោ

[២២] យោ ភិក្ខវេ រូបានំ ឧប្បាទោ ឋិតិ អភិ-
និព្វត្តិ បាតុភាវោ ទុក្ខស្សេសោ ឧប្បាទោ រោគានំ
ឋិតិ ជរាមរណស្ស បាតុភាវោ ។ យោ សទ្ទានំ ។ បេ ។
យោ ធម្មានំ ឧប្បាទោ ឋិតិ អភិនិព្វត្តិ បាតុភាវោ
ទុក្ខស្សេសោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស
បាតុភាវោ ។

[២៣] យោ ច ខោ ភិក្ខវេ រូបានំ និរោធោ វូប-
សមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ
វូបសមោ ជរាមរណស្ស អត្ថង្គមោ ។ យោ សទ្ទានំ ។
យោ គន្ធានំ ។ យោ រសានំ ។ យោ ផោដ្ឋព្វានំ ។
យោ ធម្មានំ និរោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេ-
សោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គ-
មោតិ ។ ទសមំ ។

យមកវគ្គោ ទុតិយោ ។

យមកវគ្គ ទី ២

[២២] ម្នាលភិក្ខុទាំងឡាយ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដ នៃរូបទាំងឡាយណា នុ៎ះ ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគទាំងឡាយ ការកើតប្រាកដនៃជរានិងមរណៈ ។ (ការកើតឡើងជាដើម) នៃសំឡេងទាំងឡាយណា ។ បេ ។ ការកើតឡើង ការតាំងនៅ ការកើតចំពោះ ការកើតប្រាកដនៃធម្មារម្មណ៍ទាំងឡាយណា នុ៎ះ ឈ្មោះថាការកើតឡើងនៃទុក្ខ ការតាំងនៅនៃរោគទាំងឡាយ ការកើតប្រាកដនៃជរានិងមរណៈ ។

[២៣] ម្នាលភិក្ខុទាំងឡាយ លុះតែការរលត់ ការរម្ងាប់ ការវិនាស នៃរូបទាំងឡាយណា នុ៎ះ ទើបឈ្មោះថាការរលត់នៃទុក្ខ ការរម្ងាប់នៃរោគទាំងឡាយ ការវិនាសនៃជរានិងមរណៈបាន ។ (ការរលត់ជាដើម) នៃសំឡេងទាំងឡាយណា ។ នៃក្លិនទាំងឡាយណា ។ នៃរសទាំងឡាយណា ។ នៃផោដ្ឋព្វៈទាំងឡាយណា ។ ការរលត់ ការរម្ងាប់ ការវិនាស នៃធម្មារម្មណ៍ទាំងឡាយណា នុ៎ះ ឈ្មោះថាការរលត់នៃទុក្ខ ការរម្ងាប់នៃរោគទាំងឡាយ ការវិនាសនៃជរានិងមរណៈបាន ។ ចប់សូត្រ ទី ១០ ។

ចប់ យមកវគ្គ ទី ២ ។

៣២



# តស្សុទ្ទានំ

សម្ពោធេន ទុវេ វុត្តា

អស្សាទេន អបរេ ទ្វេ

នោ ចេតេន ទ្វេ វុត្តា

អភិនន្ទេន អបរេ ទ្វេ

ឧប្បាទេន ទុវេ វុត្តា

វគ្គោ តេន បវុច្ចតីតិ ។

---

សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ

# ឧទ្ទាននៃយមកវគ្គនោះ គឺ

*និយាយ អំពីការត្រាស់ដឹងពីរលើក អំពីអានិសង្សពីរលើក ដទៃទៀត អំពីចិត្តមិនបានប្រព្រឹត្តកន្លងនូវដែនគឺកិលេសនិង វដ្តៈពីរលើក អំពីការត្រេកអរពីរលើកដទៃទៀត អំពីការ កើតឡើងពីរលើក ហេតុនោះ ទើបហៅថា វគ្គ ។*

---

# សព្វវគ្គោ

[២៤] សព្វំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ ។ កិញ្ច ភិក្ខវេ សព្វំ ចក្ខុញ្ចេវ រូបា ច សោតញ្ច សទ្ទា ច ឃានញ្ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្វា ច មនោ ច ធម្មា ច ។ ឥទំ វុច្ចតិ ភិក្ខវេ សព្វំ ។ យោ ភិក្ខវេ ឯវំ វទេយ្យ អហមេតំ សព្វំ បច្ចក្ខាយ អញ្ញំ[១] បញ្ញាបេស្សាមីតិ ។ តស្ស វាចា វត្ថុ ទេវស្ស[២] ។ បុដ្ឋោ ច ន សម្បាយេយ្យ[៣] ឧត្តរឹ ច វិឃាតំ អាបជ្ជេយ្យ ។ តំ កិស្ស ហេតុ ។ យថា តំ ភិក្ខវេ អវិសយស្មិន្តិ ។ បឋមំ ។

---

១ កត្ថចិ អញ្ញំ សព្វំ ។ ២ ឱ. វត្ថុវេវស្ស ។ ម. វត្ថុកមេវស្ស ។ ៣ ឱ. ន សម្បាយេយ្យ ។

# សព្វវគ្គ

[២៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអាយតនៈទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចាំស្តាប់នូវអាយតនៈនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង តើដូចម្តេច គឺភ្នែក ១ រូប ១ ត្រចៀក ១ សំឡេង ១ ច្រមុះ ១ ក្លិន ១ អណ្តាត ១ រស ១ កាយ ១ ផោដ្ឋព្វៈ ១ ចិត្ត ១ ធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអាយតនៈទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណានិយាយយ៉ាងនេះថា អញឃាត់នូវអាយតនៈទាំងពួងនុ៎ះ ហើយនឹងបញ្ញត្តនូវវត្ថុដទៃ ។ វាចារបស់បុគ្គលនោះ គ្រាន់តែឲ្យកើតទៅជារឿងប៉ុណ្ណោះឯង ។ បុគ្គលនោះ បើមានគេសួរមក ក៏មិនអាចញុំាងរឿងនោះឲ្យសម្រេចបាន នាំឲ្យលំបាកទៅខាងមុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា (សត្វទាំងឡាយតែងបាននូវសេចក្តីទុក្ខ) ក្នុងទីមិនមែនជាវិស័យដោយពិត ។ ចប់សូត្រ ទី ១ ។

[២៨] សព្វំ បហានាយ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ សព្វំ បហានាយ ធម្មោ ។ ចក្ខុំ ភិក្ខវេ បហាតព្វំ រូបា បហាតព្វា ចក្ខុវិញ្ញាណំ បហាតព្វំ ចក្ខុសម្ផស្សោ បហាតព្វោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បហាតព្វំ ។ សោតំ បហាតព្វំ ។ ឃានំ បហាតព្វំ ។ ជិវ្ហា បហាតព្វា រសា បហាតព្វា ជិវ្ហាវិញ្ញាណំ បហាតព្វំ ជិវ្ហាសម្ផស្សោ បហាតព្វោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បហាតព្វំ ។ កាយោ បហាតព្វោ ។ មនោ បហាតព្វោ ធម្មា បហាតព្វា មនោវិញ្ញាណំ បហាតព្វំ មនោសម្ផស្សោ បហាតព្វោ យម្បិទំ

[២៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម៌ ដើម្បីការលះបង់នូវអាយតនៈទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចាំស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌សម្រាប់ការលះបង់នូវអាយតនៈទាំងពួង ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវលះបង់ចក្ខុ អ្នកទាំងឡាយត្រូវលះបង់រូប អ្នកទាំងឡាយត្រូវលះបង់ចក្ខុវិញ្ញាណ អ្នកទាំងឡាយត្រូវលះបង់ចក្ខុសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ អ្នកទាំងឡាយត្រូវលះបង់នូវវេទនានោះចេញ ។ អ្នកទាំងឡាយ ត្រូវលះបង់សោតៈ ។ អ្នកទាំងឡាយត្រូវលះបង់ឃានៈ ។ អ្នកទាំង-ឡាយត្រូវលះបង់ជិវ្ហា អ្នកទាំងឡាយត្រូវលះបង់ជិវ្ហាសម្ផស្ស ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ អ្នកទាំងឡាយត្រូវលះបង់នូវវេទនានោះចេញ ។ អ្នកទាំងឡាយត្រូវលះបង់កាយ ។ អ្នកទាំងឡាយត្រូវលះបង់មនោ អ្នកទាំងឡាយត្រូវលះបង់ធម្មារម្មណ៍ អ្នកទាំងឡាយត្រូវលះបង់មនោវិញ្ញាណ អ្នកទាំងឡាយត្រូវលះបង់មនោសម្ផស្ស ទោះបីវេទនាណា

មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បហាតព្វំ ។ អយំ ខោ ភិក្ខវេ សព្វំ បហានាយ ធម្មោតិ ។ ទុតិយំ ។

[២៦] សព្វំ អភិញ្ញាបរិញ្ញា បហានាយ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ សព្វំ អភិញ្ញាបរិញ្ញា បហានាយ ធម្មោ ។ ចក្ខុំ ភិក្ខវេ អភិញ្ញាបរិញ្ញា បហាតព្វំ រូបា អភិញ្ញា-បរិញ្ញា បហាតព្វា ចក្ខុវិញ្ញាណំ អភិញ្ញាបរិញ្ញា ប-ហាតព្វំ ចក្ខុសម្ផស្សោ អភិញ្ញាបរិញ្ញា បហាតព្វោ

ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ អ្នកទាំងឡាយត្រូវលះបង់ នូវវេទនានោះចេញ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាធម៌សម្រាប់ការលះបង់ នូវអាយតនៈទាំងពួង ។ ចប់សូត្រ ទី ២ ។

[២៦] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ ចំពោះអ្នកទាំងឡាយ ដើម្បីការលះបង់នូវអាយតនៈទាំងពួង ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយចាំស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ សម្រាប់ការលះបង់នូវអាយតនៈទាំងពួង ដោយអភិញ្ញានិងបរិញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវលះបង់នូវចក្ខុ ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវរូប ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវចក្ខុវិញ្ញាណ ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវចក្ខុសម្ផស្ស ដោយអភិញ្ញានិងបរិញ្ញា

យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិញ្ញាបរិញ្ញា បហាតព្វំ ។ បេ ។ ជិវ្ហា អភិញ្ញាបរិញ្ញា បហាតព្វា រសា អភិញ្ញាបរិញ្ញា បហាតព្វា ជិវ្ហាវិញ្ញាណំ អភិញ្ញាបរិញ្ញា បហាតព្វំ ជិវ្ហាសម្ផស្សោ អភិញ្ញាបរិញ្ញា បហាតព្វោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិញ្ញាបរិញ្ញា បហាតព្វំ ។ កាយោ អភិញ្ញាបរិញ្ញា បហាតព្វោ ។ មនោ អភិញ្ញាបរិញ្ញា បហាតព្វោ ធម្មា អភិញ្ញាបរិញ្ញា បហាតព្វា មនោវិញ្ញាណំ អភិញ្ញាបរិញ្ញា បហាតព្វំ មនោសម្ផស្សោ អភិញ្ញាបរិញ្ញា បហាតព្វោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិញ្ញាបរិញ្ញា

វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ អ្នកទាំងឡាយ ត្រូវលះបង់នូវវេទនានោះ ដោយអភិញ្ញានិងបរិញ្ញា ។ បេ ។ អ្នកទាំងឡាយ ត្រូវលះបង់នូវជិវ្ហា ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវរស ដោយអភិញ្ញា និងបរិញ្ញា អ្នកទាំងឡាយ ត្រូវលះបង់នូវជិវ្ហាវិញ្ញាណ ដោយអភិញ្ញា និងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវជិវ្ហាសម្ផស្ស ដោយអភិញ្ញា និងបរិញ្ញា វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ អ្នកទាំងឡាយត្រូវលះបង់នូវវេទ-នានោះ ដោយអភិញ្ញានិងបរិញ្ញា ។ អ្នកទាំងឡាយត្រូវលះបង់នូវកាយ ដោយអភិញ្ញានិងបរិញ្ញា ។ អ្នកទាំងឡាយត្រូវលះបង់នូវមនោ ដោយអភិញ្ញានិងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវធម្មារម្មណ៍ ដោយអភិញ្ញា និងបរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវមនោវិញ្ញាណ ដោយអភិញ្ញានិង បរិញ្ញា អ្នកទាំងឡាយត្រូវលះបង់នូវមនោសម្ផស្ស ដោយអភិញ្ញានិងបរិញ្ញា វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ អ្នកទាំងឡាយ ត្រូវលះបង់នូវវេទនានោះ

បហាតព្វំ ។ អយំ ខោ ភិក្ខវេ សព្វំ អភិញ្ញាបរិញ្ញា
បហានាយ ធម្មោតិ ។ តតិយំ ។

[២៧] សព្វំ ភិក្ខវេ អនភិជានំ អបរិជានំ អវិរា-
ជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ កិញ្ច
ភិក្ខវេ សព្វំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជ-
ហំ អភព្វោ ទុក្ខក្ខយាយ ។ ចក្ខុំ ភិក្ខវេ អនភិ-
ជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខ-
ក្ខយាយ ។ រូបេ អនភិជានំ អបរិជានំ អវិរាជយំ
អប្បជហំ អភព្វោ ទុក្ខក្ខយាយ ចក្ខុវិញ្ញាណំ ។ បេ ។
ចក្ខុសម្ផស្សំ ។ បេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា
។ បេ ។ ទុក្ខក្ខយាយ ។ ជិវ្ហា អនភិជានំ អបរិជានំ
អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ រសេ
។ បេ ។ ជិវ្ហាវិញ្ញាណំ ។ បេ ។ ជិវ្ហាសម្ផស្សំ ។ បេ ។

ដោយអភិញ្ញានិងបរិញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថាធម៌សម្រាប់ការលះបង់នូវអាយតនៈទាំងពួង ដោយអភិញ្ញានិងបរិញ្ញា ។ ចប់សូត្រ ទី ៣ ។

[២៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវចក្ខុ មិនគួរដើម្បីអស់ទៅនៃទុក្ខឡើយ ។ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវរូបទាំងឡាយ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ នូវចក្ខុវិញ្ញាណ ។ បេ ។ នូវចក្ខុសម្ផស្ស ។ បេ ។ ព្រោះចក្ខុសម្ផស្សជាបច្ច័យណា ។ បេ ។ ដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវជិវ្ហា មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ នូវរសទាំងឡាយ ។ បេ ។ នូវជិវ្ហាវិញ្ញាណ ។ បេ ។ នូវជិវ្ហាសម្ផស្ស ។ បេ ។

យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ កាយំ មនំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ធម្មេ ។ បេ ។ មនោវិញ្ញាណំ ។ បេ ។ មនោសម្ផស្សំ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ ឥទំ ខោ ភិក្ខវេ សព្វំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។

ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវវេទនានោះ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវកាយនិងមនោ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ នូវធម្មារម្មណ៍ ។ បេ ។ នូវមនោវិញ្ញាណ ។ បេ ។ នូវមនោសម្ផស្ស ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវវេទនានោះ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំងពួងនេះឯង មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។

៣៩

សព្វវគ្គោ តតិយោ

[២៨] សព្វញ្ច ខោ ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ កិញ្ច ភិក្ខវេ សព្វំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ ចក្ខុំ ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ រូបេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ចក្ខុវិញ្ញាណំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ចក្ខុសម្ផស្សំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ បេ ។ ជិវ្ហា អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ រសេ ។ បេ ។

សព្វវគ្គ ទី ៣

[២៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអាយតនៈទាំងពួង ទើបគួរដើម្បីអស់ទៅនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអាយតនៈទាំងពួង ទើបគួរដើម្បីអស់ទៅនៃទុក្ខបាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវចក្ខុ គួរដើម្បីអស់ទៅនៃទុក្ខបាន ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវរូប គួរដើម្បីអស់ទៅនៃទុក្ខបាន ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវចក្ខុវិញ្ញាណ គួរដើម្បីអស់ទៅនៃទុក្ខបាន ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវចក្ខុសម្ផស្ស គួរដើម្បីអស់ទៅនៃទុក្ខបាន ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវវេទនានោះ គួរដើម្បីអស់ទៅនៃទុក្ខបាន ។ បេ ។ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវជិវ្ហា គួរដើម្បីអស់ទៅនៃទុក្ខបាន នូវរសទាំងឡាយ ។ បេ ។

ជិវ្ហាវិញ្ញាណំ ។ បេ ។ ជិវ្ហាសម្ផស្សំ ។ បេ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ កាយំ មនំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ធម្មេ ។ បេ ។ មនោវិញ្ញាណំ ។ បេ ។ មនោសម្ផស្សំ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ ឥទំ ខោ ភិក្ខវេ សព្វំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ ចតុត្ថំ ។

នូវជិវ្ហាវិញ្ញាណ ។ បេ ។ នូវជិវ្ហាសម្ផស្ស ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវវេទនានោះ គួរដើម្បីអស់ទៅនៃទុក្ខបាន ។ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវកាយនិងមនោ គួរដើម្បីអស់ទៅនៃទុក្ខបាន នូវធម្មារម្មណ៍ ។ បេ ។ នូវមនោវិញ្ញាណ ។ បេ ។ នូវមនោសម្ផស្ស ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវវេទនានោះ គួរដើម្បីអស់ទៅនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអាយតនៈទាំងពួងនេះឯង គួរដើម្បីអស់ទៅនៃទុក្ខបាន ។ ចប់សូត្រ ទី ៤ ។

សព្វវគ្គោ តតិយោ

[២៩] សព្វំ ភិក្ខវេ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ កិញ្ច ភិក្ខវេ សព្វំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ យញ្ច ភិក្ខវេ ចក្ខុំ យេ ច រូបា យញ្ច ចក្ខុវិញ្ញាណំ យេ ច ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា ។ បេ ។ យា ច ជិវ្ហា យេ ច រសា យញ្ច ជិវ្ហាវិញ្ញាណំ យេ ច ជិវ្ហាវិញ្ញាណវិញ្ញាតព្វា ធម្មា ។ បេ ។ យោ ច មនោ យេ ច ធម្មា យញ្ច មនោវិញ្ញាណំ យេ ច មនោវិញ្ញាណវិញ្ញាតព្វា ធម្មា ។ ឥទំ ខោ ភិក្ខវេ សព្វំ អនភិជានំ អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។

[៣០] សព្វញ្ច[១] ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ កិញ្ច ភិក្ខវេ សព្វំ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ ។ យញ្ច ភិក្ខវេ ចក្ខុំ យេ ច រូបា យញ្ច ចក្ខុវិញ្ញាណំ

១ ឱ. សព្វញ្ច ខោ ។

សព្វវគ្គ ទី ៣

[២៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំង-ពួង មិនគួរដើម្បីអស់ទៅនៃទុក្ខបាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុណាក្តី រូបណាក្តី ចក្ខុវិញ្ញាណណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយចក្ខុវិញ្ញាណក្តី ។ បេ ។ ជិវ្ហាណាក្តី រសណាក្តី ជិវ្ហាវិញ្ញាណណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណក្តី ។ បេ ។ មនោណាក្តី ធម្មារម្មណ៍ណាក្តី មនោវិញ្ញាណណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយមនោវិញ្ញាណក្តី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិននឿយណាយ មិនលះបង់ នូវអាយតនៈទាំងពួងនេះឯង មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។

[៣០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអាយតនៈទាំងពួង គួរដើម្បីអស់ទៅនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដឹងច្បាស់ កំណត់ដឹង នឿយ-ណាយ លះបង់ នូវអាយតនៈទាំងពួង គួរដើម្បីអស់ទៅនៃទុក្ខបាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុណាក្តី រូបណាក្តី ចក្ខុវិញ្ញាណ

យេ ច ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា ។ បេ ។ យា ច ជិវ្ហា យេ ច រសា យញ្ច ជិវ្ហាវិញ្ញាណំ យេ ច ជិវ្ហាវិញ្ញាណវិញ្ញាតព្វា ធម្មា ។ បេ ។ យោ ច មនោ យេ ច ធម្មា យញ្ច មនោវិញ្ញាណំ យេ ច មនោវិញ្ញាណវិញ្ញាតព្វា ធម្មា ។ ឥទំ ខោ ភិក្ខវេ សព្វំ អភិញាធំ បរិញាធំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ បញ្ចមំ ។

[៣១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា គយាយំ វិហរតិ គយាសីសេ សទ្ធឹ ភិក្ខុសហស្សេន ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ សព្វំ ភិក្ខវេ អាទិត្តំ ។ កិញ្ច ភិក្ខវេ សព្វំ អាទិត្តំ ។ ចក្ខុំ ភិក្ខវេ អាទិត្តំ រូបា អាទិត្តា ចក្ខុវិញ្ញាណំ អាទិត្តំ ចក្ខុសម្ផស្សោ អាទិត្តោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

ណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយចក្ខុវិញ្ញាណក្តី ។ បេ ។ ជិវ្ហាណាក្តី រសណាក្តី ជិវ្ហាវិញ្ញាណណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណក្តី ។ បេ ។ មនោណាក្តី ធម្មារម្មណ៍ណាក្តី មនោ-វិញ្ញាណណាក្តី ធម្មារម្មណ៍ណាដែលត្រូវដឹងដោយមនោវិញ្ញាណក្តី ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអាយតនៈទាំងពួងនេះឯង គួរដើម្បីអស់ទៅនៃទុក្ខបាន ។ ចប់សូត្រ ទី ៥ ។

[៣១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅជិតស្រះក្នុងស្រុកឈ្មោះគយាសីសៈ ជាមួយនឹងភិក្ខុ ១០០០ រូប ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ក្តៅ រូបជារបស់ក្តៅ ចក្ខុវិញ្ញាណជារបស់ក្តៅ ចក្ខុសម្ផស្សជារបស់ក្តៅ ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ

៤៣

## សព្វវគ្គោ តតិយោ

តម្បិ អាទិត្តំ ។ កេន អាទិត្តំ ។ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ ។ បេ ។ ។ ជិវ្ហា អាទិត្តា រសា អាទិត្តា ជិវ្ហាវិញ្ញាណំ អាទិត្តំ ជិវ្ហាសម្ផស្សោ អាទិត្តោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អាទិត្តំ ។ កេន អាទិត្តំ ។ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ ។ បេ ។ មនោ អាទិត្តោ ធម្មា អាទិត្តា មនោវិញ្ញាណំ អាទិត្តំ

វេទនានោះក៏ជារបស់ក្តៅដែរ ។ ក្តៅដោយអ្វី ។ តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីគ្រាំគ្រា ដោយសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ បេ ។ អណ្តាតជារបស់ក្តៅ រសជារបស់ក្តៅ ជិវ្ហាវិញ្ញាណជារបស់ក្តៅ ជិវ្ហាសម្ផស្សជារបស់ក្តៅ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះក៏ជារបស់ក្តៅដែរ ។ ក្តៅដោយអ្វី ។ តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយភ្លើងគឺសេចក្តីកើត ដោយសេចក្តីគ្រាំគ្រា ដោយសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ បេ ។ មនោជារបស់ក្តៅ ធម្មារម្មណ៍ជារបស់ក្តៅ មនោវិញ្ញាណជារបស់ក្តៅ

មនោសម្ផស្សោ អាទិត្តោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អាទិត្តំ ។ កេន អាទិត្តំ ។ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមិ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ

មនោសម្ផស្សជារបស់ក្តៅ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏ជារបស់ក្តៅដែរ ។ ក្តៅដោយអ្វី ។ តថាគតពោលថា ក្តៅដោយភ្លើងគឺរាគៈ ដោយភ្លើងគឺទោសៈ ដោយភ្លើងគឺមោហៈ ក្តៅដោយសេចក្តីកើត ដោយសេចក្តីគ្រាំគ្រា ដោយសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ជាអ្នកចេះដឹង បានយល់ឃើញយ៉ាងនេះហើយ ក៏នឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ទោបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះផង ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ

សព្វវគ្គោ តតិយោ

វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករ-ណីយំ ដាបរំ ឥត្ថត្តាយាតិ បជាជាតីតិ ។ ឥទមវោច ភគវា ។ អត្តមជា តេ ភិក្ខូ ភគវតោ ភាសិតំ អភិ-ជន្ទុំ ។ ឥមស្មឹ ច បជ វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុសហស្សស្ស អដុបាដាយ អាសវេហិ ចិត្តាជិ វិមុច្ចឹសូតិ ។ ឆដ្ឋំ ។

ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអញក៏បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះមានព្រះភាគបានត្រាស់ភាសិតនេះហើយ ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិតនៃព្រះមានព្រះភាគ ។ នាកាលវេយ្យាករណ៍ (ព្រះសូត្រឥតមានគាថា) នេះ ដែលព្រះមានព្រះភាគកំពុងត្រាស់ទេសនា ចិត្តរបស់ភិក្ខុទាំង ១.០០០ រូបនោះ ក៏បានផុតស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះការមិនប្រកាន់មាំ ។ ចប់សូត្រ ទី ៦ ។

[៣២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគ-
ហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តត្រ ខោ
ភគវា ភិក្ខូ អាមន្តេសិ សព្វំ ភិក្ខវេ អន្ធភូតំ ។ កិញ្ច
ភិក្ខវេ សព្វំ អន្ធភូតំ ។ ចក្ខុំ ភិក្ខវេ អន្ធភូតំ រូបា អន្ធ-
ភូតា ចក្ខុវិញ្ញាណំ អន្ធភូតំ ចក្ខុសម្ផស្សោ អន្ធភូតោ
យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ
វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អន្ធភូតំ ។ កេន
អន្ធភូតំ ។ ជាតិយា ជរាយ មរណេន សោកេហិ បរិទេ-
វេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អន្ធភូតន្តិ
វទាមិ ។ បេ ។ ជិវ្ហា អន្ធភូតា រសា អន្ធភូតា ជិវ្ហា-

[៣២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួង ជារបស់ខ្វាក់ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួង ជារបស់ខ្វាក់ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជារបស់ខ្វាក់ រូបជារបស់ខ្វាក់ ចក្ខុវិញ្ញាណជារបស់ខ្វាក់ ចក្ខុសម្ផស្សជារបស់ខ្វាក់ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏ជារបស់ខ្វាក់ ។ ជារបស់ខ្វាក់ដោយអ្វី ។ តថាគតពោលថា ជារបស់ខ្វាក់ដោយសេចក្តីកើត សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខក្នុងកាយ សេចក្តីទុក្ខក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ បេ ។ ជិវ្ហាជារបស់ខ្វាក់ រសជារបស់ខ្វាក់ ជិវ្ហា-

៤៧

សព្វវគ្គោ តតិយោ

វិញ្ញាណំ អនុក្ខតំ ជិវ្ហាសម្ផស្សោ អនុក្ខតោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនុក្ខតំ ។ កេន អនុក្ខតំ ។ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អនុក្ខតន្តិ វទាមិ ។ បេ ។ មនោ អនុក្ខតោ ធម្មា អនុក្ខតា មនោ-វិញ្ញាណំ អនុក្ខតំ មនោសម្ផស្សោ អនុក្ខតោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនុក្ខតំ ។ កេន អនុក្ខតំ ។ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អនុក្ខតន្តិ វទាមិ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយ-សាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ

សឡាយតនវគ្គ ទី ៣

វិញ្ញាណជារបស់ខ្វាក់ ជិវ្ហាសម្ផស្សជារបស់ខ្វាក់ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្ស ជាបច្ច័យ វេទនានោះជារបស់ខ្វាក់ ។ ជារបស់ខ្វាក់ដោយអ្វី ។ តថាគត ពោលថា ជារបស់ខ្វាក់ ដោយសេចក្តីកើត សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខក្នុងកាយ សេចក្តីទុក្ខក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ បេ ។ មនោជារបស់ខ្វាក់ ធម្មា-រម្មណ៍ជារបស់ខ្វាក់ មនោវិញ្ញាណជារបស់ខ្វាក់ មនោសម្ផស្សជារបស់ខ្វាក់ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែល កើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏ជារបស់ខ្វាក់ ។ ជា របស់ខ្វាក់ដោយអ្វី ។ តថាគតពោលថា ជារបស់ខ្វាក់ ដោយសេចក្តីកើត សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តី ទុក្ខក្នុងកាយ សេចក្តីទុក្ខក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ជាអ្នកចេះដឹង យល់ឃើញ យ៉ាងនេះ ក៏នឿយណាយនឹងចក្ខុផង នឿយណាយនឹងចក្ខុវិញ្ញាណផង

ចក្ខុសម្ផស្សេបិ និព្ពិន្ទតិ ។ បេ ។ យម្បិទំ មនោ-
សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ
វា អទុក្ខមសុខំ វា តស្មឹបិ និព្ពិន្ទតិ និព្វិន្ទំ វិរជ្ជតិ
វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។
ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ
ឥត្ថត្តាយាតិ បជានាតីតិ ។ សត្តមំ ។

[៣៣] សព្វមញ្ញិតសមុគ្ឃាតសារុប្បំ វោ ភិក្ខវេ
បដិបទំ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិ-
ករោថ ភាសិស្សាមីតិ ។ កតមា ច សា ភិក្ខវេ
សព្វមញ្ញិតសមុគ្ឃាតសារុប្បា បដិបទា ។ ឥធ ភិក្ខវេ

នឿយណាយនឹងចក្ខុសម្ផស្សផង ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះឯង កាលបើនឿយណាយ ក៏ប្រាសចាកតម្រេក ព្រោះតែការប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ។ កាលបើចិត្តផុតស្រឡះ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ (អរិយសាវកនោះ) ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អញ បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គ-ភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៧ ។

[៣៣] ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្តែងនូវបដិបទាដ៏សមគួរដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ដល់អ្នកទាំង-ឡាយ ។ ចូរស្តាប់នូវបដិបទានោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគត នឹងសម្តែង ។ ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាដ៏សមគួរដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួងនោះ តើដូចម្តេចខ្លះ ។ ម្នាល

៤៩

សព្វវគ្គោ តតិយោ

ចក្ខុំ ន មញ្ញតិ ចក្ខុស្មឹ ន មញ្ញតិ ចក្ខុតោ ន មញ្ញតិ ចក្ខុំ មេតិ ន មញ្ញតិ ។ រូបេ ន មញ្ញតិ រូបេសុ ន មញ្ញ-តិ រូបតោ ន មញ្ញតិ រូបា មេតិ ន មញ្ញតិ ចក្ខុវិញ្ញា-ណំ ន មញ្ញតិ ចក្ខុវិញ្ញាណស្មឹ ន មញ្ញតិ ចក្ខុវិញ្ញាណ-តោ ន មញ្ញតិ ចក្ខុវិញ្ញាណំ មេតិ ន មញ្ញតិ ចក្ខុ-សម្ផស្សំ ន មញ្ញតិ ចក្ខុសម្ផស្សស្មឹ ន មញ្ញតិ ចក្ខុ-សម្ផស្សតោ ន មញ្ញតិ ចក្ខុសម្ផស្សោ មេតិ ន មញ្ញតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ បេ ។ ជិវ្ហំ ន មញ្ញតិ ជិវ្ហាយ ន មញ្ញតិ ជិវ្ហាតោ ន មញ្ញតិ ជិវ្ហា មេតិ ន មញ្ញតិ រសេ ន មញ្ញតិ

សព្វវគ្គ ទី ៣

ភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសម្គាល់នូវចក្ខុ មិនសម្គាល់ក្នុងចក្ខុ មិនសម្គាល់ដោយចក្ខុ មិនសម្គាល់ថាចក្ខុជារបស់អញ ។ មិនសំគាល់នូវរូបទាំងឡាយ មិនសម្គាល់ក្នុងរូបទាំងឡាយ មិនសម្គាល់ដោយរូប មិនសម្គាល់ថារូបទាំងឡាយជារបស់អញ មិនសម្គាល់នូវចក្ខុវិញ្ញាណ មិនសម្គាល់ក្នុងចក្ខុវិញ្ញាណ មិនសម្គាល់ដោយចក្ខុវិញ្ញាណ មិនសម្គាល់ថាចក្ខុវិញ្ញាណជារបស់អញ មិនសម្គាល់នូវចក្ខុសម្ផស្ស មិនសម្គាល់ក្នុងចក្ខុសម្ផស្ស មិនសម្គាល់ដោយចក្ខុសម្ផស្ស មិនសម្គាល់ថាចក្ខុសម្ផស្សជារបស់អញ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនសម្គាល់នូវវេទនានោះផង មិនសម្គាល់ក្នុងវេទនានោះផង មិនសម្គាល់ដោយវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។ បេ ។ មិនសម្គាល់នូវអណ្តាត មិនសម្គាល់ក្នុងអណ្តាត មិនសម្គាល់ដោយអណ្តាត មិនសម្គាល់ថាអណ្តាតជារបស់អញ មិនសម្គាល់នូវរសទាំងឡាយ

រសេសុ ន មញ្ញតិ រសតោ ន មញ្ញតិ រសា មេតិ ន មញ្ញតិ ។ ជិវ្ហាវិញ្ញាណំ ន មញ្ញតិ ជិវ្ហាវិញ្ញាណស្មឹ ន មញ្ញតិ ជិវ្ហាវិញ្ញាណតោ ន មញ្ញតិ ជិវ្ហាវិញ្ញាណំ មេតិ ន មញ្ញតិ ជិវ្ហាសម្ផស្សំ ន មញ្ញតិ ជិវ្ហាសម្ផស្សស្មឹ ន មញ្ញតិ ជិវ្ហាសម្ផស្សតោ ន មញ្ញតិ ជិវ្ហាសម្ផស្សោ មេតិ ន មញ្ញតិ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ បេ ។ មនំ ន មញ្ញតិ មនស្មឹ ន មញ្ញតិ មនតោ ន មញ្ញតិ មនោ មេតិ ន មញ្ញតិ ។ ធម្មេ ន មញ្ញតិ ធម្មេសុ ន មញ្ញតិ ធម្មតោ ន មញ្ញតិ ធម្មា មេតិ ន មញ្ញតិ ។ មនោវិញ្ញាណំ ន មញ្ញតិ មនោវិញ្ញាណស្មឹ ន មញ្ញតិ មនោវិញ្ញាណតោ ន មញ្ញតិ មនោវិញ្ញាណំ មេតិ ន មញ្ញតិ ។ មនោសម្ផស្សំ ន មញ្ញតិ

មិនសម្គាល់ក្នុងរសទាំងឡាយ មិនសម្គាល់ដោយរស មិនសម្គាល់ថា រសទាំងឡាយជារបស់អញ ។ មិនសម្គាល់នូវជិវ្ហាវិញ្ញាណ មិនសំគាល់ក្នុងជិវ្ហាវិញ្ញាណ មិនសម្គាល់ដោយជិវ្ហាវិញ្ញាណ មិនសម្គាល់ថា ជិវ្ហាវិញ្ញាណជារបស់អញ មិនសម្គាល់នូវជិវ្ហាសម្ផស្ស មិនសម្គាល់ក្នុង ជិវ្ហាសម្ផស្ស មិនសម្គាល់ដោយជិវ្ហាសម្ផស្ស មិនសម្គាល់ថាជិវ្ហាសម្ផស្ស ជារបស់អញ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែន ទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ក៏មិន សម្គាល់នូវវេទនានោះផង មិនសម្គាល់ក្នុងវេទនានោះផង មិនសម្គាល់ ដោយវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។ បេ ។ មិនសម្គាល់នូវមនោ មិនសម្គាល់ក្នុងមនោ មិនសម្គាល់ដោយមនោ មិន សម្គាល់ថាមនោជារបស់អញ ។ មិនសម្គាល់នូវធម្មារម្មណ៍ទាំងឡាយ មិនសម្គាល់ក្នុងធម្មារម្មណ៍ទាំងឡាយ មិនសម្គាល់ដោយធម្មារម្មណ៍ មិន សម្គាល់ថាធម្មារម្មណ៍ទាំងឡាយជារបស់អញ ។ មិនសម្គាល់នូវមនោ-វិញ្ញាណ មិនសម្គាល់ក្នុងមនោវិញ្ញាណ មិនសម្គាល់ដោយមនោវិញ្ញាណ មិនសម្គាល់ថាមនោវិញ្ញាណជារបស់អញ ។ មិនសម្គាល់នូវមនោសម្ផស្ស

៤១

សព្វវគ្គោ តតិយោ

មនោសម្ផស្សស្មឹ ន មញ្ញតិ មនោសម្ផស្សតោ ន មញ្ញតិ មនោសម្ផស្សោ មេតិ ន មញ្ញតិ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ សព្វំ ន មញ្ញតិ សព្វស្មឹ ន មញ្ញតិ សព្វតោ ន មញ្ញតិ សព្វំ មេតិ ន មញ្ញតិ ។ សោ ឯវំ អមញ្ញមានោ ន ច កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ សា ភិក្ខវេ សព្វមញ្ញិតសមុគ្ឃាតសារុប្បា បដិបទាតិ ។ អដ្ឋមំ ។

សឡាយតនៈវគ្គ ទី ៣

មិនសម្គាល់ក្នុងមនោសម្ផស្ស មិនសម្គាល់ដោយមនោសម្ផស្ស មិនសំគាល់ថាមនោសម្ផស្សជារបស់អញ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ មិនសម្គាល់នូវវេទនានោះផង មិនសម្គាល់ក្នុងវេទនានោះផង មិនសម្គាល់ដោយវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។ មិនសម្គាល់នូវវត្ថុទាំងពួង មិនសម្គាល់ក្នុងវត្ថុទាំងពួង មិនសម្គាល់ដោយវត្ថុទាំងពួង មិនសម្គាល់ថាវត្ថុទាំងពួងជារបស់អញ ។ លុះភិក្ខុនោះ មិនសម្គាល់យ៉ាងនេះ ក៏មិនបានប្រកាន់ នូវវត្ថុអ្វីតិចតួចក្នុងលោក កាលបើមិនប្រកាន់ ក៏មិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រលត់ចំពោះខ្លួនឯង បានដឹងច្បាស់ថា ជាតិរបស់អញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថាបដិបទា ដ៏សមគួរដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ។ ចប់សូត្រ ទី ៨ ។

[៣៤] សព្វមញ្ញិតសមុគ្ឃាតសប្បាយំ វោ ភិក្ខវេ បដិបទំ ទេសិស្សាមិ តំ សុណាថ ។ កតមា ច សា ភិក្ខវេ សព្វមញ្ញិតសមុគ្ឃាតសប្បាយា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុំ ន មញ្ញតិ ចក្ខុស្មឹ ន មញ្ញតិ ចក្ខុតោ ន មញ្ញតិ ចក្ខុំ មេតិ ន មញ្ញតិ ។ រូបេ ន មញ្ញតិ ។ ចក្ខុវិញ្ញាណំ ន មញ្ញតិ ។ ចក្ខុសម្ផស្សំ ន មញ្ញតិ ។ យម្បិទំ ចក្ខុសម្ផស្សប្ប-ច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខម-សុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ យំ ហិ ភិក្ខវេ មញ្ញ-តិ យស្មឹ មញ្ញតិ យតោ មញ្ញតិ យំ មេតិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិនន្ទតិ ។ បេ ។ ជិវ្ហំ ន មញ្ញតិ

[៣៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវបដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវបដិបទានោះចុះ ។ ម្នាលភិក្ខុទាំង-ឡាយ បដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួងនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសម្គាល់នូវចក្ខុ មិនសម្គាល់ក្នុងចក្ខុ មិនសម្គាល់ដោយចក្ខុ មិនសម្គាល់ថាចក្ខុជារបស់អញ ។ មិនសម្គាល់នូវរូបទាំងឡាយ ។ មិនសម្គាល់នូវចក្ខុវិញ្ញាណ ។ មិនសម្គាល់នូវចក្ខុសម្ផស្ស ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនសម្គាល់នូវវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុសម្គាល់នូវអារម្មណ៍ណា សម្គាល់ក្នុងអារម្មណ៍ណា សម្គាល់ដោយអារម្មណ៍ណា សម្គាល់ថាអារម្មណ៍ណាជារបស់អញ អារម្មណ៍នោះ កើតឡើងព្រោះសេចក្តីសម្គាល់នោះ សត្វលោកដែលជាប់ក្នុងភព មានសេចក្តីប្រែប្រួលផ្សេង ៗ រមែងត្រេកអរនឹងភពប៉ុណ្ណោះឯង ។ បេ ។ មិនសម្គាល់នូវជិវ្ហា

៤៣

សព្វវគ្គោ តតិយោ

ជិវ្ហាយ ន មញ្ញតិ ជិវ្ហាតោ ន មញ្ញតិ ជិវ្ហា មេតិ ន មញ្ញតិ ។ រសេ ជិវ្ហាវិញ្ញាណំ ជិវ្ហាសម្ផស្សំ ន មញ្ញតិ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ យំ ហិ ភិក្ខវេ មញ្ញតិ យស្មឹ មញ្ញតិ យតោ មញ្ញតិ យំ មេតិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិនន្ទតិ ។ បេ ។ មនំ ន មញ្ញតិ មនស្មឹ ន មញ្ញតិ មនតោ ន មញ្ញតិ មនោ មេតិ ន មញ្ញតិ ធម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ ន មញ្ញតិ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។

សព្វវគ្គ ទី ៣

មិនសម្គាល់ក្នុងជិវ្ហា មិនសម្គាល់ដោយជិវ្ហា មិនសម្គាល់ថាជិវ្ហាជារបស់អញ ។ មិនសម្គាល់ នូវរសទាំងឡាយ នូវជិវ្ហាវិញ្ញាណ នូវជិវ្ហា-សម្ផស្ស ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ មិនសម្គាល់នូវវេទនានោះផង មិនសម្គាល់ក្នុងវេទនានោះផង មិនសម្គាល់ដោយវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុ សម្គាល់នូវអារម្មណ៍ណា សម្គាល់ក្នុងអារម្មណ៍ណា សម្គាល់ដោយអារម្មណ៍ណា សម្គាល់នូវអារម្មណ៍ណាថាជារបស់អញ អារម្មណ៍នោះ កើតឡើងព្រោះសេចក្តីសម្គាល់នោះ សត្វលោកដែលជាប់ក្នុងភពមានសេចក្តីប្រែប្រួលផ្សេង ៗ រមែងត្រេកអរនឹងភពប៉ុណ្ណោះឯង ។ បេ ។ មិនសម្គាល់នូវមនោ មិនសម្គាល់ក្នុងមនោ មិនសម្គាល់ដោយមនោ មិនសម្គាល់ថាមនោជារបស់អញ មិនសម្គាល់ នូវធម្មារម្មណ៍ នូវមនោ-វិញ្ញាណ នូវមនោសម្ផស្ស ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនសម្គាល់នូវវេទនានោះផង មិនសម្គាល់ក្នុងវេទនានោះផង មិនសំ-គាល់ដោយវេទនានោះផង មិនសម្គាល់ថាវេទនានោះជារបស់អញ ។

យំ ហិ ភិក្ខវេ មញ្ញតិ យស្មឹបិ មញ្ញតិ យតោ មញ្ញតិ យំ មេតិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិនន្ទតិ ។ យាវតា ភិក្ខវេ ខន្ធធាតុអាយតនំ តម្បិ ន មញ្ញតិ តស្មឹបិ ន មញ្ញតិ តតោបិ ន មញ្ញតិ តំ មេតិ ន មញ្ញតិ ។ សោ ឯវំ អមញ្ញមានោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ សា ភិក្ខវេ សព្វមញ្ញិតសមុគ្ឃាតសប្បាយា បដិបទាតិ ។ ទសមំ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុសម្គាល់នូវអារម្មណ៍ណា សម្គាល់ក្នុងអារម្មណ៍ណា សម្គាល់ដោយអារម្មណ៍ណា សម្គាល់ថាអារម្មណ៍ណាជារបស់អញ អារម្មណ៍នោះ កើតឡើងព្រោះសេចក្តីសម្គាល់នោះ សត្វលោកដែលជាប់ក្នុងភព មានសេចក្តីប្រែប្រួលផ្សេង ៗ រមែងត្រេកអរនឹងភពប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំងឡាយ ខន្ធ ធាតុ អាយតនៈ ទាំងប៉ុន្មាន ភិក្ខុ មិនសម្គាល់នូវខន្ធ ធាតុ អាយតនៈនោះផង មិនសម្គាល់ក្នុងខន្ធ ធាតុ អាយតនៈនោះផង មិនសម្គាល់ដោយខន្ធ ធាតុ អាយតនៈនោះផង មិនសម្គាល់ថាខន្ធ ធាតុ អាយតនៈនោះជារបស់អញ ។ កាលបើភិក្ខុនោះមិនសម្គាល់យ៉ាងនេះ ក៏មិនប្រកាន់នូវអារម្មណ៍តិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ ក៏មិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រលត់ចំពោះខ្លួនឯង រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថាបដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ។ ចប់សូត្រ ទី ៩ ។

៨៤

សព្វវគ្គោ តតិយោ

[៣៨] សព្វមញ្ញិតសមុគ្ឃាតសប្បាយំ វោ ភិក្ខវេ បដិបទំ ទេសិស្សាមិ តំ សុណាថ ។ កតមា ច សា ភិក្ខវេ សព្វមញ្ញិតសមុគ្ឃាតសប្បាយា បដិបទា ។ តំ កឹ មញ្ញថ ភិក្ខវេ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ រូបា ។ បេ ។ ចក្ខុ-វិញ្ញាណំ ។ ចក្ខុសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ បេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ

## សព្វវគ្គ ទី ៣

[៣៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវបដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវបដិបទានោះចុះ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួងនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែ-ប្រួលទៅជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ រូប ។ បេ ។ ចក្ខុវិញ្ញាណ ។ ចក្ខុសម្ផស្សទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង

ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ រសា ។ បេ ។ ជិវ្ហាវិញ្ញាណំ ។ ជិវ្ហាសម្ផស្សោ ។ បេ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ធម្មា មនោវិញ្ញាណំ មនោ-សម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហ-មស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ ប-ស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ

របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះ ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរនឹង យល់ឃើញដូច្នោះទេ ព្រះអង្គ ។ បេ ។ ជិវ្ហាទៀងឬមិនទៀង ។ មិន ទៀងទេ ព្រះអង្គ ។ រស ។ បេ ។ ជិវ្ហាវិញ្ញាណ ។ ជិវ្ហាសម្ផស្ស ។ បេ ។ ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផស្ស ទៀងឬ មិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ទោះបីវេទនាណាជាសុខក្តី ជា ទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិន ទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវ របស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ អរិយសាវ័កជាអ្នកចេះដឹងបានឃើញយ៉ាងនេះ ក៏នឿយណាយនឹងចក្ខុផង

៤៧



រូបេសុបិ ចក្ខុវិញ្ញាណេបិ ចក្ខុសម្ផស្សេបិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ ។ បេ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ មនោសម្ផស្សេបិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ

សព្វវគ្គ ទី ៣

នឹងរូបទាំងឡាយផង នឹងចក្ខុវិញ្ញាណផង នឹងចក្ខុសម្ផស្សផង ទោះបីវេទ-នាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះផង ។ បេ ។ ក៏នឿយណាយនឹងជិវ្ហាផង នឹងរសទាំងឡាយផង ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះផង ។ បេ ។ នឿយណាយនឹងមនោផង នឿយណាយនឹងធម្មារម្មណ៍ទាំងឡាយផង នឹងមនោវិញ្ញាណផង នឹងមនោសម្ផស្សផង ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ ក៏ប្រាសចាកតម្រេក ព្រោះការប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងប្រាកដថា ចិត្តផុតស្រឡះហើយ ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ

៥៨



កាតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ សា ភិក្ខវេ សព្វមញ្ញិតសមុគ្ឃាតសប្បាយា បដិបទាតិ ។ ទសមំ ។

សព្វវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សព្វញ្ច ទ្វេបិ បហានា
បរិជានា អបរេ ទុវេ
អាទិត្តំ អទ្ធភូតញ្ច
សារុប្បា ទ្វេ ច សប្បាយា
វគ្គោ តេន បវុច្ចតីតិ ។

សោឡសកិច្ចអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថាបដិបទា ជាទីសប្បាយដល់ការដកឡើងព្រមនូវសេចក្តីសម្គាល់វត្ថុទាំងពួង ។ ចប់សូត្រ ទី ១០ ។

ចប់ សព្វវគ្គ ទី ៣ ។

# ឧទ្ទាននៃសព្វវគ្គនោះ គឺ

និយាយអំពីវត្ថុទាំងពួង ១ អំពីការលះបង់មានពីរលើក អំពីការកំណត់ដឹងមានពីរលើកដទៃទៀត អំពីរបស់ក្តៅ ១ អំពីរបស់ខ្វាក់ ១ អំពីបដិបទាដ៏សមគួរ ១ អំពីបដិបទាជាទីសប្បាយមានពីរលើក ហេតុនោះ ទើបហៅថាវគ្គ ។

# ជាតិធម្មវគ្គោ

[៣៦] សាវត្ថិយំ ។ តត្រ ខោ សព្វំ ភិក្ខវេ ជាតិធម្មំ ។ កិញ្ច ភិក្ខវេ សព្វំ ជាតិធម្មំ ។ បេ ។ ចក្ខុំ ភិក្ខវេ ជាតិធម្មំ រូបា ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ ជាតិធម្មោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ជាតិធម្មំ ។ បេ ។ ជិវ្ហា រសា ជិវ្ហាវិញ្ញាណំ ជិវ្ហាសម្ផស្សោ ជាតិធម្មោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ជាតិធម្មំ ។ បេ ។ មនោ ជាតិធម្មោ ធម្មា ជាតិធម្មា មនោវិញ្ញាណំ ជាតិធម្មំ មនោសម្ផស្សោ ជាតិធម្មោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

# ជាតិធម្មវគ្គ

[៣៦] ក្នុងក្រុងសាវត្ថី ។ ក្នុងទីនោះឯង (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានជាតិគឺការកើតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានជាតិជាធម្មតា តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមានជាតិជាធម្មតា រូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស មានជាតិជាធម្មតា ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏មានជាតិជាធម្មតា ។ បេ ។ ជិវ្ហា រស ជិវ្ហាវិញ្ញាណ ជិវ្ហាសម្ផស្ស មានជាតិជាធម្មតា ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះមានជាតិជាធម្មតា ។ បេ ។ មនោមានជាតិជាធម្មតា ធម្មារម្មណ៍មានជាតិជាធម្មតា មនោវិញ្ញាណមានជាតិជាធម្មតា មនោសម្ផស្សមានជាតិជាធម្មតា ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ

តម្បិ ជាតិធម្មំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ ចក្ខុសម្ផស្សេបិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[៣៧] សព្វំ ភិក្ខវេ ជរាធម្មំ ។

[៣៨] សព្វំ ភិក្ខវេ ព្យាធិធម្មំ ។ ឯវំ បស្សំ ភិក្ខវេ ។

[៣៩] សព្វំ ភិក្ខវេ មរណធម្មំ ។

[៤០] សព្វំ ភិក្ខវេ សោកធម្មំ ។

[៤១] សព្វំ ភិក្ខវេ សង្កិលេសធម្មំ ។

វេទនានោះក៏មានជាតិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កជាអ្នកចេះដឹង បានឃើញយ៉ាងនេះ ក៏នឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបទាំងឡាយផង នឹងចក្ខុវិញ្ញាណផង នឹងចក្ខុសម្ផស្សផង ។ (អរិយសាវ័កនោះ) ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៣៧] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានជរាជាធម្មតា ។

[៣៨] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានព្យាធិជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កបានឃើញយ៉ាងនេះ ។

[៣៩] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានមរណៈជាធម្មតា ។

[៤០] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានសេចក្តីសោកជាធម្មតា ។

[៤១] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានសេចក្តីសៅហ្មងជាធម្មតា ។

ជាតិធម្មវគ្គោ ចតុត្ថោ

[៤២] សង្ខិត្តំ សព្វំ ភិក្ខវេ ខយធម្មំ ។

[៤៣] សង្ខិត្តំ សព្វំ ភិក្ខវេ វយធម្មំ ។

[៤៤] សង្ខិត្តំ សព្វំ ភិក្ខវេ សមុទយធម្មំ ។

[៤៥] សង្ខិត្តំ សព្វំ ភិក្ខវេ និរោធធម្មំ ។ កិញ្ច ភិក្ខវេ សព្វំ និរោធធម្មំ ចក្ខុំ ភិក្ខវេ និរោធធម្មំ រូបា និរោធធម្មា ចក្ខុវិញ្ញាណំ និរោធធម្មំ ចក្ខុសម្ផស្សោ និរោធធម្មោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និរោធធម្មំ ។ បេ ។ ជិវ្ហា និរោធធម្មា រសា និរោធធម្មា ជិវ្ហាវិញ្ញាណំ និរោធធម្មំ ជិវ្ហាសម្ផស្សោ និរោធធម្មោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និរោធធម្មំ

ជាតិធម្មវគ្គ ទី ៥

[៤២] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានកិរិយាអស់ទៅជាធម្មតា ។

[៤៣] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានកិរិយាសូន្យទៅជាធម្មតា ។

[៤៤] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានការប្រជុំកើតឡើងជាធម្មតា ។

[៤៥] សេចក្តីសង្ខេប ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានការរលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងមានការរលត់ជាធម្មតា តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុមានការរលត់ជាធម្មតា រូបមានការរលត់ជាធម្មតា ចក្ខុវិញ្ញាណមានការរលត់ជាធម្មតា ចក្ខុសម្ផស្សមានការរលត់ជាធម្មតា ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏មានការរលត់ជាធម្មតា ។ បេ ។ ជិវ្ហាមានការរលត់ជាធម្មតា រសមានការរលត់ជាធម្មតា ជិវ្ហាវិញ្ញាណមានការរលត់ជាធម្មតា ជិវ្ហាសម្ផស្សមានការរលត់ជាធម្មតា ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះមានការរលត់ជាធម្មតា

។ បេ ។ មនោ និរោធធម្មោ ធម្មា និរោធធម្មា មនោ-
វិញ្ញាណំ និរោធធម្មំ មនោសម្ផស្សោ និរោធធម្មោ
យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុ-
ខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និរោធធម្មំ ។
ឯវំ បស្សំ ភិក្ខវេ សុតវា អរិយស្សាវកោ ចក្ខុស្មឹបិ
និព្វិន្ទតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ជាតិធម្មវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

ជាតិជរាព្យាធិមរណំ
សោកា ច សង្កិលេសា ច
ខយធម្មញ្ច[១] វយធម្មញ្ច សមុទយធម្មំ
និរោធធម្មេន តេ ទសាតិ ។

---

១ ម. ជាតិ... សោកា ច សង្កិលេសិកំ ខយវយសមុទយំ...តិ ។ ឱ. សង្កិលេសោ ច ។

ៗ បេ ៗ មនោមានការរលត់ជាធម្មតា ធម្មារម្មណ៍មានការរលត់ជាធម្មតា មនោវិញ្ញាណមានការរលត់ជាធម្មតា មនោសម្ផស្សមានការរលត់ជាធម្មតា ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏មានការរលត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក ជាអ្នកចេះដឹងបានយល់ឃើញយ៉ាងនេះ ក៏នឿយណាយនឹងចក្ខុផង ៗ បេ ៗ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ចប់ ជាតិធម្មវគ្គ ទី ៤ ។

## ឧទ្ទាននៃជាតិធម្មវគ្គនោះ គឺ

និយាយអំពីធម៌ ១០ យ៉ាងនោះ គឺជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ សោក ១ សង្កិលេស ១ ខយធម៌ ១ វយធម៌ ១ សមុទយធម៌ ១ និរោធធម៌ ១ ។

---

# អនិច្ចវគ្គោ

[៤៦] សាវត្ថិយំ ។ តត្រ ខោ ។ សព្វំ ភិក្ខវេ អនិច្ចំ ។ កិញ្ច ភិក្ខវេ សព្វំ អនិច្ចំ ចក្ខុំ ភិក្ខវេ អនិច្ចំ រូបា អនិច្ចា ចក្ខុវិញ្ញាណំ អនិច្ចំ ចក្ខុសម្ផស្សោ អនិច្ចោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេ-ទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ ។ បេ ។ ជិវ្ហា អនិច្ចា រសា អនិច្ចា ជិវ្ហាវិញ្ញាណំ អនិច្ចំ ជិវ្ហាសម្ផស្សោ អនិច្ចោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ ។ បេ ។ មនោ អនិច្ចោ ធម្មា អនិច្ចា មនោវិញ្ញាណំ អនិច្ចំ មនោសម្ផស្សោ អនិច្ចោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

# អនិច្ចវគ្គ

[៤៦] ក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់មិនទៀង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀង រូបមិនទៀង ចក្ខុវិញ្ញាណមិនទៀង ចក្ខុសម្ផស្សមិនទៀង ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏មិនទៀង ។ បេ ។ ជិវ្ហាមិនទៀង រសមិនទៀង ជិវ្ហា-វិញ្ញាណមិនទៀង ជិវ្ហាសម្ផស្សមិនទៀង ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះក៏មិនទៀង ។ បេ ។ មនោមិនទៀង ធម៌មិនទៀង មនោវិញ្ញាណមិនទៀង មនោសម្ផស្សមិនទៀង ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ វេទនានោះក៏មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយក្នុងចក្ខុផង ។ បេ ។ រមែងដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៤៧] សព្វំ ភិក្ខវេ ទុក្ខំ ។

[៤៨] សព្វំ ភិក្ខវេ អនត្តា ។

[៤៩] សព្វំ ភិក្ខវេ អភិញ្ញេយ្យំ ។

[៥០] សព្វំ ភិក្ខវេ បរិញ្ញេយ្យំ ។

[៥១] សព្វំ ភិក្ខវេ បហាតព្វំ ។

[៥២] សព្វំ ភិក្ខវេ សច្ឆិកាតព្វំ ។

[៥៣] សព្វំ ភិក្ខវេ អភិញ្ញា បរិញ្ញេយ្យំ ។

[៥៤] សព្វំ ភិក្ខវេ ឧបទ្ទុតំ ។

[៥៥] សព្វំ ភិក្ខវេ ឧបស្សដ្ឋំ ។ កិញ្ច ភិក្ខវេ សព្វំ ឧបស្សដ្ឋំ ចក្ខុំ ភិក្ខវេ ឧបស្សដ្ឋំ រូបា ឧបស្សដ្ឋា ចក្ខុវិញ្ញាណំ ឧបស្សដ្ឋំ ចក្ខុសម្ផស្សោ ឧបស្សដ្ឋោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ឧបស្សដ្ឋំ ។ បេ ។

[៤៧] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ជាទុក្ខ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់មិនមែនជារបស់ខ្លួន ។

[៤៩] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់បុគ្គលត្រូវដឹងជាក់ ។

[៥០] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់បុគ្គលត្រូវកំណត់ដឹង ។

[៥១] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់បុគ្គលត្រូវតែលះបង់ ។

[៥២] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ។

[៥៣] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ បុគ្គលត្រូវកំណត់ដឹង ដោយប្រាជ្ញាដ៏ក្រៃលែង ។

[៥៤] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ មានទោសជាគ្រឿងបៀតបៀន ។

[៥៥] ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ជាគ្រឿងអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ ជាគ្រឿងអន្តរាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុ ជាគ្រឿងអន្តរាយ រូប ជាគ្រឿងអន្តរាយ ចក្ខុវិញ្ញាណ ជាគ្រឿងអន្តរាយ ចក្ខុសម្ផស្ស ជាគ្រឿងអន្តរាយ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏ជាគ្រឿងអន្តរាយ ។ បេ ។

៦៨

អនិច្ចវគ្គោ បញ្ចមោ

ជិវ្ហា ឧបស្សដ្ឋា រសា ឧបស្សដ្ឋា ជិវ្ហាវិញ្ញាណំ ឧបស្សដ្ឋំ ជិវ្ហាសម្ផស្សោ ឧបស្សដ្ឋោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ឧបស្សដ្ឋំ ។ មនោ ឧបស្សដ្ឋោ ធម្មា ឧបស្សដ្ឋា មនោវិញ្ញាណំ ឧបស្សដ្ឋំ មនោសម្ផស្សោ ឧបស្សដ្ឋោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ឧបស្សដ្ឋំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិ-ន្ទតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

អនិច្ចវគ្គោ បញ្ចមោ ។

អនិច្ចវគ្គ ទី ៥

ជិវ្ហា ជាគ្រឿងអន្តរាយ រស ជាគ្រឿងអន្តរាយ ជិវ្ហាវិញ្ញាណ ជាគ្រឿងអន្តរាយ ជិវ្ហាសម្ផស្ស ជាគ្រឿងអន្តរាយ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះក៏ជាគ្រឿងអន្តរាយ ។ ចិត្តជាគ្រឿងអន្តរាយ ធម៌ជាគ្រឿងអន្តរាយ មនោវិញ្ញាណ ជាគ្រឿងអន្តរាយ មនោសម្ផស្ស ជាគ្រឿងអន្តរាយ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះ ក៏ជាគ្រឿងអន្តរាយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក អ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ចប់ អនិច្ចវគ្គ ទី ៥ ។

## តស្សុទ្ទានំ

អនិច្ចំ ទុក្ខំ អនត្តា
អភិញ្ញេយ្យំ បរិញ្ញេយ្យំ
បហាតព្វំ សច្ឆិកាតព្វំ
អភិញ្ញេយ្យំ[១] បរិញ្ញេយ្យំ
ឧបទ្ទុតំ ឧបស្សដ្ឋំ
វគ្គោ តេន បវុច្ចតីតិ ។

សឡាយតនវគ្គេ បណ្ណាសកំ បឋមំ ។

## តស្សុទ្ទានំ

សុទ្ធវគ្គោ យមកោ ច
សព្វវគ្គជរានិ ច[២]
អនិច្ចវគ្គោ បញ្ញាសំ
បញ្ចមោ តេន បវុច្ចតីតិ ។

១ ឱ. ម. អភិញ្ញាតំ ។ ២ សុទ្ធវគ្គញ្ច នោ ចេតំ សព្វំ វគ្គំ ជនានិ ច ។ ម. សព្វំ វគ្គំ ជាតិធម្មំ ។

## ឧទ្ទាននៃអនិច្ចវគ្គនោះ គឺ

និយាយអំពីរបស់ មិនទៀង ១ ជាទុក្ខ ១ មិនមែនជារបស់ខ្លួន ១ ត្រូវដឹងជាក់ ១ ត្រូវកំណត់ដឹង ១ ត្រូវតែលះបង់ ១ ត្រូវធ្វើឲ្យជាក់ច្បាស់ ១ ត្រូវកំណត់ដឹងដោយប្រាជ្ញាដ៏ក្រៃលែង ១ ជាគ្រឿងបៀតបៀន ១ ជាគ្រឿងអន្តរាយ ១ ហេតុនោះ ទើបលោកចាត់ជា ១ វគ្គ ។

ចប់ បឋមបណ្ណាសកៈក្នុងសឡាយតនវគ្គ ។

## ឧទ្ទាននៃបឋមបណ្ណាសកៈនោះ គឺ

សុទ្ធវគ្គ ១ យមកវគ្គ ១ សព្វវគ្គ ១ ជរាវគ្គ ១ អនិច្ចវគ្គជាគម្រប់ប្រាំ ១ លោកចាត់ជាមួយបណ្ណាសកៈ តាមសឡាយ-តនវគ្គនោះ ។

# ទុតិយបណ្ណាសកំ

## អវិជ្ជាវគ្គោ

[៤៦] សាវត្ថិយំ ។ បេ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតីតិ ។ ចក្ខុំ ខោ ភិក្ខុ អនិច្ចតោ ជានតោ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ រូបេ អនិច្ចតោ ជានតោ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សំ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចតោ ជានតោ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ ។ សោតំ ឃានំ ជិវ្ហំ កាយំ មនំ អនិច្ចតោ ជានតោ បស្សតោ អវិជ្ជា បហីយតិ

# ទុតិយបណ្ណាសកៈ

## អវិជ្ជាវគ្គ

[៥៦] ក្រុងសាវត្ថី ។ បេ ។ គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្ដេច ឃើញដូចម្ដេច ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ម្នាលភិក្ខុ បុគ្គលកាលដឹង កាលឃើញ នូវភ្នែកថាមិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង កាលដឹង កាលឃើញ នូវរូបថាមិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង កាលដឹង កាលឃើញ នូវចក្ខុវិញ្ញាណ នូវចក្ខុសម្ផស្ស នូវវេទនាទោះជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ថាមិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ កាលដឹង កាលឃើញ នូវត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ថាមិនទៀង ទើបលះបង់អវិជ្ជាបាន

វិជ្ជា ឧប្បជ្ជតិ ជម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ យម្បិ-
ទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា
ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចតោ ជានតោ
បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ ។ ឯវំ ខោ
ភិក្ខុ ជានតោ ឯវំ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា
ឧប្បជ្ជតីតិ ។ បឋមំ ។

[៤៧] កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ
សញ្ញោជនា បហីយន្តីតិ ។ ចក្ខុំ ខោ ភិក្ខវេ[១] អ-
និច្ចតោ ជានតោ បស្សតោ សញ្ញោជនា បហីយន្តិ រូបេ
អនិច្ចតោ ជានតោ បស្សតោ សញ្ញោជនា បហីយន្តិ
ចក្ខុវិញ្ញាណំ អនិច្ចតោ ជានតោ បស្សតោ សញ្ញោ-
ជនា បហីយន្តិ ចក្ខុសម្ផស្សំ អនិច្ចតោ ជានតោ
បស្សតោ សញ្ញោជនា បហីយន្តិ ។ បេ ។ យម្បិទំ
មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា
ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចតោ ជានតោ
បស្សតោ សញ្ញោជនា បហីយន្តិ ។ ឯវំ ខោ ភិក្ខវេ

១ ឱ. ម. ភិក្ខុ ។

វិជ្ជាក៏កើតឡើង កាលដឹង កាលឃើញ នូវធម៌ នូវមនោវិញ្ញាណ នូវមនោសម្ផស្ស នូវវេទនា ទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ថាមិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ម្នាលភិក្ខុ បុគ្គលកាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។

ចប់សូត្រ ទី ១ ។

[៥៧] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលកាលដឹងដូចម្តេច កាលឃើញដូចម្តេច ទើបលះបង់សញ្ញោជនៈបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង កាលឃើញ នូវភ្នែកថាមិនទៀង ទើបលះបង់សញ្ញោជនៈបាន កាលដឹង កាលឃើញ នូវរូបថាមិនទៀង ទើបលះបង់សញ្ញោជនៈបាន កាលដឹង កាលឃើញ នូវចក្ខុវិញ្ញាណថាមិនទៀង ទើបលះបង់សញ្ញោ-ជនៈបាន កាលដឹង កាលឃើញ នូវចក្ខុសម្ផស្សថាមិនទៀង ទើបលះបង់សញ្ញោជនៈបាន ។ បេ ។ បុគ្គលកាលដឹង កាលឃើញនូវវេទនាទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ថាមិនទៀង ទើបលះបង់សញ្ញោជនៈបាន ។ ម្នាលភិក្ខុទាំងឡាយ

ជានតោ ឯវំ បស្សតោ សញ្ញោជនា បហីយន្តីតិ ។ ទុតិយំ ។

[៤៨] កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ សញ្ញោជនា សមុគ្ឃាតំ គច្ឆន្តីតិ ។ ចក្ខុំ ខោ ភិក្ខវេ អនត្តតោ ជានតោ បស្សតោ សញ្ញោជនា សមុគ្ឃាតំ គច្ឆន្តិ រូបេ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សំ យម្បិទំ ចក្ខុ-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តតោ ជានតោ បស្សតោ សញ្ញោជនា សមុគ្ឃាតំ គច្ឆន្តិ ។ សោតំ ឃានំ ជិវ្ហំ កាយំ មនំ ធម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តតោ ជានតោ បស្សតោ សញ្ញោជនា សមុគ្ឃាតំ គច្ឆន្តិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ សញ្ញោជនា សមុគ្ឃាតំ គច្ឆន្តីតិ ។ តតិយំ ។

[៤៩] កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ អាសវា បហីយន្តីតិ ។ បេ ។ ចតុត្ថំ ។

បុគ្គលកាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ទើបលះបង់សញ្ញោជនៈបាន ។ ចប់សូត្រ ទី ២ ។

[៥៨] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលកាលដឹងដូចម្តេច កាលឃើញដូចម្តេច ទើបសញ្ញោជនៈរលើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹង កាលឃើញ នូវភ្នែកថាមិនមែនជារបស់ខ្លួន ទើបសញ្ញោជនៈរលើងទៅបាន កាលដឹង កាលឃើញ នូវរូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស នូវវេទនាទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ថាមិនមែនជារបស់ខ្លួន ទើបសញ្ញោជនៈរលើងទៅបាន ។ បុគ្គលកាលដឹង កាលឃើញ នូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ធម៌ មនោវិញ្ញាណ មនោសម្ផស្ស នូវវេទនាទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ថាមិនមែនជារបស់ខ្លួន ទើបសញ្ញោជនៈរលើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ទើបសញ្ញោជនៈរលើងទៅបាន ។ ចប់សូត្រ ទី ៣ ។

[៥៩] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលកាលដឹងដូចម្តេច កាលឃើញដូចម្តេច ទើបលះបង់អាសវៈបាន ។ បេ ។ ចប់សូត្រ ទី ៤ ។

[៦០] ។ បេ ។ អាសវា សមុគ្ឃាតំ គច្ឆន្តីតិ ។ បេ ។ បញ្ចមំ ។

[៦១] ។ បេ ។ អនុសយា បហីយន្តីតិ ។ បេ ។ ឆដ្ឋំ ។

[៦២] ។ បេ ។ អនុសយា សមុគ្ឃាតំ គច្ឆន្តីតិ ។ ចក្ខុំ ខោ ភិក្ខវេ អនត្តតោ ជានតោ បស្សតោ អនុ-សយា សមុគ្ឃាតំ គច្ឆន្តិ ។ បេ ។ សោតំ ឃានំ ជិវ្ហំ កាយំ មនំ ធម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តតោ ជានតោ បស្សតោ អនុសយា សមុគ្ឃាតំ គច្ឆន្តិ ។ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អនុសយា សមុគ្ឃាតំ គច្ឆន្តីតិ ។ សត្តមំ ។

[៦០] ។ បេ ។ ទើបអាសវៈរលើងទៅបាន ។ បេ ។ ចប់សូត្រ ទី ៥ ។

[៦១] ។ បេ ។ ទើបលះបង់អនុស័យបាន ។ បេ ។ ចប់សូត្រ ទី ៦ ។

[៦២] ។ បេ ។ ទើបអនុស័យរលើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង កាលឃើញ នូវភ្នែកថាមិនមែនជារបស់ខ្លួន ទើបអនុស័យរលើងទៅបាន ។ បេ ។ កាលដឹង កាលឃើញ នូវត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ធម៌ មនោវិញ្ញាណ មនោសម្ផស្ស នូវវេទនា ទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ថាមិនមែនជារបស់ខ្លួន ទើបអនុស័យរលើងទៅបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ទើបអនុស័យរលើងទៅបាន ។ ចប់សូត្រ ទី ៧ ។

៧១

## អវិជ្ជាវគ្គោ បឋមោ

[៦៣] សព្វុបាទានបរិញ្ញាយ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ សព្វុបាទានបរិញ្ញាយ ធម្មោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមោក្ខបរិញ្ញាតំ មេ ឧបាទានន្តិ បជានាតិ ។ សោតញ្ច បដិច្ច សទ្ទេ ច ។ ឃានញ្ច បដិច្ច គន្ធេ ច ។ ជិវ្ហញ្ច បដិច្ច រសេ ច ។ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ

អវិជ្ជាវគ្គ ទី ១

[៦៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវឧបាទានទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដូចម្តេចដែលប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវឧបាទានទាំងពួង ។ ព្រោះអាស្រ័យចក្ខុនិងរូប ទើបចក្ខុវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ (នេះ) ហៅថា ផស្សៈ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង នឿយណាយនឹងវេទនាផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តទើបរួចស្រឡះ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ឧបាទានអាត្មាអញបានកំណត់ដឹងហើយ ព្រោះការរួចស្រឡះ ។ ព្រោះអាស្រ័យត្រចៀកនិងសំឡេង ។ ព្រោះអាស្រ័យច្រមុះនិងក្លិន ។ ព្រោះអាស្រ័យចិត្តនិងធម៌ ទើបមនោវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ ហៅថា ផស្សៈ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ

មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមោក្ខបរិញ្ញាតំ មេ ឧបា-ទានន្តិ បជានាតិ ។ អយំ ខោ ភិក្ខវេ សព្វុបាទាន-បរិញ្ញាយ ធម្មោតិ ។ អដ្ឋមំ ។

[៦៤] សព្វុបាទានបរិយាទានាយ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ សព្វុបាទានបរិយាទានាយ ធម្មោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ

រមែងនឿយណាយនឹងចិត្តផង នឿយណាយនឹងធម៌ផង នឿយណាយនឹងមនោវិញ្ញាណផង នឿយណាយនឹងមនោសម្ផស្សផង នឿយណាយនឹងវេទនាផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែការប្រាសចាកតម្រេក ចិត្តទើបរួចស្រឡះ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ឧបាទានអាត្មាអញបានកំណត់ដឹងហើយ ព្រោះការរួចស្រឡះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ធម៌ប្រព្រឹត្តទៅដើម្បីកំណត់ដឹងនូវឧបាទានទាំងពួង ។ ចប់សូត្រ ទី ៨ ។

[៦៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលប្រព្រឹត្តទៅ ដើម្បីគ្របសង្កត់នូវឧបាទានទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំង-ឡាយ ចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដូចម្តេចដែលប្រព្រឹត្តទៅ ដើម្បីគ្របសង្កត់នូវឧបាទានទាំងពួង ។ ព្រោះអាស្រ័យចក្ខុនិងរូប ទើបចក្ខុវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ អរិយ-សាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង

៧៣

អវិជ្ជាវគ្គោ បឋមោ

រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុ-សម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមោក្ខបរិយាទិន្នំ មេ ឧបាទានន្តិ ប-ជានាតិ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមោក្ខបរិយាទិន្នំ មេ ឧបាទានន្តិ បជានាតិ ។ អយំ ខោ ភិក្ខវេ សព្វុបា-ទានបរិយាទាយ ធម្មោតិ ។ នវមំ ។

នឿយណាយនឹងរូបទាំងឡាយផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង នឿយណាយនឹងវេទនាផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តទើបរួចស្រឡះ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ឧបាទានអាត្មាអញបានគ្រប់សង្កត់ហើយ ព្រោះការរួចស្រឡះ ។ បេ ។ ព្រោះអាស្រ័យអណ្តាតនិងរស ទើបជិវ្ហាវិញ្ញាណកើតឡើង ។ បេ ។ ព្រោះអាស្រ័យចិត្តនិងធម៌ ទើបមនោវិញ្ញាណកើតឡើង ប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយអរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចិត្តផង នឿយណាយនឹងធម៌ផង នឿយណាយនឹងមនោវិញ្ញាណផង នឿយណាយនឹងមនោសម្ផស្សផង នឿយណាយនឹងវេទនាផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តទើបរួចស្រឡះ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ឧបាទានអា-ត្មាអញបានគ្រប់សង្កត់ហើយ ព្រោះការរួចស្រឡះ ។ ម្នាលភិក្ខុទាំង-ឡាយ នេះឯង ជាធម៌ប្រព្រឹត្តទៅ ដើម្បីគ្រប់សង្កត់នូវឧបាទានទាំង-ពួង ។ ចប់សូត្រ ទី ៩ ។

[៦៨] សព្វុបាទានបរិយាទានាយ វោ ភិក្ខវេ ធម្មំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ សព្វុបាទានបរិយាទានាយ ធម្មោ ។ តំ កឹ មញ្ញថ ភិក្ខវេ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ រូបា ។ បេ ។ ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ ចក្ខុសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ ធម្មា មនោវិញ្ញាណំ មនោសម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។

[៦៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ដែលប្រព្រឹត្តទៅដើម្បីគ្របសង្កត់នូវឧបាទានទាំងពួង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដូចម្តេច ដែលប្រព្រឹត្តទៅ ដើម្បីគ្របសង្កត់នូវឧបាទានទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវសេចក្តីនោះដូចម្តេច ភ្នែកទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដូច្នេះ ដែរឬ ។ មិនគួរនឹងយល់ដូច្នោះទេ ព្រះអង្គ ។ រូប ។ បេ ។ ចក្ខុ-វិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចក្ខុសម្ផស្សទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះវេទនាណា ទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ធម៌ មនោវិញ្ញាណ មនោ-សម្ផស្ស វេទនាណាទោះជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។

៧៤

## អវិជ្ជាវគ្គោ បឋមោ

អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាម-ធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯ-សោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញា-ណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ជិវ្ហាវិញ្ញា-ណេបិ ជិវ្ហាសម្ផស្សេបិ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ច-យា ឧប្បជ្ជតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ

មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ទោះវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏រមែងនឿយណាយនឹងវេទនានោះផង ។ បេ ។ រមែងនឿយណាយនឹងអណ្តាតផង នឿយណាយនឹងរសផង នឿយណាយនឹងជិវ្ហាវិញ្ញាណផង នឿយណាយនឹងជិវ្ហាសម្ផស្សផង វេទនាណា កើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។ បេ ។ រមែងនឿយណាយនឹងចិត្តផង នឿយណាយនឹងធម៌ផង នឿយណាយនឹងមនោវិញ្ញាណផង នឿយណាយនឹងមនោសម្ផស្សផង

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ ភិក្ខវេ សព្វុបាទានបរិយាទានាយ ធម្មោតិ ។ ទសមំ ។

អវិជ្ជាវគ្គោ បឋមោ ។

## តស្សុទ្ទានំ

អវិជ្ជា សញ្ញោជនា ទ្វេ
អាសវេន ទ្វេ វុត្តា
អនុសយា អបរេ ទ្វេ
បរិញ្ញា ទ្វេ បរិយាទិន្នា[១]
វគ្គោ តេន បវុច្ចតីតិ ។

១ ឱ. ម. បរិយាទិន្នំ ។

*ទោះវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏រមែងនឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ចិត្តទើបរួចស្រឡះ ។ កាលបើចិត្ត រួចស្រឡះហើយ ញាណ ក៏កើតឡើងថា ចិត្ត (របស់អាត្មាអញ) រួចស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាធម៌ប្រព្រឹត្តទៅដើម្បីគ្របសង្កត់នូវឧបាទានទាំងពួង ។ ចប់សូត្រ ទី ១០ ។*

ចប់ អវិជ្ជាវគ្គ ទី ១ ។

## ឧទ្ទាននៃអវិជ្ជាវគ្គនោះ គឺ

*និយាយអំពីអវិជ្ជា ១ សញ្ញោជនៈពីរលើក អាសវៈពីរលើក*
*អនុស័យពីរលើក ការកំណត់ដឹង ១ ធម៌គ្របសង្កត់ពីរលើក*
*ហេតុនោះ ទើបលោកចាត់ជាមួយវគ្គ ។*

# មិគជាលវគ្គោ

[៦៦] សាវត្ថីនិទានំ ។ អថខោ អាយស្មា មិគជាលោ យេន ភគវា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មិគជាលោ ភគវន្តំ ឯតទវោច ឯកវិហារី ឯកវិហារីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ឯកវិហារី ហោតិ កិត្តាវតា ច បន សទុតិយវិហារី ហោតីតិ ។ សន្តិ ខោ មិគជាល ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិយា សតិ សារាគោ ហោតិ សារាគេ សតិ

# មិគជាលវគ្គ

[៦៦] និទានក្នុងក្រុងសាវត្ថី ។ គ្រានោះ ព្រះមិគជាលៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះមិគជាលៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា បុគ្គលមានប្រក្រតីនៅម្នាក់ឯង មានប្រក្រតីនៅម្នាក់ឯងដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ចុះបុគ្គលមានប្រក្រតីនៅម្នាក់ឯង តើដោយហេតុដូចម្ដេច ចំណែកបុគ្គលមានប្រក្រតីនៅរួមគ្នាជាគម្រប់ពីរ តើដោយហេតុដូចម្ដេច ។ ម្នាលមិគជាលៈ មានរូបទាំងឡាយ ដែលបុគ្គលគប្បីដឹងច្បាស់ ដោយភ្នែក ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តចំពោះរូបនោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តចំពោះរូបនោះ សេចក្ដីត្រេកត្រអាល រមែងកើតឡើង កាលបើមានសេចក្ដីត្រេកត្រអាល សេចក្ដីប្រាថ្នាក៏មាន កាលបើមានសេចក្ដីប្រាថ្នា

សញ្ញោគោ ហោតិ ។ នន្ទិសញ្ញោជនសំយុត្តោ ខោ មិគជាល ភិក្ខុ សទុតិយវិហារីតិ វុច្ចតិ ។ បេ ។ សន្តិ ខោ មិគជាល ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិយា សតិ សារាគោ ហោតិ សារាគេ សតិ សញ្ញោគោ ហោតិ ។ នន្ទិសញ្ញោជនសំយុត្តោ ខោ មិគជាល ភិក្ខុ សទុតិយវិហារីតិ វុច្ចតិ ។ ឯវំ វិហារី ច មិគជាល ភិក្ខុ កិញ្ចាបិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ អថខោ សទុតិយវិហារីតិ វុច្ចតិ ។

សំយោជនៈក៏មាន ។ ម្នាលមិគជាលៈ ភិក្ខុដែលជាប់ចំពាក់ដោយចំណង គឺសេចក្តីត្រេកត្រអាលហ្នឹងឯង ហៅថាអ្នកមានប្រក្រតីនៅរួមគ្នាជាគម្រប់ពីរ ។ បេ ។ ម្នាលមិគជាលៈ មានរសដែលត្រូវដឹងដោយអណ្តាត ។ បេ ។ មានធម្មារម្មណ៍ ដែលត្រូវដឹងច្បាស់ដោយចិត្ត ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តចំពោះធម៌នោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តចំពោះធម៌នោះ សេចក្តីត្រេកត្រអាល រមែងកើតឡើង កាលបើមានសេចក្តីត្រេកត្រអាល សេចក្តីប្រាថ្នាក៏មាន កាលបើសេចក្តីប្រាថ្នាមាន សំយោជនៈក៏មាន ។ ម្នាលមិគជាលៈ ភិក្ខុដែលជាប់ចំពាក់ដោយចំណងគឺសេចក្តីត្រេកត្រអាលហ្នឹងឯង ហៅថាអ្នកមានប្រក្រតីនៅរួមគ្នាជាគម្រប់ពីរ ។ ម្នាលមិគជាលៈ ភិក្ខុ ដែលមានធម៌ជាគ្រឿងនៅយ៉ាងនេះ ទុកជានៅក្នុងទីសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃតូចព្រៃធំ ជាកន្ទែងមានសំឡេងតិច មានសន្ទឹកគឹកកងតិច មិនមានខ្យល់ គួរដល់អំពើស្ងាត់កំបាំងរបស់មនុស្ស គួរដល់ការពួនសម្ងំក៏ដោយ ក៏នៅតែហៅថា អ្នកមានប្រក្រតីនៅរួមគ្នាជាគម្រប់ពីរ ។

តំ កិស្ស ហេតុ ។ តណ្ហា ហិស្ស ទុតិយា សាស្ស អប្បហីនា តស្មា សទុតិយវិហារីតិ វុច្ចតិ ។

[៦៧] សន្តិ ច ខោ មិគជាល ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោ-សាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អ-នជ្ឈោសាយ តិដ្ឋតោ នន្ទិ និរុជ្ឈតិ នន្ទិយា អសតិ សារាគោ ន ហោតិ សារាគេ អសតិ សញ្ញោគោ ន ហោតិ ។ នន្ទិសញ្ញោជនវិសំយុត្តោ ខោ មិគជាល ភិក្ខុ ឯកវិហារីតិ វុច្ចតិ ។ បេ ។ សន្តិ ខោ មិគជាល ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ មិគជាល មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា

ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា ភិក្ខុនោះមានតណ្ហា ជាគម្រប់ពីរ ឯតណ្ហានោះឯង ភិក្ខុនោះមិនបានលះបង់ហើយ ព្រោះហេតុនោះ បានជាហៅថា អ្នកមានប្រក្រតីនៅរួមគ្នាជាគម្រប់ពីរ ។

[៦៧] ម្នាលមិគជាលៈ មានរូបដែលត្រូវដឹងច្បាស់ដោយភ្នែក ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តចំពោះរូបនោះទេ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្ត ចំពោះរូបនោះ សេចក្ដីត្រេកត្រអាលក៏រលត់ទៅ កាលបើមិនមានសេចក្ដីត្រេកត្រអាល សេចក្ដីប្រាថ្នាក៏មិនមាន កាលបើមិនមានសេចក្ដីប្រាថ្នា សំយោជនៈក៏មិនមាន ។ ម្នាលមិគជាលៈ ភិក្ខុដែលរួចចាកចំណងគឺសេចក្ដីត្រេកត្រអាលហ្នឹងឯង ហៅថាអ្នកមានប្រក្រតីនៅម្នាក់ឯង ។ បេ ។ ម្នាលមិគជាលៈ មានរសដែលត្រូវដឹងច្បាស់ដោយអណ្ដាត ។ បេ ។ ម្នាលមិគជាលៈ មានធម្មារម្មណ៍ ដែលត្រូវដឹងច្បាស់ដោយចិត្ត ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់

កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ នន្ទី និរុជ្ឈតិ នន្ទិយា អសតិ សារាគោ ន ហោតិ សារាគេ អសតិ សញ្ញោគោ ន ហោតិ ។ នន្ទិសញ្ញោជនវិសំយុត្តោ[១] ខោ មិគជាល ភិក្ខុ ឯកវិហារីតិ វុច្ចតិ ។ ឯកវិហារី ច មិគជាល ភិក្ខុ កិញ្ចាបិ គាមន្តេ វិហរតិ អាកិណ្ណោ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ អថខោ ឯកវិហារីតិ វុច្ចតីតិ ។ តំ កិស្ស ហេតុ ។ តណ្ហា ហិស្ស ទុតិយា សាស្ស[២] បហីនា តស្មា ឯកវិហារីតិ វុច្ចតីតិ ។ បឋមំ ។

១ ម. នន្ទិសំយោជនវិប្បយុត្តោ ខោ ។ ២ ម. សាយំ ។

ប្រកបដោយកាម គួរជាទីត្រេកអរ បើភិក្ខុ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្ត ចំពោះធម៌នោះទេ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងធម៌នោះ សេចក្តីត្រេកត្រអាលក៏រលត់ទៅ កាលបើមិនមានសេចក្តីត្រេកត្រអាល សេចក្តីប្រាថ្នាក៏មិនមាន កាលបើមិនមានសេចក្តីប្រាថ្នា សំយោជនៈក៏មិនមាន ។ ម្នាលមិគជាលៈ ភិក្ខុ ដែលរួចចាកចំណងគឺសេចក្តីត្រេកត្រអាល ហៅថាអ្នកមានប្រក្រតីនៅម្នាក់ឯង ។ ម្នាលមិគជាលៈ ភិក្ខុមានប្រក្រតីនៅយ៉ាងនេះ ទុកជានៅក្នុងស្រុកច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ពួកស្តេចនិងអាមាត្យធំរបស់ស្តេច ពួកតិរ្ថិយនិងសាវ័ករបស់តិរ្ថិយក៏ដោយ ក៏នៅតែហៅថា អ្នកមានប្រក្រតីនៅម្នាក់ឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា ភិក្ខុនោះមានតណ្ហាជាគម្រប់ពីរមែន តែតណ្ហានោះ ភិក្ខុនោះបានលះហើយ ព្រោះហេតុនោះ បានជាហៅថា អ្នកមានប្រក្រតីនៅម្នាក់ឯង ។ ចប់សូត្រ ទី ១ ។

៨១

មិគជាលវគ្គោ ទុតិយោ

[៦៨] អថខោ អាយស្មា មិគជាលោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មិគជាលោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ សន្តិ ខោ មិគជាល ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ មិគជាលាតិ វទាមិ ។ បេ ។ សន្តិ ខោ មិគជាល ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ មិគជាល មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា

មិគជាលវគ្គ ទី ២

[៦៨] គ្រានោះ ព្រះមិគជាលៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះមិគជាលៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបើបានស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង ចៀសចេញអំពីពួក មិនបានប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ម្នាលមិគជាលៈ មានរូប ដែលត្រូវដឹងច្បាស់ដោយភ្នែក ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តចំពោះរូបនោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តចំពោះរូបនោះ សេចក្តីត្រេកត្រអាលក៏កើតឡើង ម្នាលមិគជាលៈ តថាគតពោលថា ការកើតឡើងនៃកងទុក្ខ មកពីហេតុកើតឡើងនៃសេចក្តីត្រេកត្រអាល ។ បេ ។ ម្នាលមិគជាលៈ មានរសដែលត្រូវដឹងច្បាស់ដោយអណ្តាត ។ បេ ។ ម្នាលមិគជាលៈ មានធម្មារម្មណ៍ដែលត្រូវដឹងច្បាស់ដោយចិត្ត ដែលជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ មិគជាលាតិ វទាមិ ។

[៦៩] សន្តិ ខោ មិគជាល ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ នន្ទិ និរុជ្ឈតិ នន្ទិនិរោធា ទុក្ខនិរោធោ មិគ-
ជាលាតិ វទាមិ ។ បេ ។ សន្តិ ខោ មិគជាល ជិវ្ហា-
វិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ មិគជាល មនោ-
វិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូប-

ជាទីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តចំពោះធម៌នោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តចំពោះធម៌នោះ សេចក្តីត្រេកត្រអាលក៏កើតឡើង ម្នាលមិគជាលៈ តថាគតពោលថា ការកើតឡើងនៃកងទុក្ខ មកពីហេតុកើតឡើងនៃសេចក្តីត្រេកត្រអាល ។

[៦៩] ម្នាលមិគជាលៈ មានរូបដែលត្រូវដឹងច្បាស់ដោយភ្នែក ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងរូបនោះទេ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងរូបនោះ សេចក្តីត្រេកត្រអាល រមែងរលត់ទៅ ម្នាលមិគជាលៈ តថាគតពោលថា ការរលត់ទៅនៃកងទុក្ខ មកពីហេតុរលត់ទៅនៃសេចក្តីត្រេកត្រអាល ។ បេ ។ ម្នាលមិគជាលៈ មានរស ដែលត្រូវដឹងច្បាស់ដោយអណ្តាត ។ បេ ។ ម្នាលមិគជាលៈ មានធម៌ ដែលត្រូវដឹងច្បាស់ដោយចិត្ត ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

សញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ
អនជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អន-
ភិវទតោ អនជ្ឈោសាយ តិដ្ឋតោ នន្ទិ និរុជ្ឈតិ នន្ទិនិ-
រោធា ទុក្ខនិរោធោ មិគជាលាតិ វទាមីតិ ។

[៧០] អថខោ អាយស្មា មិគជាលោ ភគវតោ
ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ
អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អា-
យស្មា មិគជាលោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី
បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា
សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្ម-
ចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិ-
កត្វា ឧបសម្បជ្ជ វិហរតិ[១] ខីណា ជាតិ វុសិតំ ព្រហ្ម-

១ ឱ. វិហាសិ ។

ជាទីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងធម៌នោះទេ កាលភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងធម៌នោះ សេចក្តីត្រេកត្រអាលរមែងរលត់ទៅ ម្នាលមិគជាលៈ តថាគតពោលថា ការរលត់ទៅនៃកងទុក្ខ មកពីហេតុរលត់ទៅនៃសេចក្តីត្រេក-ត្រអាល ។

[៧០] គ្រានោះ ព្រះមិគជាលៈមានអាយុ ត្រេកអរអនុមោទនានូវភាសិត របស់ព្រះមានព្រះភាគ ហើយក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយ ក៏ចៀសចេញទៅ ។ លំដាប់នោះ ព្រះមិគជាលៈមានអាយុ ជាបុគ្គលម្នាក់ឯង ចៀសចេញអំពីពួក ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់សម្រេច នូវទីបំផុតព្រហ្មចរិយៈ មិនមានគុណជាតដទៃលើសលុបជាងដែលជាទីត្រូវការរបស់ពួកកុលបុត្រ ដែលចេញចាកផ្ទះបួសដោយប្រពៃដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មា

ចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា មិគជាលោ អរហតំ អហោសីតិ ។ ទុតិយំ ។

[៧១] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មា សមិទ្ធិ យេន ភគវា ។ បេ ។ ភគវន្តំ ឯតទវោច មារោ មារោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ មារោ វា អស្ស មារបញ្ញត្តិ វាតិ ។ យត្ថ ខោ សមិទ្ធិ អត្ថិ ចក្ខុ អត្ថិ រូបា អត្ថិ ចក្ខុវិញ្ញាណំ អត្ថិ ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារបញ្ញត្តិ វា ។ អត្ថិ សោតំ អត្ថិ សទ្ទា អត្ថិ សោតវិញ្ញាណំ អត្ថិ សោតវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារបញ្ញត្តិ វា ។ អត្ថិ ឃានំ អត្ថិ គន្ធា អត្ថិ ឃានវិញ្ញាណំ

អញបានទៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះមិគជាលៈមានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រ ទី ២ ។

[៧១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះសមិទ្ធិមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា មារ មារ បពិត្រព្រះអង្គដ៏ចម្រើន មារ ឬសេចក្តីបញ្ញត្តថាមារ ដោយហេតុដូចម្តេចខ្លះ ។ ម្នាលសមិទ្ធិ ទីណាមានចក្ខុ មានរូប មានចក្ខុវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយសោតវិញ្ញាណ ទីនោះក៏មានមារ ឬសេចក្តីបញ្ញត្តថាមារ ។ មានច្រមុះ មានក្លិន មានឃានវិញ្ញាណ

អត្ថិ ឃានវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។ អត្ថិ ជិវ្ហា អត្ថិ រសា អត្ថិ ជិវ្ហា-វិញ្ញាណំ អត្ថិ ជិវ្ហាវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។ អត្ថិ កាយោ អត្ថិ ផោដ្ឋព្វា អត្ថិ កាយវិញ្ញាណំ អត្ថិ កាយវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។ អត្ថិ មនោ អត្ថិ ធម្មា អត្ថិ មនោវិញ្ញាណំ អត្ថិ មនោវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។

[៧២] យត្ថ ច ខោ សមិទ្ធិ នត្ថិ ចក្ខុ នត្ថិ រូបា នត្ថិ ចក្ខុវិញ្ញាណំ នត្ថិ ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា នត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។ បេ ។ នត្ថិ ជិវ្ហា នត្ថិ រសា នត្ថិ ជិវ្ហាវិញ្ញាណំ នត្ថិ ជិវ្ហាវិញ្ញាណវិញ្ញា-តព្វា ធម្មា នត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វា ។ បេ ។ នត្ថិ មនោ នត្ថិ ធម្មា នត្ថិ មនោវិញ្ញាណំ នត្ថិ មនោ-វិញ្ញាណវិញ្ញាតព្វា ធម្មា នត្ថិ តត្ថ មារោ វា មារប្បញ្ញត្តិ វាតិ ។ តតិយំ ។

មានធម៌ដែលត្រូវដឹងដោយឃានវិញ្ញាណ ទីនោះ ក៏មានមារឬសេចក្តីបញ្ញត្តថាមារ ។ មានអណ្តាត មានរស មានជិវ្ហាវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណ ទីនោះ ក៏មានមារ ឬសេចក្តីបញ្ញត្តថាមារ ។ មានកាយ មានផ្សព្វ មានកាយវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយកាយវិញ្ញាណ ទីនោះ ក៏មានមារឬសេចក្តីបញ្ញត្តថាមារ ។ មានចិត្ត មានធម៌ មានមនោវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយមនោ-វិញ្ញាណ ទីនោះ ក៏មានមារឬសេចក្តីបញ្ញត្តថាមារ ។

[៧២] ម្នាលសមិទ្ធិ ចំណែកខាងទីណាមិនមានចក្ខុ មិនមានរូប មិនមានចក្ខុវិញ្ញាណ មិនមានធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណ ទីនោះក៏មិនមានមារឬសេចក្តីបញ្ញត្តថាមារទេ ។ បេ ។ មិនមានអណ្តាត មិនមានរស មិនមានជិវ្ហាវិញ្ញាណ មិនមានធម៌ដែលត្រូវដឹងដោយជិវ្ហា-វិញ្ញាណ ទីនោះក៏មិនមានមារឬសេចក្តីបញ្ញត្តថាមារដែរ ។ បេ ។ មិនមានចិត្ត មិនមានធម៌ មិនមានមនោវិញ្ញាណ មិនមានធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណ ទីនោះក៏មិនមានមារឬសេចក្តីបញ្ញត្តថាមារដែរ ។

ចប់សូត្រ ទី ៣ ។

[៧៣] សត្តោ សត្តោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សត្តោ វា អស្ស សត្តបញ្ញត្តិ វាតិ ។ បេ ។ ចតុត្ថំ ។

[៧៤] ទុក្ខំ ទុក្ខន្តិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ទុក្ខំ វា អស្ស ទុក្ខបញ្ញត្តិ វាតិ ។ បេ ។ បញ្ចមំ ។

[៧៥] លោកោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ លោកោ វា អស្ស លោកបញ្ញត្តិ វាតិ ។ យត្ថ ខោ សមិទ្ធិ អត្ថិ ចក្ខុ អត្ថិ រូបា អត្ថិ ចក្ខុវិញ្ញាណំ អត្ថិ ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ លោកោ វា លោកបញ្ញត្តិ វា ។ បេ ។ អត្ថិ ជិវ្ហា ។ បេ ។ អត្ថិ មនោ អត្ថិ ធម្មា អត្ថិមនោវិញ្ញាណំ អត្ថិ មនោវិញ្ញាណវិញ្ញាតព្វា ធម្មា អត្ថិ តត្ថ លោកោ វា លោកបញ្ញត្តិ វា ។

[៧៣] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា សត្វ សត្វ បពិត្រព្រះអង្គដ៏ចម្រើន សត្វ ឬសេចក្តីបញ្ញត្តថាសត្វ តើដោយហេតុដូចម្តេចខ្លះ ។ បេ ។ ចប់សូត្រ ទី ៤ ។

[៧៤] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា ទុក្ខ ទុក្ខ បពិត្រព្រះអង្គដ៏ចម្រើន ទុក្ខ ឬសេចក្តីបញ្ញត្តថាទុក្ខ តើដោយហេតុដូចម្តេចខ្លះ ។ បេ ។ ចប់សូត្រ ទី ៥ ។

[៧៥] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា លោក លោក បពិត្រព្រះអង្គដ៏ចម្រើន លោក ឬសេចក្តីបញ្ញត្តថាលោក តើដោយហេតុដូចម្តេចខ្លះ ។ ម្នាលសមិទ្ធិ ទីណាមានចក្ខុ មានរូប មានចក្ខុវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណ ទីនោះរមែងមានលោកឬសេចក្តីបញ្ញត្តថាលោក ។ បេ ។ មានអណ្តាត ។ បេ ។ មានចិត្ត មានធម៌ មានមនោវិញ្ញាណ មានធម៌ដែលត្រូវដឹងដោយមនោ-វិញ្ញាណ ទីនោះរមែងមានលោកឬសេចក្តីបញ្ញត្តថាលោកដែរ ។

[៨៦] យត្ថ ច ខោ សមិទ្ធិ នត្ថិ ចក្ខុ នត្ថិ រូបា នត្ថិ ចក្ខុវិញ្ញាណំ នត្ថិ ចក្ខុវិញ្ញាណវិញ្ញាតព្វា ធម្មា នត្ថិ តត្ថ លោកោ វា លោកប្បញ្ញត្តិ វា ។ បេ ។ នត្ថិ ជិវ្ហា ។ បេ ។ នត្ថិ មនោ នត្ថិ ធម្មា នត្ថិ មនោវិញ្ញាណំ នត្ថិ មនោវិញ្ញាណវិញ្ញាតព្វា ធម្មា នត្ថិ តត្ថ លោកោ វា លោកប្បញ្ញត្តិ វាតិ ។ ឆដ្ឋំ ។

[៧៧] ឯកំ សមយំ ភគវា អាយស្មា ច សារីបុត្តោ អាយស្មា ច ឧបសេនោ រាជគហេ វិហ-រន្តិ សីតវនេ សប្បសោណ្ឌិកបព្ភារេ ។ តេន ខោ បន សមយេន អាយស្មតោ ឧបសេនស្ស កាយេ អាសីវិសោ បតិតោ ហោតិ ។ អថខោ អាយស្មា ឧបសេនោ ភិក្ខូ អាមន្តេសិ ឯថ មេ អាវុសោ ឥមំ កាយំ មញ្ចកំ អារោបេត្វា ពហិទ្ធា នីហរថ បុរាយំ កាយោ[១] ឥធេវ វិកិរតិ សេយ្យថាបិ ភុស-មុដ្ឋីតិ ។ ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ ឧបសេនំ ឯតទវោច ន ខោ បន មយំ បស្សាម អាយស្មតោ ឧបសេនស្ស កាយស្ស វា អញ្ញថត្តំ

១ អដ្ឋកថាយំ បន បុរាណកាយោតិ ទិស្សតិ ។

មិគជាលវគ្គ ទី ២

[៧៦] ម្នាលសមិទ្ធិ ចំណែកខាងទីណាមិនមានចក្ខុ មិនមានរូប មិនមានចក្ខុវិញ្ញាណ មិនមានធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ទីនោះក៏មិនមានលោកឬសេចក្តីបញ្ញត្តថាលោកទេ ។ បេ ។ មិនមានអណ្តាត ។ បេ ។ មិនមានចិត្ត មិនមានធម៌ មិនមានមនោវិញ្ញាណ មិនមានធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណ ទីនោះក៏មិនមានលោក ឬសេចក្តីបញ្ញត្តថាលោកទេ ។ ចប់សូត្រ ទី ៦ ។

[៧៧] សម័យមួយ ព្រះមានព្រះភាគ ព្រះសារីបុត្តមានអាយុ និងព្រះឧបសេនមានអាយុ គង់នៅក្នុងព្រៃស្មសាន ឈ្មោះសីតវ័ន ទៀបញកភ្នំឈ្មោះសប្បសោណ្ឌិក ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ពស់អាសីពិស ធ្លាក់មកលើកាយព្រះឧបសេនមានអាយុ ។ គ្រានោះ ព្រះឧបសេនមានអាយុហៅភិក្ខុទាំងឡាយមកថា នែអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមកលើកកាយខ្ញុំនេះដាក់លើគ្រែ ហើយសែងទៅខាងក្រៅ ព្រោះថាកាយនេះជារបស់ចាស់ គង់នឹងរោយរាយក្នុងទីនេះ ដូចជាអង្កាមមួយក្តាប់ ។ កាលបើព្រះឧបសេនមានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ ក៏និយាយនឹងព្រះឧបសេនមានអាយុដូច្នេះថា យើងមិនឃើញព្រះឧបសេនមានអាយុ មានកាយផ្សេង

ឥន្ទ្រិយានំ វា វិបរិណាមោ អថ បជាយស្មា ឧបសេនោ ឯវមាហ ឯថ មេ អាវុសោ ឥមំ កាយំ មញ្ចកំ អារោបេត្វា ពហិទ្ធា នីហរថ បុរាយំ កាយោ ឥធេវ វិកិរតិ សេយ្យថាបិ ភុសមុដ្ឋីតិ ។ យស្ស នូន អាវុសោ សារីបុត្ត ឯវមស្ស អហំ ចក្ខុន្តិ វា មម ចក្ខុន្តិ វា ។ បេ ។ អហំ ជិវ្ហាតិ វា មម ជិវ្ហាតិ វា ។ បេ ។ អហំ មនោតិ វា មម មនោតិ វា តស្ស អាវុសោ សារីបុត្ត សិយា កាយស្ស វា អញ្ញថត្តំ ឥន្ទ្រិយានំ វា វិបរិណាមោ ។ មយ្ហញ្ច ខោ អាវុសោ សារីបុត្ត ន ឯវំ ហោតិ អហំ ចក្ខុន្តិ វា មម ចក្ខុន្តិ វា ។ បេ ។ អហំ ជិវ្ហាតិ វា មម ជិវ្ហាតិ វា ។ បេ ។ អហំ មនោតិ វា មម មនោតិ វា តស្ស មយ្ហញ្ច ខោ អាវុសោ សារីបុត្ត កឹ កាយស្ស វា អញ្ញថត្តំ ភវិស្សតិ ឥន្ទ្រិយានំ វា វិបរិណាមោតិ ។ តថា ហិ បជាយស្មតោ ឧបសេនស្ស

ឬមានឥន្ទ្រិយប្រែប្រួលទៅសោះ កាលបើយ៉ាងនេះម្តេចក៏ព្រះឧបសេន មានអាយុនិយាយយ៉ាងនេះថា នែអាវុសោ អ្នកទាំងឡាយចូរមកលើក កាយខ្ញុំនេះដាក់លើគ្រែ ហើយសែងទៅខាងក្រៅ ព្រោះថាកាយនេះ ជារបស់ចាស់ គង់នឹងរោយរាយក្នុងទីនេះ ដូចជាអង្កាមមួយក្តាប់ ។ ព្រះឧបសេនឆ្លើយថា នែអាវុសោសារីបុត្ត អ្នកណាមានសេចក្តីប្រកាន់ យ៉ាងនេះថា ចក្ខុគឺអាត្មាអញ ឬថាចក្ខុរបស់អាត្មាអញ ។ បេ ។ ថា ជិវ្ហាគឺអាត្មាអញ ឬថាជិវ្ហារបស់អាត្មាអញ ។ បេ ។ ថាមនោគឺអាត្មា អញ ឬថាមនោរបស់អាត្មាអញ នែអាវុសោសារីបុត្ត អ្នកនោះទើប មានកាយផ្សេង ឬមានឥន្ទ្រិយប្រែប្រួល ។ នែអាវុសោសារីបុត្ត ចំ-ណែកខ្ញុំមិនមានសេចក្តីត្រិះរិះយ៉ាងនេះទេថា ចក្ខុគឺអាត្មាអញ ឬថាចក្ខុ របស់អាត្មាអញ ។ បេ ។ ថាជិវ្ហាគឺអាត្មាអញ ឬថាជិវ្ហារបស់អាត្មា អញ ។ បេ ។ ថាមនោគឺអាត្មាអញ ឬថាមនោរបស់អាត្មាអញ នែ អាវុសោសារីបុត្ត ខ្ញុំនោះ នឹងមានកាយផ្សេង ឬ មានឥន្ទ្រិយប្រែ ប្រួលដូចម្តេចកើត ។ បើយ៉ាងនោះ មានតែព្រះឧបសេនមានអាយុ

ទីឃរត្តំ អហង្ការមមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ ឧបសេនស្ស ន ឯវំ ហោតិ អហំ ចក្ខុន្តិ វា មម ចក្ខុន្តិ វា ។ បេ ។ អហំ ជិវ្ហាតិ វា មម ជិវ្ហាតិ វា ។ បេ ។ អហំ មនោតិ វា មម មនោតិ វាតិ ។ អថខោ តេ ភិក្ខូ អាយស្មតោ ឧបសេនស្ស កាយំ មញ្ចកំ អារោបេត្វា ពហិទ្ធា នីហរឹសុ ។ អថខោ អាយស្មតោ ឧបសេនស្ស កាយោ តត្ថេវ វិកិរិ សេយ្យថាបិ ភុសមុដ្ឋីតិ ។ សត្តមំ ។

[៧៨] អថខោ អាយស្មា ឧបវាណោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបវាណោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិកោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

បានគាស់រំលើងអនុស័យគឺសេចក្តីប្រកាន់ថាអញ ថារបស់អញ មកយូរហើយ ហេតុនោះ បានជាព្រះឧបសេនមានអាយុ មិនមានសេចក្តីត្រិះរិះយ៉ាងនេះទេថា ចក្ខុគឺអាត្មាអញ ឬថាចក្ខុរបស់អាត្មាអញ ។ បេ ។ ជិវ្ហាគឺអាត្មាអញ ឬថាជិវ្ហារបស់អាត្មាអញ ។ បេ ។ ថាមនោគឺអាត្មាអញ ឬថាមនោរបស់អាត្មាអញ ។ គ្រានោះ ភិក្ខុទាំងនោះ លើកកាយព្រះឧបសេនមានអាយុដាក់លើគ្រែ ហើយសែងចេញទៅខាងក្រៅ ។ លំដាប់នោះ កាយរបស់ព្រះឧបសេនមានអាយុ ក៏រោយរាយក្នុងទីនោះ ដូចអង្កាមមួយក្តាប់ ។ ចប់សូត្រ ទី ៧ ។

[៧៨] គ្រានោះ ព្រះឧបវាណមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះឧបវាណមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យគេតែងនិយាយថា ធម៌បុគ្គលឃើញច្បាស់ដោយខ្លួនឯង ធម៌បុគ្គលឃើញច្បាស់ដោយខ្លួនឯងដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ដោយហេតុដូចម្តេច ។

[៧៩] ឥធ បន ឧបវាណ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រូបប្បដិសំវេទី ច ហោតិ រូបរាគប្បដិសំវេទី ច សន្តញ្ច អជ្ឈត្តំ រូបេសុ រាគំ អត្ថិ មេ អជ្ឈត្តំ រូបេសុ រាគោតិ បជានាតិ ។ យន្តំ ឧបវាណ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រូបប្បដិសំវេទី ច ហោតិ រូបរាគប្បដិសំវេទី ច សន្តញ្ច អជ្ឈត្តំ រូបេសុ រាគំ អត្ថិ មេ អជ្ឈត្តំ រូបេសុ រាគោតិ បជានាតិ ។ ឯវម្បិ ខោ ឧបវាណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ បេ ។

[៨០] បុន ចបរំ ឧបវាណ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា រសប្បដិសំវេទី ច ហោតិ រសរាគប្បដិសំវេទី ច

[៧៩] ម្នាលឧបវាណ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយកត់សម្គាល់នូវរូបផង កត់សម្គាល់នូវតម្រេកក្នុងរូបផង ដឹងច្បាស់នូវតម្រេកដែលមានក្នុងរូបខាងក្នុងថា អាត្មាអញមានតម្រេកក្នុងរូបខាងក្នុងផង ។ ម្នាលឧបវាណ ត្រង់ដែលភិក្ខុ ឃើញរូបដោយចក្ខុ ហើយកត់សម្គាល់នូវរូបផង កត់សម្គាល់នូវតម្រេកក្នុងរូបផង ដឹងច្បាស់នូវតម្រេកដែលមានក្នុងរូបខាងក្នុងថា អាត្មាអញ មានតម្រេកក្នុងរូបខាងក្នុងផង ។ ម្នាលឧបវាណ ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន យ៉ាងនេះក៏មាន ។ បេ ។

[៨០] ម្នាលឧបវាណ មួយទៀត ភិក្ខុ លិទ្ធភ្លក្សរសដោយអណ្ដាត ហើយកត់សម្គាល់នូវរសផង កត់សម្គាល់នូវតម្រេកក្នុងរសផង

សន្តញ្ច អជ្ឈត្តំ រសេសុ រាគំ អត្ថិ មេ អជ្ឈត្តំ រសេសុ រាគោតិ បជានាតិ ។ យន្តំ ឧបវាណ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា រសប្បដិសំវេទី ច ហោតិ រសរាគប្បដិសំវេទី ច សន្តញ្ច អជ្ឈត្តំ រសេសុ រាគំ អត្ថិ មេ អជ្ឈត្តំ រសេសុ រាគោតិ បជានាតិ ។ ឯវម្បិ ខោ ឧបវាណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ បេ ។

[៨១] បុន ចបរំ ឧបវាណ ភិក្ខុ មនសា ធម្មំ វិញ្ញាយ ធម្មប្បដិសំវេទី ច ហោតិ ធម្មរាគប្បដិសំវេទី ច សន្តញ្ច អជ្ឈត្តំ ធម្មេសុ រាគំ អត្ថិ មេ អជ្ឈត្តំ ធម្មេសុ រាគោតិ បជានាតិ ។ យន្តំ ឧបវាណ ភិក្ខុ មនសា ធម្មំ វិញ្ញាយ ធម្មប្បដិសំវេទី ច ហោតិ ធម្មរាគប្បដិសំវេទី ច សន្តញ្ច អជ្ឈត្តំ ធម្មេសុ រាគំ អត្ថិ មេ អជ្ឈត្តំ ធម្មេសុ រាគោតិ បជានាតិ ។ ឯវម្បិ ខោ ឧបវាណ សន្ទិដ្ឋិកោ ធម្មោ ហោតិ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

ដឹងច្បាស់នូវតម្រេកដែលមានក្នុងរសខាងក្នុងថា អាត្មាអញមានតម្រេកក្នុងរសខាងក្នុងផង ។ ម្នាលឧបវាណ ភិក្ខុ លិឍរក្ខក្សរសដោយអណ្តាត ហើយកត់សម្គាល់នូវរសផង កត់សម្គាល់នូវតម្រេកក្នុងរសផង ដឹងច្បាស់នូវតម្រេកដែលមានក្នុងរសខាងក្នុងថា អាត្មាអញមានតម្រេកក្នុងរសខាងក្នុងផង ដោយហេតុណា ។ ម្នាលឧបវាណ ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ដោយហេតុយ៉ាងនេះក៏មាន ។ បេ ។

[៨១] ម្នាលឧបវាណ មួយវិញទៀត ភិក្ខុ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយកត់សម្គាល់នូវធម៌ផង កត់សម្គាល់នូវតម្រេកក្នុងធម៌ផង ដឹងច្បាស់នូវតម្រេកដែលមានក្នុងធម៌ខាងក្នុងថា អាត្មាអញ មានតម្រេកក្នុងធម៌ខាងក្នុងផង ។ ម្នាលឧបវាណ ភិក្ខុ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយកត់សម្គាល់នូវធម៌ផង កត់សម្គាល់នូវតម្រេកក្នុងធម៌ផង ដឹងច្បាស់នូវតម្រេកដែលមានក្នុងធម៌ខាងក្នុងថា អាត្មាអញមានតម្រេកក្នុងធម៌ខាងក្នុង ដោយហេតុណា ។ ម្នាលឧបវាណ ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ។ បេ ។ ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ដោយហេតុយ៉ាងនេះក៏មាន ។

[៨២] ឥធ បន ឧបវាណ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រូបប្បដិសំវេទី ច ហោតិ នោ ច រូបរាគប្បដិសំវេទី អសន្តញ្ច អជ្ឈត្តំ រូបេសុ រាគំ នត្ថិ មេ អជ្ឈត្តំ រូបេសុ រាគោតិ បជានាតិ ។ យន្តំ ឧបវាណ ភិក្ខុ ចក្ខុនា រូបំ ទិស្វា រូបប្បដិសំវេទី ហិ ខោ ហោតិ នោ ច រូបរាគប្បដិសំវេទី អសន្តញ្ច អជ្ឈត្តំ រូបេសុ រាគំ នត្ថិ មេ អជ្ឈត្តំ រូបេសុ រាគោតិ បជានាតិ ។ ឯវម្បិ ខោ ឧបវាណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។

[៨៣] បុន ចបរំ ឧបវាណ ភិក្ខុ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា រសប្បដិសំវេទី ហិ ខោ ហោតិ នោ ច រសរាគប្បដិសំវេទី អសន្តញ្ច អជ្ឈត្តំ រសេសុ រាគំ នត្ថិ មេ អជ្ឈត្តំ រសេសុ រាគោតិ បជានាតិ ។ បេ ។

[៨២] ម្នាលឧបវាណ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ហើយគ្រាន់តែកត់សម្គាល់នូវរូប តែមិនកត់សម្គាល់នូវតម្រេកក្នុងរូប ទាំងដឹងច្បាស់នូវតម្រេកដែលមិនមានក្នុងរូបខាងក្នុងថា អាត្មាអញមិនមានតម្រេកក្នុងរូបខាងក្នុងទេ ។ ម្នាលឧបវាណ ត្រង់ដែលភិក្ខុឃើញរូបដោយចក្ខុ ហើយគ្រាន់តែកត់សម្គាល់នូវរូប តែមិនកត់សម្គាល់នូវតម្រេកក្នុងរូប ទាំងដឹងច្បាស់នូវតម្រេកដែលមិនមានក្នុងរូបខាងក្នុងថា អាត្មាអញមិនមានតម្រេកក្នុងរូបខាងក្នុងទេ ។ ម្នាលឧបវាណ ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន យ៉ាងនេះក៏មាន ។

[៨៣] ម្នាលឧបវាណ មួយទៀត ភិក្ខុ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ លិទ្ធភ្លក្សរសដោយអណ្តាត ហើយគ្រាន់តែកត់សម្គាល់រស តែមិនកត់សម្គាល់តម្រេកក្នុងរស ទាំងដឹងច្បាស់នូវតម្រេកដែលមិនមានក្នុងរសខាងក្នុងថា អាត្មាអញ មិនមានតម្រេកក្នុងរសខាងក្នុងទេ ។ បេ ។

៩៣

មិគជាលវគ្គោ ទុតិយោ

[៨៤] បុន ចបរំ ឧបវាណ ភិក្ខុ មនសា ធម្មំ វិញ្ញាយ ធម្មប្បដិសំវេទី ហិ ខោ ហោតិ នោ ច ធម្មរាគប្បដិសំវេទី អសន្តញ្ច អជ្ឈត្តំ ធម្មេសុ រាគំ នត្ថិ មេ អជ្ឈត្តំ ធម្មេសុ រាគោតិ បជានាតិ ។ យន្តំ ឧបវាណ ភិក្ខុ មនសា ធម្មំ វិញ្ញាយ ធម្មប្បដិសំវេទី ហិ ខោ ហោតិ នោ ច ធម្មរាគប្បដិសំវេទី អសន្តញ្ច អជ្ឈត្តំ ធម្មេសុ រាគំ នត្ថិ មេ អជ្ឈត្តំ ធម្មេសុ រាគោតិ បជានាតិ ។ ឯវម្បិ ខោ ឧបវាណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អដ្ឋមំ ។

[៧៩] យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ អវុសិតន្តេន ព្រហ្មចរិយំ អារកា សោ ឥមស្មា ធម្មវិនយាតិ ។

មិគជាលវគ្គ ទី ២

[៨៤] ម្នាលឧបវាណ មួយវិញទៀត ភិក្ខុ ដឹងនូវធម៌ដោយចិត្ត ហើយគ្រាន់តែកត់សម្គាល់នូវធម៌ តែមិនកត់សម្គាល់នូវតម្រេកក្នុងធម៌ ទាំងដឹងច្បាស់នូវតម្រេកដែលមិនមានក្នុងធម៌ខាងក្នុងថា អាត្មាអញមិនមានតម្រេកក្នុងធម៌ខាងក្នុង ។ ម្នាលឧបវាណ ភិក្ខុ ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយគ្រាន់តែកត់សម្គាល់នូវធម៌ តែមិនកត់សម្គាល់នូវតម្រេកក្នុងធម៌ ទាំងដឹងច្បាស់នូវតម្រេក ដែលមិនមានក្នុងធម៌ខាងក្នុងថា អាត្មាអញមិនមានតម្រេកក្នុងធម៌ខាងក្នុង ដោយហេតុណា ។ ម្នាលឧបវាណ ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងចំពោះខ្លួន ដោយហេតុយ៉ាងនេះក៏មាន ។ ចប់សូត្រ ទី ៨ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិតថា ភិក្ខុណាមួយ មិនដឹងច្បាស់ តាមពិត នូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ទេ ភិក្ខុនោះឈ្មោះថាមិនបានប្រព្រឹត្តព្រហ្មចរិយៈទេ ភិក្ខុនោះឈ្មោះថាឆ្ងាយអំពីធម្មវិន័យនេះ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច ឯត្ថាហំ ភន្តេ អនស្សាសំ[១] អហំ ហិ ភន្តេ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាមីតិ ។ តំ កឹ មញ្ញសិ ភិក្ខុ ចក្ខុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខុ ឯត្ថ ច តេ ភិក្ខុ ចក្ខុំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯសេវន្តោ ទុក្ខស្ស ។ បេ ។ ជិវ្ហំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខុ ឯត្ថ ច តេ ភិក្ខុ ជិវ្ហា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯសេវន្តោ ទុក្ខស្ស ។ បេ ។ មនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសីតិ ។

១ ឱ. អនស្សាសី ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ វិនាសចាកធម៌វិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់ដឹងច្បាស់តាមពិត នូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ឡើយ ។ ម្នាលភិក្ខុ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញចក្ខុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនមែនឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញចក្ខុនុ៎ះដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ នុ៎ះឯងជាទីបំផុតនៃទុក្ខ ។ អ្នកពិចារណាឃើញអណ្តាតថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនមែនឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញអណ្តាតនុ៎ះដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ នុ៎ះឯងជាទីបំផុតនៃទុក្ខ ។ បេ ។ អ្នកពិចារណាឃើញចិត្តថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។

នោ ហេតំ ភន្តេ ។ សាធុ ភិក្ខុ ឯត្ថ ច តេ ភិក្ខុ មនោ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯសេវន្តោ ទុក្ខស្សាតិ ។ នវមំ ។

[៨៦] យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ អវុសិតន្តេន ព្រហ្មចរិយំ អារកា សោ ឥមស្មា ធម្មវិនយាតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច ឯត្ថាហំ ភន្តេ បនស្សាសំ(១) អហំ ហិ ភន្តេ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្ប-ជានាមីតិ ។ តំ កឹ មញ្ញសិ ភិក្ខុ ចក្ខុំ នេតំ មម នេ-សោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសីតិ ។

១ ឱ. អនស្សាសឹ ។ ម. អនស្សស្សំ ។ អដ្ឋកថាយំ បនស្សិសន្តិ បាឋោ ទិស្សតិ ។

មិនមែនឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញចិត្តនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ នុ៎ះឯងជាទីបំផុតនៃទុក្ខ ។ ចប់សូត្រ ទី ៩ ។

[៨៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណានីមួយ មិនដឹងច្បាស់តាមពិត នូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ទេ ភិក្ខុនោះមិនឈ្មោះថានៅចប់ព្រហ្មចរិយៈឡើយ ភិក្ខុនោះឈ្មោះថាឆ្ងាយអំពីធម្មវិន័យនេះ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គខូចប្រយោជន៍ក្នុងធម្មវិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនបានដឹងច្បាស់តាមពិត នូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ឡើយ ។ ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្តីនោះដូចម្តេច អ្នកពិចារណាឃើញចក្ខុថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ដូច្នេះដែរឬ ។

ឯវំ ភន្តេ ។ សាធុ ភិក្ខុ ឯត្ថ ច តេ ភិក្ខុ ចក្ខុំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯវំ តេ ឯតំ បឋមំ ផស្សាយតនំ បហីនំ ភវិស្សតិ អាយតឹ អបុនព្ភវាយ តស្ស ។ បេ ។ ជិវ្ហំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសីតិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខុ ឯត្ថ ច តេ ភិក្ខុ ជិវ្ហា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯវំ តេ ឯតំ ចតុត្ថំ ផស្សាយតនំ បហីនំ ភវិស្សតិ អាយតឹ អបុនព្ភវាយ តស្ស ។ បេ ។ មនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសីតិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខុ

ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញចក្ខុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ កាលបើយ៉ាងនេះ អ្នកនឹងបានលះបង់ផស្សាយតនៈជាបឋមនុ៎ះ ដើម្បីមិនឲ្យផស្សាយតនៈនោះកើតតទៅទៀតបាន ។ បេ ។ អ្នកពិចារណាឃើញអណ្តាតថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញអណ្តាតនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ កាលបើយ៉ាងនេះ អ្នកនឹងបានលះបង់ផស្សាយតនៈជាគម្រប់ ៤ នុ៎ះ ដើម្បីមិនឲ្យផស្សាយតនៈនោះកើតតទៅទៀតបាន ។ បេ ។ អ្នកពិចារណាឃើញចិត្តថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុ ប្រពៃហើយ

ឯត្ថ ច តេ ភិក្ខុ មនោ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ភវិស្សតិ ឯវំ តេ ឯតំ ឆដ្ឋំ ផស្សាយតនំ បហីនំ ភវិស្សតិ អាយតឹ អបុនព្ភវាយ តស្សាតិ[1] ។ ឆសមំ ។

[៨៧] យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ អវុសិតំ តេន ព្រហ្មចរិយំ អារកា សោ ឥមស្មា ធម្មវិនយាតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច ឯត្ថាហំ ភន្តេ បនស្សាសំ អហំ ហិ ភន្តេ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាមីតិ ។ តំ កឹ មញ្ញសិ ភិក្ខុ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ

---

១ ឱ. ម. អបុនព្ភវាយាតិ ។

ម្នាលភិក្ខុ ក្នុងរឿងនេះ អ្នកនឹងបានឃើញចិត្តនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ កាលបើយ៉ាងនេះ អ្នកនឹងបានលះបង់ផស្សាយតនៈជាគម្រប់ ៦ នុ៎ះ ដើម្បីមិនឲ្យផស្សាយតនៈនោះកើតតទៅទៀតបាន ។ ចប់សូត្រ ទី ១០ ។

[៨៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាទីមួយមិនដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ទេ ភិក្ខុនោះឈ្មោះថាមិនបាននៅចប់ព្រហ្មចរិយៈឡើយ ភិក្ខុនោះឈ្មោះថាឆ្ងាយអំពីធម្មវិន័យនេះ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គខូចប្រយោជន៍ក្នុងធម្មវិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនដឹងច្បាស់តាមពិតនូវការកើត ការរលត់ អានិសង្ស ទោស និងការរលាស់ចេញ នូវអាការរបស់ផស្សៈទាំង ៦ ។ ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្ដីនោះដូចម្ដេចភ្នែកទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀងរបស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា

ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនា-និច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខុ សុតវា អរិយស្សា-វកោ ចក្ខុស្មឹបិ និព្វិន្ទតិ សោតស្មឹបិ ឃានស្មឹបិ ជិវ្ហា-យបិ កាយស្មឹបិ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តា-យាតិ បជានាតីតិ ។ ឯកាទសមំ ។

មិគជាលវគ្គោ ទុតិយោ ។

នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងភ្នែកផង នឿយណាយនឹងត្រចៀកផង នឹងច្រមុះផង នឹងអណ្តាតផង នឹងកាយផង នឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះបាន ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងយ៉ាងនេះថា ចិត្តរួចស្រឡះហើយ ។ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ១១ ។

ចប់ មិគជាលវគ្គ ទី ២ ។

៩៩

មិគជាលវគ្គោ ទុតិយោ

# តស្សុទ្ទានំ

មិគជាលេន ទ្វេ វុត្តា
ចត្តារោ ច សមិទ្ធិនា
ឧបសេនោ ឧបវាណោ
ឆផស្សាយតនិកា តយោតិ ។

---

មិគជាលវគ្គ ទី ២

# ឧទ្ទាននៃមិគជាលវគ្គនោះ គឺ

*និយាយ អំពីព្រះមិគជាលៈមានអាយុមាន ២ លើក អំពីព្រះសមិទ្ធិមានអាយុមាន ២ លើក អំពីព្រះឧបសេនមានអាយុ ១ អំពីព្រះឧបវាណមានអាយុ ១ អំពីអាការរបស់ផស្សៈ ៦ មាន ៣ លើក ។*

# គិលានវគ្គោ

[៨៨] សាវត្ថីនិទានំ ។ អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អមុកស្មឹ ភន្តេ វិហារេ អញ្ញតរោ ភិក្ខុ នវោ អប្បញ្ញាតោ អាពា-ធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សាធុ ភន្តេ ភគវា យេន សោ ភិក្ខុ តេនុបសង្កមតុ អនុកម្បំ ឧបា-ទាយាតិ ។ អថខោ ភគវា នវតរញ្ច សុត្វា គិលាន-តរញ្ច(១) អប្បញ្ញាតោ ភិក្ខូតិ ឥតិ វិទិត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ។ អទ្ទសា ខោ សោ ភិក្ខុ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វា(២) មញ្ចកេ សម-តេសិ(៣) ។ អថខោ ភគវា តំ ភិក្ខុំ ឯតទវោច អលំ ភិក្ខូ មា ត្វំ មញ្ចកេ សមតេសិ សន្តិមានិ អា-សនានិ បញ្ញត្តានិ តត្ថាហំ និសីទិស្សាមីតិ ។ និសី-ទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគ-វា តំ ភិក្ខុំ ឯតទវោច កច្ចិ តេ ភិក្ខុ ខមនីយំ

---

១ ឱ. នវវាទញ្ច សុត្វា គិលានវាទញ្ច សុត្វា ។ ២ ឱ. ម. ទិស្វាន ។ ៣ ម. សមធោសិ ។ ឱ. សមញ្ចោបិ ។

# គិលានវគ្គ

[៨៨] សាវត្ថីនិទាន ។ គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវត្តឯណោះ មានភិក្ខុថ្មីមួយរូប មិនទាន់មានគេស្គាល់ មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគអនុគ្រោះ ស្តេចទៅស្រោចស្រង់ភិក្ខុនោះផង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ឮថា ភិក្ខុថ្មីណាស់ផង ឈឺធ្ងន់ផង ទ្រង់ជ្រាបច្បាស់ដូច្នេះថា ភិក្ខុមិនទាន់មានគេស្គាល់ ក៏ស្តេចចូលទៅរកភិក្ខុនោះ ។ ភិក្ខុនោះបានឃើញព្រះមានព្រះភាគ ស្តេចមកអំពីចម្ងាយ លុះឃើញហើយក៏ប្រវេប្រវា (ចង់ក្រោក) លើគ្រែ ។ គ្រានោះព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកា នឹងភិក្ខុនោះដូច្នេះថា ណ្ហើយភិក្ខុ អ្នកកុំប្រវេប្រវាលើគ្រែឡើយ ព្រោះមានអាសនៈគេក្រាលទុកនេះហើយ តថាគតនឹងអង្គុយលើអាសនៈនោះ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់ស៊ប់ហើយ ក៏ត្រាស់សួរភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ទ្រាំបានដែរឬ

កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ កច្ចិ តេ ភិក្ខុ ន កិញ្ចិ កុក្កុច្ចំ ន កោចិ វិប្បដិសារោតិ ។ តគ្ឃ មេ ភន្តេ អនប្បកំ កុក្កុច្ចំ អនប្បកោ វិប្បដិសារោតិ ។ កច្ចិ បន តេ[១] ភិក្ខុ អត្តា សីលតោ ន ឧបវទតីតិ ។ ន ខោ មេ ភន្តេ[២] អត្តា សីលតោ ឧបវទតីតិ ។ នោ ចេ កិរ តំ ភិក្ខុ អត្តា សីលតោ ឧបវទតិ អថ កិស្មិញ្ច តេ កុក្កុច្ចំ កោ ច វិប្បដិសារោតិ ។ ន ខ្វាហំ ភន្តេ សីលវិសុទ្ធត្ថំ ភគវតា ធម្មំ ទេសិតំ អាជានាមីតិ ។ នោ ចេ កិរ តំ ភិក្ខុ សីលវិសុទ្ធត្ថំ មយា ធម្មំ ទេសិតំ អាជានាសិ អថ កិមត្ថំ ចរហិ តំ ភិក្ខុ មយា ធម្មំ ទេសិតំ អាជានាសីតិ ។ រាគវិរាគត្ថំ ខ្វាហំ ភន្តេ

១ ឱ. តំ ។ ២ ម. នោ ហេតំ ភន្តេ ។

អ្នកល្មមប្រព្រឹត្តទៅបានស្រួលដែរឬ ទុក្ខវេទនាចេះតែថយទៅ មិនចម្រើនឡើង មានតែស្រាកស្រាន្តទៅ មិនរឹតឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ទ្រាំមិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ តែងចម្រើនឡើង មិនធូរថយទេ មានតែរឹតឡើង មិនស្រាកស្រាន្តទេ ។ ម្នាលភិក្ខុ អ្នកមិនមានសេចក្តីរង្កៀសតិចតួច មិនមានវិប្បដិសារៈនីមួយទេឬ ។ ព្រះករុណា ព្រះអង្គ ខ្ញុំព្រះអង្គមានសេចក្តីរង្កៀសច្រើន មានវិប្បដិសារៈច្រើន ។ ម្នាលភិក្ខុ ចុះអ្នកមិនបានតិះដៀលខ្លួន ដោយសីលទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានតិះដៀលខ្លួន ដោយសីលទេ ។ ម្នាលភិក្ខុ បើអ្នកមិនបានតិះដៀលខ្លួនដោយសីលទេ ម្នាលភិក្ខុ កាលបើយ៉ាងនេះ អ្នកមានសេចក្តីរង្កៀសក្នុងអ្វី ទាំងមានវិប្បដិសារៈអ្វីទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់យល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងថា មានការស្អាតសីលជាប្រយោជន៍ ។ ម្នាលភិក្ខុ បើអ្នកមិនទាន់យល់ច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយថា មានការស្អាតសីលជាប្រយោជន៍ទេ ម្នាលភិក្ខុ កាលបើយ៉ាងនេះ អ្នកយល់ច្បាស់នូវធម៌ដែលតថាគតសម្តែងហើយ ថាមានអ្វីជាប្រយោជន៍ ។ បពិត្រព្រះអង្គដ៏ចម្រើន

ភគវតា ធម្មំ ទេសិតំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ រាគវិរាគត្ថំ មយា ធម្មំ ទេសិតំ អាជានាសិ រាគវិរាគត្ថោ ហិ ភិក្ខុ មយា ធម្មោ ទេសិតោ ។

[៨៩] តំ កឹ មញ្ញសិ ភិក្ខុ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខុ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ

ខ្ញុំព្រះអង្គយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ថាមានការកម្ចាត់បង់នូវរាគៈជាប្រយោជន៍ ។ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ប្រពៃណាស់ហើយ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ដែលអ្នកយល់ច្បាស់នូវធម៌ដែលតថាគតសម្តែងហើយ ថាមានការកម្ចាត់បង់នូវរាគៈជាប្រយោជន៍ ម្នាលភិក្ខុ ព្រោះថា ធម៌ដែលតថាគតបានសម្តែងហើយ សុទ្ធតែមានការកម្ចាត់បង់នូវរាគៈជាប្រយោជន៍ ។

[៨៩] ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្តីនោះដូចម្តេច ភ្នែកទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរនឹងយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ កាលបើអរិយសាវ័កអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងភ្នែកផង ។ បេ ។ រមែងនឿយណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាស

វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឥទមវោច ភគវា អត្តមនោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុនោ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ បឋមំ ។

[៩០] អថខោ អញ្ញតរោ ភិក្ខុ ។ បេ ។ ភគវន្តំ ឯតទវោច អមុកស្មឹ ភន្តេ វិហារេ អញ្ញតរោ ភិក្ខុ ន-វោ អប្បញ្ញាតោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សាធុ ភន្តេ ភគវា យេន សោ ភិក្ខុ តេនុប-សង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អថខោ ភគវា

ចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះបាន ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញ រួចស្រឡះហើយ ។ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ ។ បេ ។ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រនេះចប់ហើយ ភិក្ខុនោះក៏មានចិត្តរីករាយ ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ សម្តែងវេយ្យាករណ៍នេះចប់ហើយ ធម្មចក្ខុ គឺសោតាបត្តិផលដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ភិក្ខុនោះថា ធម្មជាតណានីមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។ ចប់សូត្រ ទី ១ ។

[៩០] គ្រានោះ ភិក្ខុមួយរូប ។ បេ ។ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវត្តឯណោះ មានភិក្ខុថ្មីមួយរូប មិនទាន់មានគេស្គាល់ មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគទ្រង់អនុគ្រោះ ស្តេចទៅជួបភិក្ខុនោះផង ។ គ្រានោះ ព្រះមានព្រះភាគ

នវតរញ្ច សុត្វា គិលានតរញ្ច អប្បញ្ញាតោ ភិក្ខូតិ ឥតិ វិទិត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ។ អទ្ទសា ខោ ភិក្ខុ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន មញ្ចកេ សមតេសិ ។ អថខោ ភគវា តំ ភិក្ខុំ ឯតទវោច អលំ ភិក្ខុ មា ត្វំ មញ្ចកេ សមតេហិ សន្តិមានិ អាសនានិ បញ្ញត្តានិ តត្ថាហំ និសីទិស្សាមីតិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា តំ ភិក្ខុំ ឯតទវោច កច្ចិ តេ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ។ បេ ។ ន ខោ មេ ភន្តេ អត្តា សីលតោ ឧបវទតីតិ ។ នោ ចេ កិរ ត្វំ ភិក្ខុ អត្តា សីលតោ ឧបវទតិ អថ

ទ្រង់ព្រថា ភិក្ខុថ្មីណាស់ផង ឈឺធ្ងន់ណាស់ផង ជ្រាបច្បាស់ដូច្នេះថា ភិក្ខុមិនទាន់មានគេស្គាល់ ហើយក៏ស្តេចចូលទៅរកភិក្ខុនោះ ។ ភិក្ខុនោះបានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ប្រវេប្រវាលើគ្រែ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកា នឹងភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ ណ្ហើយ អ្នកកុំប្រវេប្រវាលើគ្រែឡើយ ព្រោះមានអាសនៈដែលគេក្រាលទុកនេះហើយ តថាគតនឹងអង្គុយលើអាសនៈនោះ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏ទ្រង់ត្រាស់សួរទៅភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ទ្រាំបានដែរឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលដែរឬ ទុក្ខវេទនាថយទៅ មិនចម្រើនឡើង មានតែស្រាកស្រាន្តទៅ មិនចម្រើនឡើងទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអត់ទ្រាំមិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានតិះដៀលខ្លួនដោយសីលទេ ។ ម្នាលភិក្ខុ បើអ្នកមិនបានតិះដៀលខ្លួនដោយសីលទេ កាលបើយ៉ាងនេះ

កិស្មឹ ច តេ កុក្កុច្ចំ កោ ច វិប្បដិសារោតិ ។ ន ខ្វាហំ ភន្តេ សីលវិសុទ្ធត្ថំ ភគវតា ធម្មំ ទេសិតំ អាជានាមីតិ ។ នោ ចេ កិរ ត្វំ ភិក្ខុ សីលវិសុទ្ធត្ថំ មយា ធម្មំ ទេសិតំ អាជានាសិ អថ កិមត្ថំ ចរហិ ត្វំ ភិក្ខុ មយា ធម្មំ ទេសិតំ អាជានាសីតិ ។ អនុបាទាបរិនិព្វានត្ថំ ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមីតិ ។ សាធុ សាធុ ភិក្ខុ សាធុ ខោ ត្វំ ភិក្ខុ អនុបាទាបរិនិព្វានត្ថំ មយា ធម្មំ ទេសិតំ អាជានាសិ អនុបាទាបរិនិព្វានត្ថោ ហិ ភិក្ខុ មយា ធម្មោ ទេសិតោ ។

[៩១] តំ កឹ មញ្ញសិ ភិក្ខុ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ សោតំ ឃានំ ជិវ្ហា កាយោ មនោ មនោវិញ្ញាណំ មនោសម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។

អ្នកមានសេចក្ដីរង្កៀសក្នុងរឿងអ្វី មានវិប្បដិសារៈអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមិនទាន់យល់ច្បាស់ធម៌ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយថា សីលមានសេចក្ដីស្អាតជាប្រយោជន៍ ។ ម្នាលភិក្ខុ បើអ្នកមិនទាន់យល់ច្បាស់ធម៌ ដែលតថាគតសម្ដែងហើយថា សីលមានសេចក្ដីស្អាតជាប្រយោជន៍ទេ ម្នាលភិក្ខុ កាលបើយ៉ាងនេះ អ្នកយល់ច្បាស់ធម៌ដែលតថាគតសម្ដែងហើយ ថាមានអ្វីជាប្រយោជន៍ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយល់ច្បាស់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយថា មានអនុបាទាបរិនិព្វាន (បរិនិព្វានកិលេសព្រមទាំងខន្ធ) ជាប្រយោជន៍ ។ ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ម្នាលភិក្ខុ ប្រពៃណាស់ហើយ ដែលអ្នកយល់ច្បាស់ធម៌ ដែលតថាគតសម្ដែងហើយថា មានអនុបាទាបរិនិព្វានជាប្រយោជន៍ ម្នាលភិក្ខុ ព្រោះថាធម៌ដែលតថាគតបានសម្ដែងហើយ សុទ្ធតែមានអនុបាទាបរិនិព្វានជាប្រយោជន៍ ។

[៩១] ម្នាលភិក្ខុ អ្នកសម្គាល់នូវសេចក្ដីនោះ ដូចម្ដេច ភ្នែកទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត មនោវិញ្ញាណ មនោសម្ផស្ស ទោះបីវេទនាណា ជាសុខក្ដី ជាទុក្ខក្ដី មិនជាទុក្ខមិនជាសុខក្ដី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះទៀងឬមិនទៀង ។

អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខុ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុ កាលបើអរិយសាវ័កអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងភ្នែកផង ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះ កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញ រួចស្រឡះហើយ ។ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ឥទមវោច ភគវា អត្តមនោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិ ។ ឥមស្មឹ ច បន វេយ្យាករណស្មឹ ភញ្ញមានេ តស្ស ភិក្ខុស្ស អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចីតិ ។ ទុតិយំ ។

[៩២] អថខោ អាយស្មា រាធោ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាធោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យំ ខោ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ កិញ្ច រាធ អនិច្ចំ ចក្ខុំ ខោ រាធ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា អនិច្ចា ។

លុះព្រះមានព្រះភាគទ្រង់សម្តែងសូត្រនេះចប់ហើយ ភិក្ខុនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ទ្រង់សម្តែងវេយ្យាករណ៍នេះចប់ហើយ ចិត្តរបស់ភិក្ខុនោះក៏រួចស្រឡះចាកអាសវៈ ព្រោះមិនបានប្រកាន់មាំ ។ ចប់សូត្រ ទី ២ ។

[៩២] គ្រានោះ ព្រះរាធៈមានអាយុ ។ បេ ។ លុះព្រះរាធៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង ចៀសចេញទៅ មិនបានប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ។ ម្នាលរាធៈ របស់ណាមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលរាធៈ ចុះរបស់ដូចម្តេចមិនទៀង ម្នាលរាធៈ ភ្នែកហ្នឹងឯងមិនទៀងទេ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងភ្នែកនោះចេញ ។ រូបមិនទៀងទេ ។

ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ យម្បិទំ ចក្ខុសម្ផស្សប្ប-
ច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខម-
សុខំ វា តម្បិ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ
។ បេ ។ ជិវ្ហា កាយោ មនោ អនិច្ចោ តត្រ តេ ឆន្ទោ
បហាតព្វោ ។ ធម្មា មនោវិញ្ញាណំ មនោសម្ផស្សោ
យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ
វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ តត្រ តេ
ឆន្ទោ បហាតព្វោ ។ យំ ខោ រាធ អនិច្ចំ តត្រ តេ
ឆន្ទោ បហាតព្វោតិ ។ តតិយំ ។

ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្ស ជាបច្ច័យ វេទនានោះមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវេទនានោះចេញ ។ បេ ។ អណ្តាត កាយ ចិត្ត មិនទៀងទេ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងចិត្តនោះចេញ ។ ធម៌ មនោវិញ្ញាណ មនោសម្ផស្ស ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ វេទនានោះ មិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវេទនានោះចេញ ។ ម្នាលរាធៈ របស់ណាមិនទៀង អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ចប់សូត្រ ទី ៣ ។

គិលានវគ្គោ បឋមោ

[៩៣] យំ ខោ រាធ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ កិញ្ច រាធ ទុក្ខំ ចក្ខុំ ខោ រាធ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ។ បេ ។ អទុក្ខមសុខំ វា តម្បិ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ មនោ ទុក្ខោ ធម្មា មនោវិញ្ញាណំ មនោសម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ យំ ខោ រាធ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ចតុត្ថំ ។

[៩៤] យោ ខោ រាធ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ កោ ច រាធ អនត្តា ។ ចក្ខុំ ខោ រាធ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា

[៩៣] ម្នាលរាធៈ របស់ណាជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលរាធៈ ចុះរបស់អ្វីជាទុក្ខ ម្នាលរាធៈ ភ្នែកហ្នឹងឯងជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងភ្នែកនោះចេញ ។ រូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស ទោះបីវេទនាណាមិនជាទុក្ខមិនជាសុខក្តី ។ បេ ។ ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះឯងក៏ជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវេទនានោះចេញ ។ បេ ។ ចិត្តជាទុក្ខ ធម៌ មនោវិញ្ញាណ មនោសម្ផស្ស ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏ជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលរាធៈ របស់ណាជាទុក្ខ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ចប់សូត្រ ទី ៤ ។

[៩៤] ម្នាលរាធៈ សភាវៈណាមិនមែនជារបស់ខ្លួន អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងសភាវៈនោះចេញ ។ ម្នាលរាធៈ ចុះសភាវៈដូចម្តេច មិនមែនជារបស់ខ្លួន ។ ម្នាលរាធៈ ភ្នែកហ្នឹងឯងមិនមែនជារបស់ខ្លួនទេ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងភ្នែកនោះចេញ ។ រូប

ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ។ បេ ។ មនោ អនត្តា ធម្មា មនោវិញ្ញាណំ មនោសម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ យោ ខោ រាធ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោតិ ។ បញ្ចមំ ។

[៩៤] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភន្តេ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ អត្ថិ ខោ ភិក្ខុ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ កតមោ បន ភន្តេ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ អវិជ្ជា ខោ ភិក្ខុ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។

ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស ទោះបីវេទនាណា ។ បេ ។ ព្រោះចក្ខុសម្ផស្ស ជាបច្ច័យ ចិត្តមិនមែនជារបស់ខ្លួនទេ ធម៌ មនោវិញ្ញាណ មនោសម្ផស្ស ទោះបីវេទនាណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ វេទនានោះក៏មិនមែនជារបស់ខ្លួនដែរ អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងវេទនានោះចេញ ។ ម្នាលរាធៈ សភាវៈណាមិនមែនជារបស់ខ្លួន អ្នកត្រូវលះបង់សេចក្តីប៉ុនប៉ងក្នុងសភាវៈនោះចេញ ។ ចប់សូត្រ ទី ៥ ។

[៩៥] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌តែមួយ ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បានដែរ វិជ្ជាក៏កើតឡើង មានដែរឬ ។ ម្នាលភិក្ខុ ធម៌តែមួយ ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង ក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះធម៌តែមួយដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង តើដូចម្តេច ។ ម្នាលភិក្ខុ ធម៌តែមួយ គឺអវិជ្ជាហ្នឹងឯង ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង ។

កថំ បន ភន្តេ ជានតោ កថំ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ ចក្ខុំ ខោ ភិក្ខុ អនិច្ចតោ ជានតោ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតិ ។ រូបេ ។ បេ ។ យម្បិទំ ចក្ខុសម្ផស្ស-ប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចតោ ជានតោ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតិ ។ ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ ឆដ្ឋំ ។

[៩៦] អថខោ អញ្ញតរោ ភិក្ខុ ។ បេ ។ អត្ថិ នុ ខោ ភន្តេ ឯកោ ធម្មោ យស្ស បហានា ភិក្ខុ-នោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ អត្ថិ ខោ ភិក្ខុ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ កតមោ បន ភន្តេ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា

បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុកាលដឹងដូចម្ដេច ឃើញដូចម្ដេច ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ម្នាលភិក្ខុ ភិក្ខុកាលដឹង កាលឃើញនូវភ្នែកថា ជារបស់មិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ភិក្ខុកាលដឹង កាលឃើញនូវរូប ។ បេ ។ ភិក្ខុកាលដឹង កាលឃើញនូវវេទនា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ថាមិនទៀង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ម្នាលភិក្ខុ កាលបើភិក្ខុដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ចប់សូត្រទី ៦ ។

[៩៦] គ្រានោះ ភិក្ខុមួយរូប ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌មួយ ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង មានដែរឬ ។ ម្នាលភិក្ខុ ធម៌តែមួយ ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង ក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះធម៌តែមួយ ដែលភិក្ខុលះបង់ហើយ អវិជ្ជា

បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ អវិជ្ជា ខោ ភិក្ខុ ឯកោ ធម្មោ យស្ស បហានា ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ កថំ បន ភន្តេ ជានតោ កថំ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជតីតិ ។ ឥធ ភិក្ខុ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ។ ឯវញ្ចេតំ ភិក្ខុ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ។ សោ សព្វំ ធម្មំ អភិជានាតិ សព្វំ ធម្មំ អភិញ្ញាយ សព្វំ ធម្មំ បរិជានាតិ សព្វំ ធម្មំ បរិញ្ញាយ សព្វនិមិត្តានិ អញ្ញតោ បស្សតិ ចក្ខុំ អញ្ញតោ បស្សតិ រូបេ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សំ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អញ្ញតោ បស្សតិ ។ បេ ។ មនំ អញ្ញតោ បស្សតិ ធម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ

ក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង តើដូចម្តេច ។ ម្នាលភិក្ខុ ធម៌តែមួយ គឺអវិជ្ជាហ្នឹងឯង ដែលភិក្ខុលះបង់ហើយ អវិជ្ជាក៏ឈ្មោះថាលះបង់បាន វិជ្ជាក៏កើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុកាលដឹងដូចម្តេច ឃើញដូចម្តេច ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ បានស្តាប់ហើយថា ធម៌ទាំងពួងមិនគួរនឹងប្រកាន់មាំទេ ។ ម្នាលភិក្ខុ បើភិក្ខុបានស្តាប់ពុទ្ធវចនៈនុ៎ះថា ធម៌ទាំងពួងមិនគួរនឹងប្រកាន់មាំឡើយ យ៉ាងនេះហើយ ។ ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ រមែងកំណត់ដឹង នូវធម៌ទាំងពួង លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងឃើញច្បាស់ នូវនិមិត្តទាំងពួងថាជារបស់ដទៃ ឃើញនូវភ្នែកថាជារបស់ដទៃ ឃើញនូវរូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស នូវវេទនា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យថាជារបស់ដទៃ ។ បេ ។ ឃើញនូវចិត្តថាជារបស់ដទៃ ឃើញនូវធម៌ មនោវិញ្ញាណ មនោសម្ផស្ស នូវវេទនា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ

អញ្ញតោ បស្សតិ ។ ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ ភិក្ខុនោ អវិជ្ជា បហិយ្យតិ វិជ្ជា ឧប្បជ្ជ-តីតិ ។ សត្តមំ ។

[៩៧] អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ។ បេ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ នោ ភន្តេ អញ្ញតិត្ថិយា បរិព្វាជកា អម្ហេ ឯវំ បុច្ឆន្តិ កិមត្ថិយំ អាវុសោ ស-មណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ឯវំ បុដ្ឋា មយំ ភន្តេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករោម ទុក្ខស្ស ខោ អាវុសោ បរិញ្ញត្ថំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ កច្ចិ មយំ ភន្តេ ឯវំ បុដ្ឋា ឯវំ ព្យាករមានា

ថាជារបស់ដទៃ ។ ម្នាលភិក្ខុ ភិក្ខុកាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ឯង ទើបលះបង់អវិជ្ជាបាន វិជ្ជាក៏កើតឡើង ។ ចប់សូត្រ ទី ៧ ។

[៩៧] គ្រានោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកអន្យតិរ្ថិយបរិព្វាជកក្នុងទីឯណោះ សួរពួកខ្ញុំព្រះអង្គយ៉ាងនេះថា នៃអាវុសោទាំងឡាយ ព្រហ្មចរិយៈ មានអ្វីជាប្រយោជន៍ ដែលពួកលោកប្រព្រឹត្តក្នុងសំណាក់ព្រះសមណគោតម បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះហើយ យើងខ្ញុំព្រះអង្គក៏ដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះយ៉ាងនេះថា នៃអាវុសោទាំងឡាយ ព្រហ្មចរិយៈ មានការកំណត់ដឹងនូវទុក្ខហ្នឹងឯងជាប្រយោជន៍ ដែលពួកយើងប្រព្រឹត្តក្នុងសំណាក់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន កាលបើពួកអន្យតិរ្ថិយបរិព្វាជក សួរយ៉ាងនេះហើយ ពួកខ្ញុំព្រះអង្គដោះស្រាយយ៉ាងនេះ

វុត្តវាទិនោ ចេវ ភគវតោ ហោម ន ច ភគវន្តំ អភូតេន អព្ភាចិក្ខាម ធម្មស្ស ចានុធម្មំ ព្យាករោម ន កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតីតិ ។ តគ្ឃ តុម្ហេ ភិក្ខវេ ឯវំ បុដ្ឋា ឯវំ ព្យាករមានា វុត្តវា-ទិនោ ចេវ មេ ហោថ ន ច មំ អភូតេន អព្ភាចិក្ខថ ធម្មស្ស ចានុធម្មំ ព្យាករោថ ន ច កោចិ សហធម្មិ-កោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតិ ។ ទុក្ខស្ស ហិ ភិក្ខវេ បរិញ្ញត្ថំ មយិ ព្រហ្មចរិយំ វុស្សតិ ។ សចេ បន វោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កតមញ្ច បន តំ អាវុសោ ទុក្ខំ យស្ស បរិញ្ញាយ សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជ-កានំ ឯវំ ព្យាករេយ្យាថ ចក្ខុំ ខោ អាវុសោ ទុក្ខំ

ឈ្មោះថានិយាយតាមព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគសម្តែងហើយផង មិននិយាយបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ព្យាករនូវធម៌សមគួរតាមធម៌ផង ទាំងលំអាននៃពាក្យទីមួយ ដែលសមតាមហេតុ មិនដល់ថ្នាក់គួរតិះដៀលទេឬ ។ ម្នាលភិក្ខុទាំងឡាយ អើ កាលបើគេសួរយ៉ាងនេះហើយ អ្នកទាំងឡាយដោះស្រាយយ៉ាងនេះ ឈ្មោះថានិយាយតាមពាក្យដែលតថាគតសម្តែងហើយផង មិននិយាយបង្កាច់តថាគតដោយពាក្យមិនពិតផង ព្យាករនូវធម៌សមគួរតាមធម៌ផង ទាំងលំអាននៃពាក្យទីមួយ ដែលសមតាមហេតុ មិនដល់ថ្នាក់គួរតិះដៀលទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រហ្មចរិយៈ មានការកំណត់ដឹងនូវទុក្ខជាប្រយោជន៍ គឺពួកអ្នកបានប្រព្រឹត្តក្នុងសំណាក់តថាគត ។ ម្នាលភិក្ខុទាំងឡាយ តែប្រសិនបើពួកអន្យតិរ្ថិយបរិព្វាជក សួរអ្នកទាំងឡាយយ៉ាងនេះវិញថា នែអាវុសោទាំងឡាយ ចុះព្រហ្មចរិយៈ គឺពួកលោក បានប្រព្រឹត្តក្នុងសំណាក់ព្រះសមណគោតម ដើម្បីកំណត់ដឹងនូវទុក្ខនោះដូចម្តេច ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជកសួរយ៉ាងនេះ អ្នកទាំងឡាយ ត្រូវដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ យ៉ាងនេះថា នែអាវុសោទាំងឡាយ ភ្នែកហ្នឹងឯងជាទុក្ខ

១១៤

គិលានវគ្គោ តតិយោ

តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ រូបា ។ បេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទ-យិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ បេ ។ មនោ ទុក្ខោ ។ បេ ។ យម្បិទំ មនោសម្ផ-ស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អ-ទុក្ខមសុខំ វា តម្បិ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ ឥទំ ខោ តំ អាវុសោ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។ អដ្ឋមំ ។

ព្រហ្មចរិយៈ គឺពួកយើងបានប្រព្រឹត្ត ក្នុងសំណាក់ព្រះមានព្រះភាគ ក៏ដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ រូបទាំងឡាយ ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះឯង ក៏ជាទុក្ខ ព្រហ្មចរិយៈគឺពួកយើងបានប្រព្រឹត្ត ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ បេ ។ ចិត្តជាទុក្ខ ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលតែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះឯង ក៏ជាទុក្ខ ព្រហ្មចរិយៈគឺពួកយើងបានប្រព្រឹត្ត ក្នុងសំ-ណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ នែអាវុសោទាំងឡាយ នេះឯងឈ្មោះថាទុក្ខ ព្រហ្មចរិយៈគឺពួកយើងប្រព្រឹត្ត ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកអន្យតិរ្ថិយបរិព្វាជក សួរយ៉ាងនេះហើយ អ្នកទាំងឡាយ ត្រូវដោះស្រាយដល់ពួកអន្យតិរ្ថិយបរិព្វាជកទាំងនោះ យ៉ាងនេះចុះ ។ ចប់សូត្រ ទី ៨ ។

[៩៨] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។ បេ ។ ឯកាមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច លោកោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ លោកោតិ វុច្ចតីតិ ។ លុជ្ជតីតិ ខោ ភិក្ខុ តស្មា លោ-កោតិ វុច្ចតិ ។ កិញ្ច លុជ្ជតិ ចក្ខុំ ខោ ភិក្ខុ លុជ្ជតិ រូបា លុជ្ជន្តិ ចក្ខុវិញ្ញាណំ លុជ្ជតិ ចក្ខុសម្ផស្សោ លុជ្ជតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទ-យិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ ។ បេ ។ ជិវ្ហា លុជ្ជតិ ។ បេ ។ មនោ លុជ្ជតិ ធម្មា លុជ្ជន្តិ មនោវិញ្ញាណំ លុជ្ជតិ មនោសម្ផស្សោ លុជ្ជតិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ លុជ្ជតិ ។ បលុជ្ជតីតិ ខោ ភិក្ខុ តស្មា លោកោតិ វុច្ចតីតិ ។ នវមំ ។

[៩៨] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលគេតែងនិយាយថា លោក លោក ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថាលោក តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ សភាវៈណា តែងបែកធ្លាយ ព្រោះហេតុនោះ ទើបហៅថាលោក ។ ចុះរបស់អ្វី តែងបែកធ្លាយ ម្នាលភិក្ខុ ភ្នែក តែងបែកធ្លាយ រូបទាំងឡាយ តែងបែកធ្លាយ ចក្ខុវិញ្ញាណ តែងបែកធ្លាយ ចក្ខុសម្ផស្ស តែងបែកធ្លាយ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏តែងបែកធ្លាយ ។ បេ ។ អណ្តាត តែងបែកធ្លាយ ។ បេ ។ ចិត្ត តែងបែកធ្លាយ ធម៌ទាំងឡាយ តែងបែកធ្លាយ មនោវិញ្ញាណ តែងបែកធ្លាយ មនោសម្ផស្ស តែងបែកធ្លាយ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះឯង ក៏តែងបែកធ្លាយ ។ ម្នាលភិក្ខុ សភាវៈណា តែងបែកធ្លាយ ព្រោះហេតុនោះ ទើបហៅថាលោក ។ ចប់សូត្រ ទី ៩ ។

១១៧

គិលានវគ្គោ តតិយោ

[៩៩] អថខោ អាយស្មា ផគ្គុនោ ។ បេ ។ ឯក-
មន្តំ និសិន្នោ ខោ អាយស្មា ផគ្គុនោ ភគវន្តំ ឯតទវោច
អត្ថិ នុ ខោ ភន្តេ តំ ចក្ខុំ យេន ចក្ខុនា អតីតេ ពុទ្ធេ
បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វ-
ទុក្ខវីតិវត្តេ បញ្ញាបយមានោ បញ្ញាបេយ្យ ។ បេ ។ អត្ថិ
នុ ខោ ភន្តេ សា ជិវ្ហា យាយ ជិវ្ហាយ អតីតេ ពុទ្ធេ
បរិនិព្វុតេ ។ បេ ។ បញ្ញាបេយ្យ ។ បេ ។ អត្ថិ នុ ខោ
សោ ភន្តេ មនោ យេន មនេន អតីតេ ពុទ្ធេ បរិនិព្វុ-
តេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខ-
វីតិវត្តេ បញ្ញាបយមានោ បញ្ញាបេយ្យាតិ ។

[១០០] នត្ថិ ខោ តំ ផគ្គុន ចក្ខុំ យេន ចក្ខុ-
នា អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ

គិលានវគ្គ ទី ៣

[៩៩] គ្រានោះ ព្រះផគ្គុនៈមានអាយុ ។ បេ ។ លុះព្រះផគ្គុនៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអតីតពុទ្ធ ព្រះអង្គមានដំណើរឃើតឃូរគឺតណ្ហាកាត់ចោលហើយ មានផ្លូវគឺតណ្ហាកាត់ចោលហើយ មានវដ្តៈគ្របសង្កត់បានហើយ ទ្រង់កន្លងនូវទុក្ខទាំងពួងបានហើយ បរិនិព្វានទៅហើយ កាលបើគេបញ្ញត្ត គប្បីបញ្ញត្តដោយភ្នែកណា ភ្នែកនោះមានដែរឬ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអតីតពុទ្ធបរិនិព្វានទៅហើយ ។ បេ ។ គប្បីបញ្ញត្ត ដោយអណ្តាតណា អណ្តាតនោះមានដែរឬ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអតីតពុទ្ធ ព្រះអង្គមានដំណើរឃើតឃូរគឺតណ្ហាកាត់ចោលហើយ មានផ្លូវគឺតណ្ហាកាត់ចោលហើយ មានវដ្តៈគ្របសង្កត់បានហើយ ទ្រង់កន្លងនូវទុក្ខទាំងពួងបានហើយ បរិនិព្វានទៅហើយ កាលបើគេបញ្ញត្ត គប្បីបញ្ញត្តដោយចិត្តណា ចិត្តនោះមានដែរឬ ។

[១០០] ម្នាលផគ្គុនៈ កាលដែលព្រះអតីតពុទ្ធ ព្រះអង្គមានដំណើរឃើតឃូរគឺតណ្ហាកាត់ចោលហើយ មានផ្លូវគឺតណ្ហាកាត់ចោលហើយ

បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ បញ្ញាបយមានោ បញ្ញ-
បេយ្យាតិ ។ បេ ។ ឯត្ថិ ខោ សា ផគ្គុន ជិវ្ហា យាយ
ជិវ្ហាយ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ
បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ បញ្ញាបយមានោ បញ្ញ-
បេយ្យ ។ បេ ។ ឯត្ថិ ខោ សោ ផគ្គុន មនោ យេន
មនេន អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ
បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ បញ្ញាបយមានោ បញ្ញ-
បេយ្យាតិ ។ ឥសមំ ។

គិលានវគ្គោ តតិយោ ។

## តស្សុទ្ទានំ

គិលានេន ទ្វេ វុត្តា
រាធេន អបរេ តយោ
អវិជ្ជាយ ច ទ្វេ វុត្តា
ភិក្ខុ លោកោ ច ផគ្គុនោតិ ។

មានវដ្តៈគ្របសង្កត់បានហើយ ទ្រង់កន្លងនូវទុក្ខទាំងពួងបានហើយ បរិ-និព្វានទៅហើយ កាលបើគេបញ្ញត្ត គប្បីបញ្ញត្តដោយក្អែកណា ក្អែកនោះមិនមានទេ ។ បេ ។ ម្នាលផគ្គុនៈ កាលដែលព្រះអតីតពុទ្ធ ព្រះអង្គមានដំណើរយឺតយូរ គឺតណ្ហាកាត់ចោលហើយ មានផ្លូវគឺតណ្ហាកាត់ចោលហើយ មានវដ្តៈគ្របសង្កត់បានហើយ ទ្រង់កន្លងនូវទុក្ខទាំងពួងបានហើយ បរិនិព្វានទៅហើយ កាលបើគេបញ្ញត្ត គប្បីបញ្ញត្ត ដោយអណ្តាតណា អណ្តាតនោះមិនមានទេ ។ បេ ។ ម្នាលផគ្គុនៈ កាលដែលព្រះអតីតពុទ្ធ ព្រះអង្គមានដំណើរយឺតយូរ គឺតណ្ហាកាត់ចោលហើយ មានផ្លូវគឺតណ្ហាកាត់ចោលហើយ មានវដ្តៈគ្របសង្កត់បានហើយ ទ្រង់កន្លងនូវទុក្ខទាំង-ពួងបានហើយ បរិនិព្វានទៅហើយ កាលបើគេបញ្ញត្ត គប្បីបញ្ញត្តដោយចិត្តណា ចិត្តនោះមិនមានទេ ។ ចប់សូត្រ ទី ១០ ។

ចប់ គិលានវគ្គ ទី ៣ ។

## ឧទ្ទាននៃគិលានវគ្គនោះ គឺ

និយាយអំពីភិក្ខុឈឺមាន ២ លើក អំពីព្រះរាធៈមានអាយុមាន ៣ លើក អំពីអវិជ្ជាមាន ២ លើក អំពីពួកភិក្ខុ ១ អំពីលោក ១ អំពីព្រះផគ្គុនៈមានអាយុ ១ ។

# ឆន្នវគ្គោ

[១០១] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច លោកោ លោកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ លោកោតិ វុច្ចតីតិ ។ យំ ខោ អានន្ទ បលោកធម្មំ អយំ វុច្ចតិ អរិយស្ស វិនយេ លោកោ ។ កិញ្ចានន្ទ បលោកធម្មំ ចក្ខុំ ខោ អានន្ទ បលោកធម្មំ រូបា បលោកធម្មា ចក្ខុវិញ្ញាណំ បលោកធម្មំ ចក្ខុសម្ផស្សោ បលោកធម្មោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ។ បេ ។ តម្បិ[១] បលោកធម្មំ ។ បេ ។ ជិវ្ហា បលោកធម្មា រសា បលោក-

១ ឱ. តម្បិទម្បលោកធម្មំ ។

# ឆន្នវគ្គ

[១០១] គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ពាក្យដែលគេតែងហៅថា លោក លោក បពិត្រព្រះអង្គដ៏ចម្រើន ដែលគេហៅថាលោក តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ របស់ណា មានសេចក្តីបែកធ្លាយជាធម្មតា នេះហៅថាលោកក្នុងអរិយវិន័យ ។ ម្នាលអានន្ទ របស់អ្វីដែលមានសេចក្តីបែកធ្លាយជាធម្មតា ម្នាលអានន្ទ ចក្ខុហ្នឹងឯងមានសេចក្តីបែកធ្លាយជាធម្មតា រូបមានសេចក្តីបែកធ្លាយជាធម្មតា ចក្ខុវិញ្ញាណ មានសេចក្តីបែកធ្លាយជាធម្មតា ចក្ខុសម្ផស្ស មានសេចក្តីបែកធ្លាយជាធម្មតា ទោះបីវេទនាណា ។ បេ ។ ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏មានសេចក្តីបែកធ្លាយជាធម្មតា ។ បេ ។ ជិវ្ហាមានសេចក្តីបែកធ្លាយជាធម្មតា រសមានសេចក្តីបែកធ្លាយ

ជម្មា ជិវ្ហាវិញ្ញាណំ បលោកជម្មំ ជិវ្ហាសម្ផស្សោ ប-
លោកជម្មោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ។ បេ ។
តម្បិ បលោកជម្មំ ។ បេ ។ មនោ បលោកជម្មោ ជម្មា
បលោកជម្មា មនោវិញ្ញាណំ បលោកជម្មំ មនោ-
សម្ផស្សោ បលោកជម្មោ យម្បិទំ មនោសម្ផស្សប្បច្ច-
យា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ
វា តម្បិ បលោកជម្មំ ។ យំ ខោ អានន្ទ បលោក-
ជម្មំ អយំ វុច្ចតិ អរិយស្ស វិនយេ លោកោតិ ។ បឋមំ ។

[១០២] អថខោ អាយស្មា អានន្ទោ ។ បេ ។
ភគវន្តំ ឯតទវោច សុញ្ញោ លោកោ សុញ្ញោ លោ-
កោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សុញ្ញោ
លោកោតិ វុច្ចតីតិ ។ យស្មា ច ខោ អានន្ទ
សុញ្ញំ អត្តេន វា អត្តនីយេន វា តស្មា សុញ្ញោ
លោកោតិ វុច្ចតិ ។ កិញ្ច អានន្ទ សុញ្ញំ អត្តេន វា

ជាធម្មតា ជិវ្ហាវិញ្ញាណ មានសេចក្តីបែកធ្លាយជាធម្មតា ជិវ្ហាសម្ផស្ស មានសេចក្តីបែកធ្លាយជាធម្មតា ទោះបីវេទនាណា ។ បេ ។ ព្រោះជិវ្ហា-សម្ផស្សជាបច្ច័យ វេទនានោះក៏មានសេចក្តីបែកធ្លាយជាធម្មតា ។ បេ ។ មនោមានសេចក្តីបែកធ្លាយជាធម្មតា ធម៌មានសេចក្តីបែកធ្លាយជាធម្មតា មនោវិញ្ញាណមានសេចក្តីបែកធ្លាយជាធម្មតា មនោសម្ផស្សមានសេចក្តីបែកធ្លាយជាធម្មតា ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ វេទនានោះក៏មានសេចក្តីបែកធ្លាយជាធម្មតា ។ ម្នាលអានន្ទ របស់ណា មានសេចក្តីបែកធ្លាយជាធម្មតា នេះហៅថា លោក ក្នុងអរិយវិន័យ ។ ចប់សូត្រ ទី ១ ។

[១០២] គ្រានោះឯង ព្រះអានន្ទមានអាយុ ។ បេ ។ ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ពាក្យដែលគេតែងហៅថា លោកសូន្យ ៗ បពិត្រព្រះអង្គដ៏ចម្រើន ដែលគេហៅថា លោកសូន្យ តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ ព្រោះហេតុតែ (របស់ទាំងអស់) សូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ហេតុនោះបានជាគេហៅថាលោកសូន្យ ។ ម្នាលអានន្ទ របស់អ្វីដែលសូន្យចាកខ្លួន

ឆន្នវគ្គោ ចតុត្ថោ

អត្តនីយេន វា ចក្ខុំ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនីយេន វា រូបា សុញ្ញា អត្តេន វា អត្តនីយេន វា ចក្ខុវិញ្ញាណំ សុញ្ញំ អត្តេន វា អត្តនីយេន វា ចក្ខុ-សម្ផស្សោ សុញ្ញោ អត្តេន វា អត្តនីយេន វា ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុ-ខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សុញ្ញំ អត្តេន វា អត្តនីយេន វា ។ យស្មា ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនីយេន វា តស្មា សុញ្ញោ លោកោតិ វុច្ចតីតិ ។ ទុតិយំ ។

[១០៣] ឯកមន្តំ និសិន្នោ ខោ អាយស្មា អា-នន្ទោ ។ បេ ។ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តំ កឹ មញ្ញសិ អានន្ទ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ

ឬចាកបរិក្ខាររបស់ខ្លួន ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន រូបសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ចក្ខុវិញ្ញាណសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ចក្ខុសម្ផស្សសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ។ បេ ។ ទោះបីវេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏សូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ។ ម្នាលអានន្ទ ព្រោះហេតុតែ (ខន្ធបញ្ចកៈ) សូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ហេតុនោះ បានជាហៅថាលោកសូន្យ ។ ចប់សូត្រ ទី ២ ។

[១០៣] លុះព្រះអានន្ទមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ។ បេ ។ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្តាប់ធម៌ណា របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតបង់នូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សូមព្រះមានព្រះភាគសម្តែងធម៌នោះដោយសង្ខេប ប្រោសខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលអានន្ទ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ

សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ជិវ្ហាវិញ្ញាណំ ជិវ្ហាសម្ផស្សោ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ

ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ បេ ។ ជិវ្ហាទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ជិវ្ហាវិញ្ញាណ ជិវ្ហាសម្ផស្ស ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះ ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា

១២៣

ឆន្នវគ្គោ ចតុត្ថោ

កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ អានន្ទ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផ-ស្សេបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្ម-ចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជា-នាតីតិ ។ តតិយំ ។

ឆន្នវគ្គ ទី ៤

គួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ព្រះអង្គ ។ ម្នាលអានន្ទ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងភ្នែកផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោ-សម្ផស្ស ជាបច្ច័យ ក៏រមែងនឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែការប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្ត ផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ចប់សូត្រ ទី ៣ ។

[១០៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ច សារីបុត្តោ អាយស្មា ច មហាចុន្ទោ អាយស្មា ច ឆន្នោ គិជ្ឈកូដេ បព្វតេ វិហរន្តិ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាចុន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាចុន្ទំ ឯតទវោច អាយាមាវុសោ ចុន្ទ យេនាយស្មា ឆន្នោ តេនុបសង្កមិស្សាម គិលានបុច្ឆកាតិ ។ ឯវមាវុសោតិ ខោ អាយស្មា មហាចុន្ទោ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសិ ។ អថខោ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាចុន្ទោ យេនាយស្មា ឆន្នោ តេនុបសង្កមឹសុ

[១០៤] សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ព្រះសារីបុត្តមានអាយុ ១ ព្រះមហាចុន្ទមានអាយុ ១ ព្រះឆន្នៈមានអាយុ ១ គង់លើភ្នំគិជ្ឈកូដ ។ សម័យនោះឯង ព្រះឆន្នៈមានអាយុ មានអាពាធប្រកបដោយទុក្ខ ឈឺធ្ងន់ ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុចេញអំពីទីពួនសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះមហាចុន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏បបួលព្រះមហាចុន្ទមានអាយុ យ៉ាងនេះថា នែអាវុសោចុន្ទ មក យើងនឹងទៅសួរជំងឺព្រះឆន្នៈមានអាយុ ។ ព្រះមហាចុន្ទមានអាយុ បានទទួលតបពាក្យព្រះសារីបុត្តមានអាយុថា ករុណា អាវុសោ ។ ទើបព្រះសារីបុត្តមានអាយុ និងព្រះមហាចុន្ទមានអាយុ ចូលទៅរកព្រះឆន្នៈមានអាយុ

ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹសុ ។ និសជ្ជ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ឆន្នំ ឯតទវោច កច្ចិ តេ អាវុសោ ឆន្ន ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។

[១០៥] ន មេ អាវុសោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ សេយ្យថាបិ អាវុសោ ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធនំ[១] អភិមត្ថេយ្យ ឯវមេវ ខោ មេ អាវុសោ អធិមត្តា វាតា មុទ្ធនិ ឧបហនន្តិ ។ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ។ បេ ។ នោ បដិក្កមោតិ ។ សេយ្យថាបិ អាវុសោ ពលវា បុរិសោ ទឡ្ហេន វរត្តក្ខណ្ឌេន សីសេ សីសវេឋំ ទទេយ្យ ឯវមេវ ខោ អាវុសោ អធិមត្តា វាតា សីសេ សីសវេទនា ។ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ។ បេ ។ នោ បដិក្កមោតិ ។

១ ឱ. មុទ្ធានំ ។ ម. មុទ្ធនិ ។

លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ លុះព្រះសារីបុត្តមានអាយុគង់ហើយ ទើបសួរព្រះឆន្នៈមានអាយុ ដូច្នេះថា ម្នាលអាវុសោឆន្នៈ សរីរយន្តរបស់អ្នក ល្មមអត់ទ្រាំបានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាធូរថយទៅ មិនចម្រើនឡើង មានតែស្រាកស្រាន្តទៅ មិនចម្រើនឡើងទេឬ ។

[១០៥] ព្រះឆន្នត្ថេរតបថា ម្នាលអាវុសោសារីបុត្ត សរីរយន្តរបស់ខ្ញុំមិនល្មមអត់ទ្រាំបានទេ មិនល្មមប្រព្រឹត្តទៅបានទេ (ព្រោះ) ទុក្ខវេទនារបស់ខ្ញុំដ៏ក្លៀវក្លា តែងចម្រើនឡើង មិនធូរថយទេ មានតែរឹតឡើងមិនស្បើយទេ ។ ម្នាលអាវុសោ បុរសមានកម្លាំង យកដែកស្រួចដ៏មុតមកចាក់លលាដ៍ក្បាល ដូចម្តេចមិញ ម្នាលអាវុសោ ខ្យល់ដ៏ក្រៃលែងចាក់ដោតក្បាលរបស់ខ្ញុំ ក៏ដូច្នោះដែរ ។ ម្នាលអាវុសោ ខ្ញុំមិនល្មមអត់ទ្រាំបានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានស្រួលទេ ។ បេ ។ មិនធូរថយទេ ។ ម្នាលអាវុសោ បុរសមានកម្លាំង យកចង្វាយព្រ័ត្រដ៏មាំ មកត្របែងក្បាល យ៉ាងណាមិញ ម្នាលអាវុសោ ខ្យល់ខ្លាំងហួសប្រមាណ សីសវេទនាកើតក្នុងសីសៈក៏យ៉ាងនោះឯង ។ ម្នាលអាវុសោ ខ្ញុំមិនល្មមអត់ទ្រាំបានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានទេ ។ បេ ។ មិនធូរថយទេ ។

១២៦



សេយ្យថាបិ អាវុសោ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ អាវុសោ អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ។ បេ ។ នោ បដិក្កមោតិ ។ សេយ្យថាបិ អាវុសោ ទ្វេ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានា ពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ សំបរិតាបេយ្យុំ ឯវមេវ ខោ មេ អាវុសោ អធិមត្តោ កាយស្មឹ ឌាហោ ។ ន មេ អាវុសោ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ សត្ថំ អាវុសោ សារីបុត្ត អាហរិស្សាមិ នាវកង្ខាមិ ជីវិតន្តិ អាយស្មា ឆន្នោ សត្ថំ អាហរេសិ ។

ម្នាលអាវុសោ បុរសអ្នកសម្លាប់គោ ឬកូនឈ្នួលអ្នកសម្លាប់គោ ដែលឈ្លាសវៃ អារពន្ទះពោះ(គោ) ដោយគ្រឿងសម្រាប់ពន្ទះគោដ៏មុត ដូចម្តេចមិញ ម្នាលអាវុសោ ខ្យល់ដ៏ក្រៃលែង អារពោះខ្ញុំក៏ដូច្នោះឯង ។ ម្នាលអាវុសោ ខ្ញុំមិនល្មមអត់ទ្រាំបានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានទេ ។ បេ ។ មិនបានស្រាកស្រាន្តទេ ។ ម្នាលអាវុសោ បុរសមានកម្លាំង ២ នាក់ ចាប់បុរសដែលមានកម្លាំងខ្សោយ ត្រង់ដើមដៃម្ខាងម្នាក់ ផ្អើរពោលលើរណ្តៅរងើកភ្លើង ដូចម្តេចមិញ ការក្តៅក្រហាយក្នុងកាយរបស់ខ្ញុំដ៏ក្រៃលែង ក៏ដូច្នោះឯង ។ ម្នាលអាវុសោ ខ្ញុំមិនល្មមអត់ទ្រាំបានទេ មិនល្មមឲ្យប្រព្រឹត្តទៅបានទេ (ព្រោះ) ទុក្ខវេទនាដ៏ក្លៀវក្លារបស់ខ្ញុំ តែងតែចម្រើនឡើង មិនធូរថយទេ មានតែរឹតឡើង មិនស្រាកស្រាន្តទេ ។ ម្នាលអាវុសោសារីបុត្ត ខ្ញុំនឹងយកគ្រឿងសស្ត្រា (មកសម្លាប់ខ្លួន) ខ្ញុំមិនចង់នៅរស់ទេ លុះព្រះឆន្នៈមានអាយុពោលដូច្នេះហើយ ក៏នាំយកគ្រឿងសស្ត្រាមក ។

ឆន្នវគ្គោ ចតុត្ថោ

[១០៦] យាបេតាយស្មា ឆន្នោ យាបេន្តំ មយំ អាយស្មន្តំ ឆន្នំ ឥច្ឆាម សចេ អាយស្មតោ ឆន្នស្ស នត្ថិ សប្បាយានិ ភោជនានិ អហំ អាយស្មតោ ឆន្នស្ស សប្បាយានិ ភោជនានិ បរិយេសិស្សាមិ សចេ អាយស្មតោ ឆន្នស្ស នត្ថិ សប្បាយានិ ភេសជ្ជានិ អហំ អាយស្មតោ ឆន្នស្ស សប្បាយានិ ភេសជ្ជានិ បរិយេសិស្សាមិ សចេ អាយស្មតោ ឆន្នស្ស នត្ថិ បដិរូបា ឧបដ្ឋាកា អហំ អាយស្មន្តំ ឆន្នំ ឧបដ្ឋហិស្សាមិ មា ច អាយស្មា ឆន្នោ សត្ថំ អាហរេសិ យាបេតាយស្មា ឆន្នោ យាបេន្តំ មយំ អាយស្មន្តំ ឆន្នំ ឥច្ឆាមាតិ ។ ន មេ អាវុសោ សារីបុត្ត នត្ថិ សប្បាយានិ ភោជនានិ អត្ថិ មេ សប្បាយានិ ភោជនានិ នបិ មេ នត្ថិ សប្បាយានិ ភេសជ្ជានិ អត្ថិ មេ សប្បាយានិ ភេសជ្ជានិ នបិ មេ នត្ថិ បដិរូបា ឧបដ្ឋាកា អត្ថិ មេ បដិរូបា ឧបដ្ឋាកា ។ អបិ ច មេ អាវុសោ

ឆន្នវគ្គ ទី ៤

[១០៦] ព្រះសារីបុត្តអង្វរថា សូមព្រះឆន្នៈមានអាយុ រស់នៅសិន យើងចង់ឲ្យព្រះឆន្នៈមានអាយុនៅរស់ បើព្រះឆន្នៈមានអាយុ មិនមានភោជនជាទីសប្បាយទេ ខ្ញុំនឹងស្វែងរកភោជនជាទីសប្បាយ ដើម្បីព្រះឆន្នៈមានអាយុ បើព្រះឆន្នៈមានអាយុមិនមានភេសជ្ជៈជាទីសប្បាយទេ ខ្ញុំនឹងស្វែងរកភេសជ្ជៈជាទីសប្បាយ ដើម្បីព្រះឆន្នៈមានអាយុ បើព្រះឆន្នៈមានអាយុមិនមានឧបដ្ឋាកដ៏សមគួរទេ ខ្ញុំនឹងបម្រើព្រះឆន្នៈមានអាយុ កុំឲ្យតែព្រះឆន្នៈមានអាយុ នាំយកគ្រឿងសស្ត្រាមក សូមព្រះឆន្នៈមានអាយុរស់នៅសិន (ព្រោះ) យើងចង់ឲ្យព្រះឆន្នៈមានអាយុនៅរស់ ។ ព្រះឆន្នត្ថេរតបថា ម្នាលអាវុសោសារីបុត្ត ខ្ញុំមិនមែនគ្មានភោជនជាទីសប្បាយទេ ខ្ញុំមានភោជនជាទីសប្បាយ មួយទៀត ខ្ញុំមិនមែនគ្មានភេសជ្ជៈជាទីសប្បាយទេ ខ្ញុំមានភេសជ្ជៈជាទីសប្បាយ មួយវិញទៀត ខ្ញុំមិនមែនគ្មានឧបដ្ឋាកដ៏សមគួរទេ ខ្ញុំមានឧបដ្ឋាកដ៏សមគួរ ។ ម្នាលអាវុសោ

សត្ថា បរិចិណ្ណោ ទីឃរត្តំ មនាបេនេវ នោ អមនាបេន ។ ឯតំ ហិ អាវុសោ សាវកស្ស បតិរូបំ យំ សត្ថារំ បរិចរេយ្យ មនាបេនេវ នោ អមនាបេន តំ អនុបវជ្ជំ ឆន្នោ ភិក្ខុ សត្ថំ អាហរិស្សតីតិ ឯវមេតំ អាវុសោ សារីបុត្ត ធារេហីតិ ។

[១០៧] បុច្ឆេយ្យាម មយំ អាយស្មន្តំ ឆន្នំ កញ្ចិទេវ ទេសំ សចេ អាយស្មា ឆន្នោ ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ បុច្ឆាវុសោ សារីបុត្ត សុត្វា វេទយាមាតិ[១] ។ ចក្ខុំ អាវុសោ ឆន្ន ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសិ ។ បេ ។ ជិវ្ហំ អាវុសោ ឆន្ន ជិវ្ហាវិញ្ញាណំ ជិវ្ហាវិញ្ញាណវិញ្ញាតព្វេ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសិ ។ បេ ។ មនំ អាវុសោ ឆន្ន មនោវិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសីតិ ។

១ ឱ. វេទិស្សាមាតិ ។

ទាំងព្រះសាស្តាសោត ខ្ញុំក៏បានបម្រើដោយសេចក្តីពេញចិត្តមកយូរហើយ មិនមែនដោយការមិនពេញចិត្តទេ ។ ម្នាលអាវុសោ សាវ័កត្រូវតែបម្រើព្រះសាស្តាដោយសេចក្តីគាប់ចិត្ត មិនត្រូវបម្រើដោយសេចក្តីមិនគាប់ចិត្តទេ អំពើនោះ ទើបជាការសមគួរដល់សាវ័ក នៃអាវុសោសារីបុត្ត អ្នកចូរចាំទុកដំណើរនុ៎ះយ៉ាងនេះថា ការនុ៎ះមិននៅទាក់ទាមទេ ឆន្នភិក្ខុមុខជានឹងនាំយកគ្រឿងសស្រ្តាមកផ្តាច់បង់ជីវិត ។

[១០៧] ព្រះសារីបុត្តនិយាយថា យើងនឹងសួរនូវហេតុនីមួយនឹងព្រះឆន្នៈមានអាយុ បើព្រះឆន្នៈមានអាយុបើកឱកាសឲ្យ ដើម្បីដោះស្រាយនូវប្រស្នា ។ ម្នាលអាវុសោសារីបុត្ត អ្នកចូរសួរចុះ យើងស្តាប់ហើយគង់នឹងដឹងបាន ។ ម្នាលអាវុសោឆន្នៈ អ្នកយល់នូវចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬ ។ បេ ។ ម្នាលអាវុសោឆន្នៈ អ្នកយល់នូវជិវ្ហា ជិវ្ហាវិញ្ញាណ ធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬ ។ បេ ។ ម្នាលអាវុសោឆន្នៈ អ្នកយល់មនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះឬ ។

១២៩

ឆន្នវគ្គោ ចតុត្ថោ

ចក្ខុំ អាវុសោ សារីបុត្ត ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណ-វិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមិ ។ បេ ។ ជិវ្ហំ អាវុសោ សារីបុត្ត ជិវ្ហាវិញ្ញាណំ ជិវ្ហាវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ។ បេ ។ មនំ អាវុសោ សារីបុត្ត មនោ-វិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេ-សោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមីតិ ។

[១០៨] ចក្ខុស្មឹ អាវុសោ ឆន្ន ចក្ខុវិញ្ញាណេ ចក្ខុវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ កឹ ទិស្វា កឹ អភិញ្ញាយ ចក្ខុំ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសិ ។ បេ ។ ជិវ្ហាយ អាវុសោ ឆន្ន ជិវ្ហា-វិញ្ញាណេ ជិវ្ហាវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ កឹ ទិស្វា កឹ អភិញ្ញាយ ជិវ្ហំ ជិវ្ហាវិញ្ញាណំ ជិវ្ហាវិញ្ញាណវិញ្ញា-តព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសិ ។ បេ ។ មនស្មឹ អាវុសោ ឆន្ន

ឆន្នវគ្គ ទី ៤

ម្នាលអាវុសោសារីបុត្ត ខ្ញុំយល់ចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ខ្ញុំយល់ជិវ្ហា ជិវ្ហាវិញ្ញាណ ធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ខ្ញុំយល់មនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។

[១០៨] ម្នាលអាវុសោឆន្នៈ អ្នកឃើញដូចម្តេច ដឹងដូចម្តេចក្នុងចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណ បានជាយល់ចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ បេ ។ ម្នាលអាវុសោឆន្នៈ អ្នកឃើញដូចម្តេច ដឹងដូចម្តេច ក្នុងជិវ្ហា ជិវ្ហា-វិញ្ញាណ ធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ បេ ។ ម្នាលអាវុសោ

មនោវិញ្ញាណេ មនោវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ កឹ ទិស្វា កឹ អភិញ្ញាយ មនំ មនោវិញ្ញាណំ មនោ-វិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសីតិ ។

[១០៩] ចក្ខុស្មឹ អាវុសោ សារីបុត្ត ចក្ខុវិញ្ញាណេ ចក្ខុវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ និព្វេទំ ទិស្វា និព្វេទំ អភិញ្ញាយ ចក្ខុំ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមិ ។ បេ ។ ជិវ្ហាយ អាវុសោ សារីបុត្ត ជិវ្ហា-វិញ្ញាណេ ជិវ្ហាវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ និព្វេទំ ទិ-ស្វា និព្វេទំ អភិញ្ញាយ ជិវ្ហំ ជិវ្ហាវិញ្ញាណំ ជិវ្ហាវិញ្ញាណ-វិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមិ ។ បេ ។ មនស្មឹ អាវុសោ សារី-បុត្ត មនោវិញ្ញាណេ មនោវិញ្ញាណវិញ្ញាតព្វេសុ ធម្មេ-សុ និព្វេទំ ទិស្វា និព្វេទំ អភិញ្ញាយ មនំ មនោវិញ្ញា-ណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោ-ហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមីតិ ។

ឆន្ទៈ អ្នកឃើញដូចម្តេច ដឹងដូចម្តេច ក្នុងមនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណ បានជាយល់មនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ដូច្នេះ ។

[១០៩] ម្នាលអាវុសោសារីបុត្ត ខ្ញុំឃើញនូវសេចក្តីរលត់ ដឹងនូវសេចក្តីរលត់ ក្នុងចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណ បានជាយល់ចក្ខុ ចក្ខុវិញ្ញាណ ធម៌ដែលត្រូវដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ខ្ញុំឃើញនូវសេចក្តីរលត់ ដឹងនូវសេចក្តីរលត់ ក្នុងជិវ្ហា ជិវ្ហាវិញ្ញាណ ធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណ បានជាយល់ជិវ្ហា ជិវ្ហាវិញ្ញាណ ធម៌ដែលត្រូវដឹងដោយជិវ្ហាវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ បេ ។ ម្នាលអាវុសោសារីបុត្ត ខ្ញុំឃើញនូវសេចក្តីរលត់ ដឹងនូវសេចក្តីរលត់ ក្នុងមនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោ-វិញ្ញាណ បានជាយល់មនោ មនោវិញ្ញាណ ធម៌ដែលត្រូវដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ដូច្នេះ ។

## ឆន្នវគ្គោ ចតុត្ថោ

[១១០] ឯវំ វុត្តេ អាយស្មា មហាចុន្ទោ អាយស្មន្តំ
ឆន្នំ ឯតទវោច តស្មាតិហាវុសោ ឆន្ន ឥទម្បិ តស្ស
ភគវតោ សាសនំ និច្ចកប្បំ សាធុកំ មនសិកាតព្វំ
និស្សិតស្ស ចលិតំ អនិស្សិតស្ស ចលិតំ នត្ថិ ចលិតេ
អសតិ បស្សទ្ធិ ហោតិ បស្សទ្ធិយា សតិ នន្ទិ ន ហោតិ
នន្ទិយា[១] អសតិ អាគតិគតិ ន ហោតិ អាគតិគតិយា
អសតិ ចុតូបបាតោ ន ហោតិ ចុតូបបាតេ អសតិ នេ-
វិធ ន ហុរំ ន ឧភយមន្តរេន ឯសេវន្តោ ទុក្ខស្សាតិ ។
អថខោ អាយស្មា ច សារីបុត្តោ អាយស្មា ច មហា-
ចុន្ទោ អាយស្មន្តំ ឆន្នំ ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋា-
យាសនា បក្កមឹសុ ។ អថខោ អាយស្មា ឆន្នោ អចិ-
របក្កន្តេសុ តេសុ អាយស្មន្តេសុ សត្ថំ អាហរេសិ ។

---

១ ឱ. ម. នតិ ន ហោតិ នតិយា ។

ឆន្នវគ្គ ទី ៤

[១១០] កាលព្រះឆន្នៈនិយាយយ៉ាងនេះហើយ ព្រះមហាចុន្ទមានអាយុ បាននិយាយនឹងព្រះឆន្នៈមានអាយុដូច្នេះថា ម្នាលអាវុសោឆន្នៈ បើដូច្នោះ អ្នកគួរយកចិត្តទុកដាក់ឲ្យប្រពៃ ចំពោះសាសនារបស់ព្រះមានព្រះភាគនោះ អស់កាលជានិច្ចចុះ បុគ្គល ដែលតណ្ហាមានះទិដ្ឋិអាស្រ័យនៅហើយ រមែងមានសេចក្តីកម្រើក បុគ្គល ដែលមិនមានតណ្ហាមានះទិដ្ឋិអាស្រ័យនៅ រមែងមិនមានសេចក្តីកម្រើកទេ កាលបើមិនមានសេចក្តីកម្រើក ទើបមានសេចក្តីស្ងប់ កាលបើមានសេចក្តីស្ងប់ ទើបមិនមានសេចក្តីត្រេកត្រអាល កាលបើមិនមានសេចក្តីត្រេកត្រអាល ដំណើរមកនិងដំណើរទៅ ក៏មិនមាន កាលបើមិនមានដំណើរមកនិងដំណើរទៅ ចុតិនិងបដិសន្ធិក៏មិនមាន កាលបើចុតិនិងបដិសន្ធិមិនមាន ទើបមិនមានកិច្ចអ្វី ក្នុងលោកនេះ មិនមានក្នុងលោកខាងមុខ មិនមានក្នុងចន្លោះនៃលោកទាំងពីរ នេះឯង ជាទីបំផុតនៃទុក្ខ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ និងព្រះមហាចុន្ទមានអាយុ លុះទូន្មានព្រះឆន្នៈមានអាយុ ដោយឱវាទនេះហើយ ទើបក្រោកអំពីអាសនៈចៀសចេញទៅ ។ គ្រានោះឯង ព្រះឆន្នៈមានអាយុ កាលដែលព្រះថេរៈមានអាយុទាំងនោះ និមន្តចេញទៅមិនយូរប៉ុន្មាន ក៏នាំយកគ្រឿងសស្ត្រាមក ។

[១១១] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច អាយស្មតា ភន្តេ ឆន្នេន សត្ថំ អាហរិតំ តស្ស កា គតិ កោ អភិសម្បរាយោ-តិ ។ ននុ តេ សារីបុត្ត ឆន្នេន ភិក្ខុនា សម្មុខាយេវ អនុបវជ្ជតា ព្យាកតាតិ ។ អត្ថិ ភន្តេ បុព្វវិជ្ជនំ នាម វជ្ជិគ្គាមោ តត្ថាយស្មតោ ឆន្នស្ស មិត្តកុលានិ សុហជ្ជ-កុលានិ ឧបវជ្ជកុលានីតិ ។ ហោន្តិ ហេតេ សារីបុត្ត ឆន្នស្ស ភិក្ខុនោ មិត្តកុលានិ សុហជ្ជកុលានិ ឧ-បវជ្ជកុលានីតិ ។ ន ខោ បនាហំ សារីបុត្ត ឯត្តាវតា សឧបវជ្ជោតិ វទាមិ ។ យោ ខោ សារីបុត្ត ឥមញ្ច កា-យំ និក្ខិបតិ អញ្ញញ្ច កាយំ ឧបាទិយតិ តមហំ សឧ-បវជ្ជោតិ វទាមិ ។ តំ ឆន្នស្ស ភិក្ខុនោ នត្ថិ អនុបវជ្ជំ

[១១១] គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឆន្នៈមានអាយុ បាននាំយកគ្រឿងសស្ត្រាមកហើយ តើព្រះឆន្នៈមានអាយុនោះ មានគតិដូចម្តេច មានបរលោកដូចម្តេច ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ក្រែងឆន្នភិក្ខុបានដោះស្រាយការដែលមិននៅទាក់ទាម ក្នុងទីចំពោះមុខរបស់អ្នករួចហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មានស្រុកក្នុងដែនវជ្ជីឈ្មោះបុព្វវិជ្ជនៈ ក្នុងស្រុកនោះឯង ព្រះឆន្នៈមានអាយុ មានត្រកូលជាមិត្ត ត្រកូលជាសំឡាញ់ត្រកូលដែលនៅជាប់ទាក់ទាម (គួរចូលទៅរក) ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលសារីបុត្ត ឆន្នភិក្ខុ មានត្រកូលជាមិត្ត ត្រកូលជាសំឡាញ់ ត្រកូលដែលនៅជាប់ទាក់ទាមនុ៎ះ ពិតមែន ។ ម្នាលសារីបុត្ត តែតថាគតមិនឲ្យឈ្មោះថា ជាអ្នកប្រកបដោយការទាក់ទាមព្រោះហេតុប៉ុណ្ណោះឡើយ ។ ម្នាលសារីបុត្ត លុះតែអ្នកណាមួយ ដាក់ចុះនូវកាយនេះផង កាន់យកនូវកាយដទៃផង ទើបតថាគតហៅអ្នកនោះថាជាអ្នកប្រកបដោយការទាក់ទាម ។ ការណ៍នោះមិនមានដល់ឆន្នភិក្ខុទេ

ឆន្នវគ្គោ ចតុត្ថោ

ឆន្នេន ភិក្ខុនា សត្ថំ អាហារិតន្តិ ឯវមេតំ សារីបុត្ត ធារេហីតិ ។ ចតុត្ថំ ។

[១១២] អថខោ អាយស្មា បុណ្ណោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា បុណ្ណោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ សន្តិ ខោ បុណ្ណ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ បុណ្ណាតិ វទាមិ ។ បេ ។ សន្តិ ខោ បុណ្ណ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ បុណ្ណ មនោវិញ្ញេយ្យា ធម្មា

ឆន្នភិក្ខុ បាននាំយកគ្រឿងសស្ត្រាមក មិនមានការទាក់ទាមគឺមិនមានបដិសន្ធិទេ ម្នាលសារីបុត្ត ហេតុនោះ អ្នកចូរចាំទុកនូវដំណើរនុ៎ះយ៉ាងនេះចុះ ។ ចប់សូត្រ ទី ៤ ។

[១១២] គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះបុណ្ណៈមានអាយុគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគសម្ដែងធម៌ ដោយសង្ខេប ប្រោសខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ បានស្ដាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស បញ្ជូនចិត្តទៅរកព្រះនិព្វាន ។ ព្រះសម្ពុទ្ធត្រាស់ថា ម្នាលបុណ្ណៈ រូបដែលត្រូវដឹងបានដោយចក្ខុ ជាទីប្រាថ្នា ជាទីរីករាយ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ មានពិត បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តនឹងរូបនោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តនឹងរូបនោះ សេចក្ដីរីករាយរមែងកើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ព្រោះតែកើតសេចក្ដីរីករាយ ទើបកើតទុក្ខ ។ បេ ។ ម្នាលបុណ្ណៈ រសដែលត្រូវដឹងដោយអណ្ដាត ។ បេ ។ ម្នាលបុណ្ណៈ ធម៌ដែលត្រូវដឹងដោយមនោ

ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ បុណ្ណាតិ វទាមិ ។

[១១៣] សន្តិ ខោ បុណ្ណ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ និរុជ្ឈតិ នន្ទិ នន្ទិនិរោធា ទុក្ខនិរោធោ បុណ្ណាតិ វទាមិ ។ បេ ។ សន្តិ ច ខោ បុណ្ណ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ

ជាទីប្រាថ្នា ជាទីរីករាយ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ មានពិត បើភិក្ខុត្រេកអរ សរសើរ ជាប់ចិត្តនឹងធម៌នោះ កាលភិក្ខុនោះ ត្រេកអរ សរសើរ ជាប់ចិត្តនឹងធម៌នោះ សេចក្តីរីករាយរមែងកើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ព្រោះតែកើតសេចក្តីរីករាយ ទើបកើតទុក្ខ ។

[១១៣] ម្នាលបុណ្ណៈ រូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីរីករាយ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ មានពិត បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងរូបនោះទេ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងរូបនោះ សេចក្តីរីករាយ រមែងរលត់ ម្នាលបុណ្ណៈ តថាគតពោលថា លុះតែរលត់សេចក្តីត្រេកអរ ទើបទុក្ខរលត់ ។ បេ ។ ម្នាលបុណ្ណៈ ធម៌ដែលត្រូវដឹងដោយមនោ ជាទីប្រាថ្នា ជាទីរីករាយ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីត្រេកអរ មានពិត បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនជាប់ចិត្តនឹងធម៌នោះទេ កាលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនជាប់ចិត្ត

ឆន្នវគ្គោ ចតុត្ថោ

អនជ្ឈោសាយ តិដ្ឋតោ និរុជ្ឈតិ នន្ទិ នន្ទិនិរោធា ទុក្ខនិរោធោ បុណ្ណាតិ វទាមិ ។ ឥមិនា ត្វំ បុណ្ណ មយា សង្ខិត្តេន ឱវាទេន ឱវទិតោ កតមស្មឹ ជនបទេ វិហរិស្សសីតិ ។ អត្ថិ ភន្តេ សុនាបរន្តោ នាម ជនបទោ តត្ថាហំ វិហរិស្សាមីតិ ។

[១១៤] ចណ្ឌា ខោ បុណ្ណ សុនាបរន្តកា មនុស្សា ផរុសា ខោ បុណ្ណ សុនាបរន្តកា មនុស្សា សចេ តំ បុណ្ណ សុនាបរន្តកា មនុស្សា អក្កោសិស្សន្តិ បរិភាសិស្សន្តិ តត្រ តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មំ ភន្តេ សុនាបរន្តកា មនុស្សា អក្កោសិស្សន្តិ បរិភាសិស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ បាណិនា បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។ សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា

នឹងធម៌នោះ សេចក្ដីរីករាយ រមែងរលត់ ម្នាលបុណ្ណៈ តថាគតពោលថា ទាល់តែរលត់សេចក្ដីរីករាយ ទើបទុក្ខរលត់ ។ ម្នាលបុណ្ណៈ អ្នកឯងតថាគតបានទូន្មាន ដោយឱវាទសង្ខេបនេះហើយ តើនឹងនៅក្នុងជនបទណា ។ ព្រះបុណ្ណត្ថេរក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មានជនបទ ១ ឈ្មោះសុនាបរន្តៈ ខ្ញុំព្រះអង្គនឹងនៅក្នុងសុនាបរន្តជនបទនោះ ។

[១១៤] ព្រះមានបុណ្យត្រាស់ថា ម្នាលបុណ្ណៈ ពួកមនុស្សនៅក្នុងសុនាបរន្តជនបទ កាច ៗ ណាស់ ម្នាលបុណ្ណៈ ពួកមនុស្សក្នុងសុនាបរន្តជនបទរឹងរូសណាស់ ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងជេរប្រទេចអ្នក ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិតដូចម្ដេចក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុសុនាបរន្ទតជនបទ នឹងជេរប្រទេចខ្ញុំព្រះអង្គ ៗ នឹងមានគំនិតក្នុងដំណើរនោះយ៉ាងនេះថា ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលល្អដែរ ព្រោះថាមនុស្សទាំងអម្បាលនេះមិនប្រហារខ្ញុំព្រះអង្គដោយដៃទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ។ ម្នាលបុណ្ណៈ បើពួកមនុស្សក្នុង

បាណិនា បហារំ ទស្សន្តិ តត្រ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ[១] ភន្តេ សុនាបរន្តកា មនុស្សា បាណិនា បហារំ ទស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ លេឌ្ឌុនា បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។ សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា លេឌ្ឌុនា បហារំ ទស្សន្តិ តត្រ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនាបរន្តកា មនុស្សា លេឌ្ឌុនា បហារំ ទស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ ទណ្ឌេន បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។ សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា ទណ្ឌេន បហារំ ទស្សន្តិ

១ ឱ. ម. សចេ ភន្តេ ។

សុនាបរន្តជនបទ នឹងប្រហារអ្នកដោយដៃ តើអ្នកនឹងមានគំនិតដូចម្តេចវិញក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយដៃ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនោះយ៉ាងនេះថា ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលល្អដែរ ព្រោះថាមនុស្សទាំងអម្បាលនេះ មិនប្រហារខ្ញុំព្រះអង្គដោយដុំដីទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ។ ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយដុំដី តើអ្នកនឹងមានគំនិតដូចម្តេចវិញក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយដុំដី ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនោះ យ៉ាងនេះថា ពួកមនុស្សក្នុងសុនាបរន្តជនបទនេះ ស្រួលដែរ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះស្រួលល្អដែរ ព្រោះថាមនុស្សទាំងអម្បាលនេះ មិនប្រហារខ្ញុំព្រះអង្គដោយដំបងទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះយ៉ាងនេះឯង ។ ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយដំបង

១៣៧

ឆន្នវគ្គោ ចតុត្ថោ

តត្រ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនាបរន្តកា មនុស្សា ទណ្ឌេន បហារំ ទស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ សត្ថេន បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។ សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា សត្ថេន បហារំ ទស្សន្តិ តត្រ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ ស-ចេ មេ ភន្តេ សុនាបរន្តកា មនុស្សា សត្ថេន បហារំ ទស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនា-បរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ តិណ្ហេន សត្ថេន ជីវិតា វោរោបេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

ឆន្នវគ្គ ទី ៤

ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិតដូចម្តេច ក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយដំបង ខ្ញុំព្រះអង្គនឹងមានគំនិត ក្នុងដំណើរនោះយ៉ាងនេះថា ពួកមនុស្សក្នុងសុនាបរន្តជនបទនេះស្រួលដែរ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះស្រួលល្អដែរ ព្រោះថា មនុស្សទាំងអម្បាលនេះ មិនប្រហារខ្ញុំព្រះអង្គដោយគ្រឿងសស្ត្រាទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ។ ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយគ្រឿងសស្ត្រា ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិតដូចម្តេចក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយគ្រឿងសស្ត្រា ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនោះយ៉ាងនេះថា ពួកមនុស្សក្នុងសុនាបរន្តជនបទនេះស្រួលដែរ ពួកមនុស្សក្នុងសុនាបរន្តជនបទនេះស្រួលល្អដែរ ព្រោះថាមនុស្សទាំងអម្បាលនេះ មិនប្រហារជីវិតខ្ញុំព្រះអង្គ ដោយគ្រឿងសស្ត្រាដ៏មុតទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង ។

[១១៥] សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា តិណ្ហេន សត្ថេន ជីវិតា វោរោបេស្សន្តិ តត្រ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនាបរន្តកា មនុស្សា តិណ្ហេន សត្ថេន ជីវិតា វោរោ-បេស្សន្តិ តត្រ មេ ឯវំ ភវិស្សតិ សន្តិ ខោ តស្ស ភគវតោ សាវកា កាយេន ច ជីវិតេន ច អដ្ដិយ-មានា ហរាយមានា ជិគុច្ឆមានា សត្ថហារកំ បរិយេ-សន្តិ តំ មេ ឥទំ អបរិយិដ្ឋញ្ញេវ សត្ថហារកំ លទ្ធន្តិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។ សាធុ សាធុ បុណ្ណ សក្ខិស្សសិ ត្វំ បុណ្ណ ឥមិនា ទមូបសមេន សមន្នាគតោ សុនាបរន្តស្មឹ ជនបទេ វត្ថុំ យស្សទានិ ត្វំ បុណ្ណ កាលំ មញ្ញសីតិ ។

[១១៥] ម្នាលបុណ្ណៈ បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងយកគ្រឿងសស្ត្រាដ៏មុតមកផ្តាច់ជីវិតរបស់អ្នក ម្នាលបុណ្ណៈ តើអ្នកនឹងមានគំនិតដូចម្តេច ក្នុងដំណើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើពួកមនុស្សក្នុងសុនាបរន្តជនបទ នឹងយកគ្រឿងសស្ត្រាដ៏មុត មកផ្តាច់ជីវិតរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនោះយ៉ាងនេះថា ពួកសាវ័ករបស់ព្រះមានបុណ្យនោះ ដែលនឿយណាយ ធុញទ្រាន់ ខ្ពើមឆ្អើម ចំពោះកាយនិងជីវិត ហើយស្វែងរកបុគ្គលអ្នកសម្លាប់ដោយគ្រឿងសស្ត្រាក៏មាន ខ្ញុំព្រះអង្គបានអ្នកសម្លាប់ដោយគ្រឿងសស្ត្រានោះ ដែលមិនបាច់ស្វែងរកសោះទេ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនុ៎ះ យ៉ាងនេះឯង បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងមានគំនិតក្នុងដំណើរនោះ យ៉ាងនេះឯង ។ ម្នាលបុណ្ណៈ ប្រពៃហើយ ប្រពៃហើយ ម្នាលបុណ្ណៈ អ្នកប្រកបដោយសេចក្តីស្ងប់រម្ងាប់គឺសេចក្តីអត់ធន់នេះ អាចនឹងនៅក្នុងសុនាបរន្តជនបទបាន ម្នាលបុណ្ណៈ ចូរអ្នកសម្គាល់នូវកាលដ៏គួរ (នឹងទៅ) ក្នុងកាលឥឡូវនេះចុះ ។

១៣៩

## ឆន្នវគ្គោ ចតុត្ថោ

[១១៦] អថខោ អាយស្មា បុណ្ណោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរំ អាទាយ យេន សុនាបរន្តោ ជនបទោ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សុនាបរន្តោ ជនបទោ តទវសរិ ។ តត្រ សុទំ អាយស្មា បុណ្ណោ សុនាបរន្តស្មឹ ជនបទេ វិហរតិ ។ អថខោ អាយស្មា បុណ្ណោ តេនេវ អន្តរវស្សេន បញ្ចមត្តានិ ឧបាសកសតានិ បដិវេទេសិ តេនេវ អន្តរវស្សេន តិស្សោ វិជ្ជា សច្ឆាកាសិ តេនេវ អន្តរវស្សេន បរិនិព្វាយិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យោ សោ ភន្តេ បុណ្ណោ នាម កុលបុត្តោ ភគវតា សង្ខិត្តេន ឱវាទេន ឱវទិតោ សោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ បណ្ឌិតោ ភិក្ខវេ បុណ្ណោ កុលបុត្តោ អហោសិ សច្ចវាទី ធម្មស្សានុធម្មំ

ឆន្នវគ្គ ទី ៤

[១១៦] គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចរៀបចំសេនាសនៈ ហើយប្រដាប់ដោយបាត្រនិងចីវរ ចេញទៅកាន់ចារិកក្នុងសុនាបរន្តជនបទ កាលលោកចេញទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់សុនាបរន្តជនបទ ។ បានឮថា ព្រះបុណ្ណៈមានអាយុគង់នៅក្នុងសុនាបរន្តជនបទនោះ ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ប្រោសពួកឧបាសកបានប្រមាណ ៥០០ នាក់ ខាងក្នុងវស្សានោះឯង ទាំងបានធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ខាងក្នុងវស្សានោះដែរ ហើយបរិនិព្វានខាងក្នុងវស្សានោះតែម្តង ។ វេលានោះ ពួកភិក្ខុច្រើនរូប នាំគ្នាចូលទៅគាល់ព្រះមានបុណ្យ លុះភិក្ខុទាំងនោះគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានបុណ្យ ដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស កុលបុត្តឈ្មោះបុណ្ណៈ ដែលព្រះអង្គបានទូន្មានដោយឱវាទសង្ខេប ឥឡូវនេះ លោកធ្វើមរណកាលហើយ លោកមានគតិដូចម្តេច មានបរលោកដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តឈ្មោះបុណ្ណៈ ជាបណ្ឌិត ជាអ្នកនិយាយពិត មិនបៀតបៀននូវធម៌

ន ច[១] ធម្មាធិករណំ វិហេសេសិ បរិនិព្ពុតោ ភិក្ខវេ បុណ្ណោ កុលបុត្តោតិ ។ បញ្ចមំ ។

[១០៧] អថខោ អាយស្មា ពាហិយោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ពាហិយោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តំ កឹ មញ្ញសិ ពាហិយ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ

១ ឱ. ន ច មំ ។

តាមសមគួរដល់ធម៌ផង មិនបៀតបៀន នូវធម្មាធិករណ៍ផង ម្នាលភិក្ខុទាំងឡាយ កុលបុត្តឈ្មោះបុណ្ណៈ បរិនិព្វានហើយ ។ ចប់សូត្រ ទី ៥ ។

[១១៧] គ្រានោះឯង ព្រះពាហិយៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះពាហិយៈមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ បានស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាលពាហិយៈ អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។ រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស

១៤១



។ បេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ពាហិយ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ឆន្នវគ្គ ទី ៤

។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ តើវេទនានោះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរនឹងយល់របស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។ ម្នាលពាហិយៈ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ រមែងនឿយណាយនឹងវេទនានោះ កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[១១៨] អថខោ អាយស្មា ពាហិយោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា ពាហិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តា-យាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ពាហិ-យោ អរហតំ អហោសីតិ ។ ឆដ្ឋំ ។

[១១៨] គ្រានោះឯង ព្រះពាហិយៈមានអាយុ ត្រេកអរ រីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ លំដាប់នោះ ព្រះពាហិយៈមានអាយុ ជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់សម្រេច ដោយប្រាជ្ញាដ៏ប្រសើរខ្លួនឯង ក្នុងបច្ចុប្បន្ន នូវទីបំផុតនៃព្រហ្មចរិយធម៌ដ៏ប្រសើរ ដែលជាទីត្រូវការរបស់ពួកកុលបុត្តអ្នកចេញចាកផ្ទះ ហើយបួសដោយប្រពៃ ក៏បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះពាហិយៈមានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រទី ៦ ។

១៤៣

ឆន្ទវគ្គោ ចតុត្ថោ

[១១៩] ឯជា ភិក្ខវេ រោគោ ឯជា គណ្ឌោ ឯជា សល្លំ ។ តស្មាតិហ ភិក្ខវេ តថាគតោ អនេជោ វិហរតិ វីតសល្លោ ។ តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ អនេជោ វិហរេយ្យំ វីតសល្លោតិ ។ ចក្ខុំ ន មញ្ញេយ្យ ចក្ខុស្មឹ ន មញ្ញេយ្យ ចក្ខុតោ ន មញ្ញេយ្យ ចក្ខុំ មេតិ ន មញ្ញេយ្យ រូបេ ន មញ្ញេយ្យ រូបេសុ ន មញ្ញេយ្យ រូបតោ ន មញ្ញេយ្យ រូបា មេតិ ន មញ្ញេយ្យ ចក្ខុវិញ្ញាណំ ន មញ្ញេយ្យ ចក្ខុវិញ្ញាណស្មឹ ន មញ្ញេយ្យ ចក្ខុវិញ្ញាណតោ ន មញ្ញេយ្យ ចក្ខុវិញ្ញាណំ មេតិ ន មញ្ញេយ្យ ចក្ខុសម្ផស្សំ ន មញ្ញេយ្យ ចក្ខុសម្ផស្ស-ស្មឹ ន មញ្ញេយ្យ ចក្ខុសម្ផស្សតោ ន មញ្ញេយ្យ ចក្ខុសម្ផស្សោ មេតិ ន មញ្ញេយ្យ យម្បិទំ ចក្ខុ-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តម្មេតិ ន មញ្ញេយ្យ ។ សោតំ ន មញ្ញេយ្យ ។ ឃានំ ន មញ្ញេយ្យ ។ ជិវ្ហំ ន មញ្ញេយ្យ

## ឆន្នវគ្គ ទី ៤

[១១៩] ម្នាលភិក្ខុទាំងឡាយ តណ្ហា (ជាគ្រឿងញាប់ញ័រ) ជារោគ តណ្ហាជាបូស តណ្ហាជាសរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងលោកនេះ តថាគតមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ប្រាសចាកសរគឺតណ្ហាហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ បើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ប្រាសចាកសរគឺតណ្ហា ។ ភិក្ខុនោះ មិនត្រូវប្រកាន់ចក្ខុ មិនត្រូវប្រកាន់ក្នុងចក្ខុ មិនត្រូវប្រកាន់អំពីចក្ខុ មិនត្រូវប្រកាន់ថាចក្ខុរបស់អញឡើយ មិនត្រូវប្រកាន់រូប មិនត្រូវប្រកាន់ក្នុងរូប មិនត្រូវប្រកាន់អំពីរូប មិនត្រូវប្រកាន់ថារូបរបស់អញឡើយ មិនត្រូវប្រកាន់ចក្ខុវិញ្ញាណ មិនត្រូវប្រកាន់ក្នុងចក្ខុវិញ្ញាណ មិនត្រូវប្រកាន់អំពីចក្ខុវិញ្ញាណ មិនត្រូវប្រកាន់ថាចក្ខុវិញ្ញាណរបស់អញឡើយ មិនត្រូវប្រកាន់ចក្ខុសម្ផស្ស មិនត្រូវប្រកាន់ក្នុងចក្ខុសម្ផស្ស មិនត្រូវប្រកាន់អំពីចក្ខុសម្ផស្ស មិនត្រូវប្រកាន់ថាចក្ខុសម្ផស្សរបស់អញឡើយ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិនត្រូវប្រកាន់ថាវេទនានោះរបស់អញឡើយ ។ មិនត្រូវប្រកាន់សោតៈ ។ មិនត្រូវប្រកាន់ឃានៈ ។ មិនត្រូវប្រកាន់ជិវ្ហា

ជិវ្ហាយ ន មញ្ញេយ្យ ជិវ្ហាតោ ន មញ្ញេយ្យ ជិវ្ហា មេតិ ន មញ្ញេយ្យ រសេ ន មញ្ញេយ្យ ជិវ្ហាវិញ្ញាណំ ន មញ្ញេយ្យ ជិវ្ហាសម្ផស្សំ ន មញ្ញេយ្យ យម្បិទំ ជិវ្ហា-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តម្មេតិ ន មញ្ញេយ្យ ។ កាយំ ន មញ្ញេយ្យ ។ មនំ ន មញ្ញេយ្យ មនស្មឹ ន មញ្ញេយ្យ មនតោ ន មញ្ញេយ្យ មនោ មេតិ ន មញ្ញេយ្យ ធម្មេ ន មញ្ញេយ្យ មនោវិញ្ញាណំ មនោ-សម្ផស្សំ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តម្មេតិ ន មញ្ញេយ្យ ។ សព្វំ ន មញ្ញេយ្យ សព្វស្មឹ ន មញ្ញេយ្យ សព្វតោ ន មញ្ញេយ្យ សព្វំ មេតិ ន មញ្ញេយ្យ ។ សោ ឯវំ អមញ្ញមានោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្ស-តិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ

មិនត្រូវប្រកាន់ក្នុងជិវ្ហា មិនត្រូវប្រកាន់អំពីជិវ្ហា មិនត្រូវប្រកាន់ថា ជិវ្ហារបស់អញឡើយ មិនត្រូវប្រកាន់រស មិនត្រូវប្រកាន់ជិវ្ហាវិញ្ញាណ មិនត្រូវប្រកាន់ជិវ្ហាសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិនត្រូវប្រកាន់ថាវេទនានោះរបស់អញឡើយ ។ មិនត្រូវប្រកាន់កាយ ។ មិនត្រូវប្រកាន់មនោ មិនត្រូវប្រកាន់ក្នុងមនោ មិនត្រូវប្រកាន់អំពីមនោ មិនត្រូវប្រកាន់ថាមនោរបស់អញឡើយ មិនត្រូវប្រកាន់ធម៌ មនោវិញ្ញាណ មនោសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិនត្រូវប្រកាន់ថា វេទនានោះរបស់អញឡើយ ។ មិនត្រូវប្រកាន់វត្ថុទាំងពួង មិនត្រូវប្រកាន់ក្នុងវត្ថុទាំងពួង មិនត្រូវប្រកាន់អំពីវត្ថុទាំងពួង មិនត្រូវប្រកាន់ថាវត្ថុទាំងពួងរបស់អញឡើយ ។ កាលភិក្ខុនោះ មិនប្រកាន់យ៉ាងនេះ រមែងមិនក្តួចកាន់នូវរបស់បន្តិចបន្តួចក្នុងលោក កាលបើមិនក្តួចកាន់ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត រមែងរលត់កិលេសចំពោះខ្លួនឯង ហើយដឹងច្បាស់ថា ជាតិអស់ហើយ

វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ សត្តមំ ។

[១២០] ឯជា ភិក្ខវេ រោគោ ឯជា គណ្ឌោ ឯជា សល្លំ ។ តស្មាតិហ ភិក្ខវេ តថាគតោ អនេជោ វិហរតិ វីតសល្លោ ។ តស្មាតិហ ភិក្ខវេ ភិក្ខុ ចេបិ អាកង្ខេយ្យ អនេជោ វិហរេយ្យំ វីតសល្លោតិ ។ ចក្ខុំ ន មញ្ញេយ្យ ចក្ខុស្មឹ ន មញ្ញេយ្យ ចក្ខុតោ ន មញ្ញេយ្យ ចក្ខុំ មេតិ ន មញ្ញេយ្យ រូបេ ន មញ្ញេយ្យ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សំ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តម្មេតិ ន មញ្ញេយ្យ ។ យំ ហិ ភិក្ខវេ មញ្ញតិ យស្មឹ មញ្ញតិ យតោ មញ្ញតិ យំ មេតិ មញ្ញតិ

មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បី សោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៧ ។

[១២០] ម្នាលភិក្ខុទាំងឡាយ តណ្ហាជារោគ តណ្ហាជាបូស តណ្ហាជាសរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងលោក នេះ តថាគតមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ប្រាសចាកសរគឺតណ្ហា ហើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ ប្រសិនបើភិក្ខុប្រាថ្នាថា សូមឲ្យអាត្មាអញ មិនមានតណ្ហាជាគ្រឿងញាប់ ញ័រ ប្រាសចាកសរគឺតណ្ហា ។ ភិក្ខុមិនត្រូវប្រកាន់ចក្ខុ មិនត្រូវប្រកាន់ ក្នុងចក្ខុ មិនត្រូវប្រកាន់អំពីចក្ខុ មិនត្រូវប្រកាន់ថា ចក្ខុរបស់អញឡើយ មិនត្រូវប្រកាន់រូប ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស វេទនាណា ជាសុខ ក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្ស ជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិនត្រូវប្រកាន់ថា វេទនានោះរបស់អញ ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាភិក្ខុប្រកាន់របស់ណា ប្រកាន់ ក្នុងរបស់ណា ប្រកាន់អំពីរបស់ណា ប្រកាន់ថា របស់ណារបស់អញ

តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិនន្ទតិ ។ បេ ។ ជិវ្ហំ ន មញ្ញេយ្យ ជិវ្ហាយ ន មញ្ញេយ្យ ជិវ្ហាតោ ន មញ្ញេយ្យ ជិវ្ហា មេតិ ន មញ្ញេយ្យ រសេ ន មញ្ញេយ្យ ជិវ្ហាវិញ្ញាណំ ជិវ្ហាសម្ផស្សំ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តម្មេតិ ន មញ្ញេយ្យ ។ យំ ហិ ភិក្ខវេ មញ្ញតិ យស្មឹ មញ្ញតិ យតោ មញ្ញតិ យំ មេតិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិនន្ទតិ ។ បេ ។ មនំ ន មញ្ញេយ្យ មនស្មឹ ន មញ្ញេយ្យ មនតោ ន មញ្ញេយ្យ មនោ មេតិ ន មញ្ញេយ្យ ធម្មេ ន មញ្ញេយ្យ មនោវិញ្ញាណំ មនោសម្ផស្សំ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន មញ្ញេយ្យ តស្មឹបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ

របស់នោះ រមែងប្រែប្រួលចាករបស់នោះ ព្រោះសត្វក្នុងភព តែងប្រែប្រួលជានិច្ច តែសត្វលោកនៅតែត្រេកអរនឹងភពដដែល ។ បេ ។ មិនត្រូវប្រកាន់ជិវ្ហា មិនត្រូវប្រកាន់ក្នុងជិវ្ហា មិនត្រូវប្រកាន់អំពីជិវ្ហា មិនត្រូវប្រកាន់ថា ជិវ្ហារបស់អញឡើយ មិនត្រូវប្រកាន់រស ជិវ្ហាវិញ្ញាណ ជិវ្ហាសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិនត្រូវប្រកាន់ថា វេទនានោះរបស់អញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុ ប្រកាន់របស់ណា ប្រកាន់ក្នុងរបស់ណា ប្រកាន់អំពីរបស់ណា ប្រកាន់ថា របស់ណារបស់អញ របស់នោះ ក៏តែងប្រែប្រួលចាករបស់នោះ ព្រោះសត្វក្នុងភព រមែងប្រែប្រួលជាប្រក្រតី តែសត្វលោក នៅតែត្រេកអរនឹងភពដដែល ។ បេ ។ មិនត្រូវប្រកាន់មនោ មិនត្រូវប្រកាន់ក្នុងមនោ មិនត្រូវប្រកាន់អំពីមនោ មិនត្រូវប្រកាន់ថា មនោរបស់អញឡើយ មិនត្រូវប្រកាន់ធម៌ មនោវិញ្ញាណ មនោសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនត្រូវប្រកាន់វេទនានោះ មិនត្រូវប្រកាន់ក្នុងវេទនានោះ មិនត្រូវប្រកាន់អំពីវេទនានោះ មិន

១៤៧

ឆន្នវគ្គោ ចតុត្ថោ

តស្មិំ ន មញ្ញេយ្យ ។ យំ ហិ ភិក្ខវេ មញ្ញតិ យស្មិំ មញ្ញតិ យតោ មញ្ញតិ យម្មេតិ មញ្ញតិ តតោ តំ ហោតិ អញ្ញថា អញ្ញថាភាវី ភវសត្តោ លោកោ ភវមេវ អភិ-នន្ទតិ ។ យាវតា ភិក្ខវេ ខន្ធធាតុអាយតនា តម្បិ ន មញ្ញេយ្យ តស្មិំបិ ន មញ្ញេយ្យ តតោបិ ន មញ្ញេយ្យ តំ មេតិ ន មញ្ញេយ្យ ។ សោ ឯវំ អមញ្ញមានោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជា-នាតីតិ ។ អដ្ឋមំ ។

ឆន្នវគ្គ ទី ៤

ត្រូវប្រកាន់ថា វេទនានោះរបស់អញឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុប្រកាន់របស់ណា ប្រកាន់ក្នុងរបស់ណា ប្រកាន់អំពីរបស់ណា ប្រកាន់ថា របស់ណារបស់អញ របស់នោះក៏រមែងប្រែប្រួលចាករបស់នោះ ព្រោះសត្វក្នុងភព តែងប្រែប្រួលជាប្រក្រតី តែសត្វលោកនៅតែត្រេកអរនឹងភពដដែល ។ ម្នាលភិក្ខុទាំងឡាយ ខន្ធ ធាតុ អាយតនៈទាំងប៉ុន្មាន ភិក្ខុមិនត្រូវប្រកាន់ខន្ធ ធាតុ អាយតនៈនោះ មិនត្រូវប្រកាន់ក្នុងខន្ធ ធាតុ អាយតនៈនោះ មិនត្រូវប្រកាន់អំពីខន្ធ ធាតុ អាយតនៈនោះ មិនត្រូវប្រកាន់ថា ខន្ធ ធាតុ អាយតនៈនោះ របស់អញឡើយ ។ ភិក្ខុនោះកាលបើមិនប្រកាន់យ៉ាងនេះ រមែងមិនក្ដួចកាន់អ្វីបន្តិចបន្តួចក្នុងលោក កាលបើមិនក្ដួចកាន់ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត រមែងរលត់កិលេសចំពោះខ្លួនឯង ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៨ ។

[១២១] ទ្វយំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណា-ថ ។ កិញ្ច ភិក្ខវេ ទ្វយំ ចក្ខុញ្ចេវ រូបា ច សោតញ្ច សទ្ទា ច ឃានញ្ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្វា ច មនោ ច ធម្មា ច ឥទំ វុច្ចតិ ភិក្ខវេ ទ្វយំ ។ យោ ភិក្ខវេ ឯវំ វទេយ្យ អហមេតំ ទ្វយំ បច្ចក្ខាយ អញ្ញំ ទ្វយំ បញ្ញបេស្សាមីតិ ។ តស្ស វាចា វត្ថុ ទេវស្ស[១] បុដ្ឋោ ច ន សម្បាយេយ្យ ឧត្តរឹ ច វិឃាតំ អាបជ្ជេយ្យ ។ តំ កិស្ស ហេតុ ។ យថា តំ ភិក្ខវេ អវិសយស្មិន្តិ ។ ឆដ្ឋំ ។

[១២២] ទ្វយំ ភិក្ខវេ បដិច្ច វិញ្ញាណំ សម្ភោតិ ។ កថញ្ច ភិក្ខវេ ទ្វយំ បដិច្ច វិញ្ញាណំ សម្ភោតិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ ចក្ខុំ អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ រូបា អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ឥត្ថេតំ ទ្វយំ ចលញ្ចេវ ព្យាធញ្ច អនិច្ចំ

១ ឱ. ម. វត្ថុកមេវស្ស ។

[១២១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងធម្មជាតជាគូៗ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរចាំស្តាប់ធម្មជាតនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតជាគូៗ តើដូចម្តេចខ្លះ គឺភ្នែកនិងរូប ត្រចៀកនិងសំឡេង ច្រមុះនិងក្លិន អណ្តាតនិងរស កាយនិងផ្សព្វ ចិត្តនិងធម៌ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថាធម្មជាតជាគូៗ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលណានិយាយយ៉ាងនេះថា ខ្ញុំនឹងបដិសេធនូវធម្មជាតជាគូៗ នុ៎ះចេញ ហើយបញ្ញត្តធម្មជាតជាគូៗ ឯទៀតវិញបាន ។ ពាក្យរបស់បុគ្គលនោះ គ្រាន់តែជាហេតុប៉ុណ្ណោះឯង តែបុគ្គលនោះ កាលបើគេសួរហើយ មុខជាដោះស្រាយមិនរួចផង ដល់នូវសេចក្តីចង្អៀតចង្អល់ចិត្តផង ។ ដំណើរនោះ ព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះការណ៍នោះហួសវិស័យ ។ ចប់សូត្រ ទី ៩ ។

[១២២] ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យអារម្មណ៍ជាគូៗ ទើបកើតបាន ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណអាស្រ័យអារម្មណ៍ជាគូៗ ទើបកើតបាន តើដូចម្តេចខ្លះ ។ គឺចក្ខុវិញ្ញាណកើតឡើងព្រោះអា-ស្រ័យចក្ខុនិងរូប ចក្ខុមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេង ៗ រូបមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេង ៗ កាលបើយ៉ាងនេះ ធម្មជាតជាគូៗ នុ៎ះ ជាវត្ថុញាប់ញ័រផង ឃ្លើចាប់ផង មិនទៀង

វិបរិណាមិ អញ្ញថាភាវិ ចក្ខុវិញ្ញាណំ អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ ។ យោបិ ហេតុ យោបិ បច្ចយោ ចក្ខុវិញ្ញា-ណស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នំ ចក្ខុវិញ្ញាណំ កុតោ និច្ចំ ភវិស្សតិ ។ យោ[១] ខោ ភិក្ខវេ ឥមេសំ តិណ្ណំ ធម្មានំ សង្គតិ សន្និបាតោ សមវាយោ អយំ វុច្ចតិ ភិក្ខវេ ចក្ខុសម្ផស្សោ ។

[១២៣] ចក្ខុសម្ផស្សោបិ អនិច្ចោ វិបរិណាមី អ-ញ្ញថាភាវី ។ យោបិ ហេតុ យោបិ បច្ចយោ ចក្ខុសម្ផ-ស្សស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នោ ចក្ខុសម្ផស្សោ កុតោ

១ ឱ. យា ខោ ។

ឆន្នវគ្គ ទី ៤

មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ចក្ខុវិញ្ញាណមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ទុកជាហេតុណា បច្ច័យណា នាំឲ្យកើតចក្ខុវិញ្ញាណ ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ គួរចាប់ភ្លឹកថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យដែលមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ ការចួបជុំ សន្និបាត សមាគម នៃធម៌ទាំង ៣ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចក្ខុសម្ផស្ស ។

[១២៣] សូម្បីចក្ខុសម្ផស្ស ក៏មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ទុកជាហេតុណា បច្ច័យណា ដែលនាំឲ្យកើតចក្ខុសម្ផស្ស ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ គួរកត់សម្គាល់ថា ចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យបច្ច័យមិនទៀងទៅហើយ តើនឹង

និច្ចោ ភវិស្សតិ ។ ផុដ្ឋោ ភិក្ខវេ វេទេតិ ផុដ្ឋោ ចេតេតិ ផុដ្ឋោ សញ្ជានាតិ ឥត្ថេតេបិ ធម្មា ចលា ចេវ ព្យាធា[១] ច អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ ជិវ្ហា អនិច្ចា វិបរិណាមី អញ្ញថាភាវី រសា អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ឥត្ថេតំ ទ្វយំ ចលញ្ចេវ ព្យាធញ្ច អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ ជិវ្ហាវិញ្ញាណំ អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ ។ យោបិ ហេតុ យោបិ បច្ចយោ ជិវ្ហាវិញ្ញាណស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នំ ជិវ្ហាវិញ្ញាណំ កុតោ និច្ចំ ភវិស្សតិ ។ យោ ខោ ភិក្ខវេ ឥមេសំ តិណ្ណំ ធម្មានំ សង្គតិ សន្និបាតោ សមវាយោ អយំ វុច្ចតិ ភិក្ខវេ ជិវ្ហាសម្ផស្សោ ។

---

១ ឱ. វយយា ច ។ ម. ព្យធា ច ។

បានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលអារម្មណ៍ពាល់ត្រូវហើយ រមែងដឹងច្បាស់ ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងគិត ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងចាំបាន កាលបើយ៉ាងនេះ ធម៌ទាំងនុ៎ះឯង ជាវត្ថុញាប់ញ័រផង ឃើចាប់ផង មិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ ។ បេ ។ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យជិវ្ហានិងរស ជិវ្ហាមិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ រសក៏មិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ កាលបើយ៉ាងនេះ ធម្មជាតជាគូៗ នុ៎ះ ជាវត្ថុញាប់ញ័រផង ឃើចាប់ផង មិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ ជិវ្ហាវិញ្ញាណមិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ទុកជាហេតុណា បច្ច័យណា ដែលនាំឲ្យកើតជិវ្ហាវិញ្ញាណ ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្ដីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ គួរឲ្យយល់ថា ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ ការប្រជុំ សន្និបាត សមាគម នៃធម៌ទាំង ៣ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ជិវ្ហាសម្ផស្ស ។

ឆន្នវគ្គោ ចតុត្ថោ

[១២៤] ជិវ្ហាសម្ផស្សោបិ អនិច្ចោ វិបរិណាមី អញ្ញ-ថាភាវី ។ យោបិ ហេតុ យោបិ បច្ចយោ ជិវ្ហាសម្ផស្ស-ស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិ-ច្ចោ វិបរិណាមី អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នោ ជិវ្ហាសម្ផស្សោ កុតោ និច្ចោ ភវិស្សតិ ។ ផុដ្ឋោ ភិក្ខវេ វេទេតិ ផុដ្ឋោ ចេតេតិ ផុដ្ឋោ សញ្ជានាតិ ឥត្ថេតេបិ ធម្មា ចលា ចេវ ព្យាធា ច អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ មនោ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ធម្មា អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ឥត្ថេតំ ទ្វយំ ចលញ្ចេវ ព្យាធញ្ច អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ មនោ-វិញ្ញាណំ អនិច្ចំ វិបរិណាមិ អញ្ញថាភាវិ ។ យោបិ ហេតុ យោបិ បច្ចយោ មនោវិញ្ញាណស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិច្ចោ វិបរិណាមី

ឆន្នវគ្គ ទី ៤

[១២៤] ជិវ្ហាសម្ផស្សមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ទុកជាហេតុណា បច្ច័យណា ដែលនាំឲ្យកើតជិវ្ហា-សម្ផស្ស ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ គួរចាំទុកថា ជិវ្ហាសម្ផស្ស កើតឡើងព្រោះអាស្រ័យបច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលអារម្មណ៍ពាល់ត្រូវហើយ រមែងដឹងច្បាស់ ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងគិត ដែលអា-រម្មណ៍ពាល់ត្រូវហើយ រមែងចាំបាន កាលបើយ៉ាងនេះ ធម៌ទាំងនោះឯង ជាវត្ថុញាប់ញ័រផង ឃើចាប់ផង មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ បេ ។ មនោវិញ្ញាណ កើតឡើងព្រោះអាស្រ័យមនោនិងធម៌ មនោមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ធម៌មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ កាលបើយ៉ាងនេះ ធម្ម-ជាតជាគូៗ នុ៎ះ ជាវត្ថុញាប់ញ័រផង ឃើចាប់ផង មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ មនោវិញ្ញាណមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេងៗ ។ ទុកជាហេតុណា បច្ច័យណា ដែលនាំឲ្យកើតមនោ-វិញ្ញាណ ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្តីប្រែប្រួល

អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នំ មនោវិញ្ញាណំ កុតោ និច្ចំ ភវិស្សតិ ។ យោ ខោ ភិក្ខវេ ឥមេសំ តិណ្ណំ ធម្មានំ សង្គតិ សន្និបាតោ សមវាយោ អយំ វុច្ចតិ ភិក្ខវេ មនោសម្ផស្សោ ។

[១២៥] មនោសម្ផស្សោបិ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ។ យោបិ ហេតុ យោបិ បច្ចយោ មនោ-សម្ផស្សស្ស ឧប្បាទាយ សោបិ ហេតុ សោបិ បច្ចយោ អនិច្ចោ វិបរិណាមី អញ្ញថាភាវី ។ អនិច្ចំ ខោ បន ភិក្ខវេ បច្ចយំ បដិច្ច ឧប្បន្នោ មនោសម្ផស្សោ កុតោ និច្ចោ ភវិស្សតិ ។ ផុដ្ឋោ ភិក្ខវេ វេទេតិ ផុដ្ឋោ ចេតេតិ ផុដ្ឋោ សញ្ជានាតិ ឥត្ថេតេបិ ធម្មា ចលា ចេវ ព្យាធា ច

មានវិបត្តិផ្សេង ៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ គួរចូលចិត្តថា មនោ-វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ ការចួបជុំ សន្និបាតសមាគម នៃធម៌ទាំង ៣ នេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មនោ-សម្ផស្ស ។

[១២៥] មនោសម្ផស្សមិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេង ៗ ។ ទុកជាហេតុណា បច្ច័យណា ដែលនាំឲ្យកើតមនោ-សម្ផស្ស ហេតុនោះ បច្ច័យនោះ ក៏មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេង ៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវសង្កេតថា បើមនោ-សម្ផស្សកើតឡើង ព្រោះអាស្រ័យបច្ច័យមិនទៀងទៅហើយ តើនឹងបានទៀងទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងដឹងច្បាស់ ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងគិត ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងចាំបាន កាលបើយ៉ាងនេះ ធម៌ទាំងនោះឯង ជាវត្ថុញាប់ញ័រផង ឃើចាប់ផង

១៤៣



អនិច្ចា វិបរិណាមិនោ អញ្ញថាភាវិនោ ។ ឯវំ[១] ភិក្ខវេ ទ្វយំ បដិច្ច មនោវិញ្ញាណំ សម្ភោតីតិ ។ ទសមំ ។

ឆន្នវគ្គោ ចតុត្ថោ

## តស្សុទ្ទានំ

បលោកសុញ្ញា[២] សង្ខិត្តំ
ឆន្នោ បុណ្ណោ ច ពាហិយោ
ឯជេន[៣] ច ទ្វេ វុត្តា
ទ្វយេហិ អបរេ ទ្វេតិ ។

---

១ ឱ. ម. ឯវំ ខោ ។ ២ ឱ. អបលោកសុញ្ញោ ។ ៣ ឱ. ម. ឯជេនេវ ច ទ្វេ វុត្តា ។

ឆន្នវគ្គ ទី ៤

មិនទៀង មានសេចក្តីប្រែប្រួល មានវិបត្តិផ្សេង ៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ មនោវិញ្ញាណ អាស្រ័យអារម្មណ៍ជាគូ ៗ ទើបកើតបាន យ៉ាងនេះឯង ។ ចប់សូត្រទី ១០ ។

ចប់ ឆន្នវគ្គ ទី ៤ ។

## ឧទ្ទាននៃឆន្នវគ្គនោះ គឺ

និយាយអំពីលោកបែកធ្លាយ ១ លោកសូន្យ ១ ធម៌សង្ខេប ១ ឆន្នត្ថេរ ១ បុណ្ណត្ថេរ ១ ពាហិយត្ថេរ ១ តណ្ហាជាគ្រឿងញាប់ញ័រមាន ២ លើក ធម្មជាតជាគូៗ មាន ២ លើក ។

# ឆឡវគ្គោ

[១២៦] ឆយិមេ ភិក្ខវេ ផស្សាយតនា អទន្តា អគុត្តា អរក្ខិតា អសំវុតា ទុក្ខាធិវាហា ហោន្តិ ។ កតមេ ឆ ។ ចក្ខុំ ភិក្ខវេ ផស្សាយតនំ អទន្តំ អគុត្តំ អរក្ខិតំ អសំវុតំ ទុក្ខាធិវាហំ ហោតិ ។ បេ ។ ជិវ្ហា ភិក្ខវេ ផស្សាយតនំ អទន្តំ អគុត្តំ អរក្ខិតំ អសំវុតំ ទុក្ខាធិវាហំ ហោតិ ។ បេ ។ មនោ ភិក្ខវេ ផស្សាយតនំ អទន្តំ អគុត្តំ អរក្ខិតំ អសំវុតំ ទុក្ខាធិវាហំ ហោតិ ។ ឥមេ ខោ ភិក្ខវេ ឆ ផស្សាយតនា អទន្តា អគុត្តា អរក្ខិតា អសំវុតា ទុក្ខាធិវាហា ហោន្តិ ។

# ឆទ្វារវគ្គ

[១២៦] ម្នាលភិក្ខុទាំងឡាយ ហេតុឲ្យកើតផស្សៈទាំង ៦ នេះ ដែលបុគ្គលមិនទូន្មាន មិនគ្រប់គ្រង មិនរក្សា មិនសង្រួមហើយ តែង នាំមកនូវទុក្ខដ៏ក្រៃលែង ។ ហេតុឲ្យកើតផស្សៈទាំង ៦ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវ ទុក្ខដ៏ក្រៃលែង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ជិវ្ហាជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបាន សង្រួមហើយ តែងនាំមកនូវទុក្ខដ៏ក្រៃលែង ។ បេ ។ ម្នាលភិក្ខុទាំង- ឡាយ មនោជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលមិនបានទូន្មាន មិនបាន គ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងនាំមកនូវទុក្ខដ៏ក្រៃ លែង ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាហេតុឲ្យកើតផស្សៈទាំង ៦ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបាន សង្រួមហើយ តែងនាំមកនូវទុក្ខដ៏ក្រៃលែង ។

ឆឡវគ្គោ បញ្ចមោ

[១២៧] ឆយិមេ ភិក្ខវេ ផស្សាយតនា សុទន្តា សុគុត្តា សុរក្ខិតា សុសំវុតា សុខាធិវាហា ហោន្តិ ។ កតមេ ឆ ។ ចក្ខុំ ភិក្ខវេ ផស្សាយតនំ សុទន្តំ សុគុត្តំ សុរក្ខិតំ សុសំវុតំ សុខាធិវាហំ ហោតិ ។ បេ ។ ជិវ្ហា ភិក្ខវេ ផស្សាយតនំ សុទន្តំ សុគុត្តំ សុរក្ខិតំ សុសំវុតំ សុខាធិវាហំ ហោតិ ។ បេ ។ មនោ ភិក្ខវេ ផស្សាយតនំ សុទន្តំ សុគុត្តំ សុរក្ខិតំ សុសំវុតំ សុខា-ធិវាហំ ហោតិ ។ ឥមេ ខោ ភិក្ខវេ ឆ ផស្សាយតនានិ សុទន្តា សុគុត្តា សុរក្ខិតា សុសំវុតា សុខាធិវាហា ហោន្តីតិ ។ ឥទមវោច ភគវា ។ បេ ។ ឯតទវោច សត្ថា ។

[១២៨] ឆឡេវ ផស្សាយតនានិ ភិក្ខវេ

អសំវុតោ យត្ថ ទុក្ខំ និគច្ឆតិ

## ឆឡវគ្គ ទី ៤

[១២៧] ម្នាលភិក្ខុទាំងឡាយ ហេតុឲ្យកើតផស្សៈទាំង ៦ នេះ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសេចក្តីសុខដ៏ក្រៃលែង ។ ហេតុឲ្យកើតផស្សៈទាំង ៦ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសេចក្តីសុខដ៏ក្រៃលែង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ជិវ្ហាជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសេចក្តីសុខដ៏ក្រៃលែង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មនោជាហេតុឲ្យកើតផស្សៈ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសេចក្តីសុខដ៏ក្រៃលែង ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាហេតុឲ្យកើតផស្សៈទាំង ៦ ដែលបុគ្គលទូន្មានល្អ គ្រប់គ្រងល្អ រក្សាល្អ សង្រួមល្អហើយ តែងនាំមកនូវសុខដ៏ក្រៃលែង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សេចក្តីនេះចប់ហើយ ។ បេ ។ ទើបព្រះសាស្តាត្រាស់សេចក្តីនេះថា

[១២៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនសង្រួម
ក្នុងផស្សាយតនៈ ទាំង ៦ ណា រមែងដល់នូវសេចក្តីទុក្ខ

តេសញ្ច យេ សំវរណំ អវេទិសុំ

សទ្ធាទុតិយា វិហរន្តិ ជវស្សុតា ។

ទិស្វាន រូបានិ មនោរមានិ

អថោបិ ទិស្វា អមនោរមានិ

មនោរមេ រាគបថំ វិនោទយេ

ន ចាប្បិយម្មេតិ មនំ បទោសយេ ។

សទ្ទញ្ច សុត្វា ទុតិយំ បិយាប្បិយំ

បិយម្ហិ សទ្ទេ ន សមុច្ឆិតោ សិយា

អថោ បិយេ ទោសគតំ វិនោទយេ

ន ចាប្បិយម្មេតិ មនំ បទោសយេ ។

គន្ធញ្ច ឃត្វា សុរភឹ មនោរមំ

ពួកបុគ្គលណា បានសង្រួមនូវផស្សាយតនៈ ទាំង ៦ នោះ ហើយ ពួកបុគ្គលនោះ ឈ្មោះថាមានសទ្ធាជាគម្រប់ពីរ កម្ចាត់បង់នូវកិលេស មានចិត្តមិនបានទទឹកដោយរាគៈ ។ បុគ្គល ឃើញរូបជាទីពេញចិត្ត ឬឃើញរូបដែលមិនជាទីពេញចិត្ត ហើយត្រូវបន្ទោបង់នូវផ្លូវតម្រេក ក្នុងរូបដែលជាទីពេញចិត្ត ទាំងមិនត្រូវទោមនស្សថា អារម្មណ៍នេះ អញមិនស្រឡាញ់ ដូច្នេះឡើយ ។ ឮនូវអារម្មណ៍ ទី ២ គឺ សំឡេងដែលគួរស្រឡាញ់និងគួរស្អប់ ហើយមិនត្រូវងប់ចិត្តក្នុងសំឡេងដែលគួរស្រឡាញ់ បន្ទោបង់នូវទោស ក្នុងសំឡេងដែលគួរស្រឡាញ់ ទាំងមិនត្រូវទោមនស្សថាអារម្មណ៍នេះ អញមិនស្រឡាញ់ឡើយ ។ ធុំក្លិនក្រអូបគួរពេញចិត្ត

១៨៧

ឆឡវគ្គោ បញ្ចមោ

អថោបិ ឃត្វា អសុចឹ អកន្តិយំ
អកន្តិយស្មឹ បដិឃំ វិនោទយេ
ឆន្ទានុនីតោ ន ច កន្តិយេ សិយា ។
រសញ្ច ភោត្វា បរិតំ ច សាទុ[១]
អថោបិ ភោត្វាន អសាទុ មេកទា
សាទុំ រសំ នាជ្ឈោសាយ កុញ្ឆតិ
វិភេជមាសាទុ សុ នោ បនោសយេ ។
ផស្សេន ផុដ្ឋោ ន សុខេន មជ្ជេ
ទុក្ខេន ផុដ្ឋោបិ ន សម្បវេធេ
ផស្សទ្វយំ សុខទុក្ខំ ឧបេក្ខេ
អនានុរុទ្ធោ អវិរុទ្ធ កេនចិ ។
បបញ្ចសញ្ញា ឥតរីតរា នរា
បបញ្ចយន្តា ឧបយន្តិ សញ្ញិនោ

១ ឱ. សាទុញ្ច ។

ឆឡវគ្គ ទី ៥

ឬជុំក្លិនស្អុយមិនគួរត្រេកអរហើយ ត្រូវបន្ទោបង់នូវការចង្អៀតចង្អល់ចិត្តក្នុងក្លិនដែលមិនគួរត្រេកអរ ទាំងមិនត្រូវបណ្តោយទៅតាមសេចក្តីពេញចិត្ត ក្នុងក្លិនដែលគួរត្រេកអរឡើយ ។ បរិភោគរសឆ្ងាញ់បន្តិច ៗ ក្តី ឬបរិភោគរសដែលមិនឆ្ងាញ់សោះក្តី ក្នុងកាលម្តង ៗ ហើយ មិនត្រូវជាប់ចិត្តបរិភោគតែរសដែលឆ្ងាញ់ ទាំងមិនត្រូវទោមនស្សនឹងរសដែលស្អប់ដែលមិនឆ្ងាញ់ឡើយ ។ បុគ្គលដែលត្រូវផស្សៈជាសុខប៉ះពាល់ហើយ មិនត្រូវស្រើងទេ ទោះត្រូវផស្សៈជាទុក្ខប៉ះពាល់ហើយ ក៏មិនត្រូវរំភើបដែរ ត្រូវតែព្រងើយកន្តើយនឹងផស្សៈទាំង ២ គឺសុខនិងទុក្ខ ទាំងមិនត្រូវស្រឡាញ់មិនត្រូវស្អប់ផស្សៈណាមួយឡើយ ។ ពួកសត្វ ជោកទាបតែងមានសេចក្តីសម្គាល់ក្នុងធម៌ដ៏យឺតយូរ ពួកសត្វមានសញ្ញាត្រេកអរនឹងធម៌យឺតយូរ រមែងវិលមកទៅរក (វដ្តៈ)

មនោមយំ គេហសិតញ្ច សព្វំ
បនុជ្ជ នេក្ខម្មសិតំ ហិ ឥរិយតិ ។
ឯវំ មនោ ឆស្សុ យទា សុភាវិតោ
ផុដ្ឋស្ស ចិត្តំ ន វិកម្បតេ ក្វចិ
តេ រាគទោសេ ហិ អភិភុយ្យ ភិក្ខវោ
ភវថ ជាតិមរណស្ស បារគាតិ ។ បឋមំ ។

[១២៩] អថខោ អាយស្មា មាលុក្យបុត្តោ អាតាបី បហិតត្តោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មាលុក្យបុត្តោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ

បុគ្គល បានបន្ទោបង់ចិត្តទាំងអស់ ដែលអាស្រ័យនៅផ្ទះគឺបញ្ចកាមគុណដែលសម្រេចអំពីចិត្ត តែងប្រព្រឹត្តនូវចិត្តដែលអាស្រ័យនឹងនេក្ខម្មៈ ។ កាលណា បុគ្គលបានចម្រើនចិត្តក្នុងអារម្មណ៍ទាំង ៦ ដោយប្រពៃ យ៉ាងនេះហើយ បុគ្គលនោះឯង ទោះបីសុខសម្ផស្សពាល់ត្រូវ ចិត្តក៏មិនរន្ធត់ក្នុងកាលម្តងឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរគ្រប សង្កត់នូវរាគៈ ទោសៈនោះ ចូរទៅឲ្យដល់ត្រើយនៃជាតិនិងមរណៈគឺព្រះនិព្វានចុះ ។ ចប់សូត្រ ទី ១ ។

[១២៩] លំដាប់នោះឯង ព្រះមាលុក្យបុត្តមានអាយុ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះមាលុក្យបុត្តមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានស្តាប់ធម៌របស់ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ

អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ ឯត្ថទានិ មាលុ-ក្យបុត្ត កឹ ទហរេ ភិក្ខូ វក្ខាមិ យត្រ ហិ នាម ត្វំ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ សង្ខិត្តេន ឱវាទំ យាចសីតិ ។

[១៣០] កិញ្ចាបិហំ ភន្តេ ជិណ្ណោ វុឌ្ឍោ ម-ហល្លកោ អទ្ធគតោ វយោអនុប្បត្តោ ។ ទេសេតុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ សុគតោ សង្ខិ-ត្តេន ធម្មំ អប្បេវ នាមាហំ ភគវតោ ភាសិតស្ស អត្ថំ អាជានេយ្យំ អប្បេវ នាមាហំ ភគវតោ ភាសិតស្ស ទាយាទោ អស្សន្តិ ។ តំ កឹ មញ្ញសិ មាលុក្យបុត្ត យេ តេ ចក្ខុវិញ្ញេយ្យា រូបា អទិដ្ឋា អទិដ្ឋបុព្វា ន ច បស្សសិ ន ច តេ ហោតិ បស្សេយ្យន្តិ អត្ថិ តេ តត្ថ ឆន្ទោ វា បេមំ វាតិ ។ នោ ហេតំ ភន្តេ ។

មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានបាន ។ ម្នាលមាលុក្យបុត្ត អម្បាលប្រហែលអ្នក ជាមនុស្សជរា មានអាយុចម្រើនហើយ ចាស់កន្លងបឋមវ័យ ចូលសិប់ក្នុងបច្ឆិមវ័យហើយ ទើបនឹងសូមឱវាទដោយសង្ខេប ក្នុងកាលឥឡូវនេះ តើនឹងឲ្យតថាគតនិយាយនឹងពួកភិក្ខុកម្លោះដូចម្តេច ក្នុងការសូមឱវាទនុ៎ះ ។

[១៣០] សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សគ្រាំគ្រា មានអាយុចម្រើនហើយ ចាស់កន្លងបឋមវ័យ ចូលសិប់ក្នុងបច្ឆិមវ័យក៏មែនពិត ។ បពិត្រព្រះអង្គដ៏ចម្រើន តែសូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេប សូមព្រះសុគតសម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គឲ្យទាន ធ្វើដូចម្តេចឲ្យតែខ្ញុំព្រះអង្គបានយល់សេចក្តីភាសិតរបស់ព្រះមានព្រះភាគ ធ្វើដូចម្តេចឲ្យតែខ្ញុំព្រះអង្គបានជាទាយាទ (អ្នកទទួលមត៌ក) នៃភាសិតរបស់ព្រះមានព្រះភាគឲ្យទាន ។ ម្នាលមាលុក្យបុត្ត អ្នកសម្គាល់សេចក្តីនោះដូចម្តេច រូបត្រូវដឹងដោយចក្ខុ ដែលបុគ្គលមិនដែលឃើញ មិនធ្លាប់ឃើញ អ្នកក៏មិនបានឃើញ ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែឃើញដូច្នេះឡើយ តើអ្នកមានសេចក្តីពេញចិត្ត ឬមានតម្រេក ឬក៏មានសេចក្តីស្រឡាញ់ក្នុងរូបនោះដែរឬ ។ មិនមានទេ ព្រះអង្គ ។

១៦០



យេ តេ សោតវិញ្ញេយ្យា សទ្ទា អស្សុតា អស្សុតបុព្វា ន ច សុណាសិ ន ច តេ ហោតិ សុណេយ្យន្តិ អត្ថិ តេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ។ នោ ហេតំ ភន្តេ ។ យេ តេ ឃានវិញ្ញេយ្យា គន្ធា អឃាយិតា អឃាយិតបុព្វា ន ច ឃាយសិ ន ច តេ ហោតិ ឃាយេយ្យន្តិ អត្ថិ តេ តត្ថ ។ បេ ។ យេ តេ ជិវ្ហាវិញ្ញេយ្យា រសា អសាយិតា អសាយិតបុព្វា ន ច សាយសិ ន ច តេ ហោតិ សាយេយ្យន្តិ អត្ថិ តេ តត្ថ ។ បេ ។ យេ តេ កាយវិញ្ញេយ្យា ផោដ្ឋព្វា អសម្ផុដ្ឋា អសម្ផុដ្ឋបុព្វា ន ច ផុសសិ ន ច តេ ហោតិ ផុសេយ្យន្តិ អត្ថិ តេ តត្ថ ។ បេ ។ យេ តេ មនោវិញ្ញេយ្យា ធម្មា អវិញ្ញាតា អវិញ្ញាតបុព្វា ន ច វិជានាសិ ន ច តេ ហោតិ វិជានេយ្យន្តិ អត្ថិ តេ តត្ថ ឆន្ទោ វា រាគោ វា បេមំ វាតិ ។ នោ ហេតំ ភន្តេ ។

សំឡេងត្រូវដឹងដោយត្រចៀក ដែលបុគ្គលមិនដែលឮ មិនធ្លាប់ឮ អ្នកក៏មិនបានឮ ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែឮដូច្នេះឡើយ តើអ្នកមានសេចក្តីពេញចិត្ត ឬមានតម្រេក ឬក៏មានសេចក្តីស្រឡាញ់ក្នុងសំឡេងនោះដែរឬ ។ មិនមានទេ ព្រះអង្គ ។ ក្លិនត្រូវដឹងដោយច្រមុះ ដែលបុគ្គលមិនដែលធុំ មិនធ្លាប់ធុំ អ្នកក៏មិនបានធុំ ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែធុំដូច្នេះឡើយ តើអ្នកមាន ។ បេ ។ ក្នុងក្លិននោះដែរឬ ។ រសត្រូវដឹងដោយអណ្តាត ដែលបុគ្គលមិនដែលលិទ្ធភ្លក្ស មិនធ្លាប់លិទ្ធភ្លក្ស អ្នកក៏មិនបានលិទ្ធភ្លក្ស ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែលិទ្ធភ្លក្សដូច្នេះឡើយ តើអ្នកមាន ។ បេ ។ ក្នុងរសនោះដែរឬ ។ ផ្សព្វត្រូវដឹងដោយកាយ ដែលបុគ្គលមិនដែលពាល់ មិនធ្លាប់ពាល់ អ្នកក៏មិនបានពាល់ ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែពាល់ដូច្នេះឡើយ តើអ្នកមាន ។ បេ ។ ក្នុងផ្សព្វនោះដែរឬ ។ ធម៌ដែលត្រូវដឹងដោយចិត្ត ដែលបុគ្គលមិនដែលដឹង មិនធ្លាប់ដឹង អ្នកក៏មិនបានដឹង ទាំងមិនដែលមានគំនិតថា អាត្មាអញត្រូវតែដឹងដូច្នេះឡើយ តើអ្នកមានសេចក្តីពេញចិត្ត ឬមានតម្រេក ឬក៏មានសេចក្តីស្រឡាញ់ក្នុងធម៌នោះដែរឬ ។ មិនមានទេ ព្រះអង្គ ។

ឆឡវគ្គោ បញ្ចមោ

[១៣១] ឯត្ថ ច តេ មាលុក្យបុត្ត ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ ។ យតោ ខោ តេ មាលុក្យបុត្ត ទិដ្ឋសុតមុតវិញ្ញាតព្វេសុ ធម្មេសុ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ តតោ ត្វំ មាលុក្យបុត្ត ន តេន យតោ ត្វំ មាលុក្យបុត្ត ន តេន តតោ ត្វំ មាលុក្យបុត្ត ន តត្ថ យតោ ត្វំ មាលុក្យបុត្ត ន តត្ថ តតោ ត្វំ មាលុក្យបុត្ត នេវិធ ន ហុរំ ន ឧភយ-

ឆឡវគ្គ ទី ៥

[១៣១] ម្នាលមាលុក្យបុត្ត បណ្តាធម៌ដែលត្រូវឃើញ ត្រូវឮ ត្រូវហិត ត្រូវដឹងច្បាស់ ក្នុងរឿងនុ៎ះ អ្នកនឹងមានត្រឹមតែការឃើញចំពោះរូបដែលឃើញហើយ ត្រឹមតែការឮចំពោះសំឡេងដែលឮហើយ ត្រឹមតែការហិតចំពោះក្លិនដែលហិតហើយ ត្រឹមតែការដឹងច្បាស់ចំពោះធម៌ដែលដឹងច្បាស់ហើយ ។ ម្នាលមាលុក្យបុត្ត បណ្តាធម៌ដែលត្រូវឃើញ ត្រូវឮ ត្រូវហិត ត្រូវដឹងច្បាស់ កាលណា អ្នកនឹងមានត្រឹមតែការឃើញចំពោះរូបដែលឃើញហើយ ត្រឹមតែការឮចំពោះសំ-ឡេងដែលឮហើយ ត្រឹមតែការប៉ះពាល់ចំពោះអារម្មណ៍ ដែលប៉ះពាល់ហើយ ត្រឹមតែការដឹងច្បាស់ចំពោះធម៌ដែលដឹងច្បាស់ហើយ ម្នាលមា-លុក្យបុត្ត អ្នកនឹងមិនមានរវល់ដោយរាគៈទោសៈឬមោហៈនោះ ក្នុងកាលនោះ ម្នាលមាលុក្យបុត្ត កាលណា អ្នកមិនមានរវល់ដោយរាគៈទោសៈឬមោហៈនោះទេ ម្នាលមាលុក្យបុត្ត អ្នកមុខជានឹងមិនជាប់ចំពាក់ចិត្តក្នុងរូបារម្មណ៍ជាដើមនោះ ក្នុងកាលនោះ ម្នាលមាលុក្យបុត្ត កាលណា អ្នកមិនបានជាប់ចំពាក់ចិត្តក្នុងរូបារម្មណ៍ជាដើមនោះទេ ម្នាលមាលុក្យបុត្ត អ្នកនឹងមិនមានកិច្ចក្នុងលោកនេះ មិនមានក្នុងលោកខាងមុខ មិនមានក្នុង

មន្តវេ ឯសេវន្តោ ទុក្ខស្សាតិ ។ ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាមិ ។

[១៣២] រូបំ ទិស្វា សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ[១]
តស្ស វឌ្ឍន្តិ វេទនា
អនេកា រូបសម្ភវា
អភិជ្ឈា ច វិហេសា ច
ចិត្តមស្សូបហញ្ញតិ
ឯវំ អាចិនតោ ទុក្ខំ
អារា និព្វាន វុច្ចតិ ។
សទ្ទំ សុត្វា សតិ មុដ្ឋា

១ ឱ. ម. តញ្ច អជ្ឈោសស តិដ្ឋតិ ។

ចន្លោះនៃលោកទាំងពីរ ក្នុងកាលនោះ នេះឯង ជាទីបំផុតនៃទុក្ខ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ យល់សេចក្ដីនៃធម៌ដែលព្រះមានព្រះភាគសម្ដែងហើយ ដោយសង្ខេបនេះឯង ដោយពិស្ដារបាន ។

[១៣២] កាលបើបុគ្គលឃើញរូប ហើយភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្តឲ្យជាទីស្រឡាញ់ហើយ រមែងមានចិត្តត្រេក-ត្រអាលផង នៅឱបក្រសោបអារម្មណ៍នោះផង ។ វេទនាច្រើនប្រការដែលកើតអំពីរូបារម្មណ៍ រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងខ្ទាំងខ្ទប់ព្រោះអភិជ្ឈានិងវិ-ហេសា កាលដែលបុគ្គលសន្សំតែទុក្ខយ៉ាងនេះ ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលឮសំឡេង ហើយភាន់ស្មារតី

១៦៣

## ឆឡវគ្គោ បញ្ចមោ

បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា សទ្ទសម្ភវា
អភិជ្ឈា ច វិហេសា ច
ចិត្តមស្សូបហញ្ញតិ
ឯវំ អាចិនតោ ទុក្ខំ
អារា និព្វាន វុច្ចតិ ។
គន្ធំ ឃត្វា សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ

ឆទ្បវគ្គ ទី ៥

ធ្វើទុកក្នុងចិត្តនូវនិមិត្ត ឲ្យជាទីស្រឡាញ់ហើយ រមែងមាន

ចិត្តត្រេកត្រអាលផង នៅឱបក្រសោបតែនឹងអារម្មណ៍នោះ

ផង ។ វេទនាច្រើនប្រការ ដែលកើតអំពីសទ្ទារម្មណ៍ រមែង

ចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងខ្ទាំងខ្ទប់

ព្រោះអភិជ្ឈានិងវិហេសា កាលបុគ្គលសន្សំតែទុក្ខយ៉ាងនេះ

ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលធុំក្លិន ហើយ

ភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្ត ឲ្យជាទីស្រឡាញ់ហើយ

១៦៤



សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា គន្ធសម្ភវា
អភិជ្ឈា ច វិហេសា ច
ចិត្តមស្សូបហញ្ញតិ
ឯវំ អាចិនតោ ទុក្ខំ
អារា និព្វាន វុច្ចតិ ។
រសំ ភោត្វា សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា រសសម្ភវា
។ បេ ។

រមែងមានចិត្តត្រេកត្រអាលផង នៅឱបក្រសោបតែនឹងអា-
រម្មណ៍នោះផង ។ វេទនាច្រើនប្រការ ដែលកើតអំពីគន្ធា-
រម្មណ៍ រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ
រមែងខ្ទាំងខ្ទប់ព្រោះអភិជ្ឈានិងវិហេសា កាលបើបុគ្គលសន្សំ
តែទុក្ខយ៉ាងនេះ ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាល
បរិភោគរស ហើយភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្ត ឲ្យ
ជាទីស្រឡាញ់ហើយ រមែងមានចិត្តត្រេកត្រអាលផង នៅ
ឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ វេទនាច្រើនប្រការ
ដែលកើតអំពីរសារម្មណ៍ ក៏ចម្រើនដល់បុគ្គលនោះ ។ បេ ។

១៦៨

ឆឡវគ្គោ បញ្ចមោ

អារា និព្វាន វុច្ចតិ ។
ផោដ្ឋព្វំ ផុស្ស[១] សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា ផោដ្ឋព្វសម្ភវា
។ បេ ។
អារា និព្វាន វុច្ចតិ ។
ធម្មំ ញត្វា សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា ធម្មសម្ភវា
អភិជ្ឈា ច វិហេសា ច
ចិត្តមស្សូបហញ្ញតិ

១ ឱ. ម. ផស្សំ ផុស្ស ។

ឆឡវគ្គ ទី ៥

ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលពាល់ត្រូវនូវផោដ្ឋព្វៈ ហើយភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្ត ឲ្យជាទីស្រឡាញ់ហើយ រមែងមានចិត្តត្រេកត្រអាលផង នៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ វេទនាច្រើនប្រការដែលកើតអំពីផោដ្ឋព្វារម្មណ៍ តែងចម្រើនដល់បុគ្គលនោះ ។ បេ ។ ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បុគ្គលកាលដឹងធម្មារម្មណ៍ ហើយភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្តឲ្យជាទីស្រឡាញ់ហើយ រមែងមានចិត្តត្រេកត្រអាលផង នៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ វេទនាច្រើនប្រការដែលកើតអំពីធម្មារម្មណ៍ រមែងចម្រើនដល់បុគ្គលនោះចិត្តរបស់បុគ្គលនោះ រមែងខ្ទាំងខ្ទប់ ព្រោះអភិជ្ឈានិងវិហេសា

ឯវំ អាចិនតោ ទុក្ខំ
អារា និព្វាន វុច្ចតិ ។
[១៣៣] ន សោ រជ្ជតិ រូបេសុ
រូបំ ទិស្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស បស្សតោ រូបំ
សេវតោ ចាបិ វេទនំ
ខិយ្យតិ នោ បចិយតិ
ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ
សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ សទ្ទេសុ
សទ្ទំ សុត្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។

កាលបើបុគ្គលសន្សំតែទុក្ខយ៉ាងនេះ ហៅថាឆ្ងាយអំពីព្រះនិព្វាន ។

[១៣៣] បុគ្គលនោះឃើញរូបហើយ ប្រុងស្មារតី មិនត្រេកអរនឹងរូប រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ កាលបុគ្គលនោះឃើញរូប ហើយទទួលនូវលោកុត្តរវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខយ៉ាងណា បុគ្គលនោះក៏មានស្មារតីប្រព្រឹត្តយ៉ាងនោះ កាលបើបុគ្គលមិនសន្សំទុក្ខយ៉ាងនេះ ហៅថាបានជិតព្រះនិព្វាន ។ បុគ្គលនោះឮសំឡេង ហើយប្រុងស្មារតី មិនត្រេកអរនឹងសំឡេង រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។

១៦៧

ឆទ្ឋវគ្គោ បញ្ចមោ

យថាស្ស សុណតោ សទ្ទំ
សេវតោ ចាបិ វេទនំ
ខិយ្យតិ នោ បចិយតិ
ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ
សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ គន្ធេសុ
គន្ធំ ឃត្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស ឃាយតោ គន្ធំ
សេវតោ ចាបិ វេទនំ
ខិយ្យតិ នោ បចិយតិ
ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ

## ឆឡវគ្គ ទី ៥

កាលបុគ្គលនោះឮសំឡេង ហើយទទួលនូវលោកុត្តរវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខយ៉ាងណា បុគ្គលនោះក៏មានស្មារតីប្រព្រឹត្តយ៉ាងនោះ កាលបុគ្គលមិនសន្សំទុក្ខយ៉ាងនេះ ហៅថាបានជិតព្រះនិព្វាន ។ បុគ្គលនោះធុំក្លិន ហើយប្រុងស្មារតី មិនត្រេកអរនឹងក្លិន រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ កាលបុគ្គលនោះធុំក្លិន ហើយទទួលនូវលោកុត្តរវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខយ៉ាងណា បុគ្គលនោះក៏មានស្មារតីប្រព្រឹត្តយ៉ាងនោះ កាលបើបុគ្គលមិនសន្សំនូវទុក្ខយ៉ាងនេះ

សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ រសេសុ
រសំ ភោត្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស សាយតោ រសំ
សេវតោ ចាបិ វេទនំ

។ បេ ។

សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ ផស្សេសុ
ផស្សំ ផុស្ស បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស ផុសតោ ផស្សំ
សេវតោ ចាបិ វេទនំ

ហៅថាបានជិតព្រះនិព្វាន ។ បុគ្គលនោះបរិភោគរស ហើយ ប្រុងស្មារតី មិនត្រេកអរនឹងរស រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ កាលបុគ្គលនោះលិទ្ធភ្លក្សរស ហើយទទួលនូវលោកុត្តរវេទ-នា ។ បេ ។ ហៅថាបានជិតព្រះនិព្វាន ។ បុគ្គលនោះពាល់ត្រូវនូវផស្សៈ ហើយប្រុងសារត្មី មិនត្រេកអរក្នុងផស្សៈ រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ កាលបុគ្គលនោះពាល់ត្រូវនូវផស្សៈ

១៦៩

ឆឡវគ្គោ បញ្ចមោ

សន្តិកេ និព្វាន វុច្ចតិ ។
ន សោ រជ្ជតិ ធម្មេសុ
ធម្មំ ញត្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស ជានតោ ធម្មំ
សេវតោ ចាបិ វេទនំ
ខិយ្យតិ នោ បចិយតិ
ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ
សន្តិកេ និព្វាន វុច្ចតិ ។

ឥមស្ស ខ្វាហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។

[១៣៤] សាធុ សាធុ មាលុក្យបុត្ត សាធុ ខោ ត្វំ មាលុក្យបុត្ត មយា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានាសិ ។

ឆឡវគ្គ ទី ៥

ហើយទទួលនូវលោកុត្តរវេទនា ។ បេ ។ ហៅថាបានជិតព្រះនិព្វាន ។ បុគ្គលនោះដឹងធម៌ ហើយប្រុងស្មារតី មិនត្រេកអរក្នុងធម៌ រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោបតែនឹងអារម្មណ៍នោះផង ។ កាលបុគ្គលនោះដឹងធម៌ ហើយទទួលនូវលោកុត្តរវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខយ៉ាងណា បុគ្គលនោះក៏មានស្មារតីប្រព្រឹត្តយ៉ាងនោះ កាលបុគ្គលមិនសន្សំទុក្ខយ៉ាងនេះ ហៅថាបានជិតព្រះនិព្វាន ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកា ដែលព្រះអង្គសម្តែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារបាន យ៉ាងនេះឯង ។

[១៣៤] ម្នាលមាលុក្យបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលមាលុក្យបុត្ត ពាក្យដែលតថាគតសម្តែងដោយសង្ខេប អ្នកយល់សេចក្តីដោយពិស្តារបានទុំះ ជាការប្រពៃហើយ ។

[១៣៥] រូបំ ទិស្វា សតិ មុដ្ឋា
បិយំ និមិត្តំ មនសិករោតោ
សារត្តចិត្តោ វេទេតិ
តញ្ច អជ្ឈោសា តិដ្ឋតិ ។
តស្ស វឌ្ឍន្តិ វេទនា
អនេកា រូបសម្ភវា
អភិជ្ឈា ច វិហេសា ច
ចិត្តមស្សូបហញ្ញតិ
ឯវំ អាចិនតោ ទុក្ខំ
អារា និព្វាន វុច្ចតិ ។ បេ ។
[១៣៦] ន សោ រជ្ជតិ ធម្មេសុ
ធម្មំ ញត្វា បដិស្សតោ
វិរត្តចិត្តោ វេទេតិ
តញ្ច នាជ្ឈោសា តិដ្ឋតិ ។
យថាស្ស ជានតោ ធម្មំ

[១៣៥] កាលបុគ្គលឃើញរូប ហើយភាន់ស្មារតី ធ្វើទុកក្នុងចិត្តនូវនិមិត្ត ឲ្យជាទីស្រឡាញ់ តែងមានចិត្តត្រេកត្រអាលផង នៅឱបក្រសោប តែនឹងអារម្មណ៍នោះផង ។ វេទនាច្រើនប្រការ ដែលកើតអំពីរូបារម្មណ៍ រមែងចម្រើនដល់បុគ្គលនោះ ចិត្តរបស់បុគ្គលនោះ រមែងខ្ទាំងខ្ទប់ព្រោះអភិជ្ឈានិងវិហេសា កាលបុគ្គលសន្សំ តែទុក្ខយ៉ាងនេះ ហៅថាឆ្ងាយអំពីព្រះនិព្វាន ។ បេ ។

[១៣៦] បុគ្គលនោះដឹងធម៌[១] ហើយប្រុងស្មារតី មិនត្រេកអរនឹងធម៌ រមែងមានចិត្តប្រាសចាកតម្រេកផង មិននៅឱបក្រសោប តែនឹងអារម្មណ៍នោះផង ។ បុគ្គលនោះកាលដឹង

១ ធម៌ គឺធម្មារម្មណ៍ ។

១៧១

ឆឡវគ្គោ បញ្ចមោ

សេវតោ ចាបិ វេទនំ
ខិយ្យតិ នោ បចិយតិ
ឯវំ សោ ចរតី សតោ
ឯវំ អបចិនតោ ទុក្ខំ
សន្តិកេ និព្វាន វុច្ចតិ ។

ឥមស្ស ខោ មាលុក្យបុត្ត មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

[១៣៧] អថខោ អាយស្មា មាលុក្យបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា មាលុក្យបុត្តោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ

នូវធម៌ ហើយទទួលនូវលោកុត្តរវេទនា ទុក្ខរមែងអស់ទៅ មិនសន្សំទុក្ខយ៉ាងណា បុគ្គលនោះ ក៏មានស្មារតីប្រព្រឹត្ត យ៉ាងនោះ កាលបុគ្គលមិនសន្សំទុក្ខយ៉ាងនេះ ហៅថាបាន ជិតព្រះនិព្វាន ។

ម្នាលមាលុក្យបុត្ត ពាក្យដែលតថាគតសម្តែង ដោយសង្ខេបនេះ ឯង អ្នកត្រូវយល់សេចក្តីដោយពិស្តារ យ៉ាងនេះ ។

[១៣៧] គ្រានោះឯង ព្រះមាលុក្យបុត្តមានអាយុ ត្រេកអររីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះ មានព្រះភាគ ធ្វើប្រទក្សិណរួចចេញទៅ ។ វេលានោះ ព្រះមាលុក្យបុត្ត មានអាយុ ជាបុគ្គលម្នាក់ឯង គេចចេញអំពីពួក ជាអ្នកមិនប្រមាទ មាន ព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិន យូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេច ដោយប្រាជ្ញាដ៏ប្រសើរខ្លួនឯង ក្នុងបច្ចុប្បន្ន នូវបរិយោសាននៃព្រហ្មចរិយៈដ៏ប្រសើរបំផុត ដែលជាទីត្រូវ ការនៃពួកកុលបុត្ត ចេញចាកផ្ទះហើយបួសដោយប្រពៃ ក៏បានដឹងច្បាស់ ថាជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ

ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា មាលុក្យបុត្តោ អរហតំ អហោសីតិ ។ ទុតិយំ ។

[១៣៨] បរិហានធម្មញ្ច វោ ភិក្ខវេ ទេសិស្សាមិ អបរិហានធម្មញ្ច ឆ ច អភិភាយតនានិ តំ សុណាថ ។ កថញ្ច ភិក្ខវេ បរិហានធម្មោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ បាបកា អកុ-សលា ធម្មា សរសង្កប្បា សញ្ញោជនិយា តញ្ចេ ភិក្ខុ អធិវាសេតិ នប្បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា បរិហាយាមិ កុសលេហិ ធម្មេហិ បរិហានំ ហេតំ វុត្តំ ភគវតាតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ ជិវ្ហាយ រសំ សាយិត្វា ឧប្បជ្ជន្តិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា តញ្ចេ ភិក្ខុ

ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំង-ឡាយ ព្រះមាលុក្យបុត្តក៏ជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រ ទី ២ ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបរិហាន-ធម៌ (ធម៌ជាហេតុសាបសូន្យ) ផង នូវអបរិហានធម៌ (ធម៌ជាហេតុមិនសាបសូន្យ) ផង នូវអភិភាយតនៈ (អាយតនៈដ៏ចម្រើនក្រៃពេក) ៦ ផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយចាំស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ បរិហានធម៌តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អកុសល-ធម៌ដ៏លាមក ដែលមានសេចក្តីត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ កើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយភ្នែក បើភិក្ខុនៅអត់ទ្រាំនឹងអារម្មណ៍នោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនកម្ចាត់បង់ទេ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញសាបសូន្យចាកកុសលធម៌ទាំងឡាយ ព្រោះព្រះមានព្រះភាគបានត្រាស់នូវដំណើរនុ៎ះ ថាជាហេតុសាបសូន្យហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ។ បេ ។ កើតឡើងដល់ភិក្ខុ ព្រោះលិទ្ធភ្លក្សរសដោយអណ្តាត ម្នាលភិក្ខុទាំងឡាយ មួយទៀត អកុសល-ធម៌ដ៏លាមក ដែលមានសេចក្តីត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ កើតឡើងដល់ភិក្ខុ ព្រោះដឹងធម៌ដោយចិត្ត បើភិក្ខុនៅអត់ទ្រាំនឹង

អធិវាសេតិ នប្បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវំ គមេតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា បរិហាយាមិ កុសលេហិ ធម្មេហិ បរិហានំ ហេតំ វុត្តំ ភគវតាតិ ។ ឯវំ ខោ ភិក្ខវេ បរិហានធម្មោ ហោតិ ។

[១៣៩] កថញ្ច ភិក្ខវេ អបរិហានធម្មោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា តញ្ចេ ភិក្ខុ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីក-រោតិ អនភាវំ គមេតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ន បរិហាយាមិ កុសលេហិ ធម្មេហិ អបរិហានំ ហេតំ វុត្តំ ភគវតាតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ ជិវ្ហាយ រសំ សាយិត្វា ឧប្បជ្ជន្តិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា តញ្ចេ ភិក្ខុ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ

អារម្មណ៍នោះ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនកម្ចាត់បង់ទេ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញសាបសូន្យចាកកុសលធម៌ ព្រោះព្រះមានព្រះភាគត្រាស់នូវដំណើរនុ៎ះ ថាជាហេតុសាបសូន្យហើយ ។ ម្នាលភិក្ខុទាំងឡាយ បរិហានធម៌យ៉ាងនេះឯង ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ ចំណែកខាងអបរិហានធម៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក ដែលមានសេចក្តីត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ កើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយភ្នែក បើភិក្ខុមិនទទួលអារម្មណ៍នោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស កម្ចាត់បង់ចេញ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ ព្រោះព្រះមានព្រះភាគត្រាស់នូវដំណើរនុ៎ះ ថាជាហេតុមិនសាបសូន្យទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ។ បេ ។ កើតឡើងដល់ភិក្ខុ ព្រោះលិទ្ធភ្លក្សរសដោយអណ្តាត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អកុសលធម៌ដ៏លាមក ដែលមានសេចក្តីត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ កើតឡើងដល់ភិក្ខុ ព្រោះដឹងធម៌ដោយចិត្ត បើភិក្ខុមិនទទួលអារម្មណ៍នោះទេ បានលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស

អនភាវំ គមេតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ន បរិ-
ហាយាមិ កុសលេហិ ធម្មេហិ អបរិហានំ ហេតំ វុត្តំ
ភគវតាតិ ។ ឯវំ ខោ ភិក្ខវេ អបរិហានធម្មោ ហោតិ ។

[១៤០] កាតមានិ ច ភិក្ខវេ ឆ អភិភាយតនានិ ។
ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ន ឧប្បជ្ជន្តិ
បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា
វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា អភិភូតមេតំ អាយតនំ
អភិភាយតនំ ហេតំ វុត្តំ ភគវតាតិ ។ បេ ។ បុន ចបរំ
ភិក្ខវេ ភិក្ខុនោ មនសា ធម្មំ វិញ្ញាយ ន ឧប្បជ្ជន្តិ
បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា
វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា អភិភូតមេតំ អាយតនំ
អភិភាយតនំ ហេតំ វុត្តំ ភគវតាតិ ។ ឥមានិ វុច្ចន្តិ
ភិក្ខវេ ឆ អភិភាយតនានីតិ ។ តតិយំ ។

កម្ចាត់បង់ចេញ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ឡើយ ព្រោះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវដំណើរនុ៎ះ ថាជាហេតុមិនសាបសូន្យទេ ។ ម្នាលភិក្ខុ ទាំងឡាយ អបរិហានធម៌ យ៉ាងនេះឯង ។

[១៤០] ម្នាលភិក្ខុទាំងឡាយ ឯអភិភាយតនៈទាំង ៦ តើដូចម្តេច ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក ដែលមានសេចក្តី ត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ មិនកើតឡើងដល់ភិក្ខុក្នុង សាសនានេះ ព្រោះឃើញរូបដោយភ្នែក ម្នាលភិក្ខុទាំងឡាយ ដំណើរ នុ៎ះភិក្ខុត្រូវដឹងថា នេះជាអាយតនៈដ៏ចម្រើនក្រៃពេក ព្រោះព្រះមានព្រះ ភាគបានត្រាស់នូវដំណើរនុ៎ះ ថាជាអាយតនៈដ៏ចម្រើនក្រៃពេក ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អកុសលធម៌ដ៏លាមក ដែលមានសេចក្តី ត្រិះរិះជាទីស្មុះទៅ ជាបច្ច័យនៃការជាប់ចំពាក់ មិនកើតឡើងដល់ភិក្ខុ ព្រោះដឹងធម៌ដោយចិត្ត ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះភិក្ខុត្រូវដឹងថា នេះជាអាយតនៈដ៏ចម្រើនក្រៃពេក ព្រោះព្រះមានព្រះភាគបានត្រាស់នូវ ដំណើរនុ៎ះ ថាជាអាយតនៈដ៏ចម្រើនក្រៃពេក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអភិភាយតនៈទាំង ៦ ។ ចប់សូត្រ ទី ៣ ។

ឆឡវគ្គោ បញ្ចមោ

[១៤១] សាវត្ថីនិទានំ ។ បេ ។ បមាទវិហារិញ្ច វោ ភិក្ខវេ ទេសិស្សាមិ អប្បមាទវិហារិញ្ច តំ សុណាថ ។ កថញ្ច ភិក្ខវេ បមាទវិហារី ហោតិ ។ ចក្ខុន្ទ្រិយំ អសំវុតស្ស ភិក្ខវេ វិហរតោ ចិត្តំ ព្យាសិច្ចតិ ចក្ខុ-វិញ្ញេយ្យេសុ រូបេសុ តស្ស ព្យាសិត្តចិត្តស្ស បាមុជ្ជំ ន ហោតិ បាមុជ្ជេ អសតិ បីតិ ន ហោតិ បីតិយា អសតិ បស្សទ្ធិ ន ហោតិ បស្សទ្ធិយា អសតិ ទុក្ខំ វិហរតិ[១] ទុក្ខិនោ ចិត្តំ ន សមាធិយតិ អសមាហិតេ ចិត្តេ ធម្មា ន បាតុភវន្តិ ធម្មានំ អបាតុភាវា បមាទវិហារីត្វេវ សង្ខំ គច្ឆតិ ។ បេ ។ ជិវ្ហិន្ទ្រិយំ អសំវុតស្ស ភិក្ខវេ វិហរតោ ចិត្តំ ព្យាសិច្ចតិ ជិវ្ហាវិញ្ញេយ្យេសុ រសេសុ តស្ស ព្យាសិត្តចិត្តស្ស ។ បេ ។ បមាទវិហារីត្វេវ សង្ខំ គច្ឆតិ ។ បេ ។ មនិន្ទ្រិយំ អសំវុតស្ស ភិក្ខវេ វិហរតោ

១ ម. ទុក្ខំ ហោតិ ។

ឆឡវគ្គ ទី ៥

[១៤១] សាវត្ថីនិទាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្តែង នូវបុគ្គលដែលមានប្រក្រតីនៅដោយសេចក្តីប្រហែសផង នូវបុគ្គលដែលមានប្រក្រតីនៅដោយការមិនប្រហែសផង ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមានប្រក្រតីនៅដោយសេចក្តីប្រហែស តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើភិក្ខុមិនសង្រួមចក្ខុន្ទ្រិយ ចិត្តក៏ជោកជាំ (ដោយកិលេស) ក្នុងរូបដែលត្រូវដឹងដោយភ្នែក កាលបើភិក្ខុនោះមានចិត្តជោកជាំ (ដោយកិលេស) បាមុជ្ជៈក៏មិនមាន កាលបើបាមុជ្ជៈមិនមាន បីតិក៏មិនមាន កាលបើបីតិមិនមាន បស្សទ្ធិក៏មិនមាន កាលបើបស្សទ្ធិមិនមាន រមែងនៅជាទុក្ខ ចិត្តរបស់ភិក្ខុអ្នកមានទុក្ខ តែងមិនតម្កល់នៅនឹង កាលបើចិត្តមិនតម្កល់នៅនឹង ធម៌ក៏មិនកើតប្រាកដ ព្រោះតែធម៌មិនកើតប្រាកដ ភិក្ខុនោះ ក៏រាប់ថាអ្នកនៅដោយសេចក្តីប្រហែសធ្វេស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមិនសង្រួមជិវ្ហិន្ទ្រិយ ចិត្តក៏ជោកជាំ (ដោយកិលេស) ក្នុងរសដែលត្រូវដឹងដោយអណ្តាត កាលបើភិក្ខុនោះមានចិត្តជោកជាំ (ដោយកិលេស) ។ បេ ។ ភិក្ខុនោះក៏រាប់ថាអ្នកនៅដោយសេច-ក្តីប្រហែសធ្វេស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមិនសង្រួម

ចិត្តំ ព្យាសិច្ចតិ មនោវិញ្ញេយ្យេសុ ធម្មេសុ តស្ស ព្យាសិត្តចិត្តស្ស បាមុជ្ជំ ន ហោតិ បាមុជ្ជេ អសតិ បីតិ ន ហោតិ បីតិយា អសតិ បស្សទ្ធិ ន ហោតិ បស្សទ្ធិ-យា អសតិ ទុក្ខំ វិហរតិ ទុក្ខិនោ ចិត្តំ ន សមា-ធិយតិ អសមាហិតេ ចិត្តេ ធម្មា ន បាតុភវន្តិ ធម្មានំ អបាតុភាវា បមាទវិហារីត្វេវ សង្ខំ គច្ឆតិ ។ ឯវំ ខោ ភិក្ខវេ បមាទវិហារី ហោតិ ។

[១៤២] កថញ្ច ភិក្ខវេ អប្បមាទវិហារី ហោតិ ។ ចក្ខុន្ទ្រិយំ សំវុតស្ស ភិក្ខវេ វិហរតោ ចិត្តំ ព្យាសិច្ចតិ ចក្ខុវិញ្ញេយ្យេសុ រូបេសុ តស្ស អព្យាសិត្តចិត្តស្ស បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វិហរតិ សុខិនោ ចិត្តំ សមាធិយតិ សមាហិតេ ចិត្តេ ធម្មា

មនិន្ទ្រិយ ចិត្តក៏ជោកជាំ (ដោយកិលេស) ក្នុងធម៌ដែលត្រូវដឹងដោយចិត្ត កាលបើភិក្ខុនោះមានចិត្តជោកជាំ (ដោយកិលេស) បាមុជ្ជៈក៏មិនមាន កាលបើបាមុជ្ជៈមិនមាន បីតិក៏មិនមាន កាលបើបីតិមិនមាន បស្សទ្ធិក៏មិនមាន កាលបើបស្សទ្ធិមិនមាន ក៏រមែងនៅជាទុក្ខ ចិត្តរបស់ភិក្ខុអ្នកមានទុក្ខ រមែងមិនតម្កល់នៅនឹង កាលបើចិត្តមិនតម្កល់នៅនឹង ធម៌ទាំងឡាយ រមែងមិនកើតប្រាកដ ព្រោះធម៌មិនបានកើតប្រាកដ ភិក្ខុនោះក៏រាប់ថាអ្នកនៅដោយសេចក្តីប្រហែសធ្វេស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានប្រក្រតីនៅដោយសេចក្តីប្រហែសធ្វេស យ៉ាងនេះឯង ។

[១៤២] ម្នាលភិក្ខុទាំងឡាយ ចំណែកខាងបុគ្គលអ្នកនៅដោយសេចក្តីមិនប្រហែសធ្វេសតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសង្រួមចក្ខុន្ទ្រិយ ចិត្តក៏មិនជោកជាំ (ដោយកិលេស) ក្នុងរូបដែលត្រូវដឹងដោយចក្ខុ កាលបើបុគ្គលនោះមានចិត្តមិនជោកជាំ (ដោយកិលេស) បាមុជ្ជៈក៏កើតឡើង កាលបើបុគ្គលនោះមានបាមុជ្ជៈ បីតិក៏កើតឡើង កាលបុគ្គលនោះមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ បុគ្គលដែលមានកាយស្ងប់រម្ងាប់ហើយ រមែងនៅជាសុខ ចិត្តរបស់បុគ្គលអ្នកមានសេចក្តីសុខ តែងតម្កល់នៅនឹង កាលបើចិត្តតម្កល់នៅនឹង ធម៌ទាំងឡាយ

១៧៧

ឆឡវគ្គោ បញ្ចមោ

ចាតុករវត្តិ ជម្មានំ ចាតុភាវា អប្បមាទវិហារីត្វេវ សង្ខំ កច្ឆតិ ។ បេ ។ ជិវ្ហិន្ទ្រិយំ សំវុតស្ស ភិក្ខុវេ វិហរតោ ចិត្តំ ន ព្យាសិច្ចតិ ។ បេ ។ អប្បមាទវិហារីត្វេវ សង្ខំ កច្ឆតិ ។ បេ ។ មនិន្ទ្រិយំ សំវុតស្ស ភិក្ខុវេ វិហរតោ ចិត្តំ ន ព្យាសិច្ចតិ មនោវិញ្ញេយ្យេសុ ជម្មេសុ តស្ស អព្យាសិត្តចិត្តស្ស ចាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ[១] សុខិនោ ចិត្តំ សមាជិយតិ សមាហិតេ ចិត្តេ ជម្មា ចាតុករវត្តិ ជម្មានំ ចាតុភាវា អប្បមាទវិហារីត្វេវ សង្ខំ កច្ឆតិ ។ ឯវំ ខោ ភិក្ខុវេ អប្បមាទវិហារី ហោតីតិ ។ ចតុត្ថំ ។

---

១ ម. សុខំ វិហរតិ ។

ឆឡវគ្គ ទី ៥

តែងកើតប្រាកដ ព្រោះធម៌កើតប្រាកដ បុគ្គលនោះក៏រាប់ថាមានប្រក្រតីនៅដោយសេចក្តីមិនប្រហែសធ្វេស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសង្រួមជិវ្ហិន្ទ្រិយ ចិត្តក៏មិនជោកជាំ (ដោយកិលេស) ។ បេ ។ បុគ្គលនោះក៏រាប់ថាមានប្រក្រតីនៅដោយសេចក្តីមិនប្រហែសធ្វេស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសង្រួមមនិន្ទ្រិយ ចិត្តក៏មិនជោកជាំ (ដោយកិលេស) ក្នុងធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ កាលបុគ្គលនោះមានចិត្តមិនជោកជាំ (ដោយកិលេស) បាមុជ្ជៈក៏កើតឡើង កាលបើបុគ្គលនោះមានបាមុជ្ជៈ បីតិក៏កើតឡើង កាលបើមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ បុគ្គលដែលមានកាយស្ងប់រម្ងាប់ រមែងសោយអារម្មណ៍ជាសុខ ចិត្តរបស់បុគ្គលដែលមានសេចក្តីសុខ តែងតម្កល់នៅនឹង កាលបើចិត្តតម្កល់នៅនឹង ធម៌ទាំងឡាយតែងកើតប្រាកដ ព្រោះតែធម៌កើតប្រាកដ បុគ្គលនោះក៏រាប់ថាមានប្រក្រតីនៅដោយសេចក្តីមិនប្រហែសធ្វេស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានប្រក្រតីនៅដោយសេចក្តីមិនប្រហែសធ្វេស យ៉ាងនេះឯង ។ ចប់សូត្រ ទី ៤ ។

[១៤៣] សំវរញ្ច វោ ភិក្ខវេ ទេសិស្សាមិ អសំវ-
រញ្ច តំ សុណាថ ។ កថញ្ច ភិក្ខវេ អសំវរោ ហោតិ ។
សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា
បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិ-
នន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ វេទិតព្វមេតំ
ភិក្ខវេ ភិក្ខុនា បរិហាយាមិ កុសលេហិ ធម្មេហិ បរិ-
ហានំ ហេតំ វុត្តំ ភគវតាតិ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហា-
វិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា
ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា
រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ
តិដ្ឋតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា បរិហាយាមិ
កុសលេហិ ធម្មេហិ បរិហានំ ហេតំ វុត្តំ ភគវតាតិ ។
ឯវំ ខោ ភិក្ខវេ អសំវរោ ហោតិ ។

[១៤៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវការសង្រួម និងការមិនសង្រួម ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ការមិនសង្រួម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបដែលត្រូវដឹងដោយភ្នែក គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត គួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល រមែងមាន បើភិក្ខុត្រេកអរ ស្រើបស្រាល ជ្រុលជ្រប់ ចំពោះរូបនោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះភិក្ខុត្រូវដឹងថា អាត្មាអញសាបសូន្យ ចាកកុសលធម៌ទាំងឡាយ ព្រោះការសាបសូន្យនុ៎ះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រសដែលត្រូវដឹងដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវដឹងដោយចិត្ត គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត គួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល រមែងមាន បើភិក្ខុត្រេកអរ ស្រើបស្រាល ជ្រុលជ្រប់ ចំពោះធម៌នោះ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះភិក្ខុត្រូវដឹងថា អាត្មាអញសាបសូន្យចាកកុសលធម៌ទាំងឡាយ ព្រោះការសាបសូន្យនុ៎ះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ ម្នាលភិក្ខុទាំងឡាយ ការមិនសង្រួមយ៉ាងនេះឯង ។

## ឆឡវគ្គោ បញ្ចមោ

[១៨៨] កថញ្ច ភិក្ខវេ សំវរោ ហោតិ ។ សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយ-រូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ន បរិហាយាមិ កុសលេហិ ធម្មេហិ អបរិហានំ ហេតំ វុត្តំ ភគវតាតិ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ វេទិតព្វមេតំ ភិក្ខវេ ភិក្ខុនា ន បរិហាយាមិ កុសលេហិ ធម្មេហិ អបរិហានំ ហេតំ វុត្តំ ភគវតាតិ ។ ឯវំ ខោ ភិក្ខវេ សំវរោ ហោតីតិ ។ បញ្ចមំ ។

## ឆឡវគ្គ ទី ៥

[១៤៤] ម្នាលភិក្ខុទាំងឡាយ ចំណែកការសង្រួមតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបដែលត្រូវដឹងដោយភ្នែក គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត គួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល រមែងមាន បើភិក្ខុមិនត្រេកអរ មិនស្រើបស្រាល មិនជ្រុលជ្រប់ ចំពោះរូបនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ទាំងឡាយឡើយ ព្រោះការមិនសាបសូន្យនុ៎ះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រសដែលត្រូវដឹងដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលត្រូវដឹងដោយចិត្ត គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត គួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកត្រអាល រមែងមាន បើភិក្ខុមិនត្រេកអរ មិនស្រើបស្រាល មិនជ្រុលជ្រប់ ចំពោះធម៌នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុត្រូវដឹងថា អាត្មាអញមិនសាបសូន្យចាកកុសលធម៌ទាំងឡាយឡើយ ព្រោះការមិនសាបសូន្យនុ៎ះ ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។ ម្នាលភិក្ខុទាំងឡាយ ការសង្រួម យ៉ាងនេះឯង ។ ចប់សូត្រ ទី ៤ ។

[១៤៨] សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ ចក្ខុំ អនិច្ចន្តិ យថាភូតំ បជានាតិ រូបា អនិច្ចាតិ យថាភូតំ បជានាតិ ចក្ខុវិញ្ញាណំ អនិច្ចន្តិ យថាភូតំ បជានាតិ ចក្ខុសម្ផស្សោ អនិច្ចោតិ យថា-ភូតំ បជានាតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ បជានាតិ ។ បេ ។ មនោ អនិច្ចោតិ យថាភូតំ បជានាតិ ធម្មា មនោវិញ្ញាណំ មនោ-សម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ បជានាតិ ។ សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតីតិ ។ ឆដ្ឋំ ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចម្រើននូវសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានចិត្តតម្កល់នៅនឹងនួនតែងដឹងច្បាស់តាមពិត ។ ដឹងច្បាស់តាមពិតនូវអ្វី ។ ដឹងច្បាស់តាមពិតថា ចក្ខុមិនទៀង ដឹងច្បាស់តាមពិតថា រូបមិនទៀង ដឹងច្បាស់តាមពិតថា ចក្ខុវិញ្ញាណមិនទៀង ដឹងច្បាស់តាមពិតថា ចក្ខុសម្ផស្សមិនទៀង វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏ដឹងច្បាស់តាមពិតថា វេទនានោះឯង មិនទៀង ។ បេ ។ ដឹងច្បាស់តាមពិតថា មនោមិនទៀង ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏ដឹងច្បាស់តាមពិតថា វេទនានោះឯងមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចម្រើនសមាធិចុះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុដែលមានចិត្តតម្កល់នៅនឹងនួន រមែងដឹងច្បាស់តាមពិតដូច្នេះ ។ ចប់សូត្រ ទី ៦ ។

១៨១

ឆឡវគ្គោ បញ្ចមោ

[១៤៦] បដិសល្លីនា ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតិ ។ កិញ្ច យថាភូតំ បជានាតិ ។ ចក្ខុំ អនិច្ចន្តិ យថាភូតំ បជានាតិ រូបា អនិច្ចាតិ យថាភូតំ បជានាតិ ចក្ខុវិញ្ញាណំ អនិច្ចន្តិ យថាភូតំ បជានាតិ ចក្ខុសម្ផស្សោ អនិច្ចោតិ យថាភូតំ បជានាតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ បជានាតិ ។ បដិសល្លីនា ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនោ ភិក្ខវេ ភិក្ខុ យថាភូតំ បជានាតីតិ ។ សត្តមំ ។

[១៤៧] យម្បិ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ ចក្ខុំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។

ឆឡវគ្គ ទី ៥

[១៤៦] ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយស្ងាប់ស្ងាត់ ហើយប្រកបព្យាយាមទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីស្ងប់ស្ងាត់តែងដឹងច្បាស់តាមពិត ។ ដឹងច្បាស់តាមពិតនូវអ្វី ។ ដឹងច្បាស់តាមពិតថា ចក្ខុមិនទៀង ដឹងច្បាស់តាមពិតថា រូបមិនទៀង ដឹងច្បាស់តាមពិតថា ចក្ខុវិញ្ញាណមិនទៀង ដឹងច្បាស់តាមពិតថា ចក្ខុសម្ផស្សមិនទៀង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏ដឹងច្បាស់តាមពិតថា វេទនានោះឯងមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្ងប់ស្ងាត់ ហើយប្រកបព្យាយាមចុះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានសេចក្តីស្ងប់ស្ងាត់ តែងដឹងច្បាស់តាមពិតដូច្នេះ ។ ចប់សូត្រទី ៧ ។

[១៤៧] ម្នាលភិក្ខុទាំងឡាយ របស់ណាដែលមិនមែនជារបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់នូវរបស់នោះចេញ របស់នោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ អ្វីមិនមែនរបស់ពួកអ្នក ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់ចក្ខុនោះចេញ ចក្ខុនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។

រូបា ច តុម្ហាកំ តេ បជហថ តេ វោ បហីនា ហិ-
តាយ សុខាយ ភវិស្សន្តិ ។ ចក្ខុវិញ្ញាណំ ច តុម្ហាកំ តំ
បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។
ចក្ខុសម្ផស្សោ ច តុម្ហាកំ តំ បជហថ សោ វោ បហីនោ
ហិតាយ សុខាយ ភវិស្សតិ ។ យម្បិទំ ចក្ខុសម្ផស្ស-
ប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខ-
មសុខំ វា តម្បិ ច តុម្ហាកំ តំ បជហថ តំ វោ បហីនំ
ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ ជិវ្ហា ច តុម្ហាកំ
តំ បជហថ សា វោ បហីនា ហិតាយ សុខាយ
ភវិស្សតិ ។ រសា ច តុម្ហាកំ តេ បជហថ តេ វោ
បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ ជិវ្ហាវិញ្ញាណំ

រូបមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់រូបនោះចេញ រូបនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ចក្ខុវិញ្ញាណមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ចក្ខុវិញ្ញាណនោះចេញ ចក្ខុវិញ្ញាណនោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ចក្ខុសម្ផស្សមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ចក្ខុសម្ផស្សនោះចេញ ចក្ខុសម្ផស្សនោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ សូម្បីវេទនានោះ ក៏មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់នូវវេទនានោះចេញ វេទនានោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ បេ ។ ជិវ្ហាមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់នូវជិវ្ហានោះចេញ ជិវ្ហានោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ រសមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់រសនោះចេញ រសនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ជិវ្ហាវិញ្ញាណ

១៨៣

ឆទ្វារវគ្គោ បញ្ចមោ

ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ ជិវ្ហាសម្ផស្សោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ ហិតាយ សុខាយ ភវិស្សតិ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ មនោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ ហិតាយ សុខាយ ភវិស្សតិ ។ ធម្មា ន តុម្ហាកំ តេ បជហថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ មនោវិញ្ញាណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ

ឆឡវគ្គ ទី ៥

មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ជិវ្ហាវិញ្ញាណនោះចេញ ជិវ្ហាវិញ្ញាណនោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ជិវ្ហាសម្ផស្សមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ជិវ្ហាសម្ផស្សនោះចេញ ជិវ្ហាសម្ផស្សនោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ សូម្បីវេទនានោះ ក៏មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់វេទនានោះចេញ វេទនានោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ បេ ។ មនោមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់មនោនោះចេញ មនោនោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ធម្មារម្មណ៍មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ធម្មារម្មណ៍នោះចេញ ធម្មារម្មណ៍នោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ មនោវិញ្ញាណមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់នូវមនោវិញ្ញាណនោះចេញ មនោវិញ្ញាណនោះបើពួកអ្នកលះបង់បានហើយ

ហិតាយ សុខាយ ភវិស្សតិ ។ មនោសម្ផស្សោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ ហិតាយ សុខាយ ភវិស្សតិ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ សេយ្យថាបិ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនោ ហ-រេយ្យ វា ឌហេយ្យ វា យថាបច្ចយំ វា ករេយ្យ អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ វា ឌហតិ វា យថាបច្ចយំ វា ករោតីតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ ន ហិ នោ ឯតំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ ចក្ខុំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ រូបា ន តុម្ហាកំ ។ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ ។ បេ ។

គង់មានប្រយោជន៍និងសេចក្តីសុខ ។ មនោសម្ផស្សមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់នូវមនោសម្ផស្សនោះចេញ មនោ-សម្ផស្សនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ សូម្បីវេទនានោះ ក៏មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់វេទនានោះចេញ វេទនានោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ដូចស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើណា ដែលមានក្នុងវត្តជេតពននេះ គេក៏ជញ្ជូនយកស្មៅជាដើមនោះ ឬដុត ឬក៏ធ្វើឲ្យសមគួរតាមហេតុ អ្នកទាំងឡាយនឹងមានយោបល់យ៉ាងនេះថា គេតែងនាំយកយើង ឬដុត ឬក៏ធ្វើតាមសមគួរដល់ហេតុ ដូច្នេះដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះស្មៅជាដើមនុ៎ះ មិនមែនជាខ្លួន ឬជាវត្ថុអាស្រ័យនៅខ្លួនរបស់យើងខ្ញុំទេ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ចក្ខុនោះចេញ ចក្ខុនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ រូបមិនមែនរបស់ពួកអ្នកទេ ។ ចក្ខុវិញ្ញាណ ចក្ខុសម្ផស្ស ។ បេ ។

យស្មិំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មិំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតីតិ ។ អដ្ឋមំ ។

[១៤៨] យស្មិំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ ចក្ខុំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ រូបា ន តុម្ហាកំ តេ បជហថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ ចក្ខុវិញ្ញាណំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ ចក្ខុសម្ផស្សោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ

វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ សូម្បីវេទនានោះ មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់វេទនានោះចេញ វេទនានោះ បើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ក៏យ៉ាងនោះឯង ។ ចប់សូត្រ ទី ៨ ។

[១៤៨] ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់របស់នោះចេញ របស់នោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ របស់អ្វីដែលមិនមែនរបស់ពួកអ្នក ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់ចក្ខុនោះចេញ ចក្ខុនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ រូបមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់រូបនោះចេញ រូបនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ចក្ខុ-វិញ្ញាណមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់ចក្ខុវិញ្ញាណនោះចេញ ចក្ខុវិញ្ញាណនោះបើពួកអ្នកលះបង់បានហើយ គង់មានប្រ-យោជន៍និងសេចក្តីសុខ ។ ចក្ខុសម្ផស្សមិនមែនរបស់ពួកអ្នកទេ អ្នកទាំង-ឡាយចូរលះបង់ចក្ខុសម្ផស្សនោះចេញ ចក្ខុសម្ផស្សនោះបើពួកអ្នកលះបង់

ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ យម្បិ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតីតិ ។ នវមំ ។

[១៤៩] ឧទកោ សុទំ ភិក្ខវេ រាមបុត្តោ ឯវំ វាចំ ភាសតិ ឥទំ ជាតុ វេទគូ ឥទំ ជាតុ បព្វជិ[១] ឥទំ ជាតុ អបលិខតំ[២] គណ្ឌមូលំ បលិខណឹតិ ។ តំ ខោ បនេតំ ភិក្ខវេ ឧទកោ រាមបុត្តោ អវេទគូ យេវ សមានោ វេទគូស្មីតិ ភាសតិ អប្បព្វជិ យេវ សមានោ បព្វជិស្មីតិ

---

១ ឱ. ម. សព្វជិ ។ ២ ឱ. បលិខិតំ ។

បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើងព្រោះមនោ-សម្ផស្សជាបច្ច័យ សូម្បីវេទនានោះ ក៏មិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយចូរលះបង់វេទនានោះចេញ វេទនានោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនមែនរបស់ពួកអ្នកទេ អ្នកទាំងឡាយ ចូរលះបង់របស់នោះចេញ របស់នោះបើពួកអ្នកលះបង់បានហើយ គង់មានប្រយោជន៍និងសេចក្តីសុខ ។ ចប់សូត្រ ទី ៩ ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បានឮថា ឧទករាមបុត្ត និយាយយ៉ាងនេះថា ខ្ញុំជាអ្នកសម្រេចវេទពិត ខ្ញុំជាអ្នកគ្របសង្កត់នូវវដ្តៈពិត ខ្ញុំបានជីកឫសគល់នៃទុក្ខ ដែលមិនទាន់ជីកហើយពិត ។ ម្នាលភិក្ខុទាំង-ឡាយ ឯឧទករាមបុត្ត មិនមែនសម្រេចវេទទេ តែប្រកាសសេចក្តីនោះថា ខ្ញុំជាអ្នកសម្រេចវេទ មិនគ្របសង្កត់នូវវដ្តៈទេ តែប្រកាសថា ខ្ញុំជា

១៨៧

## ឆឡវគ្គោ បញ្ចមោ

ភាសតិ អបលិខតំ យេវ គណ្ឌាមូលំ បលិខតំ មេ គណ្ឌាមូលន្តិ ភាសតិ ។ អថខោ តំ ភិក្ខវេ ភិក្ខុ សម្មា វេទមានោ វេទេយ្យ ឥទំ ជាតុ វេទគូ ឥទំ ជាតុ បព្វជិ ឥទំ ជាតុ អបលិខតំ គណ្ឌាមូលំ បលិខណឹតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វេទគូ ហោតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វេទគូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បព្វជិ ហោតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទា វិមុត្តោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ បព្វជិ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុនោ ច អបលិខតំ គណ្ឌាមូលំ បលិខតំ ហោតិ ។ គណ្ឌោតិ ខោ ភិក្ខវេ ឥមស្សេតំ ចាតុម្មហាភូតិកស្ស កាយស្ស អធិវចនំ

ឆឡវគ្គ ទី ៥

អ្នកគ្របសង្កត់នូវវដ្ដៈ មិនទាន់ដីកឫសគល់នៃទុក្ខបានទេ តែប្រកាសថា ឫសគល់នៃទុក្ខខ្ញុំដីករំលើងបានហើយ ។ ម្នាលភិក្ខុទាំងឡាយ កាល ភិក្ខុ នឹងនិយាយឲ្យសមហេតុ ត្រូវនិយាយថា ខ្ញុំជាអ្នកសម្រេចវេទពិត ខ្ញុំជាអ្នកគ្របសង្កត់នូវវដ្ដៈពិត ខ្ញុំជាអ្នកដីករំលើងនូវឫសគល់នៃទុក្ខ ដែល មិនទាន់បានដីកពិត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្រេចវេទ តើដូច ម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់តាមពិតនូវការកើត ឡើង ការរលត់ អានិសង្ស ទោស និងការរលាស់ចេញនូវហេតុកើត ឡើងនៃផស្សៈទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកដល់នូវវេទ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកគ្របសង្កត់នូវវដ្ដៈតើដូច ម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុដឹងច្បាស់តាមពិតនូវការកើត ឡើង ការរលត់ អានិសង្ស ទោស និងការរលាស់ចេញនូវហេតុកើត ឡើងនៃផស្សៈទាំង ៦ ហើយ ជាអ្នករួចស្រឡះ (ចាកទុក្ខ) ព្រោះមិន បានប្រកាន់មាំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកគ្របសង្កត់នូវវដ្ដៈយ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឫសគល់នៃទុក្ខដែលមិនទាន់ដីករំលើង ភិក្ខុបានដីករំលើងហើយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពាក្យ ថាទុក្ខ ៗ ដូច្នេះនេះ ជាឈ្មោះរបស់កាយដែលប្រកបដោយមហាភូតរូប

មាតាបេត្តិកសម្ភវស្ស ឱទនកុម្មាសូបចយស្ស អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស ។ តណ្ហាមូលន្តិ ខោ ភិក្ខវេ តណ្ហាយេតំ អធិវចនំ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ ឯវំ ខោ ភិក្ខវេ ភិក្ខុនោ អបលិខតំ តណ្ហាមូលំ បលិខតំ ហោតិ ។ ឧទកោ សុទំ ភិក្ខវេ រាមបុត្តោ ឯវំ វាចំ ភាសតិ ឥទំ ជាតុ វេទគូ ឥទំ ជាតុ បព្វជិ ឥទំ ជាតុ អបលិខតំ តណ្ហាមូលំ បលិខណឹតិ ។ តំ ខោ បនេតំ ភិក្ខវេ ឧទកោ រាមបុត្តោ អវេទគូ យេវ សមានោ វេទគូស្មីតិ ភាសតិ អប្បព្វជិ យេវ សមានោ បព្វជិស្មីតិ ភាសតិ អបលិខតញ្ញេវ តណ្ហាមូលំ បលិខតម្មេ តណ្ហាមូលន្តិ ភាសតិ ។ ឥទំ ខោ ភិក្ខវេ

ទាំង ៤ កើតអំពីទឹកសុក្កៈជារបស់មាតានិងបិតា ដែលសន្សំឡើងដោយបាយនិងនំ មានសេចក្តីមិនទៀង ត្រូវប្រស់ព្រំគក់ច្របាច់ បែកធ្លាយខ្ចាត់ខ្ចាយជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ឫសគល់នៃទុក្ខនេះ ជាឈ្មោះរបស់តណ្ហា ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុលះបង់តណ្ហា ផ្តាច់ផ្តិលឫសគល់ ធ្វើមិនឲ្យមានទីកើតដូចជាត្នោតកំបុតក ធ្វើមិនឲ្យមានកំណើត មិនឲ្យកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ឫសគល់នៃទុក្ខដែលមិនទាន់ជីករំលើង ឈ្មោះថាភិក្ខុបានគាស់រំលើងហើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧទកពាមបុត្តប្រកាសវាចាយ៉ាងនេះថា ខ្ញុំជាអ្នកសម្រេចនូវវេទពិត ខ្ញុំជាអ្នកគ្រប់សង្កត់នូវវដ្តៈពិត ខ្ញុំជាអ្នកជីកឫសគល់នៃទុក្ខ ដែលគេមិនទាន់ជីកពិត ។ ម្នាលភិក្ខុទាំងឡាយ ឧទកពាមបុត្ត ជាអ្នកមិនទាន់សម្រេចនូវវេទទេ តែប្រកាសសេចក្តីនោះថាខ្ញុំជាអ្នកសម្រេចនូវវេទ មិនមែនជាអ្នកគ្រប់សង្កត់នូវវដ្តៈទេ តែប្រកាសថា ខ្ញុំជាអ្នកគ្រប់សង្កត់នូវវដ្តៈ មិនទាន់ជីករំលើងឫសគល់នៃទុក្ខទេ តែប្រកាសថា ខ្ញុំបានជីកឫសគល់នៃទុក្ខហើយ ។ ម្នាលភិក្ខុទាំងឡាយ

ឆឡវគ្គោ បញ្ចមោ

ភិក្ខុ សម្មា វេទមានោ វេទេយ្យ ឥទំ ជាតុ វេទគូ ឥទំ ជាតុ បព្វជិ ឥទំ ជាតុ អបលិខតំ គណ្ឌាមូលំ បលិខ-ណីតិ ។ ទសមំ ។

ឆឡវគ្គោ បញ្ចមោ ។

តស្សុទ្ទានំ

ទ្វេ សង្គយ្ហា បរិហានំ
បមាទវិហារី ច សំវរោ
សមាធិ បដិសល្លីនំ
ទ្វេ ន តុម្ហាកេន ឧទកោតិ ។

សឡាយតនវគ្គេ បណ្ណាសកំ ទុតិយំ ។

តស្សុទ្ទានំ

អវិជ្ជា មិគជាលំ[១] ខោ
គិលានំ ឆន្នំ ចតុត្ថកំ
ឆឡវគ្គេន បញ្ញាសំ
ទុតិយោ បញ្ញាសកោ អយន្តិ ។

១ ម. មិគជាលញ្ច ។

ឆឡវគ្គ ទី ៥

កាលបើភិក្ខុ នឹងនិយាយឲ្យសមហេតុ ត្រូវនិយាយថា ខ្ញុំជាអ្នកសម្រេចនូវវេទពិត ខ្ញុំជាអ្នកគ្រប់សង្កត់នូវវេដ្ដៈពិត ខ្ញុំជាអ្នកដកលំលើងនូវឫសគល់នៃទុក្ខដែលមិនទាន់ដកលំលើងពិត ។ ចប់សូត្រ ទី ១០ ។

ចប់ ឆឡវគ្គ ទី ៥ ។

## ឧទ្ទាននៃឆឡវគ្គនោះ គឺ

និយាយអំពីការរួបរួម ២ សូត្រ ការសាបសូន្យ ១ ភិក្ខុអ្នកនៅដោយសេចក្ដីប្រហែស ១ ការសង្រួម ១ សមាធិ ១ ការស្ងប់ស្ងាត់ ១ របស់មិនមែនរបស់អ្នកទាំងឡាយ ២ សូត្រ ឧទកវាមបុត្ត ១ ។

ចប់ ទុតិយបណ្ណាសកៈ ក្នុងសឡាយតនវគ្គ ។

## ឧទ្ទាននៃទុតិយបណ្ណាសកៈនោះ គឺ

អវិជ្ជាវគ្គ ១ មិគជាលវគ្គ ១ គិលានវគ្គ ១ ឆន្នវគ្គជាគម្រប់បួន ១ ឆឡវគ្គ ១ ហាសិបសូត្រនេះ ជាទុតិយបណ្ណាសកៈ ។

# តតិយបណ្ណាសកំ

# យោគក្ខេមិវគ្គោ

[១៨០] យោគក្ខេមិបរិយាយំ វោ ភិក្ខវេ ធម្មប-
រិយាយំ ទេសិស្សាមិ តំ សុណាថ ។ កតមោ ច
ភិក្ខវេ យោគក្ខេមិបរិយាយោ ធម្មបរិយាយោ ។ សន្តិ
ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា
បិយរូបា កាមូបសញ្ហិតា រជនីយា តេ តថាគ-
តស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កត-
តា អាយតឹ អនុប្បាទធម្មា តេសញ្ច បហានាយ
អក្ខាសិ យោគំ តស្មា តថាគតោ យោគក្ខេមីតិ
វុច្ចតិ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា
។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា

# តតិយបណ្ណាសកៈ

## យោគក្ខេមិវគ្គ

[១៥០] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម្មបរិយាយ[១] ជាហេតុរបស់បុគ្គលអ្នកមានសេចក្តីក្សេមចាកយោគៈ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវពាក្យនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះធម្មបរិយាយជាហេតុរបស់បុគ្គលអ្នកមានសេចក្តីក្សេមចាកយោគៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបដែលបុគ្គលគប្បីដឹងបានដោយភ្នែក ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ រូបទាំងនោះ តថាគតបានលះបង់ បានគាស់រំលើងឫសគល់ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅ មួយទៀត តថាគតក៏បានប្រាប់នូវសេចក្តីព្យាយាម ដើម្បីលះបង់នូវរូបទាំងនោះចេញ ព្រោះហេតុនោះ បានជាគេហៅតថាគតថាជាបុគ្គលមានសេចក្តីក្សេមចាកយោគៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រសដែលបុគ្គលគប្បីដឹងបានដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម្មារម្មណ៍ដែលបុគ្គលគប្បីដឹងបានដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា

---

១ ធម៌ជាហេតុ ។

កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តេសញ្ច បហានាយ អក្ខាសិ យោគំ តស្មា តថាគតោ យោគក្ខេមីតិ វុច្ចតិ ។ អយំ ខោ ភិក្ខវេ យោគក្ខេមិបរិយាយោ ធម្មបរិយាយោតិ ។ បឋមំ ។

[១៨១] កិស្មឹ នុ ខោ ភិក្ខវេ សតិ កិំ[១] ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ ចក្ខុស្មឹ ខោ ភិក្ខវេ សតិ ចក្ខុំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ ជិវ្ហាយ សតិ ជិវ្ហំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ មនស្មឹ សតិ មនំ ឧបាទាយ ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ តំ កឹ មញ្ញថ ភិក្ខវេ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។

---

១ ម. កិន្តិ ទិស្សតិ ។

គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ធម្មារម្មណ៍ទាំងនោះ តថាគតបានលះបង់ បានគាស់រំលើងឫសគល់ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត បានធ្វើឲ្យលែងមានបែបភាព មានសភាពមិនកើតឡើងតទៅ មួយទៀត តថាគត បានប្រាប់នូវសេចក្តីព្យាយាម ដើម្បីលះបង់នូវធម្មារម្មណ៍ទាំងនោះចេញ ព្រោះហេតុនោះ បានជាគេហៅតថាគត ថាជាបុគ្គលមានសេចក្តីក្សេមចាកយោគៈ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាធម្មបរិយាយ ជាហេតុនៃបុគ្គលមានសេចក្តីក្សេមចាកយោគៈ ។ ចប់សូត្រ ទី ១ ។

[១៩១] ម្នាលភិក្ខុទាំងឡាយ កាលបើហេតុអ្វីមាន អាស្រ័យហេតុអ្វី ទើបសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ ម្នាលភិក្ខុទាំងឡាយ កាលបើចក្ខុមាន អាស្រ័យចក្ខុ ទើបសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបាន ។ បេ ។ កាលបើអណ្តាតមាន អាស្រ័យអណ្តាត ទើបសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបាន ។ បេ ។ កាលបើចិត្តមាន អាស្រ័យចិត្ត ទើបសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះថាដូចម្តេច ចក្ខុទៀង ឬមិនទៀង ។

អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យ អជ្ឈត្តំ សុខទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យ អជ្ឈត្តំ សុខទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។ បេ ។ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ ឧប្បជ្ជេយ្យ អជ្ឈត្តំ សុខទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា

មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះ តើនឹងមានសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបាន ដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ បេ ។ អណ្តាតទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះ តើនឹងមានសេចក្តីសុខទុក្ខខាងក្នុងកើតឡើងបានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ បេ ។ ចិត្តទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះ តើនឹងមានសេចក្តីសុខទុក្ខខាងក្នុង កើតឡើងបានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវកអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង ។ បេ ។ នឿយណាយនឹងអណ្តាតផង នឿយណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក

វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថ-ត្តាយាតិ បជានាតីតិ ។ ទុតិយំ ។

[១៥២] ទុក្ខស្ស ភិក្ខវេ សមុទយញ្ច អត្ថង្គមញ្ច ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ ទុក្ខស្ស សមុទយោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទ-នា វេទនាបច្ចយា តណ្ហា អយំ ទុក្ខស្ស សមុទយោ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនា-បច្ចយា តណ្ហា អយំ ទុក្ខស្ស សមុទយោ ។ បេ ។

ចិត្តក៏រួចស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងថាចិត្តរួចស្រឡះហើយ ក៏កើតមាន ។ អរិយសាវ័កនោះ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ២ ។

[១៥២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើងនិងសេចក្តីអស់ទៅនៃទុក្ខ ចូរអ្នកទាំងឡាយប្រុងស្តាប់នូវពាក្យនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីកើតឡើងនៃទុក្ខ តើដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ នេះជាសេចក្តីកើតឡើងនៃទុក្ខ ។ បេ ។ ជិវ្ហាវិញ្ញាណកើតឡើងព្រោះអាស្រ័យអណ្តាតនិងរស ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើងព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើងព្រោះវេទនាជាបច្ច័យ នេះ ជាសេចក្តីកើតឡើងនៃទុក្ខ ។ បេ ។

មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា ។ អយំ ខោ ភិក្ខវេ ទុក្ខស្ស សមុទយោ ។

[១៨៣] កតមោ ច ភិក្ខវេ ទុក្ខស្ស អត្ថង្គមោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោ-ធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ ទុក្ខស្ស អត្ថង្គមោ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា

មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម៌ ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើងព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើងព្រោះវេទនាជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្តីកើតឡើងនៃទុក្ខ ។

[១៥៣] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីអស់ទៅនៃទុក្ខ តើដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើងព្រោះវេទនាជាបច្ច័យ សេចក្តីរលត់នៃឧបាទាន ព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង សេចក្តីរលត់នៃភពព្រោះរលត់នៃឧបាទាន សេចក្តីរលត់នៃជាតិព្រោះរលត់នៃភព ជរាមរណៈរលត់ទៅព្រោះរលត់នៃជាតិ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏រលត់ទៅដែរ ។ សេចក្តីរលត់នៃទុក្ខទាំងអស់នេះយ៉ាងនេះ ។ នេះជាសេចក្តីអស់ទៅនៃទុក្ខ ។ បេ ។ ជិវ្ហាវិញ្ញាណកើតឡើងព្រោះអាស្រ័យអណ្តាតនិងរស ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើងព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ

តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ។ បេ ។ អយំ ទុក្ខស្ស អត្ថង្គមោ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ ខោ ភិក្ខវេ ទុក្ខស្ស អត្ថង្គមោតិ ។ តតិយំ ។

[១៨៤] លោកស្ស ភិក្ខវេ សមុទយញ្ច អត្ថង្គមញ្ច ទេសិស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ លោកស្ស សមុទយោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ

សេចក្តីរលត់នៃឧបាទាន ព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង ព្រោះរលត់នៃឧបាទាន ។ បេ ។ នេះជាសេចក្តីអស់ទៅនៃទុក្ខ ។ បេ ។ មនោវិញ្ញាណកើតឡើងព្រោះអាស្រ័យចិត្តនិងធម៌ ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើងព្រោះវេទនាជាបច្ច័យ សេចក្តីរលត់នៃឧបាទានព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង សេចក្តីរលត់នៃភព ព្រោះរលត់នៃឧបាទាន សេចក្តីរលត់នៃជាតិព្រោះរលត់នៃភព ជរាមរណៈរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏រលត់ទៅដែរ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាសេចក្តីរលត់ទៅនៃទុក្ខ ។ ចប់សូត្រ ទី ៣ ។

[១៥២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេចក្តីកើតឡើងនិងសេចក្តីរលត់ទៅនៃលោក[១] ចូរអ្នកទាំងឡាយប្រុងស្តាប់នូវពាក្យនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីកើតឡើងនៃលោក តើដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ

១ សំដៅយកសង្ខារលោក ។

ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ អយំ លោកស្ស សមុទយោ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ អយំ ខោ ភិក្ខវេ លោកស្ស សមុទយោ ។

[១៩៥] កតមោ ច ភិក្ខវេ លោកស្ស អត្ថង្គមោ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ

ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏កើតមានដែរ ។ នេះឯងជាសេចក្ដីកើតឡើងនៃលោក ។ បេ ។ រមែងកើតឡើងព្រោះអាស្រ័យអណ្ដាតនិងរស ។ បេ ។ មនោវិញ្ញាណកើតឡើងព្រោះអាស្រ័យចិត្តនិងធម៌ ការប្រជុំនៃធម៌ទាំង៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាបច្ច័យ ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខ តូច-ចិត្ត ចង្អៀតចិត្ត ក៏កើតមានដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្ដីកើតឡើងនៃលោក ។

[១៥៥] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីអស់ទៅនៃលោក តើដូចម្ដេច ។ ចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ សេចក្ដីរលត់នៃឧបាទានព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង សេចក្ដីរលត់នៃភព ព្រោះរលត់នៃឧបាទាន

## យោគក្ខេមិវគ្គោ បឋមោ

ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ លោកស្ស អត្ថង្គមោ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ អយំ ខោ ភិក្ខវេ លោកស្ស អត្ថង្គមោតិ ។ ចតុត្ថំ ។

[១៨៦] កិស្មឹ នុ ខោ ភិក្ខវេ សតិ កឹ ឧបាទាយ កឹ អភិនិវិស្ស សេយ្យោហមស្មីតិ វា ហោតិ សទិសោហមស្មីតិ វា ហោតិ ហីនោហមស្មីតិ វា ហោតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ។ ចក្ខុស្មឹ ខោ ភិក្ខវេ សតិ ចក្ខុំ ឧបាទាយ ចក្ខុំ អភិនិវិស្ស

សេចក្តីរលត់នៃជាតិព្រោះរលត់នៃភព ជរាមរណៈរលត់ទៅ ព្រោះរលត់នៃជាតិ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏រលត់ទៅដែរ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះយ៉ាងនេះ ។ នេះឯងជាសេចក្តីអស់ទៅនៃលោក ។ បេ ។ កើតឡើងព្រោះអាស្រ័យអណ្តាតនិងរស ។ បេ ។ មនោវិញ្ញាណកើតឡើងព្រោះអាស្រ័យចិត្តនិងធម៌ ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ សេចក្តីរលត់ទៅនៃឧបាទានព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង ។ បេ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្តីអស់ទៅនៃលោក ។ ចប់សូត្រ ទី ៨ ។

[១៥៦] ម្នាលភិក្ខុទាំងឡាយ កាលបើហេតុអ្វីមាន អាស្រ័យហេតុអ្វី ធ្វើអ្វីឲ្យជាហេតុ ទើបមានការប្រកាន់ថា អាត្មាអញប្រសើរ (ជាងគេ) ឬថា អាត្មាអញស្មើ (នឹងគេ) ឬក៏ថា អាត្មាអញថោកទាប (ជាងគេ) ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌របស់យើងខ្ញុំទាំងឡាយ មានព្រះមានព្រះភាគជាមូល ។ ម្នាលភិក្ខុទាំងឡាយ កាលបើចក្ខុមាន អាស្រ័យនូវចក្ខុ ធ្វើចក្ខុឲ្យជាហេតុ

សេយ្យោហមស្មីតិ វា ហោតិ សទិសោហមស្មីតិ វា ហោតិ ហីនោហមស្មីតិ វា ហោតិ ។ បេ ។ ជិវ្ហាយ សតិ ។ បេ ។ មនស្មឹ សតិ មនំ ឧបាទាយ មនំ អភិនិវិស្ស សេយ្យោហមស្មីតិ វា ហោតិ សទិសោហមស្មីតិ វា ហោតិ ហីនោហមស្មីតិ វា ហោតិ ។ តំ កឹ មញ្ញថ ភិក្ខវេ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុ-បាទាយ សេយ្យោហមស្មីតិ វា អស្ស សទិសោហ-មស្មីតិ វា អស្ស ហីនោហមស្មីតិ វា អស្សាតិ ។ នោ ហេតំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ អបិ នុ តំ អនុបាទាយ សេយ្យោហមស្មីតិ វា

ទើបមានការប្រកាន់ថា អាត្មាអញប្រសើរ (ជាងគេ) ឬថា អាត្មាអញស្មើ (នឹងគេ) ឬក៏ថា អាត្មាអញថោកទាប (ជាងគេ) ។ បេ ។ កាលបើអណ្តាតមាន ។ បេ ។ កាលបើចិត្តមាន អាស្រ័យនូវចិត្ត ធ្វើចិត្តឲ្យជាហេតុ ទើបមានការប្រកាន់ថា អាត្មាអញប្រសើរ (ជាងគេ) ឬថា អាត្មាអញស្មើ (នឹងគេ) ឬក៏ថា អាត្មាអញថោកទាប (ជាងគេ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះថាដូចម្តេច ចក្ខុទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះ តើនឹងមានសេចក្តីប្រកាន់ថា អាត្មាអញប្រសើរ (ជាងគេ) ឬថា អាត្មាអញស្មើ (នឹងគេ) ឬក៏ថា អាត្មាអញថោកទាប (ជាងគេ) បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ បេ ។ អណ្តាត ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចិត្តទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បើមិនអាស្រ័យនូវរបស់នោះ តើនឹងមានសេចក្តីប្រកាន់ថា អាត្មាអញប្រសើរ (ជាងគេ)

អស្ស សទិសោហមស្មីតិ វា អស្ស ហីនោហមស្មីតិ វា អស្សាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ បញ្ចមំ ។

[១៨៧] សញ្ញោជនិយេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ សញ្ញោជនញ្ច តំ សុណាថ ។ កតមេ ច ភិក្ខវេ សញ្ញោជនិយា ធម្មា កតមញ្ច សញ្ញោជនំ ។ ចក្ខុំ ភិក្ខវេ សញ្ញោជនិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ តំ

ឬថា អាត្មាអញស្មើ (នឹងគេ) ឬក៏ថា អាត្មាអញថោកទាប (ជាងគេ) បានដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង ។ បេ ។ នឿយណាយនឹងអណ្តាតផង ។ បេ ។ នឿយណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏រួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹង ថាចិត្តរួចស្រឡះហើយ ក៏កើតមាន ។ អរិយសាវ័កនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៥ ។

[១៥៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ជាហេតុនៃសំយោជនៈ និងសំយោជនៈ ចូរអ្នកទាំងឡាយប្រុងស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាហេតុនៃសំយោជនៈតើដូចម្តេច សំ-យោជនៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុឈ្មោះថាធម៌ជាហេតុនៃសំយោជនៈ សេចក្តីត្រេកត្រអាលណា ក្នុងចក្ខុនោះ សេចក្តីត្រេក

តត្ថ សញ្ញោជនំ ។ បេ ។ ជិវ្ហា សញ្ញោជនិយោ ធម្មោ ។ បេ ។ មនោ សញ្ញោជនិយោ ធម្មោ យោ តត្ថ ឆន្ទ-រាគោ តំ តត្ថ សញ្ញោជនំ ។ ឥមេ វុច្ចន្តិ ភិក្ខវេ សញ្ញោជនិយា ធម្មា ឥទំ សញ្ញោជនន្តិ ។ ឆដ្ឋំ ។

[១៩៨] ឧបាទានិយេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ ឧបាទានំ ច តំ សុណាថ ។ កតមេ ច ភិក្ខវេ ឧបាទានិយា ធម្មា កតមញ្ចុបាទានំ ។ ចក្ខុំ ភិក្ខវេ ឧបាទានិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានំ ។ បេ ។ ជិវ្ហា ឧបាទានិយា ធម្មា ។ បេ ។ មនោ ឧបាទានិយោ ធម្មោ យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានំ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ឧបាទានិយា ធម្មា ឥទំ ឧបាទានន្តិ ។ សត្តមំ ។

ត្រអាលនោះ ឈ្មោះថាសំយោជនៈក្នុងចក្ខុនោះ ។ បេ ។ អណ្តាតឈ្មោះថាធម៌ជាហេតុនៃសំយោជនៈ ។ បេ ។ ចិត្តឈ្មោះថាធម៌ជាហេតុនៃសំ-យោជនៈ សេចក្តីត្រេកត្រអាលណា ក្នុងចិត្តនោះ សេចក្តីត្រេកត្រអាលនោះ ឈ្មោះថាសំយោជនៈ ក្នុងចិត្តនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ជាហេតុនៃសំយោជនៈ នេះហៅថាសំយោជនៈ ។ ចប់សូត្រ ទី ៦ ។

[១៥៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម៌ជាហេតុនៃឧបាទាននិងឧបាទាន ចូរអ្នកទាំងឡាយ ប្រុងស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាហេតុនៃឧបាទាន តើដូចម្តេច ឧបាទាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុឈ្មោះថាធម៌ជាហេតុនៃឧបាទាន សេចក្តីត្រេកត្រអាលណាក្នុងចក្ខុនោះ សេចក្តីត្រេកត្រអាលនោះ ឈ្មោះថាឧបាទានក្នុងចក្ខុនោះ ។ បេ ។ អណ្តាតឈ្មោះថាធម៌ជាហេតុនៃឧបា-ទាន ។ បេ ។ ចិត្តឈ្មោះថាធម៌ជាហេតុនៃឧបាទាន សេចក្តីត្រេកត្រអាលណាក្នុងចិត្តនោះ សេចក្តីត្រេកត្រអាលនោះ ឈ្មោះថាឧបាទានក្នុងចិត្តនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាធម៌ជាហេតុនៃឧបាទាន នេះហៅថាឧបាទាន ។ ចប់សូត្រ ទី ៧ ។

២០១

## យោគក្ខេមិវគ្គោ បឋមោ

[១៨៩] ចក្ខុំ ភិក្ខវេ អនភិជានំ អបរិជានំ អវិរា-
ជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។ បេ ។ ជិវ្ហំ
។ បេ ។ មនំ អនភិជានំ អបរិជានំ អវិរាជយំ អប្ប-
ជហំ អភព្វោ ទុក្ខក្ខយាយ ។ ចក្ខុញ្ច ខោ ភិក្ខវេ
អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយ
។ បេ ។ ជិវ្ហំ កាយំ មនំ អភិជានំ បរិជានំ វិរាជយំ
បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ រូបេ ភិក្ខវេ អនភិជានំ
អបរិជានំ អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ ។
សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ អនភិជានំ អបរិជានំ
អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ រូបេ ច
ខោ ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ

យោគក្ខេមិវគ្គ ទី ១

[១៥៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនបានដឹងច្បាស់ មិនបានកំណត់ដឹង មិនបាននឿយណាយ មិនបានលះបង់ នូវចក្ខុទេ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ បេ ។ នូវអណ្តាត ។ បេ ។ បុគ្គលដែលមិនបានដឹងច្បាស់ មិនបានកំណត់ដឹង មិនបាននឿយណាយ មិនបានលះបង់ នូវចិត្តទេ មិនគួរដើម្បីអស់ទៅនៃទុក្ខបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលដែលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវចក្ខុនោះឯង ទើបគួរដើម្បីអស់ទៅនៃទុក្ខបាន ។ បេ ។ បុគ្គលដែលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវអណ្តាត កាយ ចិត្ត ទើបគួរដើម្បីអស់ទៅនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនបានដឹងច្បាស់ មិនបានកំណត់ដឹង មិនបាននឿយណាយ មិនបានលះបង់ នូវរូបទេ មិនគួរដើម្បីអស់ទៅ នៃទុក្ខបានឡើយ ។ បុគ្គលដែលមិនបានដឹងច្បាស់ មិនបានកំណត់ដឹង មិនបាននឿយណាយ មិនបានលះបង់ នូវសំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ទេ មិនគួរដើម្បីអស់ទៅ នៃទុក្ខបានឡើយ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលដែលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវរូប ទើបគួរ

ទុក្ខក្ខយាយ ។ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ ទុក្ខក្ខយាយាតិ ។ អដ្ឋមំ ។

[១៦០] ឯកំ សមយំ ភគវា ញាតិកេ[១] វិហរតិ គិញ្ជកាវសថេ ។ អថខោ ភគវា រហោគតោ បដិសល្លីនោ ឥមំ ធម្មបរិយាយំ អភាសិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ។ បេ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា

១ ឱ. ម. នាតិកេ ។

ដើម្បីអស់ទៅនៃទុក្ខបាន ។ បុគ្គលដែលដឹងច្បាស់ កំណត់ដឹង នឿយណាយ លះបង់ នូវសំឡេង ក្លិន រស ផ្សព្វ ធម្មារម្មណ៍ ទើបគួរដើម្បីអស់ទៅនៃទុក្ខបាន ។ ចប់សូត្រ ទី ៨ ។

[១៦០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងផ្ទះសំណាក់ដែលធ្វើដោយឥដ្ឋ ជិតស្រុកមួយឈ្មោះញាតិកៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចូលទៅសម្ងំនៅក្នុងទីស្ងាត់ ហើយសម្តែងនូវធម្មបរិយាយនេះថា ចក្ខុវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏កើតមានដែរ ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ យ៉ាងនេះ ។ បេ ។ រមែងកើតឡើងព្រោះអាស្រ័យអណ្តាតនិងរស ។ បេ ។ មនោវិញ្ញាណ រមែងកើតឡើងព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ

តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[១៦១] ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ បេ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ។ បេ ។

ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏កើតមានដែរ ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ យ៉ាងនេះ ។

[១៦១] ចក្ខុវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូប ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ សេចក្តីរលត់នៃឧបាទាន ព្រោះវិនាសនិងរលត់មិនសល់ នៃតណ្ហានោះឯង សេចក្តីរលត់នៃភព ព្រោះរលត់នៃឧបាទាន សេចក្តីរលត់នៃជាតិព្រោះរលត់នៃភព ជរាមរណៈរលត់ ព្រោះរលត់នៃជាតិ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ តូចចិត្ត ចង្អៀតចិត្ត ក៏រលត់ទៅដែរ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ យ៉ាងនេះ ។ បេ ។ រមែងកើតឡើងព្រោះអាស្រ័យអណ្តាតនិងរស ។ បេ ។

មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ។ បេ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។ នវមំ ។

[១៦២] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភគវតោ ឧបស្សុតឹ ឋិតោ ហោតិ ។ អទ្ទសា ខោ ភគវា តំ ភិក្ខុំ ឧបស្សុតឹ ឋិតំ ទិស្វាន តំ ភិក្ខុំ ឯតទវោច អស្សោសិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយន្តិ ។ ឯវំ ភន្តេ ។ ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយំ បរិយាបុណាហិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយំ ធារេហិ ត្វំ ភិក្ខុ ឥមំ ធម្មបរិយាយំ អត្ថសញ្ហិតោយំ ភិក្ខុ ធម្មបរិយាយោ អាទិព្រហ្មចរិយកោតិ ។ ទសមំ ។

យោគក្ខេមិវគ្គោ បឋមោ ។

មនោវិញ្ញាណ រមែងកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការប្រជុំនៃធម៌ទាំង ៣ ឈ្មោះថាផស្សៈ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ សេចក្តីរលត់នៃឧបាទាន ព្រោះវិនាសនិងរលត់មិនសល់នៃតណ្ហានោះឯង សេចក្តីរលត់នៃភពព្រោះរលត់នៃឧបាទាន ។ បេ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ យ៉ាងនេះ ។ ចប់សូត្រ ទី ៩ ។

[១៦២] សម័យនោះឯង ភិក្ខុមួយរូប ឈរអែបស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ក៏ទ្រង់ទតឃើញភិក្ខុនោះកំពុងឈរអែបស្តាប់ លុះឃើញហើយ ក៏ត្រាស់សួរភិក្ខុនោះ ដូច្នេះថា ម្នាលភិក្ខុ អ្នកបានឮធម្មបរិយាយនេះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុ ចូរអ្នករៀននូវធម្មបរិយាយនេះចុះ ម្នាលភិក្ខុ ចូរអ្នកទន្ទេញនូវធម្មបរិយាយនេះចុះ ម្នាលភិក្ខុ ចូរអ្នកចាំទុកនូវធម្មបរិយាយនេះចុះ ម្នាលភិក្ខុ ធម្មបរិយាយនេះឯង ប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ។ ចប់សូត្រ ទី ១០ ។

ចប់ យោគក្ខេមិវគ្គ ទី ១ ។

យោគក្ខេមិវគ្គោ បឋមោ

# តស្សុទ្ទានំ

យោគក្ខេមិ ឧបាទាយ
ទុក្ខលោកោ ច សេយ្យោ ច
សញ្ញោជនំ ឧបាទានំ
ទ្វេបរិជានំ(១) ឧបស្សុតីតិ ។

១ ឱ. ម. ទ្វេ បជានំ ។

យោគក្ខេមិវគ្គ ទី ១

# ឧទ្ទាននៃយោគក្ខេមិវគ្គនោះ គឺ

*និយាយអំពីបុគ្គលមានសេចក្តីក្សេមចាកយោគៈ ១ អំពីសុខទុក្ខកើតឡើងព្រោះអាស្រ័យ (ចក្ខុជាដើម) ១ អំពីសេចក្តីកើតនិងរលត់នៃទុក្ខ ១ អំពីសេចក្តីកើតនិងរលត់នៃលោក ១ អំពីសេចក្តីប្រកាន់ថា ប្រសើរជាដើម ១ អំពីសំយោជនៈ ១ អំពីឧបាទាន ១ អំពីបុគ្គលកំណត់ដឹងមាន ២ លើក អំពីភិក្ខុឈរអែបស្តាប់ធម៌ ១ ។*

---

# លោកកាមគុណវគ្គោ

[១៦៣] សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អាវាសគតោ មារស្ស មារស្ស វសំ គតោ បដិមុក្កស្ស មារចាសោ ពន្ធោ សោ មារពន្ធនេន យថាកាមករណីយោ ចាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អាវាសគតោ មារស្ស មារស្ស វសំ គតោ បដិមុក្កស្ស មារចាសោ ពន្ធោ សោ មារពន្ធនេន យថាកាមករណីយោ ចាបិមតោ ។

# លោកកាមគុណវគ្គ

[១៦៣] ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងបានដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ[១] ចំពោះរូបនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ទៅកាន់លំនៅនៃមារ ទៅកាន់អំណាចនៃមារ អន្ទាក់នៃមារ ក៏ចងអវយវៈភិក្ខុនោះ ភិក្ខុនោះឈ្មោះថាជាប់ដោយចំណងនៃមារ គួរមារធ្វើតាមប្រាថ្នាបាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងបានដោយអណ្ដាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះអារម្មណ៍នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ទៅកាន់លំនៅនៃមារ ទៅកាន់អំណាចនៃមារ អន្ទាក់របស់មារ ក៏ចងអវយវៈភិក្ខុនោះ ភិក្ខុនោះឈ្មោះថាជាប់ដោយចំណងនៃមារ គួរមារធ្វើតាមប្រាថ្នាបាន ។

១ ជាឈ្មោះរបស់តណ្ហា ។

## ២០៧

### លោកកាមគុណវគ្គោ ទុតិយោ

[១៦៨] សន្តិ ច ខោ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន អាវាសគតោ មារស្ស ន មារស្ស វសំ គតោ ឧម្មុក្កស្ស មារបាសោ មុត្តោ សោ មារពន្ធនេន ន យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន អាវាសគតោ មារស្ស ន មារស្ស វសំ គតោ ឧម្មុក្កស្ស មារបាសោ មុត្តោ សោ មារពន្ធនេន ន យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា

លោកកាមគុណវគ្គ ទី ២

[១៦៤] ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងបានដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនប៉ិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះទេ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនេះហៅថា មិនទៅកាន់លំនៅនៃមារ មិនទៅកាន់អំណាចនៃមារ អន្ទាក់របស់មារក៏របូតចេញអំពីអវយវៈភិក្ខុនោះ ភិក្ខុនោះឈ្មោះថារួចចាកចំណងនៃមារ មិនគួរមារធ្វើតាមប្រាថ្នាបានឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងបានដោយអណ្តាត ជារសគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនប៉ិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរសនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មិនទៅកាន់លំនៅនៃមារ មិនទៅកាន់អំណាចនៃមារ អន្ទាក់របស់មារក៏របូតចេញអំពីអវយវៈភិក្ខុនោះ ភិក្ខុនោះឈ្មោះថារួចចាកចំណងនៃមារ មិនគួរមារធ្វើតាមប្រាថ្នាបានឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន អាវាសគតោ មារស្ស ន មារស្ស វសំ គតោ ឧម្មុក្កោ មារបាសោ មុត្តោ សោ មារពន្ធនេន ន យថាកាមករណីយោ បាបិមតោតិ ។ បឋមំ ។

[១៦៥] សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ពទ្ធោ ចក្ខុវិញ្ញេយ្យេសុ រូបេសុ អាវាសគតោ មារស្ស មារស្ស វសំ គតោ យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា

ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនបិត នៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មិនទៅកាន់លំនៅនៃមារ មិនទៅកាន់អំណាចនៃមារ អន្ទាក់នៃមារក៏របូតចេញអំពីអវយវៈភិក្ខុនោះ ភិក្ខុនោះឈ្មោះថារួចចាកចំណងនៃមារ មិនគួរមារធ្វើតាមប្រាថ្នាបានឡើយ ។ ចប់សូត្រ ទី ១ ។

[១៦៥] ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងបានដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ បិត នៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ជាប់ក្នុងរូបដែលគប្បីដឹងដោយចក្ខុ ទៅកាន់លំនៅនៃមារ ទៅកាន់អំណាចនៃមារ គួរមារធ្វើតាមប្រាថ្នាបាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងបានដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

វេជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ពទ្ធោ មនោវិញ្ញេយ្យេសុ ធម្មេសុ អាវាសគតោ មារស្ស មារស្ស វសំ គតោ យថាកាមករណីយោ បាបិមតោ ។

[១៦៦] សន្តិ ច ខោ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ មុត្តោ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ន អាវាសគតោ មារស្ស ន មារស្ស វសំ គតោ ន យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។

ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ជាប់ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ទៅកាន់លំនៅនៃមារ ទៅកាន់អំណាចនៃមារ គួរមារធ្វើតាមប្រាថ្នាបាន ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងបានដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះរូបនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថារួចចាករូបដែលគប្បីដឹងបានដោយចក្ខុ មិនទៅកាន់លំនៅនៃមារ មិនទៅកាន់អំណាចនៃមារ មិនគួរមារធ្វើតាមប្រាថ្នាបានឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងដោយអណ្ដាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើ មិនឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះទេ ។

អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ មុត្តោ មនោវិញ្ញេយ្យេហិ ធម្មេហិ ន អាវាសគតោ មារស្ស ន មារស្ស វសំ គតោ ន យថាកាមករណីយោ បាបិមតោតិ ។ ទុតិយំ ។

[១៦៧] នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ។ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមីតិ ។ ឥទំ វត្វា ភគវា ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា រួចចាកជម្នារម្មណ៍ដែលគប្បីដឹង បានដោយចិត្ត មិនទៅកាន់លំនៅនៃមារ មិនទៅកាន់អំណាចនៃមារ មិនគួរមារធ្វើតាមប្រាថ្នាបានឡើយ ។ ចប់សូត្រ ទី ២ ។

[១៦៧] ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវទីបំផុតនៃលោក[១]ថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វ ដែលមិនទាន់ដល់នូវទីបំផុតនៃលោក[២] ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ លុះព្រះមានព្រះភាគពោលពាក្យនេះហើយ ក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ។ កាលដែលព្រះមានព្រះភាគទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ទើបភិក្ខុទាំងនោះមានសេចក្តីប្រឹក្សា ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគសម្តែងនូវឧទ្ទេសនេះឯង ដោយសង្ខេប ដល់យើងទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារវិញទៅ (សេចក្តីដែលព្រះអង្គសម្តែងនោះថា) ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត

១ សំដៅយកចក្រវាល ។ ២ សំដៅយកសង្ខារ ។

អប្បត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមីតិ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចា-យស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុប-សង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯត-មត្ថំ បដិបុច្ឆេយ្យាមាតិ ។

[១៦៨] អថខោ តេ ភិក្ខូ យេន អាយស្មា អា-នន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អា-នន្ទេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណី-យំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ អានន្ទ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា

តថាគត មិនពោលនូវដំណើរសត្វ ដែលមិនទាន់ដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ឧទ្ទេសនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ នរណាហ្ន៎ នឹងគប្បីចែករំលែកនូវសេចក្តីដោយពិស្តារបាន ។ លំដាប់នោះឯង ភិក្ខុទាំងនោះ មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះអានន្ទមានអាយុនេះឯង ព្រះសាស្តាក៏ទ្រង់បានសរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារី-បុគ្គលក៏បានលើកតម្កើង ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ ព្រះអានន្ទមានអាយុ អាចនឹងចែករំលែកនូវសេចក្តីដោយពិស្តារបាន បើដូច្នោះពួកយើង គួរចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនុ៎ះ ចំពោះព្រះអានន្ទមានអាយុ ។

[១៦៨] គ្រានោះ ភិក្ខុទាំងនោះ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ គួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ដំណាលសេចក្តីនុ៎ះ ចំពោះព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគសម្តែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប ដល់យើង

វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមី-តិ ។ តេសន្នោ អាវុសោ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភ-ជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ អប្ប-ត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមីតិ ។

ទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ (សេចក្តីដែលព្រះអង្គសម្តែងនោះថា) ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ម្នាលអាវុសោ កាលដែលព្រះមានព្រះភាគស្តេចចេញទៅមិនយូរប៉ុន្មាន យើងទាំងឡាយ ក៏មានសេចក្តីប្រឹក្សាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ សម្តែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប ដល់យើងទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ (សេចក្តីដែលព្រះអង្គសម្តែងនោះថា) ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។

២១៣

លោកកាមគុណវគ្គោ ទុតិយោ

កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសន្នោ អាវុសោ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។ វិភជតាយស្មា អានន្ទោតិ ។ សេយ្យថាបិ នាម អាវុសោ បុរិសោ សារត្ថិកោ

លោកកាមគុណវគ្គ ទី ២

ឧទ្ទេសនេះ ព្រះមានព្រះភាគសម្តែងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ នរណាហ្ន៎ នឹងគប្បីចែករំលែកនូវសេចក្តីដោយពិស្តារបាន ។ ម្នាលអាវុសោ យើងទាំងឡាយ ក៏មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះអានន្ទមានអាយុនេះឯង ព្រះសាស្តាក៏ទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារីបុគ្គលក៏លើកតម្កើង ឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប មិនបានចែករំលែកនូវសេចក្តីដោយពិស្តារ ព្រះអានន្ទមានអាយុ អាចនឹងចែករំលែកនូវសេចក្តីដោយពិស្តារបាន បើដូច្នោះ គួរយើងទាំងឡាយ ចូលទៅរកព្រះអានន្ទមានអាយុលុះចូលទៅដល់ហើយ គួរសាកសួរសេចក្តីនុ៎ះ ចំពោះព្រះអានន្ទមានអាយុ ។ សូមព្រះអានន្ទមានអាយុ ចែករំលែកនូវសេចក្តីនោះ ។ ព្រះអានន្ទ តបថា ម្នាលអាវុសោទាំងឡាយ ដូចបុរសអ្នកត្រូវការខ្លឹមឈើ

សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ សាខាបលាសេ សារំ បរិយេសិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ ភគវន្តំ អតិសិត្វា តុម្ហេ[១] ឯតមត្ថំ បដិបុច្ឆិតព្វំ មញ្ញថ ។ សោ ហាវុសោ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុ-ភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថា-គតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តំ យេវ ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ អានន្ទ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ

ស្វែងរកខ្លឹមឈើ ត្រាច់ទៅកាន់ទីស្វែងរកខ្លឹមឈើ កាលបើឈើធំមានខ្លឹមនៅមាន រំលងគល់ រំលងដើមហើយសម្គាល់នូវមែកនិងស្លឹកថាជាខ្លឹមដែលត្រូវស្វែងរក មានឧបមាយ៉ាងណាមិញ សេចក្តីនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង គឺថាព្រះសាស្តា ទ្រង់គង់ក្នុងទីចំពោះមុខនៃលោកមានអាយុទាំងឡាយ អ្នកទាំងឡាយ រំលងព្រះមានព្រះភាគ ហើយសម្គាល់នូវយើង ថាជាបុគ្គលគួរសាកសួរចំពោះសេចក្តីនោះ ។ ម្នាលអាវុសោទាំងឡាយ ព្រោះថាព្រះមានព្រះភាគនោះ តែងជ្រាបនូវហេតុដែលគប្បីជ្រាប តែងឃើញនូវហេតុដែលគប្បីឃើញ ព្រះអង្គមានចក្ខុមានញាណ មានធម៌ មានសភាពជាបុគ្គលប្រសើរ ជាអ្នកប្រតិបត្តិធម៌ប្រព្រឹត្តធម៌ ណែនាំនូវប្រយោជន៍ ឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ទ្រង់មកហើយដោយប្រការដូច្នោះ ឯកាលដ៏សមគួរ ដល់ប្រស្នានុ៎ះ គឺកាលវេលាដែលអ្នកទាំងឡាយគួរតែសាកសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគដោះស្រាយ នឹងអ្នកទាំងឡាយ យ៉ាងណាអ្នកទាំងឡាយគប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះ ។ ម្នាលអាវុសោអានន្ទ ពិតដូច្នោះមែន ព្រះមានព្រះភាគទ្រង់ជ្រាប នូវហេតុដែលគប្បីជ្រាប ទ្រង់ឃើញនូវហេតុដែលគប្បីឃើញដោយពិត ព្រះអង្គមានចក្ខុ

២១៨

## លោកកាមគុណវគ្គោ ទុតិយោ

ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តញ្ញេវ ឯតមត្ថំ បដិបុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាម អបិ ចាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ វិភជតាយស្មា អានន្ទោ អគរុំ ករិត្វាតិ ។

មានញាណ មានធម៌ មានសភាពជាបុគ្គលប្រសើរ ជាអ្នកប្រតិបត្តិធម៌ ប្រព្រឹត្តធម៌ ណែនាំនូវប្រយោជន៍ ឲ្យនូវព្រះនិព្វាន ជាម្ចាស់នៃធម៌ ទ្រង់មកហើយ ដោយប្រការដូច្នោះ ឯកាលដ៏សមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលពួកយើង គួរតែសាកសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគទ្រង់ដោះស្រាយ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះ ចំណែកខាងព្រះអានន្ទមានអាយុ ព្រះសាស្តាក៏ទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារីបុគ្គលក៏លើកតម្កើង ឧទ្ទេសនេះ ដែលព្រះមានព្រះភាគសម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ សូមព្រះអានន្ទមានអាយុធ្វើនូវសេចក្តីមិនធូន់[១] ហើយចែករំលែកឲ្យទាន ។

---

១ អ្នកសម្តែងធម៌ ធ្វើឲ្យគេអារាធនារឿយ ៗ ឈ្មោះថាធ្វើឲ្យធ្ងន់ មួយទៀត កាលដែលសម្តែងធម៌ក៏សម្តែងឲ្យពិបាកស្តាប់ ពិបាកចូលចិត្តសេចក្តី ក្រពិបាកប្រហែលគេកកាយយកដីខ្សាច់អំពីបាតភ្នំសិនេរុ ឈ្មោះថាធ្វើឲ្យធ្ងន់ ។ អ្នកសម្តែងធម៌មិនធ្វើដូច្នេះ ឈ្មោះថាធ្វើមិនឲ្យធ្ងន់ ។ អដ្ឋកថា ។

[១៦៩] តេនហាវុសោ សុណាថ សាធុកំ ម-
នសិករោថ ភាសិស្សាមីតិ ឯវមាវុសោតិ ខោ តេ
ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយ-
ស្មា អានន្ទោ ឯតទវោច យំ ខោ វោ អាវុសោ ភគវា
សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា
ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ ជាហំ ភិក្ខវេ តមនេន
លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ បត្តេយ្យន្តិ វ-
ទាមិ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ
ទុក្ខស្សន្តកិរិយំ វទាមីតិ ។ ឥមស្ស ខ្វាហំ អាវុសោ
ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ
អវិភត្តស្ស វិត្ថារេន អត្ថំ អាជានាមិ ។ យេន ខោ
អាវុសោ លោកស្មឹ លោកសញ្ញី ហោតិ លោកមានី

[១៦៩] ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងស្តាប់ ធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំនឹងសម្តែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទមានអាយុ បានសម្តែងសេចក្តីនុ៎ះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសណា ដោយសង្ខេប ដល់អ្នកទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវទីបំផុតនៃលោកថា បុគ្គល គប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វ ដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ម្នាលអាវុសោទាំងឡាយ ឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ ខ្ញុំអាចដឹងសេចក្តីដោយពិស្តារបាន ។ ម្នាលអាវុសោទាំងឡាយ បុគ្គល ជាអ្នកមានសេចក្តីសម្គាល់ថាលោក មានសេចក្តីរាប់អានថាលោក ក្នុងលោក ដោយសភាវៈណា

២១៧

លោកកាមគុណវគ្គោ ទុតិយោ

អយំ វុច្ចតិ អរិយស្ស វិនយេ លោកោ ។ កេនាវុ-
សោ លោកស្មឹ លោកសញ្ញី ហោតិ លោកមានី ។
ចក្ខុនា ខោ អាវុសោ លោកស្មឹ លោកសញ្ញី
ហោតិ លោកមានី ។ សោតេន ខោ អាវុសោ ។
ឃានេន ខោ អាវុសោ ។ ជិវ្ហាយ ខោ អាវុសោ លោ-
កស្មឹ លោកសញ្ញី ហោតិ លោកមានី ។ កាយេន
ខោ អាវុសោ ។ មនេន ខោ អាវុសោ លោកស្មឹ
លោកសញ្ញី ហោតិ លោកមានី ។ យេន ខោ អា-
វុសោ លោកស្មឹ លោកសញ្ញី ហោតិ លោកមានី
អយំ វុច្ចតិ អរិយស្ស វិនយេ លោកោ ។ យំ ខោ នោ
អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន
អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ ជាយំ
ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទិដ្ឋេយ្យំ

*សភាវៈនេះហៅថាលោក ក្នុងអរិយវិន័យ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលជាអ្នកមានសេចក្ដីសម្គាល់ថាលោក មានសេចក្ដីរាប់អានថាលោក ក្នុងលោក តើដោយវត្ថុដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ បុគ្គលជាអ្នកមានសេចក្ដីសម្គាល់ថាលោក មានសេចក្ដីរាប់អានថាលោក ក្នុងលោក ដោយភ្នែកហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ ដោយត្រចៀកហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ ដោយច្រមុះហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ បុគ្គល ជាអ្នកមានសេចក្ដីសម្គាល់ថាលោក មានសេចក្ដីរាប់អានថាលោក ក្នុងលោក ដោយអណ្ដាតហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ ដោយកាយហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ បុគ្គល ជាអ្នកមានសេចក្ដីសម្គាល់ថាលោក មានសេចក្ដីរាប់អានថាលោក ក្នុងលោក ដោយចិត្តហ្នឹងឯង ។ ម្នាលអាវុសោទាំងឡាយ បុគ្គលជាអ្នកមានសេចក្ដីសម្គាល់ថាលោក មានសេចក្ដីរាប់អានថាលោក ក្នុងលោកដោយសភាវៈណា សភាវៈនេះហៅថាលោក ក្នុងអរិយវិន័យ ។ ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគសម្ដែង នូវឧទ្ទេសណាដោយសង្ខេប មិនចែករំលែកនូវសេចក្ដីដោយពិស្ដារ រួចក៏ក្រោកអំពីអាសនៈ ស្ដេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ*

បត្ថេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមីតិ ។ ឥមស្ស ខ្វាហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ អាកង្ខមានា ច បន តុម្ហេ អាយស្មន្តោ ភគវន្តញ្ញេវ ឧបសង្កមិត្វា ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។

[១៧០] ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បដិស្សុត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វ ដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ម្នាលអាវុសោទាំងឡាយ ឧទ្ទេសនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ ខ្ញុំអាចដឹងសេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ ម្នាលលោកមានអាយុទាំងឡាយ បើអ្នកទាំងឡាយប្រាថ្នាចង់ដឹង គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលសួរសេចក្តីនុ៎ះទៀតចុះ បើព្រះមានព្រះភាគទ្រង់ព្យាករយ៉ាងណា អ្នកទាំងឡាយគប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

[១៧០] ភិក្ខុទាំងនោះ បានទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ដូច្នេះហើយ ក៏ក្រោកអំពីអាសនៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ

២១៩

លោកកាមគុណវគ្គោ ទុតិយោ

ភគវន្តំ ឯតទវោចុំ យំ ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ បត្តេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ ទុក្ខស្ស-ន្តកិរិយំ វទាមីតិ ។ តេសំ នោ ភន្តេ អម្ហាកំ អចិ-របក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អា-វុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ នាហំ ភិក្ខវេ គមនេន លោកស្ស អន្តំ ញាតេយ្យំ ទដ្ឋេយ្យំ

លោកកាមគុណវគ្គ ទី ២

បានក្រាបទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សម្តែង នូវឧទ្ទេសណា ដោយសង្ខេបដល់ខ្ញុំព្រះអង្គទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ទ្រង់ចៀសចេញទៅពុំយូរប៉ុន្មាន ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្តីប្រឹក្សាដូច្នេះថា ម្នាលអាវុសោ ព្រះអង្គទ្រង់សម្តែងនូវឧទ្ទេសនេះឯងដោយសង្ខេប ដល់យើងទាំងឡាយ ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវទីបំផុតនៃលោកថា បុគ្គលគប្បីដឹង គប្បីឃើញ

បត្ថេយ្យន្តិ វទាមិ ន ច បនាហំ ភិក្ខវេ អប្បត្វា លោកស្ស អន្តំ ទុក្ខស្សន្តកិរិយំ វទាមីតិ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។ អថខោ មយំ ភន្តេ យេនាយស្មា អានន្ទោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆិម្ហា ។ តេសំ នោ ភន្តេ អាយស្មតា អានន្ទេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ អត្ថោ វិភត្តោតិ ។ បណ្ឌិតោ ភិក្ខវេ អានន្ទោ

គប្បីដល់ ដោយដំណើរទៅបានឡើយ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតមិនពោលនូវដំណើរសត្វ ដែលមិនបានដល់នូវទីបំផុតនៃលោក ហើយធ្វើនូវទីបំផុតនៃទុក្ខបានឡើយ ។ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ នរណាហ្ន៎ នឹងគប្បីចែករំលែកនូវសេចក្តីដោយពិស្តារបាន ។ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះ អានន្ទមានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាស-ព្រហ្មចារីបុគ្គលក៏លើកតម្កើង ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ ព្រះអានន្ទ មានអាយុ អាចចែករំលែកនូវសេចក្តីដោយពិស្តារបាន បើដូច្នោះ ពួក យើងត្រូវចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ត្រូវ សាកសួរសេចក្តីនុ៎ះ ចំពោះព្រះអានន្ទមានអាយុ ។ បពិត្រព្រះអង្គដ៏ ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយបាននាំគ្នាចូលទៅរកព្រះអានន្ទ មានអាយុ លុះចូលទៅដល់ហើយ បានសាកសួរសេចក្តីនុ៎ះចំពោះព្រះ អានន្ទមានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុក៏បាន ចែករំលែកនូវសេចក្តី ដោយអាការនេះ ដោយបទនេះ ដោយព្យញ្ជនៈ នេះ ដល់ខ្ញុំព្រះអង្គទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត

មហាបញ្ញោ ភិក្ខវេ អានន្ទោ មញ្ចេបិ តុម្ហេ ភិក្ខវេ ឯតមត្ថំ បដិបុច្ឆេយ្យាថ អហម្បិ តំ ឯវមេវ ព្យាករេយ្យំ យថាតំ អានន្ទេន ព្យាកតំ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ ។ តតិយំ ។

[១៧១] បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ យេ មយ្ហំ បញ្ច កាមគុណា ចេតសោ សម្ផុដ្ឋបុព្វា អតីតា និរុទ្ធា វិបរិណតា តត្រ មេ ចិត្តំ ពហុលំ គច្ឆមានំ គច្ឆេយ្យ បច្ចុប្បន្នេសុ វា អប្បំ វា អនាគតេសុ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ យេ មយ្ហំ បញ្ច កាមគុណា ចេតសោ សម្ផុដ្ឋបុព្វា អតីតា និរុទ្ធា វិបរិណតា តត្រ មេ អត្តរូបេន អប្បមាទោ សតិ ចេតសោ អារក្ខោ ករណីយោ ។ តស្មាតិហ ភិក្ខវេ តុម្ហាកម្បិ យេ តេ បញ្ច កាមគុណា ចេតសោ សម្ផុដ្ឋបុព្វា អតីតា

ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកមានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ បើទុកជាអ្នកទាំងឡាយសាកសួរសេចក្តីនុ៎ះនឹងតថាគត តថាគតក៏នឹងដោះស្រាយសេចក្តីនោះដូច្នោះដែរ ពាក្យនោះ អានន្ទដោះស្រាយយ៉ាងណា នុ៎ះ ជាសេចក្តីរបស់ពាក្យនោះ អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តីនោះយ៉ាងនោះចុះ ។ ចប់សូត្រ ទី ៣ ។

[១៧១] ម្នាលភិក្ខុទាំងឡាយ កាលមុនអំពីការត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មានសេចក្តីត្រិះរិះដូច្នេះថា កាមគុណទាំង ៥ ណា ដែលអាត្មាអញធ្លាប់ពាល់ត្រូវដោយចិត្ត ជាកាមគុណកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ ចិត្តរបស់អាត្មាអញ ច្រើនត្រាច់ទៅក្នុងកាមគុណនោះ ក្នុងបច្ចុប្បន្នកាល ឬចិត្តត្រាច់ទៅបន្តិចបន្តួចក្នុងកាមគុណជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាមគុណទាំង ៥ ណា ដែលអាត្មាអញធ្លាប់ពាល់ត្រូវដោយចិត្ត ជាកាមគុណកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ សេចក្តីមិនធ្វេសប្រហែស ការនឹករឭក ការរក្សានូវចិត្ត អាត្មាអញគួរធ្វើដោយសមគួរដល់ខ្លួន ក្នុងកាមគុណទាំង ៥ នោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ កាមគុណទាំង ៥ ណា ដែលអ្នកទាំងឡាយធ្លាប់ពាល់ត្រូវដោយចិត្ត ជាកាមគុណកន្លងទៅ

និរុទ្ធា វិបរិណតា តត្ថ វោ ចិត្តំ ពហុលំ គច្ឆមានំ គច្ឆេយ្យ បច្ចុប្បន្នេសុ វា អប្បំ វា អនាគតេសុ ។ តស្មា-តិហ ភិក្ខវេ តុម្ហាកម្បិ យេ តេ បញ្ច កាមគុណា ចេតសោ សម្ផុដ្ឋបុព្វា អតីតា និរុទ្ធា វិបរិណតា តត្ថ វោ អត្តរូបេន អប្បមាទោ សតិ ចេតសោ អារក្ខោ ករ-ណីយោតិ ។ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេ-ទិតព្វេ ។ យត្ថ ចក្ខុ និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ[១] សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ ជិវ្ហា និរុជ្ឈតិ រសសញ្ញា ច វិរជ្ជតិ ។ បេ ។ សេ អាយតនេ វេទិតព្វេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេតិ ។ ឥទំ វត្វា ភគវា

---

១ ម. និរុជ្ឈតិ ។

រលត់ទៅ ប្រែប្រួលទៅហើយ ចិត្តរបស់អ្នកទាំងឡាយ ច្រើនត្រាច់ទៅក្នុងកាមគុណនោះ ក្នុងបច្ចុប្បន្នកាល ឬចិត្តត្រាច់ទៅបន្តិចបន្តួចក្នុងកាមគុណជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ កាមគុណទាំង ៥ ណា ដែលអ្នកទាំងឡាយធ្លាប់ពាល់ត្រូវដោយចិត្ត ជាកាមគុណកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយ សេចក្ដីមិនធ្វេសប្រហែស ការទឹករឭក ការរក្សានូវចិត្ត អ្នកទាំងឡាយគួរធ្វើដោយសមគួរដល់ខ្លួន ក្នុងកាមគុណទាំង ៥ នោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ចក្ខុរមែងរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរូបក៏រមែងសាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ អណ្ដាតរមែងរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរសក៏រមែងសាបរលាបទៅក្នុងទីនោះ ។ បេ ។ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ចិត្តរមែងរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងធម្មារម្មណ៍ក៏រមែងសាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ

២២៣



ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និ-រុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ ជិវ្ហា ច និរុជ្ឈតិ រសសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេតិ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិ-តោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ

ក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ទើបភិក្ខុទាំងនោះ មានសេចក្តីប្រឹក្សា ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគសម្តែងនូវឧទ្ទេសនេះឯង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរូប ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ អណ្តាតរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរស ក៏សាបរលាបទៅ ក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ឧទ្ទេសដែលព្រះមានព្រះភាគសម្តែងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ នរណាហ្ន៎ នឹងគប្បីចែករំលែកសេចក្តីដោយពិស្តារបាន ។ លំដាប់នោះ ភិក្ខុទាំងនោះ មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះអានន្ទមានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារីបុគ្គល ក៏លើកតម្កើង

ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។

[១៧២] អថខោ តេ ភិក្ខូ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ អានន្ទ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ ជិវ្ហា ច និរុជ្ឈតិ រសសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។

ឧទ្ទេសដែលព្រះមានព្រះភាគសម្ដែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្ដី ដោយពិស្ដារនេះ ព្រះអានន្ទមានអាយុ អាចចែករំលែកនូវសេចក្ដីដោយពិស្ដារបាន បើដូច្នោះ ពួកយើងគួរចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ គួរសាកសួរសេចក្ដីនុ៎ះនឹងព្រះអានន្ទមានអាយុ ។

[១៧២] គ្រានោះឯង ភិក្ខុទាំងនោះ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ គួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ដំណាលសេចក្ដីនុ៎ះ ចំពោះព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគទ្រង់សម្ដែងនូវឧទ្ទេសនេះឯង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្ដីដោយពិស្ដារ រួចក៏ក្រោកអំពីអាសនៈ ស្ដេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរូបក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ អណ្ដាតរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរសក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។

លោកកាមគុណវគ្គោ ទុតិយោ

យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេតិ ។ តេសំ នោ អាវុសោ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និ-រុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ ជិវ្ហា ច និរុជ្ឈតិ រសសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និ-រុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិ-តព្វេតិ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ អាវុសោ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ

ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ម្នាលអាវុសោ កាលដែលព្រះមានព្រះភាគ ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ពួកយើង ក៏មានសេចក្តីប្រឹក្សា ដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសនេះឯង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរូប ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ អណ្តាតរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរស ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ នរណាហ្ន៎ នឹងចែករំលែកនូវសេចក្តី ដោយពិស្តារបាន ។ ម្នាលអាវុសោ ពួកយើង ក៏មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះអានន្ទមានអាយុនេះឯង ព្រះសាស្តា

ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។ វិភជតាយស្មា អានន្ទោតិ ។ សេយ្យថាបិ នាម អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ មហតោ រុក្ខស្ស ។ បេ ។ វិភជតាយស្មា អានន្ទោ អគរុំ ករិត្វាតិ ។

[១៧៣] តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អាយស្មា អានន្ទោ ឯតទវោច យំ ខោ វោ អាវុសោ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ

ទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារីបុគ្គលក៏លើកតម្កើង ឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែក នូវសេចក្តីដោយពិស្តារនេះ ព្រះអានន្ទមានអាយុ អាចនឹងចែករំលែកនូវ សេចក្តីដោយពិស្តារបាន បើដូច្នោះ ពួកយើងគប្បីចូលទៅរកព្រះអានន្ទ មានអាយុ លុះចូលទៅដល់ហើយ គប្បីសាកសួរសេចក្តីនុ៎ះចំពោះព្រះ អានន្ទមានអាយុ ។ សូមព្រះអានន្ទមានអាយុ ចែករំលែកសេចក្តីឲ្យ ទាន ។ ព្រះអានន្ទសម្តែងថា ម្នាលអាវុសោទាំងឡាយ ដូចបុរសអ្នក ត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅកាន់ទីស្វែងរកខ្លឹម ឈើ ។ បេ ។ សូមព្រះអានន្ទមានអាយុ ធ្វើសេចក្តីមិនធ្ងន់ ហើយ ចែករំលែកសេចក្តីឲ្យទាន ។

[១៧៣] ម្នាលអាវុសោទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយ ប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំនឹងសម្តែងឲ្យស្តាប់ ។ ភិក្ខុ ទាំងនោះ ក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទមានអាយុ ក៏សម្តែងនូវឧទ្ទេសនុ៎ះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសណា ដោយសង្ខេប ពុំបានចែក រំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅ កាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ

២២៧



សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេតិ ។ ឥមស្ស ខ្វាហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ អាជានាមិ ។ សឡាយតននិរោធំ ខោ ឯតំ អាវុសោ ភគវតា សន្ធាយ ភាសិតំ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ ។ សេ អាយតនេ វេទិតព្វេតិ ។ យំ ខោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ

លោកកាមគុណវគ្គ ទី ២

អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរូបក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ម្នាលអាវុសោទាំងឡាយ ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តី ដោយពិស្តារនេះ ខ្ញុំអាចដឹងនូវសេចក្តីដោយពិស្តារបាន ។ ម្នាលអាវុសោទាំងឡាយ ពាក្យនុ៎ះ ព្រះមានព្រះភាគ ទ្រង់ផ្អែកទៅលើសេចក្តីរលត់នៃសឡាយតនៈ ទើបទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរូប ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសណាដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារ រួចក៏ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះដំណើរនោះ

សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូប-សញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេតិ ។ ឥមស្ស ខ្វាហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ អាកង្ខមានា ច បន តុម្ហេ អាយស្មន្តោ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ ប-ដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។

[១៧៤] ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បដិស្សុត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯ-កមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ

អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងរូបក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ។ ម្នាលអាវុសោទាំងឡាយ ឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ ខ្ញុំអាចដឹងសេចក្តីដោយពិស្តារ យ៉ាងនេះឯង ។ ម្នាលលោកមានអាយុទាំងឡាយ បើអ្នកទាំងឡាយចង់ដឹង គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលសួរសេចក្តីនុ៎ះ ព្រះមានព្រះភាគទ្រង់ព្យាករដល់អ្នកទាំងឡាយ យ៉ាងណា អ្នកទាំងឡាយគប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

[១៧៤] ភិក្ខុទាំងនោះ ក៏ទទួលពាក្យនៃព្រះអានន្ទមានអាយុថា ករុណា អាវុសោ រួចក៏ក្រោកអំពីអាសនៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ

២២៩

## លោកកាមគុណវគ្គោ ទុតិយោ

ភគវន្តំ ឯតទវោចុំ យំ ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ ជិវ្ហា ច និរុជ្ឈតិ រសសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ តេសំ នោ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥធំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តស្មាតិហ ភិក្ខវេ សេ អាយតនេ វេទិតព្វេ យត្ថ ចក្ខុ ច និរុជ្ឈតិ រូបសញ្ញា ច វិរជ្ជតិ

ក៏ក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវឧទ្ទេសណា ដោយសង្ខេប ពុំបាន ចែករំលែកនូវសេចក្ដី ដោយពិស្ដារ រួចក៏ក្រោកអំពីអាសនៈ ស្ដេច ចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះ ដំណើរនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរូប ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បី ដឹងហេតុនោះ ។ បេ ។ អណ្ដាតរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ ក្នុងរស ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាប រលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បពិត្រព្រះ អង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ទ្រង់ចៀសចេញទៅមិនយូរ ប៉ុន្មាន ខ្ញុំព្រះអង្គទាំងឡាយ ក៏មានសេចក្ដីប្រឹក្សាដូច្នេះថា ម្នាលអាវុសោ ទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្ដែងនូវឧទ្ទេសនេះឯងដោយសង្ខេប ពុំបានចែករំលែកនូវសេចក្ដី ដោយពិស្ដារ ដល់យើងទាំងឡាយ រួចក៏ ក្រោកអំពីអាសនៈ ស្ដេចចូលទៅកាន់វិហារ ឯឧទ្ទេសនោះថា ម្នាល ភិក្ខុទាំងឡាយ ព្រោះដំណើរនោះ អ្នកទាំងឡាយ គប្បីដឹងហេតុនោះ ចក្ខុរលត់ទៅក្នុងទីណា សេចក្ដីសម្គាល់ក្នុងរូបក៏សាបរលាបទៅក្នុងទីនោះ

សេ អាយតនេ វេទិតព្វេ ។ បេ ។ យត្ថ មនោ ច និរុជ្ឈតិ ធម្មសញ្ញា ច វិរជ្ជតិ សេ អាយតនេ វេទិតព្វេ ។ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ តេសំ នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា អានន្ទោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា អានន្ទោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យ-ន្នូន មយំ យេនាយស្មា អានន្ទោ តេនុបសង្កមេ-យ្យាម ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯត-មត្ថំ បដិបុច្ឆេយ្យាមាតិ ។ អថខោ មយំ ភន្តេ យេនាយស្មា អានន្ទោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា

អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ បេ ។ ចិត្តរលត់ទៅក្នុងទីណា សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍ ក៏សាបរលាបទៅក្នុងទីនោះ អ្នកទាំងឡាយគប្បីដឹងហេតុនោះ ។ ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារនេះ នរណាហ្ន៎ នឹងចែករំលែកនូវសេចក្តី ដោយពិស្តារបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ក៏មានសេចក្តីប្រឹក្សាដូច្នេះថា ព្រះអានន្ទមានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរ ពួកអ្នកប្រាជ្ញជាសព្រហ្មចារីបុគ្គល ក៏លើកតម្កើង ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែង ដោយសង្ខេប ពុំបានចែករំលែកនូវសេចក្តីដោយពិស្តារបាន បើដូច្នោះ ពួកយើងគួរចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ត្រូវសាកសួរសេចក្តីនុ៎ះ ចំពោះព្រះអានន្ទមានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយ ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់

អាយស្មន្តំ អានន្ទំ ឯតមត្ថំ បដិបុច្ឆិម្ហា ។ តេសំ នោ ភន្តេ អាយស្មតោ អានន្ទេន ឥមេហិ អាការេហិ ឥមេហិ លិង្គេហិ[១] ឥមេហិ ព្យញ្ជនេហិ អត្ថោ វិភត្តោតិ ។ បណ្ឌិតោ ភិក្ខវេ អានន្ទោ មហាបញ្ញោ ភិក្ខវេ អានន្ទោ មមញ្ចេបិ តុម្ហេ ភិក្ខវេ ឯតមត្ថំ បដិបុច្ឆេយ្យាថ អហម្បិ តំ ឯវមេវ ព្យាករេយ្យំ យថា តំ អានន្ទេន ព្យាកតំ ឯសោ ចេវស្ស[២] អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ ។ ចតុត្ថំ ។

[១៧៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ សក្កោ ទេវានមិន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សក្កោ ទេវា-

១ ឱ. ម. បទេហិ ។ ២ ចេវ តស្សាតិបិ បាឋោ ។

ក៏សាកសួរសេចក្ដីនុ៎ះ ចំពោះព្រះអានន្ទមានអាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុបានចែករំលែកសេចក្ដី ដោយអាការនេះ ដោយលិង្គនេះ ដោយព្យញ្ជនៈនេះ ដល់យើងខ្ញុំទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ អានន្ទមានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ បើទុកជាអ្នកទាំងឡាយ សាកសួរសេចក្ដីនុ៎ះចំពោះតថាគត តថាគតក៏ដោះស្រាយសេចក្ដីនុ៎ះយ៉ាងហ្នឹងដែរ ពាក្យនោះអានន្ទដោះស្រាយយ៉ាងណា នុ៎ះជាសេចក្ដីរបស់ពាក្យនោះ អ្នកទាំង-ឡាយគប្បីចាំទុកនូវសេចក្ដីនោះ យ៉ាងនោះចុះ ។ ចប់សូត្រ ទី ៤ ។

[១៧៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង សក្កទេវានមិន្ទចូលមកគាល់ព្រះមានព្រះភាគ លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវានមិន្ទឋិតនៅក្នុងទីដ៏

នមិន្ទោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។

[១៧៦] សន្តិ ច ខោ ទេវានមិន្ទ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ ស-ឧបាទានោ ទេវានមិន្ទ ភិក្ខុ នោ បរិនិព្វាយតិ ។ បេ ។ សន្តិ ខោ ទេវានមិន្ទ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ ទេវានមិន្ទ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា

សមគួរហើយ ក៏ទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះមិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។

[១៧៦] ម្នាលទេវានមិន្ទ មានរូបដែលគប្បីដឹងដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ កាលដែលភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះ ក៏មាន សេចក្តីប្រកាន់មាំនូវរូបនោះក៏មាន ។ ម្នាលទេវានមិន្ទ ភិក្ខុដែលប្រកបដោយសេចក្តីប្រកាន់មាំរមែងមិនបរិនិព្វានឡើយ ។ បេ ។ ម្នាលទេវានមិន្ទ មានរសដែលគប្បីដឹងដោយអណ្តាត ។ បេ ។ ម្នាលទេវានមិន្ទ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ

មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទានោ ភេក្ខុ ទ្ធមិន្ទ ភិក្ខុ នោ បរិនិព្វាយតិ ។ អយំ ខោ ទេវានមិន្ទ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។

[១៧៧] សន្តិ ច ខោ ទេវានមិន្ទ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោ-សាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទានំ ។ អនុបាទានោ ទេវានមិន្ទ ភិក្ខុ បរិនិព្វា-យតិ ។ បេ ។ សន្តិ ខោ ទេវានមិន្ទ ជិវ្ហាវិញ្ញេយ្យា រសា

ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំចំពោះធម្មារម្មណ៍នោះ កាលដែលភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏មាន សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះក៏មាន ។ ម្នាលទេវានមិន្ទ ភិក្ខុដែលប្រកបដោយសេចក្តីប្រកាន់មាំ រមែងមិនបរិ-និព្វានឡើយ ។ ម្នាលទេវានមិន្ទ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។

[១៧៧] ម្នាលទេវានមិន្ទ មានរូបដែលគប្បីដឹងដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ កាលដែលភិក្ខុនោះ មិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះមិនមាន សេចក្តីប្រកាន់មាំនូវរូបនោះក៏មិនមាន ។ ម្នាលទេវានមិន្ទ ភិក្ខុដែលមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។ បេ ។ ម្នាលទេវានមិន្ទ មានរសដែលគប្បីដឹងដោយអណ្តាត

។ បេ ។ សន្តិ ខោ ឧបវាណ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទានំ ។ អនុបាទានោ ឧបវាណ ភិក្ខុ បរិនិព្វាយតិ ។ អយំ ខោ ឧបវាណ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ បញ្ចមំ ។

[១៧៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ បញ្ចសិខោ គន្ធព្វបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ បញ្ចសិខោ គន្ធព្វបុត្តោ ភគវន្តំ ឯតទវោច

។ បេ ។ ម្នាលទេវានមិន្ទ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលដែលភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះមិនមានសេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះក៏មិនមាន ។ ម្នាលទេវានមិន្ទ ភិក្ខុដែលមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។ ម្នាលទេវានមិន្ទ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ បរិ-និព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រទី ៤ ។

[១៧៨] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈ-កូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង បញ្ចសិខគន្ធព្វបុត្ត ចូលមកគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ លុះបញ្ចសិខគន្ធព្វបុត្តឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា

កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។

[១៧៩] សន្តិ ច ខោ បញ្ចសិខ ចក្ខុវិញ្ញេយ្យា រូបា ។ បេ ។ សន្តិ ខោ បញ្ចសិខ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទានោ បញ្ចសិខ ភិក្ខុ នោ បរិនិព្វាយតិ ។ អយំ ខោ បញ្ចសិខ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។

បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះមិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។

[១៧៩] ម្នាលបញ្ចសិខៈ មានរូបដែលគប្បីដឹងដោយចក្ខុ ។ បេ ។ ម្នាលបញ្ចសិខៈ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលដែលភិក្ខុនោះ ត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះ ក៏មាន សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះ ក៏មាន ។ ម្នាលបញ្ចសិខៈ ភិក្ខុដែលប្រកបដោយសេចក្តីប្រកាន់មាំ មិនបរិនិព្វានឡើយ ។ ម្នាលបញ្ចសិខៈ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។

[១៨០] សន្តិ ច ខោ បញ្ចសិខ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា ។ បេ ។ សន្តិ ខោ បញ្ចសិខ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទានំ ។ អនុបាទានោ បញ្ចសិខ ភិក្ខុ បរិនិព្វាយតិ ។ អយំ ខោ បញ្ចសិខ ហេតុ អយំ បច្ចយោ យេន មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ ឆដ្ឋំ ។

[១៨០] ម្នាលបញ្ចសិខៈ មានរូបដែលគប្បីដឹងដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ។ បេ ។ ម្នាលបញ្ចសិខៈ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលដែលភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះ មិនមាន សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះក៏មិនមាន ។ ម្នាលបញ្ចសិខៈ ភិក្ខុដែលមិនមានសេចក្តីប្រកាន់មាំ ទើបបរិនិព្វាន ។ ម្នាលបញ្ចសិខៈ ហេតុនេះឯង បច្ច័យនេះឯង ដែលនាំឲ្យសត្វពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។

ចប់សូត្រ ទី ៦ ។

លោកកាមគុណវគ្គោ ទុតិយោ

[១៨១] ឯកំ សមយំ អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរោ ភិក្ខុ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ អាយស្មន្តំ សារីបុត្តំ ឯតទវោច សទ្ធិវិហារិកោ អាវុសោ សារីបុត្ត ភិក្ខុ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោតិ ។ ឯវំ ហេតំ អាវុសោ ហោតិ ឥន្ទ្រិយេសុ អគុត្តទ្វារស្ស ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តស្ស ។ សោ វតាវុសោ ភិក្ខុ ឥន្ទ្រិយេសុ អគុត្តទ្វារោ ភោជនេ អមត្តញ្ញូ ជាគរិយំ អននុយុត្តោ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ សន្តានេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វតាវុសោ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ ជាគរិយំ អនុយុត្តោ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ សន្តានេស្សតីតិ ឋានមេតំ វិជ្ជតិ ។

## លោកកាមគុណវគ្គ ទី ២

[១៨១] សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្ត ជេតពនរបស់អនាថបណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុមួយរូប ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ គួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏សាកសួរសេចក្ដីនុ៎ះ ចំពោះព្រះសារីបុត្តមានអាយុថា ម្នាលអាវុសោសារីបុត្ត (ហេតុដូចម្ដេច) ភិក្ខុជាសទ្ធិវិហារិកពោលលាសិក្ខាហើយវិលមកកាន់ភេទដ៏ថោកទាប ។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ ពាក្យដែលអ្នកពោលនុ៎ះ រមែងមានដល់ភិក្ខុដែលមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបនូវសេចក្ដីភ្ញាក់រឭកយ៉ាងនេះឯង ។ ម្នាលអាវុសោ ភិក្ខុនោះឯង ជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបនូវសេចក្ដីភ្ញាក់រឭកនឹងបន្តនូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។ ម្នាលអាវុសោ ភិក្ខុនោះឯង ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ដឹងប្រមាណក្នុងភោជន ប្រកបនូវសេចក្ដីភ្ញាក់រឭក នឹងបន្តនូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[១៨២] កថញ្ចាវុសោ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ឯវំ ខោ អាវុសោ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

[១៨២] ម្នាលអាវុសោ ចុះភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ឃើញនូវរូបារម្មណ៍ដោយចក្ខុហើយ មិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមនូវបុគ្គល ដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុតែមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក ។ បានធុំក្លិនដោយច្រមុះ ។ បានទទួលរសដោយអណ្តាត ។ បានពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ដោយកាយ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត មិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមនូវបុគ្គល ដែលមិនសង្រួមនូវឥន្ទ្រិយនោះ ព្រោះហេតុតែមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលអាវុសោ ភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ យ៉ាងនេះឯង ។

២៣៩

## លោកកាមគុណវគ្គោ ទុតិយោ

[១៨៣] កថញ្ចាវុសោ ភោជនេ មត្តញ្ញូ ហោតិ ។ ឥធាវុសោ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អា-ហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូ-សនាយ យាវ ទេវ ឥមស្ស កាយស្ស ឋិតិយា យាប-នាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បា-ទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ ឯវំ ខោ អាវុសោ ភោជនេ មត្តញ្ញូ ហោតិ ។

[១៨៤] កថញ្ចាវុសោ ជាគរិយំ អនុយុត្តោ ហោតិ ។ ឥធាវុសោ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេន បាទំ អច្ចាធាយ សតោ

លោកកាមគុណវគ្គ ទី ២

[១៨៣] ម្នាលអាវុសោ ចុះភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ បានពិចារណាដោយឧបាយហើយ ទើបបរិភោគនូវអាហារ មិនបរិភោគដើម្បីលេង មិនបរិភោគដើម្បីស្រវឹង មិនបរិភោគដើម្បីប្រដាប់កាយ មិនបរិភោគដើម្បីស្អិតស្អាងកាយ បរិភោគដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ បរិភោគដោយគិតថា អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង នឹងញុំាងវេទនាថ្មីមិនឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅ (នៃឥរិយាបថ) ក្តី សេចក្តីមិនមានទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ ម្នាលអាវុសោ ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន យ៉ាងនេះឯង ។

[១៨៤] ម្នាលអាវុសោ ចុះភិក្ខុជាអ្នកប្រកបនូវសេចក្តីភ្ញាក់រឭក តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ធ្វើចិត្តឲ្យបរិសុទ្ធចាកអាវរណីយធម៌ ដោយការដើរ ដោយការអង្គុយ អស់មួយថ្ងៃ ធ្វើចិត្តឲ្យបរិសុទ្ធចាកអាវរណីយធម៌ ដោយការដើរ ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចនូវដំណេកដូចសីហៈ ដោយបង្អៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្កល់ជើងដោយជើង ជាអ្នកមានសតិ-

សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ។ ឯវំ ខោ អាវុសោ ជាគរិយំ អនុយុត្តោ ហោតិ ។ តស្មាតិហាវុសោ ឯវំ សិក្ខិតព្វំ ឥន្ទ្រិយេសុ គុត្តទ្វារា ភវិស្សាម ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តាតិ ។ ឯវំ ហិ ខោ អាវុសោ សិក្ខិ-តព្វន្តិ ។ សត្តមំ ។

[១៨៥] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវ-តោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិ-វិតក្កោ ឧទបាទិ បរិបក្កា ខោ រាហុលស្ស វិមុត្តិបរិបា-ចនិយា ធម្មា យន្នូនាហំ រាហុលំ ឧត្តរិអាសវានំ ខយេ វិនេយ្យន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិ-យំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ

សម្បជញ្ញៈ កំណត់ទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា ហើយក្រោកឡើង ធ្វើចិត្តឲ្យបរិសុទ្ធចាកអាវរណីយធម៌ ដោយការដើរ ដោយការអង្គុយ អស់បច្ឆិមយាមនៃរាត្រី ។ ម្នាលអាវុសោ ភិក្ខុជាអ្នកប្រកបនូវសេចក្តីភ្ញាក់រឭកយ៉ាងនេះឯង ។ ម្នាលអាវុសោ ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ជាអ្នកដឹងប្រមាណក្នុងភោជន ជាអ្នកប្រកបនូវសេចក្តីភ្ញាក់រឭក ។ ម្នាលអាវុសោ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រ ទី ៧ ។

[១៨៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគកំពុងសម្ងំក្នុងទីស្ងាត់ ទ្រង់មានសេចក្តីត្រិះរិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ធម៌ទាំងឡាយ ដែលសម្រាប់ធ្វើវិមុត្តិឲ្យចាស់ក្លារបស់រាហុល ចាស់ក្លាហើយតើ បើដូច្នោះ គួរតែតថាគតទូន្មានរាហុលក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវៈខាងលើ ។ គ្រានោះព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ លុះត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ក្នុងកាលជាបច្ឆាភត្ត ទ្រង់ត្រឡប់មកអំពីបិណ្ឌបាត

អាយស្មន្តំ រាហុលំ អាមន្តេសិ គណ្ហាហិ រាហុល និ-
សីទនំ យេន អន្ធវនំ តេនុបសង្កមិស្សាម ទិវាវិហារា-
យាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា រាហុលោ ភគវតោ
បដិស្សុត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ អនុ-
ពន្ធិ ។ តេន ខោ បន សមយេន អនេកានិ ទេវ-
តាសហស្សានិ ភគវន្តំ អនុពទ្ធានិ ភវន្តិ អជ្ជ ភគវា
អាយស្មន្តំ រាហុលំ ឧត្តរិអាសវានំ ខយេ វិនេស្សតីតិ ។

[១៨៦] អថខោ ភគវា អន្ធវនំ អជ្ឈោគាហេត្វា
អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ អាសនេ និសីទិ ។
អាយស្មាបិ ខោ រាហុលោ ភគវន្តំ អភិវាទេត្វា ឯក-
មន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ
រាហុលំ ភគវា ឯតទវោច តំ កឹ មញ្ញសិ រាហុល
ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ
បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ
បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-
បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។

ក៏ទ្រង់ហៅព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកចូរកាន់យកនិសីទនៈមក យើងនឹងចូលទៅឯអន្ធវ័ន ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។ ព្រះរាហុលមានអាយុ ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ រួចក៏កាន់យកនិសីទនៈ ដើរទៅតាមក្រោយព្រះមានព្រះភាគទៅ ។ ចួនសម័យនោះ មានទេវតាច្រើនពាន់ ដើរទៅតាមព្រះមានព្រះភាគដោយគិតថា ក្នុងថ្ងៃនេះ ព្រះមានព្រះភាគនឹងទូន្មាននូវព្រះរាហុលមានអាយុ ក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវៈខាងលើ ។

[១៨៦] លំដាប់នោះ ព្រះមានព្រះភាគ ស្តេចចូលទៅកាន់អន្ធវ័ន ហើយទ្រង់គង់លើអាសនៈដែលក្រាលទុកទៀបគល់ឈើមួយ ។ ព្រះរាហុលមានអាយុក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនុ៎ះដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់នូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ។

នោ ហេតំ ភន្តេ ។ រូចា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ ចក្ខុសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគ-តំ តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុ-បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ រសា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ ជិវ្ហាវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ ជិវ្ហាសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អ-និច្ចោ ភន្តេ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តម្បិ

មិនគួរនឹងយល់ឃើញដូច្នោះទេ ព្រះអង្គ ។ រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ចក្ខុវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចក្ខុសម្ផស្សទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះធម្មជាតណា គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ បេ ។ អណ្ដាតទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ រសទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ជិវ្ហាវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ជិវ្ហាសម្ផស្សទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះធម្មជាតណា គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ធម្មជាតនោះ

និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ បេ ។ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ធម្មា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ មនោវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ មនោសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ

ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ បេ ។ ចិត្តទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ធម្មារម្មណ៍ទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ មនោវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ មនោសម្ផស្សទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះធម្មជាតណា គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ តើរបស់នោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ

ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ជិវ្ហាវិញ្ញា-ណេបិ និព្វិន្ទតិ ជិវ្ហាសម្ផស្សេបិ និព្វិន្ទតិ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តស្មឹបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ ។ បេ ។ តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ

ព្រះអង្គ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុ-វិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ធម្មជាតណាគឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏រមែងនឿយណាយនឹងធម្មជាតនោះផង ។ បេ ។ នឿយណាយនឹងអណ្តាតផង នឿយណាយនឹងរសផង នឿយណាយនឹងជិវ្ហាវិញ្ញាណផង នឿយណាយនឹងជិវ្ហាសម្ផស្សផង ធម្មជាតណា គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ រមែងកើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ក៏រមែងនឿយណាយនឹងធម្មជាតនោះផង ។ បេ ។ នឿយណាយនឹងចិត្តផង នឿយណាយនឹងធម្មារម្មណ៍ផង ។ បេ ។ នឿយណាយនឹងធម្មជាតនោះផង កាលបើនឿយណាយ ក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តក៏រួចស្រឡះចាកអាសវៈ ។ កាលបើចិត្តរួចស្រឡះហើយ

លោកកាមគុណវគ្គោ ទុតិយោ

វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មច-

រិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ឥទមវោច ភគវា អត្តមនោ អាយស្មា រាហុលោ ភគវ-

តោ ភាសិតំ អភិនន្ទិ ។ ឥមស្មិញ្ច បន វេយ្យាករ-

ណស្មឹ ភញ្ញមានេ អាយស្មតោ រាហុលស្ស អនុបាទា-

យ អាសវេហិ ចិត្តំ វិមុច្ចតិ អនេកានំ ច ទេវតាស-

ហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ

សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ អដ្ឋមំ ។

សេចក្តីដឹងថារួចស្រឡះហើយក៏កើតមាន ។ អរិយសាវ័កនោះ រមែង ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួច ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះ មានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអា- យុ ជាអ្នកមានសេចក្តីត្រេកអរ ក៏បានត្រេកអរចំពោះភាសិត របស់ព្រះ មានព្រះភាគ ។ កាលបើព្រះមានព្រះភាគ កំពុងសម្តែងវេយ្យាករណ៍ នេះ ចិត្តរបស់ព្រះរាហុលមានអាយុ ក៏រួចស្រឡះចាកអាសវក្កិលេសទាំង- ឡាយ ព្រោះមិនបានប្រកាន់មាំ ទាំងធម្មចក្ខុ ដែលប្រាសចាកធូលីគឺកិ- លេស ប្រាសចាកមន្ទិលគឺអកុសល ក៏កើតឡើងដល់ទេវតាជាច្រើនពាន់ ថា របស់ណាមួយ មានកិរិយាកើតឡើងជាធម្មតា របស់ទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតាដែរ ។ ចប់សូត្រ ទី ៨ ។

[១៨៧] សញ្ញោជនិយេ ច ភិក្ខវេ ធម្មេ ទេសិស្សា-
មិ សញ្ញោជនញ្ច ច តំ សុណាថ ។ កតមេ ច ភិក្ខវេ
សញ្ញោជនិយា ធម្មា កតមញ្ច សញ្ញោជនំ ។ សន្តិ
ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយ-
រូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ វុច្ចន្តិ ភិក្ខវេ
សញ្ញោជនិយា ធម្មា ។ យោ តត្ថ ឆន្ទរាគោ តំ តត្ថ
សញ្ញោជនំ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា
។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា
មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ
វុច្ចន្តិ ភិក្ខវេ សញ្ញោជនិយា ធម្មា ។ យោ តត្ថ ឆន្ទ-
រាគោ តំ តត្ថ សញ្ញោជនន្តិ ។ នវមំ ។

[១៨៧] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសំយោជនិយធម៌គឺធម៌ជាហេតុកើតឡើងនៃសំយោជនៈផង នូវសំយោជនៈផង ចូរអ្នកទាំងឡាយ ប្រុងស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះសំយោជនិយធម៌ តើដូចម្តេច សំយោជនៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ រូបទាំងនេះ ហៅថាសំយោជនិយធម៌ ។ សេចក្តីត្រេកត្រអាលណា ក្នុងរូបនោះ សេចក្តីត្រេកត្រអាលនោះ ហៅថាសំយោជនៈក្នុងចក្ខុសម្ផស្សនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ ធម្មារម្មណ៍ទាំងនេះ ហៅថាសំយោជនិយធម៌ ។ សេចក្តីត្រេកត្រអាលណា ក្នុងធម្មារម្មណ៍នោះ សេចក្តីត្រេកត្រអាលនោះ ហៅថាសំយោជនៈក្នុងមនោសម្ផស្សនោះ ។ ចប់សូត្រ ទី ៩ ។

លោកកាមគុណវគ្គោ ទុតិយោ

[១៨៨] ឧបាទានិយេ ច ភិក្ខវេ ធម្មេ ទេសិស្សាមិ ឧបាទានញ្ច តំ សុណាថ ។ កតមេ ច ភិក្ខវេ ឧបាទានិយា ធម្មា កតមញ្ច ឧបាទានំ ។ សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ វុច្ចន្តិ ភិក្ខវេ ឧបាទានិយា ធម្មា ។ យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានំ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ។ ឥមេ វុច្ចន្តិ ភិក្ខវេ ឧបាទានិយា ធម្មា ។ យោ តត្ថ ឆន្ទរាគោ តំ តត្ថ ឧបាទានន្តិ ។ ទសមំ ។

លោកកាមគុណវគ្គោ ទុតិយោ ។

## លោកកាមគុណវគ្គ ទី ២

[២៨៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវឧបាទានិយធម៌គឺធម៌ជាហេតុកើតនៃឧបាទានផង នូវឧបាទានផង ចូរអ្នកទាំងឡាយប្រុងស្តាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះឧបាទានិយធម៌ តើដូចម្តេច ឧបាទាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មានរូបដែលគប្បីដឹងដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ រូបទាំងនេះ ហៅថាឧបាទានិយធម៌ ។ សេចក្តីត្រេកត្រអាលណា ក្នុងរូបនោះ សេចក្តីត្រេកត្រអាលនោះ ហៅថាឧបាទានក្នុងចក្ខុសម្ផស្សនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលគប្បីដឹងដោយអណ្តាត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ ធម្មារម្មណ៍ទាំងនេះ ហៅថាឧបាទានិយធម៌ ។ សេចក្តីត្រេកត្រអាលណា ក្នុងធម្មារម្មណ៍នោះ សេចក្តីត្រេកត្រអាលនោះ ហៅថាឧបាទានក្នុងមនោសម្ផស្សនោះ ។ ចប់សូត្រ ទី ១០ ។

ចប់ លោកកាមគុណវគ្គ ទី ២ ។

## ២៤៨



# តស្សុទ្ទានំ

មារបាសេន ទ្វេ វុត្តា
លោកកាមគុណេន ច
សក្កោ បញ្ចសិខោ ចេវ
សារីបុត្តោ ច រាហុលោ
សញ្ញោជនំ ឧបាទានំ
វគ្គោ តេន បវុច្ចតីតិ ។

---

## ឧទ្ទាននៃលោកកាមគុណវគ្គនោះ គឺ

*និយាយអំពីអន្ទាក់មារ ២ លើក អំពីទីបំផុតនៃលោក ១ អំពីកាមគុណ ១ ព្រះឥន្ទ ១ បញ្ចសិខគន្ធព្វបុត្ត ១ ព្រះសារីបុត្ត ១ ព្រះរាហុល ១ សំយោជនៈ ១ ឧបាទាន ១ ព្រោះហេតុនោះ ទើបហៅថា លោកកាមគុណវគ្គ ។*

# គហបតិវគ្គោ

[១៨៩] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ឧគ្គោ គហបតិ វេសាលិកោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ឧគ្គោ គហបតិ វេសាលិកោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ សន្តិ ខោ គហបតិ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទានោ គហបតិ ភិក្ខុ

# គហបតិវគ្គ

[១៨៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ ឧគ្គគហបតីអ្នកក្រុងវេសាលី ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះឧគ្គគហបតីអ្នកក្រុងវេសាលី អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ ព្រះអង្គត្រាស់ថា ម្នាលគហបតី មានរូបដែលគប្បីដឹងច្បាស់ដោយភ្នែក ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ កាលភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏មាន សេចក្តីប្រកាន់មាំនូវរូបនោះក៏មាន ។ ម្នាលគហបតី ភិក្ខុដែលមានសេចក្តីប្រកាន់មាំ

នោ បរិនិព្វាយតិ ។ បេ ។ សន្តិ ខោ គហបតិ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ គហបតិ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទានា-នោ គហបតិ ភិក្ខុ នោ បរិនិព្វាយតិ អយំ ខោ គហ-បតិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។

មិនបរិនិព្វានទេ ។ បេ ។ ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្តាត ។ បេ ។ ម្នាលគហបតី មានធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលបើភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏មាន សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះក៏មាន ។ ម្នាលគហបតី ភិក្ខុមានសេចក្តីប្រកាន់មាំ មិនបរិនិព្វានទេ ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។

គហបតិវគ្គោ តតិយោ

[១៩០] សន្តិ ច ខោ គហបតិ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទា-នំ ។ អនុបាទានោ គហបតិ ភិក្ខុ បរិនិព្វាយតិ ។ បេ ។ សន្តិ ខោ គហបតិ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ គហបតិ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនា-បា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ

## គហបតិវគ្គ ទី ៣

[១៩០] ម្នាលគហបតី មានរូបដែលគប្បីដឹងច្បាស់ដោយភ្នែក ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ កាលបើភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ វិញ្ញាណដែលអាស្រ័យនូវរូបនោះ ក៏មិនមាន សេចក្តីប្រកាន់មាំនូវរូបនោះ ក៏មិនមានដែរ ។ ម្នាលគហបតី ភិក្ខុមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។ បេ ។ ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្តាត ។ បេ ។ ម្នាលគហបតី មានធម្មារម្មណ៍ ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលបើភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ

ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទានំ ។ អនុ-
បាទានោ គហបតិ ភិក្ខុ បរិនិព្វាយតិ អយំ ខោ គ-
ហបតិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចេ សត្តា
ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ បឋមំ ។

[១៩១] ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ
ហត្ថិគ្គាមេ ។ អថខោ ឧគ្គោ គហបតិ ហត្ថិគ្គាមកោ
យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ
ខោ ឧគ្គោ គហបតិ ហត្ថិគ្គាមកោ ភគវន្តំ ឯតទវោច
កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនមិធេ-
កច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ
បន ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា
ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ (យថា បុរិមសុត្តន្តំ ឯវំ
វិត្ថារេតព្វំ) ។ អយំ ខោ គហបតិ ហេតុ អយំ បច្ចយោ
យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។
ទុតិយំ ។

វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏មិនមាន សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះ ក៏មិនមានដែរ ។ ម្នាលគហបតី ភិក្ខុមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ១ ។

[១៩១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងហត្ថិគ្រាម ក្នុងដែនវជ្ជី ។ គ្រានោះ ឧគ្គគហបតី អ្នកហត្ថិគ្រាមបានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះឧគ្គគហបតី អ្នកហត្ថិគ្រាម អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ (សូត្រមុនយ៉ាងណា បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ យ៉ាងនោះចុះ) ។ ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ២ ។

គហបតិវគ្គោ តតិយោ

[១៩២] ឯកំ សមយំ ភគវា នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ អថខោ ឧបាលិ គហបតិ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ឧបាលិ គហបតិ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ (យថា បុរិមសុត្តន្តំ ឯវំ វិត្ថារេតព្វំ) ។ អយំ ខោ គហបតិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ តតិយំ ។

គហបតិវគ្គ ទី ៣

[១៩២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្ត បាវារិកម្ពវ័ន ជិតក្រុងនាឡន្ទា ។ គ្រានោះ ឧបាលិគហបតីបានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះឧបាលិគហបតី អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើនមួយយ៉ាងទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ (សូត្រមុនយ៉ាងណា បណ្ឌិតគប្បីសម្តែងឲ្យពិស្តារយ៉ាងនោះចុះ) ។ ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៣ ។

[១៩៣] ឯកំ សមយំ ភគវា អាយស្មា បិណ្ឌោលភារទ្វាជោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថ ខោ រាជា ឧទេនោ យេនាយស្មា បិណ្ឌោលភារទ្វាជោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា បិណ្ឌោលភារទ្វាជេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា ឧទេនោ អាយស្មន្តំ បិណ្ឌោលភារទ្វាជំ ឯតទវោច កោ នុ ខោ ភោ ភារទ្វាជ ហេតុ កោ បច្ចយោ យេនិមេ ទហរា ភិក្ខូ សុសូ កាឡកេសា ភទ្រេន យោព្វនេន សមន្នាគតា បឋមេន វយសា អនិកីឡិតាវិនោ កាមេសុ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តិ អទ្ធានញ្ច អាបាទេន្តីតិ ។ វុត្តំ ខោ ឯតំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯថ តុម្ហេ ភិក្ខវេ មាតុមត្តីសុ មាតុចិត្តំ ឧបដ្ឋបេថ ភគិនីមត្តីសុ ភគិនីចិត្តំ ឧបដ្ឋបេថ ធីតុមត្តីសុ ធីតុចិត្តំ ឧបដ្ឋបេថាតិ ។

[១៩៣] សម័យមួយ ព្រះមានព្រះភាគ និងព្រះបិណ្ឌោលភារទ្វាជ មានអាយុ គង់នៅក្នុងវត្តឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ព្រះបាទឧទេន ស្តេចចូលទៅរកព្រះបិណ្ឌោលភារទ្វាជៈមានអាយុ លុះស្តេចចូលទៅដល់ហើយ ទ្រង់ធ្វើសេចក្តីរីករាយជាមួយនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏ទ្រង់គង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទឧទេន ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ទើបទ្រង់មានព្រះបន្ទូលទៅនឹងព្រះបិណ្ឌោលភារទ្វាជៈមានអាយុដូច្នេះថា បពិត្រព្រះភារទ្វាជៈដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញុំាងបវេណិធម៌ឲ្យប្រព្រឹត្តទៅអស់កាលយូរអង្វែងបាន ។ ព្រះបិណ្ឌោលភារទ្វាជៈថ្វាយព្រះពរថា បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរតាំងចិត្តឲ្យដូចជាមាតា ក្នុងពួកស្រីល្មមជាមាតា ចូរតាំងចិត្តឲ្យដូចជាបងប្អូនស្រី ក្នុងពួកស្រីល្មមជាបងប្អូនស្រី ចូរតាំងចិត្តឲ្យដូចជាកូនស្រី ក្នុងពួកស្រីល្មមជាកូនស្រី ។

អយំ ខោ មហារាជ ហេតុ អយំ បច្ចយោ យេនិមេ ឥធ ភិក្ខូ សុសូ កាឡកេសា ភទ្រេន យោព្វ-នេន សមន្នាគតា បឋមេន វយសា អនិកីឡិតា-វិនោ កាមេសុ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មច-រិយំ ចរន្តិ អទ្ធានញ្ច អាបាទេន្តីតិ ។

[១៩៤] លោលំ ខោ ភោ ភារទ្វាជ ចិត្តំ អប្បេកទា មាតុមត្តីសុបិ លោភធម្មា ឧប្បជ្ជន្តិ ភគិនីមត្តីសុបិ លោ-ភធម្មា នុ ខោ ភោ ភារទ្វាជ អញ្ញោ ច ហេតុ អញ្ញោ ច បច្ចយោ យេនិមេ ឥធ ភិក្ខូ សុសូ កាឡកេសា ។ បេ ។ អទ្ធានញ្ច អាបាទេន្តីតិ ។ វុត្តំ ខោ ឯតំ ម-ហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯថ តុម្ហេ ភិក្ខវេ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នា-នប្បការស្ស អសុចិនោ បច្ចវេក្ខថ អត្ថិ ឥមស្មឹ កា-យេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ

បពិត្រមហារាជ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធអស់មួយជីវិត ទាំងញ៉ាំងបវេណិធម៌ឲ្យប្រព្រឹត្តទៅ អស់កាលជាយូរអង្វែងបាន ។

[១៩២] បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ចិត្តជាធម្មជាតឡេះឡោះចួនកាល លោភធម៌កើតឡើងក្នុងពួកស្រីល្មមជាមាតាក៏មាន លោភធម៌កើតឡើងក្នុងពួកស្រីល្មមជាបងប្អូនស្រីក៏មាន លោភធម៌កើតឡើងក្នុងពួកស្រីល្មមជាកូនស្រីក៏មាន ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ហេតុដទៃបច្ច័យដទៃទៀត មានដែរឬ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះមានសក់ខ្មៅ ។ បេ ។ ទាំងញ៉ាំងបវេណិធម៌ឲ្យប្រព្រឹត្តទៅអស់កាលជាយូរអង្វែងបាន ។ បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកអាយ ចូរពិចារណានូវកាយនេះឯង តាំងអំពីបាតជើងឡើងទៅលើ អំពីចុងសក់ចុះមកក្រោម ដែលមានស្បែកជាទីបំផុត ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេង ៗ ថា ក្នុងកាយនេះមាន សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ

អដ្ឋិ អដ្ឋិមិញ្ជំ[១] វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។ អយម្បិ ខោ មហារាជ ហេតុ អយំ បច្ចយោ យេនិមេ ទហរា ភិក្ខូ សុសូ កាឡកេសា ។ បេ ។ អទ្ធានញ្ច អាបាទេន្តីតិ ។

[១៩៤] យេ តេ ភោ[២] ភារទ្វាជ ភិក្ខូ ភាវិតកាយា ភាវិតសីលា ភាវិតចិត្តា ភាវិតបញ្ញា តេសន្តំ ន ទុក្ករំ ហោតិ ។ យេ ច ខោ តេ ភោ ភារទ្វាជ ភិក្ខូ អភាវិតកាយា អភាវិតសីលា អភាវិតចិត្តា អភាវិតបញ្ញា តេសន្តំ ទុក្ករំ ហោតិ ។ អប្បេកទា ភោ ភារទ្វាជ អសុភតោ មនសិ ករិស្សាមាតិ សុភតោ ច អាគច្ឆតិ អត្ថិ នុ ខោ ភោ ភារទ្វាជ អញ្ញោ ច ហេតុ

១ ឱ. អដ្ឋិមិញ្ជា ។ ២ ម. យេ ហិ ភោ ។

ឆ្អឹង ខួរក្នុងឆ្អឹង តម្រងទឹកមូត្រ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះ-វៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ បពិត្រមហារាជ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះ មានសក់ខ្មៅ ។ បេ ។ ទាំងញុំាងបវេណិធម៌ឲ្យប្រព្រឹត្តទៅ អស់កាលជាយូរអង្វែងបាន ។

[១៩៥] បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ភិក្ខុទាំងឡាយណា ដែលបានចម្រើនកាយ ចម្រើនសីល ចម្រើនចិត្ត ចម្រើនបញ្ញាហើយ កិច្ចគឺការពិចារណាឲ្យឃើញថាជាអសុភនោះ ភិក្ខុទាំងនោះ មិនមែនធ្វើបានដោយលំបាកឡើយ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន តែភិក្ខុទាំងឡាយណា ដែលមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនចិត្ត មិនបានចម្រើនបញ្ញាហើយ កិច្ចនោះ ភិក្ខុទាំងនោះ ធ្វើបានដោយកម្រណាស់ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ចួនកាល យើងខ្ញុំគិតថា នឹងធ្វើទុកក្នុងចិត្តថា អារម្មណ៍មិនល្អ ក៏ប្រែក្លាយទៅជាអា-រម្មណ៍ល្អវិញក៏មាន បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ក្រែងមានហេតុដទៃ

២៨៧

## គហបតិវគ្គោ តតិយោ

អញ្ញោ ច បច្ចយោ យេនិមេ ទហរា ភិក្ខូ សុសូ កា-
ឡកេសា ។ បេ ។ អទ្ធានញ្ច អាបាទេន្តីតិ ។ វុត្តំ ខោ
ឯតំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា
សម្មាសម្ពុទ្ធេន ឯថ តុម្ហេ ភិក្ខវេ ឥន្ទ្រិយេសុ គុត្តទ្វារា
វិហរថ ចក្ខុនា រូបំ ទិស្វា មា និមិត្តគ្គាហិនោ អហុវត្ថ
មា អនុព្យញ្ជនគ្គាហិនោ យត្វាធិករណមេនំ ចក្ខុ-
ន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា
អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិ-
បជ្ជថ រក្ខថ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជថ ។

គហបតិវគ្គ ទី ៣

បច្ច័យដទៃទៀតដែរឬ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះ មានសក់ខ្មៅ ។ បេ ។ ទាំងញុំាងបវេណិធម៌ឲ្យប្រព្រឹត្តទៅអស់កាលជាយូរអង្វែងបាន ។ បពិត្រមហារាជ ពាក្យនេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមកអាយ ចូររក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ អ្នកទាំងឡាយ បានឃើញរូបដោយចក្ខុហើយ កុំប្រកាន់និមិត្ត កុំប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវឥន្ទ្រិយនុ៎ះ ព្រោះហេតុតែចក្ខុន្ទ្រិយណា អ្នកទាំងឡាយចូរប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ ចូររក្សានូវចក្ខុន្ទ្រិយ ចូរដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ។

សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហា-
យ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មន-
សា ធម្មំ វិញ្ញាយ មា និមិត្តគ្គាហិនោ អហុវត្ថ មា អនុ-
ព្យញ្ជនគ្គាហិនោ យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ
វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា
អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជថ រក្ខថ មនិន្ទ្រិយំ
មនិន្ទ្រិយេ សំវរំ អាបជ្ជថាតិ ។ អយម្បិ ខោ មហារាជ
ហេតុ អយំ បច្ចយោ យេនិមេ ទហរា ភិក្ខូ សុសូ
កាឡកេសា ភទ្រេន យោព្វនេន សមន្នាគតា បឋមេន
វយសា អនិកីឡិតាវិនោ កាមេសុ យាវជីវំ បរិបុណ្ណំ
បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តិ អទ្ធានញ្ច អាបាទេន្តីតិ ។

[១៩៦] អច្ឆរិយំ ភោ ភារទ្វាជ អព្ភុតំ ភោ ភារទ្វា-
ជ ។ យាវ សុភាសិតញ្ចិទំ ភោ ភារទ្វាជ តេន ភគវតា
ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឯសេវ ខោ
ភោ ភារទ្វាជ ហេតុ ឯស បច្ចយោ យេនិមេ ទហរា
ភិក្ខូ សុសូ កាឡកេសា ភទ្រេន យោព្វនេន សមន្នា-

ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ អ្នកទាំងឡាយដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ កុំប្រកាន់និមិត្ត កុំប្រកាន់អនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែមិនសង្រួមមនិន្ទ្រិយណា អ្នកទាំងឡាយចូរប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ ចូររក្សាមនិន្ទ្រិយ ចូរដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ បពិត្រមហារាជនេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះមានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើនគឺបឋមវ័យ មិនឈ្ងក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញុំាងបវេណិធម៌ឲ្យប្រព្រឹត្តទៅ អស់កាលជាយូរអង្វែងបាន ។

[១៩៦] បពិត្រព្រះភារទ្វាជៈដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន មិនដែលមានទេ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ពាក្យនេះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានត្រាស់ទុកដោយប្រពៃហើយ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន នេះហើយជាហេតុ នេះហើយជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុនេះ នៅក្មេងកម្លោះ មានសក់ខ្មៅ ប្រកបដោយវ័យដ៏ចម្រើន

២៤៩

គហបតិវគ្គោ តតិយោ

គតា បឋមេន វយសា អនិកីឡិតាវិនោ កាមេសុ យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តិ អទ្ធានញ្ច អាចាេន្តីតិ ។ អហម្បិ ខោ ភោ ភារទ្វាជ យស្មឹ សមយេ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ អន្តេបុរំ បវិសាមិ អតិវិយ មំ តស្មឹ សម-យេ លោភធម្មា បរិសហន្តិ ។ យស្មិញ្ច ខ្វាហំ ភោ ភារទ្វាជ សមយេ រក្ខិតេនេវ កាយេន រក្ខិតាយ វាចាយ រក្ខិតេន ចិត្តេន ឧបដ្ឋិតាយ សតិយា សំវុ-តេហិ ឥន្ទ្រិយេហិ អន្តេបុរំ បវិសាមិ ន មំ តត្ថ តស្មឹ សមយេ លោភធម្មា បរិសហន្តិ ។ អភិក្កន្តំ ភោ ភារទ្វាជ អភិក្កន្តំ ភោ ភារទ្វាជ ។ សេយ្យថាបិ ភោ ភារទ្វាជ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ

គឺបឋមវ័យ មិនឈ្លក់នៅក្នុងកាមទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌បរិបូណ៌ បរិសុទ្ធ អស់មួយជីវិត ទាំងញ៉ាំងបវេណិធម៌ឲ្យប្រព្រឹត្តទៅអស់កាលជាយូរអង្វែងបាន ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ចំណែកខ្ញុំករុណាវិញ សម័យណា មិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនបានប្រុងស្មារតី មិនបានសង្រួមឥន្ទ្រិយ ចូលទៅនៅក្នុងព្រះរាជវាំង សម័យនោះ លោភធម៌ទាំងឡាយ តែងគ្របសង្កត់ខ្ញុំករុណាពន់ពេក ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន លុះតែសម័យណា ខ្ញុំករុណាបានរក្សាកាយ រក្សាវាចា រក្សាចិត្ត ប្រុងស្មារតី សង្រួមឥន្ទ្រិយចូលទៅក្នុងព្រះរាជវាំង លោភធម៌ទាំងឡាយ ក៏មិនបានគ្របសង្កត់ចិត្តខ្ញុំករុណាក្នុងសម័យនោះឡើយ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ច្បាស់ណាស់ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលគេបិទបាំងទុក ឬដូចគេបង្ហាញផ្លូវដល់បុគ្គលអ្នកវង្វេងទិស ពុំនោះសោតដូចបុគ្គលទ្រោលបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា បុគ្គលទាំងឡាយមានចក្ខុ នឹងមើលឃើញរូបទាំងឡាយបាន មានឧបមាយ៉ាងណា

ឯវមេវ ខោ ភោតា ភារទ្វាជេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភោ ភារទ្វាជ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ ភារទ្វាជោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ ចតុត្ថំ ។

[១៩៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ សោណោ គហបតិបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណោ គហបតិបុត្តោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ (យថា បុរិមសុត្តន្តំ ឯវំ វិត្ថារេតព្វំ) ។ បញ្ចមំ ។

ព្រះភារទ្វាជៈដ៏ចម្រើន បានប្រកាសធម៌ដោយអនេកបរិយាយ មានឧបមេយ្យយ៉ាងនោះដែរ ។ បពិត្រព្រះភារទ្វាជៈដ៏ចម្រើន ខ្ញុំករុណាសូមដល់ព្រះមានព្រះភាគនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរឭក សូមព្រះភារទ្វាជៈដ៏ចម្រើន ចាំទុកនូវខ្ញុំករុណា ថាជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។ ចប់សូត្រ ទី ៨ ។

[១៩៧] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ សោណគហបតិបុត្ត បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោណគហបតិបុត្តអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ (សូត្រមុនយ៉ាងណា បណ្ឌិតគប្បីសម្ដែងឲ្យពិស្ដារយ៉ាងនោះផងចុះ) ។ ចប់សូត្រ ទី ៩ ។

គហបតិវគ្គោ តតិយោ

[១៩៨] ឯកំ សមយំ ភគវា អាយស្មា អានន្ទោ កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ ឃោសិ-តោ គហបតិ យេនាយស្មា អានន្ទោ តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ឃោសិតោ គហបតិ អាយស្មន្តំ អានន្ទំ ឯតទវោច ធាតុនានត្តំ ធាតុនានត្តន្តិ ភន្តេ អានន្ទ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធាតុនានត្តំ វុត្តំ ភគវតាតិ ។ សំវិជ្ជតិ ខោ គហបតិ ចក្ខុធាតុ រូបា ច មនាបា ចក្ខុវិញ្ញាណញ្ច សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។ សំវិជ្ជតិ ខោ គហបតិ ចក្ខុធាតុ រូបា ច អមនាបា ចក្ខុវិញ្ញាណញ្ច ទុក្ខវេ-ទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សំវិជ្ជតិ ខោ គហបតិ ចក្ខុធាតុ រូបា ច ឧបេក្ខដ្ឋានីយា[១] ចក្ខុវិញ្ញាណញ្ច អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ បេ ។ សំវិជ្ជតិ ខោ គហបតិ ជិវ្ហាធាតុ រសា ច មនាបា ជិវ្ហាវិញ្ញាណញ្ច សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។

១ ឱ. ឧបេក្ខាឋានិយា ។ ម. ឧបេក្ខាវេទនិយា ។

## គហបតិវគ្គ ទី ៣

[១៩៨] សម័យមួយ ព្រះមានព្រះភាគ និងព្រះអានន្ទមានអាយុ គង់នៅក្នុងវត្តឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង ឃោសិតគហបតីចូលទៅរកព្រះអានន្ទមានអាយុ ។ បេ ។ លុះឃោសិតគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានពោលនឹងព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ថា ធាតុផ្សេងៗ គ្នា ធាតុផ្សេងៗ គ្នា បពិត្រលោកម្ចាស់ដ៏ចម្រើន តើធាតុផ្សេងៗ គ្នា ព្រះមានព្រះភាគត្រាស់ ដោយហេតុយ៉ាងណា ។ ម្នាលគហបតី ចក្ខុធាតុ ១ រូបដែលជាទីគាប់ចិត្ត ១ ចក្ខុវិញ្ញាណ ១ មានហើយ ទើបសុខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃសុខវេទនា ។ ម្នាលគហបតី ចក្ខុធាតុ ១ រូបមិនជាទីគាប់ចិត្ត ១ ចក្ខុវិញ្ញាណ ១ មានហើយ ទើបទុក្ខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈ ដែលជាទីតាំងនៃទុក្ខវេទនា ។ ម្នាលគហបតី ចក្ខុធាតុ ១ រូបជាទីតាំងនៃឧបេក្ខា ១ ចក្ខុវិញ្ញាណ ១ មានហើយ ទើបអទុក្ខមសុខវេទនា (វេទនាមិនជាទុក្ខមិនជាសុខ) កើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃអទុក្ខមសុខវេទនា ។ បេ ។ ម្នាលគហបតី ជិវ្ហាធាតុ ១ រសជាទីគាប់ចិត្ត ១ ជិវ្ហាវិញ្ញាណ ១ មានហើយ ទើបសុខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃសុខវេទនា ។

សំវិជ្ជតិ ខោ គហបតិ ជិវ្ហាធាតុ រសា ច អមនាបា ជិវ្ហាវិញ្ញាណញ្ច ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សំវិជ្ជតិ ខោ គហបតិ ជិវ្ហាធាតុ រសា ច ឧបេក្ខដ្ឋានីយា ជិវ្ហាវិញ្ញាណញ្ច អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ បេ ។ សំវិជ្ជតិ ខោ គហបតិ មនោធាតុ ធម្មា ច មនាបា មនោវិញ្ញាណញ្ច សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។ សំវជ្ជតិ ខោ គហបតិ មនោធាតុ ធម្មា ច អមនាបា មនោវិញ្ញាណញ្ច ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សំវិជ្ជតិ ខោ គហបតិ មនោធាតុ ធម្មា ច ឧបេក្ខដ្ឋានីយា មនោវិញ្ញាណញ្ច អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ ឯត្តាវតា គហបតិ ធាតុនានត្តំ វុត្តំ ភគវតាតិ ។ ឆដ្ឋំ ។

ម្នាលគហបតី ជិវ្ហាធាតុ ១ រសមិនជាទីគាប់ចិត្ត ១ ជិវ្ហាវិញ្ញាណ ១ មានហើយ ទើបទុក្ខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃទុក្ខវេទនា ។ ម្នាលគហបតី ជិវ្ហាធាតុ ១ រសជាទីតាំងនៃឧបេក្ខា ១ ជិវ្ហាវិញ្ញាណ ១ មានហើយ ទើបអទុក្ខមសុខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃអទុក្ខមសុខវេទនា ។ បេ ។ ម្នាលគហបតី មនោធាតុ ១ ធម្មារម្មណ៍ជាទីគាប់ចិត្ត ១ មនោវិញ្ញាណ ១ មានហើយ ទើបសុខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃសុខវេទនា ។ ម្នាលគហបតី មនោធាតុ ១ ធម្មារម្មណ៍មិនជាទីគាប់ចិត្ត ១ មនោវិញ្ញាណ ១ មានហើយ ទើបទុក្ខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃទុក្ខវេទនា ។ ម្នាលគហបតី មនោធាតុ ១ ធម្មារម្មណ៍ជាទីតាំងនៃឧបេក្ខា ១ មនោវិញ្ញាណ ១ មានហើយ ទើបអទុក្ខមសុខវេទនាកើតឡើងបាន ព្រោះអាស្រ័យផស្សៈដែលជាទីតាំងនៃអទុក្ខមសុខវេទនា ។ ម្នាលគហបតី ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងធាតុផ្សេង ៗ គ្នា ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ចប់សូត្រ ទី ៦ ។

២៦៣

## គហបតិវគ្គោ តតិយោ

[១៩៩] ឯកំ សមយំ អាយស្មា មហាកច្ចានោ អវន្តីសុ វិហរតិ កុលឃរេ[១] សំបវត្តេ បព្វតេ ។ អថខោ ហាលិទ្ទកានិ គហបតិ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ហា-លិទ្ទកានិ គហបតិ អាយស្មន្តំ មហាកច្ចានំ ឯតទ-វោច វុត្តមិទំ ភន្តេ ភគវតា ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានា-នត្តន្តិ ។ កថំ នុ ខោ ភន្តេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានា-នត្តន្តិ ។

[២០០] ឥធ គហបតិ ភិក្ខុ ចក្ខុនា រូបំ ទិស្វា មនា-បំ ឥត្ថេតន្តិ បជានាតិ ចក្ខុវិញ្ញាណំ សុខវេទនីយំ ច សុ-ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខវេទនា ។ ចក្ខុនា ច ខោ បនេវ រូបំ ទិស្វា អមនាបំ ឥត្ថេតន្តិ បជានាតិ

១ ឱ. កុររឃរេ ។

គហបតិវគ្គ ទី ៣

[១៩៩] សម័យមួយ ព្រះមហាកច្ចានៈមានអាយុ គង់នៅលើភ្នំសំបវត្តៈ ជិតស្រុកកុលឃរៈ ក្នុងអវន្តិជនបទ ។ គ្រានោះ ហាលិទ្ទិកានិគហបតី បានចូលទៅរកព្រះមហាកច្ចានៈមានអាយុ ។ បេ ។ លុះហាលិទ្ទិកានិគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានពោលទៅនឹងព្រះមហាកច្ចានៈមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន ពាក្យនេះព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ការផ្សេង ៗ គ្នានៃផស្សៈ កើតឡើងព្រោះអាស្រ័យធាតុផ្សេង ៗ គ្នា ការផ្សេង ៗ គ្នានៃវេទនា កើតឡើងព្រោះអាស្រ័យការផ្សេង ៗ គ្នានៃផស្សៈ ។ បពិត្រលោកដ៏ចម្រើន ការផ្សេង ៗ គ្នានៃផស្សៈកើតឡើង ព្រោះអាស្រ័យធាតុផ្សេង ៗ និងការផ្សេង ៗ គ្នានៃវេទនាកើតឡើង ព្រោះអាស្រ័យការផ្សេង ៗ គ្នានៃផស្សៈតើដូចម្ដេច ។

[២០០] ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ក៏ដឹងច្បាស់ថា រូបនេះជាទីគាប់ចិត្តយ៉ាងនេះ សុខវេទនាក៏កើតឡើង ព្រោះអាស្រ័យនូវចក្ខុវិញ្ញាណ ជាទីតាំងនៃសុខវេទនាផង នូវផស្សៈដែលជាទីតាំងនៃសុខវេទនាផង ។ មួយទៀត ភិក្ខុឃើញរូបដោយចក្ខុយ៉ាងនេះហើយ ក៏ដឹងច្បាស់ថា រូបនេះមិនជាទីគាប់ចិត្តយ៉ាងនេះ

ចក្ខុវិញ្ញាណំ ទុក្ខវេទនីយំ ច ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ ចក្ខុនា ខោ បនេវំ រូបំ ទិស្វា ឧបេក្ខដ្ឋានីយំ ឥត្ថេតន្តិ បជានាតិ ចក្ខុវិញ្ញាណំ អទុក្ខមសុខវេទនីយំ ច អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ បុន ចបរំ គហបតិ ភិក្ខុ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ មនាបំ ឥត្ថេតន្តិ បជានាតិ មនោវិញ្ញាណំ សុខវេទនីយំ ច សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។ មនសា ខោ បនេវំ ធម្មំ វិញ្ញាយ អមនាបំ ឥត្ថេតន្តិ បជានាតិ មនោវិញ្ញាណំ ទុក្ខវេទនីយំ ច ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ មនសា ខោ បនេវំ ធម្មំ វិញ្ញាយ ឧបេក្ខដ្ឋានីយំ ឥត្ថេតន្តិ បជានាតិ មនោវិញ្ញាណំ អទុក្ខមសុខវេទនីយំ ច អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។

ទុក្ខវេទនាកើតឡើង ព្រោះអាស្រ័យនូវចក្ខុវិញ្ញាណ ជាទីតាំងនៃទុក្ខវេទនាផង នូវផស្សៈជាទីតាំងនៃទុក្ខវេទនាផង ។ មួយទៀត ភិក្ខុឃើញរូបដោយចក្ខុយ៉ាងនេះហើយ ក៏ដឹងច្បាស់ថា រូបនេះគួរជាទីតាំងនៃឧបេក្ខាយ៉ាងនេះ អទុក្ខមសុខវេទនាក៏កើតឡើង ព្រោះអាស្រ័យនូវចក្ខុវិញ្ញាណជាទីតាំងនៃអទុក្ខមសុខវេទនាផង នូវផស្សៈដែលជាទីតាំងនៃអទុក្ខមសុខវេទនាផង ។ ម្នាលគហបតី មួយទៀត ភិក្ខុឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ហើយដឹងច្បាស់ថា ធម្មារម្មណ៍នេះជាទីគាប់ចិត្តយ៉ាងនេះ សុខវេទនាក៏កើតឡើង ព្រោះអាស្រ័យនូវមនោវិញ្ញាណជាទីតាំងនៃសុខវេទនាផង នូវផស្សៈជាទីតាំងនៃសុខវេទនាផង ។ ភិក្ខុដឹងនូវធម្មារម្មណ៍ដោយចិត្តយ៉ាងនេះហើយ ក៏ដឹងច្បាស់ថា ធម្មារម្មណ៍នេះមិនជាទីគាប់ចិត្តយ៉ាងនេះ ទុក្ខវេទនាក៏កើតឡើង ព្រោះអាស្រ័យនូវមនោវិញ្ញាណ ជាទីតាំងនៃទុក្ខវេទនាផង នូវផស្សៈជាទីតាំងនៃទុក្ខវេទនាផង ។ ភិក្ខុដឹងនូវធម្មារម្មណ៍ដោយចិត្តយ៉ាងនេះហើយ ក៏ដឹងច្បាស់ថា ធម្មារម្មណ៍នេះគួរជាទីតាំងនៃឧបេក្ខាយ៉ាងនេះ អទុក្ខមសុខវេទនាក៏កើតឡើង ព្រោះអាស្រ័យនូវមនោវិញ្ញាណជាទីតាំងនៃអទុក្ខមសុខវេទនាផង នូវផស្សៈជាទីតាំងនៃអទុក្ខមសុខវេទនាផង ។

ឯវំ ខោ គហបតិ ជាតុជានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សជា-នត្តំ ផស្សជានត្តំ បដិច្ច ឧប្បជ្ជតិ វេទនាជានត្តន្តិ ។ សត្តមំ ។

[២០១] ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ អថខោ នកុលបិតា គហបតិ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ នកុលបិតា គហបតិ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ច-យោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វា-យន្តិ ។ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន-មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ សន្តិ ខោ គហបតិ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិ-យរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ

ម្នាលគហបតី ការផ្សេងៗគ្នា នៃផស្សៈកើតឡើង ព្រោះអាស្រ័យធាតុផ្សេងៗ គ្នា និងការផ្សេងៗ គ្នានៃវេទនាកើតឡើង ព្រោះអាស្រ័យការផ្សេងៗ គ្នានៃផស្សៈ យ៉ាងនេះឯង ។ ចប់សូត្រ ទី ៧ ។

[២០១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័នជាទីឲ្យអភ័យដល់ពួកម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គ-ជនបទ ។ គ្រានោះ គហបតីឈ្មោះនកុលបិតា បានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះនកុលបិតាគហបតីអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ បរិនិព្វានក្នុងបច្ចុប្បន្នន ។ ម្នាលគហបតី មានរូបដែលគប្បីដឹងច្បាស់ដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុ

អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទានោ គហបតិ ភិក្ខុ នោ បរិនិព្វាយតិ ។ បេ ។ សន្តិ ខោ គហបតិ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ គហបតិ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តំ និស្សិតំ វិញ្ញាណំ ហោតិ តទុបាទានំ ។ សឧបាទា-នោ គហបតិ ភិក្ខុ នោ បរិនិព្វាយតិ ។ អយំ ខោ គហបតិ ហេតុ អយំ បច្ចយោ យេនមិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ នោ បរិនិព្វាយន្តិ ។

ត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះរូបនោះ កាលបើភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះរូបនោះហើយ វិញ្ញាណដែលអាស្រ័យនូវរូបនោះក៏កើតឡើង សេចក្ដីប្រកាន់មាំនូវរូបនោះក៏មានឡើង ។ ម្នាលគហបតី ភិក្ខុមានសេចក្ដីប្រកាន់មាំ រមែងមិនបរិនិព្វាន ។ បេ ។ ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្ដាត ។ បេ ។ ម្នាលគហបតី មានធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្ដីត្រេកអរ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ កាលបើភិក្ខុនោះត្រេកអរ សរសើរ ឋិតនៅដោយសេចក្ដីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះហើយ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះក៏កើតឡើង សេចក្ដីប្រកាន់មាំនូវធម្មារម្មណ៍នោះ ក៏មានឡើង ។ ម្នាលគហបតី ភិក្ខុមានសេចក្ដីប្រកាន់មាំ រមែងមិនបរិនិព្វាន ។ ម្នាលគហបតី នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ មិនបរិនិព្វានក្នុងបច្ចុប្បន្ន ។

[២០២] សន្តិ ច ខោ គហបតិ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោ-សាយ តិដ្ឋតោ ន តំ និស្សិតំ វិញ្ញាណំ ហោតិ ន តទុបាទានំ ។ អនុបាទានោ គហបតិ ភិក្ខុ បរិនិព្វា-យតិ ។ បេ ។ សន្តិ ខោ គហបតិ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ខោ គហបតិ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោ-សាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តន្និស្សិតំ វិញ្ញាណំ ហោតិ

គហបតិវគ្គ ទី ៣

[២០២] ម្នាលគហបតី មានរូបដែលគប្បីដឹងច្បាស់ដោយចក្ខុ ជារូបគួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ កាលបើភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះហើយ វិញ្ញាណដែលអាស្រ័យនូវរូបនោះ ក៏មិនកើតឡើង សេចក្តីប្រកាន់មាំនូវរូបនោះ ក៏មិនមានដែរ ។ ម្នាលគហបតី ភិក្ខុមិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។ បេ ។ ម្នាលគហបតី មានរសដែលគប្បីដឹងច្បាស់ដោយអណ្តាត ។ បេ ។ ម្នាលគហបតី មានធម្មារម្មណ៍ដែលគប្បីដឹងច្បាស់ដោយចិត្ត ជាធម្មារម្មណ៍គួរប្រាថ្នា គួរត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាហេតុនៃសេចក្តីត្រេកអរ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះទេ កាលបើភិក្ខុនោះមិនត្រេកអរ មិនសរសើរ មិនបិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះហើយ វិញ្ញាណដែលអាស្រ័យនូវធម្មារម្មណ៍នោះ ក៏មិនកើតឡើង

ន តទុបាទានំ ។ អនុបាទានោ គហបតិ ភិក្ខុ បរិនិព្វា-
យតិ ។ អយំ ខោ គហបតិ ហេតុ អយំ បច្ចយោ យេន-
មិធេកច្ចេ សត្តា ទិដ្ឋេវ ធម្មេ បរិនិព្វាយន្តីតិ ។ អដ្ឋមំ ។

[២០៣] ឯកំ សមយំ អាយស្មា មហាកច្ចានោ
អវន្តីសុ វិហរតិ មក្ករកដេ អរញ្ញកុដិកាយំ ។ អថខោ
លោហិច្ចស្ស ព្រាហ្មណស្ស សម្ពហុលា អន្តេវាសិកា
កដ្ឋហារកា មាណវកា យេនាយស្មតោ មហាកច្ចា-
នស្ស អរញ្ញកុដិកា តេនុបសង្កមឹសុ ឧបសង្កមិត្វា
បរិតោ បរិតោ កុដិកាយំ អនុចង្កមន្តិ អនុវិចរន្តិ
ឧច្ចាសទ្ទា មហាសទ្ទា កានិចិ កានិចិ សេលេយ្យ-
កានិ[១] ករោន្តិ ។ ឥមេ បន មុណ្ឌកា សមណកា
ឥព្ភា កណ្ហា[២] ពន្ធុ បាទាបច្ចា ឥមេសំ ភារតកានំ
សក្កតា គរុកតា មានិតា បូជិតា អបចិតាតិ ។
អថខោ អាយស្មា មហាកច្ចានោ វិហារា និក្ខ-
មិត្វា តេ មាណវកេ ឯតទវោច មា មាណវកា[៣]

១ ឱ. សេលិស្សកានិ ។ អដ្ឋកថាយំ បន សេលោកស្សតានីតិ ។ ២ កិណ្ហា ។ ៣ មា
វោ មាណវកា ។

សេចក្តីប្រកាន់មាំនូវធម្មារម្មណ៍នោះ ក៏មិនមានដែរ ។ ម្នាលគហបតី ភិក្ខុ មិនមានសេចក្តីប្រកាន់មាំ រមែងបរិនិព្វាន ។ ម្នាលគហបតី នេះឯង ជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយពួកខ្លះ ក្នុងលោក នេះ បរិនិព្វានក្នុងបច្ចុប្បន្ន ។ ចប់សូត្រ ទី ៨ ។

[២០៣] សម័យមួយ ព្រះមហាកច្ចានៈមានអាយុ គង់នៅក្នុង អរញ្ញកុដិ (កុដិតូចតាំងនៅក្នុងព្រៃ) ជិតនគរមក្ករកដៈ ក្នុងអវន្តិជនបទ ។ គ្រានោះ ពួកមាណពអ្នករកឧសច្រើននាក់ ជាសិស្សរបស់លោហិច្ច-ព្រាហ្មណ៍ បានចូលទៅរកអរញ្ញកុដិរបស់ព្រះមហាកច្ចានៈមានអាយុ លុះ ចូលទៅដល់ហើយ ក៏ដើរវង្កាត់ព័ទ្ធជុំវិញអរញ្ញកុដិ ស្រែកហ៊ោកញ្ជ្រៀវ នាំគ្នាលេងល្បែងសេលេយ្យកៈ[១] ណាមួយ (តាមទំនើងចិត្ត) ។ មាណព ទាំងនោះនិយាយថា សមណៈត្រងោលទាំងនេះ ជាពួកគហបតីកណ្ហ-គោត្រ កើតអំពីខ្នងជើងនៃព្រហ្ម ដែលពួកកុដុម្ពីក៏ធ្វើសក្ការៈគោរពរាប់ អានបូជាកោតក្រែង ។ វេលានោះ ព្រះមហាកច្ចានៈមានអាយុ បានចេញ អំពីវិហារហើយ ពោលទៅនឹងមាណពទាំងនោះដូច្នេះថា នៃពួកមាណព

១ គឺលេងល្បែងចាប់ខ្នងគ្នាទៅវិញទៅមក ហើយលោតកញ្ឆោងទៅខាងណេះម្តងខាងណោះ ម្តង ។ អដ្ឋកថា ។

គហបតិវគ្គោ តតិយោ

សទ្ធមកាត្ត ជម្មំ រោ កាសិស្សាមីតិ ។ ឯវំ វុត្តេ តេ មាណវកា តុណ្ហី អហេសុំ ។ អថខោ អាយស្មា មហាកច្ចានោ តេ មាណវកេ គាថាហិ អជ្ឈភាសិ

[២០៤] សីលុត្តមា បុព្វតរា អហេសុំ
តេ ព្រាហ្មណា យេ បុរាណំ សរន្តិ
គុត្តានិ ទ្វារានិ សុរក្ខិតានិ
អហេសុំ តេសំ អភិភុយ្យ កោធំ ។
ធម្មេ ចជ្ឈានេ ចរតា អហេសុំ
តេ ព្រាហ្មណា យេ បុរាណំ សរន្តិ
ឥមេវ រោក្កម្ម ជហាម្ហសេតិ
គោត្តេន មត្តា វិសមំ ចរន្តិ

អ្នកទាំងឡាយកុំស្រែកហ៊ោឡើយ យើងនឹងសម្តែងធម៌ ដល់អ្នកទាំង-ឡាយ ។ កាលបើព្រះថេរៈពោលយ៉ាងនេះហើយ មាណពទាំងនោះក៏នាំគ្នាស្ងៀម ។ ទើបព្រះមហាកច្ចានៈមានអាយុ បានពោលទៅនឹងមាណពទាំងនោះ ដោយគាថាទាំងឡាយ ថា

[២០៤] ព្រាហ្មណ៍ទាំងឡាយណា រឭកធម៌ (របស់ព្រាហ្មណ៍) បុរាណ ព្រាហ្មណ៍ទាំងនោះ ឈ្មោះថាមានសីលដ៏ឧត្តម មានគុណប្រាកដមកពីដើម ព្រាហ្មណ៍ទាំងនោះ ឈ្មោះថាបានគ្រប់គ្រងរក្សានូវទ្វារដោយប្រពៃ ទាំងគ្របសង្កត់នូវសេចក្តីក្រោធបាន ។ ព្រាហ្មណ៍ទាំងឡាយណា រឭកធម៌ (របស់ព្រាហ្មណ៍) បុរាណ ព្រាហ្មណ៍ទាំង-ឡាយនោះ ឈ្មោះថាប្រព្រឹត្តក្នុងធម៌គឺកុសលកម្មបថ ១០ ប្រការ និងសមាបត្តិជ្ឈាន ៨ យ៉ាង ព្រាហ្មណ៍ទាំងនេះឯងបានចៀសចេញ (ចាកគុណ) ស្រវឹងដោយគោត្រ គិតថា យើងទាំងឡាយរមែងលះបង់ (អកុសលកម្ម) ហើយនាំគ្នាប្រព្រឹត្តកម្មមិនស្មើគឺធ្វើកម្មមិនស្មើគ្នា មានកាយកម្មជាដើម ។

កោធាភិភូតា សុបុថុត្តទណ្ឌា
វិរុជ្ឈមានា តសថាវរេសុ[១]
អគុត្តទ្វារស្ស ភវន្តិ មោឃា
សុបិនេវ លទ្ធំ បុរិសស្ស វិត្តំ ។
អនាសកា ថណ្ឌិលសាយិកា ច
បាតោ សិនានញ្ច តយោ ច វេទា
ខរាជិនំ ជដា បង្កោ
មន្តា សីលព្វតំ តបោ
កុហនា វង្កទណ្ឌា ច
ឧទកា ច មនានិ ច
វណ្ណា ឯតេ ព្រាហ្មណានំ
កតា កិញ្ចិក្ខភាវនា
ចិត្តញ្ច សុសមាហិតំ
វិប្បសន្នមនាវិលំ
អខិលំ សព្វភូតេសុ
សោ មគ្គោ ព្រហ្មបត្តិយា ។

១ ឱ. វិរុជ្ឈមានា សតណ្ហាតណ្ហេសុ ។

ព្រាហ្មណ៍ទាំងឡាយ ដែលសេចក្តីក្រោធគ្របសង្កត់ មានអាជ្ញាលើខ្លួនជាច្រើន នាំគ្នាប្រព្រឹត្តខុសក្នុងបុគ្គលដែលមានតណ្ហានិងបុគ្គលដែលឥតតណ្ហាទាំងឡាយ បុគ្គលដែលមិនបានគ្រប់គ្រងទ្វារ រមែងមានសេចក្តីសាបសូន្យទទេ ដូចទ្រព្យ ដែលបុរសបានក្នុងវេលាយប់សប្តិ ។ ការអត់អាហារ ១ ការដេកលើផែនដី ១ ការជម្រះរាងកាយអំពីព្រឹក ១ ត្រៃភេទ ១ ស្បែកខ្លាឃ្មុំមានសម្ពស្សរឹង ១ ផ្នួងសក់ ១ មន្ទិលរបស់ធ្មេញ ១ មន្ត ១ សីលនិងវត្ត ១ តបៈ ១ ការញ៉ាំងមហាជនឲ្យភ័ន្តភាំង ១ ទំពក់ ១ ទឹក ១ គ្រឿងដុសខាត់មុខ ១ ទាំងនេះជាគ្រឿងបរិក្ខាររបស់ពួកព្រាហ្មណ៍ ដែលពួកព្រាហ្មណ៍បានធ្វើភាវនាបន្តិចបន្តួច ទាំងបានតម្កល់ចិត្តខ្ជាប់ខ្ជួនល្អ ជាចិត្តថ្លា មិនកករល្អក់ ជាចិត្តមិនរឹងត្អឹង គឺទន់ភ្លន់ក្នុងពួកសត្វទាំងពួង ផ្លូវនោះ តែងប្រព្រឹត្តទៅដើម្បីដល់នូវធម៌ដ៏ប្រសើរ ។

២៧១

គហបតិវគ្គោ តតិយោ

[២០៤] អថខោ តេ មាណវកា កុបិតា អនត្តមនា យេន លោហិច្ចោ ព្រាហ្មណោ តេនុបសង្កមឹសុ ឧបសង្កមិត្វា លោហិច្ចំ ព្រាហ្មណំ ឯតទវោចុំ យគ្ឃេ ភវំ ជានេយ្យ សមណោ មហាកច្ចានោ ព្រាហ្មណានំ មន្តេ ឯកំសេន អសំវទតិ[១] បដិក្កោសតីតិ ។ ឯវំ វុត្តេ លោហិច្ចោ ព្រាហ្មណោ កុបិតោ អហោសិ អនត្តមនោ ។ អថខោ លោហិច្ចស្ស ព្រាហ្មណស្ស ឯតទហោសិ ន ខោ បន មេតំ បដិរូបំ យោហំ អញ្ញទត្ថុ មាណវកានំយេវ សុត្វា សមណំ មហាកច្ចានំ អក្កោសេយ្យំ វិរុជ្ឈេយ្យំ បរិភាសេយ្យំ យន្នូនាហំ ឧបសង្កមិត្វា បុច្ឆេយ្យន្តិ ។ អថខោ លោហិច្ចោ ព្រាហ្មណោ តេហិ មាណវកេហិ សទ្ធឹ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ លោហិច្ចោ ព្រាហ្មណោ

១ អបវត្តតិ ។

គហបតិវគ្គ ទី ៣

[២០៥] គ្រានោះ មាណពទាំងនោះក៏ខឹងអាក់អន់ចិត្ត ហើយនាំគ្នាចូលទៅរកលោហិច្ចព្រាហ្មណ៍ លុះចូលទៅដល់ហើយ បានពោលនឹងលោហិច្ចព្រាហ្មណ៍ដូច្នេះថា នែលោកដ៏ចម្រើន លោកគប្បីដឹងថាសមណៈឈ្មោះមហាកច្ចានៈ មិនពោលសរសើរ ត្រឡប់ជាពោលបដិសេធចំពោះមន្តទាំងឡាយរបស់ពួកព្រាហ្មណ៍ ដោយដាច់ខាត ។ កាលពួកមាណពនិយាយយ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ក៏ខឹងអាក់អន់ចិត្ត ។ ទើបលោហិច្ចព្រាហ្មណ៍មានសេចក្តីត្រិះរិះដូច្នេះថា បើតាមអញស្តាប់សម្តីរបស់ពួកមាណព គួរតែជេរ ប្រទេច គម្រាមព្រះសមណៈមហាកច្ចានៈដោយពិត តែអំពើនេះ មិនសមគួរដល់អញឡើយ បើដូច្នោះគួរតែអញចូលទៅសួរលោកសិន ។ លំដាប់នោះ លោហិច្ចព្រាហ្មណ៍ ព្រមដោយមាណពទាំងនោះ បានចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ គួរជាទីរឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះលោហិច្ចព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ

អាយស្មន្តំ មហាកច្ចានំ ឯតទវោច អាគមំសុ នុ ខ្វិធ ភោ កច្ចាន អម្ហាកំ សម្ពហុលា អន្តេវាសិកា កដ្ឋហារកា មាណវកាតិ ។ អាគមំសុ ខ្វិធ តេ ព្រាហ្មណ សម្ពហុលា អន្តេវាសិកា កដ្ឋហារកា មាណវកាតិ ។ អហុ បន ភោតោ កច្ចានស្ស តេហិ មាណវកេហិ សទ្ធឹ កោចិទេវ កថាសល្លាចោតិ ។ អហុ ខោ មេ ព្រាហ្មណ តេហិ មាណវកេហិ សទ្ធឹ អហោសិ កថាសល្លាចោតិ ។ យថាកថំ បន ភោតោ កច្ចានស្ស តេហិ មាណវកេហិ សទ្ធឹ អហោសិ កថាសល្លាចោតិ ។ ឯវំ ខោ មេ ព្រាហ្មណ តេហិ មាណវកេហិ សទ្ធឹ អហោសិ កថាសល្លាចោតិ

សីលុត្តមា បុព្វតរា អហេសុំ
តេ ព្រាហ្មណា យេ បុរាណំ សរន្តិ
។ បេ ។ អខិលំ សព្វភូតេសុ
សោ មគ្គោ ព្រហ្មបត្តិយាតិ ។

បានពោលនឹងព្រះមហាកច្ចានៈមានអាយុ ដូច្នេះថា បពិត្រព្រះកច្ចានៈដ៏ចម្រើន ពួកមាណពអ្នករកឧស ជាសិស្សរបស់ខ្ញុំ ច្រើននាក់ បានមកក្នុងទីនេះដែរឬ ។ ម្នាលព្រាហ្មណ៍ ពួកមាណពអ្នករកឧស ជាសិស្សរបស់អ្នកច្រើននាក់ បានមកក្នុងទីនេះមែន ។ ចុះព្រះកច្ចានៈដ៏ចម្រើន បានពោលចរចា ជាមួយនឹងពួកមាណពទាំងនោះ ខ្លះដែរឬ ។ ម្នាលព្រាហ្មណ៍ អាត្មាបានពោលពាក្យចរចា ជាមួយនឹងពួកមាណពទាំងនោះ ខ្លះដែរ ។ ចុះព្រះកច្ចានៈដ៏ចម្រើន បានពោលពាក្យចរចាជាមួយនឹងពួកមាណពទាំងនោះ ដូចម្ដេចខ្លះ ។ ម្នាលព្រាហ្មណ៍ អាត្មាបានពោលពាក្យចរចា ជាមួយនឹងពួកមាណពទាំងនោះ យ៉ាងនេះថា

ព្រាហ្មណ៍ទាំងឡាយណា រឭកធម៌ (របស់ពួកព្រាហ្មណ៍) បុរាណ ព្រាហ្មណ៍ទាំងឡាយនោះ ឈ្មោះថាជាអ្នកមានសីលដ៏ឧត្តម មានគុណប្រាកដមកអំពីមុន ។ បេ ។ ជាចិត្តមិនរឹងត្អឹងគឺទន់ភ្លន់ ក្នុងពួកសត្វទូទៅ ផ្លូវនោះ រមែងប្រព្រឹត្តទៅដើម្បីដល់នូវធម៌ដ៏ប្រសើរ ។

២៧៣

គហបតិវគ្គោ តតិយោ

ឯវំ ខោ មេ ព្រាហ្មណា តេហិ សទ្ធឹ អហោសិ ក-
ថាសល្លាបោតិ ។ អគុត្តទ្វារោតិ ភវំ កច្ចានោ អាហ
កិត្តាវតា នុ ខោ ភោ កច្ចាន អគុត្តទ្វារោ ហោតី-
តិ ។ ឥធ ព្រាហ្មណា ឯកច្ចោ ចក្ខុនា រូបំ ទិស្វា
បិយរូបេ រូបេ អធិមុច្ចតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ
អនុបដ្ឋិតាយ សតិយា ច វិហរតិ បរិត្តចេតសោ តញ្ច
ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ ។ យ-
ត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិ-
សេសា ន និរុជ្ឈន្តិ ។ សោតេន សទ្ទំ សុត្វា ។ បេ ។
ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។
កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ

គហបតិវគ្គ ទី ៣

ម្នាលព្រាហ្មណ៍ អាត្មាបានពោលពាក្យចរចាជាមួយនឹងពួកមាណព ទាំងនោះ យ៉ាងនេះឯង ។ ព្រះកច្ចានៈដ៏ចម្រើនពោលថា បុគ្គលមិន បានគ្រប់គ្រងទ្វារដូច្នេះ បពិត្រព្រះកច្ចានៈដ៏ចម្រើន បុគ្គលដែលមិនបាន គ្រប់គ្រងទ្វារ តើដោយហេតុដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គល ខ្លះក្នុងលោកនេះ បានឃើញរូបដោយចក្ខុហើយ ជាប់ចិត្តក្នុងរូបដែល ជាទីស្រឡាញ់ ព្យាបាទក្នុងរូបដែលមិនជាទីស្រឡាញ់ មិនបានប្រុង ស្មារតី មានចិត្តប្រកបដោយកិលេស ទាំងមិនដឹងច្បាស់តាមពិត នូវ ចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ អកុសលធម៌ដ៏លាមកទាំងនោះ របស់ បុគ្គលនោះ ដែលកើតហើយ រមែងមិនរលត់ទៅវិញ ដោយមិនមាន សេសសល់ ដោយប្រការយ៉ាងណា ។ បុគ្គលឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្តាត ។ ពាល់ ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ

បិយរូបេ ធម្មេ អធិមុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតាយ សតិយា ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ ។ យ-ថាស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិ-សេសា ន និរុជ្ឈន្តិ ។ ឯវំ ខោ ព្រាហ្មណ អគុត្តទ្វារោ ហោតីតិ ។

[២០៦] អច្ឆរិយំ ភោ កច្ចាន អព្ភុតំ ភោ កច្ចាន យាវញ្ចិទំ ភោតា កច្ចានេន អគុត្តទ្វារោ ច សមានោ អគុត្តទ្វារោតិ អក្ខាតោ ។ គុត្តទ្វារោតិ ភវំ កច្ចានោ អាហ កិត្តាវតា នុ ខោ ភោ កច្ចាន គុត្តទ្វារោ ហោ-តីតិ ។ ឥធ ព្រាហ្មណ ភិក្ខុ ចក្ខុនា រូបំ ទិស្វា

រមែងជាប់ចិត្តក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ ព្យាបាទក្នុងធម្មារម្មណ៍ដែលមិនជាទីស្រឡាញ់ មិនប្រុងស្មារតី មានចិត្តប្រកបដោយកិលេស ទាំងមិនដឹងតាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ អកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើង រមែងមិនរលត់ទៅវិញ ដោយមិនមានសេសសល់ ដោយប្រការយ៉ាងណា ។ ម្នាលព្រាហ្មណ៍ បុគ្គលមិនបានគ្រប់គ្រងទ្វារ រមែងមាន ដោយប្រការយ៉ាងនោះៗ ឯង ។

[២០៦] បពិត្រព្រះកច្ចានៈដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ចំឡែកណាស់ បុគ្គលដែលមិនបានគ្រប់គ្រងទ្វារ ព្រះកច្ចានៈដ៏ចម្រើន ពោលថា ជាបុគ្គលមិនបានគ្រប់គ្រងទ្វារមែន ។ ចុះព្រះកច្ចានៈដ៏ចម្រើន ពោលថាបុគ្គលគ្រប់គ្រងទ្វារដូច្នេះ បពិត្រព្រះកច្ចានៈដ៏ចម្រើន តើបុគ្គលដែលបានគ្រប់គ្រងទ្វារ ដោយហេតុដូចម្តេច ។ ម្នាលព្រាហ្មណ៍ ភិក្ខុ ក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ

បិយរូបេ រូបេ នាធិមុច្ចតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតាយ សតិយា ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ ។ យថាស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ នាធិ-មុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ ឧបដ្ឋិតាយ សតិយា ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញា-វិមុត្តឹ យថាភូតំ បជានាតិ ។ យថាស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ ឯវំ ខោ ព្រាហ្មណ គុត្តទ្វារោ ហោតីតិ ។

គហបតិវគ្គ ទី ៣

មិនជាប់ចិត្តក្នុងរូបដែលជាទីស្រឡាញ់ មិនព្យាបាទក្នុងរូបដែលមិនជាទីស្រឡាញ់ ប្រុងស្មារតី មានចិត្តមិនប្រកបដោយកិលេស ទាំងដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ អកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើង រមែងរលត់ទៅវិញ ដោយមិនមានសេសសល់ ដោយប្រការយ៉ាងណា ។ បុគ្គល ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ មិនជាប់ចិត្តក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ មិនព្យាបាទក្នុងធម្មារម្មណ៍ដែលមិនជាទីស្រឡាញ់ ប្រុងស្មារតី មានចិត្តមិនប្រកបដោយកិលេស ទាំងដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ ដែលកើតឡើង រមែងរលត់ទៅ ដោយមិនមានសេសសល់ ដោយប្រការយ៉ាងណា ។ ម្នាលព្រាហ្មណ៍ បុគ្គលបានគ្រប់គ្រងទ្វារ ដោយប្រការយ៉ាងនោះ ៗ ឯង ។

[២០៧] អច្ឆរិយំ ភោ កច្ចាន អព្ភុតំ ភោ កច្ចាន យាវញ្ចិទំ ភោតា កច្ចានេន គុត្តទ្វារោ វ សមានោ គុត្តទ្វារោតិ អក្ខាតោ ។ អភិក្កន្តំ ភោ កច្ចាន អ-ភិក្កន្តំ ភោ កច្ចាន សេយ្យថាបិ ភោ កច្ចាន និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវំ ភោតា កច្ចានេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភោ កច្ចាន តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ កច្ចានោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។ យថា ច

[២០៧] បពិត្រព្រះកច្ចានៈដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ចំឡែកណាស់ បុគ្គលដែលគ្រប់គ្រងទ្វារ ព្រះកច្ចានៈដ៏ចម្រើន ពោលថាជាអ្នកគ្រប់គ្រងទ្វារមែន ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ដូចគេផ្ងាររបស់ដែលគេផ្កាប់ ឬបើកបង្ហាញរបស់ដែលបិទបាំងទុក ពុំនោះសោត ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា មនុស្សទាំងឡាយដែលមានភ្នែកភ្លឺ នឹងបានឃើញនូវរូបទាំងឡាយ មានឧបមាយ៉ាងណា ។ ធម៌ដែលព្រះកច្ចានៈដ៏ចម្រើន បានប្រកាសដោយអនេកបរិយាយ ក៏មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ខ្ញុំព្រះករុណានេះសូមដល់ព្រះមានព្រះភាគនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរឭក សូមព្រះកច្ចានៈដ៏ចម្រើនចាំទុក នូវខ្ញុំព្រះករុណាថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមតទៅ ។ មួយទៀត

ភវំ កច្ចានោ មក្ករកដេ ឧបាសកកុលានិ ឧបសង្ក-
មតិ ឯវមេវំ លោហិច្ចកុលំ ឧបសង្កមតុ ។ តត្ថ យេ
មាណវកា មាណវិកា វា ភវន្តំ កច្ចានំ អភិវាទេស្សន្តិ
បច្ចុបដ្ឋិស្សន្តិ អាហរិស្សន្តិ អាសនំ វា ឧទកំ វា
ទស្សន្តិ តេសន្តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខា-
យាតិ ។ នវមំ ។

[២០៨] ឯកំ សមយំ អាយស្មា ឧទាយិ កា-
មណ្ឌាយំ វិហរតិ តោទេយ្យស្ស ព្រាហ្មណស្ស អម្ពវ-
នេ ។ អថខោ វេរហញ្ចានិគោត្តាយ ព្រាហ្មណិយា អន្តេ-
វាសី មាណវកោ យេនាយស្មា ឧទាយិ តេនុបសង្កមិ
ឧបសង្កមិត្វា អាយស្មតា ឧទាយិនា សទ្ធឹ សម្មោទិ
សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តំ មាណវកំ អាយស្មា
ឧទាយិ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ
សមុត្តេជេសិ សម្បហំសេសិ ។ អថខោ មាណវកោ អា-
យស្មតា ឧទាយិនា ធម្មិយា កថាយ សន្ទស្សិតោ ស-
មាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា

ព្រះកច្ចានៈដ៏ចម្រើន តែងចូលទៅរកត្រកូលនៃឧបាសកក្នុងនគរមក្ករកដៈ យ៉ាងណា សូមលោកចូលទៅរកត្រកូល នៃលោហិច្ចព្រាហ្មណ៍ យ៉ាងនោះដែរ ។ ពួកមាណពឬមាណវិកាណា ក្នុងត្រកូលនោះ នឹងថ្វាយបង្គំ នឹងក្រោកទទួល នឹងក្រាលអាសនៈ ឬនឹងប្រគេនទឹក ចំពោះព្រះកច្ចានៈដ៏ចម្រើន អំពើនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកមាណពនិងមាណវិកាទាំងនោះ អស់កាលជាយូរអង្វែង ។ ចប់សូត្រ ទី ៩ ។

[២០៨] សម័យមួយ ព្រះឧទាយិមានអាយុ គង់ក្នុងព្រៃស្វាយរបស់តោទេយ្យព្រាហ្មណ៍ ជិតនគរកាមណ្ឌា ។ គ្រានោះ មាណពជាសិស្ស របស់ព្រាហ្មណី ឈ្មោះវេរហញ្ចានិគោត្តា បានចូលទៅរកព្រះឧទាយិមានអាយុ លុះចូលទៅដល់ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះឧទាយិមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះមាណពនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះឧទាយិមានអាយុ បានពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ មាណពដែលព្រះឧទាយិមានអាយុ បានពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកអំពីអាសនៈ

យេន វេរហច្ចានិគោត្តា ព្រាហ្មណី តេនុបសង្កមិ ឧ-
បសង្កមិត្វា វេរហច្ចានិគោត្តំ ព្រាហ្មណឹ ឯតទវោច
យគ្ឃេ ភោតី ជានេយ្យ សមណោ ឧទាយិ ធម្មំ ទេ-
សេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-
កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ
ព្រហ្មចរិយំ បកាសេតីតិ ។ តេនហិ ត្វំ មាណវក មម
វចនេន សមណំ ឧទាយឹ និមន្តេហិ ស្វាតនាយ ភត្តេ-
នាតិ ។ ឯវំ ភោតីតិ ខោ សោ មាណវកោ វេរហច្ចានិ-
គោត្តាយ ព្រាហ្មណិយា បដិស្សុត្វា យេនាយស្មា ឧ-
ទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ
ឯតទវោច អធិវាសេតុ កិរ ភវំ ឧទាយិ អម្ហាកំ អាច-
រិយភរិយាយ វេរហច្ចានិគោត្តាយ ព្រាហ្មណិយា ស្វា-
តនាយ ភត្តន្តិ ។ អធិវាសេសិ ខោ អាយស្មា ឧទាយិ
តុណ្ហីភាវេន ។ អថខោ អាយស្មា ឧទាយិ តស្សា
រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរំ អា-

ហើយចូលទៅរកវេរហញ្ចានិគោត្តាព្រាហ្មណី លុះចូលទៅដល់ហើយ ក៏បានពោលនឹងវេរហញ្ចានិគោត្តាព្រាហ្មណី ដូច្នេះថា បពិត្រនាងជាម្ចាស់ នាងដ៏ចម្រើនគួរដឹងថា ព្រះសមណៈឧទាយិ តែងសម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសព្រហ្មចរិយធម៌បរិសុទ្ធបរិបូណ៌ទាំងអស់ ព្រមទាំងអត្ថព្រមទាំងព្យញ្ជនៈ ។ នែមាណព បើដូច្នោះ អ្នកចូរទៅនិមន្តសមណៈឧទាយិដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក តាមពាក្យរបស់យើង ។ មាណពនោះ ទទួលស្តាប់ពាក្យវេរ-ហញ្ចានិគោត្តាព្រាហ្មណីថា បាទ នាងជាម្ចាស់ ហើយចូលទៅរកព្រះឧទាយិមានអាយុ លុះចូលទៅដល់ បានពោលនឹងព្រះឧទាយិមានអាយុ ដូច្នេះថា សូមព្រះឧទាយិដ៏ចម្រើនទទួលភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែករបស់វេរហញ្ចានិគោត្តាព្រាហ្មណី ជាកិរិយារបស់អាចារ្យ នៃខ្ញុំករុណា ។ ព្រះឧទាយិមានអាយុ ក៏ទទួលនិមន្ត ដោយតុណ្ហីភាព ។ លុះកន្លងរាត្រីនោះទៅ ព្រះឧទាយិមានអាយុ ក៏ស្លៀកស្បង់ ប្រដាប់បាត្រនិង

២៧៩

គហបតិវគ្គោ តតិយោ

ទាយ យេន វេរហញ្ចានិគោត្តាយ ព្រាហ្មណិយា និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ វេរហញ្ចានិគោត្តា ព្រាហ្មណី អាយស្មន្តំ ឧទាយឹ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ វេរហញ្ចានិគោត្តា ព្រាហ្មណី អាយស្មន្តំ ឧទាយឹ ភុត្តាវឹ ឱនីតបត្តបាណឹ បាទុកា អារោហិត្វា ឧច្ចេ អាសនេ និសីទិត្វា សីសំ ឱគុណ្ឋិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច ភណ សមណ ធម្មន្តិ ។ ភវិស្សតិ ភគិនិ សមយោតិ វត្វា ឧដ្ឋាយាសនា បក្កាមិ ។

គហបតិវគ្គ ទី ៣

ចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅ របស់វេរហញ្ញានិគោត្តាព្រាហ្មណី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក ។ គ្រានោះ វេរហញ្ញានិគោត្តាព្រាហ្មណី (អង្គាស) ព្រះឧទាយិមានអាយុ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែលោកប្រកែក ។ ទើបវេរហញ្ញានិគោត្តាព្រាហ្មណី (ដឹងថា) ព្រះឧទាយិមានអាយុឆាន់ស្រេច លែងលូកដៃក្នុងបាត្រហើយ ក៏ពាក់ស្បែកជើង អង្គុយលើអាសនៈខ្ពស់ ទទូរក្បាលបានពោលនឹងព្រះឧទាយិមានអាយុដូច្នេះថា បពិត្រព្រះសមណៈ សូមលោកសម្តែងធម៌ទៅ ។ ព្រះឧទាយិពោលថា ម្នាលនាង សម័យគួរនឹងមាន (ទៅថ្ងៃក្រោយ) ហើយក៏ក្រោកអំពីអាសនៈចៀសចេញទៅ ។

[២០៩] ទុតិយម្បិ ខោ សោ មាណវកោ យេនា-
យស្មា ឧទាយិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា
ឧទាយិនា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-
ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ
ខោ តំ មាណវកំ អាយស្មា ឧទាយិ ធម្មិយា កថាយ
សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេ-
សិ ។ ទុតិយម្បិ ខោ សោ មាណវកោ អាយស្មតា
ឧទាយិនា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ
សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា យេន
វេរហញ្ចានិគោត្តា ព្រាហ្មណី តេនុបសង្កមិ ឧបសង្ក-
មិត្វា វេរហញ្ចានិគោត្តំ ព្រាហ្មណឹ ឯតទវោច យគ្ឃេ
ភោតី ជានេយ្យ សមណោ ឧទាយិ ធម្មំ ទេសេតិ
អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យា-
ណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-
ចរិយំ បកាសេតីតិ ។ ឯវមេវំ បន ត្វំ មាណវក សម-
ណស្ស ឧទាយិស្ស វណ្ណំ ភាសសិ សមណោ ឧទាយិ

[២០៩] មាណពនោះ ចូលទៅរកព្រះឧទាយិជាគម្រប់ពីរដង ទៀត លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះឧទាយិមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យគួរជាទីរឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះមាណពនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះឧទាយិមានអាយុ ក៏ពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ មាណពនោះ លុះព្រះឧទាយិបានពន្យល់ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកអំពីអាសនៈចូលទៅរកវេរហញ្ញានិគោត្តាព្រាហ្មណី លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងវេរហញ្ញានិគោត្តាព្រាហ្មណីដូច្នេះថា បពិត្រនាងជាម្ចាស់ នាងដ៏ចម្រើនគួរដឹងថា ព្រះសមណៈឧទាយិ តែងសម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសព្រហ្មចរិយធម៌បរិសុទ្ធបរិបូណ៌ទាំងអស់ ព្រមទាំងអត្ថព្រមទាំងព្យញ្ជនៈ ។ នៃមាណព អ្នកពោលសរសើរគុណព្រះសមណៈឧទាយិ យ៉ាងនេះពិតមែនហើយ ប៉ុន្តែព្រះសមណៈឧទាយិ

២៨១



ភណ សមណ ធម្មន្តិ វុត្តោ សមានោ ភវិស្សតិ ភគិនិ សមយោតិ វត្វា ឧដ្ឋាយាសនា បក្កន្តោតិ ។ តថា ហិ បន ត្វំ ភោតិ បាទុកា អារោហិត្វា ឧច្ចេ អាសនេ និសីទិត្វា សីសំ ឱគុណ្ឋិត្វា ឯតទវោច ភណ សមណ ធម្មន្តិ ធម្មគរុនោ ហិ តេ ភវន្តោ ធម្មគារវាតិ ។ តេនហិ ត្វំ មាណវកា មម វចនេន សមណំ ឧបាលឹ និមន្តេហិ ស្វាតនាយ ភត្តេនាតិ ។ ឯវំ ភោតីតិ ខោ សោ មាណវកោ វេរហច្ចានិគោត្តាយ ព្រាហ្មណិយា បដិស្សុត្វា យេនាយស្មា ឧបាលិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបាលឹ ឯតទវោច អធិវាសេតុ កិរ ភវំ ឧបាលិ អម្ហាកំ អាចរិយភរិយាយ វេរហច្ចានិគោត្តាយ ព្រាហ្មណិយា ស្វាតនាយ ភត្តន្តិ ។ អធិវាសេសិ ខោ អាយស្មា ឧបាលិ តុណ្ហីភាវេន ។ អថខោ អាយស្មា ឧបាលិ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន វេរហច្ចានិគោត្តាយ ព្រាហ្មណិយា និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ វេរហច្ចានិគោត្តា ព្រាហ្មណី

គហបតិវគ្គ ទី ៣

កាលយើងនិយាយថា បពិត្រព្រះសមណៈ សូមលោកសម្តែងធម៌ទៅ ដូច្នេះ លោកឆ្លើយថា ម្នាលនាង សម័យគួរ នឹងមាន (ទៅថ្ងៃក្រោយ) ហើយក្រោកអំពីអាសនៈចេញទៅ ។ ពិតដូច្នោះមែន ដ្បិតនាងដ៏ចម្រើន ពាក់ស្បែកជើង អង្គុយលើអាសនៈខ្ពស់ ទទូរក្បាល បានពោលដូច្នេះថា បពិត្រព្រះសមណៈ ចូរលោកសម្តែងធម៌ទៅ ព្រោះថាលោកដ៏ចម្រើនទាំងនោះ ជាអ្នកគោរពធម៌ មានធម៌ជាទីគោរព ។ ម្នាលមាណព បើដូច្នោះ អ្នកចូរទៅនិមន្តព្រះសមណៈឧទាយិដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែកតាមពាក្យរបស់យើង ។ មាណពនោះទទួលពាក្យវេរហញ្ញានិ-គោត្តាព្រាហ្មណីថា បាទ នាងដ៏ចម្រើន ហើយចូលទៅរកព្រះឧទាយិមានអាយុ លុះចូលទៅដល់ហើយ បានពោលនឹងព្រះឧទាយិមានអាយុដូច្នេះថា សូមព្រះឧទាយិដ៏ចម្រើន ទទួលនិមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក របស់វេរហញ្ញានិគោត្តាព្រាហ្មណីជាភរិយានៃអាចារ្យរបស់ខ្ញុំព្រះករុណា ។ ព្រះឧទាយិមានអាយុ ក៏បានទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះឧទាយិមានអាយុ លុះកន្លងរាត្រីនោះទៅ ក៏ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃវេរហញ្ញានិគោត្តាព្រាហ្មណី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក ។ ទើបវេរហញ្ញានិគោត្តាព្រាហ្មណី

អាយស្មន្តំ ឧទាយឹ បណីតេន ខាទនីយេន ភោជនី-
យេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ
វេរហញ្ចានិគោត្តា ព្រាហ្មណី អាយស្មន្តំ ឧទាយឹ ភុត្តាវឹ
ឱនីតបត្តបាណឹ បាទុកា ឱរោហិត្វា នីចេ អាសនេ
និសីទិត្វា សីសំ វិរិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច
កិស្មឹ នុ ខោ ភន្តេ សតិ អរហន្តោ សុខទុក្ខំ បញ្ញបេន្តិ
កិស្មឹ អសតិ អរហន្តោ សុខទុក្ខំ ន បញ្ញបេន្តីតិ ។

[២១០] ចក្ខុស្មឹ ខោ ភគិនិ សតិ អរហន្តោ សុ-
ខទុក្ខំ បញ្ញបេន្តិ ចក្ខុស្មឹ អសតិ អរហន្តោ សុខ-
ទុក្ខំ ន បញ្ញបេន្តិ ។ បេ ។ ជិវ្ហាយ សតិ អរហន្តោ

អង្គាសព្រះឧទាយិមានអាយុ ដោយខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ត្រាតែលោកប្រកែក ។ លំដាប់នោះ វេរហញ្ចានិគោត្តាព្រាហ្មណី (ដឹងថា) ព្រះឧទាយិមានអាយុឆាន់ស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏ដោះស្បែកជើង អង្គុយលើ អាសនៈទាប ផាត់ (សំពត់) អំពីក្បាលចេញហើយ បានពោលនឹងព្រះ ឧទាយិមានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន កាលបើអ្វីមាន ទើប ព្រះអរហន្តទាំងឡាយបញ្ញត្តនូវសុខនិងទុក្ខ កាលបើអ្វីមិនមាន ទើប ព្រះអរហន្តទាំងឡាយមិនបញ្ញត្តនូវសុខនិងទុក្ខ ។

[២១០] ម្នាលនាង កាលបើចក្ខុមាន ទើបព្រះអរហន្តទាំង-ឡាយបញ្ញត្តនូវសុខនិងទុក្ខ កាលបើចក្ខុមិនមាន ព្រះអរហន្តទាំងឡាយ មិនបញ្ញត្តនូវសុខនិងទុក្ខ ។ បេ ។ កាលបើអណ្តាតមាន ទើបព្រះ

សុខទុក្ខំ បញ្ញបេន្តិ ជិវ្ហាយ អសតិ អរហន្តោ សុខទុក្ខំ ន បញ្ញបេន្តិ ។ បេ ។ មនស្មឹ សតិ អរហន្តោ សុខ-ទុក្ខំ បញ្ញបេន្តិ មនស្មឹ អសតិ អរហន្តោ សុខទុក្ខំ ន បញ្ញបេន្តីតិ ។ ឯវំ វុត្តេ វេរហញ្ចានិគោត្តា ព្រាហ្ម-ណី អាយស្មន្តំ ឧទាយឹ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ។ ឯវមេវំ អយ្យេន ឧទា-យិនា អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯ-សាហំ ភន្តេ ឧទាយិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ អយ្យោ ឧទាយិ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ ទសមំ ។

គហបតិវគ្គ ទី ៣

អរហន្តទាំងឡាយបញ្ញត្តនូវសុខនិងទុក្ខ កាលបើអណ្តាតមិនមាន ព្រះអរហន្តទាំងឡាយមិនបញ្ញត្តនូវសុខនិងទុក្ខទេ ។ បេ ។ កាលបើចិត្តមាន ទើបព្រះអរហន្តទាំងឡាយបញ្ញត្តនូវសុខនិងទុក្ខ កាលបើចិត្តមិនមាន ព្រះអរហន្តទាំងឡាយមិនបញ្ញត្តនូវសុខនិងទុក្ខទេ ។ កាលបើព្រះឧទាយិ ពោលយ៉ាងនេះហើយ ទើបវេរហញ្ចានិគោត្តាព្រាហ្មណីពោលនឹងព្រះឧទាយិមានអាយុដូច្នេះថា ច្បាស់ណាស់ លោកម្ចាស់ ច្បាស់ណាស់ លោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលបិទបាំង ពុំនោះសោត ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា បុគ្គលទាំងឡាយ មានភ្នែកភ្លឺ នឹងមើលឃើញនូវរូបទាំងឡាយបាន មានឧបមាយ៉ាងណា ។ លោកម្ចាស់ឧទាយិ បានប្រកាសធម៌ដោយអនេកបរិយាយ ក៏មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះឧទាយិដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះមានព្រះភាគនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមលោកម្ចាស់ឧទាយិចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសិកាអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។ ចប់សូត្រ ទី ១០ ។

ចប់ គហបតិវគ្គ ទី ៣

# តស្សុទ្ទានំ

វេសាលី វជ្ជី នាលន្ទា
ភារទ្វាជសោណោ ច ឃោសិតា
ហាលិទ្ទកោ នកុលបិតា
លោហិច្ចោ វេរហញ្ចានីតិ ។

---

# ឧទ្ទាននៃគហបតិវគ្គនោះ គឺ

*និយាយអំពីឧគ្គគហបតីនៅក្រុងវេសាលី ១ អំពីឧគ្គគហបតីអ្នកហត្ថិគ្រាមក្នុងដែនវជ្ជី ១ អំពីព្រះមានព្រះភាគគង់នៅក្នុងក្រុងនាឡន្ទា ១ អំពីព្រះបិណ្ឌោលភារទ្វាជត្ថេរ ១ អំពីសោណគហបតិបុត្ត ១ អំពីឃោសិតគហបតី ១ អំពីហាលិទ្ទកានិគហបតី ១ អំពីនកុលបិតាគហបតី ១ អំពីលោហិច្ចព្រាហ្មណ៍ ១ អំពីវេរហញ្ចានិគោត្តាព្រាហ្មណី ១ ។*

# ទេវទហវគ្គោ

[២១១] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ ទេវទហន្នាម សក្យានំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ នាហំ ភិក្ខវេ សព្វេសញ្ញេវ ភិក្ខូនំ ឆសុ ផស្សាយតនេសុ អប្បមាទេន ករណីយន្តិ វទាមិ ។ ន ច បនាហំ ភិក្ខវេ សព្វេសញ្ញេវ ភិក្ខូនំ ឆសុ ផស្សាយតនេសុ នាប្បមាទេន ករណីយន្តិ វទាមិ ។ យេ តេ ភិក្ខវេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេសាហំ ភិក្ខវេ ភិក្ខូនំ ឆសុ ផស្សាយតនេសុ នាប្បមាទេន ករណីយន្តិ វទាមិ ។ តំ កិស្ស ហេតុ ។ កតន្តេ-

# ទេវទហវគ្គ

[២១១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគមរបស់ពួកសក្យៈឈ្មោះទេវទហៈ ក្នុងសក្យជនបទ ។ ក្នុងទីនោះព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលថា ភិក្ខុគ្រប់ ៗ រូប ត្រូវបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈទាំង ៦ ដោយសេចក្តីមិនប្រមាទដូច្នេះទេ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត តថាគតមិនពោលថា ភិក្ខុគ្រប់ៗ រូប មិនត្រូវបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈ ទាំង ៦ ដោយសេចក្តីមិនប្រមាទដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈនៅរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ ជាអ្នកផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុទាំងនោះឯង មិនត្រូវបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈទាំង ៦ ដោយសេចក្តីមិនប្រមាទ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ (ព្រោះ) ភិក្ខុទាំងនោះ បានធ្វើកិច្ច

សំ អប្បមាទេន អភព្វា តេ បមជ្ជិតុំ ។ យេ ច ខោ តេ ភិក្ខវេ ភិក្ខូ សេខា(១) អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វ វិហរន្តិ ។ តេសាហំ ភិក្ខវេ ភិក្ខូនំ ឆសុ ផស្សាយតនេសុ អប្បមាទេន ការណីយន្តិ វទាមិ ។ តំ កិស្ស ហេតុ ។ សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា មនោរមាបិ អមនោរមាបិ ត្យាស្ស ផុស្ស ផុស្ស ចិត្តំ ន បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា(២) បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ ។ ឥមំ ខ្វាហំ ភិក្ខវេ អប្បមាទផលំ សម្បស្សមានោ តេសំ ភិក្ខូនំ ឆសុ ផស្សាយតនេសុ អប្បមាទេន ការណីយន្តិ វទាមិ ។ បេ ។ សន្តិ ភិក្ខវេ

១ សេក្ខាតិ វា បាឋោ ។ ២ ឱ. ម. អសំមុដ្ឋា ។

រូបហើយ ដោយសេចក្តីមិនប្រមាទ ភិក្ខុទាំងនោះ មិនគួរប្រមាទទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាសេក្ខបុគ្គល មិនទាន់បានសម្រេចអរហត្តផលនៅឡើយ ក៏ប្រាថ្នានូវព្រះនិព្វាន ជាធម្មជាតក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលថា ភិក្ខុទាំងនោះ ត្រូវបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈទាំង ៦ ដោយសេចក្តីមិនប្រមាទ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ រូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយភ្នែក ជាទីពេញចិត្តក្តី មិនជាទីពេញចិត្តក្តី រមែងមាន រូបទាំងនោះពាល់ត្រូវរឿយ ៗ តែមិនគ្របសង្កត់ចិត្តរបស់ភិក្ខុនោះបានឡើយ ព្រោះតែគ្របសង្កត់ចិត្តមិនបាន ទើបភិក្ខុនោះ ប្រារព្ធសេចក្តីព្យាយាមមិនរួញរា តម្កល់ស្មារតី មិនភ្លេចខ្លួន កាយក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏តាំងនៅខ្ជាប់ខ្ជួន មានអារម្មណ៍មូលតែមួយ ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) តថាគតសំឡឹងឃើញផលនៃសេចក្តីមិនប្រមាទនេះឯង ទើបពោលថា ភិក្ខុទាំងនោះ គួរបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈទាំង ៦ ដោយសេចក្តីមិនប្រមាទ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ជិវ្ហាវិញ្ញេយ្យា រសា មនោរមាបិ អមនោរមាបិ ត្យាស្ស ផុស្ស ផុស្ស ចិត្តំ ន បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិ-តំ ចិត្តំ ឯកគ្គំ ។ ឥមំ ខ្វាហំ ភិក្ខវេ អប្បមាទផលំ សម្បស្សមានោ តេសំ ភិក្ខូនំ ឆសុ ផស្សាយតនេសុ អប្បមាទេន ករណីយន្តិ វទាមីតិ ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា មនោរមាបិ អមនោរមាបិ ត្យាស្ស ផុស្ស ផុស្ស ចិត្តំ ន បរិយាទាយ តិដ្ឋន្តិ ចេតសោ អបរិយាទានា អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមា-ហិតំ ចិត្តំ ឯកគ្គំ ។ ឥមំ ខ្វាហំ ភិក្ខវេ អប្បមាទផលំ សម្បស្សមានោ តេសំ ភិក្ខូនំ ឆសុ ផស្សាយតនេសុ អប្បមាទេន ករណីយន្តិ វទាមីតិ ។ បឋមំ ។

រសទាំងឡាយដែលគប្បីដឹងច្បាស់ដោយអណ្ដាត ជាទីពេញចិត្តក្ដី មិនជាទីពេញចិត្តក្ដី រមែងមាន រសទាំងនោះពាល់ត្រូវរឿយ ៗ តែមិនគ្របសង្កត់ចិត្តរបស់ភិក្ខុនោះបានឡើយ ព្រោះតែគ្របសង្កត់ចិត្តមិនបាន ទើបភិក្ខុនោះ ប្រារព្ធសេចក្ដីព្យាយាមមិនរួញរា តម្កល់ស្មារតី មិនភ្លេចខ្លួន កាយក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏តាំងនៅខ្ជាប់ខ្ជួន មានអារម្មណ៍មូលតែមួយ ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) តថាគតសំឡឹងឃើញផលនៃសេចក្ដីមិនប្រមាទនេះឯង ទើបពោលថា ភិក្ខុទាំងនោះ គួរបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈទាំង ៦ ដោយសេចក្ដីមិនប្រមាទ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងច្បាស់ដោយចិត្ត ជាទីពេញចិត្តក្ដី មិនជាទីពេញចិត្តក្ដី រមែងមាន ធម្មារម្មណ៍ទាំងនោះពាល់ត្រូវរឿយ ៗ តែមិនគ្របសង្កត់ចិត្តរបស់ភិក្ខុនោះបានឡើយ ព្រោះតែគ្របសង្កត់ចិត្តមិនបាន ទើបភិក្ខុនោះ ប្រារព្ធសេចក្ដីព្យាយាមមិនរួញរា តម្កល់ស្មារតី មិនភ្លេចខ្លួន កាយក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏តាំងនៅខ្ជាប់ខ្ជួន មានអារម្មណ៍មូលតែមួយ ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) តថាគតសំឡឹងឃើញផលនៃសេចក្ដីមិនប្រមាទនេះឯង ទើបពោលថា ភិក្ខុទាំងនោះ គួរបំពេញកិច្ចក្នុងអាយតនៈគឺផស្សៈ ទាំង ៦ ដោយសេចក្ដីមិនប្រមាទ ។ ចប់សូត្រ ទី ១ ។

[២១២] លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ ភិក្ខវេ បដិលទ្ធោ ព្រហ្មចរិយវាសាយ ។ ទិដ្ឋា មយា ភិក្ខវេ ឆ ផស្សាយតនិកា នាម និរយា តត្ថ យំ កិញ្ចិ ចក្ខុ រូបំ បស្សតិ អនិដ្ឋរូបញ្ញេវ បស្សតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ បស្សតិ នោ កន្តរូបំ អមនាបរូបញ្ញេវ បស្សតិ នោ មនាបរូបំ យំ កិញ្ចិ សោតេន សទ្ទំ សុណាតិ ។ យំ កិញ្ចិ ឃានេន គន្ធំ ឃាយតិ ។ យំ កិញ្ចិ ជិវ្ហាយ រសំ សាយតិ ។ យំ កិញ្ចិ កាយេន ផោដ្ឋព្វំ ផុសតិ ។ យំ កិញ្ចិ មនសា ធម្មំ វិជានាតិ អនិដ្ឋរូបញ្ញេវ វិជានាតិ នោ ឥដ្ឋរូបំ អកន្តរូបំយេវ វិជានាតិ នោ កន្តរូបំ អមនាបរូបញ្ញេវ វិជានាតិ នោ មនាបរូបំ ។

[២១២] ម្នាលភិក្ខុទាំងឡាយ ជាលាភរបស់អ្នកទាំងឡាយហើយ ម្នាលភិក្ខុទាំងឡាយ អត្តភាពជាមនុស្ស ឈ្មោះថាអ្នកទាំងឡាយបាន ល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏ឈ្មោះថាអ្នកទាំងឡាយបានហើយ ។ ម្នាលភិក្ខុទាំងឡាយ នរក ឈ្មោះផស្សាយតនិកៈទាំង ៦ តថាគតបានឃើញហើយ បុគ្គលឃើញ រូបណាមួយក្នុងនរកនោះ ដោយភ្នែក រមែងឃើញតែរូបដែលមិនជាទី ប្រាថ្នា មិនឃើញរូបដែលជាទីប្រាថ្នា ឃើញតែរូបដែលមិនជាទីត្រេក អរ មិនឃើញរូបដែលជាទីត្រេកអរ ឃើញតែរូបដែលមិនជាទីគាប់ចិត្ត មិនឃើញរូបដែលជាទីគាប់ចិត្តឡើយ ឮសំឡេងណាមួយ ដោយត្រ-ចៀក ។ ធុំក្លិនណាមួយដោយច្រមុះ ។ ជញ្ជាប់រសណាមួយដោយ អណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈណាមួយដោយកាយ ។ ដឹងច្បាស់នូវ ធម្មារម្មណ៍ណាមួយដោយចិត្ត រមែងដឹងធម្មារម្មណ៍ដែលមានសភាពមិន ជាទីប្រាថ្នា មិនដឹងនូវធម្មារម្មណ៍ដែលមានសភាពជាទីប្រាថ្នា ដឹងតែ ធម្មារម្មណ៍ដែលមានសភាពមិនជាទីត្រេកអរ មិនដឹងនូវធម្មារម្មណ៍ដែល មានសភាពជាទីត្រេកអរ ដឹងតែធម្មារម្មណ៍ដែលមានសភាពមិនជាទីគាប់ ចិត្ត មិនដឹងនូវធម្មារម្មណ៍ដែលមានសភាពជាទីគាប់ចិត្តឡើយ ។

ទេវទហវគ្គោ ចតុត្ថោ

[២១៣] លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ ភិក្ខវេ បដិលទ្ធោ ព្រហ្មចរិយវាសាយ ។ ទិដ្ឋា មយា ភិក្ខវេ ឆ ផស្សាយតនិកា នាម សគ្គា តត្ថ យំ កិញ្ចិ ចក្ខុនា រូបំ បស្សតិ ឥដ្ឋរូបំយេវ បស្សតិ នោ អនិដ្ឋរូបំ កន្តរូបំយេវ បស្សតិ នោ អកន្តរូបំ មនាបរូបំយេវ បស្សតិ នោ អមនាបរូបំ ។ បេ ។ យំ កិញ្ចិ ជិវ្ហាយ រសំ សាយតិ ។ បេ ។ យំ កិញ្ចិ មនសា ធម្មំ វិជានាតិ ឥដ្ឋរូបំយេវ វិជានាតិ

ទេវទហវគ្គ ទី ៤

[២១៣] ម្នាលភិក្ខុទាំងឡាយ ជាលាភរបស់អ្នកទាំងឡាយហើយ ម្នាលភិក្ខុទាំងឡាយ អត្តភាពជាមនុស្ស ឈ្មោះថាអ្នកទាំង-ឡាយបានដោយល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ឈ្មោះថាអ្នកទាំងឡាយបានហើយ ។ ម្នាលភិក្ខុទាំង-ឡាយ ឋានសួគ៌ឈ្មោះផស្សាយតនិកៈទាំង ៦ តថាគតបានឃើញហើយ បុគ្គលឃើញរូបណាមួយក្នុងឋានសួគ៌នោះ ដោយភ្នែក រមែងឃើញតែរូបដែលជាទីប្រាថ្នា មិនឃើញនូវរូបដែលមិនជាទីប្រាថ្នា ឃើញតែរូបដែលជាទីត្រេកអរ មិនឃើញនូវរូបដែលមិនជាទីត្រេកអរ ឃើញតែរូបដែលជាទីគាប់ចិត្ត មិនឃើញនូវរូបដែលមិនជាទីគាប់ចិត្តឡើយ ។ បេ ។ ជញ្ជាប់រសណាមួយដោយអណ្តាត ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ណាមួយដោយចិត្ត រមែងដឹងតែធម្មារម្មណ៍ដែលមានសភាពជាទីប្រាថ្នា

ជោ អនិដ្ឋរូបំ កន្តរូបំយេវ វិជាជាតិ ជោ អកន្តរូបំ មនាបរូបញ្ញេវ វិជាជាតិ ជោ អមនាបរូបំ ។ លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ ភិក្ខវេ បដិលទ្ធោ ព្រហ្មចរិយវាសាយាតិ ។ ទុតិយំ ។

[២១៤] រូបារាមា ភិក្ខវេ ទេវមនុស្សា រូបរតា រូបសម្មុទិតា រូបវិបរិណាមវិរាគនិរោធា ទុក្ខា ភិក្ខវេ ទេវមនុស្សា វិហរន្តិ ។ សទ្ទារាមា ភិក្ខវេ ទេវមនុស្សា សទ្ទរតា សទ្ទសម្មុទិតា សទ្ទវិបរិណាមវិរាគនិរោធា ទុក្ខា ភិក្ខវេ ទេវមនុស្សា វិហរន្តិ ។ គន្ធារាមា រសា-រាមា ផោដ្ឋព្វារាមា ធម្មារាមា ភិក្ខវេ ទេវមនុស្សា

មិនដឹងនូវធម្មារម្មណ៍ដែលមានសភាពមិនជាទីប្រាថ្នា ដឹងតែធម្មារម្មណ៍ដែលមានសភាពជាទីត្រេកអរ មិនដឹងនូវធម្មារម្មណ៍ដែលមានសភាពមិនជាទីត្រេកអរ ដឹងតែធម្មារម្មណ៍ដែលមានសភាពជាទីគាប់ចិត្ត មិនដឹងនូវធម្មារម្មណ៍ដែលមានសភាពមិនជាទីគាប់ចិត្តឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ ជាលាភរបស់អ្នកទាំងឡាយហើយ ម្នាលភិក្ខុទាំងឡាយ អត្ត-ភាពជាមនុស្ស ឈ្មោះថាអ្នកទាំងឡាយបានល្អហើយ ម្នាលភិក្ខុទាំង-ឡាយ ខណៈនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ឈ្មោះថាអ្នកទាំងឡាយបានហើយ ។ ចប់សូត្រ ទី ២ ។

[២១៤] ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយមានសេចក្តីរីករាយនឹងរូប ត្រេកអរនឹងរូប ពេញចិត្តនឹងរូប ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ តែងកើតទុក្ខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃរូប ។ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ មានសេចក្តីរីករាយនឹងសំឡេង ត្រេកអរនឹងសំឡេង ពេញចិត្តនឹងសំឡេង ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ តែងកើតទុក្ខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃសំឡេង ។ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ មានសេចក្តីរីករាយនឹងក្លិន រីករាយនឹងរស រីករាយនឹងផោដ្ឋព្វៈ រីករាយនឹងធម្មារម្មណ៍

ទេវទហវគ្គោ ចតុត្ថោ

ធម្មរតា ធម្មសម្មុទិតា ធម្មវិបរិណាមវិរាគនិរោធា ទុក្ខា
ភិក្ខវេ ទេវមនុស្សា វិហរន្តិ ។ តថាគតោ ច ខោ ភិក្ខវេ
អរហំ សម្មាសម្ពុទ្ធោ រូបានំ សមុទយញ្ច អត្ថង្គមញ្ច
អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា
ន រូបារាមោ ន រូបរតោ ន រូបសម្មុទិតោ រូបវិបរិណា-
មវិរាគនិរោធា សុខោ ភិក្ខវេ តថាគតោ វិហរតិ ។
សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានំ ធម្មានំ សមុទយញ្ច
អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថា-
ភូតំ វិទិត្វា ន ធម្មារាមោ ន ធម្មរតោ ន ធម្មសម្មុទិតោ
ធម្មវិបរិណាមវិរាគនិរោធា សុខោ ភិក្ខវេ តថាគតោ
វិហរតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ
អថាបរំ ឯតទវោច សត្ថា

ត្រេកអរនឹងធម្មារម្មណ៍ ពេញចិត្តនឹងធម្មារម្មណ៍ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ តែងកើតទុក្ខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃធម្មារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ បានដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង ហេតុជាទីរលត់ទៅផង អានិសង្សផង ទោសផង ឧបាយជាគ្រឿងរលាស់ចេញផង នៃរូបទាំងឡាយ ទើបជាអ្នកមិនរីករាយនឹងរូប មិនត្រេកអរនឹងរូប មិនពេញចិត្តនឹងរូប ម្នាលភិក្ខុទាំងឡាយ តថាគតរមែងមានសេចក្តីសុខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃរូប ។ ព្រះតថាគតបានដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង ហេតុជាទីរលត់ផង អានិសង្សផង ទោសផង ឧបាយជាគ្រឿងរលាស់ចេញផង នៃសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ទើបមិនមានសេចក្តីរីករាយនឹងធម្មារម្មណ៍ មិនត្រេកអរនឹងធម្មារម្មណ៍ មិនពេញចិត្តនឹងធម្មារម្មណ៍ ម្នាលភិក្ខុទាំងឡាយ តថាគតរមែងមានសេចក្តីសុខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃធម្មារម្មណ៍ ។ ព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ លុះព្រះសុគតជាសាស្តាត្រាស់ព្រះសូត្រនេះហើយ ទើបទ្រង់សម្តែងនូវគាថាពន្ធដទៃទៀត ដូច្នេះថា

[២១៥] រូបា សទ្ទា គន្ធា រសា
ផស្សា ធម្មា ច កេវលា
ឥដ្ឋា កន្តា មនាបា ច
យាវតត្ថីតិ វុច្ចតិ ។
សទេវកស្ស លោកស្ស
ឯតេ វោ សុខសម្មតា
យត្ថ ចេ តេ និរុជ្ឈន្តិ
តំ តេសំ ទុក្ខសម្មតំ ។
សុខំ ច ទិដ្ឋមរិយេភិ
សក្កាយស្ស និរោធនំ
បច្ចនិកមិទំ ហោតិ
សព្វលោកេន បស្សតំ ។
យំ បរេ សុខតោ អាហុ
តទរិយា អាហុ ទុក្ខតោ
យំ បរេ ទុក្ខតោ អាហុ
តទរិយា សុខតោ វិទូ ។
បស្ស ធម្មំ ទុវិជានំ

[២១៥] រូប សំឡេង ក្លិន រស ផស្សៈ ធម្មារម្មណ៍ ទាំងអស់ តថាគតពោលថាជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ។ អារម្មណ៍ទាំងនុ៎ះឯង មនុស្សលោកព្រមទាំងទេវលោកសន្មតថាជាសុខ ប្រសិនបើអារម្មណ៍ទាំងនុ៎ះរលត់ទៅក្នុងទីណា ទីនោះ ពួកមនុស្សលោកព្រមទាំងទេវលោកសន្មតថាជាទុក្ខ ។ ក៏ឯសេចក្តីរលត់នូវសក្កាយទិដ្ឋិ ព្រះអរិយៈទាំងឡាយបានឃើញច្បាស់ថាជាសុខ សេចក្តីសុខនេះតែងមានដល់បណ្ឌិតទាំងឡាយដែលឃើញច្បាស់ (ដោយប្រាជ្ញា) ប៉ុន្តែជាសត្រូវនឹងលោកទាំងមូល ។ ជនទាំងឡាយដទៃពោលនូវអារម្មណ៍ណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវអារម្មណ៍នោះថាជាទុក្ខវិញ ជនទាំងឡាយដទៃពោលនូវអារម្មណ៍ណាថាជាទុក្ខ ព្រះអរិយៈទាំងឡាយអ្នកដឹងច្បាស់ (ពោល) នូវអារម្មណ៍នោះថាជាសុខវិញ។ អ្នកចូរមើលនូវនិព្វានធម៌ ដែលបុគ្គលដឹងបានដោយកម្រ

២៩៣

ទេវទហវគ្គោ ចតុត្ថោ

សម្មូឡ្ហេត្ថ អវិទ្ទសុ
និវុតានំ តមោ ហោតិ
អន្ធការោ អបស្សតំ ។
សតញ្ច វិវដំ ហោតិ
អាលោកោ បស្សតាមិវ
សន្តិកេ ន វិជានន្តិ
មគា ធម្មស្ស អកោវិទា ។
ភវរាគបរេតេហិ
ភវសោតានុសារិភិ[១]
មារធេយ្យានុបន្នេហិ
នាយំ ធម្មោ សុសម្ពុទ្ធោ ។
កោ នុ អញ្ញត្រមរិយេហិ
បទំ សម្ពុទ្ធមរហតិ
យំ បទំ សម្មទញ្ញាយ
បរិនិព្វន្តិ អនាសវាតិ ។ តតិយំ ។

១ ម. ភវរាគានុសារីភិ ។

## ទេវទហវគ្គ ទី ៤

ឯពួកមនុស្សល្ងង់ខ្លៅតែងវង្វេងក្នុងនិញ្វានធម៌នោះឯង សេចក្ដីងងឹត គឺមានអាការដូចជាមនុស្សខ្វាក់ រមែងមានដល់ជនទាំងឡាយដែលត្រូវកិលេសរួបរឹតហើយ មិនឃើញនូវព្រះនិញ្វាន ។ មួយទៀត ព្រះនិញ្វាន ជាទីបើកចំហទទួលពួកសប្បុរស (ដែលឃើញច្បាស់ដោយប្រាជ្ញាញាណ) ប្រៀបដូចជាពន្លឺ ជនទាំងឡាយ ដែលមិនប៉ិនប្រសប់នូវផ្លូវនិងមិនមែនផ្លូវ រមែងមិនដឹងច្បាស់នូវព្រះនិញ្វាន ដែលមាននៅក្នុងទីជិត ។ ធម៌នេះហើយ ដែលជនទាំងឡាយត្រូវភវរាគៈគ្របសង្កត់ មានប្រក្រតីអន្ទោលទៅតាមក្រសែនៃភព ចូលទៅកាន់លំនៅ របស់មាររឿយៗ មិនបានត្រាស់ដឹងដោយប្រពៃឡើយ ។ ព្រះអរិយៈទាំងឡាយដែលមិនមានអាសវៈបានត្រាស់ដឹងដោយប្រពៃនូវព្រះនិញ្វានណា ហើយបរិនិញ្វាននរណាហ្ន៎ លើកលែងតែព្រះអរិយៈទាំងឡាយចេញ គួរត្រាស់ដឹងនូវព្រះនិញ្វាននោះបាន ។ ចប់សូត្រ ទី ៣ ។

[២១៦] រូបារាមា ភិក្ខវេ ទេវមនុស្សា រូបរតា រូប-
សម្មុទិតា រូបវិបរិណាមវិរាគនិរោធា ទុក្ខា ភិក្ខវេ ទេវ-
មនុស្សា វិហរន្តិ ។ សទ្ទារាមា គន្ធារាមា រសារាមា
ផោដ្ឋព្វារាមា ធម្មារាមា ភិក្ខវេ ទេវមនុស្សា ធម្មរតា
ធម្មសម្មុទិតា ធម្មវិបរិណាមវិរាគនិរោធា ទុក្ខា ភិក្ខវេ
ទេវមនុស្សា វិហរន្តិ ។ តថាគតោ ច ខោ ភិក្ខវេ
អរហំ សម្មាសម្ពុទ្ធោ រូបានំ សមុទយញ្ច អត្ថង្គមញ្ច
អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា
ន រូបារាមោ ន រូបរតោ ន រូបសម្មុទិតោ រូបវិបរិណា-
មវិរាគនិរោធា សុខោ ភិក្ខវេ តថាគតោ វិហរតិ ។
សទ្ទានំ គន្ធានំ រសានំ ផោដ្ឋព្វានំ ធម្មានំ សមុទយញ្ច
អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថា-
ភូតំ វិទិត្វា ន ធម្មារាមោ ន ធម្មរតោ ន ធម្មសម្មុ-

[២១៦] ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ ជាអ្នករីករាយនឹងរូប ត្រេកអរនឹងរូប ពេញចិត្តនឹងរូប ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ រមែងមានទុក្ខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃរូប ។ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយ ជាអ្នករីករាយនឹងសំឡេង រីករាយនឹងក្លិន រីករាយនឹងរស រីករាយនឹងផោដ្ឋព្វៈ រីករាយនឹងធម្មារម្មណ៍ ត្រេកអរនឹងធម្មារម្មណ៍ ពេញចិត្តនឹងធម្មារម្មណ៍ ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្សទាំងឡាយរមែងមានទុក្ខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃធម្មារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ ឯតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង ហេតុជាទីរលត់ផង អានិសង្សផង ទោសផង ឧបាយជាគ្រឿងរលាស់ចេញផង នៃរូបទាំងឡាយ ទើបមិនរីករាយនឹងរូប មិនត្រេកអរនឹងរូប មិនពេញចិត្តនឹងរូប ម្នាលភិក្ខុទាំងឡាយ តថាគតរមែងមានតែសេចក្តីសុខ ព្រោះការប្រែប្រួល ប្រាស រលត់ នៃរូប ។ តថាគតដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង ហេតុជាទីរលត់ផង អានិសង្សផង ទោសផង ឧបាយជាគ្រឿងរលាស់ចេញផង នៃសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ទើបមិនរីករាយនឹងធម្មារម្មណ៍ មិនត្រេកអរនឹងធម្មារម្មណ៍ មិនពេញចិត្តនឹងធម្មារម្មណ៍

ទិតោ ធម្មវិបរិណាមវិរាគនិរោធា សុខោ ភិក្ខវេ តថា-
គតោ វិហរតីតិ ។ ចតុត្ថំ ។

[២១៧] យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ ចក្ខុំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ ជិវ្ហា ន តុម្ហាកំ តំ បជហថ សា វោ បហីនា ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ មនោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ ហិតាយ សុខាយ ភវិស្សតិ ។ សេយ្យថាបិ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ តំ ជនោ ហរេយ្យ វា

ម្នាលភិក្ខុទាំងឡាយ តថាគតមានតែសេចក្ដីសុខ ព្រោះការប្រែប្រួលប្រាស រលត់ នៃធម្មារម្មណ៍ ។ ចប់សូត្រ ទី ២ ។

[២១៧] ម្នាលភិក្ខុទាំងឡាយ របស់ណាដែលមិនមែនជារបស់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់របស់នោះចេញ របស់នោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់អ្វី ដែលមិនមែនជារបស់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភ្នែកមិនមែនជារបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ភ្នែកនោះចេញ ភ្នែកនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ បេ ។ អណ្ដាតមិនមែនជារបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់អណ្ដាតនោះចេញ អណ្ដាតនោះ ដែលអ្នកទាំង-ឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ បេ ។ ចិត្តមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់ចិត្តនោះចេញ ចិត្តនោះបើអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រ-ព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្មៅ ឧស មែក ស្លឹក ណា ក្នុងវត្តជេតពននេះ ជននាំយកទៅក្ដី

ឌហេយ្យ វា យថាបច្ចយំ វា ករេយ្យ អបិ នុ តុម្ហាកំ ឯវមស្ស អម្ហេ ជនោ ហរតិ វា ឌហតិ វា យថាបច្ចយំ វា ករោតីតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ ន ហិ នោ ឯតំ ភន្តេ អត្តា វា អត្តនិយំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ ចក្ខុំ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ បេ ។ ជិវ្ហា ន តុម្ហាកំ តំ បជហថ សា វោ បហីនា ហិតាយ សុ-ខាយ ភវិស្សតិ ។ បេ ។ មនោ ន តុម្ហាកំ តំ បជហថ សោ វោ បហីនោ ហិតាយ សុខាយ ភវិស្សតីតិ ។

បញ្ចមំ ។

ដុតក្តី ប្រើប្រាស់នូវស្មៅជាដើមនោះតាមត្រូវការក្តី តើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ជននាំយកទៅក្តី ដុតក្តី ប្រើប្រាស់តាមត្រូវការក្តី នូវយើងទាំងឡាយ ដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ដំ-ណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា វត្ថុនុ៎ះមិនមែនជាខ្លួន ឬជាទ្រព្យរបស់ខ្លួន នៃយើងខ្ញុំព្រះអង្គទេ ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីនេះមានឧបមេយ្យ ដូចភ្នែកមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់ភ្នែកនោះចេញ ភ្នែកនោះដែលអ្នកទាំង-ឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ ។ បេ ។ អណ្តាតមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់អណ្តាតនោះចេញ អណ្តាតនោះ ដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ ។ បេ ។ ចិត្តមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់ចិត្តនោះចេញ ចិត្តនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្តីសុខ ។ ចប់សូត្រ ទី ៥ ។

ទេវទហវគ្គោ ចតុត្ថោ

[២១៨] យំ ភិក្ខវេ ន តុម្ហាកំ តំ បជហថ តំ វោ បហីនំ ហិតាយ សុខាយ ភវិស្សតិ ។ កិញ្ច ភិក្ខវេ ន តុម្ហាកំ ។ រូបា ភិក្ខវេ ន តុម្ហាកំ តេ បជហថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ន តុម្ហាកំ តេ បជហថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។ សេយ្យថាបិ ភិក្ខវេ យំ ឥមស្មឹ ជេតវនេ តិណកដ្ឋសាខាបលាសំ ។ បេ ។ ឯវមេវ ខោ ភិក្ខវេ រូបា ន តុម្ហាកំ តេ បជ-ហថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តិ ។

### ទេវទហវគ្គ ទី ៤

[២១៨] ម្នាលភិក្ខុទាំងឡាយ របស់ណាដែលមិនមែនជារបស់អ្នកទាំងឡាយ អ្នកទាំងឡាយចូរលះបង់របស់នោះចេញ របស់នោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ ចុះរបស់អ្វីដែលមិនមែនជារបស់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់រូបទាំងនោះចេញ រូបទាំងនោះ ដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់របស់នោះចេញ របស់ទាំងនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្មៅ ឧស មែក ស្លឹក ណា ក្នុងវត្តជេតពននេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមានឧបមេយ្យដូច រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់រូបទាំងនោះចេញ រូបទាំងនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្ដីសុខ ។

សត្វា គន្ធា រសា ផោដ្ឋព្វា ធម្មា ច តស្មាកំ តេ បជហាថ តេ វោ បហីនា ហិតាយ សុខាយ ភវិស្សន្តីតិ ។ ឆដ្ឋំ ។

[២១៩] ចក្ខុំ ភិក្ខវេ អនិច្ចំ យោបិ ហេតុ យោបិ បច្ចយោ ចក្ខុស្ស ឧប្បាទាយ សោបិ អនិច្ចោ អនិច្ចសម្ភូតំ ភិក្ខវេ ចក្ខុំ កុតោ និច្ចំ ភវិស្សតិ ។ បេ ។ ជិវ្ហា អនិច្ចា យោបិ ហេតុ យោបិ បច្ចយោ ជិវ្ហាយ ឧប្បាទាយ សោបិ អនិច្ចោ អនិច្ចសម្ភូតា ភិក្ខវេ ជិវ្ហា កុតោ និច្ចា ភវិស្សតិ ។ បេ ។ មនោ អនិច្ចោ យោបិ ភិក្ខវេ ហេតុ យោបិ បច្ចយោ មនស្ស ឧប្បាទាយ សោបិ អនិច្ចោ អនិច្ចសម្ភូតោ ភិក្ខវេ មនោ

សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ មិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយចូរលះបង់របស់ទាំងនោះចេញ របស់ទាំងនោះដែលអ្នកទាំងឡាយលះបង់ចេញហើយ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ ។ ចប់សូត្រ ទី ៦ ។

[២១៩] ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀងទេ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចក្ខុ ហេតុនិងបច្ច័យនោះឯង ក៏មិនទៀងដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចក្ខុ កើតមកអំពីហេតុនិងបច្ច័យដែលមិនទៀងហើយ ចក្ខុនឹងមានសេចក្តីទៀងទាត់ មកពីណា ។ បេ ។ អណ្តាតមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតអណ្តាត ហេតុនិងបច្ច័យនោះឯង ក៏មិនទៀងដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើអណ្តាត កើតមកអំពីហេតុនិងបច្ច័យដែលមិនទៀងហើយ អណ្តាតនឹងមានសេចក្តីទៀងទាត់ មកពីណា ។ បេ ។ ចិត្តមិនទៀងទេ ម្នាលភិក្ខុទាំងឡាយ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចិត្ត ហេតុនិងបច្ច័យនោះឯង ក៏មិនទៀងដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចិត្តកើតមកអំពីហេតុនិងបច្ច័យដែលមិនទៀងហើយ ចិត្តនឹងមានសេចក្តីទៀង

កុតោ និច្ចោ ភវិស្សតីតិ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខី-ណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ សត្តមំ ។

[២២០] ចក្ខុំ ភិក្ខវេ ទុក្ខំ យោបិ ហេតុ យោបិ បច្ចយោ ចក្ខុស្ស ឧប្បាទាយ សោបិ ទុក្ខោ ទុក្ខសម្ភូតំ ភិក្ខវេ ចក្ខុំ កុតោ សុខំ ភវិស្សតិ ។ បេ ។ ជិវ្ហា ទុក្ខា

ទាត់មកពីណា ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័ក អ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង ។ បេ ។ នឿយណាយនឹងអណ្តាតផង ។ បេ ។ នឿយណាយនឹងចិត្តផង កាលបើនឿយណាយ ចិត្តក៏ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ទើបផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ អរិយសាវ័កនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៧ ។

[២២០] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចក្ខុ ហេតុនិងបច្ច័យនោះឯង ក៏ជាទុក្ខដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចក្ខុ កើតមកអំពីហេតុនិងបច្ច័យដែលជាទុក្ខហើយ ចក្ខុនឹងមានសេចក្តីសុខមកពីណា ។ បេ ។ អណ្តាតជាទុក្ខ ហេតុណាក្តី

យោបិ ហេតុ យោបិ បច្ចយោ ជិវ្ហាយ ឧប្បាទាយ សោបិ ទុក្ខោ ទុក្ខសម្ភូតា ភិក្ខវេ ជិវ្ហា កុតោ សុខា ភវិស្សតិ ។ បេ ។ មនោ ទុក្ខោ យោបិ ហេតុ យោបិ បច្ចយោ មនស្ស ឧប្បាទាយ សោបិ ទុក្ខោ ទុក្ខសម្ភូតោ ភិក្ខវេ មនោ កុតោ សុខោ ភវិស្សតិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២២១] ចក្ខុំ ភិក្ខវេ អនត្តា យោបិ ហេតុ យោបិ បច្ចយោ ចក្ខុស្ស ឧប្បាទាយ សោបិ អនត្តា អនត្តសម្ភូតំ ភិក្ខវេ ចក្ខុំ កុតោ អត្តា ភវិស្សតិ ។ បេ ។ ជិវ្ហា អនត្តា យោបិ ហេតុ យោបិ បច្ចយោ ជិវ្ហាយ ឧប្បាទាយ សោបិ អនត្តា អនត្តសម្ភូតា ភិក្ខវេ ជិវ្ហា កុតោ អត្តា

បច្ច័យណាក្តី ដែលនាំឲ្យកើតអណ្តាត ហេតុនិងបច្ច័យនោះឯង ក៏ជាទុក្ខដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើអណ្តាតកើតមកអំពីហេតុនិងបច្ច័យដែលជាទុក្ខហើយ អណ្តាតនឹងមានសេចក្តីសុខមកពីណា ។ បេ ។ ចិត្តក៏ជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចិត្ត ហេតុនិងបច្ច័យនោះឯង ក៏ជាទុក្ខដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចិត្តកើតមកអំពីហេតុនិងបច្ច័យដែលជាទុក្ខហើយ ចិត្តនឹងមានសេចក្តីសុខមកពីណា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២២១] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចក្ខុ ហេតុនិងបច្ច័យនោះឯង ក៏ជាអនត្តាដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចក្ខុកើតមកអំពីហេតុនិងបច្ច័យដែលជាអនត្តាហើយ ចក្ខុនឹងទៅជាអត្តាម្តេចកើត ។ បេ ។ អណ្តាតជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតអណ្តាត ហេតុនិងបច្ច័យនោះឯង ក៏ជាអនត្តាដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើអណ្តាតកើតមកអំពីហេតុនិងបច្ច័យដែលជាអនត្តាហើយ អណ្តាតនឹងទៅជាអត្តាម្តេចកើត

ភវិស្សតិ ។ បេ ។ មនោ អនត្តា យោបិ ហេតុ យោបិ បច្ចយោ មនស្ស ឧប្បាទាយ សោបិ អនត្តា អនត្តសម្ភូតោ ភិក្ខវេ មនោ កុតោ អត្តា ភវិស្សតិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ អដ្ឋមំ ។

[២២២] រូបា ភិក្ខវេ អនិច្ចា យោបិ ហេតុ យោបិ បច្ចយោ រូបានំ ឧប្បាទាយ ។ បេ ។ សោបិ អនិច្ចោ អនិច្ចសម្ភូតា ភិក្ខវេ រូបា កុតោ និច្ចា ភវិស្សន្តិ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា យោបិ ហេតុ យោបិ បច្ចយោ ធម្មានំ ឧប្បាទាយ សោបិ អនិច្ចោ អនិច្ចសម្ភូតា ភិក្ខវេ ធម្មា កុតោ និច្ចា ភវិស្សន្តិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

។ បេ ។ ចិត្តជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតចិត្ត ហេតុនិងបច្ច័យនោះឯង ក៏ជាអនត្តាដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើចិត្តកើតមកអំពីហេតុនិងបច្ច័យដែលជាអនត្តាហើយ ចិត្តនឹងទៅជាអត្តាម្តេចកើត ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រទី ៨ ។

[២២២] ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតរូប ។ បេ ។ ហេតុនិងបច្ច័យនោះឯង ក៏មិនទៀងដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើរូបកើតមកអំពីហេតុនិងបច្ច័យដែលមិនទៀងហើយ រូបនឹងមានសេចក្តីទៀងទាត់ មកពីណា ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ មិនទៀង ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតធម្មារម្មណ៍ ហេតុនិងបច្ច័យនោះឯង ក៏មិនទៀងដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើធម្មារម្មណ៍កើតមកអំពីហេតុនិងបច្ច័យដែលមិនទៀងហើយ ធម្មារម្មណ៍នឹងមានសេចក្តីទៀងទាត់ មកពីណា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២២៣] រូបា ភិក្ខវេ ទុក្ខា យោបិ ហេតុ យោបិ បច្ចយោ រូបានំ ឧប្បាទាយ សោបិ ទុក្ខោ ទុក្ខសម្ភូតា ភិក្ខវេ រូបា កុតោ សុខា ភវិស្សន្តិ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា យោបិ ហេតុ យោបិ បច្ចយោ ធម្មានំ ឧប្បាទាយ សោបិ ទុក្ខោ ទុក្ខសម្ភូតា ភិក្ខវេ ធម្មា កុតោ សុខា ភវិស្សន្តិ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ នវមំ ។

[២២៣] ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតរូប ហេតុនិងបច្ច័យនោះឯង ក៏ជាទុក្ខដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើរូបកើតមកអំពីហេតុនិងបច្ច័យដែលជាទុក្ខហើយ រូបនឹងមានសេចក្តីសុខមកពីណា ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ជាទុក្ខ ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតធម្មារម្មណ៍ ហេតុនិងបច្ច័យនោះឯង ក៏ជាទុក្ខដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើធម្មារម្មណ៍ កើតមកអំពីហេតុនិងបច្ច័យដែលជាទុក្ខហើយ ធម្មារម្មណ៍នឹងមានសេចក្តីសុខមកពីណា ។ កាលឃើញយ៉ាងនេះ ។ បេ ។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៩ ។

## ទេវទហវគ្គោ ចតុត្ថោ

[២២៤] រូបា ភិក្ខវេ អនត្តា យោបិ ហេតុ យោបិ បច្ចយោ រូបានំ ឧប្បាទាយ សោបិ អនត្តា អនត្តសម្ភូតា ភិក្ខវេ រូបា កុតោ អត្តា ភវិស្សន្តិ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា យោបិ ហេតុ យោបិ បច្ចយោ ធម្មានំ ឧប្បាទាយ សោបិ អនត្តា អនត្តសម្ភូតា ភិក្ខវេ ធម្មា កុតោ អត្តា ភវិស្សន្តិ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបេសុ និព្វិន្ទតិ សទ្ទេសុ គន្ធេសុ រសេសុ ផោដ្ឋព្វេសុ ធម្មេសុ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទសមំ ។

ទេវទហវគ្គោ ចតុត្ថោ ។

## ទេវទហវគ្គ ទី ៤

[២២៤] ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតរូប ហេតុនិងបច្ច័យនោះឯង ក៏ជាអនត្តាដែរ ម្នាលភិក្ខុទាំងឡាយ ចុះបើរូបកើតមកអំពីហេតុនិងបច្ច័យ ដែលជាអនត្តាហើយ រូបនឹងទៅជាអត្តាម្តេចកើត ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ជាអនត្តា ហេតុណាក្តី បច្ច័យណាក្តី ដែលនាំឲ្យកើតធម្មារម្មណ៍ ហេតុនិងបច្ច័យនោះឯង ក៏ជាអនត្តាដែរ ម្នាលភិក្ខុទាំង-ឡាយ ចុះបើធម្មារម្មណ៍ កើតមកអំពីហេតុនិងបច្ច័យ ដែលជាអនត្តាហើយ ធម្មារម្មណ៍នឹងទៅជាអត្តាម្តេចកើត ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងរូប នឿយណាយនឹងសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ទាំងឡាយ កាលបើនឿយណាយ ចិត្តក៏ប្រាសចាកតម្រេក ព្រោះការប្រាសចាកតម្រេក ទើបផុតស្រឡះ (ចាកអាសវៈ) ។ កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ។ អរិយសាវ័កនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ១០ ។

ចប់ ទេវទហវគ្គ ទី ៤ ។

# តស្សុទ្ទានំ

ទេវទហខណោបគ្គយ្ហ[១]
អគ្គយ្ហ ទ្វេ ហោន្តិ មជសិជា[២]
ហោតុជាបិ តយោ វុត្តា
ទុវេ អជ្ឈត្តពាហិរាតិ ។

---

១ ឱ. ម. សំគយ្ហ ។ ២ បលាសិនា ។

សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ

# ឧទ្ទាននៃទេវទហវគ្គនោះ គឺ

*និយាយ អំពីព្រះមានព្រះភាគគង់ក្នុងទេវទហនិគម ១ អំពីខណៈនៃការប្រព្រឹត្តព្រហ្មចរិយធម៌ ១ អំពីការទទួលត្រេកអរនូវអារម្មណ៍ ១ អំពីការមិនទទួលត្រេកអរនូវអារម្មណ៍ដោយចិត្តមាន ២ លើក អំពីព្រះមានព្រះភាគទ្រង់សម្តែងហេតុនៃការកើតឡើង នៃអារម្មណ៍មានរូបជាដើម ៣ លើក អំពីអាយតនៈខាងក្នុងនិងខាងក្រៅ ២ លើក ។*

---

# នវបុរាណវគ្គោ

[២២៥] នវបុរាណានិ ភិក្ខវេ កម្មានិ ទេសិស្សាមិ កម្មនិរោធញ្ច កម្មនិរោធគាមិនិញ្ច បដិបទំ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ កតមញ្ច ភិក្ខវេ បុរាណកម្មំ ។ ចក្ខុំ ភិក្ខវេ បុរាណកម្មំ អភិសង្ខតំ អភិសញ្ចេតយិតំ វេទនិយំ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា បុរាណកម្មា អភិសង្ខតា អភិសញ្ចេតយិតា វេទនិយា ទដ្ឋព្វា ។ បេ ។ មនោ បុរាណកម្មោ អភិសង្ខតោ អភិសញ្ចេតយិតោ វេទនិយោ ទដ្ឋព្វោ ។ ឥទំ វុច្ចតិ ភិក្ខវេ បុរាណកម្មំ ។

[២២៦] កតមញ្ច ភិក្ខវេ នវកម្មំ ។ យំ ខោ ភិក្ខវេ ឯតរហិ កម្មំ ករោតិ កាយេន វាចាយ មនសា ។ ឥទំ វុច្ចតិ ភិក្ខវេ នវកម្មំ ។

# នវបុរាណវគ្គ

[២២៥] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវកម្មថ្មីផង កម្មចាស់ផង ការរំលត់កម្មផង បដិបទាជាដំណើរទៅកាន់ទីរំលត់កម្មផង ចូរអ្នកទាំងឡាយស្តាប់ធម៌នោះ ចូរអ្នកទាំងឡាយយកចិត្តទុកដាក់ឲ្យប្រពៃ តថាគតនឹងសម្តែងប្រាប់ ។ ម្នាលភិក្ខុទាំងឡាយ កម្មចាស់តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាកម្មចាស់[១] ដែលបច្ច័យតាក់តែង សម្រេចហើយដោយចេតនា បណ្ឌិតគប្បីឃើញថាជាហេតុនៃវេទនា ។ បេ ។ ជិវ្ហាជាកម្មចាស់ ដែលបច្ច័យតាក់តែង សម្រេចហើយដោយចេតនា បណ្ឌិតគប្បីឃើញថាជាហេតុនៃវេទនា ។ បេ ។ មនោជាកម្មចាស់ ដែលបច្ច័យតាក់តែង សម្រេចហើយដោយចេតនា បណ្ឌិតគប្បីឃើញថាជាហេតុនៃវេទនា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាកម្មចាស់ ។

[២២៦] ម្នាលភិក្ខុទាំងឡាយ កម្មថ្មី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំពុងធ្វើអំពើណា ដោយកាយ វាចា ចិត្ត ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មថ្មី ។

---

១ ចក្ខុមិនមែនចាស់ទេ កម្មទើបបានហៅថារបស់ចាស់ ព្រោះចក្ខុកើតមកអំពីកម្ម ។ អដ្ឋកថា ។

[២២៧] កតមោ ច ភិក្ខវេ កម្មនិរោធោ ។ យោ ខោ ភិក្ខវេ កាយកម្មវចីកម្មមនោកម្មស្ស និរោធា វិមុត្តឹ ផុសតិ ។ អយំ វុច្ចតិ ភិក្ខវេ កម្មនិរោធោ ។

[២២៨] កតមា ច ភិក្ខវេ កម្មនិរោធគាមិនី បដិបទា ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ វុច្ចតិ ភិក្ខវេ កម្មនិរោធគាមិនី បដិបទា ។

[២២៩] ឥតិ ខោ ភិក្ខវេ ទេសិតំ វោ មយា បុរាណកម្មំ ទេសិតំ នវកម្មំ ទេសិតោ កម្មនិរោធោ ទេសិតា កម្មនិរោធគាមិនី បដិបទា ។ យំ ខោ ភិក្ខវេ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ ខោ[១] មយា ។ ឯតានិ ភិក្ខវេ រុក្ខមូលានិ

១ ឱ. ម. កតំ វោ មយា ។ ឱ. កតំ វោ តម្មយា ។

[២២៧] ម្នាលភិក្ខុទាំងឡាយ ចុះការរំលត់កម្ម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាប៉ះពាល់នូវវិមុត្តិព្រោះរំលត់កាយកម្ម វចី-កម្ម មនោកម្ម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការរំលត់កម្ម ។

[២២៨] ម្នាលភិក្ខុទាំងឡាយ ចុះបដិបទាជាដំណើរទៅកាន់ទីរំលត់កម្ម តើដូចម្ដេច ។ មគ្គដែលប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរនេះឯង ។ មគ្គប្រកបដោយអង្គ ៨ តើអ្វីខ្លះ ។ គឺសេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្ដីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបដិបទាជាដំណើរទៅកាន់ទីរំលត់កម្ម ។

[២២៩] ម្នាលភិក្ខុទាំងឡាយ កម្មចាស់ តថាគតបានសម្ដែងហើយ កម្មថ្មី តថាគតបានសម្ដែងហើយ ការរំលត់កម្ម តថាគតបានសម្ដែងហើយ បដិបទាជាដំណើរទៅកាន់ទីរំលត់កម្ម តថាគតក៏បានសម្ដែងហើយ ដល់អ្នកទាំងឡាយ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កិច្ចណា ដែលសាស្ដាជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ គប្បីធ្វើដល់សាវ័កទាំងឡាយ កិច្ចនោះ តថាគតបានធ្វើហើយ ព្រោះអាស្រ័យសេចក្ដីអនុគ្រោះ ចំពោះសាវ័កទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កិច្ចដែលតថាគតធ្វើនោះ គឺ រុក្ខមូលទាំងឡាយហ្នឹងឯង

ឯតានិ សុញ្ញាគារានិ ។ ឈាយថ[១] ភិក្ខវេ មា បមា-
ទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ អយំ វោ អម្ហាកំ
អនុសាសនីតិ ។ បឋមំ ។

[២៣០] និព្វានសប្បាយំ វោ ភិក្ខវេ បដិបទំ ទេ-
សិស្សាមិ តំ សុណាថ ។ បេ ។ កាតមា ច សា ភិក្ខវេ
និព្វានសប្បាយា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុំ
អនិច្ចន្តិ បស្សតិ រូបា អនិច្ចាតិ បស្សតិ ចក្ខុវិញ្ញាណំ
អនិច្ចន្តិ បស្សតិ ចក្ខុសម្ផស្សោ អនិច្ចោតិ បស្សតិ
យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ
វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ បស្សតិ
។ បេ ។ ជិវ្ហា អនិច្ចាតិ បស្សតិ រសា អនិច្ចាតិ បស្ស-
តិ ជិវ្ហាវិញ្ញាណំ អនិច្ចន្តិ បស្សតិ ជិវ្ហាសម្ផស្សោ អ-
និច្ចោតិ បស្សតិ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជ-
តិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ
អនិច្ចន្តិ បស្សតិ ។ បេ ។ មនោ អនិច្ចោតិ បស្សតិ ធម្មា

១ ឱ. ម. ឈាយថ ។

សុញ្ញាគារដ្ឋានទាំងឡាយហ្នឹងឯង ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយខំប្រឹងប្រែង កុំប្រមាទ កុំឲ្យមានវិប្បដិសារៈជាខាងក្រោយ នេះឯងហើយ ដែលជាពាក្យប្រៀនប្រដៅ របស់តថាគត ដល់អ្នកទាំងឡាយ ។ ចប់សូត្រ ទី ១ ។

[២៣០] ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្តែងនូវបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ចូរអ្នកទាំងឡាយ ស្តាប់នូវបដិបទានោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាទីសប្បាយដើម្បីព្រះនិព្វាននោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញថាចក្ខុមិនទៀង ឃើញថារូបមិនទៀង ឃើញថាចក្ខុវិញ្ញាណមិនទៀង ឃើញថាចក្ខុសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាមិនទៀង ។ បេ ។ ឃើញថាជិវ្ហាមិនទៀង ឃើញថារសមិនទៀង ឃើញថាជិវ្ហាវិញ្ញាណមិនទៀង ឃើញថាជិវ្ហាសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាមិនទៀង ។ បេ ។ ឃើញថាមនោមិនទៀង ឃើញថាធម្មា-

អនិច្ចាតិ បស្សតិ មនោវិញ្ញាណំ អនិច្ចន្តិ បស្សតិ មនោសម្ផស្សោ អនិច្ចោតិ បស្សតិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ បស្សតិ ។ អយំ ខោ[១] ភិក្ខវេ និព្វានសប្បាយា បដិបទាតិ ។ ទុតិយំ ។

[២៣១] និព្វានសប្បាយំ វោ ភិក្ខវេ បដិបទំ ទេសិស្សាមិ តំ សុណាថ ។ បេ ។ កតមា ច សា ភិក្ខវេ និព្វានសប្បាយា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុំ ទុក្ខន្តិ បស្សតិ រូបា ទុក្ខាតិ បស្សតិ ចក្ខុវិញ្ញាណំ ទុក្ខន្តិ បស្សតិ ចក្ខុសម្ផស្សោ ទុក្ខោតិ បស្សតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខន្តិ បស្សតិ ។ បេ ។ ជិវ្ហា ទុក្ខាតិ បស្សតិ ។ បេ ។ មនោ ទុក្ខោតិ បស្សតិ ធម្មា ទុក្ខាតិ បស្សតិ មនោវិញ្ញាណំ ទុក្ខន្តិ បស្សតិ មនោសម្ផស្សោ ទុក្ខោតិ បស្សតិ

---

១ ឱ. ម. អយំ ខោ សា ។

រម្មណ៍មិនទៀង ឃើញថាមនោវិញ្ញាណមិនទៀង ឃើញថាមនោ-សម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ នេះឯង បដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ។ ចប់សូត្រ ទី ២ ។

[២៣១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់នូវបដិបទានោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាទីសប្បាយ ដើម្បីព្រះនិព្វាននោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ឃើញថាចក្ខុជាទុក្ខ ឃើញថារូបជាទុក្ខ ឃើញថាចក្ខុវិញ្ញាណជាទុក្ខ ឃើញថាចក្ខុសម្ផស្សជាទុក្ខ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាជាទុក្ខ ។ បេ ។ ឃើញថាជិវ្ហាជាទុក្ខ ។ បេ ។ ឃើញថាមនោជាទុក្ខ ឃើញថាធម្មារម្មណ៍ជាទុក្ខ ឃើញថាមនោវិញ្ញាណជាទុក្ខ ឃើញថាមនោសម្ផស្សជាទុក្ខ

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខន្តិ បស្សតិ ។ អយំ ខោ សា ភិក្ខវេ និព្វានសប្បាយា បដិបទាតិ ។ តតិយំ ។

[២៣២] និព្វានសប្បាយំ វោ ភិក្ខវេ បដិបទំ ទេ-សិស្សាមិ តំ សុណាថ ។ បេ ។ កាតមា ច សា ភិក្ខវេ និព្វានសប្បាយា បដិបទា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុំ អនត្តាតិ បស្សតិ រូបា អនត្តាតិ បស្សតិ ចក្ខុ-វិញ្ញាណំ អនត្តាតិ បស្សតិ ចក្ខុសម្ផស្សោ អនត្តា-តិ បស្សតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តាតិ បស្សតិ ។ បេ ។ ជិវ្ហា អនត្តាតិ បស្សតិ ។ បេ ។ មនោ អនត្តាតិ បស្សតិ ធម្មា អនត្តាតិ បស្សតិ មនោវិញ្ញាណំ អនត្តាតិ បស្សតិ មនោសម្ផស្សោ អនត្តាតិ បស្សតិ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ។ ចប់សូត្រ ទី ៣ ។

[២៣២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់នូវបដិបទានោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាទីសប្បាយដើម្បីព្រះនិព្វាននោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញថាចក្ខុជាអនត្តា ឃើញថារូបជាអនត្តា ឃើញថាចក្ខុវិញ្ញាណជាអនត្តា ឃើញថាចក្ខុសម្ផស្សជាអនត្តា វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ភិក្ខុឃើញវេទនានោះថាជាអនត្តា ។ បេ ។ ឃើញថាជិវ្ហាជាអនត្តា ។ បេ ។ ឃើញថាមនោជាអនត្តា ឃើញថាធម្មារម្មណ៍ជាអនត្តា ឃើញថាមនោវិញ្ញាណជាអនត្តា ឃើញថាមនោសម្ផស្សជាអនត្តា វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ

តម្បិ អនត្តាតិ បស្សតិ ។ អយំ ខោ សា ភិក្ខវេ និព្វា-
នសប្បាយា បដិបទាតិ ។ ចតុត្ថំ ។

[២៣៣] និព្វានសប្បាយំ វោ ភិក្ខវេ បដិបទំ
ទេសិស្សាមិ តំ សុណាថ ។ បេ ។ កតមា ច សា
ភិក្ខវេ និព្វានសប្បាយា បដិបទា ។ តំ កឹ មញ្ញថ
ភិក្ខវេ ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ
បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ
បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិ-
តុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ
ហេតំ ភន្តេ ។ រូបា និច្ចា វា អនិច្ចា វាតិ ។ អ-
និច្ចា ភន្តេ ។ ចក្ខុវិញ្ញាណំ ចក្ខុសម្ផស្សោ ។ បេ ។
យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ
សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ និច្ចំ វា
អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ
វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ
ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ

ភិក្ខុឃើញវេទនានោះថាជាអនត្តា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងបដិ-
បទាជាទីសប្បាយដើម្បីព្រះនិព្វាន ។ ចប់សូត្រ ទី ៤ ។

[២៣៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវបដិបទាជា
ទីសប្បាយដើម្បីព្រះនិព្វាន ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុង
ស្ដាប់នូវបដិបទានោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បដិបទាជាទី
សប្បាយដើម្បីព្រះនិព្វាននោះ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អ្នក
ទាំងឡាយសម្គាល់សេចក្ដីនោះថាដូចម្ដេច ចក្ខុទៀងឬមិនទៀង ។ មិន
ទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជា
សុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិនទៀង ជាទុក្ខ មានកិរិយា
ប្រែប្រួលជាធម្មតា តើគួរនឹងយល់របស់នោះថា នុ៎ះរបស់អញ នុ៎ះជា
អញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរនឹងយល់ឃើញដូច្នោះ
ទេ ព្រះអង្គ ។ រូបទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចក្ខុ-
វិញ្ញាណ ចក្ខុសម្ផស្ស ។ បេ ។ វេទនាណា ជាសុខក្ដី ជាទុក្ខក្ដី មិនជា
ទុក្ខមិនជាសុខក្ដី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនា
នោះទៀងឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ណាមិនទៀង
របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ របស់ណា មិន
ទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញរបស់នោះថា

៣១១

នវបុរាណវគ្គោ បញ្ចមោ

ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ សា ភិក្ខវេ និព្វានសប្បាយា បដិបទាតិ ។ បញ្ចមំ ។

នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ មិនគួរយល់ឃើញដូច្នោះទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ រមែងនឿយណាយនឹងវេទនានោះផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេកទើបចិត្តរួចស្រឡះបាន ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះបដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ។ ចប់សូត្រទី ៥ ។

[២៣៤] អនន្តេវាសិកមិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ អនាចរិយកំ ។ សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ទុក្ខំ ន ផាសុ[១] វិហរតិ អនន្តេវាសិកោ ភិក្ខវេ ភិក្ខុ អនាចរិយកោ សុខំ ផាសុ វិហរតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស អន្តោ វសន្តិ អន្តស្ស វសន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ ។ តេ នំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ។ បេ ។

---

១ ឱ. ផាសុំ វិហរតិ ។ តេ នំ សមុទាចរន្តិ ។ នំ សមុទាចរន្តិ បាបកា ។

[២៣៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈនេះដែលមិនមានកិលេសដូចជាកូនសិស្ស ដែលមិនមានកិលេសដូចជាអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយកិលេសដូចជាកូនសិស្ស ប្រកបដោយកិលេសដូចជាអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកិលេសដូចជាកូនសិស្ស ទាំងមិនមានកិលេសដូចជាអាចារ្យ រមែងនៅជាសុខសប្បាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ប្រកបដោយកិលេសដូចជាកូនសិស្ស ប្រកបដោយកិលេសដូចជាអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ធម៌ទាំងនោះ រមែងនៅក្នុងទីជិតភិក្ខុនោះ អកុសលធម៌ដ៏លាមករមែងនៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រកបដោយកិលេសដូចជាកូនសិស្ស ។ អកុសលធម៌ដ៏លាមកទាំងនោះ រមែងហៅរកនូវភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រកបដោយកិលេសដូចជាអាចារ្យ ។ បេ ។

៣១៣



បុន ចបរំ ភិក្ខវេ ភិក្ខុនោ ជិវ្ហាយ រសំ សាយិត្វា ឧប្បជ្ជន្តិ ចាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស អន្តោ វសន្តិ អន្តស្ស វសន្តិ ចាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ ។ តេ នំ សមុទាចរន្តិ ចាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជន្តិ ចាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស អន្តោ វសន្តិ អន្តស្ស វសន្តិ ចាបកា អកុសលា ធម្មាតិ តស្មា សាន្តេវាសិកោតិ វុច្ចតិ ។ តេ នំ សមុទាចរន្តិ ចាបកា អកុសលា ធម្មាតិ តស្មា សាចរិយកោតិ វុច្ចតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាន្តេវាសិកោ សាច-រិយកោ ទុក្ខំ ន ផាសុ វិហរតិ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត អកុសលធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងកើតឡើងដល់ភិក្ខុ ព្រោះលិទ្ធរសដោយជិវ្ហា ធម៌ទាំងនោះរមែងនៅក្នុងទីជិតភិក្ខុនោះ អកុសលធម៌ដ៏លាមករមែងនៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រកបដោយកិលេសដូចជាកូនសិស្ស ។ អកុសលធម៌ដ៏លាមកទាំងនោះ រមែងហៅរកភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រកបដោយកិលេសដូចជាអាចារ្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ពួកអកុសល-ធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងកើតឡើងដល់ភិក្ខុ ព្រោះដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ធម៌ទាំងនោះរមែងនៅក្នុងទីជិតភិក្ខុនោះ អកុសលធម៌ដ៏លាមករមែងនៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រកបដោយកិលេសដូចជាកូនសិស្ស ។ អកុសលធម៌ដ៏លាមកទាំងនោះ រមែងហៅរកភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកប្រ-កបដោយកិលេសដូចជាអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយកិលេសដូចជាកូនសិស្ស ប្រកបដោយកិលេសដូចជាអាចារ្យរមែងនៅជាទុក្ខ មិនសប្បាយ យ៉ាងនេះឯង ។

[២៣៨] កាថញ្ច ភិក្ខវេ ភិក្ខុ អនន្តេវាសិកោ អនាចរិយកោ សុខំ ផាសុ វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ន ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស ន អន្តោ វសន្តិ នាស្ស អន្តោ វសន្តិ បាបកា អកុសលា ធម្មាតិ តស្មា អនន្តេវាសិកោតិ វុច្ចតិ ។ តេតំ[១] សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា អនាចរិយកោតិ វុច្ចតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ ជិវ្ហាយ រសំ សាយិត្វា ន ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស ន អន្តោ វសន្តិ នាស្ស អន្តោ វសន្តិ បាបកា អកុសលា ធម្មាតិ តស្មា អនន្តេវាសិកោតិ វុច្ចតិ ។ តេតំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា

១ ឱ. តេ ន នំ សមុទាចរន្តិ ន សមុទាចរន្តិ សម្បាបកា អកុសលា ធម្មាតិ ។

[២៣៥] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនមានកិលេសដូចជាកូនសិស្ស និងមិនមានកិលេសដូចជាអាចារ្យ រមែងនៅជាសុខសប្បាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងមិនកើតឡើងដល់ភិក្ខុក្នុងសាសនានេះ ព្រោះឃើញរូបដោយចក្ខុ ធម៌ទាំងនោះ រមែងមិនទៅក្នុងទីជិតភិក្ខុនោះ ពួកអកុសលធម៌ដ៏លាមក រមែងមិនទៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកមិនមានកិលេសដូចជាកូនសិស្ស ។ អកុសលធម៌ដ៏លាមកទាំងនោះ រមែងមិនហៅរកភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកមិនមានកិលេសដូចជាអាចារ្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត អកុសលធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងមិនកើតឡើងដល់ភិក្ខុ ព្រោះលិទ្ធរសដោយជិវ្ហា ធម៌ទាំងនោះ រមែងមិនទៅក្នុងទីជិតភិក្ខុនោះ ពួកអកុសលធម៌ដ៏លាមក រមែងមិនទៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកមិនមានកិលេសដូចជាកូនសិស្ស ។ ពួកអកុសលធម៌ដ៏លាមក រមែងមិនហៅរកភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា

៣១៤



អនាចរិយកោតិ វុច្ចតិ ។ បេ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មនសា ធម្មំ វិញ្ញាយ ន ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ត្យាស្ស ន អន្តោ វសន្តិ នាស្ស អន្តោ វសន្តិ បាបកា អកុសលា ធម្មាតិ តស្មា អនន្តេវាសិកោតិ វុច្ចតិ ។ នេតំ សមុទាចរន្តិ បាបកា អកុសលា ធម្មាតិ តស្មា អនាចរិយកោតិ វុច្ចតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អនន្តេវាសិកោ អនាចរិយកោ សុខំ ផាសុ វិហរតិ ។ អនន្តេវាសិកមិទំ ភិក្ខវេ ព្រហ្មចរិយំ វុស្សតិ អនាចរិយកំ ។ សាន្តេវាសិកោ ភិក្ខវេ ភិក្ខុ សាចរិយកោ ទុក្ខំ ន ផាសុ វិហរតិ អនន្តេវាសិកោ ភិក្ខវេ ភិក្ខុ អនាចរិយកោ សុខំ ផាសុ វិហរតីតិ ។ ឆដ្ឋំ ។

អ្នកមិនមានកិលេសដូចជាអាចារ្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត អកុសលធម៌ដ៏លាមក មានតម្រិះដ៏ស្មុះទៅ ប្រកបដោយសញ្ញោជនៈ រមែងមិនកើតឡើងដល់ភិក្ខុ ព្រោះដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ធម៌ទាំងនោះរមែងមិននៅក្នុងទីជិតភិក្ខុនោះ អកុសលធម៌ដ៏លាមករមែងមិនមាននៅក្នុងទីជិតភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកមិនមានកិលេសដូចជាកូនសិស្ស ។ ពួកអកុសលធម៌ដ៏លាមករមែងមិនហៅរកភិក្ខុនោះ ព្រោះហេតុនោះ បានជាតថាគតហៅភិក្ខុនោះថា អ្នកមិនមានកិលេសដូចជាអាចារ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនប្រកបដោយកិលេសដូចជាកូនសិស្ស និងមិនប្រកបដោយកិលេសដូចជាអាចារ្យ រមែងនៅជាសុខសប្បាយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈនេះ ដែលមិនមានកិលេសដូចជាកូនសិស្ស និងមិនមានកិលេសដូចជាអាចារ្យ បែបនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយកិលេសដូចជាកូនសិស្ស និងប្រកបដោយកិលេសដូចជាអាចារ្យ រមែងនៅជាទុក្ខ មិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកិលេសដូចជាកូនសិស្ស និងមិនមានកិលេសដូចជាអាចារ្យ រមែងនៅសុខសប្បាយ ។ ចប់សូត្រ ទី ៦ ។

[២៣៦] សចេ វោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កិមត្ថិយំ អាវុសោ សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ទុក្ខស្ស ខោ អាវុសោ[១] បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ សចេ បន វោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កតមំ បន[២] អាវុសោ ទុក្ខំ យស្ស បរិញ្ញាយ សមណេ គោតមេ ព្រហ្មចរិយំ វុស្សតីតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ចក្ខុំ ខោ អាវុសោ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ រូបា ទុក្ខា

---

១ ឱ. ម. យស្ស បរិញ្ញាយ ។ ២ តមាវុសោ ។

[២៣៦] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកបរិព្វាជកជាតិរិ្ថយដទៃ សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះសមណគោតម មានប្រយោជន៍អ្វី ។ ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាតិរិ្ថយដទៃ សួរយ៉ាងនេះ អ្នកទាំងឡាយត្រូវដោះស្រាយ នឹងពួកបរិព្វាជកតិរិ្ថយដទៃនោះ យ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកបរិព្វាជកជាតិរិ្ថយដទៃ សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះសមណគោតម ដើម្បីកំណត់ដឹងនូវ ទុក្ខណា ទុក្ខនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បើគេសួរអ្នកទាំងឡាយយ៉ាងនេះ អ្នកទាំងឡាយត្រូវដោះស្រាយនឹងពួកបរិព្វាជកជាតិរិ្ថយដទៃយ៉ាងនេះថា ម្នាលអាវុសោ ចក្ខុជាទុក្ខ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវចក្ខុជាទុក្ខនោះ រូបជាទុក្ខ

តេសំ បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ចក្ខុវិញ្ញាណំ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ចក្ខុសម្ផស្សោ ទុក្ខោ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ បេ ។ ជិវ្ហា ទុក្ខា មនោ ទុក្ខោ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ តស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ។ ឥទំ ខោ អាវុសោ ទុក្ខស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។

សត្តមំ ។

នវបុរាណវគ្គ ទី ៥

ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវរូបជាទុក្ខនោះ ចក្ខុវិញ្ញាណជាទុក្ខ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវចក្ខុវិញ្ញាណជាទុក្ខនោះ ចក្ខុសម្ផស្សជាទុក្ខ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវចក្ខុសម្ផស្សជាទុក្ខនោះ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏ជាទុក្ខ ។ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវវេទនាជាទុក្ខនោះ ។ បេ ។ ជិវ្ហាជាទុក្ខ មនោជាទុក្ខ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវមនោជាទុក្ខនោះ ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏ជាទុក្ខ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវវេទនាជាទុក្ខនោះ ។ ម្នាលអាវុសោ ភិក្ខុប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីកំណត់ដឹងនូវទុក្ខនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើគេសួរអ្នកទាំងឡាយយ៉ាងនេះហើយ ត្រូវអ្នកទាំង-ឡាយ ដោះស្រាយនឹងពួកបរិព្វាជកតិរ្ថិយដទៃនោះ យ៉ាងនេះឯង ។

ចប់សូត្រ ទី ៧ ។

[២៣៧] អត្ថិ នុ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករេយ្យ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា ។ សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អត្ថិ

[២៣៧] ម្នាលភិក្ខុទាំងឡាយ ហេតុដែលភិក្ខុវៀរលែងជំនឿ វៀរលែងសេចក្ដីគាប់ចិត្ត វៀរលែងការឮតៗគ្នា វៀរលែងសេចក្ដីត្រិះរិះនូវហេតុ វៀរលែងសេចក្ដីគាប់ចិត្ត តាមសេចក្ដីយល់ឃើញ ហើយបានដល់នូវអរហត្ត ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់ពួកយើងខ្ញុំ មានព្រះមានព្រះភាគជាឫសគល់ មានព្រះមានព្រះភាគជាអ្នកដឹកនាំ មានព្រះមានព្រះភាគជាទីពឹងពំនាក់ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគបំភ្លឺសេចក្ដី នៃភាសិតនុ៎ះឲ្យទាន ភិក្ខុទាំងឡាយ បានស្ដាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយស្ដាប់ ចូរយកចិត្តទុកដាក់ឲ្យប្រពៃចុះ តថាគតនឹងសម្ដែងប្រាប់ ។ ពួកភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា

ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករេយ្យ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៣៨] កតមោ ច ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ ។ បេ ។ អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា សន្តំ វា អជ្ឈត្តំ រាគទោសមោហំ អត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ យន្តំ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា សន្តំ វា អជ្ឈត្តំ រាគទោសមោហំ អត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ

ម្នាលភិក្ខុទាំងឡាយ ហេតុដែលភិក្ខុវៀរលែងជំនឿ វៀរលែងសេចក្តីគាប់ចិត្ត វៀរលែងការឮតៗគ្នា វៀរលែងសេចក្តីត្រិះរិះនូវហេតុ វៀរលែងសេចក្តីពេញចិត្ត តាមសេចក្តីយល់ឃើញ ហើយបានសម្រេចអរហត្ត ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ក៏មានដែរ ។

[២៣៨] ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលភិក្ខុវៀរលែងជំនឿ ។ បេ ។ វៀរលែងសេចក្តីគាប់ចិត្ត តាមសេចក្តីយល់ឃើញ ហើយបានសម្រេចអរហត្ត ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុងថា អាត្មាអញមានរាគៈទោសៈមោហៈនៅខាងក្នុង ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមាននៅខាងក្នុងថា អាត្មាអញមិនមានរាគៈទោសៈមោហៈនៅខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញរូបដោយចក្ខុ ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុងថា អាត្មាអញមានរាគៈទោសៈមោហៈនៅខាងក្នុង

អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ អបិ នុ ខោ មេ ភិក្ខវេ ធម្មា សទ្ធាយ វា វេទិតព្វា រុចិយា វា វេទិតព្វា អនុស្សវេន វា វេទិតព្វា អាការបរិវិតក្កេន វា វេទិតព្វា ទិដ្ឋិនិជ្ឈានក្ខន្តិយា វា វេទិតព្វាតិ ។ នោ ហេតំ ភន្តេ ។ ននុ មេ ភិក្ខវេ ធម្មា បញ្ញាយ ទិស្វា វេទិតព្វាតិ ។ ឯវំ ភន្តេ ។ អយម្បិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ បេ ។

ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមាននៅខាងក្នុងថា អាត្មាអញមិនមានរាគៈទោសៈមោហៈនៅខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយរបស់តថាគត គេត្រូវដឹងដោយជំនឿក្តី ត្រូវដឹងដោយសេចក្តីគាប់ចិត្តក្តី ត្រូវដឹងដោយការឮតៗគ្នាក្តី ត្រូវដឹងដោយសេចក្តីត្រិះរិះនូវហេតុក្តី ត្រូវដឹងដោយសេចក្តីពេញចិត្តព្រោះសេចក្តីយល់ឃើញក្តី តើមានឬទេ ។ មិនមានទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ក្រែងធម៌ទាំងឡាយរបស់តថាគត គេត្រូវឃើញដោយប្រាជ្ញាហើយដឹង ដូច្នោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាហេតុដែលភិក្ខុវៀរលែងជំនឿ វៀរលែងសេចក្តីគាប់ចិត្ត វៀរលែងការឮត ៗ គ្នា វៀរលែងសេចក្តីត្រិះរិះនូវហេតុ វៀរលែងសេចក្តីពេញចិត្តព្រោះសេចក្តីយល់ឃើញ ហើយបានសម្រេចអរហត្ត ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បេ ។

៣២១

## នវបុរាណវគ្គោ បញ្ចមោ

[២៣៩] បុន ចបរំ ភិក្ខវេ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា សន្តំ វា អជ្ឈត្តំ ។ បេ ។ រាគទោសមោហោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ យន្តំ ភិក្ខវេ ភិក្ខុ ជិវ្ហាយ រសំ សាយិត្វា សន្តំ វា អជ្ឈត្តំ រាគទោសមោហំ អត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ អបិ នុ ខោ មេ ភិក្ខវេ ធម្មា សទ្ធាយ វា វេទិតព្វា រុចិយា វា វេ-ទិតព្វា អនុស្សវេន វា វេទិតព្វា អាការបរិវិតក្កេន វា វេទិតព្វា ទិដ្ឋិនិជ្ឈានក្ខន្តិយា វា វេទិតព្វាតិ ។ នោ ហេតំ ភន្តេ ។ ននុ មេ ភិក្ខវេ ធម្មា បញ្ញាយ ទិស្វា វេទិតព្វាតិ ។ ឯវំ ភន្តេ ។ អយម្បិ ខោ ភិក្ខវេ បរិយាយោ

## នវបុរាណវគ្គ ទី ៥

[២៣៩] ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុលិទ្ធភ្នក្សរសដោយជិវ្ហា ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុង ។ បេ ។ ថា រាគៈទោសៈមោហៈខាងក្នុង ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមានខាងក្នុងថា អាត្មាអញមិនមានរាគៈទោសៈមោហៈខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលិទ្ធភ្នក្សរសដោយជិវ្ហា ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុងថា អាត្មាអញមានរាគៈទោសៈមោហៈនៅខាងក្នុង ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមាននៅខាងក្នុងថា អាត្មាអញមិនមានរាគៈទោសៈមោហៈនៅខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយរបស់តថាគត គេត្រូវដឹងដោយជំនឿក្តី ដឹងដោយសេចក្តីគាប់ចិត្តក្តី ដឹងដោយការឮត ៗ គ្នាក្តី ដឹងដោយសេចក្តីត្រិះរិះនូវហេតុក្តី ដឹងដោយសេចក្តីគាប់ចិត្ត ព្រោះសេចក្តីយល់ឃើញក្តី តើមានឬទេ ។ មិនមានទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ក្រែងធម៌ទាំងឡាយ របស់តថាគត គេត្រូវឃើញដោយប្រាជ្ញាហើយដឹងដូច្នោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងក៏ជាហេតុ

យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ បេ ។

[២៤០] បុន ចបរំ ភិក្ខវេ ភិក្ខុ មនសា ធម្មំ វិញ្ញាយ សន្តំ វា អជ្ឈត្តំ រាគទោសមោហំ អត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ យន្តំ ភិក្ខវេ ភិក្ខុ មនសា ធម្មំ វិញ្ញាយ សន្តំ វា អជ្ឈត្តំ រាគទោសមោហំ អត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ រាគទោសមោហំ នត្ថិ មេ អជ្ឈត្តំ រាគទោសមោហោតិ បជានាតិ ។ អបិ នុ ខោ មេ ភិក្ខវេ ធម្មា សទ្ធាយ វា វេទិតព្វា រុចិយា វា វេទិតព្វា

ដែលភិក្ខុវៀរលែងជំនឿ វៀរលែងសេចក្តីគាប់ចិត្ត វៀរលែងការឮត ៗ គ្នា វៀរលែងសេចក្តីត្រិះរិះនូវហេតុ វៀរលែងសេចក្តីគាប់ចិត្ត ព្រោះសេចក្តីយល់ឃើញ បានសម្រេចអរហត្ត ហើយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បេ ។

[២៤០] ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុងថា អាត្មាអញមានរាគៈទោសៈមោហៈនៅខាងក្នុង ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមាននៅខាងក្នុងថា អាត្មាអញ មិនមានរាគៈទោសៈមោហៈនៅខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមាននៅខាងក្នុងថា អាត្មាអញ មានរាគៈទោសៈមោហៈនៅខាងក្នុង ដឹងច្បាស់នូវរាគៈទោសៈមោហៈដែលមិនមាននៅខាងក្នុងថា អាត្មាអញ មិនមានរាគៈទោសៈមោហៈនៅខាងក្នុង ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំង-ឡាយរបស់តថាគត គេត្រូវដឹងដោយជំនឿក្តី ដឹងដោយសេចក្តីគាប់ចិត្តក្តី

៣២៣



អនុស្សវេន វា វេទិតព្វា អាការបរិវិតក្កេន វា វេទិតព្វា ទិដ្ឋិនិជ្ឈានក្ខន្តិយា វា វេទិតព្វា ។ នោ ហេតំ ភន្តេ ។ ននុ មេ ភិក្ខវេ ធម្មា បញ្ញាយ ទិស្វា វេទិតព្វាតិ ។ ឯវំ ភន្តេ ។ អយម្បិ ខោ ភិក្ខវេ បរិយាយោ យំ បរិយាយំ អាគម្ម ភិក្ខុ អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ អដ្ឋមំ ។

[២៤១] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥន្ទ្រិយសម្បន្នោ ឥន្ទ្រិយសម្បន្នោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ឥន្ទ្រិយសម្បន្នោ ហោតីតិ ។ ចក្ខុន្ទ្រិយេ ចេ ភិក្ខុ ឧទយព្វយានុបស្សី វិហរន្តោ ចក្ខុន្ទ្រិយេ និព្វិន្ទតិ ។ បេ ។ ជិវ្ហិន្ទ្រិយេ ចេ ភិក្ខុ

ដឹងដោយការឮតៗ គ្នាក្តី ដឹងដោយការត្រិះរិះនូវហេតុក្តី ដឹងដោយសេចក្តីគាប់ចិត្តព្រោះសេចក្តីយល់ឃើញក្តី តើមានឬទេ ។ មិនមានទេព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ក្រែងធម៌ទាំងឡាយរបស់តថាគត គេត្រូវឃើញដោយប្រាជ្ញាហើយដឹង ដូច្នោះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងក៏ជាហេតុដែលភិក្ខុវៀរលែងជំនឿ វៀរលែងសេចក្តីគាប់ចិត្ត វៀរលែងការឮត ៗ គ្នា វៀរលែងសេចក្តីត្រិះរិះនូវហេតុ វៀរលែងសេចក្តីគាប់ចិត្តព្រោះសេចក្តីយល់ឃើញ ក៏បានសម្រេចអរហត្តហើយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រ ទី ៨ ។

[២៤១] គ្រានោះ ភិក្ខុមួយរូប បានចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ថា ភិក្ខុបរិបូណ៌ដោយឥន្ទ្រិយ បរិបូណ៌ដោយឥន្ទ្រិយ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុអ្នកបរិបូណ៌ដោយឥន្ទ្រិយ តើដោយហេតុប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគត្រាស់ថា បើភិក្ខុពិចារណាឃើញនូវការកើតឡើងនិងការវិនាសក្នុងចក្ខុន្ទ្រិយ រមែងនឿយណាយនឹងចក្ខុន្ទ្រិយ ។ បេ ។ បើភិក្ខុពិចារណា

ឧទយព្វយានុបស្សី វិហរន្តោ ជិវ្ហិន្ទ្រិយេ និព្វិន្ទតិ ។ បេ ។ មនិន្ទ្រិយេ ចេ ភិក្ខុ ឧទយព្វយានុបស្សី វិហរន្តោ មនិន្ទ្រិយេ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ ។ បេ ។ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯត្តាវតា ខោ ភិក្ខុ ឥន្ទ្រិយសម្បន្នោ ហោតីតិ ។ នវមំ ។

[២៤២] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេ-នុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ធម្មកថិកោ ធម្មកថិកោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ធម្មកថិកោ ហោតីតិ ។ ចក្ខុស្ស ចេ ភិក្ខុវេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ

ឃើញនូវការកើតឡើងនិងការវិនាសក្នុងជិវ្ហិន្ទ្រិយ រមែងនឿយណាយនឹងជិវ្ហិន្ទ្រិយ ។ បេ ។ បើភិក្ខុពិចារណាឃើញនូវការកើតឡើងនិងការវិនាសក្នុងមនិន្ទ្រិយ រមែងនឿយណាយនឹងមនិន្ទ្រិយ កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ។ បេ ។ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយឥន្ទ្រិយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ចប់សូត្រ ទី ៩ ។

[២៤២] គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ថា ភិក្ខុជាធម្មកថិក ភិក្ខុជាធម្មកថិក បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាធម្មកថិក តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុសម្តែងធម៌ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចក្ខុ ទើបគួរ

ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ ចក្ខុស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ ចក្ខុស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយ ។ បេ ។ ជិវ្ហាយ ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ បេ ។ មនស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ ធម្មំ ទេសេតិ ធម្មកថិកោ ភិក្ខូតិ អលំ វចនាយ ។ មនស្ស ចេ ភិក្ខុ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ ធម្មានុធម្មប្បដិបន្នោ ភិក្ខូតិ អលំ វចនាយ ។ មនស្ស ចេ ភិក្ខុ និព្វិទា វិរាគា និរោធា អនុបាទា វិមុត្តោ ហោតិ ទិដ្ឋធម្មនិព្វានប្បត្តោ ភិក្ខូតិ អលំ វចនាយាតិ ។ ទសមំ ។

នវបុរាណវគ្គោ បញ្ចមោ ។

នវបុរាណវគ្គ ទី ៥

ហៅថាភិក្ខុជាធម្មកថិក ។ បើភិក្ខុប្រតិបត្តិដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចក្ខុ ទើបគួរហៅថាភិក្ខុជាអ្នកប្រតិបត្តិដ៏សមគួរដល់ធម៌ ។ បើភិក្ខុមានចិត្តរួចស្រឡះ ព្រោះនឿយណាយ ព្រោះវិនាស ព្រោះរំលត់ ព្រោះមិនប្រកាន់ នូវចក្ខុ ទើបគួរហៅថាភិក្ខុអ្នកដល់នូវទិដ្ឋធម្មនិព្វាន ។ បេ ។ បើភិក្ខុសម្ដែងធម៌ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវជិវ្ហា ទើបគួរហៅថាភិក្ខុជាធម្មកថិក ។ បេ ។ បើភិក្ខុសម្ដែងធម៌ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចិត្ត ទើបគួរហៅថាភិក្ខុជាធម្មកថិក ។ បើភិក្ខុប្រតិបត្តិដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចិត្ត ទើបគួរហៅថាភិក្ខុជាអ្នកប្រតិបត្តិដ៏-សមគួរដល់ធម៌ ។ បើភិក្ខុមានចិត្តរួចស្រឡះ ព្រោះនឿយណាយ ព្រោះវិនាស ព្រោះរំលត់ ព្រោះមិនប្រកាន់ នូវចិត្ត ទើបគួរហៅថាភិក្ខុអ្នកដល់នូវទិដ្ឋធម្មនិព្វាន ។ ចប់សូត្រ ទី ១០ ។

ចប់ នវបុរាណវគ្គ ទី ៥ ។

# តស្សុទ្ទានំ

កាម្មំ ចត្តារិ សប្បាយា
អនន្តេវាសិកិកមត្ថិយា
អត្ថិ នុ ខោ បរិយាយោ
ឥន្ទ្រិយកាជិកេកន វាតិ[១] ។

សឡាយតនវគ្គេ បណ្ណាសកំ តតិយំ ។

# តស្សុទ្ទានំ[២]

យោគក្ខេមិ ច លោកោ ច
គហបតិ ទេវទហេន ច
នវបុរាណេន បញ្ញាសំ
តតិយំ តេន វុច្ចតីតិ ។

១ ឱ. ម. ឯវំ កថិកេន តេទសាតិ ។ ២ តត្រ វគ្គុទ្ទានំ ។

## ឧទ្ទាននៃនវបុរាណវគ្គនោះ គឺ

*និយាយអំពីកម្ម ១ បដិបទាជាទីសប្បាយដើម្បីព្រះនិព្វាន ៤ លើក ភិក្ខុមិនមានកិលេសដូចជាកូនសិស្ស ១ ព្រហ្មចរិយៈមានប្រយោជន៍អ្វី ១ មានបរិយាយដែរឬ ១ ភិក្ខុបរិបូណ៌ដោយឥន្រ្ទិយ ១ ភិក្ខុគួរហៅថាធម្មកថិក ១ ។*

ចប់ តតិយបណ្ណាសកៈ ក្នុងសឡាយតនវគ្គ ។

## ឧទ្ទាននៃតតិយបណ្ណាសកៈនោះ គឺ

*យោគក្ខេមិវគ្គ ១ លោកកាមគុណវគ្គ ១ គហបតិវគ្គ ១ ទេវទហវគ្គ ១ នវបុរាណវគ្គ ១ ហេតុនោះបានជាហៅថាតតិយបណ្ណាសកៈ ។*

---

# ចតុត្ថបណ្ណាសកំ

## នន្ទិក្ខយវគ្គោ

[២៤៣] អនិច្ចំយេវ ភិក្ខវេ ភិក្ខុ ចក្ខុំ អនិច្ចន្តិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ បេ ។ អនិច្ចំយេវ ភិក្ខវេ ភិក្ខុ ជិវ្ហំ អនិច្ចន្តិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ ។ បេ ។ ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ បេ ។ អនិច្ចំយេវ ភិក្ខវេ ភិក្ខុ មនំ អនិច្ចន្តិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។ បឋមំ ។

# ចតុត្ថបណ្ណាសកៈ

## នន្ទិក្ខយវគ្គ

[២៤៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញចក្ខុដែលមិនទៀងថាមិនទៀង ភិក្ខុនោះ ឈ្មោះថាមានគំនិតយល់ត្រូវ កាលបើយល់ត្រូវរមែងនឿយណាយ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថា ផុតស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុឃើញជិវ្ហាដែលមិនទៀងថាមិនទៀង ភិក្ខុនោះ ឈ្មោះថាមានគំនិតយល់ត្រូវ កាលបើយល់ត្រូវ រមែងនឿយណាយ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីករាយ ។ បេ ។ ចិត្តដែលលោកហៅថាផុតស្រឡះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញចិត្តដែលមិនទៀងថាមិនទៀង ភិក្ខុនោះ ឈ្មោះថាមានគំនិតយល់ត្រូវ កាលបើយល់ត្រូវរមែងនឿយណាយ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថា រួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ ចប់សូត្រ ទី ១ ។

[២៤៤] អនិច្ចេយេវ ភិក្ខវេ ភិក្ខុ រូបេ អនិច្ចាតិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ អនិច្ចេយេវ ភិក្ខវេ ភិក្ខុ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ អនិច្ចាតិ បស្សតិ សាស្ស ហោតិ សម្មាទិដ្ឋិ សម្មា បស្សំ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។ ទុតិយំ ។

[២៤៥] ចក្ខុំ ភិក្ខវេ យោនិសោ មនសិករោថ ចក្ខុអនិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ ចក្ខុំ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ ចក្ខុអនិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ ចក្ខុស្មឹបិ និព្វិន្ទតិ នន្ទិក្ខយា

[២៤៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញរូបដែលមិនទៀងថាមិនទៀង ភិក្ខុនោះឈ្មោះថាមានគំនិតយល់ត្រូវ កាលបើយល់ត្រូវ រមែងនឿយណាយ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្ដីរីករាយ ការអស់នៃសេចក្ដីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថារួចស្រឡះ ព្រោះអស់នៃសេចក្ដីរីករាយនិងរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឃើញសំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលមិនទៀងថាមិនទៀង ភិក្ខុនោះឈ្មោះថាមានគំនិតយល់ត្រូវ កាលបើយល់ត្រូវ រមែងនឿយណាយ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្ដីរីករាយ ការអស់នៃសេចក្ដីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថាផុតស្រឡះ ព្រោះអស់នៃសេចក្ដីរីករាយនិងរាគៈ ។ ចប់សូត្រ ទី ២ ។

[២៤៩] ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយធ្វើទុកក្នុងចិត្តនូវចក្ខុដោយឧបាយប្រាជ្ញាផង ចូរពិចារណាឃើញតាមពិត នូវភាពនៃចក្ខុដែលមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តនូវចក្ខុដោយឧបាយប្រាជ្ញាផង ពិចារណាឃើញតាមពិត នូវភាពនៃចក្ខុដែលមិនទៀងផង ក៏រមែងនឿយណាយនឹងចក្ខុ ការអស់នៃរាគៈ ព្រោះ

៣២៩

នន្ទិក្ខយវគ្គោ បឋមោ

រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ បេ ។ ជិវ្ហំ ភិក្ខវេ យោនិសោ មនសិករោថ ជិវ្ហានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ ជិវ្ហំ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ ជិវ្ហានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ ជិវ្ហាយបិ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ បេ ។ មនំ ភិក្ខវេ យោនិសោ មនសិករោថ មនានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ មនំ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ មនានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ មនស្មឹបិ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។ តតិយំ ។

អស់នៃសេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថា រួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយធ្វើទុកក្នុងចិត្តនូវជិវ្ហាដោយឧបាយប្រាជ្ញាផង ចូរពិចារណាឃើញតាមពិត នូវភាពនៃជិវ្ហាដែលមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តនូវជិវ្ហាដោយឧបាយប្រាជ្ញាផង ពិចារណាឃើញតាមពិត នូវភាពនៃជិវ្ហាដែលមិនទៀងផង ក៏រមែងនឿយណាយនឹងជិវ្ហា ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថារួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយធ្វើទុកក្នុងចិត្តនូវចិត្តដោយឧបាយប្រាជ្ញាផង ចូរពិចារណាឃើញតាមពិត នូវភាពនៃចិត្តដែលមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តនូវចិត្តដោយឧបាយប្រាជ្ញាផង ពិចារណាឃើញតាមពិត នូវភាពនៃចិត្តដែលមិនទៀងផង ក៏រមែងនឿយណាយនឹងចិត្ត ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅថា រួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ ចប់សូត្រ ទី ៣ ។

[២៤៦] រូបេ ភិក្ខវេ យោនិសោ មនសិករោថ រូបានិច្ចតញ្ច យថាភូតំ សមនុបស្សថ ។ រូបេ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ រូបានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ រូបេសុ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតិ ។ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មេ ភិក្ខវេ យោនិសោ មនសិករោថ ធម្មានិច្ចតញ្ច យថាភូតំ សមនុបស្សថ ធម្មេ ភិក្ខវេ ភិក្ខុ យោនិសោ មនសិករោន្តោ ធម្មានិច្ចតញ្ច យថាភូតំ សមនុបស្សន្តោ ធម្មេសុ និព្វិន្ទតិ នន្ទិក្ខយា រាគក្ខយោ រាគក្ខយា នន្ទិក្ខយោ នន្ទិរាគក្ខយា ចិត្តំ សុវិមុត្តន្តិ វុច្ចតីតិ ។ ចតុត្ថំ ។

[២៤៦] ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយធ្វើទុកក្នុងចិត្ត នូវរូបដោយឧបាយប្រាជ្ញាផង ចូរពិចារណាឃើញតាមពិត នូវភាពនៃរូប ដែលមិនទៀងផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្តនូវ រូបដោយឧបាយប្រាជ្ញាផង ពិចារណាឃើញតាមពិត នូវភាពនៃរូបមិន ទៀងផង ក៏រមែងនឿយណាយក្នុងរូប ការអស់នៃរាគៈ ព្រោះអស់នៃ សេចក្តីរីករាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែល លោកហៅថារួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ ម្នាល ភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ធ្វើទុកក្នុងចិត្តនូវសំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយដោយឧបាយប្រាជ្ញាផង ចូរពិចារណា ឃើញតាមពិត នូវភាពនៃធម្មារម្មណ៍ដែលមិនទៀងផង ម្នាលភិក្ខុទាំង-ឡាយ កាលបើភិក្ខុធ្វើទុកក្នុងចិត្ត នូវធម្មារម្មណ៍ដោយឧបាយប្រាជ្ញាផង ពិចារណាឃើញតាមពិត នូវភាពនៃធម្មារម្មណ៍មិនទៀងផង ក៏រមែង នឿយណាយនឹងធម្មារម្មណ៍ ការអស់នៃរាគៈ ព្រោះអស់នៃសេចក្តីរីក រាយ ការអស់នៃសេចក្តីរីករាយ ព្រោះអស់នៃរាគៈ ចិត្តដែលលោកហៅ ថារួចស្រឡះ ព្រោះអស់នៃសេចក្តីរីករាយនិងរាគៈ ។ ចប់សូត្រ ទី ៤ ។

៣៣១

នន្ទិក្ខយវគ្គោ បឋមោ

[២៤៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ ជីវ-
កម្ពវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។
សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតស្ស ភិក្ខវេ ភិក្ខុនោ
យថាភូតំ ឱក្កាយតិ[១] ។ កិញ្ច យថាភូតំ ឱក្កាយតិ ។
ចក្ខុំ អនិច្ចន្តិ យថាភូតំ ឱក្កាយតិ រូបា អនិច្ចាតិ យថា-
ភូតំ ឱក្កាយតិ ចក្ខុវិញ្ញាណំ អនិច្ចន្តិ យថាភូតំ ឱក្កា-
យតិ ចក្ខុសម្ផស្សោ អនិច្ចោតិ យថាភូតំ ឱក្កាយតិ
យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ
វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ
ឱក្កាយតិ ។ បេ ។ មនោ អនិច្ចោតិ យថាភូតំ ឱក្កាយ-
តិ ធម្មា អនិច្ចាតិ យថាភូតំ ឱក្កាយតិ ។ បេ ។ យម្បិ-
ទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា
ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ
ឱក្កាយតិ ។ សមាធឹ ភិក្ខវេ ភាវេថ ។ សមាហិតស្ស
ភិក្ខវេ ភិក្ខុនោ យថាភូតំ ឱក្កាយតីតិ ។ បឋមំ ។

១ កត្ថចិ បោត្ថកេ ឱក្ខាយតីតិ ។

## នន្ទិក្ខយវគ្គ ទី ១

[២៤៧] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងជីវកម្ពវ័ន ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចម្រើនសមាធិចុះ ។ ម្នាលភិក្ខុទាំងឡាយ យថាភូតញ្ញាណរបស់ភិក្ខុដែលមានចិត្តតម្កល់មាំហើយ រមែងចុះស៊ប់ ។ យថាភូតញ្ញាណចុះស៊ប់ តើដូចម្តេច ។ យថាភូតញ្ញាណចុះស៊ប់ថា ចក្ខុមិនទៀង យថាភូតញ្ញាណចុះស៊ប់ថា រូបមិនទៀង យថាភូតញ្ញាណចុះស៊ប់ថា ចក្ខុវិញ្ញាណមិនទៀង យថាភូតញ្ញាណចុះស៊ប់ថា ចក្ខុសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ យថាភូតញ្ញាណចុះស៊ប់ថា វេទនានោះមិនទៀង ។ បេ ។ យថាភូតញ្ញាណចុះស៊ប់ថា ធម្មារម្មណ៍មិនទៀង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ យថាភូតញ្ញាណចុះស៊ប់ថា វេទនានោះមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចម្រើនសមាធិចុះ ។ ម្នាលភិក្ខុទាំងឡាយ យថាភូតញ្ញាណរបស់ភិក្ខុដែលមានចិត្តតម្កល់មាំ រមែងចុះស៊ប់ ។ ចប់សូត្រ ទី ៥ ។

[២៤៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ ជីវកម្ពវនេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។ បដិសល្លីនា ខោ ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លី-នស្ស ភិក្ខវេ ភិក្ខុនោ យថាភូតំ ឱក្កាយតិ ។ កិញ្ច ភិក្ខវេ យថាភូតំ ឱក្កាយតិ ។ ចក្ខុំ អនិច្ចន្តិ យថាភូតំ ឱក្កាយតិ រូបា អនិច្ចាតិ យថាភូតំ ឱក្កាយតិ ចក្ខុ-វិញ្ញាណំ អនិច្ចន្តិ យថាភូតំ ឱក្កាយតិ ចក្ខុសម្ផស្សោ អនិច្ចោតិ យថាភូតំ ឱក្កាយតិ យម្បិទំ ចក្ខុសម្ផស្ស-ប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខ-មសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ ឱក្កាយតិ ។ បេ ។ មនោ អនិច្ចោតិ យថាភូតំ ឱក្កាយតិ ធម្មា មនោវិញ្ញា-ណំ មនោសម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចន្តិ យថាភូតំ ឱក្កាយតិ ។ បដិសល្លីនា ភិក្ខវេ យោគមាបជ្ជថ ។ បដិសល្លីនស្ស ភិក្ខវេ ភិក្ខុនោ យថាភូតំ ឱក្កាយតីតិ ។ ឆដ្ឋំ ។

[២៤៨] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងជីវកម្ពវ័ន ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅពួកភិក្ខុ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយពួនសម្ងំ ប្រកបដោយសេចក្តីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលពួនសម្ងំ យថាភូតញ្ញាណ រមែងចុះស៊ប់ ។ ម្នាលភិក្ខុទាំងឡាយ យថាភូតញ្ញាណចុះស៊ប់តើដូចម្តេច ។ យថាភូតញ្ញាណចុះស៊ប់ថា ចក្ខុមិនទៀង យថាភូតញ្ញាណ ចុះស៊ប់ថា រូបមិនទៀង យថាភូតញ្ញាណ ចុះស៊ប់ថា ចក្ខុវិញ្ញាណមិនទៀង យថាភូតញ្ញាណចុះស៊ប់ថា ចក្ខុសម្ផស្សមិនទៀង វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ យថាភូតញ្ញាណចុះស៊ប់ថា វេទនានោះមិនទៀង ។ បេ ។ យថាភូតញ្ញាណចុះស៊ប់ថា ចិត្តមិនទៀង ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផស្ស វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ យថាភូតញ្ញាណក៏ចុះស៊ប់ថា វេទនានោះមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយពួនសម្ងំ ប្រកបដោយសេចក្តីព្យាយាមចុះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលពួនសម្ងំ យថាភូតញ្ញាណរមែងចុះស៊ប់ ។ ចប់សូត្រទី ៦ ។

នន្ទិក្ខយវគ្គោ បឋមោ

[២៤៩] អថខោ អាយស្មា មហាកោដ្ឋិកោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិកោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ យំ ខោ កោដ្ឋិក អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ កិញ្ច កោដ្ឋិក អនិច្ចំ ។ ចក្ខុំ កោដ្ឋិក អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា អនិច្ចា តត្រ តេ ឆន្ទោ ប-ហាតព្វោ ។ ចក្ខុវិញ្ញាណំ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ចក្ខុសម្ផស្សោ អនិច្ចោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

នន្ទិក្ខយវគ្គ ទី ១

[២៤៩] គ្រានោះឯង ព្រះមហាកោដ្ឋិកៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រះមហាកោដ្ឋិកៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគសម្តែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានស្តាប់ធម៌ព្រះមានព្រះភាគហើយ នឹងជាបុគ្គលម្នាក់ឯង ចៀសចេញអំពីពួក ជាអ្នកមិនប្រមាទព្យាយាមដុតកម្តៅកិលេស បញ្ជូនចិត្តទៅរកព្រះនិព្វាន ។ ម្នាលកោដ្ឋិកៈរបស់ណាមិនទៀង ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលកោដ្ឋិកៈរបស់អ្វីដែលមិនទៀង ។ ម្នាលកោដ្ឋិកៈ ចក្ខុមិនទៀង ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ងក្នុងចក្ខុនោះចេញ ។ រូបមិនទៀង ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ ចក្ខុវិញ្ញាណមិនទៀង ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ងក្នុងចក្ខុវិញ្ញាណនោះចេញ ។ ចក្ខុសម្ផស្សមិនទៀង ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ងក្នុងចក្ខុសម្ផស្សនោះចេញ ។ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ

តម្បិ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ ជិវ្ហា អនិច្ចា តត្រ តេ ឆន្ទោ បហាតព្វោ ។ រសា អនិច្ចា តត្រ តេ ឆន្ទោ បហាតព្វោ ។ ជិវ្ហាវិញ្ញាណំ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ជិវ្ហាសម្ផស្សោ អនិច្ចោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ មនោ អនិច្ចោ តត្រ តេ ឆន្ទោ បហាតព្វោ ។ ធម្មា អនិច្ចា តត្រ តេ ឆន្ទោ បហាតព្វោ ។ មនោវិញ្ញាណំ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ មនោសម្ផស្សោ អនិច្ចោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោ ។ យំ ខោ កោដ្ឋិក អនិច្ចំ តត្រ តេ ឆន្ទោ បហាតព្វោតិ ។

សត្តមំ ។

វេទនានោះក៏មិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងវេទនានោះចេញ ។ បេ ។ ជិវ្ហាមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងជិវ្ហានោះចេញ ។ រសមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងរសនោះចេញ ។ ជិវ្ហា-វិញ្ញាណមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ង ក្នុងជិវ្ហាវិញ្ញាណនោះចេញ ។ ជិវ្ហាសម្ផស្សមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងជិវ្ហា-សម្ផស្សនោះចេញ ។ វេទនាណា ជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនានោះមិនទៀងទេ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងវេទនានោះចេញ ។ បេ ។ ចិត្តមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងចិត្តនោះចេញ ។ ធម្មារម្មណ៍មិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងធម្មារម្មណ៍នោះចេញ ។ មនោ-វិញ្ញាណមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ង ក្នុងមនោវិញ្ញាណនោះចេញ ។ មនោសម្ផស្សមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងមនោ-សម្ផស្សនោះចេញ ។ វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះមិនទៀងទេ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងវេទនានោះចេញ ។ ម្នាលកោដ្ឋិកៈ របស់ណាមិនទៀង ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ចប់សូត្រ ទី ៧ ។

នន្ទិក្ខយវគ្គោ បឋមោ

[២៥០] អថខោ ។ បេ ។ វិហរេយ្យន្តិ ។ យំ ខោ កោដ្ឋិត ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ កិញ្ច កោដ្ឋិត ទុក្ខំ ។ ចក្ខុំ ខោ កោដ្ឋិត ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា ទុក្ខា តត្រ តេ ឆន្ទោ បហាតព្វោ ។ ចក្ខុវិញ្ញាណំ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ ចក្ខុសម្ផស្សោ ទុក្ខោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ ជិវ្ហា ទុក្ខា តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ មនោ ទុក្ខោ តត្រ តេ ឆន្ទោ បហាតព្វោ ។ ធម្មា ទុក្ខា តត្រ តេ ឆន្ទោ បហាតព្វោ ។ មនោវិញ្ញាណំ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ មនោសម្ផស្សោ ទុក្ខោ តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

## នន្ទិក្ខយវគ្គ ទី ១

[២៥០] គ្រានោះឯង ។ បេ ។ ម្នាលកោដ្ឋិកៈ របស់ណាជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលកោដ្ឋិកៈ របស់អ្វីជាទុក្ខ ។ ម្នាលកោដ្ឋិកៈ ចក្ខុជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងចក្ខុនោះចេញ ។ រូបជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងរូបនោះចេញ ។ ចក្ខុវិញ្ញាណជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងចក្ខុ-វិញ្ញាណនោះចេញ ។ ចក្ខុសម្ផស្សជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងចក្ខុសម្ផស្សនោះចេញ ។ វេទនាណា ជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះក៏ជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងវេទនានោះចេញ ។ បេ ។ ជិវ្ហាជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងជិវ្ហានោះចេញ ។ បេ ។ មនោជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងមនោនោះចេញ ។ ធម្មារម្មណ៍ជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងធម្មារម្មណ៍នោះចេញ ។ មនោវិញ្ញាណជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងមនោវិញ្ញាណនោះចេញ ។ មនោសម្ផស្សជាទុក្ខ ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ងក្នុងមនោសម្ផស្សនោះចេញ ។ វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះមនោ-

តម្បិ ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ យំ ខោ កោ-ដ្ឋិក ទុក្ខំ តត្រ តេ ឆន្ទោ បហាតព្វោ ។ អដ្ឋមំ ។

[២៤១] ឯកាមន្តំ ។ បេ ។ វិហរេយ្យន្តិ ។ យោ ខោ កោដ្ឋិក អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ កោ ច កោដ្ឋិក អនត្តា ។ ចក្ខុំ ខោ កោដ្ឋិក អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ រូបា អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ ចក្ខុវិញ្ញាណំ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ ចក្ខុសម្ផស្សោ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ ជិវ្ហា អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ បេ ។ មនោ អនត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ ធម្មា អនត្តា

សម្ផស្សជាបច្ច័យ វេទនានោះក៏ជាទុក្ខ ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុង វេទនានោះចេញ ។ ម្នាលកោដ្ឋិកៈ របស់ណាជាទុក្ខ ត្រូវអ្នកលះបង់ សេចក្តីប៉ុនប៉ង់ក្នុងរបស់នោះចេញ ។ ចប់សូត្រ ទី ៨ ។

[២៥១] ក្នុងទីដ៏សមគួរ ។ បេ ។ ម្នាលកោដ្ឋិកៈ សភាវៈណា ជាអនត្តា ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុងសភាវៈចេញ ។ ម្នាល កោដ្ឋិកៈ ចុះសភាវៈដូចម្តេចជាអនត្តា ។ ម្នាលកោដ្ឋិកៈ ចក្ខុជាអនត្តា ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុងចក្ខុនោះចេញ ។ រូបជាអនត្តា ត្រូវអ្នក លះបង់សេចក្តីប៉ុនប៉ង់ក្នុងរូបនោះចេញ ។ ចក្ខុវិញ្ញាណជាអនត្តា ត្រូវ អ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុងចក្ខុវិញ្ញាណនោះចេញ ។ ចក្ខុសម្ផស្សជា អនត្តា ត្រូវអ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុងចក្ខុសម្ផស្សនោះចេញ ។ វេទ- នាណា ជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏ជាអនត្តា ត្រូវអ្នកលះបង់ សេចក្តីប៉ុនប៉ង់ក្នុងវេទនានោះចេញ ។ បេ ។ ជិវ្ហាជាអនត្តា ត្រូវអ្នក លះបង់សេចក្តីប៉ុនប៉ង់ក្នុងជិវ្ហានោះចេញ ។ បេ ។ មនោជាជាអនត្តា ត្រូវ អ្នកលះបង់សេចក្តីប៉ុនប៉ង់ក្នុងមនោនោះចេញ ។ ធម្មារម្មណ៍ជាអនត្តា

តត្រ តេ ឆន្ទោ បហាតព្វោ ។ មនោវិញ្ញាណំ មនោ-
សម្ផស្សោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ
វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អ-
នត្តា តត្រ តេ ឆន្ទោ បហាតព្វោ ។ យោ ខោ ភោជ្ជក
អនត្តា តត្រ តេ ឆន្ទោ បហាតព្វោតិ ។ នវមំ ។

[២៨២] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា
តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ
ភិក្ខុ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ
កថំ បស្សតោ មិច្ឆាទិដ្ឋិ បហិយ្យតីតិ ។ ចក្ខុំ ខោ
ភិក្ខុ អនិច្ចតោ ជានតោ បស្សតោ មិច្ឆាទិដ្ឋិ បហិយ្យ-
តិ ។ រូបេ អនិច្ចតោ ជានតោ បស្សតោ មិច្ឆាទិដ្ឋិ
បហិយ្យតិ ។ ចក្ខុវិញ្ញាណំ អនិច្ចតោ ជានតោ បស្ស-
តោ មិច្ឆាទិដ្ឋិ បហិយ្យតិ ។ ចក្ខុសម្ផស្សំ អនិច្ចតោ
ជានតោ បស្សតោ មិច្ឆាទិដ្ឋិ បហិយ្យតិ ។ បេ ។

ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ង់ក្នុងធម្មារម្មណ៍នោះចេញ ។ មនោវិញ្ញាណ មនោសម្ផស្ស វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិនទុក្ខមិនសុខក្ដី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះក៏ជាអនត្តា ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ង់ក្នុងវេទនានោះចេញ ។ ម្នាលកោដ្ឋិកៈ សង្ខារៈណាជាអនត្តា ត្រូវអ្នកលះបង់សេចក្ដីប៉ុនប៉ង់ក្នុងសង្ខារៈនោះចេញ ។ ចប់សូត្រ ទី ៩ ។

[២៥២] គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្ដេច ឃើញដូចម្ដេច ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ ម្នាលភិក្ខុ កាលបុគ្គលដឹង ឃើញចក្ខុ ថាមិនទៀង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញរូប ថាមិនទៀង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុវិញ្ញាណ ថាមិនទៀង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុសម្ផស្ស ថាមិនទៀង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ បេ ។

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចតោ ជានតោ បស្សតោ មិច្ឆាទិដ្ឋិ បហិយ្យតិ ។ ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ មិច្ឆាទិដ្ឋិ បហិយ្យតីតិ ។ ទសមំ ។

[២៨៣] អថខោ អញ្ញតរោ ភិក្ខុ ។ បេ ។ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតីតិ ។ ចក្ខុំ ខោ ភិក្ខុ ទុក្ខតោ ជានតោ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតិ ។ រូបេ ទុក្ខតោ ជានតោ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតិ ។ ចក្ខុវិញ្ញាណំ ទុក្ខតោ ជានតោ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតិ ។ ចក្ខុសម្ផស្សំ ទុក្ខតោ ជានតោ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ទុក្ខតោ ជានតោ បស្សតោ

វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ កាលបុគ្គលដឹង ឃើញវេទនានោះ ថាមិនទៀង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ ម្នាលភិក្ខុ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ទើបលះបង់មិច្ឆាទិដ្ឋិបាន ។ ចប់សូត្រ ទី ១០ ។

[២៥៣] គ្រានោះឯង ភិក្ខុមួយរូប ។ បេ ។ ក្រាបបង្គំទូលដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបលះបង់សក្កាយទិដ្ឋិបាន ។ ម្នាលភិក្ខុ កាលបុគ្គលដឹង ឃើញចក្ខុ ថាជាទុក្ខ ទើបលះបង់សក្កាយទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញរូប ថាជាទុក្ខ ទើបលះបង់សក្កាយទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុវិញ្ញាណ ថាជាទុក្ខ ទើបលះបង់សក្កាយទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុសម្ផស្សថាជាទុក្ខ ទើបលះបង់សក្កាយទិដ្ឋិបាន ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ កាលបុគ្គលដឹង ឃើញវេទនានោះ ថាជាទុក្ខ

សក្កាយទិដ្ឋិ បហិយ្យតិ ។ ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ សក្កាយទិដ្ឋិ បហិយ្យតីតិ ។ ឯកាទសមំ ។

[២៤៨] អថខោ អញ្ញតរោ ភិក្ខុ ។ បេ ។ ឯតទ-វោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតីតិ ។ ចក្ខុំ ខោ ភិក្ខុ អនត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតិ ។ រូបេ អ-នត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យ-តិ ។ ចក្ខុវិញ្ញាណំ អនត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតិ ។ ចក្ខុសម្ផស្សំ អនត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតិ ។ យម្បិ-ទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តតោ ជា-នតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតិ ។ បេ ។ ជិវ្ហំ អនត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតិ ។ បេ ។ មនំ អនត្តតោ ជានតោ បស្សតោ អត្តានុ-ទិដ្ឋិ បហិយ្យតិ ។ ធម្មេ មនោវិញ្ញាណំ មនោសម្ផស្សំ

ទើបលះបង់សក្កាយទិដ្ឋិបាន ។ ម្នាលភិក្ខុ កាលបុគ្គល ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ទើបលះបង់សក្កាយទិដ្ឋិបាន ។ ចប់សូត្រ ទី ១១ ។

[២៥៤] គ្រានោះឯង ភិក្ខុមួយរូប ។ បេ ។ ក្រាបបង្គំទូលសួរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច ទើបលះបង់អត្តានុទិដ្ឋិបាន ។ ម្នាលភិក្ខុ កាលបុគ្គលដឹង ឃើញចក្ខុ ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញរូប ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុវិញ្ញាណ ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ កាលបុគ្គលដឹង ឃើញចក្ខុសម្ផស្ស ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុ-សម្ផស្សជាបច្ច័យ កាលបុគ្គលដឹង ឃើញវេទនានោះ ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ បេ ។ កាលបុគ្គលដឹង ឃើញជិវ្ហា ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ បេ ។ កាលបុគ្គលដឹង ឃើញចិត្ត ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ ធម្មារម្មណ៍ មនោវិញ្ញាណ មនោសម្ផស្ស

យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនត្តតោ ជានតោ បស្សតោ អត្តានុទិដ្ឋិ បហិយ្យតីតិ ។ ទ្វាទសមំ ។

នន្ទិក្ខយវគ្គោ បឋមោ ។

## តស្សុទ្ទានំ

នន្ទិក្ខយេន ចត្តារោ
ជីវកម្ពវនេ ទុវេ
កោដ្ឋិកេន តយោ វុត្តា
មិច្ឆាសក្កាយ អត្តនោតិ ។

---

*វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ កាលបុគ្គលដឹង ឃើញវេទនានោះ ថាជាអនត្តា ទើបលះបង់អត្តានុទិដ្ឋិបាន ។ ចប់សូត្រ ទី ១២ ។*

ចប់ នន្ទិក្ខយវគ្គ ទី ១ ។

## ឧទ្ទាននៃនន្ទិក្ខយវគ្គនោះ គឺ

*ទ្រង់សម្តែងនន្ទិក្ខយៈ ៤ លើក ក្នុងជីវកម្ពវ័ន ២ លើក កោដ្ឋិកត្ថេរ ៣ លើក មិច្ឆាទិដ្ឋិ ១ សក្កាយទិដ្ឋិ ១ អត្តានុទិដ្ឋិ ១។*

---

# សឡ្វីបេយ្យាលោ

[២៨៨] យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហា-
តព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ ។ ចក្ខុំ ភិក្ខវេ អនិច្ចំ
តត្រ វោ ឆន្ទោ បហាតព្វោ ។ បេ ។ ជិវ្ហា អនិច្ចា តត្រ
វោ ឆន្ទោ បហាតព្វោ ។ បេ ។ មនោ អនិច្ចោ តត្រ វោ
ឆន្ទោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ
បហាតព្វោតិ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ រាគោ ប-
ហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ ។ ចក្ខុំ ភិក្ខវេ អនិច្ចំ
តត្រ វោ រាគោ បហាតព្វោ ។ បេ ។ ជិវ្ហា អនិច្ចា តត្រ
វោ រាគោ បហាតព្វោ ។ បេ ។ មនោ អនិច្ចោ តត្រ
វោ រាគោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ
រាគោ បហាតព្វោតិ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ

# សង្ខេបយ្យាល

[២៥៥] ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្ដីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំង-ឡាយ របស់អ្វីមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្ដីប៉ុនប៉ងក្នុងចក្ខុនោះចេញ ។ បេ ។ ជិវ្ហាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្ដីប៉ុនប៉ងក្នុងជិវ្ហានោះចេញ ។ បេ ។ មនោ-មិនទៀង ត្រូវអ្នកទាំងឡាយ លះបង់សេចក្ដីប៉ុនប៉ងក្នុងមនោនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណា មិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្ដីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់តម្រេកក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់អ្វីដែលមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀង ត្រូវអ្នកទាំងឡាយលះបង់តម្រេកក្នុងចក្ខុនោះចេញ ។ បេ ។ ជិវ្ហាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់តម្រេកក្នុងជិវ្ហានោះចេញ ។ បេ ។ មនោមិនទៀង ត្រូវអ្នកទាំងឡាយលះបង់តម្រេកក្នុងមនោនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណា មិនទៀង ត្រូវអ្នកទាំងឡាយលះបង់តម្រេកក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង

ឆន្ទរាគោ បហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ ។ ចក្ខុំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទរាគោ បហាតព្វោ ។ បេ ។ ជិវ្ហា អនិច្ចា តត្រ វោ ឆន្ទរាគោ បហាតព្វោ ។ បេ ។ មនោ អនិច្ចោ តត្រ វោ ឆន្ទរាគោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទរាគោ បហាតព្វោតិ ។

[២៨៦] យំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កិញ្ច ភិក្ខវេ ទុក្ខំ ។ ចក្ខុំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ បេ ។ ជិវ្ហា ទុក្ខា ។ បេ ។ មនោ ទុក្ខោ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

ត្រូវអ្នកទាំងឡាយលះបង់ឆន្ទរាគក្នុងរបស់នោះចេញ ។ ម្នាលភិក្ខុទាំង-ឡាយ របស់ដែលមិនទៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀង ត្រូវអ្នកទាំងឡាយលះបង់ឆន្ទរាគក្នុងចក្ខុនោះចេញ ។ បេ ។ ជិវ្ហាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់ឆន្ទរាគក្នុងជិវ្ហានោះចេញ ។ បេ ។ មនោមិនទៀង ត្រូវអ្នកទាំងឡាយលះបង់ឆន្ទរាគក្នុងមនោនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់ឆន្ទ-រាគក្នុងរបស់នោះចេញ ។

[២៥៦] ម្នាលភិក្ខុទាំងឡាយ របស់ណាជាទុក្ខ ត្រូវអ្នកទាំង-ឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ អ្វីជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងចក្ខុនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ បេ ។ ជិវ្ហាជាទុក្ខ ។ បេ ។ មនោជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងមនោនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។

សង្ខីបេយ្យាលោ ទុតិយោ

[២៥៧] យោ ភិក្ខវេ អជ្ឈត្តា តត្រ ភវោ ឆន្ទោ បហា-
តព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។
កោ ច ភិក្ខវេ អជ្ឈត្តា ។ ចក្ខុំ ភិក្ខវេ អជ្ឈត្តា តត្រ ភវោ
ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ
បហាតព្វោ ។ បេ ។ ឃានំ អជ្ឈត្តា តត្រ ភវោ ឆន្ទោ បហា-
តព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។
ជិវ្ហា អជ្ឈត្តា តត្រ ភវោ ឆន្ទោ បហាតព្វោ ។ រាគោ
បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ បេ ។ មនោ អ-
ជ្ឈត្តា តត្រ ភវោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។
ឆន្ទរាគោ បហាតព្វោ ។ យោ ភិក្ខវេ អជ្ឈត្តា តត្រ ភវោ
ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ
បហាតព្វោតិ ។

សឋ្ឋីបេយ្យាល ទី ២

[២៩៧] ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងសភាវៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈដូចម្តេចជាអនត្តា ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងចក្ខុនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ បេ ។ ឃានៈជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងឃានៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទ-រាគ ។ ជិវ្ហាជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងជិវ្ហានោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ បេ ។ មនោជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងមនោនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង់ក្នុងសភាវៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។

[២៤៨] យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កិញ្ច ភិក្ខវេ អនិច្ចំ ។ រូបា ភិក្ខវេ អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ សទ្ទា អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ គន្ធា អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ រសា អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ ផោដ្ឋព្វា អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ ធម្មា អនិច្ចា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យំ ភិក្ខវេ អនិច្ចំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

[២៥៨] ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ របស់ដែលមិនទៀង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ សំឡេងមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងសំឡេងនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ក្លិនមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងក្លិននោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ រសមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរសនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ផោដ្ឋព្វៈមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងផោដ្ឋព្វៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ធម្មារម្មណ៍មិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងធម្មារម្មណ៍នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាមិនទៀង ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។

## សដ្ឋីបេយ្យាលោ ទុតិយោ

[២៤៩] យំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កិញ្ច ភិក្ខវេ ទុក្ខំ ។ រូបា ភិក្ខវេ ទុក្ខា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យំ ភិក្ខវេ ទុក្ខំ តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

សដ្ឋីបេយ្យាល ទី ២

[២៥៩] ម្នាលភិក្ខុទាំងឡាយ របស់ណាជាទុក្ខ ត្រូវអ្នកទាំង-ឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ របស់ដូចម្តេចដែលជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងធម្មារម្មណ៍នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទ-រាគ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាជាទុក្ខ ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរបស់នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។

[២៦០] យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ កោ ច ភិក្ខវេ អនត្តា ។ រូបំ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោ ។ យោ ភិក្ខវេ អនត្តា តត្រ វោ ឆន្ទោ បហាតព្វោ ។ រាគោ បហាតព្វោ ។ ឆន្ទរាគោ បហាតព្វោតិ ។

[២៦១] ចក្ខុំ ភិក្ខវេ អនិច្ចំ អតីតំ ។ បេ ។ ជិវ្ហា អនិច្ចា អតីតា ។ បេ ។ មនោ អនិច្ចោ អតីតោ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ ។ បេ ។ ជិវ្ហាយបិ និព្វិន្ទតិ ។ បេ ។ មនស្មឹបិ និព្វិន្ទតិ

[២៦០] ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងសភាវៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈជាអនត្តាតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងរូបនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ងក្នុងធម្មារម្មណ៍នោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាអនត្តា ត្រូវអ្នកទាំងឡាយលះបង់សេចក្តីប៉ុនប៉ង ក្នុងសភាវៈនោះចេញ ។ ត្រូវលះបង់រាគៈ ។ ត្រូវលះបង់ឆន្ទរាគ ។

[២៦១] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីតមិនទៀង ។ បេ ។ ជិវ្ហាជាអតីតមិនទៀង ។ បេ ។ មនោជាអតីតមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវកអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងចក្ខុផង ។ បេ ។ នឿយណាយនឹងជិវ្ហាផង ។ បេ ។ នឿយ

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញា-
ណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ
ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦២] ចក្ខុំ ភិក្ខវេ អនិច្ចំ អនាគតំ ។ បេ ។
ជិវ្ហា អនិច្ចា អនាគតា ។ បេ ។ មនោ អនិច្ចោ អនា-
គតោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជា-
នាតីតិ ។

[២៦៣] ចក្ខុំ ភិក្ខវេ អនិច្ចំ បច្ចុប្បន្នំ ។ បេ ។
ជិវ្ហា អនិច្ចា បច្ចុប្បន្នា ។ បេ ។ មនោ អនិច្ចោ បច្ចុ-
ប្បន្នោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជា-
នាតីតិ ។

ណាយនឹងចិត្តផង កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦២] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអនាគតមិនទៀង ។ បេ ។ ជិវ្ហាជាអនាគតមិនទៀង ។ បេ ។ មនោជាអនាគតមិនទៀង ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៣] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាបច្ចុប្បន្នមិនទៀង ។ បេ ។ ជិវ្ហាជាបច្ចុប្បន្នមិនទៀង ។ បេ ។ មនោជាបច្ចុប្បន្នមិនទៀង ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៤] ចក្ខុំ ភិក្ខវេ ទុក្ខំ អតីតំ អនាគតំ បច្ចុប្បន្នំ ។ បេ ។ ជិវ្ហា ទុក្ខា អតីតា អនាគតា បច្ចុប្បន្នា ។ បេ ។ មនោ ទុក្ខោ អតីតោ អនាគតោ បច្ចុប្បន្នោ ។ ឯវំ បស្សំ ភិក្ខវេ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦៥] ចក្ខុំ ភិក្ខវេ អនត្តា អតីតំ អនាគតំ បច្ចុប្បន្នំ ។ បេ ។ ជិវ្ហា អនត្តា ។ បេ ។ មនោ អនត្តា អតីតោ អនាគតោ បច្ចុប្បន្នោ ។ ឯវំ បស្សំ ភិក្ខវេ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦៦] រូបា ភិក្ខវេ អនិច្ចា អតីតា អនាគតា បច្ចុប្បន្នា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា អតីតា អនាគតា បច្ចុប្បន្នា ។ ឯវំ បស្សំ ភិក្ខវេ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦៤] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ បេ ។ ជិវ្ហាជាអតីត អនាគត និងបច្ចុប្បន្នជាទុក្ខ ។ បេ ។ មនោ ជាអតីត អនាគត និងបច្ចុប្បន្នជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្ត ទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៥] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីត អនាគត និងបច្ចុប្បន្ន ជាអនត្តា ។ បេ ។ ជិវ្ហាជាអនត្តា ។ បេ ។ មនោជាអតីត អនាគត និងបច្ចុប្បន្នជាអនត្តា ។ ម្នាលភិក្ខុទាំងឡាយ កាលបើឃើញយ៉ាង នេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បី សោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៦] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀង ។ សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្នមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើឃើញ យ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

សដ្ឋីបេយ្យាលោ ទុតិយោ

[២៦៧] រូបា ភិក្ខវេ ទុក្ខា អតីតា អនាគតា បច្ចុប្បន្នា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា អតីតា អនាគតា បច្ចុប្បន្នា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦៨] រូបា ភិក្ខវេ អនត្តា អតីតា អនាគតា បច្ចុប្បន្នា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា អតីតា អនាគតា បច្ចុប្បន្នា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៦៩] ចក្ខុំ ភិក្ខវេ អនិច្ចំ អតីតំ ។ យំ អនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា អនិច្ចា អតីតា ។ យទ-

សង្ខិត្តបេយ្យាល ទី ២

[២៦៧] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្នជាទុក្ខ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៨] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន ជាអនត្តា ។ សំឡេង ក្លិន រស ផោដ្ឋព្វៈនិងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្នជាអនត្តា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៦៩] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីតមិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ជិវ្ហាជាអតីតមិនទៀង ។ របស់ណា

និច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ មនោ អនិច្ចោ អតីតោ ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧០] ចក្ខុំ ភិក្ខវេ អនិច្ចំ អនាគតំ ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា អនិច្ចា អនាគតា

មិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ មនោជាអតីតមិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។

[១៧០] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអនាគត មិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ជិវ្ហាជាអនាគត មិនទៀង

៣៥១



យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ មនោ អនិច្ចោ អនាគ-តោ ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ឯវំ បស្សំ ភិក្ខវេ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

សង្ខិត្តបេយ្យាល ទី ២

របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ មនោជាអនាគតមិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧១] ចក្ខុំ ភិក្ខវេ អនិច្ចំ បច្ចុប្បន្នំ ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា អនិច្ចា បច្ចុប្បន្នា ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧១] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាបច្ចុប្បន្ន មិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនជារបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ជិវ្ហាជាបច្ចុប្បន្នមិនទៀង ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

សឡឹបេយ្យាលោ ទុតិយោ

[២៧២] ចក្ខុំ ភិក្ខវេ ទុក្ខំ អតីតំ អនាគតំ បច្ចុ-
ប្បន្នំ ។ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម
នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ
សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា ទុក្ខា ។ បេ ។ ម-
នោ ទុក្ខោ អតីតោ អនាគតោ បច្ចុប្បន្នោ ។ យំ ទុក្ខំ
តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន
មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋ-
ព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានា-
តីតិ ។

សដ្ឋីបេយ្យាល ទី ២

[២៧២] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ជិវ្ហាជាទុក្ខ ។ បេ ។ មនោជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៣] ចក្ខុំ ភិក្ខវេ អនត្តា អតីតំ អនាគតំ បច្ចុប្បន្នំ ។ យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ បេ ។ ជិវ្ហា អនត្តា ។ បេ ។ មនោ អនត្តា អតីតោ អនាគតោ បច្ចុប្បន្នោ ។ យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថា-ភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧៤] រូបា ភិក្ខវេ អនិច្ចា អតីតា អនាគតា បច្ចុប្បន្នា ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា អតីតា អនា-គតា បច្ចុប្បន្នា ។ យទនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តទ-

[២៧៣] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអតីត អនាគត និង បច្ចុប្បន្នជាអនត្តា ។ របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញទេ នុ៎ះ មិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ បេ ។ ជិវ្ហាជាអនត្តា ។ បេ ។ មនោជាអតីត អនាគត និងបច្ចុប្បន្នជាអនត្តា ។ របស់ណាជា អនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាង នេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជា ខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គ-ភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៤] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀងទេ ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញ ដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញទេ នុ៎ះ មិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្ន មិនទៀងទេ ។ របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះ

សដ្ឋីបេយ្យាលោ ទុតិយោ

នត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧៨] រូបា ភិក្ខវេ ទុក្ខា អតីតា អនាគតា បច្ចុប្បន្នា ។ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា អតីតា អនាគតា បច្ចុប្បន្នា ។ យំ ទុក្ខំ តទនត្តា យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

ជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញដោយប្រាជ្ញា ដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៥] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្ន ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនា-កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៦] រូបា ភិក្ខវេ អនត្តា អតីតា អនាគតា បច្ចុប្បន្នា ។ យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា អតីតា អនាគតា បច្ចុប្បន្នា ។ យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧៧] ចក្ខុំ ភិក្ខវេ អនិច្ចំ ។ បេ ។ ជិវ្ហា អនិច្ចា ។ បេ ។ មនោ អនិច្ចោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧៨] ចក្ខុំ ភិក្ខវេ ទុក្ខំ ។ បេ ។ ជិវ្ហា ទុក្ខា ។

[២៧៦] ម្នាលភិក្ខុទាំងឡាយ រូបជាអតីត អនាគត និងបច្ចុប្បន្ន ជាអនត្តា ។ របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអតីត អនាគត និងបច្ចុប្បន្ន ជាអនត្តា ។ របស់ណាជាអនត្តា របស់នោះបណ្ឌិតត្រូវឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៧] ម្នាលភិក្ខុទាំងឡាយ ចក្ខុមិនទៀង ។ បេ ។ ជិវ្ហាមិនទៀង ។ បេ ។ មនោមិនទៀង ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

កាយោ ទុក្ខោ ។ មនោ ទុក្ខោ ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៧៩] ចក្ខុំ ភិក្ខវេ អនត្តា ។ បេ ។ ជិវ្ហា អនត្តា ។ កាយោ អនត្តា ។ មនោ អនត្តា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៨០] រូបា ភិក្ខវេ អនិច្ចា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនិច្ចា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៨១] រូបា ភិក្ខវេ ទុក្ខា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា ទុក្ខា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

សដ្ឋីបេយ្យាល ទី ២

[២៧៨] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាទុក្ខ ។ បេ ។ ជិវ្ហាជាទុក្ខ ។ កាយជាទុក្ខ ។ មនោជាទុក្ខ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៧៩] ម្នាលភិក្ខុទាំងឡាយ ចក្ខុជាអនត្តា ។ បេ ។ ជិវ្ហាជាអនត្តា ។ កាយជាអនត្តា ។ មនោជាអនត្តា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៨០] ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ មិនទៀង ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៨១] ម្នាលភិក្ខុទាំងឡាយ រូបជាទុក្ខ ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាទុក្ខ ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៨២] រូបា ភិក្ខវេ អនត្តា ។ សទ្ទា គន្ធា រសា ផោដ្ឋព្វា ធម្មា អនត្តា ។ ឯវំ បស្សំ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

សដ្ឋីបេយ្យាលោ ទុតិយោ សមត្តោ ។

តស្សុទ្ទានំ

ឆន្ទេនដ្ឋារសា ហោន្តិ
អតីតេន ច ទ្វេ នវ
យទនិច្ចាដ្ឋារសា វុត្តា
តយោ អជ្ឈត្តពាហិរា
បេយ្យាលោ សដ្ឋិកោ វុត្តោ
ពុទ្ធេនាទិច្ចពន្ធុនាតិ ។

សុត្តន្តានិ សដ្ឋី ។

---

[២៨២] ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ។ សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ជាអនត្តា ។ កាលបើឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ច នេះទៀត មិនមានឡើយ ។

ចប់ សដ្ឋីបេយ្យាល ទី ២ ។

## ឧទ្ទាននៃសដ្ឋីបេយ្យាលនោះ គឺ

ទ្រង់សម្តែងអំពីឆន្ទៈគួរលះបង់ ១៨ លើក អាយតនៈជាអតីត ២ លើកផង ៩ លើកផង ទ្រង់សម្តែងអនិច្ចធម៌ ១៨ លើក អាយតនៈខាងក្នុងនិងខាងក្រៅ ៣ លើក សដ្ឋីបេយ្យាល គឺ ព្រះពុទ្ធជាពូជពង្សនៃព្រះអាទិត្យបានត្រាស់ហើយ ។

ចប់ សូត្រ ៦០ ។

---

# សមុទ្ទវគ្គោ

[២៨៣] សមុទ្ទោ សមុទ្ទោតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ភាសតិ ។ នេសោ ភិក្ខវេ អរិយស្ស វិនយេ សមុទ្ទោ ។ មហា ឯសោ ភិក្ខវេ ឧទករាសិ មហា-ឧទកណ្ណវោ ។ ចក្ខុំ ភិក្ខវេ បុរិសស្ស សមុទ្ទោ តស្ស រូបមយោ វេគោ យោ តំ រូបមយំ វេគំ សហតិ អយំ វុច្ចតិ ភិក្ខវេ អតរិ ចក្ខុសមុទ្ទំ សឧម្មឹ សាវដ្ដំ សគ្គា-ហំ សរក្ខសំ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្ម-ណោ ។ បេ ។ ជិវ្ហា ភិក្ខវេ បុរិសស្ស សមុទ្ទោ តស្ស រសមយោ វេគោ យោ តំ រសមយំ វេគំ សហតិ អយំ វុច្ចតិ ភិក្ខវេ អតរិ ជិវ្ហាសមុទ្ទំ សឧម្មឹ សាវដ្ដំ

# សមុទ្ទវគ្គ

[២៨៣] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនចេះដឹង រមែងពោលថា សមុទ្ទ សមុទ្ទ ។ ម្នាលភិក្ខុទាំងឡាយ សមុទ្ទនុ៎ះ មិនមែនជាសមុទ្ទក្នុងវិន័យរបស់ព្រះអរិយៈទេ ។ ម្នាលភិក្ខុទាំងឡាយ សមុទ្ទនុ៎ះ សំដៅយកជារទឹកដ៏ធំនិងអន្លង់ទឹកដ៏ជ្រៅ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុជាសមុទ្ទរបស់បុរស កម្លាំងនៃចក្ខុនោះសម្រេចដោយរូប បុគ្គលណាគ្របសង្កត់កម្លាំង ដែលសម្រេចដោយរូបនោះបាន ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថាព្រាហ្មណ៍ បានឆ្លងនូវសមុទ្ទគឺចក្ខុ ដែលប្រកបដោយរលកគឺកិលេស ប្រកបដោយទឹកវល់គឺកិលេស ប្រកបដោយសត្វសាហាវគឺកិលេស ប្រកបដោយអារក្សទឹកគឺកិលេស បានឆ្លងដល់ទៅត្រើយនាយ ឈរនៅលើគោកគឺព្រះនិព្វាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ជិវ្ហាជាសមុទ្ទរបស់បុរស កម្លាំងនៃសមុទ្ទគឺជិវ្ហានុ៎ះ សម្រេចដោយរស បុគ្គលណាគ្របសង្កត់នូវកម្លាំង (នៃសមុទ្ទគឺជិវ្ហា) សម្រេចដោយរសនោះបាន ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថាព្រាហ្មណ៍

សគ្គាហំ សរក្ខសំ តិណ្ណោ ចារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ បេ ។ មនោ ភិក្ខវេ បុរិសស្ស សមុទ្ទោ តស្ស ធម្មមយោ វេគោ យោ តំ ធម្មមយំ វេគំ សហតិ អយំ វុច្ចតិ ភិក្ខវេ អតរិ មនោសមុទ្ទំ សឱម្មឹ សាវដ្ដំ សគ្គាហំ សរក្ខសំ តិណ្ណោ ចារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ ឥទមវោច ។ បេ ។ សត្ថា

[២៨៤] យោ ឥមំ សមុទ្ទំ
សគ្គាហំ សរក្ខសំ
សឱម្មឹ ភយំ ទុត្តរំ អច្ចតរិ
សវេទគូ វុសិតព្រហ្មចរិយោ
លោកន្តគូ ចារគតោតិ វុច្ចតីតិ ។

បានឆ្លងនូវសមុទ្ទគឺជិវ្ហា ដែលប្រកបដោយរលក ប្រកបដោយទឹកវល់ ប្រកបដោយសត្វសាហាវ ប្រកបដោយអារក្សទឹក ឆ្លងទៅដល់ត្រើយ នាយ ហើយឈរនៅលើគោក ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មនោជា សមុទ្ទរបស់បុរស កម្លាំងនៃសមុទ្ទគឺមនោនោះ សម្រេចដោយធម្មារម្មណ៍ បុគ្គលណា គ្របសង្កត់នូវកម្លាំង (នៃសមុទ្ទគឺមនោ) សម្រេចដោយ ធម្មារម្មណ៍នោះបាន ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា ព្រាហ្មណ៍ បានឆ្លងនូវសមុទ្ទគឺមនោ ដែលប្រកបដោយរលក ប្រកប ដោយទឹកវល់ ប្រកបដោយសត្វសាហាវ ប្រកបដោយអារក្សទឹក ឆ្លង ដល់ត្រើយ ហើយឈរនៅលើគោក ។ ព្រះសាស្តាទ្រង់ត្រាស់សូត្រ នេះចប់ហើយ ។ បេ ។

[២៨២] បុគ្គលណាបានឆ្លងសមុទ្ទដែលប្រកបដោយសត្វ
សាហាវ ប្រកបដោយអារក្សទឹក ប្រកបដោយរលក ប្រកប
ដោយភ័យ ដែលឆ្លងបានដោយកម្រនេះបាន បុគ្គលនេះ
តថាគតហៅថា អ្នកប្រកបដោយការចេះត្រៃវេទ មាន
ព្រហ្មចរិយៈ នៅរួចហើយ ដល់នូវទីបំផុតនៃលោក ដល់
នូវត្រើយគឺព្រះនិព្វាន ។

៣៦១

សមុទ្ទវគ្គោ តតិយោ

[២៨៤] សមុទ្ទោ សមុទ្ទោតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ភាសតិ ។ នេសោ ភិក្ខវេ អរិយស្ស វិនយេ សមុទ្ទោ ។ មហា ឯសោ ភិក្ខវេ ឧទករាសិ មហា ឧទកណ្ណវោ ។ សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា អយំ វុច្ចតិ ភិក្ខវេ អរិយស្ស វិនយេ សមុទ្ទោ ឯត្ថាយំ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា យេភុយ្យេន សមុន្នា តន្តាកុលកជាតា កុលគុណ្ឋិកជាតា មុញ្ជបព្វជភូតា អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តន្តិ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា

## សមុទ្ទវគ្គ ទី ៣

[២៨៥] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនជាអ្នកមិនចេះដឹង រមែងពោលថា សមុទ្ទ សមុទ្ទ ។ ម្នាលភិក្ខុទាំងឡាយ សមុទ្ទនុ៎ះ មិនមែនជាសមុទ្ទក្នុងវិន័យរបស់ព្រះអរិយៈទេ ។ ម្នាលភិក្ខុទាំងឡាយ សមុទ្ទនុ៎ះ សំដៅយកធារទឹកដ៏ធំនិងអន្លង់ទឹកដ៏ជ្រៅ ។ ម្នាលភិក្ខុទាំងឡាយ រូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាសមុទ្ទក្នុងវិន័យនៃព្រះអរិយៈ សត្វលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ព្រមទាំងសមណៈនិងព្រាហ្មណ៍ ពពួកសត្វ ព្រមទាំងទេវតានិងមនុស្សដ៏សេស ច្រើនលិចចុះក្នុងសមុទ្ទនេះ ទទឹក រីកវរ ស្មុគស្មាញ ដូចជាស្មៅយាប្លង់និងស្មៅដំណេកទន្សាយ មិនកន្លងផុតនូវអបាយ ទុគ្គតិ វិនិបាត សង្សារ បានឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ រសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ធម្មារម្មណ៍ដែលត្រូវដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម

វេជនីយា អយំ វុច្ចតិ ភិក្ខវេ អរិយស្ស វិនយេ សមុទ្ទោ ឯត្ថាយំ សទេវកោ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា យេភុយ្យេន សមុន្នា តន្តាកុលកជាតា កុលគុណ្ឋិកជាតា មុញ្ជបព្វជភូតា អបាយំ ទុគ្គតឹ វិនិបាតំ សំសារំ នាតិវត្តន្តីតិ ។

[២៨៦] យស្ស រាគោ ច ទោសោ ច
អវិជ្ជា ច វិរាជិតា
សោ ឥមំ សមុទ្ទំ សគ្គាហំ
សរក្ខសំ សឩម្មិភយំ
សុទុត្តរំ អច្ចតរិ ។
សង្គាតិគោ[១] មច្ចុជហោ
និរូបធិ បហាសិ ទុក្ខំ[២]
អបុនព្ភវាយ អត្ថង្គតោ
សោ ន បមានមេតិ[៣]
អមោហយី មច្ចុរាជន្តិ ព្រូមីតិ ។

---

១ ឱ. សង្គាតិកោ; ម. សង្គាតិគោ ។ ២ បហាយ ទុក្ខំ ។ ៣ សោ ន បុនេតិ ។

គួរជាទីរីករាយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថាសមុទ្រក្នុងវិន័យរបស់ព្រះអរិយៈ ឯសត្វលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ព្រមទាំងសមណៈនិងព្រាហ្មណ៍ ពពួកសត្វ ព្រមទាំងទេវតានិងមនុស្សដ៏សេស ច្រើនតែលិចចុះក្នុងសមុទ្រនេះ ទទឹក រឹករវ ស្មុគស្មាញ ដូចជាស្មៅយាប្លង់និងស្មៅដំណេកទន្សាយ មិនកន្លងនូវអបាយ ទុគ្គតិ វិនិបាត សង្សារ បានឡើយ ។

[២៨៦] បុគ្គលណា មានរាគៈទោសៈនិងអវិជ្ជាប្រាសចេញហើយ បុគ្គលនោះ បានឆ្លងនូវសមុទ្រនេះ ដែលប្រកបដោយសត្វសាហាវ ប្រកបដោយអារក្សទឹក ប្រកបដោយរលក ប្រកបដោយភ័យ ដែលមិនងាយនឹងឆ្លងបាន បុគ្គលណាកន្លងបង់នូវគ្រឿងជាប់ចំពាក់ លះបង់នូវចក្ខុ មិនមានឧបធិ បំផ្លាញនូវសេចក្តីទុក្ខ ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន តថាគតពោលថាបុគ្គលនោះ សម្រេចប្រយោជន៍ មិនមកកាន់ភពថ្មីទៀត ជាអ្នកញ៉ាំងមច្ចុរាជឲ្យវង្វេង ។

[២៨៧] សេយ្យថាបិ ភិក្ខវេ ពាឡិសិកោ អាមិសគតំ ពឡិសំ គម្ភីរេ ឧទករហទេ បក្ខិបេយ្យ តមេនំ អញ្ញតរោ អាមិសចក្ខុ មច្ឆោ គិលេយ្យ ឯវំ ហិ សោ ភិក្ខវេ មច្ឆោ គិលពឡិសោ[១] ពាឡិសិកស្ស អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករណីយោ ពាឡិសិកស្ស ។ ឯវមេវ ខោ ភិក្ខវេ ឆយិមេ ពឡិសា លោកស្មឹ អនយាយ សត្តានំ វធាយ[២] បាណីនំ ។ កតមេ ឆ ។ សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ គិលពឡិសោ មារស្ស អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា

១ គិលិតពឡិសោ ។ ២ ឱ. ព្យាទាធាយ បាណិនំ ។

សមុទ្ទវគ្គ ទី ៣

[២៨៧] ម្នាលភិក្ខុទាំងឡាយ ដូចព្រានសន្ទូចបោះសន្ទូចដែលជាប់ដោយនុយទៅក្នុងអន្លង់ទឹកដ៏ជ្រៅ ត្រីមួយឃើញនុយ ក៏លេបនុយនោះទៅ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ត្រីដែលលេបសន្ទូចនោះ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃនៃព្រានសន្ទូច គួរព្រានសន្ទូចធ្វើតាមសេចក្តីប្រាថ្នា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សន្ទូចទាំង ៦ នេះប្រព្រឹត្តទៅ ដើម្បីធ្វើពួកសត្វឲ្យវិនាស ដើម្បីសម្លាប់ពួកសត្វក្នុងលោក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សន្ទូចទាំង ៦ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មានរូបដែលត្រូវដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ប្រសិនបើភិក្ខុត្រេកអរសរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា អ្នកលេបសន្ទូចរបស់មារ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស គួរមារមានចិត្តបាបធ្វើតាមសេចក្តីប្រាថ្នាបាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ

ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ តិលពទ្ធិសោ មារស្ស អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករ-ណីយោ បាបិមតោ ។

[២៨៨] សន្តិ ភិក្ខវេ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន តិលពទ្ធិសោ មារស្ស អភេទិ ពឡិសំ បរិភេទិ ពឡិសំ ន អនយំ អាបន្នោ ន ព្យសនំ អាបន្នោ ន យថាកាមករណីយោ បាបិមតោ ។ បេ ។ សន្តិ ភិក្ខវេ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ សន្តិ ភិក្ខវេ មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា

គួរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ បើភិក្ខុត្រេកអរ សរសើរ ឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា អ្នកលេបសន្ទូចរបស់មារ ដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស គួរមារមានចិត្តបាបធ្វើតាមសេចក្តីប្រាថ្នាបាន ។

[២៨៨] ម្នាលភិក្ខុទាំងឡាយ មានរូបដែលត្រូវដឹងដោយចក្ខុ គួរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ បើភិក្ខុមិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះរូបនោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា មិនលេបសន្ទូចទេ បានកាច់បំបាក់សន្ទូច ផ្តាច់សន្ទូចរបស់មារ មិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស មារមានចិត្តបាបមិនគួរធ្វើតាមសេចក្តីប្រាថ្នាបាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានរសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ គួរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ

តញ្ចេ ភិក្ខុ ន អភិនន្ទតិ ន អភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ន តិលពឡិសោ មារស្ស អភេទិ ពឡិសំ បរិភេទិ ពឡិសំ ន អនយំ អាបន្នោ ន ព្យសនំ អាបន្នោ ន យថាកាមករណីយោ ចាបិមតោតិ ។

[២៨៩] យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ចក្ខុវិញ្ញេយ្យេសុ រូបេសុ យោ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ តស្ស បរិត្តា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ បរិយាទិយន្តេវស្ស ចិត្តំ ។ កោ បន វាទោ អធិមត្តានំ ។ តំ

សមុទ្ទវគ្គ ទី ៣

បើភិក្ខុ មិនត្រេកអរ មិនសរសើរ មិនឋិតនៅដោយសេចក្តីចូលចិត្តមាំ ចំពោះធម្មារម្មណ៍នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគត ហៅថាអ្នកមិនលេបសន្ទូច បានកាច់បំបាក់សន្ទូច បានផ្តាច់សន្ទូចរបស់ មារ មិនដល់នូវសេចក្តីមិនចម្រើន មិនដល់នូវសេចក្តីវិនាស មារមាន ចិត្តបាប មិនគួរធ្វើតាមសេចក្តីប្រាថ្នាបានឡើយ ។

[២៨៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មានរាគៈ (តម្រេក) ទោសៈ (សេចក្តីប្រទូស្ត) មោហៈ (សេចក្តី វង្វេង) ក្នុងរូបដែលត្រូវដឹងដោយចក្ខុ រាគៈ ទោសៈ មោហៈ បុគ្គលនោះ មិនបានលះបង់ចោលទេ ប្រសិនបើរូបដែលត្រូវដឹងដោយចក្ខុ ជារូបមាន ប្រមាណតិច មកកាន់គន្លងចក្ខុ របស់បុគ្គលនោះ គ្របសង្កត់ចិត្តរបស់ បុគ្គលនោះ ។ ក៏នឹងបាច់ពោលទៅថ្វី ដល់រូបដ៏ក្រៃលែង ។ សេចក្តីនោះ

កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា មនោវិញ្ញេយ្យេសុ ធម្មេសុ យោ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ តស្ស បរិត្តា ចេបិ មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ បរិយាទិយន្តេវស្ស ចិត្តំ ។ កោ បន វាទោ អធិមត្តានំ ។ តំ កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ ។

ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ មោហៈ នៅមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មានរាគៈ ទោសៈ មោហៈ ក្នុងធម្មារម្មណ៍ ដែលត្រូវដឹងដោយមនោ រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោលទេ ប្រសិនបើធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ ជាធម្មារម្មណ៍មានប្រមាណតិច មកកាន់គន្លងមនោរបស់បុគ្គលនោះ គ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។ ក៏នឹងបាច់ពោលទៅថ្វី ដល់ធម្មារម្មណ៍ដ៏ក្រៃលែង ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ មោហៈ នៅមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោល ។

សមុទ្ទវគ្គោ តតិយោ

[២៩០] សេយ្យថាបិ ភិក្ខវេ ខីររុក្ខោ អស្សត្ថោ វា និគ្រោធោ វា មិលក្ខុ[១] វា ឧទុម្ពរោ វា ទហរោ តរុ-ណោ កោមារកោ តមេនំ បុរិសោ តិណ្ហាយ កុធារិយា យតោ យតោ ភិន្ទេយ្យ[២] អាគច្ឆេយ្យ ខីរន្តិ ។ ឯវំ ភន្តេ ។ តំ កិស្ស ហេតុ ។ យំ ហិ ភន្តេ ខីរំ តំ អត្ថីតិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ចក្ខុវិញ្ញេយ្យេសុ រូបេសុ យោ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ តស្ស បរិត្តា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ បរិយាទិយន្តេវស្ស ចិត្តំ ។ កោ បន វាទោ អធិមត្តានំ ។ តំ កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ អត្ថិ យោ ទោសោ

១ ឱ. ម. បិលក្ខោ ។ ២ អាភិន្ទេយ្យ ។

## សមុទ្ទវគ្គ ទី ៣

[២៩០] ម្នាលភិក្ខុទាំងឡាយ ដើមឈើមានជ័រដូចទឹកដោះ គឺ ដើមពោធិ៍បាយក្តី ដើមជ្រៃក្តី ដើមល្វៀបក្តី ដើមល្វាក្តី ដែលនៅសាវខ្ចីតូច ៗ នៅឡើយ បុរសយកពូថៅដ៏មុតមកចោះដើមឈើនោះត្រង់ណា ៗ ក៏ដោយ ជ័រដូចទឹកដោះ មុខជាចេញមក (ដែរឬ) ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនោះ យ៉ាងនោះឯង ។ ដំណើរនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះជ័រដូចទឹកដោះនោះមាន ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនុ៎ះ មានឧបមេយ្យដូចបុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មានរាគៈ ទោសៈ មោហៈ ក្នុងរូបដែលត្រូវដឹងដោយចក្ខុ រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោលទេ ប្រសិនបើរូបដែលត្រូវដឹងដោយចក្ខុ ជារូបមានប្រមាណតិច មកកាន់គន្លងចក្ខុរបស់បុគ្គលនោះ រមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។ នឹងបាច់ពោលទៅថ្វី ដល់រូបដ៏ក្រៃលែង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ

សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ជិវ្ហាវិញ្ញេយ្យេសុ រសេសុ យោ រាគោ សោ អត្ថិ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា មនោវិញ្ញេយ្យេសុ ធម្មេសុ យោ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហីនោ យោ មោហោ សោ អប្បហីនោ តស្ស បរិត្តា ចេបិ ម-នោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ បរិយា-ទិយន្តេវស្ស ចិត្តំ ។ កោ បន វាទោ អធិមត្តានំ ។ តំ កិស្ស ហេតុ ។ យោ រាគោ សោ អត្ថិ យោ ទោសោ សោ អត្ថិ យោ មោហោ សោ អត្ថិ យោ រាគោ សោ អប្បហីនោ យោ ទោសោ សោ អប្បហី-នោ យោ មោហោ សោ អប្បហីនោ ។

មោហៈនៅមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មានរាគៈក្នុងរសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មានរាគៈ ទោសៈ មោហៈ ក្នុងធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោលទេ ប្រសិនបើធម្មារម្មណ៍ ដែលត្រូវដឹងដោយមនោ ជាធម្មារម្មណ៍មានប្រមាណតិច មកកាន់គន្លងនៃមនោរបស់បុគ្គលនោះ រមែងគ្របសង្កត់ចិត្ត របស់បុគ្គលនោះ ។ នឹងបាច់ពោលទៅថ្វី ដល់ធម្មារម្មណ៍ដ៏ក្រៃលែង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះរាគៈ ទោសៈ មោហៈ នៅមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះមិនបានលះបង់ចោល ។

[២៩១] យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ចក្ខុវិញ្ញេយ្យេសុ រូបេសុ យោ រាគោ សោ ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ តស្ស អធិមត្តា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អា-គច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ ។ កោ បន វាទោ បរិត្តានំ ។ តំ កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ជិវ្ហា-វិញ្ញេយ្យេសុ រសេសុ ។ បេ ។ មនោវិញ្ញេយ្យេសុ ធម្មេសុ យោ រាគោ សោ ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ

សមុទ្ទវគ្គ ទី ៣

[២៩១] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មិនមានរាគៈ ទោសៈ មោហៈ ក្នុងរូបដែលត្រូវដឹងដោយចក្ខុ រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ប្រសិនបើរូបដែលត្រូវដឹងដោយចក្ខុ ជារូបមានប្រមាណក្រៃលែង មកកាន់គន្លងចក្ខុរបស់បុគ្គលនោះ ក៏មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបានឡើយ ។ នឹងបាច់ពោលទៅថ្វីដល់រូបមានប្រមាណតិច ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ មោហៈ មិនមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មិនមានរាគៈ ទោសៈ មោហៈ ក្នុងរសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ មិនមានរាគៈ ទោសៈ មោហៈ ក្នុងធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ

តស្ស អធិមត្តា ចេបិ មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ ។ កោ បន វាទោ បរិត្តានំ ។ តំ កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ នត្ថិ យោ ទោសោ សោ នត្ថិ យោ មោហោ សោ នត្ថិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ ។

[២៩២] សេយ្យថាបិ ភិក្ខវេ ទីរុក្ខោ អស្សត្ថោ វា និគ្រោធោ វា មិលក្ខុ វា ឧទុម្ពរោ វា សុក្ខោ កោឡាបោ តេរោវស្សិកោ តមេនំ បុរិសោ តិណ្ហាយ កុធារិយា យតោ យតោ ភិន្ទេយ្យ អាគច្ឆេយ្យ ទីវន្តិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ យំ ហិ ភន្តេ ទីរំ តំ នត្ថីតិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុស្ស វា ភិក្ខុនិយា វា ចក្ខុវិញ្ញេយ្យេសុ រូបេសុ យោ រាគោ សោ នត្ថិ យោ ទោសោ សោ នត្ថិ យោ មោហោ សោ នត្ថិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ តស្ស អធិមត្តា ចេបិ ចក្ខុវិញ្ញេយ្យា រូបា

ប្រសិនបើធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ មានប្រមាណច្រើន មកកាន់គន្លងនៃមនោរបស់បុគ្គលនោះ ក៏មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបានឡើយ ។ នឹងបាច់ពោលទៅថ្វីដល់ធម្មារម្មណ៍មានប្រមាណតិច ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ មោហៈ មិនមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ។

[២៩២] ម្នាលភិក្ខុទាំងឡាយ ដើមឈើមានជ័រដូចទឹកដោះ គឺដើមពោធិ៍បាយក្តី ដើមជ្រៃក្តី ដើមល្វៀបក្តី ដើមល្វាក្តី ដែលស្ងួតជាឈើពុក កន្លងមួយឆ្នាំហើយ បុរសយកពូថៅដ៏មុតមកចោះដើមឈើនោះត្រង់ណា ៗ ក៏ដោយ ជ័រដូចទឹកដោះចេញមកបានឬទេ ។ ជ័រដូចទឹកដោះមិនចេញទេ ព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះរបស់ដែលជាជ័រដូចទឹកដោះមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនុ៎ះ មានឧបមេយ្យដូចបុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មិនមានរាគៈ ទោសៈ មោហៈ ក្នុងរូបដែលត្រូវដឹងដោយចក្ខុ រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ប្រសិនបើរូបដែលត្រូវ

សមុទ្ទវគ្គោ តតិយោ

ចក្ខុស្ស អាចាចំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ ។ កោ បន វាទោ បរិត្តានំ ។ តំ កិស្ស ហេតុ ។ យោ រាគោ សោ ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ជិវ្ហាវិញ្ញេយ្យេសុ រសេសុ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា មនោវិញ្ញេយ្យេសុ ធម្មេសុ យោ រាគោ សោ ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ បហីនោ យោ មោហោ សោ បហីនោ តស្ស អធិមត្តា ចេបិ មនោវិញ្ញេយ្យា ធម្មា មនស្ស អាចាចំ អាគច្ឆន្តិ

ដឹងដោយចក្ខុមានប្រមាណច្រើន មកកាន់គន្លងចក្ខុរបស់បុគ្គលនោះ ក៏មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបានឡើយ ។ នឹងបាច់ពោលទៅថ្វីដល់រូបមានប្រមាណតិច ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះរាគៈ ទោសៈ មោហៈ មិនមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មិនមានរាគៈ ទោសៈ មោហៈ ក្នុងរសដែលត្រូវដឹងដោយជិវ្ហា ។ បេ ។ បុគ្គលណាមួយ ទោះបីជាភិក្ខុក្តី ភិក្ខុនីក្តី មិនមានរាគៈ ទោសៈ មោហៈ ក្នុងធម្មារម្មណ៍ដែលត្រូវដឹងដោយមនោ រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ប្រសិនបើធម្មារម្មណ៍ដែលត្រូវដឹងដោយមនោមានប្រមាណច្រើន មកកាន់គន្លងនៃមនោរបស់បុគ្គលនោះ

នេវស្ស ចិត្តំ បរិយាទិយន្តិ ។ កោ បន រាគោ បរិត្តា-
ណំ ។ តំ កិស្ស ហេតុ ។ យោ ភិក្ខវេ រាគោ សោ
ឧត្តិ យោ ទោសោ សោ ឧត្តិ យោ មោហោ សោ
ឧត្តិ យោ រាគោ សោ បហីនោ យោ ទោសោ សោ
បហីនោ យោ មោហោ សោ បហីនោតិ ។

[២៩៣] ឯកំ សមយំ អាយស្មា ច សារីបុត្តោ
អាយស្មា ច មហាកោដ្ឋិកោ ពារាណសិយំ វិហរន្តិ
ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា មហាកោ-
ដ្ឋិកោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេ-
នាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អា-
យស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ
សារាណីយំ វីតិសារេត្វា មហាកោដ្ឋិកោ អាយស្មន្តំ សា-
រីបុត្តំ ឯតទវោច កឹ នុ ខោ អាវុសោ សារីបុត្ត ចក្ខុ រូបា-
នំ សញ្ញោជនំ រូបា ចក្ខុស្ស សញ្ញោជនំ ។ បេ ។ ជិវ្ហា
រសានំ សញ្ញោជនំ រសា ជិវ្ហាយ សញ្ញោជនំ ។ បេ ។ ម-
នោ ធម្មានំ សញ្ញោជនំ ធម្មា មនស្ស សំយោជនន្តិ ។

ក៏មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបានឡើយ ។ នឹងបាច់ពោលទៅថ្វី ដល់ធម្មារម្មណ៍មានប្រមាណតិច ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរាគៈ ទោសៈ មោហៈ មិនមាន រាគៈ ទោសៈ មោហៈ បុគ្គលនោះលះបង់ហើយ ។

[២៩៣] សម័យមួយ ព្រះសារីបុត្តមានអាយុ និងព្រះមហាកោដ្ឋិកៈមានអាយុ គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះមហាកោដ្ឋិកៈមានអាយុ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ បានចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាកោដ្ឋិកៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបសួរព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ចក្ខុជាសំយោជនៈរបស់រូប រូបជាសំយោជនៈរបស់ចក្ខុឬ ។ បេ ។ ជិវ្ហាជាសំយោជនៈរបស់រស រសជាសំយោជនៈរបស់ជិវ្ហាឬ ។ បេ ។ មនោជាសំយោជនៈរបស់ធម្មារម្មណ៍ ធម្មារម្មណ៍ជាសំយោជនៈរបស់មនោឬ ។

ន ខោ អាវុសោ កោដ្ឋិក ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ន ជិវ្ហា រសានំ សញ្ញោជនំ ន រសា ជិវ្ហាយ សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ បេ ។ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។

[២៩៤] សេយ្យថាបិ អាវុសោ កាឡោ ច ពលិពទ្ទោ ឱទាតោ ច ពលិពទ្ទោ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា អស្សុ យោ នុ ខោ ឯវំ វទេយ្យ កាឡោ ពលិពទ្ទោ ឱទាតស្ស ពលិពទ្ទស្ស សញ្ញោជនំ ឱទាតោ ពលិពទ្ទោ កាឡស្ស ពលិពទ្ទស្ស សញ្ញោជនន្តិ សម្មា នុ ខោ សោ វទមានោ វទេយ្យាតិ ។ នោ ហេតំ អាវុសោ ន ខោ អាវុសោ កាឡោ ពលិពទ្ទោ ឱទាតស្ស ពលិពទ្ទស្ស សញ្ញោជនំ ន បិ ឱទាតោ ពលិ-

សមុទ្ទវគ្គ ទី ៣

ម្នាលអាវុសោកោដ្ឋិកៈ ចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ ជិវ្ហាមិនមែនជាសំយោជនៈរបស់រសទេ រសក៏មិនមែនជាសំយោជនៈរបស់ជិវ្ហាដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ បេ ។ មនោមិនមែនជាសំយោ-ជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍ក៏មិនមែនជាសំយោជនៈរបស់មនោដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។

[២៩២] ម្នាលអាវុសោ ដូចគោខ្មៅនិងគោស គេទឹមដោយខ្សែទាមមួយក្តី ខ្សែរបរមួយក្តី បើមានអ្នកណានិយាយយ៉ាងនេះថា គោខ្មៅជាសំយោជនៈរបស់គោស គោសជាសំយោជនៈរបស់គោខ្មៅដូច្នេះ តើអ្នកនោះ ឈ្មោះថានិយាយត្រូវដែរឬដូចម្តេច ។ មិនត្រូវទេ អាវុសោ ម្នាលអាវុសោ គោខ្មៅមិនមែនជាសំយោជនៈរបស់គោសទេ គោសក៏មិន

ពទ្ធោ កាឡស្ស ពលិពទ្ទស្ស សញ្ញោជនំ យេន ច ខោ តេ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា តំ តត្ថ សញ្ញោជនំ ។ ឯវមេវ ខោ អាវុសោ ន ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ បេ ។ ន ជិវ្ហា រសានំ សញ្ញោជនំ ។ បេ ។ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។

[២៩៥] ចក្ខុ វា អាវុសោ រូបានំ សញ្ញោជនំ អភវិស្ស រូបា វា ចក្ខុស្ស សញ្ញោជនំ នយិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ យស្មា ច ខោ អាវុសោ ន ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ តស្មា ព្រហ្មចរិ-

មែនជាសំយោជនៈរបស់គោខ្មៅដែរ គោទាំងពីរនេះ គេទឹមដោយខ្សែទាមមួយ ឬខ្សែបរមួយណា ខ្សែទោមនិងខ្សែបរនោះ ជាសំយោជនៈរបស់គោទាំងពីរនោះ ។ ម្នាលអាវុសោ សេចក្តីនុ៎ះ មានឧបមេយ្យដូច ចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា កើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ បេ ។ ជិវ្ហាមិនមែនជាសំយោជនៈរបស់រសទេ ។ បេ ។ មនោមិនមែនជាសំយោជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍មិនមែនជាសំយោជនៈរបស់មនោដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។

[២៩៥] ម្នាលអាវុសោ បើចក្ខុជាសំយោជនៈរបស់រូប ឬរូបជាសំយោជនៈរបស់ចក្ខុហើយ ការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ មិនប្រាកដឡើយ ម្នាលអាវុសោ ចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ហេតុណា ហេតុនោះ ការប្រព្រឹត្តព្រហ្មចរិយៈ

យវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ បេ ។ ជិវ្ហា វា អាវុសោ រសានំ សញ្ញោជនំ អកវិស្ស រសា វា ជិវ្ហាយ សញ្ញោជនំ នយិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ[១] សម្មាទុក្ខក្ខយាយ យស្មា ច ខោ អាវុសោ ន ជិវ្ហា រសានំ សញ្ញោជនំ ន រសា ជិវ្ហាយ សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ បេ ។ មនោ វា អាវុសោ ធម្មានំ សញ្ញោជនំ អភវិស្ស ធម្មា វា មនស្ស សញ្ញោជនំ នយិទំ ព្រហ្មចរិយវាសោ បញ្ញាយេថ សម្មាទុក្ខក្ខយាយ យស្មា ច ខោ អាវុសោ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ តស្មា ព្រហ្មចរិយវាសោ បញ្ញាយតិ សម្មាទុក្ខក្ខយាយ ។ ឥមិនាបេតំ អាវុសោ បរិយាយេន វេទិតព្វំ ។ យថា ន ចក្ខុ រូបានំ សំយោជនំ

---

១ ម. សព្វវារេសុ បញ្ញាយតិ ។

ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ ទើបមានប្រាកដ ។ បេ ។ បើជិវ្ហាជាសំយោជនៈរបស់រស ឬរស ជាសំយោជនៈរបស់ជិវ្ហាហើយ ការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ មិនប្រាកដឡើយ ម្នាលអាវុសោ ជិវ្ហាមិនមែនជាសំយោជនៈរបស់រសទេ រសក៏មិនមែនជាសំយោជនៈរបស់ជិវ្ហាដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ហេតុណាហេតុនោះ បានជាការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃមានប្រាកដមែន ។ បេ ។ ម្នាលអាវុសោ បើមនោជាសំយោជនៈរបស់ធម្មារម្មណ៍ ឬធម្មារម្មណ៍ជាសំយោជនៈរបស់មនោហើយ ការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ មិនប្រាកដឡើយ ម្នាលអាវុសោ មនោមិនមែនជាសំយោជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍ក៏មិនមែនជាសំយោជនៈរបស់មនោដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈហេតុណា ហេតុនោះ បានជាការប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីឲ្យអស់ទុក្ខដោយប្រពៃ មានប្រាកដមែន ។ ម្នាលអាវុសោ ដំណើរនុ៎ះ អ្នកត្រូវយល់តាមបរិយាយនេះ ។ ដូចជាចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ

ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ បេ ។ ន ជិវ្ហា រសានំ សញ្ញោជនំ ។ បេ ។ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។

[២៩៦] សំវិជ្ជតិ ខោ អាវុសោ ភគវតោ ចក្ខុ បស្សតិ ភគវា ចក្ខុនា រូបំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ខោ អាវុសោ ភគវតោ សោតំ សុណាតិ ភគវា សោតេន សទ្ទំ ឆន្ទរាគោ ភគវតោ នត្ថិ

រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ បេ ។ ជិវ្ហាមិនមែនជាសំយោជនៈរបស់រសទេ ។ បេ ។ មនោមិនមែន ជាសំយោជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍ក៏មិនមែនជាសំយោជនៈ របស់មនោដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំង ពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។

[២៩៦] ម្នាលអាវុសោ ព្រះចក្ខុរបស់ព្រះមានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់ទតឃើញរូបដោយព្រះចក្ខុដែរ តែឆន្ទរាគរបស់ ព្រះមានព្រះភាគ មិនមានទេ ព្រោះព្រះមានព្រះភាគ ព្រះអង្គមាន ព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ព្រះស្រោតរបស់ព្រះ មានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់ព្រះសណ្តាប់សំឡេង ដោយព្រះស្រោតដែរ តែឆន្ទរាគរបស់ព្រះមានព្រះភាគ មិនមានទេ

សមុទ្ទវគ្គោ តតិយោ

សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ខោ អាវុសោ ភគវតោ ឃានំ ឃាយតិ ភគវា ឃានេន គន្ធំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ខោ អាវុសោ ភគវតោ ជិវ្ហា សាយតិ ភគវា ជិវ្ហាយ រសំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ខោ អាវុសោ ភគវតោ កាយោ ផុសតិ ភគវា កាយេន ផោដ្ឋព្វំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ សំវិជ្ជតិ ខោ អាវុសោ ភគវតោ មនោ វិជានាតិ ភគវា មនសា ធម្មំ ឆន្ទរាគោ ភគវតោ នត្ថិ សុវិមុត្តចិត្តោ ភគវា ។ ឥមិនា ខោ ឯតំ អាវុសោ

ព្រោះព្រះមានព្រះភាគ ព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ព្រះឃានៈរបស់ព្រះមានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់ហិតក្លិនដោយព្រះឃានៈដែរ តែឆន្ទរាគរបស់ព្រះមានព្រះភាគ មិនមានទេ ព្រោះព្រះមានព្រះភាគ ព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ព្រះជិវ្ហារបស់ព្រះមានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់លិទ្ធរសដោយព្រះជិវ្ហាដែរ តែឆន្ទរាគរបស់ព្រះមានព្រះភាគ មិនមានទេ ព្រោះព្រះមានព្រះភាគព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ព្រះកាយរបស់ព្រះមានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់ប៉ះពាល់នូវផោដ្ឋព្វារម្មណ៍ដោយព្រះកាយដែរ តែឆន្ទរាគរបស់ព្រះមានព្រះភាគ មិនមានទេ ព្រោះព្រះមានព្រះភាគ ព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ព្រះមនោរបស់ព្រះមានព្រះភាគ ក៏មាន ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបច្បាស់នូវធម្មារម្មណ៍ដោយព្រះមនោដែរ តែឆន្ទរាគរបស់ព្រះមានព្រះភាគ មិនមានទេ ព្រោះព្រះមានព្រះភាគ ព្រះអង្គមានព្រះហឫទ័យផុតស្រឡះហើយ ។ ម្នាលអាវុសោ ហេតុនុ៎ះ អ្នក

បរិយាយេន វេទិតព្វំ ។ យថា ន ចក្ខុ រូបានំ សញ្ញោ-
ជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ
បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ន
សោតំ ។ ន ឃានំ ។ ន ជិវ្ហា រសានំ សញ្ញោជនំ ន
រសា ជិវ្ហាយ សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច
ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ ន កាយោ ។
ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោ-
ជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ
តំ តត្ថ សញ្ញោជនន្តិ ។

[២៩៧] ឯកំ សមយំ អាយស្មា ច អានន្ទោ អាយ-
ស្មា ច កាមភូ កោសម្ពិយំ វិហរន្តិ ឃោសិតារាមេ ។
អថខោ អាយស្មា កាមភូ សាយណ្ហសមយំ បដិ-
សល្លានា វុដ្ឋិតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ
ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ
សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កាមភូ

ត្រូវយល់តាមបរិយាយនេះចុះ ។ ដូចយ៉ាង ចក្ខុមិនមែនជាសំយោជនៈរបស់រូប រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ សោតៈមិនមែន ។ ឃានៈមិនមែន ។ ជិវ្ហាមិនមែនជាសំយោជនៈរបស់រស រសក៏មិនមែនជាសំយោជនៈរបស់ជិវ្ហាដែរ ឆន្ទ-រាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះទើបឈ្មោះថាសំយោជនៈ ។ កាយមិនមែន ។ មនោមិនមែនជាសំយោជនៈរបស់ធម្មារម្មណ៍ ធម្មារម្មណ៍ក៏មិនមែនជាសំយោជនៈរបស់មនោដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។

[២៩៧] សម័យមួយ ព្រះអានន្ទមានអាយុ និងព្រះកាមភូមានអាយុគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះកា-មភូមានអាយុ ចេញចាកផលសមាបត្តិក្នុងសាយណ្ហសម័យ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះកាមភូមានអាយុ

៣៧៩



អាយស្មន្តំ អានន្ទំ ឯតទវោច កឹ នុ អាវុសោ អានន្ទ ចក្ខុ រូបានំ សញ្ញោជនំ រូបា ចក្ខុស្ស សញ្ញោជនំ ។ បេ ។ ជិវ្ហា រសានំ សញ្ញោជនំ រសា ជិវ្ហាយ សញ្ញោជនំ ។ បេ ។ មនោ ធម្មានំ សញ្ញោជនំ ធម្មា មនស្ស សញ្ញោជនន្តិ ។ ន ខោ អាវុសោ កាមភុ ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ បេ ។ ន ជិវ្ហា រសានំ សញ្ញោជនំ ន រសា ជិវ្ហាយ សញ្ញោជនំ ។ បេ ។ ន មនោ ធម្មានំ សញ្ញោជនំ ន ធម្មា មនស្ស សញ្ញោជនំ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនំ ។ សេយ្យថាបិ អាវុសោ កាឡោ ច ពលិវទ្ទោ ឱទាតោ ច ពលិវទ្ទោ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា អស្សុ យោ នុ ខោ ឯវំ វទេយ្យ កាឡោ ពលិវទ្ទោ ឱទាតស្ស ពលិវទ្ទស្ស សញ្ញោជនំ ឱទាតោ ពលិវទ្ទោ

អង្គុយក្នុងទីដ៏សមគួរហើយ បានសួរព្រះមានព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអាវុសោអានន្ទ ចក្ខុជាសំយោជនៈរបស់រូប រូបជាសំយោជនៈរបស់ចក្ខុ ឬដូចម្ដេច ។ បេ ។ ជិវ្ហាជាសំយោជនៈរបស់រស រសជាសំយោជនៈរបស់ជិវ្ហាឬ ។ បេ ។ មនោជាសំយោជនៈរបស់ធម្មារម្មណ៍ ធម្មារម្មណ៍ជាសំយោជនៈរបស់មនោឬដូចម្ដេច ។ ព្រះអានន្ទតបថា ម្នាលអាវុសោកាមភូ ចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ បេ ។ ជិវ្ហាមិនមែនជាសំយោជនៈរបស់រសទេ រសក៏មិនមែនជាសំយោជនៈរបស់ជិវ្ហាដែរ ។ បេ ។ មនោមិនមែនជាសំយោជនៈរបស់ធម្មារម្មណ៍ទេ ធម្មារម្មណ៍ក៏មិនមែនជាសំយោជនៈរបស់មនោដែរ ឆន្ទរាគណា ដែលកើតឡើងព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។ ម្នាលអាវុសោ ដូច គោខ្មៅនិងគោស ដែលគេទឹមដោយខ្សែទាមមួយ ឬខ្សែរបរមួយ បើមានអ្នកណានិយាយថា គោខ្មៅជាសំយោជនៈរបស់គោស គោស

កាឡស្ស ពលិពទ្ទស្ស សញ្ញោជនន្តិ សម្មា នុ ខោ សោ វទមានោ វទេយ្យាតិ ។ នោ ហេតំ អាវុសោ ន ខោ អាវុសោ កាឡោ ពលិពទ្ទោ ឱទាតស្ស ពលិពទ្ទស្ស សញ្ញោជនំ នបិ ឱទាតោ ពលិពទ្ទោ កាឡស្ស ពលិពទ្ទស្ស សញ្ញោជនំ យេន ច ខោ តេ ឯកេន ទាមេន វា យោត្តេន វា សំយុត្តា តំ តត្ថ សញ្ញោជនន្តិ ។ ឯវមេវ ខោ អាវុសោ ន ចក្ខុ រូបានំ សញ្ញោជនំ ន រូបា ចក្ខុស្ស សញ្ញោជនំ ។ បេ ។ ន ជិវ្ហា ។ បេ ។ ន មនោ ។ បេ ។ យញ្ច តត្ថ តទុភយំ បដិច្ច ឧប្បជ្ជតិ ឆន្ទរាគោ តំ តត្ថ សញ្ញោជនន្តិ ។

[២៩៨] ឯកំ សមយំ អាយស្មា ច អានន្ទោ អាយស្មា ច ឧទាយិ កោសម្ពិយំ វិហរន្តិ ឃោសិតារាមេ ។ អថខោ អាយស្មា ឧទាយិ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧទាយិ

ជាសំយោជនៈរបស់គោខ្មៅ តើអ្នកនិយាយនោះ ឈ្មោះថានិយាយត្រូវដែរឬទេ ។ ម្នាលអាវុសោ មិនត្រូវទេ ម្នាលអាវុសោ គោខ្មៅមិនមែនជាសំយោជនៈរបស់គោសទេ គោសក៏មិនមែនជាសំយោជនៈរបស់គោខ្មៅដែរ គោទាំងនោះសុទ្ធតែគេទឹមដោយខ្សែទាមមួយ ឬខ្សែបរមួយ ខ្សែទាមនិងខ្សែបរនោះ ជាសំយោជនៈរបស់គោទាំងពីរនោះ ។ ម្នាលអាវុសោ សេចក្តីនុ៎ះ មានឧបមេយ្យដូចចក្ខុមិនមែនជាសំយោជនៈរបស់រូបទេ រូបក៏មិនមែនជាសំយោជនៈរបស់ចក្ខុដែរ ។ បេ ។ ជិវ្ហាក៏មិនមែន ។ បេ ។ មនោក៏មិនមែន ។ បេ ។ ឆន្ទរាគណា ដែលកើតឡើង ព្រោះអាស្រ័យរបស់ទាំងពីរនោះ ឆន្ទរាគនោះ ឈ្មោះថាសំយោជនៈ ។

[២៩៨] សម័យមួយ ព្រះអានន្ទមានអាយុនិងព្រះឧទាយិមានអាយុ គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះឧទាយិមានអាយុ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ បានធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះឧទាយិ

សមុទ្ទវគ្គោ តតិយោ

អាយស្មន្តំ អានន្ទំ ឯតទវោច យថេវ នុ ខោ អាវុសោ អានន្ទ អយំ កាយោ ភគវតា អនេកបរិយាយេន អក្ខាតោ វិវដោ បកាសិតោ ឥតិចាយំ កាយោ អនត្តាតិ ។ សក្កា ឯវមេវំ វិញ្ញាណម្បិទំ អាចិក្ខិតុំ ទេសេតុំ បញ្ញបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុំ ឥតិបិទំ វិញ្ញាណំ អនត្តា ។ យថេវ ខោ អាវុសោ ឧទាយិ អយំ កាយោ ភគវតា អនេកបរិយាយេន អក្ខាតោ វិវដោ បកាសិតោ ឥតិចាយំ កាយោ អនត្តាតិ ។ សក្កា ឯវមេវំ វិញ្ញាណម្បិទំ អាចិក្ខិតុំ ទេសេតុំ បញ្ញបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុំ ឥតិបិទំ វិញ្ញាណំ អនត្តាតិ ។

សមុទ្ទវគ្គ ទី ៣

មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបនិយាយនឹងព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអាវុសោអានន្ទ កាយនេះ ព្រះមានព្រះភាគតែងសម្តែង បើក ប្រកាសថា កាយនេះជាអនត្តា ដោយអនេកបរិយាយយ៉ាងណា ។ ព្រះមានព្រះភាគអាចដើម្បីប្រាប់ សម្តែង តែងតាំងផ្តួចផ្តើម បើក វែកញែក ធ្វើឲ្យងាយ នូវវិញ្ញាណនេះថា វិញ្ញាណនេះ ជាអនត្តាដូច្នេះ យ៉ាងនោះបានដែរឬ ។ ម្នាលអាវុសោឧទាយិ កាយនេះ ព្រះមានព្រះភាគត្រាស់សម្តែង បើក ប្រកាសថា កាយនេះជាអនត្តាដូច្នេះ ដោយអនេកបរិយាយ យ៉ាងណា ។ ព្រះមានព្រះភាគអាចប្រាប់ សម្តែង តែងតាំង ផ្តួចផ្តើម បើក វែកញែក ធ្វើឲ្យងាយ នូវវិញ្ញាណនេះថា វិញ្ញាណនេះជាអនត្តាដូច្នេះ យ៉ាងនោះបាន ។

[២៩៩] ចក្ខុញ្ច អាវុសោ បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ឯវមាវុសោតិ ។ យោ អាវុសោ ហេតុ យោ ច បច្ចយោ ចក្ខុវិញ្ញាណស្ស ឧប្បាទាយ សោ ច ហេតុ សោ ច បច្ចយោ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសា និរុជ្ឈេយ្យ អបិ នុ ខោ ចក្ខុវិញ្ញាណំ បញ្ញាយេថាតិ ។ នោ ហេតំ អាវុសោ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន ភគវតា អក្ខាតំ វិវដំ បកាសិតំ ឥតិបិទំ វិញ្ញាណំ អនត្តា-តិ ។ បេ ។ ជិវ្ហញ្ចាវុសោ បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណន្តិ ។ ឯវមាវុសោតិ ។ យោ ចាវុសោ ហេតុ យោ ច បច្ចយោ ជិវ្ហាវិញ្ញាណស្ស ឧប្បាទាយ សោ ច ហេតុ សោ ច បច្ចយោ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសា និរុជ្ឈេយ្យ អបិ នុ ខោ ជិវ្ហាវិញ្ញាណំ បញ្ញាយេថាតិ ។ នោ ហេតំ អាវុសោ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន ភគវតា អក្ខាតំ វិវដំ បកាសិតំ ឥតិបិទំ វិញ្ញាណំ អនត្តាតិ ។ បេ ។

[២៩៩] ម្នាលអាវុសោអានន្ទ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុនិងរូបឬ ។ ម្នាលអាវុសោឧទាយិ យ៉ាងនេះមែនហើយ ។ ម្នាលអាវុសោអានន្ទ ហេតុណា បច្ច័យណា ដែលនាំឲ្យចក្ខុវិញ្ញាណកើតឡើង ហេតុនោះ បច្ច័យនោះ នឹងរលត់ទៅឥតមានសេសសល់ ដោយអាការទាំងពួង ដោយប្រការទាំងពួង ចក្ខុវិញ្ញាណនឹងប្រាកដឬហ្ន៎ ។ ម្នាលអាវុសោឧទាយិ ចក្ខុវិញ្ញាណនុ៎ះមិនប្រាកដទេ ម្នាលអាវុសោ ឧទាយិ ហេតុនុ៎ះ ព្រះមានព្រះភាគបានត្រាស់ បានបើក បានប្រកាសហើយ ដោយបរិយាយនេះថា វិញ្ញាណនេះជាអនត្តាដូច្នេះ ។ បេ ។ ម្នាលអាវុសោអានន្ទ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យជិវ្ហានិងរសឬ ។ ម្នាលអាវុសោឧទាយិ យ៉ាងនេះមែនហើយ ។ ម្នាលអាវុសោអានន្ទ ហេតុណា បច្ច័យណា ដែលនាំឲ្យជិវ្ហាវិញ្ញាណកើតឡើង ហេតុនោះ បច្ច័យនោះ នឹងរលត់ទៅឥតមានសេសសល់ ដោយអាការទាំងពួង ដោយប្រការទាំងពួង ជិវ្ហាវិញ្ញាណនឹងប្រាកដឬហ្ន៎ ។ ម្នាលអាវុសោឧទាយិ ជិវ្ហាវិញ្ញាណនុ៎ះមិនប្រាកដទេ ម្នាលអាវុសោឧទាយិ ជិវ្ហាវិញ្ញាណនុ៎ះ ព្រះមានព្រះភាគបានត្រាស់ បានបើក បានប្រកាសហើយដោយបរិយាយនេះថា វិញ្ញាណនេះ ជាអនត្តាដូច្នេះ ។ បេ ។

មនញ្ចាវុសោ បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណន្តិ ។ ឯវមាវុសោតិ ។ យោ ចាវុសោ ហេតុ យោ ច បច្ចយោ មនោវិញ្ញាណស្ស ឧបាទាយ សោ ច ហេតុ សោ ច បច្ចយោ សព្វេន សព្វំ សព្វថា សព្វំ អបរិសេសា និរុជ្ឈេយ្យ អបិ នុ ខោ មនោវិញ្ញាណំ បញ្ញាយេថាតិ ។ នោ ហេតំ អាវុសោ ឥមិនាបិ ខោ ឯតំ អាវុសោ បរិយាយេន ភគវតា អក្ខាតំ វិវដំ បកាសិតំ ឥតិបិទំ វិញ្ញាណំ អនត្តាតិ ។

[៣០០] សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ តិណ្ហំ កុធារឹ អាទាយ វនំ បវិសេយ្យ សោ តត្ថ បស្សេយ្យ មហន្តំ កទលិក្ខន្ធំ ឧជុំ នវំ អក្កុកុជកជាតំ(១) តមេនំ មូលេ ឆិន្ទេយ្យ មូលេ ឆិត្វា អគ្គេ ឆិន្ទេយ្យ អគ្គេ ឆេត្វា បត្តវដ្ដឹ វិនិព្ភជ្ជេយ្យ(២) សោ តត្ថ ផេគ្គុម្បិ នាធិគច្ឆេយ្យ កុតោ សារំ ។ ឯវមេវ ខោ អាវុសោ ភិក្ខុ ឆសុ ផស្សាយតនេសុ នេវត្តានំ ន អត្តនីយំ សមនុបស្សតិ

---

១ កត្ថចិ បោត្ថកេ ឱ. ម. នវកំ អកុក្កុកជាតំ ។ ម. អក្កុកជជាតំ ។ ២ វិនិព្ភុជ្ជេយ្យ ។

ម្នាលអាវុសោអានន្ទ មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យមនោនិង ធម្មារម្មណ៍ឬ ។ ម្នាលអាវុសោឧទាយិ យ៉ាងនេះមែនហើយ ។ ម្នាល អាវុសោអានន្ទ ហេតុណា បច្ច័យណា ដែលនាំឲ្យមនោវិញ្ញាណកើត ឡើង ហេតុនោះ បច្ច័យនោះ នឹងរលត់ទៅឥតសេសសល់ ដោយ អាការទាំងពួង ដោយប្រការទាំងពួង មនោវិញ្ញាណនឹងប្រាកដឬហ្ន៎ ។ ម្នាលអាវុសោឧទាយិ មនោវិញ្ញាណនុ៎ះ មិនប្រាកដទេ ម្នាលអាវុសោ ឧទាយិ មនោវិញ្ញាណនុ៎ះ ព្រះមានព្រះភាគបានត្រាស់ បានបើក បាន ប្រកាស ដោយបរិយាយនេះថា វិញ្ញាណនេះ ជាអនត្តាដូច្នេះ ។

[៣០០] ម្នាលអាវុសោឧទាយិ ដូចជាបុរសអ្នកត្រូវការខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅរកខ្លឹមឈើ កាន់ដឹងដ៏មុត ចូលទៅកាន់ព្រៃ បុរសនោះឃើញដើមចេក ធំ ត្រង់ ខ្ចី មិនទាន់មានបណ្តូលស្នូង នៅក្នុង ព្រៃនោះ ក៏កាត់យកដើមចេកនោះត្រង់គល់ លុះកាត់រួចហើយ ទើបកាត់ ចុង លុះកាត់ចុងរួចហើយ ក៏បកស្រទប សូម្បីតែស្រាយ ក៏បុរសនោះ រកមិនបានក្នុងដើមចេកនោះផង នឹងបានខ្លឹមមកពីណា មានឧបមាយ៉ាង ណាមិញ ។ ម្នាលអាវុសោឧទាយិ មានឧបមេយ្យដូចភិក្ខុមិនពិចារណា ឃើញខ្លួន មិនពិចារណាឃើញវត្ថុជារបស់ខ្លួន ក្នុងផស្សាយតនៈទាំង ៦

សោ ឯវំ សមនុបស្សន្តោ ន កិញ្ចិ លោកេ ឧបាទិ-
យតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ
បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ
ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[៣០១] អាទិត្តបរិយាយំ វោ ភិក្ខវេ ធម្មបរិយា-
យំ ទេសេស្សាមិ តំ សុណាថ ។ កតមោ ច ភិក្ខវេ
អាទិត្តបរិយាយោ ធម្មបរិយាយោ ។ វរំ ភិក្ខវេ តត្តា-
យ អយោសលាកាយ អាទិត្តាយ សម្បជ្ជលិតាយ
សជោតិភូតាយ ចក្ខុន្ទ្រិយំ សម្បលិមដ្ឋំ ន ត្វេវ ចក្ខុ-
វិញ្ញេយ្យេសុ រូបេសុ អនុព្យញ្ជនសោ និមិត្តគ្គាហោ ។
និមិត្តស្សាទគថិតំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ
តិដ្ឋេយ្យ អនុព្យញ្ជនស្សាទគថិតំ វា តស្មឹ ចេ សមយេ
កាលំ ករេយ្យ ។ ឋានមេតំ វិជ្ជតិ យំ ទ្វិន្នំ គតីនំ
អញ្ញតរំ គតឹ គច្ឆេយ្យ និរយំ វា តិរច្ឆានយោនឹ វា ។

កាលបើភិក្ខុនោះ ពិចារណាឃើញយ៉ាងនេះ ក៏លែងប្រកាន់របស់អ្វីតិចតួចក្នុងលោក កាលបើលែងប្រកាន់ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត រមែងរំលត់កិលេសដោយពិត ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[៣០១] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង នូវធម្មបរិយាយឈ្មោះអាទិត្តបរិយាយ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ធម្មបរិយាយនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ចុះធម្មបរិយាយឈ្មោះអាទិត្តបរិយាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុន្ទ្រិយដែលបុគ្គលអាល ដោយបន្ទះដែកដ៏ក្តៅដែលភ្លើងកំពុងឆេះ រុងរោចន៍សន្ធោសន្ធៅប្រសើរជាង ការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ក្នុងរូបដែលបុគ្គលគប្បីដឹងដោយចក្ខុ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្តេកផ្តួលទៅរកសេចក្តីត្រេកអរក្នុងនិមិត្ត ឬ ផ្តេកផ្តួលទៅរកសេចក្តីត្រេកអរក្នុងអនុព្យញ្ជនៈ ហើយតាំងនៅ បើបុគ្គលនោះធ្វើមរណកាលក្នុងសម័យនោះ ។ បណ្តាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយគឺនរក ឬ កំណើតតិរច្ឆាន ដោយហេតុណា ហេតុនោះ រមែងមាន ។

សមុទ្ទវគ្គោ តតិយោ

ឥទំ ខោហំ ភិក្ខវេ អាទីនវំ ទិស្វា ឯវំ វទាមិ ។ វរំ ភិក្ខវេ តិណ្ហេន អយោសង្កុនា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន សោតិន្ទ្រិយំ សម្បលិមដ្ឋំ ន ត្វេវ សោតវិញ្ញេយ្យេសុ សទ្ទេសុ អនុព្យញ្ជនសោ និមិត្តគ្គាហោ ។ និមិត្តស្សាទគធិតំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ អនុព្យញ្ជនស្សាទគធិតំ វា តស្មឹ ចេ សមយេ កាលំ ករេយ្យ ។ ឋានមេតំ វិជ្ជតិ យំ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ គច្ឆេយ្យ និរយំ វា តិរច្ឆានយោនឹ វា ។ ឥទំ ខោហំ ភិក្ខវេ អាទីនវំ ទិស្វា ឯវំ វទាមិ ។ វរំ ភិក្ខវេ តិណ្ហេន នខច្ឆេទនេន អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន ឃានិន្ទ្រិយំ សម្បលិមដ្ឋំ ន ត្វេវ ឃានវិញ្ញេយ្យេសុ គន្ធេសុ អនុព្យញ្ជនសោ និមិត្តគ្គាហោ ។ និមិត្តស្សាទគធិតំ វា ភិក្ខវេ វិញ្ញាណំ

ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សោតិន្ទ្រិយដែលបុគ្គលខ្វារ ដោយកង្វារដែកដ៏មុត ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ក្នុងសំឡេងដែលបុគ្គលគប្បីដឹងដោយសោតៈ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះនិមិត្ត ឬផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះអនុព្យញ្ជនៈហើយឋិតនៅ បើបុគ្គលធ្វើមរណកាលក្នុងសម័យនោះទៅ ។ បណ្តាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយ គឺនរក ឬកំណើតតិរច្ឆាន ដោយហេតុណា ហេតុនោះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ឃានិន្ទ្រិយដែលបុគ្គលខ្វេះ ដោយក្រចកដែកដ៏មុត ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ក្នុងក្លិនទាំងឡាយ ដែលបុគ្គលគប្បីដឹងដោយឃានៈ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្តេកផ្តួលទៅរក

៣៨៦



តិដ្ឋមានំ តិដ្ឋេយ្យ អនុព្យញ្ជនស្សាទគធិតំ វា តស្មឹ ចេ សមយេ កាលំ ករេយ្យ ។ ឋានមេតំ វិជ្ជតិ យំ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ គច្ឆេយ្យ និរយំ វា តិរច្ឆានយោនឹ វា ។ ឥទំ ខោហំ ភិក្ខវេ អាទីនវំ ទិស្វា ឯវំ វទាមិ ។ វរំ ភិក្ខវេ តិណ្ហេន ខុរេន អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន ជិវ្ហិន្ទ្រិយំ សម្បលិមដ្ឋំ ន ត្វេវ ជិវ្ហាវិញ្ញេយ្យេសុ រសេសុ អនុព្យញ្ជនសោ និមិត្តគ្គាហោ ។ និមិត្តស្សាទគធិតំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ អនុព្យញ្ជនស្សាទគធិតំ វា តស្មឹ ចេ សមយេ កាលំ ករេយ្យ ។ ឋានមេតំ វិជ្ជតិ យំ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ គច្ឆេយ្យ និរយំ វា តិរច្ឆានយោនឹ វា ។ ឥទំ ខោហំ ភិក្ខវេ អាទីនវំ ទិស្វា ឯវំ វទាមិ ។ វរំ ភិក្ខវេ

សេចក្តីត្រេកអរចំពោះនិមិត្ត ឬផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះអនុ-ព្យញ្ជនៈ ហើយតាំងនៅ បើបុគ្គលនោះធ្វើមរណកាលក្នុងសម័យនោះ ។ បណ្តាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយ គឺនរកឬកំណើតតិរច្ឆាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ជិវ្ហិន្ទ្រិយដែលបុគ្គលកាត់ ដោយកាំបិតកោរដ៏មុតដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ ប្រសើរជាង ការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ក្នុងរសដែលបុគ្គលគប្បីដឹងដោយជិវ្ហា មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណដែលផ្តេកផ្តួលទៅរកសេចក្តីត្រេកអរក្នុងនិមិត្ត ឬផ្តេកផ្តួលទៅរកសេចក្តីត្រេកអរក្នុងអនុព្យញ្ជនៈ ហើយឋិតនៅ បើបុគ្គលនោះធ្វើមរណកាលក្នុងសម័យនោះទៅ ។ បណ្តាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយ គឺនរកឬកំណើតតិរច្ឆាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ

តិណ្ហាយ សត្តិយា អាទិត្តាយ សម្បជ្ជលិតាយ សញ្ជោតិភូតាយ កាយិន្ទ្រិយំ សម្បលិមដ្ឋំ ន ត្វេវ កាយវិញ្ញេយ្យេសុ ផោដ្ឋព្វេសុ អនុព្យញ្ជនសោ និមិត្តគ្គាហោ ។ និមិត្តស្សាទគធិតំ វា ភិក្ខវេ វិញ្ញាណំ តិដ្ឋមានំ តិដ្ឋេយ្យ អនុព្យញ្ជនស្សាទគធិតំ វា តស្មឹ ចេ សមយេ កាលំ ករេយ្យ ។ ឋានមេតំ វិជ្ជតិ យំ ទ្វិន្នំ គតីនំ អញ្ញតរំ គតឹ គច្ឆេយ្យ និរយំ វា តិរច្ឆានយោនឹ វា ។ ឥមំ ខោហំ ភិក្ខវេ អាទីនវំ ទិស្វា ឯវំ វទាមិ ។ វរំ ភិក្ខវេ សោត្តំ សោត្តំ ខោ បនាហំ ភិក្ខវេ វជ្ឈំ[១] ជីវិតានំ វទាមិ អផលំ ជីវិតានំ វទាមិ មោមូហំ ជីវិតានំ វទាមិ ន ត្វេវ តថារូបេ វិតក្កេ វិតក្កេយ្យ យថារូបានំ វិតក្កានំ វសង្គតោ សង្ឃំ ភិន្ទេយ្យ ។ ឥមំ ខោហំ ភិក្ខវេ វជ្ឈំ ជីវិតានំ អាទីនវំ ទិស្វា ឯវំ វទាមិ ។

---

១ ឱ. វញ្ឈំ ។ ម. វញ្ញុំ ។

សមុទ្ទវគ្គ ទី ៣

កាយិន្ទ្រិយដែលបុគ្គលពន្ធះ ដោយកាំបិតដ៏មុត ដែលភ្លើងកំពុងឆេះរុង-រោចន៍សន្ធោសន្ធៅ ប្រសើរជាង ការកាន់យកនិមិត្តដោយអនុព្យញ្ជនៈក្នុងផោដ្ឋព្វៈដែលបុគ្គលគប្បីដឹងដោយកាយ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណ ដែលផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះនិមិត្ត ឬផ្តេកផ្តួលទៅរកសេចក្តីត្រេកអរចំពោះអនុព្យញ្ជនៈ ហើយឋិតនៅ ប្រសិនបើបុគ្គលនោះធ្វើមរណកាលក្នុងសម័យនោះទៅ ។ បណ្តាគតិទាំងពីរ បុគ្គលនោះគប្បីទៅកាន់គតិណាមួយ គឺនរកឬកំណើតតិរច្ឆានដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ តថា-គតឃើញទោសនេះឯង បានជាពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដេកលក់ប្រសើរជាង ម្នាលភិក្ខុទាំងឡាយ ព្រះតថា-គតពោលការដេកលក់ ថាជាទោសរបស់មនុស្សដែលរស់នៅ តថាគតពោលការដេកលក់ ថាមិនមែនជាផលរបស់មនុស្សដែលរស់នៅ តថាគតពោលការដេកលក់ ថាជាសេចក្តីវង្វេងរបស់មនុស្សដែលរស់នៅ បុគ្គលលុះក្នុងអំណាចវិតក្កៈមានសភាពយ៉ាងណាហើយ បំបែកសង្ឃ បុគ្គលត្រិះរិះក្នុងវិតក្កៈមានសភាពយ៉ាងនោះ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតឃើញទោសនេះឯង ថាជាទោសរបស់បុគ្គលដែលរស់នៅ បានជាពោលយ៉ាងនេះ ។

[៣០៦] តត្ថ ភិក្ខវេ សុតវា អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ តិដ្ឋតុ តាវ តត្តាយ អយោ-សលាកាយ អាទិត្តាយ សម្បជ្ជលិតាយ សញ្ជោតិ-ភូតាយ ចក្ខុន្ទ្រិយំ សម្បលិមដ្ឋំ ហន្ទាហំ ឥទមេវ មនសិករោមិ ឥតិ ចក្ខុំ អនិច្ចំ រូបា អនិច្ចា ចក្ខុវិញ្ញាណំ អនិច្ចំ ចក្ខុសម្ផស្សោ អនិច្ចោ យម្បិ-ទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ ។ តិដ្ឋតុ តាវ តិណ្ហេន អយោសង្កុនា អាទិត្តេន សម្ប-ជ្ជលិតេន សញ្ជោតិភូតេន សោតិន្ទ្រិយំ សម្បលិ-មដ្ឋំ ហន្ទាហំ ឥទមេវ មនសិករោមិ ឥតិ សោតំ អនិច្ចំ សទ្ទា អនិច្ចា សោតវិញ្ញាណំ អនិច្ចំ សោត-សម្ផស្សោ អនិច្ចោ យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា

[៣០២] ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងទាំងនោះ អរិយសាវ័កអ្នកចេះដឹង ពិចារណាឃើញដូច្នេះថា ចក្ខុន្ទ្រិយដែលបុគ្គលអាលដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ លើកទុកដោយឡែកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះ ដូច្នេះថា ចក្ខុមិនទៀង រូបមិនទៀង ចក្ខុវិញ្ញាណមិនទៀង ចក្ខុសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏មិនទៀង ។ សោតិន្ទ្រិយដែលបុគ្គលខ្វារ ដោយកង្វារដែកដ៏មុត ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ លើកទុកដោយឡែកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះដូច្នេះថា សោតៈមិនទៀង សទ្ទៈមិនទៀង សោតវិញ្ញាណមិនទៀង សោតសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះសោតសម្ផស្ស

សមុទ្ទវគ្គោ តតិយោ

តម្បិ អនិច្ចំ ។ តិដ្ឋតុ តាវ តិណ្ហេន នខច្ឆេទនេន
អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន ឃានិន្ទ្រិ-
យំ សម្បលិមដ្ឋំ ហន្ទាហំ ឥទមេវ មនសិករោមិ
ឥតិ ឃានំ អនិច្ចំ គន្ធា អនិច្ចា ឃានវិញ្ញាណំ
អនិច្ចំ ឃានសម្ផស្សោ អនិច្ចោ យម្បិទំ ឃាន-
សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ ។ បេ ។ តម្បិ
អនិច្ចំ ។ តិដ្ឋតុ តាវ តិណ្ហេន ខុរេន អាទិត្តេន
សម្បជ្ជលិតេន សជោតិភូតេន ជិវ្ហិន្ទ្រិយំ សម្បលិ-
មដ្ឋំ ហន្ទាហំ ឥទមេវ មនសិករោមិ ឥតិ ជិវ្ហា
អនិច្ចា រសា អនិច្ចា ជិវ្ហាវិញ្ញាណំ អនិច្ចំ ជិវ្ហាសម្ផស្សោ
អនិច្ចោ យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ
។ បេ ។ តម្បិ អនិច្ចំ ។ តិដ្ឋតុ តាវ តិណ្ហាយ
សត្តិយា អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូ-
តាយ កាយិន្ទ្រិយំ សម្បលិមដ្ឋំ ហន្ទាហំ ឥទមេវ
មនសិករោមិ ឥតិ កាយោ អនិច្ចោ ផោដ្ឋព្វា អ-
និច្ចា កាយវិញ្ញាណំ អនិច្ចំ កាយសម្ផស្សោ អនិច្ចោ

ជាបច្ច័យ វេទនានោះមិនទៀត ។ ឃានិន្ទ្រិយដែលបុគ្គលខ្វេះ ដោយក្រចកដែកដ៏មុត ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ លើកទុកដោយឡែកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះ ដូច្នេះថា ឃានៈមិនទៀត គន្ធៈមិនទៀត ឃានវិញ្ញាណមិនទៀត ឃានសម្ផស្សមិនទៀត វេទនាណា ដែលកើតឡើង ព្រោះឃានសម្ផស្សជាបច្ច័យ ។ បេ ។ វេទនានោះក៏មិនទៀត ។ ជិវ្ហិន្ទ្រិយដែលបុគ្គលពន្ធះដោយកាំបិតកោរដ៏មុត ដែលភ្លើងកំពុងឆេះរុងរោចន៍សន្ធោសន្ធៅ លើកទុកដោយឡែកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះដូច្នេះថា ជិវ្ហាមិនទៀត រសមិនទៀត ជិវ្ហាវិញ្ញាណមិនទៀត ជិវ្ហាសម្ផស្សមិនទៀត វេទនាណា ដែលកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។ បេ ។ វេទនានោះ ក៏មិនទៀត ។ កាយិន្ទ្រិយដែលបុគ្គលចាក់ ដោយលំពែងដ៏មុត ដែលភ្លើងកំពុងឆេះ រុងរោចន៍សន្ធោសន្ធៅ លើកទុកដោយឡែកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះ ដូច្នេះថា កាយមិនទៀត ផោដ្ឋព្វារម្មណ៍មិនទៀត កាយវិញ្ញាណមិនទៀត កាយសម្ផស្សមិនទៀត

យម្បិទំ កាយសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ ។ បេ ។ តម្បិ អនិច្ចំ ។ តិដ្ឋតុ តាវ សោត្តំ ហន្ទាហំ ឥទមេវ មនសិករោមិ ឥតិ មនោ អនិច្ចោ ធម្មា អនិច្ចា មនោវិញ្ញាណំ អនិច្ចំ មនោសម្ផស្សោ អនិច្ចោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អនិច្ចំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ ។ បេ ។ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយំ ខោ ភិក្ខវេ អាទិត្តបរិយាយោ ធម្មបរិយាយោតិ ។

វេទនាណា ដែលកើតឡើង ព្រោះកាយសម្ផស្សជាបច្ច័យ ។ បេ ។ វេទនានោះ ក៏មិនទៀង ។ ការដេកលក់លើកទុកសិនចុះ បើដូច្នោះ អញធ្វើទុកក្នុងចិត្តនូវហេតុនេះ ដូច្នេះថា មនោមិនទៀង ធម្មារម្មណ៍ មិនទៀង មនោវិញ្ញាណមិនទៀង មនោសម្ផស្សមិនទៀង វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ វេទនានោះ ក៏មិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវ័កអ្នកចេះដឹង ឃើញយ៉ាងនេះ រមែងនឿយណាយ នឹងចក្ខុផង នឿយណាយនឹងរូបផង នឿយណាយនឹងចក្ខុវិញ្ញាណផង នឿយណាយនឹងចក្ខុសម្ផស្សផង ។ បេ ។ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនទុក្ខមិនសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏នឿយណាយនឹងវេទនានោះ កាលបើនឿយណាយ រមែងប្រាសចាក តម្រេក ព្រោះតែប្រាសចាកតម្រេក ទើបចិត្តរួចស្រឡះ ។ កាលបើចិត្ត រួចស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ ដឹង ច្បាស់ថា ព្រហ្មចរិយៈអាត្មាអញនៅរួចហើយ សោឡសកិច្ចអាត្មាអញ ធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម្មបរិយាយ ឈ្មោះ អាទិត្តបរិយាយ ។

សមុទ្ទវគ្គោ តតិយោ

[៣០៣] ហត្ថេសុ ភិក្ខវេ សតិ អាទាននិក្ខេបនំ បញ្ញាយតិ បាទេសុ សតិ អភិក្កមប្បដិក្កមោ បញ្ញា-យតិ បព្វេសុ សតិ សម្មិញ្ជនប្បសារណំ បញ្ញាយតិ កុច្ឆិស្មឹ សតិ ជិឃច្ឆាបិបាសា បញ្ញាយតិ ។ ឯវមេវ ខោ ភិក្ខវេ ចក្ខុស្មឹបិ សតិ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ ជិវ្ហាយ សតិ ជិវ្ហា-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ មនស្មឹ សតិ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។

[៣០៤] ហត្ថេសុ ភិក្ខវេ អសតិ អាទាននិក្ខេ-បនំ ន បញ្ញាយតិ បាទេសុ អសតិ អភិក្កមប្ប-

## សមុទ្ទវគ្គ ទី ៣

[៣០៣] ម្នាលភិក្ខុទាំងឡាយ កាលបើដៃមាន ការកាន់និងការដាក់ចុះ រមែងប្រាកដ កាលបើជើងមាន ការឈានទៅមុខនិងឈានថយក្រោយ ក៏រមែងប្រាកដ កាលបើសន្លាក់ទាំងឡាយមាន ការបត់ចូលនិងលាចេញ ក៏រមែងប្រាកដ កាលបើពោះមាន សេចក្ដីស្រេកឃ្លាន ក៏រមែងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ពិតយ៉ាងនេះឯង កាលបើចក្ខុមាន សេចក្ដីសុខនិងទុក្ខជាខាងក្នុង ក៏កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ។ បេ ។ កាលបើជិវ្ហាមាន សេចក្ដីសុខនិងទុក្ខជាខាងក្នុង ក៏កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។ បេ ។ កាលបើមនោមាន សេចក្ដីសុខនិងទុក្ខជាខាងក្នុង ក៏កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ។ បេ ។

[៣០៤] ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានដៃ ការកាន់យកនិងការដាក់ចុះ ក៏មិនប្រាកដ កាលបើមិនមានជើង ការឈាន

ជិគ្ឃមោ ន បញ្ញាយតិ បព្វេសុ អសតិ សម្មិញ្ជនប្ប-
សារណំ ន បញ្ញាយតិ កុច្ឆិស្មឹ អសតិ ជិឃច្ឆាបិបា-
សា ន បញ្ញាយតិ ។ ឯវមេវ ខោ ភិក្ខវេ ចក្ខុស្មឹ អ-
សតិ ចក្ខុសម្ផស្សប្បច្ចយា នុប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ
។ បេ ។ ជិវ្ហាយ អសតិ ជិវ្ហាសម្ផស្សប្បច្ចយា នុប្បជ្ជតិ
អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ មនស្មឹ អសតិ មនោ-
សម្ផស្សប្បច្ចយា នុប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។

[៣០៨] ហត្ថេសុ ភិក្ខវេ សតិ អាទាននិក្ខេបនំ
ហោតិ បាទេសុ សតិ អភិក្កមប្បដិក្កមោ ហោតិ
បព្វេសុ សតិ សម្មិញ្ជនប្បសារណំ ហោតិ កុច្ឆិស្មឹ
សតិ ជិឃច្ឆាបិបាសា ហោតិ ។ ឯវមេវ ខោ ភិក្ខវេ
ចក្ខុស្មឹ សតិ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ អជ្ឈត្តំ
សុខទុក្ខំ ។ បេ ។ ជិវ្ហាយ សតិ ។ បេ ។ មនស្មឹ សតិ
មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ[១] ។

---

១ ម. សុខំ ទុក្ខំ ។ បេ ។ ហត្ថេសុ ។

ទៅមុខនិងឈានថយក្រោយ ក៏មិនប្រាកដ កាលបើមិនមានសន្លាក់ ការបត់ចូលនិងលាចេញ ក៏មិនប្រាកដ កាលបើមិនមានពោះ សេចក្តីស្រេកឃ្លាន ក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ពិតយ៉ាងនេះឯង កាលបើចក្ខុមិនមាន សេចក្តីសុខទុក្ខជាខាងក្នុងក៏មិនកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ។ បេ ។ កាលជិវ្ហាមិនមាន សេចក្តីសុខទុក្ខជាខាងក្នុងក៏មិនកើតឡើង ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។ បេ ។ កាលបើមនោមិនមាន សេចក្តីសុខទុក្ខជាខាងក្នុងក៏មិនកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ ។

[៣០៥] ម្នាលភិក្ខុទាំងឡាយ កាលបើមានដៃ ការកាន់និងការដាក់ចុះក៏មាន កាលបើមានជើង ការឈានទៅមុខនិងឈានថយក្រោយក៏មាន កាលបើមានសន្លាក់ ការបត់ចូលនិងលាចេញក៏មាន កាលបើមានពោះ សេចក្តីស្រេកឃ្លានក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ពិតយ៉ាងនេះឯង កាលបើចក្ខុមាន សេចក្តីសុខទុក្ខជាខាងក្នុងក៏កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ។ បេ ។ កាលបើជិវ្ហាមាន ។ បេ ។ កាលបើមនោមាន សេចក្តីសុខទុក្ខជាខាងក្នុងក៏កើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ ។

សមុទ្ទវគ្គោ តតិយោ

[៣០៦] ហត្ថេសុ ភិក្ខវេ អសតិ អាទាននិក្ខេបនំ ន ហោតិ បាទេសុ អសតិ អភិក្កមប្បដិក្កមោ ន ហោតិ បព្វេសុ អសតិ សម្មិញ្ជនប្បសារណំ ន ហោតិ កុច្ឆិស្មឹ អសតិ ជិឃច្ឆាបិបាសា ន ហោតិ ។ ឯវមេវ ខោ ភិក្ខវេ ចក្ខុស្មឹ អសតិ ចក្ខុសម្ផស្សប្បច្ចយា នុប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខំ ។ បេ ។ ជិវ្ហាសម្ផស្សប្បច្ចយា ។ បេ ។ មនស្មឹ អសតិ មនោសម្ផស្សប្បច្ចយា នុប្បជ្ជតិ អជ្ឈត្តំ សុខទុក្ខន្តិ ។

សមុទ្ទវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ទ្វេ សមុទ្ទា ពាឡិសិកោ
ខីររុក្ខេន កោដ្ឋិកោ
កាមភូ ឧទាយិ ចេវ
អាទិត្តេន ច អដ្ឋមំ
ហត្ថបាទុបមា[១] ចេវ
វគ្គោ តេន បវុច្ចតីតិ ។

---

១ ឱ. ម. ហត្ថបាទុបមា ទុវេ វគ្គោ តេន បវុច្ចតីតិ ។

សមុទ្ទវគ្គ ទី ៣

[៣០៦] ម្នាលភិក្ខុទាំងឡាយ កាលបើមិនមានដៃ ការកាន់និង ការដាក់ចុះក៏មិនមាន កាលបើមិនមានជើង ការឈានទៅមុខនិងឈានថយក្រោយក៏មិនមាន កាលបើមិនមានសន្ទាក់ ការបត់ចូលនិងលាចេញក៏មិនមាន កាលបើមិនមានពោះ សេចក្ដីស្រេកឃ្លានក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ ពិតយ៉ាងនេះឯង កាលបើចក្ខុមិនមាន សេចក្ដីសុខទុក្ខជាខាងក្នុងក៏មិនកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ។ បេ ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។ បេ ។ កាលបើមនោមិនមាន សេចក្ដីសុខទុក្ខជាខាងក្នុងក៏មិនកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ។

ចប់ សមុទ្ទវគ្គ ទី ៣ ។

## ឧទ្ទាននៃសមុទ្ទវគ្គនោះ គឺ

ព្រះអង្គសម្ដែងប្រៀបពីសមុទ្ទ ២ រឿង រឿងព្រានសន្ទូច ១
ប្រៀបដោយដើមឈើមានជ័រដូចទឹកដោះ ១ រឿងព្រះមហា-
កោដ្ឋិកៈ ១ រឿងព្រះកាមភូ ១ រឿងព្រះឧទាយិ ១ អាទិត្ត-
បរិយាយជាគម្រប់ប្រាំបី ១ ទ្រង់សម្ដែងពីដៃជើងនិងសន្ទាក់
២ រឿង ហេតុដូច្នោះ ទើបហៅថាវគ្គ ។

# អាសីវិសវគ្គោ

[៣០៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ សេយ្យថាបិ ភិក្ខវេ ចត្តារោ អាសីវិសា ឧគ្គតេជា ឃោរវិសា ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិកូលោ តមេនំ ឯវំ វទេយ្យុំ ឥមេ តេ អម្ភោ បុរិស ចត្តារោ អាសីវិសា ឧគ្គតេជា ឃោរវិសា កាលេន កាលំ ឧដ្ឋាបេតព្វា កាលេន កាលំ នហាបេតព្វា កាលេន កាលំ ភោជេតព្វា កាលេន កាលំ បវេសេតព្វា ។ យទា ច ខោ តេ អម្ភោ បុរិស ឥមេសំ ចតុន្នំ អាសីវិសានំ ឧគ្គតេជានំ ឃោរវិសានំ អញ្ញតរោ វា អញ្ញតរោ វា កុប្បិស្សតិ តតោ ត្វំ អម្ភោ បុរិស មរណំ វា និគច្ឆសិ មរណមត្តំ វា ទុក្ខំ យំ តេ អម្ភោ បុរិស ករណីយំ តំ ករោហីតិ ។

# អាសីវិសវគ្គ

[៣០៧] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ដូចជាអាសីរពិស ៤ ពួក មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក ។ កាលណោះ មានបុរសចង់រស់ មិនចង់ស្លាប់ ប្រាថ្នាសុខ ខ្ពើមទុក្ខ ដើរមកពួកជនដទៃគប្បីនិយាយនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អាសីរពិស ទាំង៤ពួកនេះ មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹក អ្នកត្រូវឲ្យក្រោកឡើងតាមកាលដ៏គួរ ត្រូវឲ្យងូតទឹកតាមកាលដ៏គួរ ត្រូវឲ្យបរិភោគតាមកាលដ៏គួរ ត្រូវឲ្យចូលទៅដេកតាមកាលដ៏គួរ ។ ម្នាលបុរសដ៏ចម្រើន បណ្តាអាសីរពិសទាំង ៤ ពួក មានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹកទាំងនេះ អាសីរពិសណាក៏ដោយ ៗ នឹងខឹងដល់អ្នក ក្នុងកាលណា ម្នាលបុរសដ៏ចម្រើន ក្នុងកាលណោះ អ្នកនឹងដល់នូវសេចក្តីស្លាប់ ឬដល់ទុក្ខស្មើរនឹងស្លាប់ ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។

[៣០៨] អថខោ សោ ភិក្ខវេ បុរិសោ ភីតោ ចតុន្នំ អាសីវិសានំ ឧគ្គតេជានំ ឃោរវិសានំ យេន វា តេន វា បលាយេថ តមេនំ ឯវំ វទេយ្យុំ ឥមេ តេ អម្ភោ បុរិស បញ្ច វធកា បច្ចត្ថិកា បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា យត្ថេវនំ បស្សិស្សាម តត្ថេវ ជីវិតា វោរោបេស្សាមាតិ យំ តេ អម្ភោ បុរិស ករណីយំ តំ ករោហីតិ ។

[៣០៩] អថខោ សោ ភិក្ខវេ បុរិសោ ភីតោ ចតុន្នំ អាសីវិសានំ ឧគ្គតេជានំ ឃោរវិសានំ ភីតោ បញ្ចន្នំ វធ-កានំ បច្ចត្ថិកានំ យេន វា តេន វា បលាយេថ តមេនំ ឯវំ វទេយ្យុំ អយន្តេ អម្ភោ បុរិស ឆដ្ឋោ អន្តរចរោ វធ-កោ ឧក្ខិត្តាសិកោ បដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ យត្ថេវ-នំ បស្សិស្សាមិ តត្ថេវ[១] សិរោ ចាតេស្សាមីតិ យំ តេ អម្ភោ បុរិស ករណីយំ តំ ករោហីតិ ។

១ ម. តត្ថេវ តេ សិរោ ។

## អាសីវិសវគ្គ ទី ៤

[៣០៨] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង បុរសនោះមានសេចក្តីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជៈដ៏ខ្លាំង មានពិសដ៏ពន្លឹក ហើយក៏រត់ទៅតាមទីផ្តេសផ្តាស ពួកជនដទៃគប្បីនិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះជាពេជ្ឈឃាតទាំង ៥ ជាសត្រូវដេញតាមពីខាងក្រោយខ្នងៗ អ្នក ដោយគិតគ្នាថា យើងទាំងឡាយឃើញបុរសនុ៎ះ ក្នុងទីណា នឹងផ្តាច់ជីវិត ក្នុងទីនោះឯង ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។

[៣០៩] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមានសេចក្តីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជៈដ៏ខ្លាំង មានពិសដ៏ពន្លឹក មានសេចក្តីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ ហើយក៏រត់ទៅតាមទីផ្តេសផ្តាស ពួកជនដទៃគប្បីនិយាយនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នេះជាពេជ្ឈឃាត អ្នកចាំស្កាត់ខាងក្នុងជាគម្រប់ ៦ មានដាវងារឡើង ដេញតាមពីខាងក្រោយខ្នង ។ អ្នក ដោយគិតថា អញឃើញបុរសនោះក្នុងទីណា នឹងកាត់ក្បាលក្នុងទីនោះឯង ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើកិច្ចនោះចុះ ។

[៣១០] អថខោ សោ ភិក្ខវេ បុរិសោ ភីតោ ចតុន្នំ អាសីវិសានំ ឧគ្គតេជានំ ឃោរវិសានំ ភីតោ បញ្ចន្នំ វធកានំ បច្ចត្ថិកានំ ភីតោ ឆដ្ឋស្ស អន្តរចរស្ស វធកស្ស ឧក្ខិត្តាសិកស្ស យេន វា តេន វា បលាយេថ សោ បស្សេយ្យ សុញ្ញំ គាមំ យញ្ញទេវ ឃរំ បវិសេយ្យ រិត្តកំយេវ បវិសេយ្យ តុច្ឆកំយេវ បវិសេយ្យ សុញ្ញកំយេវ បវិសេយ្យ យញ្ញទេវ ភាជនំ បរិមសេយ្យ រិត្តកំយេវ បរិមសេយ្យ តុច្ឆកំយេវ បរិមសេយ្យ សុញ្ញកំយេវ បរិមសេយ្យ ។ តមេនំ ឯវំ វទេយ្យុំ ឥទានិ អម្ភោ បុរិស ឥមំ សុញ្ញគាមំ ចោរា គាមឃាតា បវិសន្តិ យំ តេ អម្ភោ បុរិស ករណីយំ តំ ករោហីតិ ។

[៣១១] អថខោ សោ ភិក្ខវេ បុរិសោ ភីតោ ចតុន្នំ អាសីវិសានំ ឧគ្គតេជានំ ឃោរវិសានំ ភីតោ បញ្ចន្នំ វធកានំ បច្ចត្ថិកានំ ភីតោ ឆដ្ឋស្ស អន្តរចរស្ស វធកស្ស ឧក្ខិត្តាសិកស្ស ភីតោ ចោរានំ គាមឃាតានំ យេន វា តេន វា បលាយេថ សោ បស្សេយ្យ មហន្តំ ឧទកណ្ណវំ ឱរិមំ តីរំ

[៣១០] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ បុរសនោះមាន សេចក្តីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មាន ពិសដ៏ពន្លឹក មានសេចក្តីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ មាន សេចក្តីភិតភ័យនឹងពេជ្ឈឃាតអ្នកចាំស្កាត់ខាងក្នុងជាគម្រប់ ៦ ដែលមាន ដាវង៉ាឡើង ហើយក៏រត់ទៅតាមទីផ្តេសផ្តាស បុរសនោះឃើញស្រុកដ៏ ស្ងាត់ ក៏ចូលទៅរកផ្ទះណាមួយ ផ្ទះនោះក៏ទទេស្អាត ស្ងាត់សូន្យសុង លូកពាវរកភាជន៍ណាមួយ ភាជន៍នោះក៏ទទេស្អាត រលីងសោះសូន្យ ដែរ ។ ពួកជនដទៃគប្បីនិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរស ដ៏ចម្រើន ឥឡូវនេះ ពួកចោរ ធ្លាប់សម្លាប់អ្នកស្រុក តែងចូលមករក ស្រុកស្ងាត់នេះ ម្នាលបុរសដ៏ចម្រើន កិច្ចណាដែលអ្នកគួរធ្វើ ចូរអ្នកធ្វើ កិច្ចនោះចុះ ។

[៣១១] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមាន សេចក្តីភិតភ័យនឹងអាសីរពិសទាំង ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិស ដ៏ពន្លឹក មានសេចក្តីភិតភ័យនឹងពេជ្ឈឃាតទាំង ៥ ជាសត្រូវ មានសេច- ក្តីភិតភ័យនឹងពេជ្ឈឃាតអ្នកចាំស្កាត់ខាងក្នុងជាគម្រប់ ៦ ដែលមានដាវ ង៉ាឡើង មានសេចក្តីភិតភ័យនឹងពួកចោរជាអ្នកសម្លាប់អ្នកស្រុក ហើយក៏ រត់ទៅតាមទីផ្តេសផ្តាស បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាង

សាសង្កំ សប្បដិភយំ បារិមំ តីរំ ខេមំ អប្បដិភយំ នច្ចស្ស នាវា សន្តារណី ឧត្តរសេតុ វា អបារា បារំ គមនាយ ។

[៣១២] អថខោ ភិក្ខវេ តស្ស បុរិសស្ស ឯវ-មស្ស អយំ ខោ មហា ឧទកណ្ណវោ ឱរិមំ តីរំ សាសង្កំ សប្បដិភយំ បារិមំ តីរំ ខេមំ អប្បដិភយំ នច្ចស្ស នាវា សន្តារណី ឧត្តរសេតុ វា អបារា បារំ គមនាយ យន្នូនាហំ តិណកដ្ឋសាខាបលាសំ សង្ក-ឌ្ឍិត្វា កុល្លំ ពន្ធិត្វា តំ កុល្លំ និស្សាយ ហត្ថេ-ហិ ច បាទេហិ ច វាយមមានោ សោត្ថិនា បារំ គច្ឆេយ្យន្តិ ។ អថខោ សោ ភិក្ខវេ បុរិសោ តិណ-កដ្ឋសាខាបលាសំ សង្កឌ្ឍិត្វា កុល្លំ ពន្ធិត្វា តំ កុល្លំ និស្សាយ ហត្ថេហិ ច បាទេហិ ច វាយមមានោ សោត្ថិនា បារំ គច្ឆេយ្យ តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។

អាយ ប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ មានត្រើយខាងនាយដ៏ក្សេម ឥតមានភ័យចំពោះមុខ ទូក ក្បូន ស្ពានឆ្លងដើម្បីឆ្លងអំពីត្រើយអាយទៅត្រើយខាងនាយ ក៏មិនមានសោះ ។

[៣១២] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា នេះឯងហើយជាអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយ ប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ មានត្រើយខាងនាយដ៏ក្សេម ឥតមានភ័យចំពោះមុខ ទូក ក្បូន ស្ពានឆ្លងដើម្បីឆ្លងអំពីត្រើយខាងអាយទៅត្រើយខាងនាយ ក៏មិនមាន បើដូច្នោះមានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើ ចងជាក្បូន អាស្រ័យក្បូននោះហើយ អុំដោយដៃនិងជើងទាំងឡាយ ទើបដល់ទៅត្រើយដោយសួស្ដីបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯងបុរសនោះប្រមូលស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើ មកចងជាក្បូន អាស្រ័យក្បូននោះហើយ អុំដោយដៃនិងជើងទាំងឡាយ ទើបដល់ទៅត្រើយ ដោយសួស្ដី បានឈ្មោះថាជាព្រាហ្មណ៍ឆ្លងដល់ត្រើយហើយឋិតនៅលើគោក ។

[៣១៣] ឧបមា ខោ ម្យាយំ ភិក្ខវេ កតា អត្ថស្ស វិញ្ញាបនាយ អយញ្ចេត្ថ អត្ថោ ចត្តារោ អាសីវិសា ឧគ្គតេជា ឃោរវិសាតិ ខោ ភិក្ខវេ ចតុន្នេតំ មហាភូតានំ អធិវចនំ បឋវីធាតុយា អាបោធាតុយា តេជោធាតុយា វាយោធាតុយា ។ បញ្ច វធកា បច្ចត្ថិកាតិ ខោ ភិក្ខវេ បញ្ចន្នេតំ ឧបាទានក្ខន្ធានំ អធិវចនំ ។ សេយ្យថីទំ ។ រូបុបាទានក្ខន្ធស្ស វេទនុបាទានក្ខន្ធស្ស សញ្ញុបាទានក្ខន្ធស្ស សង្ខារុបាទានក្ខន្ធស្ស វិញ្ញាណុបាទានក្ខន្ធស្ស ។ ឆដ្ឋោ អន្តរចរោ វធកោ ឧក្ខិត្តាសិកោតិ ខោ ភិក្ខវេ នន្ទិរាគស្សេតំ អធិវចនំ ។ សុញ្ញគាមោតិ ខោ ភិក្ខវេ ឆន្នេតំ[១] អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ។

១ ឱ. ឆន្នំ អជ្ឈកានំ ។

[៣១៣] ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើសេចក្តីឧបមានេះ ដើម្បីបញ្ជាក់នូវសេចក្តីអធិប្បាយ ឯសេចក្តីអធិប្បាយ ក្នុងសេចក្តីឧបមានុ៎ះដូច្នេះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាសីរពិស ៤ ពួក ដែលមានតេជះដ៏ខ្លាំង មានពិសដ៏ពន្លឹកនុ៎ះ ជាឈ្មោះនៃមហាភូតរូបទាំង ៤ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពេជ្ឈឃាតទាំង ៥ ជាសត្រូវនុ៎ះ ជាឈ្មោះនៃឧបាទានក្ខន្ធទាំង ៥ ។ គឺអ្វីខ្លះ ។ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពេជ្ឈឃាតអ្នកចាំស្ទាក់ខាងក្នុងជាគម្រប់ ៦ ដែលមានដាវដ៏ឡើងនុ៎ះ ជាឈ្មោះនៃនន្ទិរាគ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។

អាសីវិសវគ្គោ ចតុត្ថោ

[៣១៤] ចក្ខុតោ ចេបិ នំ ភិក្ខវេ បណ្ឌិតោ ព្យត្តោ មេធាវី ឧបបរិក្ខតិ រិត្តកំយេវ ខាយតិ តុច្ឆកំយេវ ខាយតិ សុញ្ញកំយេវ ខាយតិ ។ សោតតោ ចេបិ នំ ភិក្ខវេ បណ្ឌិតោ ព្យត្តោ មេធាវី ឧបបរិក្ខតិ រិត្តកំយេវ ខាយតិ តុច្ឆកំយេវ ខាយតិ សុញ្ញកំយេវ ខាយតិ ។ ឃានតោ ចេបិ នំ ភិក្ខវេ បណ្ឌិតោ ព្យត្តោ មេធាវី ឧបបរិក្ខតិ រិត្តកំយេវ ខាយតិ តុច្ឆកំយេវ ខាយតិ សុញ្ញកំយេវ ខាយតិ ។ ជិវ្ហាតោ ចេបិ នំ ភិក្ខវេ ។ កាយតោ ចេបិ នំ ភិក្ខវេ ។ មនតោ ចេបិ នំ ភិក្ខវេ បណ្ឌិតោ ព្យត្តោ មេធាវី ឧបបរិក្ខតិ រិត្តកំយេវ ខាយតិ តុច្ឆកំយេវ ខាយតិ សុញ្ញកំយេវ ខាយតិ ។ ចោរា គាមឃាតាតិ ខោ ភិក្ខវេ ឆន្នេតំ ពាហិរានំ អាយតនានំ អធិវចនំ ។ ចក្ខុំ ភិក្ខវេ ហញ្ញតិ មនាបាមនាបេសុ រូបេសុ ។ សោតំ ភិក្ខវេ ។ បេ ។ ឃានំ ភិក្ខវេ ។ បេ ។

## អាសីវិសវគ្គ ទី ៤

[៣១៤] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃមានប្រាជ្ញា កំណត់នូវនាមរូបនោះ ថាជាចក្ខុ ចក្ខុនោះប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងឆេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃមានប្រាជ្ញា កំណត់នូវនាមរូបនោះ ថាជាសោតៈ សោតៈនោះ ប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងឆេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃមានប្រាជ្ញា កំណត់នូវនាមរូបនោះ ថាជាឃានៈ ឃានៈនោះ ប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងឆេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលកំណត់នូវនាមរូបនោះថាជាជិវ្ហា ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលកំណត់នូវនាមរូបនោះថាជាកាយ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលជាបណ្ឌិតវាងវៃមានប្រាជ្ញា កំណត់នូវនាមរូបនោះ ថាជាមនោ មនោនោះ ប្រាកដជារបស់ទទេ ប្រាកដជារបស់រលីងឆេង ប្រាកដជារបស់សូន្យសោះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពួកចោរអ្នកសម្លាប់អ្នកស្រុកនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុរមែងបៀតបៀនចំពោះរូបទាំងឡាយ ជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ សោតៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ឃានៈ ។ បេ ។

ជិវ្ហា ភិក្ខវេ ហញ្ញតិ មនាបាមនាបេសុ រសេសុ ។ កា-
យោ ភិក្ខវេ ។ បេ ។ មនោ ភិក្ខវេ ហញ្ញតិ មនាបា-
មនាបេសុ ធម្មេសុ ។ មហាឧទកណ្ណវោតិ ខោ ភិក្ខវេ
ចតុន្នេតំ ឱឃានំ អធិវចនំ កាមោឃស្ស ភវោឃស្ស
ទិដ្ឋោឃស្ស អវិជ្ជោឃស្ស ។ ឱរិមំ តីរំ សាសង្កំ
សប្បដិភយន្តិ ខោ ភិក្ខវេ សក្កាយស្សេតំ អធិវចនំ ។
បារិមំ តីរំ ខេមំ អប្បដិភយន្តិ ខោ ភិក្ខវេ និព្វានស្សេតំ
អធិវចនំ ។ កុល្លន្តិ ខោ ភិក្ខវេ អរិយស្សេតំ អដ្ឋង្គិ-
កស្ស មគ្គស្ស អធិវចនំ ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ
។ បេ ។ សម្មាសមាធិ ។ ហត្ថេហិ ច បាទេហិ ច វា-
យមមានោតិ ខោ ភិក្ខវេ វីរិយារម្ភស្សេតំ អធិវចនំ ។
តិណ្ណោ បារគតោ ថលេ តិដ្ឋតិ ព្រាហ្មណោតិ ខោ
ភិក្ខវេ អរហតោ ឯតំ អធិវចនន្តិ ។ បឋមំ ។

ម្នាលភិក្ខុទាំងឡាយ ជិវ្ហារមែងបៀតបៀនចំពោះរសទាំងឡាយ ជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ កាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មនោរមែងបៀតបៀនចំពោះធម្មារម្មណ៍ ជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អន្លង់ទឹកជំនុំះ ជាឈ្មោះនៃឱឃៈទាំង ៤ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ត្រើយអាយប្រកបដោយសេចក្តីរង្កៀស ប្រកបដោយភ័យចំពោះមុខនុ៎ះ ជាឈ្មោះនៃសក្កាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ត្រើយនាយដ៏ក្សេម ឥតមានភ័យចំពោះមុខនុ៎ះ ជាឈ្មោះនៃព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ក្បូននុ៎ះ ជាឈ្មោះនៃមគ្គមានអង្គ ៨ ដ៏ប្រសើរ ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អុំដោយដៃនិងជើងទាំងឡាយនុ៎ះ ជាឈ្មោះនៃការប្រារព្ធសេចក្តីព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ឆ្លងដល់ត្រើយឋិតនៅលើគោកនុ៎ះ ជាឈ្មោះនៃព្រះអរហន្ត ។ ចប់សូត្រ ទី ១ ។

## អាសីវិសវគ្គោ ចតុត្ថោ

[៣១៩] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយ ។ កតមេហិ តីហិ ។ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ភោជនេ មត្តញ្ញូ ជាគរិយំ អនុយុត្តោ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ ភិក្ខវេ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។

អាសីវិសវគ្គ ទី ៤

[៣១៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ ជាអ្នកច្រើនដោយសុខនិងសោមនស្ស សម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ននេះមួយទៀត ភិក្ខុនោះប្រារព្ធហេតុដើម្បីសេចក្តីអស់ទៅ នៃអាសវៈទាំងឡាយ ។ ធម៌ ៣ តើអ្វីខ្លះ ។ គឺភិក្ខុអ្នកមានទ្វាររក្សាក្នុងឥន្ទ្រិយទាំងឡាយ ១ ដឹងប្រមាណក្នុងភោជន ១ ប្រកបរឿយ ៗ ក្នុងការភ្ញាក់រឭក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ មិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយនោះ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយនោះ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាប់រសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងច្បាស់នូវធម៌ដោយចិត្ត មិនប្រកាន់និមិត្ត មិនប្រកាន់អនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយនោះ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយនោះ ។

សេយ្យថាបិ ភិក្ខវេ សុភូមិយំ ចាតុម្មហាបថេ អាជញ្ញរថោ យុត្តោ អស្សដ្ឋិតោ ឱធតបតោទោ[១] តមេនំ ទក្ខោ យោគ្គាចរិយោ[២] អស្សទម្មសារថិ អភិរូហិត្វា វាមេន ហត្ថេន រស្មិយោ គហេត្វា ទក្ខិណេន ហត្ថេន បតោទំ គហេត្វា យេនិច្ឆកំ យទិច្ឆកំ សារេយ្យាបិ បច្ចាសារេយ្យាបិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមេសំ ឆន្នំ ឥន្ទ្រិយានំ អារក្ខាយ សិក្ខតិ សញ្ញមាយ សិក្ខតិ ទមាយ សិក្ខតិ ឧបសមាយ សិក្ខតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

[៣១៦] កថញ្ច ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ

១ ឱ. អស្ស ឱធសតបតោទោ ។ ម. ឱវន្តរបតោទោ ។ ២ យោគាចរិយោតិ យុត្តតរោ ។

ម្នាលភិក្ខុទាំងឡាយ ដូចជារថទឹមដោយសេះអាជានេយ្យដែលបុគ្គលទឹមហើយ មានសេះបញ្ឈរនៅ មានជន្ទួញផ្គងឡើងហើយ ក្នុងផ្លូវធំបែកជា ៤ មានផែនដីដ៏ស្មើ អាចារ្យបង្ហាត់ដ៏ប៉ិនប្រសប់ ជាសារថីអ្នកបង្ហាត់សេះ ឡើងជិះរថនោះ ដៃឆ្វេងកាន់ខ្សែបរ ដៃស្តាំកាន់ជន្ទួញ បរទៅបរមកកាន់ទីដែលខ្លួនប្រាថ្នាហើយ ៗ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុសិក្សាដើម្បីរក្សា សិក្សាដើម្បីសង្រួម សិក្សាដើម្បីទូន្មាន សិក្សាដើម្បីស្ងប់រម្ងាប់ឥន្ទ្រិយទាំង ៦ នេះ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយ យ៉ាងនេះឯង ។

[៣១៦] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកដឹងប្រមាណក្នុងភោជនតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយប្រាជ្ញាហើយ ឆាន់អាហារដើម្បីលេងក៏ទេ ដើម្បីសេចក្តីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងក៏ទេ ដើម្បីស្អិតស្អាងក៏ទេ កំណត់ទុកដើម្បីតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈថា អាត្មាអញ កម្ចាត់បង់នូវវេទនាចាស់ផង នឹងមិនញ៉ាំងវេទនាថ្មីឲ្យកើតឡើងផង

យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ វណំ អាលិម្បេយ្យ យាវទេវ រោបនត្ថាយ[១] សេយ្យថា វា បន អក្ខំ អព្ភញ្ជេយ្យ យាវទេវ ភារស្ស និត្ថរណត្ថាយ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។

---

១ ឱ. រោបនត្ថាយ ។ ម. គោបនត្ថាយ ។

កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសក្តី កិរិយានៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសលាបសម្បុរកាយ ប្រយោជន៍តែនឹងធ្វើសេវនកិច្ចប៉ុណ្ណោះ ឬក៏ដូចបុរសលាបភ្លៅរទេះ ប្រយោជន៍តែនឹងដឹកនាំភារៈប៉ុណ្ណោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាដោយឧបាយប្រាជ្ញាហើយទើបឆាន់អាហារ ដើម្បីលេងក៏ទេ ដើម្បីសេចក្តីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងក៏ទេ ដើម្បីស្អិតស្អាងក៏ទេ គ្រាន់តែកំណត់ដើម្បីតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់នូវសេចក្តីបៀតបៀន ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈថា អាត្មាអញកម្ចាត់បង់នូវវេទនាចាស់ផង នឹងញ៉ាំងវេទនាថ្មីមិនឲ្យកើតឡើងផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសក្តី កិរិយានៅសប្បាយក្តី នឹងមានដល់អាត្មាអញ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកដឹងប្រមាណក្នុងភោជន យ៉ាងនេះឯង ។

[៣១៧] កថញ្ច ភិក្ខវេ ភិក្ខុ ជាគរិយំ អនុ-
យុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ទិវសំ ចង្កមេន
និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ
រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេ-
ហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ
ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេន
បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ
មនសិ ករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន
និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ។
ឯវំ ខោ ភិក្ខវេ ភិក្ខុ ជាគរិយមនុយុត្តោ ហោតិ ។
ឥមេហិ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ
ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិ
ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយាតិ ។ ទុតិយំ ។

[៣១៧] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកប្រកបរឿយ ៗ ក្នុងការភ្ញាក់រឭក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជម្រះចិត្តចាកធម៌ជាគ្រឿងរាំងរាទាំងឡាយ ដោយការចង្រ្កមនិងការអង្គុយក្នុងវេលាថ្ងៃ ជម្រះចិត្តចាកធម៌ជាគ្រឿងរាំងរាទាំងឡាយ ដោយការចង្រ្កមនិងការអង្គុយអស់បឋមយាមនៃរាត្រី សម្រេចសីហសេយ្យាសដោយចំហៀងខាងស្តាំ តម្រួតជើងដោយជើង ជាអ្នកមានស្មារតី មានសេចក្តីដឹងខ្លួន ធ្វើនូវឧដ្ឋានសញ្ញា (កំណត់ពេលក្រោក) ទុកក្នុងចិត្តអស់មជ្ឈិមយាមនៃរាត្រី ក្រោកឡើងក្នុងបច្ឆិមយាមនៃរាត្រី ជម្រះចិត្តចាកធម៌ជាគ្រឿងរាំងរាទាំងឡាយ ដោយការចង្រ្កមនិងការអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រកបរឿយ ៗ ក្នុងការភ្ញាក់រឭក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ នេះឯង ជាអ្នកច្រើនដោយសុខនិងសោមនស្ស សម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ននេះមួយទៀត ភិក្ខុនោះប្រារព្ធហេតុដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ចប់សូត្រ ទី ២ ។

អាសីវិសវគ្គោ ចតុត្ថោ

[៣១៨] ភូតបុព្វំ ភិក្ខវេ កុម្មោ កច្ឆបោ សាយណ្ហសមយំ អនុនទីតីរេ គោចរបសុតោ អហោសិ ។ សិគាលោបិ ខោ ភិក្ខវេ សាយណ្ហសមយំ អនុនទីតីរេ គោចរបសុតោ អហោសិ ។ អទ្ទសា ខោ ភិក្ខវេ កុម្មោ កច្ឆបោ សិគាលំ ទូរតោវ គោចរបសុតំ ទិស្វាន សោណ្ឌិបញ្ចមានិ អង្គានិ សកេ កបាលេ សមោទហិត្វា អប្បោស្សុក្កោ តុណ្ហីភូតោ សង្កសាយតិ ។ សិគាលោបិ ខោ ភិក្ខវេ អទ្ទស កុម្មំ កច្ឆបំ ទូរតោវ គោចរបសុតំ ទិស្វាន យេន កុម្មោ កច្ឆបោ តេនុបសង្កមិ ឧបសង្កមិត្វា កុម្មំ កច្ឆបំ បច្ចុបដ្ឋិតោ អហោសិ ។ យទាយំ កុម្មោ កច្ឆបោ សោណ្ឌិបញ្ចមានំ អង្គានំ អញ្ញតរំ វា អញ្ញតរំ វា អង្គំ អភិនិន្នាមេស្សតិ តត្ថេវ នំ គហេត្វា ឧទ្ទាលិត្វា ខាទិស្សាមីតិ ។

## អាសីវិសវគ្គ ទី ៤

[៣១៨] ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកថា មានអណ្តើកសង្កល់មួយ ខ្វល់ខ្វាយរកចំណីតាមឆ្នេរស្ទឹង ក្នុងសាយណ្ហសម័យ ។ ម្នាលភិក្ខុទាំងឡាយ ឯសត្វចចកក៏ខ្វល់ខ្វាយរកចំណីតាមឆ្នេរស្ទឹង ក្នុងសាយណ្ហសម័យដែរ ។ ម្នាលភិក្ខុទាំងឡាយ អណ្តើកសង្កល់បានឃើញចចកខ្វល់ខ្វាយរកចំណីអំពីចម្ងាយ លុះឃើញហើយ ក៏ពន្ទឹបនូវអវយវៈទាំងឡាយមានក្បាលជាគម្រប់ ៥ ចូលក្នុងស្នូករបស់ខ្លួន មានសេចក្តីខ្វល់ខ្វាយតិច ស្ងៀមសម្ងំនៅ ។ ម្នាលភិក្ខុទាំងឡាយ ឯចចកបានឃើញអណ្តើកសង្កល់ខ្វល់ខ្វាយរកចំណីអំពីចម្ងាយ លុះឃើញហើយ ក៏ចូលទៅរកអណ្តើកសង្កល់ លុះចូលទៅដល់ហើយ ក៏ឈរក្នុងទីចំពោះមុខអណ្តើកសង្កល់ ។ ចចកនោះគិតថា កាលណាអណ្តើកសង្កល់នេះលៀនអវយវៈទាំងឡាយមានក្បាលគម្រប់ ៥ អវយវៈណា ៗ ចេញមកក៏ដោយ អញនឹងខាំទាញអវយវៈនោះ មកស៊ីក្នុងទីនោះឯង ក្នុងកាលណោះ ។

យថា ខោ ភិក្ខវេ កុម្មោ កច្ឆបោ សោណ្ឌិបញ្ចមានំ អង្គានំ អញ្ញតរំ វា អញ្ញតរំ វា អង្គំ អភិនិន្នាមិ ។ អថ សិគាលោ កុម្មម្ហា និព្វិជ្ជ បក្កាមិ ឱតារំ អលភមានោ ។ ឯវមេវ ខោ ភិក្ខវេ តុម្ហេហិ មារោ បាបិមា សតតំ សមិតំ បច្ចុបដ្ឋិតោ អប្បេវ នាមាហំ ឥមេសំ ចក្ខុតោ វា ឱតារំ លភេយ្យំ ។ បេ ។ ជិវ្ហាតោ វា ឱតារំ លភេយ្យំ ។ បេ ។ មនតោ វា ឱតារំ លភេយ្យន្តិ ។ តស្មាតិហ ភិក្ខវេ ឥន្ទ្រិយេសុ គុត្តទ្វារា វិហរថ ចក្ខុនា រូបំ ទិស្វា មា និមិត្តគ្គាហិនោ អហុវត្ថ មា អនុព្យញ្ជនគ្គាហិនោ យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជថ រក្ខថ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជថ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។

ម្នាលភិក្ខុទាំងឡាយ កាលណាអណ្តើកសង្កត់លៀនអវយវៈទាំងឡាយ មានក្បាលជាគម្រប់ ៥ អវយវៈណា ៗ ចេញមក ។ គ្រានោះចចកមិនបាននូវឱកាស ក៏លាកចិត្តគេចចេញអំពីអណ្តើកសង្កត់ទៅ ។ ម្នាលភិក្ខុទាំង-ឡាយ មារមានចិត្តបាប ដែលអ្នកទាំងឡាយបណ្តោយឲ្យដើបឡើងបានរឿយ ៗ ហើយ រមែងគិតថា ធ្វើម្តេច អញនឹងបានចន្លោះអំពីភ្នែករបស់ភិក្ខុទាំងឡាយនេះក្តី ។ បេ ។ គប្បីបានចន្លោះអំពីអណ្តាតក្តី ។ បេ ។ គប្បីបានចន្លោះអំពីចិត្តក្តី ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវមានទ្វាររក្សាក្នុងឥន្ទ្រិយទាំងឡាយ ឃើញរូបដោយចក្ខុ កុំប្រកាន់យកនិមិត្ត កុំប្រកាន់យកអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយនោះ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាបរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។

មនសា ធម្មំ វិញ្ញាយ មា និមិត្តគ្គាហិនោ អហុវត្ថ មា អនុព្យញ្ជនគ្គាហិនោ យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុស-លា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជថ រក្ខថ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជថ ។ យតោ តុម្ហេ ភិក្ខវេ ឥន្ទ្រិយេសុ គុត្តទ្វារា វិហរិស្សថ ។ អថ តុម្ហេហិបិ មារោ បាបិមា និព្វិជ្ជ បក្កមិស្សតិ ឱតារំ អលភមានោ ។ កុម្មម្ហាវ សិគាលោតិ ។

[៣១៩] កុម្មោវ អង្គានិ សកេ កបាលេ សមោ-ទហំ ភិក្ខុ មនោវិតក្កេ អនិស្សិតោ អញ្ញមហេឋយា-នោ[១] បរិនិព្វុតោ ន ឧបវទេយ្យ កញ្ចីតិ ។ តតិយំ ។

[៣២០] ឯកំ សមយំ ភគវា អយុជ្ឈាយំ[២] វិហរតិ គង្គាយ នទិយា តីរេ ។ អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា តីរេ សោតេន វុយ្ហមានំ

១ ម. អញ្ញមហេឋមានោ ។ ២ ឱ. កោសម្ពិយំ ។

ដឹងច្បាស់នូវធម៌ដោយចិត្ត កុំប្រកាន់យកនិមិត្ត កុំប្រកាន់យកអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនោះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា អ្នកទាំងឡាយ ចូរប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយនោះ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលណាអ្នកទាំងឡាយ មានទ្វាររក្សាហើយក្នុងឥន្ទ្រិយទាំងឡាយ សម្រេចសម្រាន្តនៅ ។ កាលនោះ មារមានចិត្តបាប កាលបើមិនបានឱកាស នឹងលាកចិត្តគេចចេញអំពីអ្នកទាំងឡាយទៅ ។ ដូចជាចចកលាកចិត្តគេចចេញអំពីអណ្តើកដូច្នោះដែរ ។

[៣១៩] ភិក្ខុមិនអាស្រ័យនូវមនោវិតក្កៈ មិនបៀតបៀនបុគ្គលដទៃ បរិនិព្វានហើយ មិនតិះដៀលបុគ្គលណាមួយឡើយ ដូចជាអណ្តើកសង្កត់លីបនូវអវយវៈទាំងឡាយចូលក្នុងស្នូករបស់ខ្លួន ។ ចប់សូត្រ ទី ៣ ។

[៣២០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅជិតឆ្នេរទន្លេគង្គា ទៀបក្រុងអជ្ឈេយៈ ។ ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹក ក្នុងឆ្នេរទន្លេគង្គា

ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ អមុំ មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា សោតេន វុយ្ហមា-នន្តិ ។ ឯវំ ភន្តេ ។ សចេ ខោ ភិក្ខវេ ទារុក្ខន្ធោ ន ឱរិមំ តីរំ ឧបគច្ឆតិ ន បារិមំ តីរំ ឧបគច្ឆតិ ន មជ្ឈេ សំសីទិស្សតិ ន ថលេ ឧស្សាទិស្សតិ ន មនុស្សគ្គាហោ គាហិយតិ[១] ន អមនុស្សគ្គាហោ គាហិយតិ ន អាវដ្ដ-គ្គាហោ គាហិយតិ ន អន្តោបូតិ ភវិស្សតិ ។ ឯវំ ហិ សោ ភិក្ខវេ ទារុក្ខន្ធោ សមុទ្ទនិន្នោ ភវិស្សតិ សមុទ្ទ-ពោណោ សមុទ្ទបព្ភារោ ។ តំ កិស្ស ហេតុ ។ សមុទ្ទ-និន្នោ ភិក្ខវេ គង្គាយ នទិយា សោតោ សមុទ្ទពោណោ សមុទ្ទបព្ភារោ ។ ឯវមេវ ខោ ភិក្ខវេ សចេ តុម្ហេបិ ន ឱរិមំ តីរំ ឧបគច្ឆថ ន បារិមំ តីរំ ឧបគច្ឆថ ន មជ្ឈេ សំសីទិស្សថ ន ថលេ ឧស្សាទិស្សថ ន មនុស្សគ្គា-ហោ គាហិយតិ[២] ន អមនុស្សគ្គាហោ គាហិយតិ ន អាវដ្ដគ្គាហោ គាហិយតិ ន អន្តោបូតិ ភវិស្សតិ ។

១ ភវិស្សតិ ។ ២ ឱ. ហេស្សថ ។ ម. គាហេស្សថ ។

លុះទតហើយទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញកំណាត់ឈើឯណោះ កំពុងអណ្តែតតាមខ្សែទឹកទន្លេគង្គាដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បើកំណាត់ឈើមិនអណ្តែតមកកាន់ត្រើយអាយ មិនទៅកាន់ត្រើយនាយ មិនលិចចុះក្នុងកណ្តាល មិនរសាត់ឡើងទៅលើគោក មិនមានមនុស្សចាប់យក មិនមានអមនុស្សចាប់យក មិនមានទឹកវល់ក្ហួចយក និងមិនស្អុយខាងក្នុងទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ កំណាត់ឈើនោះនឹងរសាត់ទៅរកសមុទ្រ វេទៅរកសមុទ្រ ផ្ទាកទៅរកសមុទ្រ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាខ្សែទឹកទន្លេគង្គា ហូរទៅរកសមុទ្រ វេទៅរកសមុទ្រ ផ្ទាកទៅរកសមុទ្រ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនឡើងកាន់ត្រើយខាងអាយ មិនចូលទៅកាន់ត្រើយខាងនាយ មិនលិចចុះត្រង់កណ្តាល មិនរសាត់ឡើងលើគោក មិនមានមនុស្សចាប់យក មិនមានអមនុស្សចាប់យក មិនមានទឹកវល់ក្ហួចយក និងមិនស្អុយខាងក្នុងទេ ។

ឯវំ តុម្ហេ ភិក្ខវេ និព្វាននិន្នា ភវិស្សថ និព្វានបោណា និព្វានបព្ភារា ។ តំ កិស្ស ហេតុ ។ និព្វាននិន្នា ភិក្ខវេ សម្មាទិដ្ឋិ និព្វានបោណា និព្វានបព្ភារាតិ ។

[៣២១] ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទ-វោច កឹ នុ ខោ ភន្តេ ឱរិមំ តីរំ កឹ បារិមំ តីរំ កោ មជ្ឈេ សំសីទិតោ កោ ថលេ ឧស្សាទោ កោ មនុ-ស្សគ្គាហោ កោ អមនុស្សគ្គាហោ កោ អាវដ្ដគ្គាហោ កោ អន្តោបូតិភាវោតិ ។ ឱរិមំ តីរន្តិ ខោ ភិក្ខុ ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ។ បារិមំ តីរន្តិ ខោ ភិក្ខុ ឆន្នេតំ ពាហិរានំ អាយតនានំ អធិវចនំ ។ មជ្ឈេ សំសីទិតោតិ[១] ខោ ភិក្ខុ នន្ទិរាគស្សេតំ អធិវចនំ ។ ថលេ ឧស្សាទោតិ ខោ ភិក្ខុ អស្មិមានស្សេតំ អធិវ-ចនំ ។ កតមោ ច ភិក្ខុ មនុស្សគ្គាហោ ។ ឥធ ភិក្ខុ គិហីហិ សំសដ្ឋោ វិហរតិ សហនន្ទិ សហសោកី

១ សំសីទោតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ អ្នកទាំងឡាយ នឹងឱនទៅរកព្រះនិព្វាន វេទៅរកព្រះនិព្វាន ផ្អាកទៅរកព្រះនិព្វាន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាសម្មាទិដ្ឋិតែងឱនទៅរកព្រះនិព្វាន វេទៅរកព្រះនិព្វាន ផ្អាកទៅរកព្រះនិព្វាន យ៉ាងនោះឯង ។

[៣២១] កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាត្រើយអាយ អ្វីជាត្រើយនាយ អ្វីដែលលិចចុះក្នុងកណ្តាល អ្វីដែលរសាត់ទៅលើគោក អ្វីជាមនុស្សចាប់យក អ្វីជាអមនុស្សចាប់យក អ្វីជាទឹកវល់ក្តួចយក អ្វីជាសភាពស្អុយក្នុង ។ ម្នាលភិក្ខុ ពាក្យថា ត្រើយអាយនេះជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។ ម្នាលភិក្ខុ ពាក្យថា ត្រើយនាយនេះជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលភិក្ខុ ពាក្យថា លិចចុះក្នុងកណ្តាល នេះជាឈ្មោះនៃនន្ទិរាគ ។ ម្នាលភិក្ខុ ពាក្យថា រសាត់ទៅលើគោក នេះជាឈ្មោះនៃអស្មិមានៈ ។ ម្នាលភិក្ខុ ចុះមនុស្សចាប់យក តើដូចម្តេច ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ នៅច្រឡូកច្រឡំដោយពួកគ្រហស្ថ មានសេចក្តីរីករាយជាមួយគ្នា មានសេចក្តីសោយសោកជាមួយគ្នា

សុខិតេសុ សុខិតោ ទុក្ខិតេសុ ទុក្ខិតោ ឧប្បន្នេសុ កិច្ចករណីយេសុ អត្តនោ យោគំ[១] អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខុ មនុស្សត្តាហោ ។ កតមោ ច ភិក្ខុ អមនុស្សត្តាហោ ។ ឥធ ភិក្ខុ ឯកច្ចោ អញ្ញតរំ ទេវនិកាយំ បណិធាយ ព្រហ្មចរិយំ ចរតិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា ទេវោ វា ភវិស្សាមិ ទេវញ្ញតរោ វាតិ ។ អយំ វុច្ចតិ ភិក្ខុ អមនុស្សត្តាហោ ។ អាវដ្តត្តាហោតិ ខោ ភិក្ខុ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ កតមោ ច ភិក្ខុ អន្តោបូតិភាវោ ។ ឥធ ភិក្ខុ ឯកច្ចោ ទុស្សីលោ ហោតិ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុកជាតោ ។ អយំ វុច្ចតិ ភិក្ខុ អន្តោបូតិភាវោតិ ។

---

១ ឱ. ម. អត្តនា តេសុយោគំ ។

កាលបើពួកគ្រហស្ថបានសុខ ក៏បានសេចក្តីសុខ កាលបើពួកគ្រហស្ថបានទុក្ខ ក៏បានសេចក្តីទុក្ខ កាលបើកិច្ចដែលត្រូវធ្វើកើតឡើង ក៏ខំប្រឹងប្រែងធ្វើដោយខ្លួនឯង ។ ម្នាលភិក្ខុ នេះហៅថា មនុស្សចាប់យក ។ ម្នាលភិក្ខុ ចុះអមនុស្សចាប់យក តើដូចម្តេច ។ ម្នាលភិក្ខុ ភិក្ខុពួកខ្លះក្នុងសាសនានេះ បានប្រព្រឹត្តព្រហ្មចរិយធម៌ដើម្បីប្រាថ្នាទៅកើតក្នុងពួកទេវតាណាមួយថា អាត្មាអញ សូមបានជាទេវតា ឬ ជាទេវតាណាមួយដោយសីលឬដោយវត្ត ដោយតបៈឬដោយព្រហ្មចរិយធម៌នេះ ។ ម្នាលភិក្ខុ នេះហៅថា អមនុស្សចាប់យក ។ ម្នាលភិក្ខុ ពាក្យថា ទឹកវល់ក្តួចយក នេះជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុ ចុះបុគ្គលមានសភាពស្អុយខាងក្នុង តើដូចម្តេច ។ ម្នាលភិក្ខុ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មិនស្អាត មានមារយាទដែលបុគ្គលដទៃគប្បីរង្កៀស មានអំពើបិទបាំងទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានសេចក្តីស្មោកគ្រោក ដោយកិលេស ។ ម្នាលភិក្ខុ នេះហៅថា បុគ្គលមានសភាពជាអ្នកស្អុយខាងក្នុង ។

អាសីវិសវគ្គោ ចតុត្ថោ

[៣៦២] តេន ខោ បន សមយេន នន្ទោ គោបាលកោ ភគវតោ អវិទូរេ ឋិតោ ហោតិ ។ អថខោ នន្ទោ គោបាលកោ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ន ឱរិមំ តីរំ ឧបគច្ឆាមិ ន បារិមំ តីរំ ឧបគច្ឆាមិ ន មជ្ឈេ សំសីទិស្សាមិ ន ថលេ ឧស្សីទិស្សាមិ[១] ន[២] មនុស្សគ្គាហោ គាហិយតិ ន អមនុស្សគ្គាហោ គាហិយតិ ន អាវដ្ដគ្គាហោ គាហិយតិ ន អន្តោបូតិ ភវិស្សាមិ សាធុ លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ តេនហិ ត្វំ នន្ទ សាមិកានំ គាវោ និយ្យាទេហីតិ ។ គមិស្សន្តិ ភន្តេ គាវោ វច្ឆគិទ្ធិនិយោតិ ។ និយ្យាទេហោវ[៣] ត្វំ នន្ទ សាមិកានំ គាវោតិ ។ អថខោ នន្ទោ គោបាលកោ សាមិកានំ គាវោ និយ្យាទេត្វា យេន ភគវា តេនុបសង្កមិ

---

១ ឱ. ម. ឧស្សីទិស្សាមិ ។ ២ ន មំ មនុស្សគ្គាហោ ។ ៣ និយ្យាតេហេវាតិ អដ្ឋកថាយំ ទិស្សតិ ។

អាសីវិសវគ្គ ទី ៤

[៣៦៦] សម័យនោះឯង នន្ទគោបាល (នាយគោបាលឈ្មោះនន្ទៈ) ឋិតនៅក្នុងទីជិតព្រះមានព្រះភាគ ។ លំដាប់នោះ នន្ទគោបាលបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឡើងមកកាន់ត្រើយអាយ មិនចូលទៅកាន់ត្រើយនាយ មិនលិចចុះត្រង់កណ្តាល មិនសោត់ទៅលើគោក មិនមានមនុស្សចាប់យក មិនមានអមនុស្សចាប់យក មិនមានទឹកវល់ក្តួចយក និងមិនស្អុយខាងក្នុងទេ បពិត្រព្រះអង្គដ៏ចម្រើន សូមមេត្តាប្រោស ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ម្នាលនន្ទៈ បើដូច្នោះ ចូរអ្នកប្រគល់គោទាំងឡាយឲ្យដល់ម្ចាស់គេវិញចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន មេគោទាំងឡាយដែលជាប់ចំពាក់ដោយកូនគោ នឹងទៅតាម (កូនគោ) ។ ម្នាលនន្ទៈ ណ្ហើយចុះ ចូរអ្នកប្រគល់គោឲ្យម្ចាស់គេចុះ ។ លំដាប់នោះ នន្ទគោបាលប្រគល់គោទាំងឡាយឲ្យដល់ម្ចាស់ហើយ

ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និយ្យាតា ភន្តេ សាមិកានំ គាវោ លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ នន្ទោ គោបាលកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទន្តិ ។ អចិរូបសម្បន្នោ ច បនាយស្មា នន្ទោ ឯកោ វូបកដ្ឋោ ។ បេ ។ អញ្ញតរោ ច បនាយស្មា នន្ទោ អរហតំ អហោសីតិ ។ ចតុត្ថំ ។

[៣២៣] ឯកំ សមយំ ភគវា កិម្ពិលាយំ វិហរតិ គង្គាយ នទិយា តីរេ ។ អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា សោតេន វុយ្ហមានំ ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ អមុំ មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា សោតេន វុយ្ហមានន្តិ ។ ឯវំ ភន្តេ ។ បេ ។ ឯវំ វុត្តេ អាយស្មា កិម្ពិលោ ភគវន្តំ ឯតទវោច កិន្នុខោ ភន្តេ ឱរិមំ តីរំ ។ បេ ។ កាតមោ ច កិម្ពិល អន្តោបូតិភាវោ ។ ឥធ កិម្ពិល ភិក្ខុ

ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គោទាំង-ឡាយ ខ្ញុំព្រះអង្គបានប្រគល់ឲ្យម្ចាស់គេហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីបានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ នន្ទគោបាលក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លុះព្រះនន្ទៈមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ជាបុគ្គលម្នាក់ឯង ចៀសចេញទៅ ។ បេ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះនន្ទៈមានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។ ចប់សូត្រ ទី ៤ ។

[៣២៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅជិតឆ្នេរទន្លេគង្គា ទៀបក្រុងកិម្មិលា ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញកំ-ណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹកទន្លេគង្គា លុះទតឃើញទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញកំណាត់ឈើធំឯណោះ កំពុងអណ្តែតតាមខ្សែទឹកទន្លេគង្គាដែរឬ ។ ព្រះករុណា ព្រះអង្គ ។ បេ ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះកិម្មិលៈមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាត្រើយនាយ ។ បេ ។ ម្នាលកិម្មិលៈ ចុះបុគ្គលមានសភាពស្អុយខាងក្នុង តើដូចម្តេច ។ ម្នាលកិម្មិលៈ ភិក្ខុក្នុង

អញ្ញតរំ សង្ឃាទិសេសំ អាបត្តឹ អាបន្នោ ហោតិ យថារូបា-
យ អាបត្តិយា ន វុដ្ឋានំ បញ្ញាយតិ អយំ វុច្ចតិ ភិក្ខវេ-
ល អន្តោបូតិភាវេតិ ។ បឋមំ ។

[៣២៤] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ
កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន
កបិលវត្ថុវាសីនំ សក្យានំ នវំ សណ្ឋាគារំ អចិរការិតំ
ហោតិ អនជ្ឈាវុត្ថំ សមណេន វា ព្រាហ្មណេន វា កេ-
នចិ វា មនុស្សភូតេន ។ អថខោ កាបិលវត្ថវា សក្យា
យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ
អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា
ខោ កាបិលវត្ថវា សក្យា ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ
កបិលវត្ថុវាសីនំ សក្យានំ នវំ សណ្ឋាគារំ អចិរកា-
រិតំ[១] អនជ្ឈាវុត្ថំ សមណេន វា ព្រាហ្មណេន វា កេនចិ
វា មនុស្សភូតេន ។ តំ ភន្តេ ភគវា បឋមំ បរិភុញ្ជតុ

---

១ ឯត្ថន្តរេ ហោតីតិ បទំ យុត្តតរំ ។

សាសនានេះ ត្រូវអាបត្តិជាគ្រឿងសៅហ្មងណាមួយ មិនបានចេញចាក អាបត្តិតាមសភាពសមគួរ ម្នាលកិម្មិលៈ នេះហៅថា បុគ្គលមានសភាព ស្អុយខាងក្នុង ។ ចប់សូត្រ ទី ៤ ។

[៣២៤] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធា-រាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះដំណាក់ថ្មី ដែលពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ ទើបនឹងធ្វើហើយ មិនយូរប៉ុន្មាន ដែលសមណៈឬព្រាហ្មណ៍ ឬមនុស្សណាមួយ មិនទាន់ដែលបានមកសំណាក់អាស្រ័យនៅឡើយ ។ លំដាប់នោះ ពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សម-គួរ ។ លុះពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ព្រះដំណាក់ថ្មី ដែលពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ ទើបតែនឹងសង់ហើយមិនយូរប៉ុន្មាន ដែលសមណៈឬព្រាហ្មណ៍ ឬមនុស្សណាមួយ មិនទាន់ដែលបានមកសំណាក់អាស្រ័យនៅឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ប្រើប្រាស់ព្រះដំណាក់នោះជាមុន

ភគវតា បឋមំ បរិភុត្តំ បច្ឆា កាបិលវត្ថវា សក្យា បរិភុញ្ជិស្សន្តិ តទស្ស កាបិលវត្ថុវាសីនំ សក្យានំ ទីឃរត្តំ ហិតាយ សុខាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ កាបិលវត្ថវា សក្យា ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន នវំ សណ្ឋាគារំ តេនុបសង្កមឹសុ ឧបសង្កមិត្វា សព្វសន្ថរិសន្ថតំ សណ្ឋាគារំ សន្ថរិត្វា អាសនានិ បញ្ញាបេត្វា ឧទកមណិកំ បតិដ្ឋាបេត្វា តេលប្បទីបំ អារោបេត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ ឯតទវោចុំ សព្វសន្ថរិសន្ថតំ ភន្តេ សណ្ឋាគារំ អាសនានិ បញ្ញត្តានិ ឧទកមណិកោ បតិដ្ឋាបិតោ តេលប្បទីបោ អារោបិតោ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។

លុះព្រះមានព្រះភាគ ប្រើប្រាស់ជាមុនហើយ សឹមពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុនឹងប្រើប្រាស់ជាខាងក្រោយ ការដែលព្រះអង្គប្រើប្រាស់នោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ អស់កាលជាយូរអង្វែង ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ ដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចូលទៅកាន់ព្រះដំណាក់ថ្មី លុះចូលទៅដល់ហើយ រៀបចំព្រះដំណាក់ឲ្យសមគួរដល់ទីដែលត្រូវរៀបចំទាំងអស់ ហើយក្រាលអាសនៈ ឲ្យតម្កល់ក្អមទឹម អុជប្រទីបប្រេង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដំណាក់ បានរៀបចំសមគួរដល់ទីដែលត្រូវរៀបចំទាំងអស់ហើយ អាសនៈបានក្រាលហើយ ក្អមទឹកបានឲ្យតម្កល់ទុកហើយ ប្រទីបប្រេងក៏ឲ្យអុជឡើងហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្គាល់ នូវកាលដ៏សមគួរនឹងស្តេចទៅឥឡូវនេះ ។

[៣២៥] អថខោ ភគវា និវាសេត្វា បត្តចីវរមាទា-
យ សទ្ធឹ ភិក្ខុសង្ឃេន យេន នវំ សណ្ឋាគារំ តេនុប-
សង្កមិ ឧបសង្កមិត្វា បាទេ បក្ខាលេត្វា សណ្ឋាគារំ
បវិសិត្វា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថាភិមុខោ និសីទិ ។
ភិក្ខុសង្ឃោបិ ខោ បាទេ បក្ខាលេត្វា សណ្ឋាគារំ
បវិសិត្វា បច្ឆិមំ ភិត្តឹ និស្សាយ បុរត្ថាភិមុខោ និសីទិ
ភគវន្តំយេវ បុរក្ខត្វា ។ កាបិលវត្ថវាបិ សក្យា បាទេ
បក្ខាលេត្វា សណ្ឋាគារំ បវិសិត្វា បុរត្ថិមំ ភិត្តឹ និស្សាយ
បច្ឆាភិមុខា និសីទឹសុ ភគវន្តំយេវ បុរក្ខត្វា ។ អថខោ
ភគវា កាបិលវត្ថវេ សក្យេ ពហុទេវ រត្តឹ ធម្មិយា
កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា
សម្បហំសេត្វា ឧយ្យោជេសិ អភិក្កន្តា ខោ គោតម
រត្តិ យស្សទានិ កាលំ មញ្ញថាតិ ។ ឯវំ ភន្តេតិ កាបិ-
លវត្ថវា សក្យា ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា
ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។

## អាសីវិសវគ្គ ទី ៤

[៣២៥] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ មួយអន្លើដោយភិក្ខុសង្ឃ ស្តេចចូលទៅកាន់ព្រះដំណាក់ថ្មី លុះចូលទៅដល់ លាងព្រះបាទទាំងគូហើយ ចូលទៅកាន់ព្រះដំ-ណាក់ គង់ផ្អែកនឹងសសរកន្លោង ឈមព្រះភ័ក្ត្រទៅទិសខាងកើត ។ ចំណែកខាងភិក្ខុសង្ឃ ក៏លាងបាទាទាំងឡាយ ហើយចូលទៅកាន់ព្រះដំណាក់ គង់ផ្អែកនឹងជញ្ជាំងខាងលិច ឈមមុខទៅទិសខាងកើតចោមរោមព្រះមានព្រះភាគ ។ ពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ លាងបាទាទាំងឡាយហើយ ស្តេចចូលទៅកាន់ព្រះដំណាក់ គង់ផ្អែកនឹងជញ្ជាំងខាងកើត ឈមព្រះភ័ក្ត្រទៅទិសខាងលិច ចោមរោមព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកសក្យៈនៅក្នុងក្រុងកបិល-ព័ស្តុ ឲ្យយល់ច្បាស់ ឲ្យសមាទាន ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា អស់រាត្រីដ៏ច្រើន ហើយទ្រង់បញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគោតម រាត្រីភ្លឺស្វាងហើយ អ្នកទាំងឡាយចូរសម្គាល់នូវកាលគួរដែលនឹងទៅឥឡូវនេះចុះ ។ ពួកសក្យៈនៅក្នុងក្រុងកបិលព័ស្តុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។

[៣៦៦] អថខោ អចិរប្បក្កន្តេសុ កាបិលវត្ថវេសុ សក្យេសុ អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ វិគតថីនមិទ្ធោ ខោ មោគ្គល្លាន ភិក្ខុសង្ឃោ បដិភាតុ តំ មោគ្គល្លាន ភិក្ខូនំ ធម្មីកថា បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា មហាមោគ្គល្លានោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិ ករិត្វា តត្រ ខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។ អាយស្មា មហាមោគ្គល្លានោ ឯតទវោច អវស្សុតបរិយាយញ្ច វោ អាវុសោ ទេសេស្សាមិ អនវស្សុតបរិយាយញ្ច

[៣៦៦] លំដាប់នោះ ព្រះមានព្រះភាគ កាលបើពួកសក្យៈនៅក្រុងកបិលព័ស្តុ ចៀសចេញទៅមិនយូរប៉ុន្មាន បានត្រាស់ហៅព្រះមហាមោគ្គល្លានមានអាយុថា ម្នាលមោគ្គល្លាន ភិក្ខុសង្ឃមានសេចក្តីងងុយងោកងក់ទៅប្រាសហើយ ម្នាលមោគ្គល្លាន អ្នកចូរសម្តែងធម្មីកថាដល់ភិក្ខុទាំងឡាយចុះ តថាគតរួយខ្នង ហេតុនោះ តថាគតនឹងសម្រាក ។ ព្រះមហាមោគ្គល្លានមានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ឲ្យក្រាលសង្ឃាដីមានជាន់ ៤ ហើយទ្រង់សម្រេចសីហសេយ្យាស ផ្ទៀងខាងស្តាំ គងព្រះបាទដោយព្រះបាទ មានព្រះសតិសម្បជញ្ញៈ ធ្វើនូវឧដ្ឋានសញ្ញាទុកក្នុងព្រះហឫទ័យ ក្នុងទីនោះឯង ព្រះមហាមោគ្គល្លានមានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយមានអាយុ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមហាមោគ្គល្លានមានអាយុថា ករុណា អាវុសោ ។ ព្រះមហាមោគ្គល្លានមានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ខ្ញុំនឹងសម្តែង នូវហេតុនៃចិត្តទទឹកដោយរាគៈផង នូវហេតុនៃចិត្តដែលមិនទទឹកដោយរាគៈផង ដល់អ្នកទាំងឡាយ

តំ សុណាថ សាធុកំ មនសិ ករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។ អាយស្មា មហាមោគ្គល្លានោ ឯតទវោច កថំ អាវុសោ អវស្សុតោ ហោតិ ។ ឥធាវុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ អធិមុច្ចតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ អធិមុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ អយំ វុច្ចតាវុសោ ភិក្ខុ អវស្សុតោ

អ្នកទាំងឡាយចូរចាំស្តាប់រឿងនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមហាមោគ្គល្លានមានអាយុថា ករុណា អាវុសោ ។ ទើបព្រះមហាមោគ្គល្លានមានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តទទឹកដោយរាគៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ជ្រប់ក្នុងរូបជាទីស្រឡាញ់ ព្យាបាទក្នុងរូបមិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនបានតាំងមាំ មានចិត្តស្តួចស្តើងក្នុងកុសលធម៌ មួយទៀត អកុសលធម៌ដ៏លាមកទាំងឡាយនោះ ដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅឥតមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ បេ ។ ជញ្ជាប់រសដោយអណ្តាត ។ ដឹងច្បាស់នូវធម៌ដោយចិត្តហើយ ជ្រប់ក្នុងធម៌ដែលជាទីស្រឡាញ់ ព្យាបាទក្នុងធម៌ដែលមិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនបានតាំងមាំ មានចិត្តស្តួចស្តើងក្នុងកុសលធម៌ មួយទៀត អកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅមិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ហៅថាមានចិត្ត

ចក្ខុវិញ្ញេយ្យេសុ រូបេសុ ។ បេ ។ អវស្សុតោ ជិវ្ហាវិញ្ញេយ្យេសុ រសេសុ ។ បេ ។ អវស្សុតោ មនោវិញ្ញេយ្យេសុ ធម្មេសុ ។

[៣២៧] ឯវំវិហារឹ ចាវុសោ ភិក្ខុំ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ លភតេវ មារោ[១] ឱតារំ លភតិ មារោ អារម្មណំ ។ បេ ។ ជិវ្ហាតោ ចេបិ នំ មារោ ឧបសង្កមតិ ។ បេ ។ មនតោ ចេបិ នំ មារោ ឧបសង្កមតិ លភតេវ មារោ ឱតារំ លភតិ មារោ អារម្មណំ ។ សេយ្យថាបិ អាវុសោ នឡាគារំ វា តិណាគារំ វា សុក្ខកាឡាសំ[២] តេរោវស្សិកំ បុរត្ថិមាយ ចេបិ នំ ទិសាយ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ លភេថេវ អគ្គិ ឱតារំ លភេថ អគ្គិ អារម្មណំ ។ បច្ឆិមាយ ចេបិ នំ ទិសាយ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ ។ បេ ។ ឧត្តរាយ ចេបិ នំ ទិសាយ ។ ទក្ខិណាយ ចេបិ នំ ទិសាយ ។ ហេដ្ឋិមតោ ចេបិ នំ ។ ឧបរិមតោ ចេបិ នំ ។ យតោ កុតោ ចេបិ នំ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ

---

១ ម. លភេថ មារោ ។ ២ ឱ. សុខ កោឡាបំ ។

ទទឹកដោយរាគៈក្នុងរូបដែលគប្បីដឹងដោយចក្ខុ ។ បេ ។ មានចិត្តទទឹកដោយរាគៈក្នុងរសទាំងឡាយដែលគប្បីដឹងដោយអណ្តាត ។ បេ ។ មានចិត្តទទឹកដោយរាគៈក្នុងធម៌ទាំងឡាយដែលគប្បីដឹងដោយចិត្ត ។

[៣២៧] ម្នាលអាវុសោទាំងឡាយ ភិក្ខុ ប្រព្រឹត្តនៅយ៉ាងនេះ បើមារចូលទៅរកភិក្ខុនោះ ដោយចក្ខុ មាររមែងបាននូវឱកាស មាររមែងបាននូវអារម្មណ៍ ។ បេ ។ បើមារចូលទៅរកភិក្ខុនោះ ដោយអណ្តាត ។ បេ ។ បើមារចូលទៅរកភិក្ខុនោះដោយចិត្ត មាររមែងបាននូវឱកាស មាររមែងបាននូវអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ ដូចផ្ទះប្រក់ដោយបបុស ឬផ្ទះប្រក់ដោយស្មៅ មានឈើស្ងួតហែង សល់នៅតែរាងទទេ បើបុរសចូលទៅឆួលផ្ទះនោះ ដោយគប់ភ្លើងដ៏ឆេះសន្ធោ ក្នុងទិសខាងកើត ភ្លើងក៏នឹងបាននូវឱកាស នឹងបាននូវអារម្មណ៍ ។ បើបុរសចូលទៅឆួលផ្ទះនោះ ដោយគប់ភ្លើងដ៏ឆេះសន្ធោ ក្នុងទិសខាងលិច ។ បេ ។ បើឆួលផ្ទះនោះក្នុងទិសខាងជើង ។ បើឆួលផ្ទះនោះក្នុងទិសខាងត្បូង ។ បើឆួលផ្ទះនោះពីខាងក្រោម ។ បើឆួលផ្ទះនោះពីខាងលើ ។ កាលបើបុរសចូលទៅឆួលផ្ទះនោះ ដោយគប់ភ្លើងដ៏ឆេះសន្ធោ អំពីទិស

លភេថេវ អត្ថិ ឱតារំ លភេថ អត្ថិ អារម្មណំ ។ ឯវមេវ ខោ អាវុសោ ឯវំវិហារី ភិក្ខុំ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ លភេតេវ មារោ ឱតារំ លភតិ មារោ អារម្មណំ ។ បេ ។ ជិវ្ហាតោ ចេបិ នំ មារោ ឧបសង្កមតិ ។ បេ ។ មនតោ ចេបិ នំ មារោ ឧបសង្កមតិ លភេថេវ មារោ ឱតារំ លភេថ មារោ អារម្មណំ ។

[៣២៨] ឯវំវិហារិញ្ចាវុសោ ភិក្ខុំ រូបា អធិភំសុ ន ភិក្ខុ រូបេ អធិភោសិ សទ្ទា ភិក្ខុំ អធិភំសុ ន ភិក្ខុ សទ្ទេ អធិភោសិ គន្ធា ភិក្ខុំ អធិភំសុ ន ភិក្ខុ គន្ធេ អធិភោសិ រសា ភិក្ខុំ អធិភំសុ ន ភិក្ខុ រសេ អធិភោសិ ផោដ្ឋព្វា ភិក្ខុំ អធិភំសុ ន ភិក្ខុ ផោដ្ឋព្វេ អធិភោសិ ធម្មា ភិក្ខុំ អធិភំសុ ន ភិក្ខុ ធម្មេ អធិភោសិ ។ អយំ វុច្ចតាវុសោ ភិក្ខុ រូបាធិភូតោ សទ្ទាធិភូតោ គន្ធាធិភូតោ រសាធិភូតោ ផោដ្ឋព្វាធិភូតោ ធម្មាធិភូតោ អនធិភូតោ អធិភំសុ[១] ចាបកា អកុសលា ធម្មា សង្កិលេសិកា ចោនោព្ភ-

១ ឱ. នំ បាបកា ។

ខាងណា ក្នុងកាលណា ភ្លើងក៏នឹងបាននូវឱកាស នឹងបាននូវអារម្មណ៍ អំពីទិសខាងណោះ ក្នុងកាលណោះ យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រព្រឹត្តនៅយ៉ាងនេះ បើមារចូលទៅរកភិក្ខុនោះ ដោយចក្ខុ មាររមែងបាននូវចន្លោះ រមែងបាននូវអារម្មណ៍ ។ បេ ។ បើមារចូលទៅរកភិក្ខុនោះដោយអណ្ដាត ។ បេ ។ បើមារចូលទៅរកភិក្ខុនោះដោយចិត្ត មាររមែងបាននូវឱកាស រមែងបាននូវអារម្មណ៍ ក៏យ៉ាងនោះដែរ ។

[៣២៨] ម្នាលអាវុសោទាំងឡាយ រូបទាំងឡាយគ្របសង្កត់ភិក្ខុដែលប្រព្រឹត្តនៅយ៉ាងនេះបាន ភិក្ខុគ្របសង្កត់នូវរូបទាំងឡាយមិនបាន សំឡេងទាំងឡាយគ្របសង្កត់ភិក្ខុបាន ភិក្ខុគ្របសង្កត់សំឡេងទាំងឡាយមិនបាន ក្លិនគ្របសង្កត់ភិក្ខុបាន ភិក្ខុគ្របសង្កត់ក្លិនមិនបាន រសគ្របសង្កត់ភិក្ខុបាន ភិក្ខុគ្របសង្កត់រសមិនបាន ផោដ្ឋព្វៈគ្របសង្កត់ភិក្ខុបាន ភិក្ខុគ្របសង្កត់ផោដ្ឋព្វៈមិនបាន ធម្មារម្មណ៍គ្របសង្កត់ភិក្ខុបាន ភិក្ខុគ្របសង្កត់ធម្មារម្មណ៍មិនបាន ។ ម្នាលអាវុសោទាំងឡាយ នេះហៅថាភិក្ខុដែលរូបគ្របសង្កត់ សំឡេងគ្របសង្កត់ ក្លិនគ្របសង្កត់ រសគ្របសង្កត់ ផោដ្ឋព្វៈគ្របសង្កត់ ធម្មារម្មណ៍គ្របសង្កត់ តែភិក្ខុគ្របសង្កត់មិនបាន អកុសលធម៌ដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង ប្រកប

វិកា សឧរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា ។

ឯវំ ខោ អាវុសោ អវស្សុតោ ហោតិ ។

[៣២៩] កថញ្ចាវុសោ អនវស្សុតោ ហោតិ ។ ឥធា-វុសោ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ នាធិមុច្ចតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ នាធិមុច្ចតិ អប្បិយរូបេ ធម្មេ ន ព្យាបជ្ជតិ ឧបដ្ឋិ-

ដោយភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈតទៅ បានគ្របសង្កត់ភិក្ខុនោះ ។ ម្នាលអាវុសោទាំងឡាយ យ៉ាងនេះឯង ឈ្មោះថាភិក្ខុមានចិត្តទទឹកដោយរាគៈ ។

[៣២៩] ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុអ្នកមានចិត្តមិនទទឹកដោយរាគៈ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ មិនជ្រប់ក្នុងរូបជាទីស្រឡាញ់ មិនព្យាបាទក្នុងរូបមិនជាទីស្រឡាញ់ មានសតិក្នុងកាយតាំងមាំ មានចិត្តប្រមាណមិនបាន មួយវិញទៀត អកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅវិញ មិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ បេ ។ ជញ្ជាប់រសដោយអណ្តាត ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ មិនជ្រប់ក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ មិនព្យាបាទក្នុងធម្មារម្មណ៍មិនជាទីស្រឡាញ់ មានសតិក្នុងកាយ

តកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេ-
តោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ
ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈ-
ន្តិ ។ អយំ វុច្ចតាវុសោ ភិក្ខុ អនវស្សុតោ ចក្ខុវិញ្ញេ-
យ្យេសុ រូបេសុ ។ បេ ។ អយំ វុច្ចតាវុសោ ភិក្ខុ អន-
វស្សុតោ ជិវ្ហាវិញ្ញេយ្យេសុ រសេសុ ។ បេ ។ អនវស្សុតោ
មនោវិញ្ញេយ្យេសុ ធម្មេសុ ។ ឯវំវិហារឹ ចាវុសោ ភិក្ខុំ
ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ នេវ លភតិ
មារោ ឱតារំ ន លភតិ មារោ អារម្មណំ ។ បេ ។ ជិវ្ហា-
តោ ចេបិ នំ មារោ ឧបសង្កមតិ ។ បេ ។ មនតោ ចេបិ
នំ មារោ ឧបសង្កមតិ នេវ លភតិ មារោ ឱតារំ ន លភតិ
មារោ អារម្មណំ ។ សេយ្យថាបិ អាវុសោ កូដាគារសាលំ
វា ពហលមត្តិកាមទ្ទាវិលេបនា[១] បុរត្ថិមាយ ចេបិ នំ
ទិសាយ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ
នេវ លភេថ អគ្គិ ឱតារំ ន លភេថ អគ្គិ អារម្មណំ
។ បេ ។ បច្ឆិមាយ ចេបិ នំ ។ ឧត្តរាយ ចេបិ នំ ។

១ ឱ. ម. អទ្ទាវលេបនា ។

តាំងមាំ មានចិត្តប្រមាណមិនបាន មួយវិញទៀត អកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅវិញឥតមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុមានចិត្តមិនទទឹកដោយរាគៈក្នុងរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ។ បេ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុមានចិត្តមិនទទឹកដោយរាគៈក្នុងរសទាំងឡាយដែលគប្បីដឹងដោយអណ្តាត ។ បេ ។ មានចិត្តមិនទទឹកដោយរាគៈ ក្នុងធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងដោយចិត្ត ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលប្រព្រឹត្តនៅយ៉ាងនេះ បើមារចូលទៅរកភិក្ខុនោះដោយចក្ខុ មារក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ ។ បេ ។ បើមារចូលទៅរកភិក្ខុនោះដោយអណ្តាត ។ បេ ។ បើមារចូលទៅរកភិក្ខុនោះដោយចិត្ត មារក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ ដូចជាកូដាគារសាលា (ផ្ទះមានកំពូល) មានដីស្អិតច្របាច់លាបដ៏ក្រាស់ បើបុរសចូលទៅជិតធ្លូលកូដាគារសាលានោះ ដោយគប់ភ្លើងឆេះសន្ធោ ក្នុងទិសខាងកើត ភ្លើងក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ ។ បេ ។ បើធ្លូលកូដាគារសាលានោះ ក្នុងទិសខាងលិច ។ បើធ្លូលកូដាគារសាលានោះ ក្នុងទិសខាងជើង ។

ទក្ខិណាយ ចេបិ នំ ។ ហេដ្ឋិមតោ ចេបិ នំ ។ ឧបរិមតោ ចេបិ នំ យតោ កុតោចិ ចេ បុរិសោ អាទិត្តាយ តិណុក្កាយ ឧបសង្កមេយ្យ នេវ លភេថ អគ្គិ ឱតារំ ន លភេថ អគ្គិ អារម្មណំ ។ ឯវមេវ ខោ អាវុសោ ឯវំវិហារី ភិក្ខុំ ចក្ខុតោ ចេបិ នំ មារោ ឧបសង្កមតិ ន លភតេវ មារោ ឱតារំ ន លភតិ មារោ អារម្មណំ ។ បេ ។ ជិវ្ហាតោ[១] ចេបិ នំ មារោ ឧបសង្កមតិ ន លភតេវ មារោ ឱតារំ ន លភតិ មារោ អារម្មណំ ។ ឯវំវិហារី ចាវុសោ ភិក្ខុ រូបេ អភិភោសិ ន រូបា ភិក្ខុំ អភិភំសុ សទ្ទេ ភិក្ខុ អភិភោសិ ន សទ្ទា ភិក្ខុំ អភិភំសុ គន្ធេ ភិក្ខុ អភិភោសិ ន គន្ធា ភិក្ខុំ អភិភំសុ រសេ ភិក្ខុ អភិភោសិ ន រសា ភិក្ខុំ អភិភំសុ ផោដ្ឋព្វេ ភិក្ខុ អភិភោសិ ន ផោដ្ឋព្វា ភិក្ខុំ អភិភំសុ ធម្មេ ភិក្ខុ អភិភោសិ ន ធម្មា ភិក្ខុំ អភិភំសុ ។ អយំ វុច្ចតាវុសោ

១ មនតោតិបិ បាឋោ ទិស្សតិ ។

បើធ្លុលកូដាគារសាលានោះ ក្នុងទិសខាងត្បូង ។ បើធ្លុលកូដាគារសាលានោះ អំពីខាងក្រោម ។ បើធ្លុលកូដាគារសាលានោះ អំពីខាងលើ បើបុរសចូលទៅជិតធ្លុលដោយគប់ភ្លើងឆេះសន្ធោអំពីទិសណា ក្នុងកាលណា ភ្លើងក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ អំពីទិសខាងណោះ ក្នុងកាលណោះ យ៉ាងណាមិញ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលប្រព្រឹត្តនៅយ៉ាងនេះ បើមារចូលទៅរកភិក្ខុនោះ ដោយចក្ខុ មារក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ ។ បេ ។ បើមារចូលទៅរកភិក្ខុនោះ ដោយអណ្តាត មារក៏មិនបាននូវឱកាស មិនបាននូវអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលប្រព្រឹត្តនៅយ៉ាងនេះជាប្រក្រតី ទើបគ្របសង្កត់រូបទាំងឡាយបាន រូបទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ភិក្ខុគ្របសង្កត់សំឡេងទាំងឡាយបាន សំឡេងទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ភិក្ខុគ្របសង្កត់ក្លិនទាំងឡាយបាន ក្លិនទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ភិក្ខុគ្របសង្កត់រសទាំងឡាយបាន រសទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ភិក្ខុគ្របសង្កត់ផោដ្ឋព្វៈទាំងឡាយបាន ផោដ្ឋព្វៈទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ភិក្ខុគ្របសង្កត់ធម្មារម្មណ៍ទាំងឡាយបាន ធម្មារម្មណ៍ទាំងឡាយគ្របសង្កត់ភិក្ខុមិនបាន ក៏យ៉ាងនោះឯង ។ ម្នាលអាវុសោទាំងឡាយ

ភិក្ខុ រូបាភិភូ សទ្ទាភិភូ គន្ធាភិភូ រសាភិភូ ផោដ្ឋព្វាភិភូ ធម្មាភិភូ[១] អភិភោសិ តេ បាបកេ អកុសលេ ធម្មេ សង្កិលេសិកេ បោនោព្ភវិកេ សទរេ ទុក្ខវិបាកេ អា-យតឹ ជាតិជរាមរណិយេ ។ ឯវំ ខោ អាវុសោ អនវ-ស្សុតោ ហោតីតិ ។ អថខោ ភគវា វុដ្ឋហិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អាមន្តេសិ សាធុ សាធុ ខោ មោគ្គ-ល្លាន សាធុ ខោ ត្វំ មោគ្គល្លាន ភិក្ខូនំ អវស្សុតបរិយា-យញ្ច អនវស្សុតបរិយាយញ្ច អភាសីតិ ។ ឥទមវោច អាយស្មា មហាមោគ្គល្លានោ ។ សមនុញ្ញោ សត្ថា អ-ហោសិ ។ អត្តមនា តេ ភិក្ខូ អាយស្មតោ មហា-មោគ្គល្លានស្ស ភាសិតំ អភិនន្ទុន្តិ[២] ។ ឆដ្ឋំ ។

---

១ ឱ. ម. អធិភូ អនធិភូតោ ។ ម. កេហិ ចិ កិលេសេហិ ។ ២ អភិនន្ទឹសុ ។

នេះហៅថា ភិក្ខុអ្នកគ្របសង្កត់រូប គ្របសង្កត់សំឡេង គ្របសង្កត់ក្លិន គ្របសង្កត់រស គ្របសង្កត់ផោដ្ឋព្វៈ គ្របសង្កត់ធម្មារម្មណ៍ គ្របសង្កត់អកុសលធម៌ដ៏លាមកទាំងនោះ ដែលប្រកបដោយសេចក្តីសៅហ្មង ប្រកបដោយភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈតទៅ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តមិនទទឹកដោយរាគៈ យ៉ាងនេះឯង ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ក្រោកឡើងហើយ ត្រាស់ហៅព្រះមហាមោគ្គល្លានមានអាយុមកថា ម្នាលមោគ្គល្លាន ប្រពៃហើយ ៗ ម្នាលមោគ្គល្លាន ប្រពៃហើយ ដែលអ្នកបានសម្តែងនូវហេតុនៃចិត្តដែលទទឹកដោយរាគៈ និងហេតុនៃចិត្តដែលមិនទទឹកដោយរាគៈ ដល់ភិក្ខុទាំងឡាយ ។ ព្រះមហាមោគ្គល្លានមានអាយុបានសម្តែងធម៌នេះហើយ ។ ព្រះសាស្តាទ្រង់សព្វព្រះហឫទ័យ ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមហាមោគ្គល្លានមានអាយុ ។ ចប់សូត្រ ទី ៦ ។

[៣៣០] យតោ ខោ ភិក្ខវេ សព្វសំយោវ ទុក្ខជម្មានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជាជាតិ ។ អថខោ[១] បនស្ស កាមា ទិដ្ឋា ហោន្តិ យថាស្ស កាមេ បស្សតោ យោ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបរិឡាហោ សោ ជានុសេតិ តថា ខោ បនស្ស ចារោ ច វិហារោ ច អនុពន្ធោ ហោតិ ។ យថា ចរន្តំ វិហរន្តំ អភិជ្ឈាទោមនស្សា ចាបកា អកុសលា ធម្មា ជានុស្សវន្តិ[២] ។ កថញ្ច ភិក្ខវេ ភិក្ខុ សព្វសំយោវ ទុក្ខជម្មានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជាជាតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ។ ឥតិ វេទនា ។ បេ ។ ឥតិ សញ្ញា ។ ឥតិ សង្ខារា ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ សព្វសំយោវ ទុក្ខជម្មានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជាជាតិ ។

---

១ តថា ខោ ។ ២ ម. នានុសេន្តិ ។

[៣៣០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើង និងសេចក្តីសូន្យនៃទុក្ខធម៌ទាំងឡាយទាំងពួង ក្នុងកាលណា ។ កាលណោះ កាមទាំងឡាយ ឈ្មោះថាភិក្ខុនោះបានឃើញហើយ កាលបើភិក្ខុនោះឃើញនូវកាមទាំងឡាយ ដោយអាការណា ចំណង់ក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រប់ក្នុងកាម សេចក្តីក្តៅក្រហាយដោយកាមណា ក្នុងកាមទាំងឡាយ ចំណង់ក្នុងកាមជាដើមនោះ ក៏ដេកត្រាំនៅពុំបាន ធម៌ជាគ្រឿងប្រព្រឹត្តនិងធម៌ជាគ្រឿងនៅរមែងជាប់តាមភិក្ខុនោះ ដោយអាការនោះ ។ អភិជ្ឈានិងទោមនស្សជាអកុសលធម៌ដ៏លាមក រមែងមិនគ្របសង្កត់ភិក្ខុដែលជាអ្នកប្រព្រឹត្ត មានធម៌ជាគ្រឿងនៅដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងនិងសេចក្តីសាបសូន្យ នៃទុក្ខធម៌ទាំងពួង តើដូចម្តេច ដឹងច្បាស់ថា រូបដូច្នេះ សេចក្តីកើតឡើងនៃរូបដូច្នេះ សេចក្តីសាបសូន្យនៃរូបដូច្នេះ ។ វេទនាដូច្នេះ ។ បេ ។ សញ្ញាដូច្នេះ ។ សង្ខារទាំងឡាយដូច្នេះ ។ វិញ្ញាណដូច្នេះ សេចក្តីកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីសាបសូន្យនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើង និងសេចក្តីសាបសូន្យនៃទុក្ខធម៌ទាំងពួង យ៉ាងនេះឯង ។

[៣៣១] កថញ្ច ភិក្ខវេ ភិក្ខុនោ កាមា ទិដ្ឋា ហោន្តិ យថាស្ស កាមេ បស្សតោ យោ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបរិឡាហោ សោ នានុសេតិ ។ សេយ្យថាបិ ភិក្ខវេ អង្គារកាសុ សាធិកបោរិសា បុណ្ណា អង្គារានំ វីតច្ចិកានំ វីតធុមានំ ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ តមេនំ ទ្វេ ពលវន្តោ បុរិសា នានា ពាហាសុ គហេត្វា តំ អង្គារកាសុំ ឧបកឌ្ឍេយ្យុំ សោ ឥតិ ឥមមេវ កាយំ សន្នាមេយ្យ ។ តំ កិស្ស ហេតុ ។ អញ្ញាណាញ្ហិ[១] ភិក្ខវេ តស្ស បុរិសស្ស ហោតិ ឥមញ្ចាហំ អង្គារកាសុំ ច បស្សាមិ តតោនិទានំ មរណំ វា គច្ឆាមិ មរណមត្តំ វា ទុក្ខន្តិ ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុនោ អង្គារកាសូបមា កាមា ទិដ្ឋា ហោន្តិ យថាស្ស កាមេ បស្សតោ

១ ឱ. ញាតញ្ហិ ។

## អាសីវិសវគ្គ ទី ៤

[៣៣១] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបានឃើញកាមទាំងឡាយ តាមទំនងដែលគេឃើញនូវកាមទាំងឡាយ ហើយចំណង់ក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រប់ក្នុងកាម សេចក្តីក្តៅក្រហាយដោយកាមណា ក្នុងកាមទាំងឡាយ ចំណង់ក្នុងកាមជាដើមនោះ មិនដេកត្រាំក្នុងសន្តាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រណ្តៅរងើកភ្លើង មានជម្រៅជាងមួយជួរបុរស ពេញដោយរងើកភ្លើង ប្រាសចាកអណ្តាត ប្រាសចាកផ្សែង ។ គ្រានោះ បុរសប្រាថ្នារស់ មិនចង់ស្លាប់ ប្រាថ្នាសុខ ខ្ពើមទុក្ខ ដើរមក មានបុរសពីរនាក់មានកម្លាំង ចាប់បុរសនោះត្រង់ដើមដៃម្ខាងម្នាក់ ប្រានបុរសនោះឲ្យចូលទៅ ក្នុងរណ្តៅរងើកភ្លើង បុរសនោះក៏ក្រាញទប់កាយនេះ ដោយអាការដូច្នេះ ៗ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុរសនោះមានការយល់ច្បាស់ថា អាត្មាអញនឹងធ្លាក់ចុះក្នុងរណ្តៅរងើកភ្លើងនោះ អាត្មាអញនឹងដល់នូវមរណៈ ឬនឹងដល់នូវទុក្ខស្ទើរមរណៈ ព្រោះការធ្លាក់ចុះនោះជាហេតុ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុបានឃើញកាមទាំងឡាយ ដែលទុកដូចជារណ្តៅរងើកភ្លើង តាមទំនងដែលគេឃើញនូវកាមទាំងឡាយហើយ

យោ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបរិឡាហោ សោ ជានុសេតិ ។

[៣៣២] កថញ្ច ភិក្ខវេ ភិក្ខុនោ ចារេ ច វិហារេ ច អនុពទ្ធោ ហោតិ យថា ចរន្តំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា ជានុស្សវន្តិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ពហុកណ្ដកំ ទាយំ បវិសេយ្យ តស្ស បុរតោបិ កណ្ដកោ បច្ឆតោបិ កណ្ដកោ ឧត្តរតោបិ កណ្ដកោ ទក្ខិណតោបិ កណ្ដកោ ហេដ្ឋិតោបិ កណ្ដកោ ឧបរិតោបិ កណ្ដកោ សោ សមតោ វ[១] អភិក្កមេយ្យ សមតោ វ បដិក្កមេយ្យ មា មំ កណ្ដកោតិ ។ ឯវមេវ ខោ ភិក្ខវេ យំ លោកេ បិយរូបំ សាតរូបំ អយំ វុច្ចតិ អរិយស្ស វិនយេ កណ្ដកោតិ ។

១ ឱ. យតោ ច ។

ចំណង់ក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រប់ក្នុងកាម សេចក្តីក្តៅក្រហាយដោយកាម ណា ក្នុងកាមទាំងឡាយ ចំណង់ក្នុងកាមជាដើមនោះ មិនដេកត្រាំក្នុងសន្ដាន យ៉ាងនោះឯង ។

[៣៣២] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមានការប្រព្រឹត្តនិងការនៅជំខ្ជាប់ខ្លួន តាមទំនងដែលគេប្រព្រឹត្តគេនៅ ហើយអភិជ្ឈានិងទោមនស្សជាអកុសលធម៌ដ៏លាមក មិនគ្របសង្កត់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសចូលទៅកាន់ដងព្រៃមានបន្លាច្រើន បន្លាខាងមុខបុរសនោះក៏មាន បន្លាខាងក្រោយក៏មាន បន្លាខាងឆ្វេងក៏មាន បន្លាខាងស្តាំក៏មាន បន្លាខាងក្រោមក៏មាន បន្លាខាងលើក៏មាន បុរសនោះគប្បីប្រុងស្មារតីឈានទៅមុខ ប្រុងស្មារតីឈានថយក្រោយ ដោយគិតថា កុំឲ្យបន្លាមុតអាត្មាអញឡើយ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចរូបជាទីស្រឡាញ់ ជាទីត្រេកអរណា ក្នុងលោកនេះ ហៅថា បន្លាក្នុងវិន័យរបស់ព្រះអរិយៈ ។

អាសីវិសវគ្គោ ចតុត្ថោ

[៣៣៣] ឥតិ វិទិត្វា អសំវរោ ច សំវរោ ច វេទិតព្វោ ។ កថញ្ច ភិក្ខវេ អសំវរោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ អធិមុច្ចតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ អធិមុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ ឯវំ ខោ ភិក្ខវេ អសំវរោ ហោតិ ។

អាសីវិសវគ្គ ទី ៤

[៣៣៣] កាលបើភិក្ខុដឹងច្បាស់យ៉ាងនេះហើយ ត្រូវដឹងច្បាស់នូវសេចក្តីមិនសង្រួម និងសេចក្តីសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីមិនសង្រួម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ជ្រប់ក្នុងរូបជាទីស្រឡាញ់ ព្យាបាទក្នុងរូបមិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនបានតាំងមាំ មានចិត្តស្តួចស្តើងក្នុងកុសលធម៌ មួយទៀត មិនដឹងច្បាស់តាមពិត នូវចេតោ-វិមុត្តិនិងបញ្ញាវិមុត្តិ ដែលជាគុណជាតិនាំឲ្យអកុសលធម៌ដ៏លាមកទាំងនោះ ដែលកើតឡើងដល់ភិក្ខុនោះ រលត់ទៅមិនមានសេសសល់ ។ បេ ។ ជញ្ជាប់រសដោយអណ្តាត ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ ដោយចិត្តហើយជ្រប់នៅក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ ព្យាបាទក្នុងធម្មារម្មណ៍ដែលមិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនបានតាំងមាំ មានចិត្តស្តួចស្តើងក្នុងកុសលធម៌ មួយវិញទៀត មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ដែលជាគុណជាតិនាំឲ្យអកុសលធម៌ដ៏លាមកទាំង-ឡាយដែលកើតឡើងដល់ភិក្ខុនោះ រលត់ទៅមិនមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនសង្រួម យ៉ាងនេះឯង ។

[៣៣៤] កថញ្ច ភិក្ខវេ សំវរោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ នាធិមុច្ចតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ នាធិមុច្ចតិ អប្បិយរូបេ ធម្មេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ ឯវំ ខោ ភិក្ខវេ សំវរោ ហោតិ ។

[៣៣៤] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីសង្រួម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ មិនជ្រប់នៅក្នុងរូបជាទីស្រឡាញ់ មិនព្យាបាទក្នុងរូបមិនជាទីស្រឡាញ់ មានសតិក្នុងកាយតាំងមាំ មានចិត្តប្រមាណមិនបាន មួយវិញទៀត ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលជាគុណជាតិនាំឲ្យអកុសលធម៌ដ៏លាមកទាំងនោះ ដែលកើតឡើងដល់ភិក្ខុនោះ រលត់ទៅមិនមានសេសសល់ ។ បេ ។ ជញ្ជាប់រសដោយអណ្តាត ។ បេ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត មិនជ្រប់នៅក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ មិនព្យាបាទក្នុងធម្មារម្មណ៍ដែលមិនជាទីស្រឡាញ់ មានសតិក្នុងកាយតាំងមាំហើយ មានចិត្តប្រមាណមិនបាន មួយវិញទៀត ដឹងច្បាស់តាមពិតនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលជាគុណជាតិនាំឲ្យអកុសលធម៌ដ៏លាមកទាំងនោះដែលកើតឡើងដល់ភិក្ខុនោះ រលត់ទៅមិនមានសេសសល់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសង្រួម យ៉ាងនេះឯង ។

អាសីវិសវគ្គោ ចតុត្ថោ

[៣៣៥] តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំ ចរតោ ឯវំ វិហរតោ កទាចិ ករហចិ សតិសម្មោសា ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ។ ទន្ធោ ភិក្ខវេ សតុប្បាទោ អថខោ នំ ខិប្បមេវ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ទិវសំ សន្តត្តេ អយោកដាហេ ទ្វេ វា តីណិ វា ឧទកផុសិតានិ និបាតេយ្យ ។ ទន្ធោ ភិក្ខវេ ឧទកផុសិតានំ និបាតោ អថខោ នំ ខិប្បមេវ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ។ ឯវមេវ ខោ ភិក្ខវេ តស្ស ចេ ភិក្ខុនោ ឯវំ ចរតោ ឯវំ វិហរតោ កទាចិ ករហចិ សតិសម្មោសា ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា សរសង្កប្បា សញ្ញោជនិយា ។ ទន្ធោ ភិក្ខវេ សតុប្បាទោ អថខោ នំ ខិប្បមេវ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ ឯវំ ខោ ភិក្ខវេ

អាសីវិសវគ្គ ទី ៤

[៣៣៥] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះប្រព្រឹត្តយ៉ាងនេះ នៅយ៉ាងនេះ អកុសលធម៌ដ៏លាមកទាំងឡាយ គឺការត្រិះរិះដោយសេចក្តីរឭក ប្រកបដោយសញ្ញោជនៈតែងកើតឡើង ព្រោះភ្លេចស្មារតី ក្នុងពេលមួយដងមួយកាល ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិដ៏យឺតយូរ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការសាបសូន្យ យ៉ាងឆាប់រហ័ស ដោយពិត ។ ម្នាលភិក្ខុទាំងឡាយ ដូចបុរសសម្រក់ចុះនូវតំណក់ទឹកពីរ ឬ បីតំណក់ ទៅក្នុងអំបែងខ្ទះដែកដ៏ក្តៅខ្លាំងក្នុងវេលាថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ការស្រក់ចុះនៃតំណក់ទឹកទាំងឡាយដ៏យឺតយូរ តែងដល់នូវការអស់ ការសាបសូន្យ យ៉ាងឆាប់រហ័សដោយពិត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនោះប្រព្រឹត្តយ៉ាងនេះ នៅយ៉ាងនេះ អកុសលធម៌ទាំងឡាយដ៏លាមក គឺការត្រិះរិះដោយសេចក្តីរឭក ប្រកបដោយសញ្ញោជនៈក៏កើតឡើងព្រោះភ្លេចស្មារតីក្នុងពេលមួយដងមួយកាល ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិដ៏យឺតយូរ ក៏តែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ដល់នូវការសាបសូន្យ យ៉ាងឆាប់រហ័សដោយពិត ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុនោ ចារោ ច វិហារោ ច អនុពន្ធោ ហោតិ យថា ចរន្តំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា នានុស្សវន្តិ ។

[៣៣៦] តញ្ចេ ភិក្ខវេ ភិក្ខុំ ឯវំ ចរន្តំ ឯវំ វិហរន្តំ រាជានោ វា រាជមហាមត្តា វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា ភោគេហិ អភិហដ្ឋុំ បវារេយ្យុំ ឯហម្ភោ បុរិស កិន្តេ ឥមេ កាសាវា អនុទហន្តិ ។ កឹ មុណ្ឌោ កបាលមនុចរសិ ។ ឯហិ ហីនាយា-វត្តិត្វា ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ សោ ច តំ ភិក្ខវេ ភិក្ខុ ឯវំ ចរន្តោ ឯវំ វិហរន្តោ

ភិក្ខុមានការប្រព្រឹត្តនិងការនៅដ៏ខ្ជាប់ខ្ជួន តាមទំនងដែលគេប្រព្រឹត្ត គេនៅ ហើយអភិជ្ឈានិងទោមនស្សជាអកុសលធម៌ដ៏លាមក មិនគ្របសង្កត់យ៉ាងនេះឯង ។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ បើពួកស្តេចក្តី ពួកមហាមាត្យនៃស្តេចក្តី ពួកមិត្តក្តី ពួកអាមាត្យក្តី ពួកញាតិក្តី ពួកសាលោហិតក្តី បាននាំភោគៈទាំងឡាយ មកបវារណាចំពោះភិក្ខុនោះ ដែលប្រព្រឹត្តយ៉ាងនេះ ដែលនៅយ៉ាងនេះ ដោយពាក្យថា នៃបុរសដ៏ចម្រើន ចូរអ្នកមកអាយ ចុះសំពត់កាសាវៈរបស់អ្នកទាំងនេះ ដុតរោលអ្នកឬទេ ។ ចុះព្រោះអ្វី ក៏អ្នកកោរត្រងោលដើរកាន់អំបែង ។ ចូរអ្នកមកអាយ ចូរត្រឡប់មកជាហីនភេទវិញ ហើយបរិភោគនូវភោគៈទាំងឡាយ ទាំងធ្វើនូវបុណ្យទាំងឡាយចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុនោះ កាលបើប្រព្រឹត្តយ៉ាងនេះ កាលនៅយ៉ាងនេះ

អាសីវិសវគ្គោ ចតុត្ថោ

សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ គង្គា នទី បាចីននិន្នា បាចីនបោណា បាចីនបព្ភារា អថ មហាជនកាយោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ មយំ ឥមំ គង្គំ នទឹ បច្ឆានិន្នំ ករិស្សាម បច្ឆាបោណំ បច្ឆាបព្ភារន្តិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ ខោ សោ មហាជ-នកាយោ គង្គំ នទឹ បច្ឆានិន្នំ ករេយ្យ បច្ឆាបោណំ បច្ឆាបព្ភារន្តិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ គង្គា ភន្តេ នទី បាចីននិន្នា បាចីនបោ-ណា បាចីនបព្ភារា សា ន សុករា បច្ឆានិន្នា កាតុំ បច្ឆាបោណា បច្ឆាបព្ភារា ។ យាវទេវ បន សោ មហាជនកាយោ កិលមថស្ស វិឃាតស្ស ភាគី អស្ស ។ ឯវមេវ ខោ ភិក្ខវេ តញ្ចេ ភិក្ខុំ ឯវំ ចរន្តំ ឯវំ វិហរន្តំ រាជានោ វា រាជមហាមត្តា វា មិត្តា វា

នឹងពោលលាសិក្ខា ហើយត្រឡប់មកជាហីនភេទវិញ ដំណើរដូច្នេះនុ៎ះ មិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាទន្លេគង្គាជម្រាលទៅទិសខាងកើត ជ្រាលទៅទិសខាងកើត ទោរទៅទិសខាងកើត គ្រានោះពពួកមហាជនកាន់យកចបកាប់និងបង្គីដើរមក ដោយគិតថា យើងទាំងឡាយនឹងទប់ទន្លេគង្គានេះឲ្យទឹកហូរជម្រាលទៅទិសខាងលិច ជ្រាលទៅទិសខាងលិច ទោរទៅទិសខាងលិចវិញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច ពពួកមហាជននោះនឹងទប់ទន្លេគង្គាឲ្យទឹកហូរជម្រាលទៅទិសខាងលិច ជ្រាលទៅទិសខាងលិច ទោរទៅទិសខាងលិចវិញបានដែរឬ ។ កិច្ចនុ៎ះមិនបានទេ ព្រះអង្គ ។ ដំណើរនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាទន្លេគង្គាជម្រាលទៅទិសខាងកើត ជ្រាលទៅទិសខាងកើត ទោរទៅទិសខាងកើត ទន្លេគង្គានោះ បុគ្គលមិនងាយនឹងទប់ ឲ្យទឹកហូរជម្រាលទៅទិសខាងលិច ជ្រាលទៅទិសខាងលិច ទោរទៅទិសខាងលិចបានឡើយ ។ ឯពពួកមហាជននោះ គប្បីបានតែចំណែកនៃសេចក្តីលំបាកនិងសេចក្តីនឿយហត់ប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា ប្រសិនបើពួកស្តេចក្តី ពួកមហាមាត្យនៃស្តេចក្តី

អមច្ចា វា ញាតី វា សាលោហិតា វា ភោគេហិ អភិហដ្ឋុំ បវារេយ្យុំ ឯហម្ភោ បុរិស កឹ តេ ឥមេ កាសាវា អនុទយ្ហន្តិ ។ កឹ មុណ្ឌោ កបាលមនុចរសិ ។ ឯហិ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ សោ វត ភិក្ខវេ ភិក្ខុ ឯវំ ចរន្តោ ឯវំ វិហរន្តោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិស្ស ហេតុ ។ យំ ហិ តំ ភិក្ខវេ ចិត្តំ ទីឃរត្តំ វិវេកនិន្នំ វិវេកបោណំ វិវេកបព្ភារំ តញ្ច ហីនាយាវត្តិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សត្តមំ ។

ពួកមិត្តក្តី ពួកអាមាត្យក្តី ញាតិក្តី ពួកសាលោហិតក្តី គប្បីនាំនូវភោគៈទាំងឡាយមកបវារណា ចំពោះភិក្ខុនោះ ដែលប្រព្រឹត្តយ៉ាងនេះ ដែលនៅយ៉ាងនេះ ដោយពាក្យថា នែបុរសដ៏ចម្រើន ចូរអ្នកមកអាយ ចុះសំពត់កាសាវៈរបស់អ្នកទាំងនេះ ដុតពោលអ្នកឬទេ ។ ចុះហេតុអ្វី ក៏អ្នកកោរត្រងោលដើរកាន់អំបែង ។ ចូរអ្នកមកអាយ ចូរអ្នកត្រឡប់មកជាហីនភេទវិញ ហើយបរិភោគនូវភោគៈទាំងឡាយ និងធ្វើបុណ្យទាំងឡាយចុះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះកាលបើប្រព្រឹត្តយ៉ាងនេះ កាលនៅយ៉ាងនេះ នឹងពោលលាសិក្ខាត្រឡប់ទៅជាហីនភេទវិញ ដំណើរដូច្នេះនុ៎ះមិនមានទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាចិត្តណាដែលឱនទៅរកវិវេក បែរទៅរកវិវេក វេទៅរកវិវេក អស់កាលជាយូរអង្វែងហើយ ចិត្តនោះនឹងត្រឡប់ទៅជាហីនភេទវិញ ដំណើរដូច្នេះមិនមានឡើយ ។ ចប់សូត្រ ទី ៧ ។

៤៣៣

## អាសីវិសវគ្គោ ចតុត្ថោ

[៣៣៧] អថខោ អញ្ញតរោ ភិក្ខុ យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ យតោ ខោ អាវុសោ ភិក្ខុ ឆន្នំ ផស្សាយ-តនានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ ឯ-ត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតី-តិ ។ អថខោ សោ ភិក្ខុ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស ប-ញ្ហាវេយ្យាករណេន យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិត្តាវតា នុ ខោ អា-វុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ យតោ ខោ អាវុសោ ភិក្ខុ បញ្ចន្នំ ឧបាទានក្ខន្ធានំ សមុទ-យញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ អ-ថខោ សោ ភិក្ខុ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស បញ្ហា-វេយ្យាករណេន យេន អញ្ញតរោ ភិក្ខុ តេនុបសង្ក-មិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។

## អាសីវិសវគ្គ ទី ៤

[៣៣៧] គ្រានោះ ភិក្ខុមួយរូបចូលទៅរកភិក្ខុមួយរូប លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងនិងសូន្យទៅ នៃផស្សាយតនៈទាំង ៦ ក្នុងកាលណា ម្នាលអាវុសោ ក្នុងកាលនោះ ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមានដោយហេតុនេះឯង ។ គ្រានោះឯង ភិក្ខុនោះមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏បានចូលទៅរកភិក្ខុមួយរូបទៀត លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើង និងសាបសូន្យទៅ នៃឧបាទានក្ខន្ធទាំង ៥ ក្នុងកាលណា ម្នាលអាវុសោ ក្នុងកាលនោះ ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមាន ដោយហេតុនេះឯង ។ គ្រានោះឯង ភិក្ខុនោះមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏បានចូលទៅរកភិក្ខុមួយរូបទៀត លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្តេច ។

យតោ ខោ អាវុសោ ភិក្ខុ ចតុន្នំ មហាភូតានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ អថខោ សោ ភិក្ខុ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស បញ្ហាវេយ្យាករណេន យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ យតោ ខោ អាវុសោ ភិក្ខុ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។

[៣៣៨] អថខោ សោ ភិក្ខុ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស បញ្ហាវេយ្យាករណេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ យេនញ្ញតរោ ភិក្ខុ តេនុបសង្កមឹ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោចំ

ម្នាលអាវុសោ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងនិងសាបសូន្យទៅ នៃមហាភូតរូបទាំង ៤ ក្នុងកាលណា ម្នាលអាវុសោ ក្នុងកាលនោះ ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមានដោយហេតុនេះឯង ។ លំដាប់នោះឯង ភិក្ខុនោះមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏ចូលទៅរកភិក្ខុមួយរូបទៀត លុះចូលទៅដល់ហើយបានពោលនឹងភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ កាលណា ភិក្ខុដឹងច្បាស់តាមពិតថា របស់ណានីមួយ មានការកើតឡើងជាធម្មតា របស់ទាំងអស់នោះ រលត់ទៅវិញជាធម្មតា ម្នាលអាវុសោ កាលនោះ ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមាន ដោយហេតុនេះឯង ។

[៣៣៨] គ្រានោះឯង ភិក្ខុនោះមិនពេញចិត្តដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គចូលទៅរកភិក្ខុមួយរូប លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុនោះដូច្នេះថា

៤៣៩

អាសីវិសវគ្គោ ចតុត្ថោ

កិត្តាវតា នុ ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ ឯវំ វុត្តេ ភន្តេ សោ ភិក្ខុ មំ ឯតទវោច យតោ ខោ អាវុសោ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតិ ។ អថខោហំ ភន្តេ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស បញ្ហា-វេយ្យាករណេន យេន អញ្ញតរោ ភិក្ខុ តេនុបសង្កមឹ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោចំ កិត្តាវតា នុ ខោ អាវុសោ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ ឯវំ វុត្តេ ភន្តេ សោ ភិក្ខុ មំ ឯតទវោច យតោ ខោ អាវុសោ ភិក្ខុ បញ្ចន្នំ ឧបាទានក្ខន្ធានំ ។ បេ ។ ចតុន្នំ មហា-ភូតានំ សមុទយញ្ច អត្ថង្គមញ្ច យថាភូតំ បជានាតិ ។ បេ ។ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធ-ធម្មន្តិ យថាភូតំ បជានាតិ ឯត្តាវតា ខោ អាវុសោ

ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ ភិក្ខុនោះបានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោ ភិក្ខុដឹងច្បាស់តាមពិតនូវហេតុជាទីកើតឡើងនិងសាបសូន្យទៅ នៃផស្សាយតនៈទាំង ៦ ក្នុងកាលណា ម្នាលអាវុសោ ក្នុងកាលនោះ ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមាន ដោយហេតុនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ខ្ញុំព្រះអង្គមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏ចូលទៅរកភិក្ខុមួយរូបទៀត លុះចូលទៅដល់ហើយ បានសួរភិក្ខុនោះដូច្នេះថា ម្នាលអាវុសោ ចុះការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ ភិក្ខុនោះបានពោលនឹងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោ ភិក្ខុដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងនិងសាបសូន្យទៅ នៃឧបាទានក្ខន្ធទាំង ៥ ។ បេ ។ នៃមហាភូតរូបទាំង ៤ ក្នុងកាលណា ។ បេ ។ ភិក្ខុដឹងច្បាស់តាមពិតថា របស់ណានីមួយមានការកើតឡើងជាធម្មតា របស់ទាំងអស់នោះរលត់ទៅវិញជាធម្មតា ម្នាលអាវុសោ

ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។ អថខោហំ ភន្តេ អសន្តុដ្ឋោ តស្ស ភិក្ខុស្ស បញ្ហាវេយ្យាករណេន យេន ភគវា តេនុបសង្កមឹ ។ បេ ។ កិត្តាវតា នុ ខោ ភន្តេ ភិក្ខុនោ ទស្សនំ សុវិសុទ្ធំ ហោតីតិ ។

[៣៣៩] សេយ្យថាបិ ភិក្ខុ បុរិសស្ស កឹសុកោ អ-ទិដ្ឋបុព្វោ អស្ស ។ សោ យេនញ្ញតរោ បុរិសោ កឹសុ-កស្ស ទស្សាវី តេនុបសង្កមេយ្យ ឧបសង្កមិត្វា តំ បុ-រិសំ ឯវំ វទេយ្យ កីទិសោ ភោ បុរិស កឹសុកោតិ ។ សោ ឯវំ វទេយ្យ កាឡកោ ខោ អម្ភោ បុរិស កឹសុកោ សេយ្យថាបិ ឈាមខាណូតិ ។ តេន ខោ បន ភិក្ខុ សមយេន តាទិសោវស្ស កឹសុកោ យថា តស្ស បុរិសស្ស ទស្សនំ ។ អថខោ សោ ភិក្ខុ បុរិសោ អសន្តុដ្ឋោ តស្ស បុរិសស្ស បញ្ហាវេយ្យាករណេន យេនញ្ញតរោ បុរិសោ កឹសុកស្ស ទស្សាវី តេនុប-សង្កមេយ្យ ឧបសង្កមិត្វា តំ បុរិសំ ឯវំ វទេយ្យ កីទិ-សោ អម្ភោ បុរិស កឹសុកោតិ ។ សោ ឯវំ វទេយ្យ

ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ក៏កើតមាន ដោយហេតុនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គមិនពេញចិត្តដោយពាក្យដោះស្រាយប្រស្នារបស់ភិក្ខុនោះ ក៏ចូលមកគាល់ព្រះមានព្រះភាគ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ការឃើញដ៏បរិសុទ្ធល្អរបស់ភិក្ខុ ដោយហេតុដូចម្តេច ។

[៣៣៩] ម្នាលភិក្ខុ ដូចបុរសមិនធ្លាប់ឃើញដើមចារ ។ បុរសនោះចូលទៅរកបុរសម្នាក់ទៀត ជាអ្នកធ្លាប់ឃើញដើមចារ លុះចូលទៅដល់ហើយ សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារដូចម្តេច ។ បុរសនោះប្រាប់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារមានសម្បុរខ្មៅដូចជាដង្កត់ដែលភ្លើងឆេះ ។ ម្នាលភិក្ខុ ក៏ក្នុងសម័យនោះឯង ដើមចារប្រាកដដូច្នោះមែន គឺដូចជាការឃើញរបស់បុរសនោះ ។ ម្នាលភិក្ខុ គ្រានោះឯង បុរសនោះមិនពេញចិត្តដោយពាក្យដោះស្រាយប្រស្នារបស់បុរសនោះ ក៏ចូលទៅរកបុរសម្នាក់ទៀត ជាអ្នកធ្លាប់ឃើញដើមចារ លុះចូលទៅដល់ហើយ សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារប្រាកដដូចជាអ្វី ។ បុរសនោះប្រាប់យ៉ាងនេះថា

## ៤៣៧

### អាសីវិសវគ្គោ ចតុត្ថោ

លោហិតកោ ខោ អម្ភោ បុរិស កឹសុកោ សេយ្យថាបិ មំសបេសីតិ ។ តេន ខោ បន ភិក្ខុ សមយេន តាទិសោវស្ស កឹសុកោ យថាបិ តស្ស បុរិសស្ស ទស្សនំ ។ អថខោ សោ ភិក្ខុ បុរិសោ អសន្តុដ្ឋោ តស្ស បុរិសស្ស បញ្ហាវេយ្យាករណេន យេនញ្ញតរោ បុរិសោ កឹសុកស្ស ទស្សាវី តេនុបសង្កមេយ្យ ឧបសង្កមិត្វា តំ បុរិសំ ឯវំ វទេយ្យ កីទិសោ ភោ បុរិស កឹសុកោតិ ។ សោ ឯវំ វទេយ្យ ឱចីរកជាតោ ខោ អម្ភោ បុរិស កឹសុកោ អាទិណ្ណសិបាដិកោ សេយ្យថាបិ សិរីសោតិ ។ តេន ខោ បន ភិក្ខុ សមយេន តាទិសោវស្ស កឹសុកោ យថាបិ តស្ស បុរិសស្ស ទស្សនំ ។ អថខោ សោ ភិក្ខុ បុរិសោ អសន្តុដ្ឋោ តស្ស បុរិសស្ស បញ្ហាវេយ្យាករណេន យេនញ្ញតរោ បុរិសោ កឹសុកស្ស ទស្សាវី តេនុបសង្កមេយ្យ ឧបសង្កមិត្វា

ម្នាលបុរសដ៏ចម្រើន ដើមចារមានសម្បុរក្រហមដូចជាដុំសាច់ ។ ម្នាលភិក្ខុ ក៏ក្នុងសម័យនោះឯង ដើមចារប្រាកដដូច្នោះមែន គឺដូចជាការឃើញរបស់បុរសនោះ ។ ម្នាលភិក្ខុ គ្រានោះឯង បុរសនោះមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់បុរសនោះ ក៏ចូលទៅរកបុរសម្នាក់ទៀត ជាអ្នកធ្លាប់ឃើញដើមចារ លុះចូលទៅដល់ហើយសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារប្រាកដដូចជាអ្វី ។ បុរសនោះប្រាប់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារមានផ្លែដូចជាសំពត់គេព្យួរ មានផ្លែដូចជាស្រោមដាវ មានមុខផ្កាប់ចុះដូចដើមច្រេស ។ ម្នាលភិក្ខុ ក៏ក្នុងសម័យនោះ ដើមចារប្រាកដដូច្នោះមែន គឺដូចជាការឃើញរបស់បុរសនោះដែរ ។ ម្នាលភិក្ខុ លំដាប់នោះឯង បុរសនោះមិនពេញចិត្ត ដោយពាក្យដោះស្រាយប្រស្នារបស់បុរសនោះ ក៏ចូលទៅរកបុរសម្នាក់ទៀត ជាអ្នកធ្លាប់ឃើញដើមចារ លុះចូលទៅដល់ហើយ

តំ បុរិសំ ឯវំ វទេយ្យ កីទិសោ ភោ បុរិស កឹសុកោតិ ។ សោ ឯវំ វទេយ្យ ពហលបត្តបលាសោ សណ្ឌច្ឆាយោ ខោ អម្ភោ បុរិស កឹសុកោ សេយ្យថាបិ និគ្រោ-ធោតិ ។ តេន ខោ បន ភិក្ខុ សមយេន តាទិសោ-វស្ស កឹសុកោ យថាបិ តស្ស បុរិសស្ស ទស្សនំ ។ ឯវមេវ ខោ ភិក្ខុ យថា យថា អធិមុត្តានំ តេសំ សប្បុរិសានំ ទស្សនំ សុវិសុទ្ធំ ហោតិ តថា តថា ខោ តេហិ(១) សប្បុរិសេហិ ព្យាកតំ ។

[៣៤០] សេយ្យថាបិ ភិក្ខុ រញ្ញោ បច្ចន្តិមំ នគរំ ទឡ្ហុទ្ទាបំ ទឡ្ហបាការតោរណំ(២) ឆទ្វារំ តត្រស្ស ទោវារិកោ បណ្ឌិតោ ព្យត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា ។ បុរត្ថិមាយ ទិសាយ អាគន្ត្វា សីឃំ ទូត-យុគំ តំ ទោវារិកំ ឯវំ វទេយ្យ កហំ ភោ បុរិស ឥមស្ស នគរស្ស សាមីតិ ។ សោ ឯវំ វទេយ្យ ឯសោ ភន្តេ មជ្ឈេ សិង្ឃាដកេ និសិន្នោតិ ។ អថខោ តំ សីឃំ ទូតយុគំ នគរស្សាមិស្ស យថាភូតំ វចនំ និយ្យាទេត្វា

១ ឱ. ម. តេហិ ។ ២ ឱ. ម. ទឡ្ហុទ្ទាបំ ទឡ្ហបាការតោរណំ ។

បានសួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារប្រាកដដូចជាអ្វី ។ បុរសនោះប្រាប់យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ដើមចារមានស្លឹកចាស់ខ្ចីដ៏ក្រាស់ មានម្លប់ដ៏ជិតដូចជាដើមជ្រៃ ។ ម្នាលភិក្ខុ ក៏ក្នុងសម័យនោះឯង ដើមចារប្រាកដដូច្នោះមែន គឺដូចជាការឃើញរបស់បុរសនោះ ។ ម្នាលភិក្ខុ សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចការឃើញដ៏បរិសុទ្ធល្អរបស់សប្បុរសទាំងនោះ ដែលមានចិត្តរួចស្រឡះហើយ ដោយអាការណា ៗ ពាក្យដែលសប្បុរសទាំងឡាយដ៏ឈ្លាសវៃ បានព្យាករហើយ ដោយអាការនោះ ៗ ។

[៣៤០] ម្នាលភិក្ខុ ដូចជានគរចុងដែនរបស់ព្រះរាជា មានកំពែងនិងខ្លោងទ្វារដ៏មាំមួន មានទ្វារ ៦ ក្នុងទ្វារទាំងនោះ មាននាយទ្វារជាបណ្ឌិតឈ្លាសវៃមានប្រាជ្ញា របស់ព្រះរាជានោះ ជាអ្នកហាមឃាត់ចំពោះពួកមនុស្សដែលមិនស្គាល់ បើកឲ្យចូលតែពួកមនុស្សដែលស្គាល់ ។ មានរាជទូតពីរនាក់ មកយ៉ាងរហ័សអំពីទិសខាងកើត ហើយនិយាយនឹងនាយទ្វារនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ម្ចាស់នគរនេះនៅក្នុងទីណា ។ នាយទ្វារនោះប្រាប់យ៉ាងនេះថា បពិត្រអ្នកដ៏ចម្រើន ម្ចាស់នុ៎ះអង្គុយនៅត្រង់កណ្តាលផ្លូវបែកជាបួន ។ គ្រានោះឯង រាជទូតពីរនាក់ដែលមកដល់ភ្លាមនោះ បានប្រគល់រាជសាសន៍តាមពិត ដល់ម្ចាស់នគរ

យថាគតមគ្គំ[១] បដិបជ្ជេយ្យ ។ បច្ឆិមាយ ទិសាយ អាគន្ត្វា សីឃំ ទូតយុគំ ។ បេ ។ ឧត្តរាយ ទិសាយ ទក្ខិណាយ ទិសាយ អាគន្ត្វា សីឃំ ទូតយុគំ តំ ទោវារិកំ ឯវំ វទេយ្យ កត្ថម្ភោ[២] បុរិស ឥមស្ស នគរស្ស នគរស្សាមីតិ ។ សោ ឯវំ វទេយ្យ ឯសោ ភន្តេ មជ្ឈេ សិង្ឃាដកេ និសិន្នោតិ ។ អថខោ តំ សីឃំ ទូតយុគំ នគរស្សាមិស្ស យថាភូតំ វចនំ និយ្យាទេត្វា យថាគតមគ្គំ បដិបជ្ជេយ្យ ។ ឧបមា ខោ មយាយំ ភិក្ខុ កតា អត្ថស្ស វិញ្ញាបនាយ អយញ្ចេត្ថ អត្ថោ នគរន្តិ ខោ ភិក្ខុ ឥមស្សេតំ ចាតុម្មហាភូតិកស្ស កាយស្ស អធិវចនំ មាតាបេត្តិកសម្ភវស្ស ឱទន-កុម្មាសូបចយស្ស និច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសន-ធម្មស្ស ។ ឆទ្វារាតិ ខោ ភិក្ខុ ឆន្នេតំ អជ្ឈត្តិ-កានំ អាយតនានំ អធិវចនំ ។ ទោវារិកោតិ ខោ ភិក្ខុ សតិយា ឯតំ អធិវចនំ ។ សីឃំ ទូតយុ-គន្តិ ខោ ភិក្ខុ សមថវិបស្សនានមេតំ អធិវចនំ ។

---

១ ឱ. ម. យថាភូតំ មគ្គំ ។ ២ ឱ. ម. កហំ ភោ ។

ហើយដើរទៅតាមផ្លូវដែលគួរទៅ ។ មានរាជទូតពីរនាក់មកយ៉ាងរហ័ស អំពីទិសខាងលិចទៀត ។ បេ ។ អំពីទិសខាងជើង មានរាជទូតពីរនាក់ទៀតមកយ៉ាងរហ័សអំពីទិសខាងត្បូង ហើយនិយាយនឹងនាយទ្វារនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ម្ចាស់នគរនេះនៅក្នុងទីណា ។ នាយទ្វារនោះប្រាប់យ៉ាងនេះថា បពិត្រអ្នកដ៏ចម្រើន ម្ចាស់នគរនុ៎ះអង្គុយនៅត្រង់កណ្តាលផ្លូវបែកជាបួន ។ គ្រានោះឯង រាជទូតពីរនាក់ដែលមកយ៉ាងរហ័សនោះ បានប្រគល់រាជសាសន៍តាមពិតដល់ម្ចាស់នគរ ហើយក៏ដើរទៅតាមផ្លូវដែលគួរទៅ ។ ម្នាលភិក្ខុ សេចក្តីឧបមានេះ តថាគតធ្វើដើម្បីបំភ្លឺនូវសេចក្តីអធិប្បាយ ឯសេចក្តីអធិប្បាយក្នុងពាក្យឧបមានោះដូច្នេះ ម្នាលភិក្ខុ ពាក្យថា នគរនុ៎ះ ជាឈ្មោះកាយនេះ ដែលប្រកបដោយមហាភូតរូបទាំង ៤ មានមាតាបិតាជាដែនកើត ចម្រើនឡើងដោយបាយនិងនំ មានការដុសខាត់គក់ច្របាច់ បំបាត់ក្លិនអាក្រក់ជានិច្ចជាធម្មតា ។ ម្នាលភិក្ខុ ពាក្យថា ទ្វារទាំង ៦ នុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។ ម្នាលភិក្ខុ ពាក្យថា នាយទ្វារនុ៎ះ ជាឈ្មោះនៃសតិ ។ ម្នាលភិក្ខុ ពាក្យថា រាជទូតពីរនាក់ដែលមករហ័សនុ៎ះ ជាឈ្មោះនៃសមថៈនិងវិបស្សនា ។

ឯតវស្សាមីតិ ខោ ភិក្ខុ វិញ្ញាណស្សេតំ អធិវចនំ ។ មជ្ឈេ សិង្ឃាដកាតិ ខោ ភិក្ខុ ចតុន្នេតំ មហាភូតានំ អធិវចនំ បឋវីធាតុយា អាបោធាតុយា តេជោធាតុយា វាយោធាតុយា ។ យថាភូតំ វចនន្តិ ខោ ភិក្ខុ និព្វា-នស្សេតំ អធិវចនំ ។ យថាគតមគ្គោតិ ខោ ភិក្ខុ អរិយស្សេតំ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ ។ សេយ្យ-ថីទំ ។ សម្មាទិដ្ឋិយា ។ បេ ។ សម្មាសមាធិស្សាតិ ។ អដ្ឋមំ ។

[៣៤១] យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ចក្ខុវិញ្ញេយ្យេសុ រូបេសុ ឧប្បជ្ជេយ្យ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា សប្បដិឃំ វាបិ ចេតសោ តតោ ចិត្តំ និវារេយ្យ សភយោ ចេសោ មគ្គោ សប្បដិភយោ សកណ្ដកោ ច សគហនោ ច ឧម្មគ្គោ ច កុម្មគ្គោ ច ទុហិតិកោ[១] ច អសប្បុរិសសេ-វិតោ ចេសោ មគ្គោ ន ចេសោ មគ្គោ សប្បុរិសសេវិតោ ន ត្វំ ឯតំ អរហសីតិ ។ តតោ ចិត្តំ និវារយេ ចក្ខុ-

១ ទ្វីហិតិកោតិបិ បាឋោ (អដ្ឋកថា) ។

ម្នាលភិក្ខុ ពាក្យថា ម្ចាស់នគរនុ៎ះ ជាឈ្មោះនៃវិញ្ញាណ ។ ម្នាលភិក្ខុ ពាក្យថា កណ្ដាលផ្លូវបែកជា ៤ នុ៎ះ ជាឈ្មោះនៃមហាភូតរូបទាំង ៤ គឺ បឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។ ម្នាលភិក្ខុ ពាក្យថា ព្រះរាជសាសន៍តាមពិតនុ៎ះ ជាឈ្មោះនៃព្រះនិព្វាន ។ ម្នាលភិក្ខុ ពាក្យថា ផ្លូវដែលគួរទៅនុ៎ះ ជាឈ្មោះនៃមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ។ ចប់សូត្រ ទី ៨ ។

[៣៤១] ម្នាលភិក្ខុទាំងឡាយ ឆន្ទៈក្ដី រាគៈក្ដី ទោសៈក្ដី មោហៈក្ដី សេចក្ដីថ្នាំងថ្នាក់នៃចិត្តក្ដី ក្នុងរូបទាំងឡាយដែលគប្បីដឹងច្បាស់ដោយចក្ខុ កើតឡើងដល់ភិក្ខុឬភិក្ខុនីណាមួយ ភិក្ខុឬភិក្ខុនីនោះត្រូវហាមឃាត់ចិត្ត ចាករូបទាំងនោះចេញថា នុ៎ះជាផ្លូវប្រកបដោយភ័យ ប្រកបដោយភ័យដ៏ពន្លឹក ប្រកបដោយបន្លា ប្រកបដោយព្រៃស្បាត ជាផ្លូវខុស ជាផ្លូវគួរខ្ពើម ជាផ្លូវទៅបានដោយកម្រ ផ្លូវនុ៎ះអសប្បុរសតែងតែសេពគប់ ផ្លូវនុ៎ះសប្បុរសមិនដែលសេពគប់ទេ អ្នកមិនគួរទៅតាមផ្លូវនុ៎ះឡើយ ។ ភិក្ខុគប្បីហាមឃាត់ចិត្តចាករូបទាំងឡាយដែលគប្បីដឹងដោយ

៤៤១

អាសីវិសវគ្គោ ចតុត្ថោ

វិញ្ញេយ្យេហិ រូបេហិ ។ បេ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា ជិវ្ហាវិញ្ញេយ្យេសុ រសេសុ ។ បេ ។ មនោវិញ្ញេយ្យេសុ ធម្មេសុ ឧប្បជ្ជេយ្យ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោ តតោ ចិត្តំ និវារេយ្យ សភយោ ចេសោ មគ្គោ សប្បដិភយោ ច សកណ្ដកោ ច សគហនោ ច ឧម្មគ្គោ ច កុម្មគ្គោ ច ទុហិតិកោ ច អសប្បុរិសសេវិតោ ចេសោ មគ្គោ ន ចេសោ មគ្គោ សប្បុរិសសេវិតោ ន ត្វំ ឯតំ អរហសីតិ ។ តតោ ចិត្តំ និវារយេ មនោវិញ្ញេយ្យេហិ ធម្មេហិ ។

ចក្ខុទាំងនោះចេញ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ឆន្ទៈក្តី រាគៈក្តី ទោសៈក្តី មោហៈក្តី សេចក្តីថ្នាំងថ្នាក់នៃចិត្តក្តី ក្នុងរសទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយអណ្តាត ។ បេ ។ ក្នុងធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងដោយចិត្ត កើតឡើងដល់ភិក្ខុឬភិក្ខុនីណាមួយ ភិក្ខុឬភិក្ខុនីនោះត្រូវហាមឃាត់ចិត្ត ចាកធម្មារម្មណ៍ទាំងនោះចេញថា នុ៎ះជាផ្លូវប្រកបដោយភ័យ ប្រកបដោយភ័យដ៏ពន្លឹក ប្រកបដោយបន្លា ប្រកបដោយព្រៃស្បាត ជាផ្លូវខុស ជាផ្លូវគួរខ្ពើម ជាផ្លូវទៅបានដោយកម្រ ផ្លូវនុ៎ះអសប្បុរសតែងតែសេពគប់ ផ្លូវនុ៎ះសប្បុរសមិនដែលសេពគប់ទេ អ្នកមិនគួរទៅតាមផ្លូវនុ៎ះឡើយ ។ ភិក្ខុឬភិក្ខុនី ត្រូវហាមឃាត់ចិត្តចាកធម្មារម្មណ៍ទាំងឡាយដែលគប្បីដឹងដោយចិត្តទាំងនោះចេញ ។

[៣៤២] សេយ្យថាបិ ភិក្ខវេ កិដ្ឋំ សម្បន្នំ កិដ្ឋារក្ខោ ច បមត្តោ គោណោ ច កិដ្ឋាទោ អទុំ កិដ្ឋំ ឱតរិត្វា យាវទត្ថំ មទំ អាបជ្ជេយ្យ បមាទំ អាបជ្ជេយ្យ ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ឆសុ ផស្សាយតនេសុ អសំវុតការី បញ្ចសុ កាមគុណេសុ យាវទត្ថំ មទំ អាបជ្ជតិ បមាទំ អាបជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ កិដ្ឋំ សម្បន្នំ កិដ្ឋារក្ខោ ច អប្បមត្តោ គោណោ ច កិដ្ឋាទោ អទុំ កិដ្ឋំ ឱតរេយ្យ តមេនំ កិដ្ឋារក្ខោ នាសាយ សុគ្គហិតំ គណ្ហេយ្យ នាសាយ សុគ្គហិតំ គហេត្វា ឧបរិឃដាយំ សុនិគ្គហិតំ និគ្គណ្ហេយ្យ ឧបរិឃដាយំ សុនិគ្គហិតំ និគ្គហេត្វា ទណ្ឌេន សុតាឡិតំ តាឡេយ្យ ទណ្ឌេន សុតាឡិតំ តាឡេត្វា ឱសជ្ជេយ្យ ។ ទុតិយម្បិ ខោ ភិក្ខវេ ។ បេ ។ តតិយម្បិ ខោ ភិក្ខវេ គោណោ កិដ្ឋាទោ

[៣៤២] ម្នាលភិក្ខុទាំងឡាយ ដូចជាសំទូងកំពុងមានពាសពេញ ឯអ្នករក្សាសំទូងក៏ធ្វេសប្រហែស ចំណែកឯគោធ្លាប់ស៊ីសំទូងក៏ចុះទៅកាន់សំទូងឯណោះ ហើយដល់នូវសេចក្តីស្រវឹង ដល់នូវសេចក្តីធ្វេសប្រហែស ស៊ីសំទូងដរាបដល់ឆ្អែត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង មិនធ្វើសេចក្តីសង្រួមក្នុងផស្សាយតនៈទាំង ៦ ក៏ដល់នូវសេចក្តីស្រវឹង ដល់នូវសេចក្តីធ្វេសប្រហែស ក្នុងកាមគុណទាំង ៥ ត្រាតែស្កប់ស្កល់ទៅ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាសំទូងកំពុងមានពាសពេញ ឯអ្នករក្សាសំទូងជាអ្នកមិនធ្វេសប្រហែស ចំណែកឯគោធ្លាប់ស៊ីសំទូង ក៏ចុះទៅកាន់សំទូងឯណោះ អ្នករក្សាសំទូងក៏ចាប់ដឹកគោនោះត្រង់ច្រមុះ លុះចាប់ដឹកត្រង់ច្រមុះបានហើយ ក៏យកទៅចងក្រៀកក្នុងប្រគាបឈើ លុះចងក្រៀកក្នុងប្រគាបឈើរួចហើយ ក៏វាយសំពងដោយដំបង លុះវាយសំពងដោយដំបងរួចហើយ ក៏ស្រាយលែងទៅ ។ ម្នាលភិក្ខុទាំងឡាយ អស់វារៈជាគម្រប់ពីរដងទៀត ។បេ។ ម្នាលភិក្ខុទាំងឡាយ គោដែលធ្លាប់ស៊ីសំទូង

អទុំ កិដ្ឋំ ឱតរេយ្យ តមេនំ កិដ្ឋារក្ខោ នាសាយ សុគ្គហិតំ គណ្ហេយ្យ នាសាយ សុគ្គហិតំ គហេត្វា ឧបរិឃដាយំ សុនិគ្គហិតំ និគ្គណ្ហេយ្យ ឧបរិឃដាយំ សុនិគ្គហិតំ និគ្គហេត្វា ទណ្ឌេន សុតាឡិតំ តាឡេយ្យ ទណ្ឌេន តាឡិតំ តាឡេត្វា ឱសជ្ជេយ្យ ។ ឯវំ ហិ សោ ភិក្ខវេ គោណោ កិដ្ឋាទោ គាមគតោ វា អរញ្ញគតោ វា ឋានពហុលោ វា អស្ស និសជ្ជពហុលោ វា ន តំ កិដ្ឋំ បុន ឱតរេយ្យ តមេវ បុរិមំ ទណ្ឌសម្ផស្សំ សម-នុស្សរន្តោ ។ ឯវមេវ ខោ ភិក្ខវេ យតោ ភិក្ខុនោ ឆសុ ផស្សាយតនេសុ ចិត្តំ ឧទុជ្ជិតំ ហោតិ សុទុជ្ជិតំ អជ្ឈត្តមេវ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ ស-មាធិយតិ ។

គប្បីចុះទៅកាន់សំទូងឯណោះ អ្នករក្សាសំទូង ក៏ចាប់ដឹកគោនោះត្រង់ច្រមុះ លុះចាប់ដឹកត្រង់ច្រមុះរួចហើយ ក៏យកទៅចងក្រៀកក្នុងប្រគាបឈើ លុះចងក្រៀកក្នុងប្រគាបឈើបានហើយ ក៏វាយសំពងដោយដំបង លុះវាយសំពងដោយដំបងរួចហើយ ក៏លែងទៅជាគម្រប់ ៣ ដងទៀត ។ ម្នាលភិក្ខុទាំងឡាយ កាលបើធ្វើយ៉ាងនេះ គោដែលធ្លាប់ស៊ីសំទូងនោះទៅក្នុងស្រុកក្តី ទៅក្នុងព្រៃក្តី ច្រើនដោយការឈរក្តី ច្រើនដោយការដេកក្តី កាលរឭកឃើញនូវសម្ពស្សដំបងអំពីមុននោះ ក៏មិនហ៊ានចុះកាន់សំទូងនោះទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូច កាលណាភិក្ខុបានគម្រាមចិត្ត បានគម្រាមល្អហើយ ក្នុងផស្សាយតនៈទាំង ៦ ចិត្តនោះក៏តាំងនៅ សម្ងំនៅតែខាងក្នុងប៉ុណ្ណោះ មានអារម្មណ៍ខ្ពស់ឯក តាំងនៅខ្ជាប់ខ្ជួន ។

[៣៨៣] សេយ្យថាបិ ភិក្ខវេ រញ្ញោ វា រាជមហាមត្តស្ស វា វីណាយ សទ្ទោ អស្សុតបុព្វោ អស្ស ។ សោ វីណាយ សទ្ទំ សុណេយ្យ សោ ឯវំ វទេយ្យ អម្ភោ កស្ស នុ ខោ ឯសោ សទ្ទោ ឯវំរជនីយោ ឯវំកម្មនីយោ ឯវំមទនីយោ ឯវំមុច្ឆនីយោ ឯវំពន្ធនីយោតិ ។ តមេនំ ឯវំ វទេយ្យ[១] ឯសា ខោ ភន្តេ វីណា នាម យស្សា ឯសោ សទ្ទោ ឯវំរជនីយោ ឯវំកម្មនីយោ ឯវំមទនីយោ ឯវំមុច្ឆនីយោ ឯវំពន្ធនីយោតិ ។ សោ ឯវំ វទេយ្យ គច្ឆថ មេ ភោ តំ វីណំ អាហរថាតិ ។ តស្ស តំ វីណំ អាហរេយ្យុំ តមេនំ ឯវំ វទេយ្យុំ អយំ ខោ សា ភន្តេ វីណា យស្សា ឯសោ សទ្ទោ ឯវំរជនីយោ ឯវំកម្មនីយោ ឯវំមទនីយោ ឯវំមុច្ឆនីយោ ឯវំពន្ធនីយោតិ ។ សោ ឯវំ វទេយ្យ អលំ មេ ភោ

---

១ ឱ. ម. ឯវំ វទេយ្យុំ ។

[៣៤៣] ម្នាលភិក្ខុទាំងឡាយ ដូចជាសំឡេងពិណដែលព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាមិនធ្លាប់បានស្តាប់ ។ ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះឮសំឡេងពិណ គប្បីសួរយ៉ាងនេះថា អើសំឡេងអ្នកណានុ៎ះហ្ន៎ គួរឲ្យមានតម្រេកអ្វីម៉្លេះ គួរឲ្យចង់ស្តាប់អ្វីម៉្លេះ គួរឲ្យភាន់ភាំងចិត្តអ្វីម៉្លេះ គួរឲ្យផប់ចិត្តអ្វីម៉្លេះ គួរឲ្យជក់ចិត្តអ្វីម៉្លេះ ។ អ្នកផងក៏ក្រាបទូលព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សំឡេងដែលគួរឲ្យមានតម្រេកយ៉ាងនេះ គួរអោយចង់ស្តាប់យ៉ាងនេះ គួរអោយភាន់ភាំងចិត្តយ៉ាងនេះ គួរអោយផប់ចិត្តយ៉ាងនេះ គួរឲ្យជក់ចិត្តយ៉ាងនេះ នុ៎ះជាសំឡេងពិណ ។ ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះក៏បង្គាប់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរទៅនាំយកពិណនោះមកឲ្យយើង ។ ពួករាជបុរសក៏នាំយកពិណនោះមកថ្វាយដល់ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សំឡេងដែលគួរឲ្យមានតម្រេកយ៉ាងនេះ គួរឲ្យចង់ស្តាប់យ៉ាងនេះ គួរឲ្យភាន់ភាំងចិត្តយ៉ាងនេះ គួរឲ្យផប់ចិត្តយ៉ាងនេះ គួរឲ្យជក់ចិត្តយ៉ាងនេះ នុ៎ះជាសំឡេងពិណនេះឯង ។ ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះត្រាស់យ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន

តាយ វីណាយ តមេវ មេ សន្តំ អាហរថាតិ ។ តមេនំ ឯវំ វទេយ្យុំ អយំ ខោ ភន្តេ វីណា នាម អនេកសម្ភារា មហាសម្ភារា អនេកេហិ សម្ភារេហិ សមារទ្ធា ចរតិ[១] ។ សេយ្យថីទំ ។ ទោណិញ្ច បដិច្ច មំញ្ច ទណ្ឌញ្ច បដិច្ច ឧបធារណេ ច បដិច្ច តន្តិយោ ច បដិច្ច កោណញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវាយំ ភន្តេ វីណា នាម អនេកសម្ភារា មហាសម្ភារា អនេកេហិ សម្ភារេហិ ចរតីតិ ។ សោ តំ វីណំ ទសធា វា សតធា វា ផាលេយ្យ ទសធា វា សតធា វា តំ ផាលេត្វា សកលិកំ សកលិកំ ករេយ្យ សកលិកំ សកលិកំ ករិត្វា អគ្គិនា ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ករេយ្យ មសឹ ករិត្វា មហាវាតេ[២] វា ឱផុនេយ្យ នទិយា វា សីឃសោតាយ បវាហេយ្យ ។ សោ ឯវំ វទេយ្យ អសតិ កិរាយំ កោ

១ ឱ. ម. វទតិ ។ ២ ឱ. ម. មហាវាតេ វា ។

យើងមិនត្រូវការនឹងពិណានោះទេ អ្នកទាំងឡាយ ចូរនាំយកតែសំឡេងពិណានោះមកឲ្យយើង ។ ពួករាជបុរសក្រាបទូលព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថាពិណានេះ មានអង្គជាអនេក មានអង្គដ៏ច្រើន ផ្សំដោយអង្គទាំងឡាយជាអនេកទើបដេញបាន ។ អង្គដូចម្តេចខ្លះ ។ គឺអាស្រ័យស្នូកផង អាស្រ័យទ្រូងផង អាស្រ័យដងផង អស្រ័យខ្នង់ទាំងឡាយផង អាស្រ័យខ្សែទាំងឡាយផង អាស្រ័យពំនូតផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់ពិណានោះ របស់បុរសផង បពិត្រព្រះអង្គដ៏ចម្រើន នេះឯងឈ្មោះថាពិណាមានអង្គជាអនេក មានអង្គដ៏ច្រើន ផ្សំដោយអង្គទាំងឡាយជាអនេក ទើបដេញបាន ។ ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះ ឲ្យបំបែកពិណានោះជា ១០ ចំណែកឬ ១០០ ចំណែក លុះអោយបំបែកពិណានោះជា ១០ ចំណែកឬ ១០០ ចំណែកហើយ ឲ្យពុះជាចម្រៀក ៗ លុះពុះជាចម្រៀក ៗ រួចហើយ ឲ្យកម្ទេចដោយភ្លើង លុះកម្ទេចដោយភ្លើងរួចហើយ ឲ្យកិនជាខ្លុកធ្យូង លុះកិនជាខ្លុកធ្យូងរួចហើយ ឲ្យរោយទៅតាមខ្យល់ដ៏ខ្លាំង ឬ បណ្តែតទៅតាមខ្សែទឹកទន្លេដ៏រហ័ស ។ ព្រះរាជាឬមហាមាត្យរបស់ព្រះរាជានោះត្រាស់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បានឮថា

វីណា នាម យថេវំ យំ កិញ្ចិ វីណា នាម ឯត្ថបនាយំ ជនោ អតិវេលម្បត្តោ បលាឡិតោតិ[១] ។ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ រូបំ សមន្នេសតិ យាវតា រូបស្ស គតិ វេទនំ សមន្នេសតិ យាវតា វេទនាយ គតិ សញ្ញំ សមន្នេសតិ យាវតា សញ្ញាយ គតិ សង្ខារេ សមន្នេសតិ យាវតា សង្ខារានំ គតិ វិញ្ញាណំ សមន្នេសតិ យាវតា វិញ្ញាណស្ស គតិ ។ តស្ស រូបំ សមន្នេសតោ យាវតា រូបស្ស គតិ វេទនំ សមន្នេសតោ ។ បេ ។ សញ្ញំ សង្ខារេ វិញ្ញាណំ សមន្នេសតោ យាវតា វិញ្ញាណស្ស គតិ យម្បិស្ស តំ ហោតិ អហន្តិ វា មមន្តិ វា អស្មីតិ វា តម្បិ តស្ស ន ហោតីតិ ។ នវមំ ។

---

១ ម. ឯត្ថ ច មហាជនោ អតិវេលំ បមត្តោ បលឡិដ្ឋិតោតិ ។

ធម្មតាពិណនេះជារបស់អាក្រក់ណាស់ ទុកជាពិណណានីមួយ ក៏សុទ្ធតែយ៉ាងនេះដែរ ដ្បិតថាជននេះដល់នូវការខូចវេលា ខ្វល់អំពល់ ព្រោះតែពិណនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចភិក្ខុពិចារណារូបថា គតិនៃរូបទាំងប៉ុន្មាន ពិចារណាវេទនាថា គតិនៃវេទនាទាំងប៉ុន្មាន ពិចារណាសញ្ញាថា គតិនៃសញ្ញាទាំងប៉ុន្មាន ពិចារណាសង្ខារទាំងឡាយថា គតិនៃសង្ខារទាំងឡាយទាំងប៉ុន្មាន ពិចារណាវិញ្ញាណថា គតិនៃវិញ្ញាណទាំងប៉ុន្មាន ។ កាលភិក្ខុនោះពិចារណារូបថា គតិនៃរូបទាំងប៉ុន្មាន ពិចារណាវេទនា ។ បេ ។ ពិចារណាសញ្ញា សង្ខារទាំងឡាយ វិញ្ញាណថា គតិនៃវិញ្ញាណទាំងប៉ុន្មាន ចិត្តណារបស់ភិក្ខុនោះថាអញ ថារបស់អញ ថាជាអញ ចិត្តនោះរបស់ភិក្ខុនោះ មិនមានឡើយ ។ ចប់សូត្រ ទី ៩ ។

៤៤៧

## អាសីវិសវគ្គោ ចតុត្ថោ

[៣៤៤] សេយ្យថាបិ ភិក្ខវេ បុរិសោ អរុកត្តោ បក្កកត្តោ សរវនំ បវិសេយ្យ តស្ស កុសកណ្ដកា ចេបិ ចាទេ វិជ្ឈេយ្យុំ ។ សរបត្តានិ បក្កកត្តានិ វិលេខេយ្យុំ[១] ។ ឯវំ ហិ សោ ភិក្ខវេ[២] ភិយ្យោសោ មត្តាយ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយេថ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ គាមគតោ វា អរញ្ញគតោ វា លភតិ វត្តារំ អយញ្ច សោ[៣] អាយស្មា ឯវំការី ឯវំសមាចារោ អសុចិគាមកណ្ដកោតិ តំ កណ្ដកោ[៤]តិ ។

---

១ ឱ. អរុបក្កាគត្តានិ វិលេខេយ្យុំ ។ ២ ឱ. ម. ភិក្ខវេ បុរិសោ ។ ៣ ឱ. ម. អយញ្ច ខោ ។ ៤ ម. តំ អសុចិគាមកណ្ដកោតិ ។

អាសីវិសវគ្គ ទី ៤

[៣៤៤] ម្នាលភិក្ខុទាំងឡាយ ដូចបុរសមានខ្លួនដំបៅ មានខ្លួនរង៉ាល (ដោយដំបៅ) បើចូលទៅកាន់ព្រៃបន្លា បន្លាស្រួច ៗ ទាំងឡាយមុតបាតជើងទាំងឡាយនៃបុរសនោះ ។ ស្លឹកឈើមានបន្លាទាំងឡាយក៏កោសរូសខ្លួនដែលរង៉ាល (ដោយដំបៅ របស់បុរសនោះ) ។ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុរសនោះ ក៏ត្រូវរងទុក្ខទោមនស្សហួសប្រមាណ ព្រោះបន្លានិងស្លឹកឈើនោះជាហេតុ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះក្នុងសាសនានេះ ទៅកាន់ស្រុកក្តី ទៅកាន់ព្រៃក្តី រមែងបាននូវអ្នកពោលចោទថា លោកមានអាយុនេះ ជាអ្នកធ្វើយ៉ាងនេះ ជាអ្នកមានមារយាទយ៉ាងនេះ ថាជាបន្លាក្នុងស្រុក មិនស្អាតដូច្នេះ (ខ្លះ) ថាជាអ្នកចាក់អ្នកស្រុកនោះដូច្នេះ (ខ្លះ) ក៏យ៉ាងនោះឯង ។

[៣៤៩] ឥតិ វិទិត្វា អសំវរោ ច សំវរោ ច វេទិតព្វោ ។ កថញ្ច ភិក្ខវេ អសំវរោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ អធិមុច្ចតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោតេន សទ្ទំ សុត្វា ។ ឃានេន គន្ធំ ឃាយិត្វា ។ ជិវ្ហាយ រសំ សាយិត្វា ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ អធិមុច្ចតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។

[៣៤៥] ភិក្ខុលុះដឹងយ៉ាងនេះហើយ ត្រូវដឹងច្បាស់ នូវសេចក្តីមិនសង្រួមនិងសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីមិនសង្រួម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ជ្រប់ក្នុងរូបជាទីស្រឡាញ់ ព្យាបាទក្នុងរូបមិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនតាំងមាំ មានចិត្តស្ដួចស្ដើងក្នុងកុសលធម៌ មួយវិញទៀត អកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងដល់ភិក្ខុនោះ រមែងរលត់ទៅ មិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ជញ្ជាប់រសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ជ្រប់ក្នុងធម្មារម្មណ៍ជាទីស្រឡាញ់ ព្យាបាទក្នុងធម្មារម្មណ៍មិនជាទីស្រឡាញ់ មានសតិក្នុងកាយមិនតាំងមាំ មានចិត្តស្ដួចស្ដើងក្នុងកុសលធម៌មួយវិញទៀត អកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅមិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។

## អាសីវិសវគ្គោ ចតុត្ថោ

[៣៤៦] សេយ្យថាបិ ភិក្ខវេ បុរិសោ ឆប្បាណកេ គហេត្វា នានាវិសយេ នានាគោចរេ ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ អហឹ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ សុំសុមារំ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ បក្ខឹ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ កុក្កុរំ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ សិគាលំ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ មក្កដំ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ ទឡ្ហាយ រជ្ជុយា ពន្ធិត្វា មជ្ឈេ គណ្ឋឹ ករិត្វា ឱសជ្ជេយ្យ ។ អថខោ តេ ភិក្ខវេ ឆប្បាណកា នានាវិសយា នានាគោចរា សកំ សកំ គោចរវិសយំ អាវិញ្ឆេយ្យុំ ។ អហិ អាវិញ្ឆេយ្យ វម្មិកំ បវេក្ខាមីតិ ។ សុំសុមារោ អាវិញ្ឆេយ្យ ឧទកំ បវេក្ខាមីតិ ។ បក្ខី អាវិញ្ឆេយ្យ អាកាសំ ឌេស្សាមីតិ ។ កុក្កុរោ អាវិញ្ឆេយ្យ គាមំ បវេក្ខាមីតិ ។ សិគាលោ អាវិញ្ឆេយ្យ សីវថិកំ បវេក្ខាមីតិ ។ មក្កដោ អាវិញ្ឆេយ្យ វនំ បវេក្ខាមីតិ ។ យទា ខោ តេ ភិក្ខវេ ឆប្បាណកាជ្ឈត្តា[១] អស្សុ កិលន្តា

---

១ ម. ឆប្បាណកាច្យុត្តា ។

## អាសីវិសវគ្គ ទី ៤

[៣៤៦] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសចាប់យកសត្វ ៦ ពួក ដែលមានវិស័យផ្សេង ៗ គ្នា មានគោចរផ្សេង ៗ គ្នា ហើយចងដោយខ្សែដ៏មាំ គឺចាប់យកពស់ចងដោយខ្សែដ៏មាំ ចាប់យកក្រពើចងដោយខ្សែដ៏មាំ ចាប់យកបក្សីចងដោយខ្សែដ៏មាំ ចាប់យកឆ្កែចងដោយខ្សែដ៏មាំ ចាប់យកចចកចងដោយខ្សែដ៏មាំ ចាប់យកស្វាចងដោយខ្សែដ៏មាំ លុះចងដោយខ្សែដ៏មាំរួចហើយ ក៏ត្របែងភ្ជាប់គ្នាត្រង់កណ្តាលហើយលែងទៅ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វទាំង ៦ ពួក ដែលមានវិស័យផ្សេង ៗ គ្នា មានគោចរផ្សេង ៗ គ្នានោះ ក៏ប្រឹងទាញមករកគោចរនិងវិស័យរបស់ខ្លួន ៗ ។ សត្វពស់ប្រឹងលូនទៅដោយគិតថា អញនឹងចូលទៅកាន់ដំបូក ។ ក្រពើប្រឹងវារទៅដោយគិតថា អញនឹងចុះទៅក្នុងទឹក ។ បក្សីប្រឹងស្ទុះទៅដោយគិតថា អញនឹងហើរទៅឰដ៏អាកាស ។ ឆ្កែប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ស្រុក ។ ចចកប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ព្រៃខ្មោច ។ ស្វាប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ព្រៃ ។ ម្នាលភិក្ខុទាំងឡាយ អត្តភាពនៃសត្វទាំង ៦ ពួកនោះ លំបាកណាស់ ក្នុងកាលណា

អថ យោ នេសំ ចាណកា[១] ពលវតរោ អស្ស តស្ស តេ អនុវត្តេយ្យុំ អនុវិធាយេយ្យុំ[២] វសំ គច្ឆេយ្យុំ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុនោ កាយគតាសតិ អភាវិតា អពហុលីកតា តំ ចក្ខុំ អាវិញ្ឆតិ មនាបិយេសុ រូបេសុ អមនាបិយា រូបា បដិក្កូលា ហោន្តិ ។ បេ ។ ជិវ្ហា អាវិញ្ឆតិ ។ កាយោ អាវិញ្ឆតិ ។ មនោ អាវិញ្ឆតិ មនាបិយេសុ ធម្មេសុ អមនាបិយា ធម្មា បដិក្កូលា ហោន្តិ ។ ឯវំ ខោ ភិក្ខវេ អសំវរោ ហោតិ ។

[៣៤៧] កថញ្ច ភិក្ខវេ សំវរោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ នាធិមុច្ចតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។

---

១ ឱ. ម. បាណកានំ ។ ២ ឱ. អនុវិធីយេយ្យុំ ។

បណ្តាសត្វទាំងនោះ សត្វណាដែលមានកម្លាំងជាងគេ សត្វទាំងនោះ ក៏ប្រព្រឹត្តទៅតាម ដោយទៅតាម លុះក្នុងអំណាចនៃសត្វដែលមានកម្លាំងនោះ ក្នុងកាលណោះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាយ-គតាសតិ ដែលភិក្ខុណាមួយមិនបានចម្រើន មិនបានធ្វើឲ្យច្រើន ចក្ខុក៏ទាញភិក្ខុនោះទៅក្នុងរូបទាំងឡាយដែលជាទីគាប់ចិត្ត រូបទាំងឡាយដែលមិនជាទីគាប់ចិត្ត ក៏ជារបស់បដិកូល ។ បេ ។ អណ្តាតក៏ទាញ ។ កាយក៏ទាញ ។ ចិត្តក៏ទាញចូលទៅក្នុងធម្មារម្មណ៍ទាំងឡាយដែលជាទីគាប់ចិត្ត ធម្មារម្មណ៍ទាំងឡាយដែលមិនជាទីគាប់ចិត្ត ក៏ជារបស់បដិកូល ក៏យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនសង្រួមយ៉ាងនេះឯង ។

[៣៤៧] ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីសង្រួម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ មិនជ្រប់ក្នុងរូបជាទីស្រឡាញ់ មិនព្យាបាទក្នុងរូបមិនជាទីស្រ-ឡាញ់ មានសតិក្នុងកាយតាំងមាំ មានចិត្តប្រមាណមិនបាន មួយទៀត អកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងដល់ភិក្ខុនោះ តែងរលត់ទៅមិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។ ឮសំឡេងដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ ជញ្ជាប់រសដោយអណ្តាត ។ បេ ។

កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ ធាធិមុច្ចតិ អប្បិយរូបេ ធម្មេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ ឧប្បន្នា បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។

[៣៤៨] សេយ្យថាបិ ភិក្ខវេ បុរិសោ ឆប្បាណកេ គហេត្វា នានាវិសយេ នានាគោចរេ ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ អហឹ គហេត្វា ។ បេ ។ សុំសុមារំ គហេត្វា ។ បេ ។ កុក្កុរំ គហេត្វា ។ សិគាលំ គហេត្វា ។ មក្កដំ គហេត្វា ទឡ្ហាយ រជ្ជុយា ពន្ធេយ្យ ទឡ្ហាយ រជ្ជុយា ពន្ធិត្វា ទឡ្ហាយ ខីលេ វា ថម្ភេ វា ឧបនិពន្ធេយ្យ ។ អថខោ តេ ភិក្ខវេ ឆប្បាណកា នានាវិសយា នានាគោចរា សកំ សកំ គោចរវិសយំ អាវិញ្ឆេយ្យុំ ។ អហិ អាវិញ្ឆេយ្យ វម្មិកំ បវេក្ខាមីតិ ។

ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ បេ ។ ដឹងធម្មារម្មណ៍ដោយចិត្តហើយ មិនជ្រប់ក្នុងធម្មារម្មណ៍ដែលជាទីស្រឡាញ់ មិនព្យាបាទក្នុងធម្មារម្មណ៍ មិនជាទីស្រឡាញ់ មានសតិក្នុងកាយតាំងមាំ មានចិត្តប្រមាណមិនបាន មួយវិញទៀត អកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងដល់ភិក្ខុនោះ រមែងរលត់ទៅមិនមានសេសសល់ ក្នុងចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ក៏ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ ។

[៣៤៨] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសចាប់យកសត្វ ៦ ពួក ដែលមានវិស័យផ្សេង ៗ គ្នា មានគោចរផ្សេង ៗ គ្នា ចងដោយខ្សែដ៏មាំ គឺចាប់យកពស់ ។ បេ ។ ចាប់យកក្រពើ ។ បេ ។ ចាប់យកឆ្កែ ។ ចាប់យកចចក ។ ចាប់យកស្វា ចងដោយខ្សែដ៏មាំ លុះចងដោយខ្សែដ៏មាំរួចហើយ ក៏ក្រៀកនឹងបង្គោល ឬ សសរដ៏មាំ ។ ម្នាលភិក្ខុទាំង-ឡាយ លំដាប់នោះឯង សត្វទាំង ៦ ពួក ដែលមានវិស័យផ្សេង ៗ គ្នា មានគោចរផ្សេង ៗ គ្នានោះ ក៏ប្រឹងទាញទៅកាន់គោចរនិងវិស័យរបស់ខ្លួន ៗ ពស់ប្រឹងលូនទៅដោយគិតថា អញនឹងចូលទៅកាន់ដំបូក ។

សុំសុមារោ អាវិញ្ឆេយ្យ ឧទកំ បវេក្ខាមីតិ ។ បក្ខី អាវិញ្ឆេយ្យ អាកាសំ ឌេស្សាមីតិ ។ កុក្កុរោ អាវិញ្ឆេយ្យ គាមំ បវេក្ខាមីតិ ។ សិគាលោ អាវិញ្ឆេយ្យ សីវថិកំ បវេក្ខាមីតិ ។ មក្កដោ អាវិញ្ឆេយ្យ វនំ បវេក្ខាមីតិ ។ យថា ខោ តេ ភិក្ខវេ ឆប្បាណកាជ្ឈត្តា អស្សុ កិលន្តា អថ តមេវ ខីលំ វា ថម្ភំ(១) វា ឧបតិដ្ឋេយ្យុំ ឧបនិសីទេយ្យុំ ឧបនិបជ្ជេយ្យុំ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុនោ កាយគតាសតិ ភាវិតា ពហុលីកតា តំ ចក្ខុ នាវិញ្ឆតិ មនាបិយេសុ រូបេសុ អមនាបិយា រូបា ន បដិក្កូលា ហោន្តិ ។ បេ ។ ជិវ្ហា នាវិញ្ឆតិ ។ បេ ។ មនោ នាវិញ្ឆតិ មនាបិយេសុ ធម្មេសុ អមនាបិយា ធម្មា ន បដិក្កូលា ហោន្តិ ។ ឯវំ ខោ ភិក្ខវេ សំវរោ ហោតិ ។ ទឡ្ហេ ខីលេ វា ថម្ភេ វាតិ ខោ ភិក្ខវេ កាយគតាសតិយា ឯតំ អធិវចនំ ។ តស្មាតិហ(២) ភិក្ខវេ

១ ឱ. ម. ខីលេ វា ថម្ភេ វា ។ ២ ឱ. ម. តិហវោ ។

ក្រពើប្រឹងវារទៅដោយគិតថា អញនឹងចុះទៅក្នុងទឹក ។ បក្សីប្រឹងស្ទុះទៅដោយគិតថា អញនឹងហើរទៅឰដ៏អាកាស ។ ឆ្កែប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ស្រុក ។ ចចកប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ព្រៃខ្មោច ។ ស្វាប្រឹងស្ទុះទៅដោយគិតថា អញនឹងចូលទៅកាន់ព្រៃ ។ ម្នាលភិក្ខុទាំងឡាយ អត្តភាពនៃសត្វទាំង ៦ ពួកនោះលំបាកណាស់ ឈរផ្អែក អង្គុយផ្អែក ដេកផ្អែកនឹងបង្គោលឬសសរនោះឯង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាទីមួយបានចម្រើន បានធ្វើឲ្យច្រើនហើយ ចក្ខុក៏មិនទាញភិក្ខុនោះចូលទៅក្នុងរូបទាំងឡាយដែលជាទីគាប់ចិត្ត រូបទាំងឡាយមិនជាទីគាប់ចិត្ត ក៏មិនមែនជារបស់បដិកូល ។ បេ ។ អណ្តាតមិនបានទាញ ។ បេ ។ ចិត្តមិនបានទាញចូលទៅក្នុងធម្មារម្មណ៍ទាំងឡាយដែលជាទីគាប់ចិត្ត ធម្មារម្មណ៍ទាំងឡាយមិនជាទីគាប់ចិត្ត ក៏មិនមែនជារបស់បដិកូលក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសង្រួមយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បង្គោល ឬសសរដ៏មាំទាំ ជាឈ្មោះនៃកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ

ឯវំ សិក្ខិតព្វំ កាយគតា នោ សតិ ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ឆសមំ ។

[៣៤៩] សេយ្យថាបិ ភិក្ខវេ យវកលាបិ ចាតុម្មហាបថេ និក្ខិត្តា អស្ស អថ ឆ បុរិសា អាគច្ឆេយ្យុំ ព្យាភង្គិហត្ថា តេ យេន[១] យវកលាបឹ ឆហិ ព្យាភង្គីហិ ហនេយ្យុំ ឯវំ ហិ សា ភិក្ខវេ យវកលាបី សុហតា អស្ស ឆហិ ព្យាភង្គីហិ ហញ្ញមានា អថ សត្តមោ បុរិសោ អាគច្ឆេយ្យ ព្យាភង្គិហត្ថោ សោ តំ យវកលាបឹ សត្តមាយ ព្យាភង្គិយា ហនេយ្យ ឯវំ ហិ សា ភិក្ខវេ យវកលាបី សុហតតរា អស្ស សត្តមាយ ព្យាភង្គិយា ហញ្ញមានា ។ ឯវមេវ ខោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ចក្ខុស្មឹ ហញ្ញតិ មនាបាមនា-

១ ឱ. តំ យវកលាបឹ ។ ម. តេ យវកលាបី ។

អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា កាយគតាសតិដែលយើងទាំង-ឡាយបានចម្រើន បានធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ ឲ្យតាំងនៅញឹកញយ សន្សំទុកមិនឲ្យបាត់ ប្រារព្ធដោយល្អ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រ ទី ១០ ។

[៣៤៩] ម្នាលភិក្ខុទាំងឡាយ ដូចកណ្តាប់ស្រូវដំណើបទាំង-ឡាយ ដែលបុគ្គលគរទុកត្រង់ផ្លូវធំបែកជា ៤ លំដាប់នោះ បុរស ៦ នាក់មានអម្រែកក្នុងដៃដើរមក បុរសទាំងនោះវាយកណ្តាប់ស្រូវដំណើបដោយដងវែកទាំង ៦ ម្នាលភិក្ខុទាំងឡាយ កាលបើកណ្តាប់ស្រូវដំណើបនោះដែលពួកបុរសកំពុងវាយព្រមគ្នា ដោយដងវែកទាំង ៦ យ៉ាងនេះ ស្រាប់តែបុរសជាគម្រប់ ៧ មានអម្រែកក្នុងដៃដើរមក បុរសនោះវាយកណ្តាប់ស្រូវដំណើបនោះដោយដងវែកទី ៧ ម្នាលភិក្ខុទាំងឡាយ ឯកណ្តាប់ស្រូវដំណើបនោះ កាលបើបុរសវាយដោយដងវែកទី ៧ យ៉ាងនេះឯង ឈ្មោះថាវាយកំទេចក្រៃលែង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានចេះដឹង តែងលំបាកដោយសាររូបទាំងឡាយដែលជាទីគាប់ចិត្ត

បេហិ រូបេហិ ។ បេ ។ ជិវ្ហាយ ហញ្ញតិ មនាបាមនាបេហិ រសេហិ ។ បេ ។ មនស្មឹ ហញ្ញតិ មនាបាមនាបេហិ ធម្មេហិ ។ សចេ សោ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អាយតឹ បុនព្ភវាយ ចេតេតិ ។ ឯវំ ហិ សោ ភិក្ខវេ មោឃបុរិសោ សុហតតរោ ហោតិ ។ សេយ្យថាបិ[១] សា យវកលាបី សត្តមាយ ព្យាភង្គិយា ហញ្ញមា-នាតិ ។ ឯកាទសមំ ។

[៣៩០] ភូតបុព្វំ ភិក្ខវេ ទេវាសុរសង្គាមោ សមុ-បព្យូឡ្ហោ អហោសិ ។ អថខោ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ

១ ឱ. សេយ្យថាបិ ភិក្ខវេ ។

និងមិនជាទីគាប់ចិត្ត (ដែលមកប៉ះ) នឹងភ្នែក ។ បេ ។ តែងលំបាកដោយសាររសទាំងឡាយ ដែលជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត (ដែលមកប៉ះ) នឹងអណ្តាត ។ បេ ។ តែងលំបាកដោយសារធម្មារម្មណ៍ទាំងឡាយ ដែលជាទីគាប់ចិត្តនិងមិនជាទីគាប់ចិត្ត (ដែលមកប៉ះ) នឹងចិត្ត ។ ម្នាលភិក្ខុទាំងឡាយ បើបុថុជ្ជនអ្នកមិនចេះដឹងនោះគិតដើម្បីភពថ្មីទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ មោឃបុរសនោះ ឈ្មោះថាជាអ្នកត្រូវអារម្មណ៍បៀតបៀនខ្លាំងក្រៃពេក ។ ដូចជាកណ្តាប់ស្រូវដំណើបនោះ ដែលបុរសវាយដោយដងរែកជាគម្រប់ ៧ ដូច្នោះឯង ។ ចប់សូត្រ ទី ១១ ។

[៣៩០] ម្នាលភិក្ខុទាំងឡាយ រឿងពីព្រេងនាយធ្លាប់មានមកថា សង្គ្រាមនៃអសុរមួយអន្លើដោយទេវតា ជាសង្គ្រាមប្រទល់គៀកគ្នាហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង អសុរិន្ទឈ្មោះវេបចិត្តិ

អសុរេ អាមន្តេសិ សចេ មារិសា ទេវាសុរសង្គាមេ សមុបព្យូឡ្ហេ អសុរា ជិនេយ្យុំ ទេវា បរាជិនេយ្យុំ យេន នំ សក្កំ ទេវានមិន្ទំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិត្វា មម សន្តិកេ អានេយ្យាថ អសុរបុរន្តិ ។ សក្កោបិ ខោ ភិក្ខវេ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ សចេ មារិសា ទេវាសុរសង្គាមេ សមុបព្យូឡ្ហេ ទេវា ជិនេយ្យុំ អសុរា បរាជិនេយ្យុំ[១] យេន នំ វេបចិត្តិអសុរិន្ទំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិត្វា មម សន្តិកេ អានេយ្យាថ សុធម្មំ ទេវសភន្តិ ។ តស្មឹ ខោ បន ភិក្ខវេ សង្គាមេ ទេវា ជិនឹសុ អសុរា បរាជិនឹសុ ។ អថខោ ភិក្ខវេ ទេវា តាវតឹសា វេបចិត្តិអសុរិន្ទំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិត្វា សក្កស្ស ទេវានមិន្ទស្ស សន្តិកេ អានេសុំ សុធម្មំ ទេវសភំ ។

---

១ កត្ថចិ បោត្ថកេ បរាជិនឹសុ ។

ហៅអសុរទាំងឡាយមកថា នៃពួកយើងរាល់គ្នា បើសង្គ្រាមនៃអសុរមួយអន្លើដោយពួកទេវតា ជាសង្គ្រាមប្រទល់កៀកគ្នាហើយ បើពួកអសុរឈ្នះ ពួកទេវតាចាញ់ អ្នកទាំងឡាយ គប្បីចងសក្កទេវរាជជាកំពូលនៃទេវតាទាំងឡាយនោះ ដោយចំណងទាំងឡាយមានចំណងកជាគម្រប់ ៥ ហើយនាំមកកាន់អសុរបុរី ក្នុងសំណាក់នៃយើង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងសក្កទេវរាជ ជាកំពូលនៃទេវតាទាំងឡាយ ត្រាស់ហៅទេវតាទាំងឡាយជាន់តាវត្តិង្សមកថា នៃពួកយើងរាល់គ្នា កាលបើសង្គ្រាមនៃអសុរមួយអន្លើដោយទេវតា មកប្រទល់កៀកគ្នាហើយ បើពួកទេវតាឈ្នះពួកអសុរចាញ់ អ្នកទាំងឡាយត្រូវចងអសុរិន្ទឈ្មោះវេបចិត្តិនោះ ដោយចំណងមានចំណងកជាគម្រប់ ៥ ហើយនាំមកកាន់ទេវសភាឈ្មោះសុធម្មា ក្នុងសំណាក់នៃយើង ។ ម្នាលភិក្ខុទាំងឡាយ ឯក្នុងសង្គ្រាមនោះឯងពួកទេវតាឈ្នះ ពួកអសុរចាញ់ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯងទេវតាឋានតាវត្តិង្ស ចាប់ចងវេបចិត្តិអសុរិន្ទ ដោយចំណងទាំងឡាយមានចំណងកជាគម្រប់ ៥ ហើយនាំមកកាន់ទេវសភាឈ្មោះសុធម្មា ក្នុងសំណាក់នៃសក្កទេវរាជ ជាកំពូលនៃទេវតាទាំងឡាយ ។

[៣៩១] តត្រ សុទំ ភិក្ខវេ វេបចិត្តិ អសុរិន្ទោ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធោ ហោតិ ។ យទា ច ខោ ភិក្ខវេ វេបចិត្តិស្ស អសុរិន្ទស្ស ឯវំ ហោតិ ធម្មិកា ខោ ទេវា អធម្មិកា អសុរា ឥធាគមិហំ ទេវបុរំ គច្ឆាមីតិ ។ អថ កណ្ឋបញ្ចមេហិ ពន្ធនេហិ មុត្តំ អត្តានំ សមនុបស្សតិ ទិព្វេហិ ច បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ។ យទា ច ខោ ភិក្ខវេ វេបចិត្តិស្ស អសុរិន្ទស្ស ឯវំ ហោតិ ធម្មិកា ខោ អសុរា អធម្មិកា ទេវា តត្ថេវាគមិហំ អសុរបុរំ គមិស្សាមីតិ ។ អថ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធំ អត្តានំ សមនុបស្សតិ ទិព្វេហិ ច បញ្ចហិ កាមគុណេហិ បរិហាយតិ ។ ឯវំ សុខុមំ ខោ ភិក្ខវេ វេបចិត្តិពន្ធនំ តតោ សុខុមតរំ មារពន្ធនំ មញ្ញមានោ ខោ ភិក្ខវេ ពន្ធោ មារស្ស អមញ្ញមានោ មុត្តោ បាបិមតោ ។

[៣៩១] ម្នាលភិក្ខុទាំងឡាយ បានឮថា ក្នុងសង្គ្រាមនោះ វេបចិត្តិអសុរិន្ទ ជាប់ដោយចំណងទាំងឡាយមានចំណងកជាគម្រប់ ៥ មែន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណាវេបចិត្តិអសុរិន្ទមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកទេវតាប្រកបដោយធម៌មែន ពួកអសុរមិនប្រកបដោយធម៌ទេ ឥឡូវនេះ អាត្មាអញទៅកាន់បុរីទេវតា ។ ក្នុងកាលនោះ វេបចិត្តិអសុរិន្ទ ក៏ពិចារណាឃើញ នូវខ្លួនដែលរួចចេញចាកចំណងទាំងឡាយ មានចំណងកជាគម្រប់ ៥ ហើយថែមទាំងបានឆ្អែតស្កប់ស្កល់គ្រប់សព្វ មានគេបម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណា វេបចិត្តអសុរិន្ទ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកអសុរប្រកបដោយធម៌មែន ពួកទេវតាមិនប្រកបដោយធម៌ទេ ឥឡូវនេះ អាត្មាអញនឹងទៅកាន់បុរីនៃអសុរក្នុងពិភពអសុរនោះវិញ ។ កាលនោះ វេបចិត្តិអសុរិន្ទពិចារណាឃើញ នូវខ្លួនដែលជាប់ដោយចំណងទាំងឡាយ មានចំណងកជាគម្រប់ ៥ ទាំងសាបសូន្យចាកកាមគុណទាំងឡាយ ៥ ដ៏ជាទិព្វ ។ ម្នាលភិក្ខុទាំងឡាយ ចំណងវេបចិត្តិដ៏សុខុមយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលសម្គាល់ឃើញ នូវចំណងមារដ៏សុខុមជាងនោះទៅទៀត ថាជាចំណងរបស់មារពិត កាលបើមិនសម្គាល់ ទើបផុតចាកមារមានចិត្តបាបបាន ។

អាសីវិសវគ្គោ ចតុត្ថោ

[៣៨២] អស្មីតិ ភិក្ខវេ មញ្ញិតមេតំ អយមហ-
មស្មីតិ មញ្ញិតមេតំ ភវិស្សន្តិ មញ្ញិតមេតំ ន ភវិស្សន្តិ
មញ្ញិតមេតំ រូបី ភវិស្សន្តិ មញ្ញិតមេតំ អរូបី ភវិស្សន្តិ
មញ្ញិតមេតំ សញ្ញី ភវិស្សន្តិ មញ្ញិតមេតំ អសញ្ញី ភ-
វិស្សន្តិ មញ្ញិតមេតំ នេវសញ្ញិនាសញ្ញី ភវិស្សន្តិ មញ្ញិ-
តមេតំ ។ មញ្ញិតំ ភិក្ខវេ រោគោ មញ្ញិតំ គណ្ឌោ
មញ្ញិតំ សល្លំ តស្មាតិហ ភិក្ខវេ អមញ្ញមានេន[១] ចេ-
តសា វិហរិស្សាមីតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

១ ឱ. ម. អមញ្ញិតមានេន ចេតសោ ។

## អាសីវិសវគ្គ ទី ៤

[៣៩២] ម្នាលភិក្ខុទាំងឡាយ សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញមាន សេចក្ដីសម្គាល់ដូច្នេះថា នេះជាអាត្មាអញ សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញនឹងមាន សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញនឹងមិនមាន សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញនឹងមានរូប សេចក្ដីសំ-គាល់ដូច្នេះថា អាត្មាអញនឹងមិនមានរូប សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញមានសញ្ញា សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញនឹងមិនមានសញ្ញា សេចក្ដីសម្គាល់ដូច្នេះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសម្គាល់ជារោគ សេចក្ដីសំ-គាល់ជាបូស សេចក្ដីសម្គាល់ជាកូនសរ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ត្រូវគិតថា អាត្មាអញនឹងមានចិត្តឥតមានសេចក្ដីសម្គាល់ នៅគ្រប់ឥរិយាបថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។

[៣៩៣] អស្មីតិ ភិក្ខវេ ឥញ្ជិតមេតំ អយមហមស្មីតិ ឥញ្ជិតមេតំ ភវិស្សន្តិ ឥញ្ជិតមេតំ ន ភវិស្សន្តិ ឥញ្ជិតមេតំ រូបី ភវិស្សន្តិ ឥញ្ជិតមេតំ អរូបី ភវិស្សន្តិ ឥញ្ជិតមេតំ សញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ អសញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ នេវសញ្ញិនាសញ្ញី ភវិស្សន្តិ ឥញ្ជិតមេតំ ។ ឥញ្ជិតំ ភិក្ខវេ រោគោ ឥញ្ជិតំ គណ្ឌោ ឥញ្ជិតំ សល្លំ តស្មាតិហ ភិក្ខវេ អនិញ្ជិយមានេន ចេតសា វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

[៣៩៤] អស្មីតិ ភិក្ខវេ ផន្ទិតមេតំ អយមហមស្មីតិ ផន្ទិតមេតំ ភវិស្សន្តិ ។ បេ ។ ន ភវិស្សន្តិ ។ រូបី ភវិស្សន្តិ ។ អរូបី ភវិស្សន្តិ ។ សញ្ញី ភវិស្សន្តិ ។ អសញ្ញី ភវិស្សន្តិ ។ នេវសញ្ញិនាសញ្ញី ភវិស្សន្តិ

[៣៥៣] ម្នាលភិក្ខុទាំងឡាយ សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញមាន សេចក្តីញាប់ញ័រដូច្នេះថា នេះជាអាត្មាអញ សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមាន សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមិនមាន សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមានរូប សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមិនមានរូប សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមានសញ្ញា សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមិនមានសញ្ញា សេចក្តីញាប់ញ័រដូច្នេះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីញាប់ញ័រជារោគ សេចក្តីញាប់ញ័រជាបូស សេចក្តីញាប់ញ័រជាកូនសរ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ត្រូវគិតថា អាត្មាអញនឹងមានចិត្តមិនញាប់ញ័រនៅគ្រប់ឥរិយាបថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[៣៥៤] ម្នាលភិក្ខុទាំងឡាយ សេចក្តីអន្ទះអន្ទែងដូច្នេះថា អាត្មាអញមាន សេចក្តីអន្ទះអន្ទែងដូច្នេះថា នេះជាអាត្មាអញ ថាអាត្មាអញនឹងមាន ។ បេ ។ ថាអាត្មាអញនឹងមិនមាន ។ ថាអាត្មាអញនឹងមានរូប ។ ថាអាត្មាអញនឹងមិនមានរូប ។ ថាអាត្មាអញនឹងមានសញ្ញា ។ ថាអាត្មាអញនឹងមិនមានសញ្ញា ។ សេចក្តីអន្ទះអន្ទែងដូច្នេះថា អាត្មាអញនឹង

ឆន្ទិតមេតំ ។ ឆន្ទិតំ ភិក្ខវេ រោគោ ឆន្ទិតំ គណ្ឌោ ឆន្ទិតំ សល្លំ តស្មាតិហ ភិក្ខវេ អឆន្ទិយមានេន ចេតសា វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

[៣៨៨] អស្មីតិ ភិក្ខវេ បបញ្ចិតមេតំ អយមហមស្មីតិ បបញ្ចិតមេតំ ភវិស្សន្តិ ។ បេ ។ ន ភវិស្សន្តិ ។ រូបី ភវិស្សន្តិ ។ អរូបី ភវិស្សន្តិ ។ សញ្ញី ភវិស្សន្តិ ។ អសញ្ញី ភវិស្សន្តិ ។ នេវសញ្ញីនាសញ្ញី ភវិស្សន្តិ បបញ្ចិតមេតំ ។ បបញ្ចិតំ ភិក្ខវេ រោគោ បបញ្ចិតំ គណ្ឌោ បបញ្ចិតំ សល្លំ តស្មាតិហ ភិក្ខវេ និប្បបញ្ចេន ចេតសា វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

មានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីអន្ទះអន្ទែងជារោគ សេចក្តីអន្ទះអន្ទែងជាបូស សេចក្តីអន្ទះអន្ទែងជាកូនសរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូច្នោះ ត្រូវគិតថា អាត្មាអញនឹងមានចិត្តមិនអន្ទះអន្ទែង នៅគ្រប់ឥរិយាបថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។

[៣៥៥] ម្នាលភិក្ខុទាំងឡាយ សេចក្តីយឺតយូរដូច្នេះថា អាត្មាអញមាន សេចក្តីយឺតយូរដូច្នេះថា នេះជាអាត្មាអញ ថាអាត្មាអញនឹងមាន ។ បេ ។ ថាអាត្មាអញនឹងមិនមាន ។ ថាអាត្មាអញនឹងមានរូប ។ ថាអាត្មាអញនឹងមិនមានរូប ។ ថាអាត្មាអញនឹងមានសញ្ញា ។ ថាអាត្មាអញនឹងមិនមានសញ្ញា ។ សេចក្តីយឺតយូរដូច្នេះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយឺតយូរជារោគ សេចក្តីយឺតយូរជាបូស សេចក្តីយឺតយូរជាកូនសរ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ត្រូវគិតថា អាត្មាអញនឹងមានចិត្តមិនយឺតយូរ នៅគ្រប់ឥរិយាបថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។

[៣៩៦] អស្មីតិ ភិក្ខវេ មាញ្ញិតមេតំ អយមហមស្មីតិ មញ្ញិតមេតំ ភវិស្សន្តិ មញ្ញិតមេតំ ន ភវិស្សន្តិ មញ្ញិតមេតំ រូបី ភវិស្សន្តិ មញ្ញិតមេតំ អរូបី ភវិស្សន្តិ មញ្ញិតមេតំ សញ្ញី ភវិស្សន្តិ មញ្ញិតមេតំ អសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ នេវសញ្ញិនាសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ ។ មញ្ញិតំ ភិក្ខវេ រោគោ មញ្ញិតំ គណ្ឌោ មញ្ញិតំ សល្លំ តស្មាតិហ ភិក្ខវេ អមញ្ញិតេន ចេតសា វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទ្វាទសមំ ។

អាសីវិសវគ្គោ ចតុត្ថោ ។

[៣៩៦] ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញមាន សេចក្តីប្រកាន់ដូច្នេះថា នេះជាអាត្មាអញ សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមាន សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមិនមាន សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមានរូប សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមិនមានរូប សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមានសញ្ញា សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមិនមានសញ្ញា សេចក្តីប្រកាន់ដូច្នេះថា អាត្មាអញនឹងមានសញ្ញាក៏ទេ មិនមានសញ្ញាក៏ទេដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រកាន់នេះជារោគ សេចក្តីប្រកាន់នេះជាបូស សេចក្តីប្រកាន់នេះជាកូនសរ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ត្រូវគិតថា អាត្មាអញនឹងមានចិត្តប្រាសចាកសេចក្តីប្រកាន់នៅគ្រប់ឥរិយាបថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រ ទី ១២ ។

ចប់ អាសីវិសវគ្គ ទី ៤ ។

អាសីវិសវគ្គោ ចតុត្ថោ

# តស្សុទ្ទានំ

អាសីវិសោ រថោ កុម្មោ
ទ្វេ ទារុក្ខន្ធេន អវស្សុតោ
ទុក្ខធម្មា កឹសុកា វីណា
ឆប្បាណា យវកលាបិកេន[១] ចាតិ ។

សឡាយតនវគ្គេ បណ្ណាសកំ ចតុត្ថំ ។

# តស្សុទ្ទានំ

នន្ទិក្ខយា សដ្ឋីនយា
សមុទ្ទោ ឧរគេន ច
ចតុប្បណ្ណាសកា ឯតេ
និបាតេសុ បកាសិតាតិ ។

១ យវកលាបីតិ ។

អាសីវិសវគ្គ ទី ៤

## ឧទ្ទាននៃអាសីវិសវគ្គនោះ គឺ

*និយាយអំពីអាសីរពិស ១ អំពីរថ ១ អំពីអណ្តើក ១ អំពីកំណាត់ឈើមាន ២ លើក អំពីភិក្ខុមានចិត្តទទឹកដោយរាគៈ ១ អំពីធម៌ជាទុក្ខ ១ អំពីដើមចារ ១ អំពីពិណ ១ អំពីសត្វ ៦ ពួក ១ អំពីកណ្តាប់ស្រូវដំណើប ១ អំពីសង្គ្រាមទេវតានិងអសុរ ១ ។*

ចប់ បណ្ណាសកៈ ទី ៤ ក្នុងសឡាយតនវគ្គ ។

## ឧទ្ទាននៃបណ្ណាសកៈ ទី ៤ នោះ គឺ

*នន្ទិក្ខយវគ្គ ១ សដ្ឋីបេយ្យាល ១ សមុទ្ទវគ្គពោលអំពីទឹក ១ បណ្ណាសកៈ ទី ៤ នេះ ព្រះមានព្រះភាគ សម្តែងហើយក្នុងពួកនិបាត ។*

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស សឡាយតនវគ្គោ

# សត្តមោ ភាគោ

---

# បឋមបណ្ណាសកំ

# អនិច្ចវគ្គោ

មាតិកា អង្កេ


សឡាយតនវគ្គស្ស បឋមបណ្ណាសកេ អនិច្ចវគ្គោ បឋមោ............................. ៣

យមកវគ្គោ ទុតិយោ.......................... ១៣

សព្វវគ្គោ តតិយោ............................ ៣៣

ជាតិធម្មវគ្គោ ចតុត្ថោ......................... ៥៩

អនិច្ចវគ្គោ បញ្ចមោ........................... ៦៣

# សុត្តន្តបិដក

# សំយុត្តនិកាយ  សឡាយតនវគ្គ

# សត្តមភាគ

---

# បឋមបណ្ណាសកៈ

# អនិច្ចវគ្គ

មាតិកា                                                                                    លេខទំព័រ


សឡាយតនវគ្គ  បឋមបណ្ណាសកៈ  អនិច្ចវគ្គ  ទី  ១ .......................................... ៣

យមកវគ្គ  ទី  ២ ................................................ ១៣

សព្វវគ្គ  ទី  ៣ ................................................ ៣៣

ជាតិធម្មវគ្គ  ទី  ៤ ............................................ ៥៩

អនិច្ចវគ្គ  ទី  ៥ ................................................ ៦៣

៤៦៤

# មាតិកាបត្តានិ

# ទុតិយបណ្ណាសកំ

# អវិជ្ជាវគ្គោ

មាតិកា អង្កេ


សឡាយតនវគ្គស្ស ទុតិយបណ្ណាសកេ អវិជ្ជាវគ្គោ បឋមោ............................ ៦៩

មិគជាលវគ្គោ ទុតិយោ...................... ៧៧

គិលានវគ្គោ តតិយោ......................... ១០០

ឆន្នវគ្គោ ចតុត្ថោ................................ ១១៩

ឆឡវគ្គោ បញ្ចមោ............................. ១៥៤


# តតិយបណ្ណាសកំ

# យោគក្ខេមិវគ្គោ


សឡាយតនវគ្គស្ស តតិយបណ្ណាសកេ យោគក្ខេមិវគ្គោ បឋមោ ..................... ១៩០

លោកកាមគុណវគ្គោ ទុតិយោ ........... ២០៦

គហបតិវគ្គោ តតិយោ ....................... ២៤៩

ទេវទហវគ្គោ ចតុត្ថោ......................... ២៨៥

នវបុរាណវគ្គោ បញ្ចមោ..................... ៣០៥

# សង្ខេបក្តុលប្រាប់មាតិកា

# ទុតិយបណ្ណាសកៈ

# អវិជ្ជាវគ្គ

មាតិកា លេខទំព័រ


សឡាយតនវគ្គ ទុតិយបណ្ណាសកៈ អវិជ្ជាវគ្គ ទី ........................................ ១៦៩

មិគជាលវគ្គ ទី ២.................................. ៧៧

គិលានវគ្គ ទី ៣................................... ១០០

ឆន្នវគ្គ ទី ៤......................................... ១១៩

ឆឡវគ្គ ទី ៥ ....................................... ១៥៤


# តតិយបណ្ណាសកៈ

# យោគក្ខេមិវគ្គ


សឡាយតនវគ្គ តតិយបណ្ណាសកៈ យោគក្ខេមិវគ្គ ទី ១.............................. ១៩០

លោកកាមគុណវគ្គ ទី ២........................ ២០៦

គហបតិវគ្គ ទី ៣ .................................. ២៤៩

ទេវទហវគ្គ ទី ៤................................... ២៨៥

នវបុរាណវគ្គ ទី ៥ ................................ ៣០៥

# មាតិកាបត្តានិ

# ចតុត្ថបណ្ណាសកំ

# នន្ទិក្ខយវគ្គោ

មាតិកា អង្កេ

សឡាយតនវគ្គស្ស ចតុត្ថបណ្ណាសកេ នន្ទិក្ខយវគ្គោ បឋមោ............................៣២៧
សដ្ឋីបេយ្យាលោ ទុតិយោ.................... ៣៤១
សមុទ្ទវគ្គោ តតិយោ............................ ៣៥៩
អាសីវិសវគ្គោ ចតុត្ថោ.......................... ៣៩២

# សង្ខិកចង្អុលប្រាប់មាតិកា

# ចតុត្ថបណ្ណាសកៈ

# នន្ទិក្ខយវគ្គ

មាតិកា លេខទំព័រ


សឡាយតនវគ្គ ចតុត្ថបណ្ណាសកៈ នន្ទិក្ខយវគ្គ ទី ១ ...................................... ៣២៧

សដ្ឋិបេយ្យាល ទី ២ ................................ ៣៤១

សមុទ្ទវគ្គ ទី ៣ ...................................... ៣៥៩

អាសីវិសវគ្គ ទី ៤ .................................... ៣៩២

